ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# វិធីសាស្ត្រនៃការសរសេរ

# តែងសេចក្តី

## សម្រាប់មធ្យមសិក្សាបឋមភូមិ

## ថ្នាក់ទី៧ ទី៨ និងទី៩



នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា

ឆ្នាំ ២០១៨

# វិធីសាស្ត្រនៃការសរសេរ

# តែងសេចក្ដី

## សម្រាប់មធ្យមសិក្សាបឋមភូមិ

## ថ្នាក់ទី៧ ទី៨ និងទី៩

**នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា**

**ឆ្នាំ២០១៨**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខ:** ៤៤០ **អយក.** ប្រក

# ប្រកាស
## ស្តីពី
## ការអនុញ្ញាតឱ្យបោះពុម្ពផ្សាយ
## «វិធីសាស្ត្រនៃការសរសេរតែងសេចក្តីសម្រាប់មធ្យមសិក្សាបឋមភូមិ»
## ថ្នាក់ទី៧ ទី៨ និងទី៩

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- យោងសេចក្តីសម្រេចលេខ ១១ អយក.សសរ. ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ របស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីប្រព័ន្ធអនុម័តសៀវភៅសិក្សា និងសម្ភារឧបទេស
- យោងកំណត់ហេតុស្តីពីកិច្ចប្រជុំសេចក្តីព្រាងឯកសារវិធីសាស្ត្រសរសេរតែងសេចក្តីសម្រាប់បឋមសិក្សា មធ្យមសិក្សាបឋមភូមិ មធ្យមសិក្សាទុតិយភូមិ នាថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៦
- តាមសំណើរបស់ប្រធានក្រុមប្រឹក្សាអនុម័តសៀវភៅសិក្សា និងសម្ភារឧបទេស

**សម្រេច**

ប្រការ ១ - អនុញ្ញាតឱ្យបោះពុម្ពផ្សាយ«វិធីសាស្ត្រនៃការសរសេរតែងសេចក្តីសម្រាប់មធ្យមសិក្សាបឋមភូមិ»ថ្នាក់ទី៧ ទី៨ និងទី៩ ដែលជាស្នាដៃនិពន្ធ និងរៀបរៀងរបស់នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ដើម្បីប្រើប្រាស់ជាឯកសារជំនួយក្នុងការរៀន និងបង្រៀននៅតាមសាលារៀនមធ្យមសិក្សាចំណោះទូទៅ ក្នុងព្រះរាជាណាចក្រកម្ពុជា។

ប្រការ ២ - អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា និងនាយកដ្ឋានមធ្យមសិក្សាចំណោះទូទៅ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌនិងសាលារៀនមធ្យមសិក្សាបឋមភូមិ មានភារកិច្ចអនុវត្តប្រកាសនេះ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៧
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិត ហង់ជួន ណារ៉ុន

កន្លែងទទួល:
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- ដូចប្រការ២
- ឯកសារ-កាលប្បវត្តិនា.អកស.

# មុខកថា

«ការពង្រឹងគុណភាពអប់រំ» គឺជាឃ្លាមួយ ដែលបានចែងច្បាស់ក្នុងមុំមួយនៃយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣របស់រាជរដ្ឋាភិបាល។ នេះបញ្ជាក់ឱ្យឃើញពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល ក្នុងការកែលម្អ និងពង្រឹងគុណភាពអប់រំ ដើម្បីផលិតធនធានមនុស្សប្រកបដោយគុណភាព មានចំណេះដឹង ជំនាញ និងគុណតម្លៃបរិបូរណ៍ រួមចំណែកអភិវឌ្ឍជាតិ និងស្របតាមតម្រូវការទីផ្សារការងារក្នុងប្រទេស តំបន់ និងពិភពលោក។

ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវគោលនយោបាយកំណែទម្រង់អាទិភាព១៥ ចំណុច រួមមាន ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការពង្រាយគ្រូបង្រៀន ការបណ្តុះបណ្តាលគ្រូ គុណវុឌ្ឍិគ្រូបង្រៀន ការងារអធិការកិច្ច ការវាយតម្លៃលទ្ធផលសិក្សា ការងារប្រឡង កម្មវិធីសិក្សា ការកសាង និងជួសជុលអគារសិក្សា គុណភាពអប់រំនៅឧត្តមសិក្សា ការងារកីឡា ការងារយុវជន ការអប់រំបច្ចេកទេស ការកសាងសាលារៀនជំនាន់ថ្មី និងការបណ្តុះបណ្តាលនាយក ព្រមទាំងមានការផ្លាស់ប្តូរពីរបៀបធ្វើការខ្លះពីការងារដោយឡែកតាមជំនាញនីមួយៗ មកជាការងាររួមតាមអនុវិស័យ។

ដើម្បីឆ្លើយតបទៅនឹងគោលនយោបាយកំណែទម្រង់នេះ ក្រសួងអប់រំ យុវជន និងកីឡា បានផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើការសិក្សាភាសាខ្មែរ និងអក្សរសាស្ត្រខ្មែរ ដែលមុខវិជ្ជានេះ ជាមូលដ្ឋានគ្រឹះសម្រាប់ការសិក្សាមុខវិជ្ជាដទៃទៀត ឱ្យបានល្អប្រសើរ និងសម្រាប់ប្រើប្រាស់គ្រប់ស្ថានភាពនៃជីវភាពរស់នៅប្រចាំថ្ងៃ។ សំណេរតែងសេចក្តី ជាសមត្ថភាពចម្បងមួយក្នុងភាសាខ្មែរ និងអក្សរសាស្ត្រខ្មែរ កើតឡើងពីការអាន ស្តាប់ និយាយ ចំណេះដឹងផ្នែកវេយ្យាករណ៍ និងចំណេះដឹងទូទៅជាច្រើនផ្នែកទៀត។ ហេតុដូច្នេះហើយ បានជាគណៈកម្មការបច្ចេកទេសផ្នែកភាសាខ្មែរ និងអក្សរសាស្ត្រខ្មែរ បានរៀបចំចងក្រងឯកសារស្តីពី«វិធីសាស្ត្រសរសេរតែងសេចក្តី»នេះឡើង។

ក្រសួងអប់រំ យុវជន និងកីឡា សង្ឃឹមថា សៀវភៅ**«វិធីសាស្ត្រសរសេរតែងសេចក្តី»** នៅមធ្យមសិក្សាបឋមភូមិនេះ នឹងបានជាប្រយោជន៍ដ៏សំខាន់ សម្រាប់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សក្នុងការបង្រៀន និងរៀនផ្នែកសំណេរតែងសេចក្តីប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៧

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិត ហង់ ជួន ណារ៉ុន

# បញ្ជីរាយនាមគណៈកម្មការ

## គណៈកម្មការគ្រប់គ្រង

ឯកឧត្តម បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

ឯកឧត្តមបណ្ឌិតសភាចារ្យ **ណាត ប៊ុនរឿន**

ឯកឧត្តមបណ្ឌិត **អ៊ឹម កុច**

លោកជំទាវ **ទន់ សាអ៊ីម**

ឯកឧត្តម **រស់ សាលីន**

## គណៈកម្មការនិពន្ធ

លោក អោ សៀម

លោក យិន ធី

លោក យ៉ង់ កំស៊ាន

លោកស្រី ម៉ៅ តាន់ណារី

លោក ព្រៃ សំបូរ

លោក ងិន សុតារា

លោកស្រី វ៉ាន់ សុភី

លោកស្រី ផាន់ សុជាតា

លោក រ៉ិត សុខខេង

លោកស្រី សេង ពិសិដ្ឋនារី

## គណៈកម្មការពិនិត្យ

ឯកឧត្តម បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

ឯកឧត្តមបណ្ឌិតសភាចារ្យ **ណាត ប៊ុនរឿន**

ឯកឧត្តមបណ្ឌិត **អ៊ឹម កុច**

លោកជំទាវ **ទន់ សាអ៊ីម**

ឯកឧត្តម **ពុត សាមិត្ត**

បណ្ឌិត **ម៉ុក សារ៉ុម**

## គណៈកម្មការបច្ចេកទេសកុំព្យូទ័រ

លោក លឹម សុត្ថារិទ្ធ

លោក អាំ សុបុល

# មាតិកា

ទំព័រ

បញ្ជីរាយនាមគណៈកម្មការ ........ i

មាតិកា ........ ii

អារម្ភកថា ........ iii

តារាងបែងចែកខ្លឹមសារវិធីសាស្ត្រសរសេរតែងសេចក្តី ........ 1

១- សេចក្តីផ្តើម ........ 2

២- ដូចម្តេចដែលហៅថាតែងសេចក្តី? ........ 2

៣- សារៈសំខាន់នៃការសរសេរតែងសេចក្តី ........ 3

៣.១- ចេះបង្ហាញមតិគំនិត ........ 3

៣.២- ចេះស្រាយបញ្ហា ........ 3

៣.៣- ពង្រីកចំណេះដឹងទូទៅ ........ 3

៣.៤- ពង្រីកគំនិតប្រាជ្ញា ........ 4

៣.៥- តែងសេចក្តីជួយមុខវិជ្ជាដទៃទៀត ........ 4

៣.៦- តែងសេចក្តីផ្សារភ្ជាប់ក្នុងជីវភាពរស់នៅ ........ 4

៤- ការត្រៀម និងការរៀបចំដំណើរការសរសេរតែងសេចក្តី ........ 4

៥- វិធីសាស្ត្រក្នុងការសរសេរតែងសេចក្តី ........ 17

៦- ប្រភេទនៃប្រធានតែងសេចក្តី ........ 18

៧- ការរចនាទម្រង់សំណេរតែងសេចក្តី ........ 20

៨- តែងសេចក្តីបែបពិពណ៌នា និងការសរសេរសំបុត្រ ........ 25

៩- តែងសេចក្តីបែបអត្ថាធិប្បាយពន្យល់ ........ 32

១០- តែងសេចក្តីបែបអត្ថាធិប្បាយពន្យល់សុភាសិត ........ 34

១១- តែងសេចក្តីបែបអត្ថាធិប្បាយពន្យល់អក្សរសិល្ប៍ ........ 37

១២- តែងសេចក្តីបែបអត្ថាធិប្បាយប្រៀបធៀប ........ 39

១៣- ឧទាហរណ៍តែងសេចក្តីបែបពណ៌នា និងការសរសេរសំបុត្រ ........ 41

១៤- តែងសេចក្តីបែបអត្ថាធិប្បាយពន្យល់ ........ 59

១៥- អត្ថបទគំរូតែងសេចក្តី ........ 150

១៧- លំនាំបង្រៀនតែងសេចក្តី ........ 158

# អារម្ភកថា

ដើម្បីពង្រឹង និងលើកកម្ពស់ការសិក្សាភាសាខ្មែរ ពិសេសផ្នែកសំណេរតែងសេចក្ដីប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់នោះ ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតគណៈកម្មការអភិវឌ្ឍឯកសារ **"វិធីសាស្ត្រសរសេរតែងសេចក្ដី"** ដើម្បីជាជំនួយក្នុងការរៀន និងបង្រៀនតែងសេចក្ដី ដែលជាមូលដ្ឋានក្នុងការជួយលោកគ្រូ អ្នកគ្រូ និងអ្នកសិក្សាទាំងឡាយ ពិសេសប្អូនៗសិស្សានុសិស្សដែលត្រូវប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ។

ក្នុងឯកសារនេះមានបង្ហាញពីៈ

✓បញ្ញត្តិនៃតែងសេចក្ដី

✓ប្រភេទនៃតែងសេចក្ដី

✓វិធីសាស្ត្រក្នុងការសរសេរតែងសេចក្ដី

✓ឧទាហរណ៍គំរូនៃតែងសេចក្ដីមួយចំនួន

✓អត្រាកំណែតែងសេចក្ដី

✓លំនាំបង្រៀនតែងសេចក្ដី។

ក្នុងផ្នែកទ្រឹស្ដី យើងបានលើកយកតែទ្រឹស្ដីលម្អិតរបស់តែងសេចក្ដីបែបពិពណ៌នា បែបអត្ថាធិប្បាយពន្យល់ និងបែបអត្ថាធិប្បាយប្រៀបធៀប មកបង្ហាញតែប៉ុណ្ណោះ។ ចំណែកឯផ្នែកឧទាហរណ៍គំរូវិញ យើងបានយកសុភាសិត ពាក្យស្លោក ទស្សនៈ និងអក្សរសិល្ប៍ ដែលជាវិញ្ញាសារបស់លោកគ្រូ អ្នកគ្រូមួយចំនួនមានស្នាដៃ និងបទពិសោធល្អក្នុងការបង្រៀន និងវិញ្ញាសាល្អៗសំខាន់ៗមួយចំនួនទៀតមកបង្ហាញ ដើម្បីបានជាទុនក្នុងការរៀន និងបង្រៀនតែងសេចក្ដីប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់។

គណៈកម្មការនិពន្ធសង្ឃឹមថា ឯកសារវិធីសាស្ត្រសរសេរតែងសេចក្ដី"នេះ មានសារប្រយោជន៍សម្រាប់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សក្នុងការបង្រៀន និងរៀនផ្នែកសំណេរតែងសេចក្ដី ព្រមទាំងរួមចំណែកលើកកម្ពស់គ្រប់សមត្ថភាពក្នុងភាសាខ្មែរ ហើយប្រើប្រាស់ភាសាខ្មែរបានត្រឹមត្រូវប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់ ។

គណៈកម្មការយើងខ្ញុំយល់ច្បាស់ថា ទោះបីជាមានការប្រយ័ត្នប្រយែងយ៉ាងណាក៏ដោយក៏ការចងក្រងរៀបរៀងឡើងមកនេះ នៅតែមានកង្វះខាតផ្សេងៗ ទាំងគុណភាព បច្ចេកទេស និងការខុសឆ្គងលើសលស់នូវពាក្យពេចន៍មួយចំនួនដោយអចេតនាជាមិនខាន។ ដូច្នេះ សូមលោកអ្នកដែលប្រើប្រាស់សៀវភៅនេះមេត្តាជួយផ្ដល់យោបល់រិះគន់កែលម្អលើឯកសារនេះ ឱ្យកាន់តែល្អប្រសើរឡើងថែមទៀត។ ហេតុនេះហើយគណៈកម្មការរៀបចំឯកសារ រង់ចាំទទួលនូវមតិយោបល់រិះគន់ និងស្វាគមនាពីសំណាក់ លោកអ្នកគ្រប់ពេលវេលាដោយមេត្រីភាព។

**គណៈកម្មការនិពន្ធ**

# តារាងបែងចែកខ្លឹមសារវិធីសាស្ត្រសរសេរតែងសេចក្ដី

## សម្រាប់មធ្យមសិក្សាបឋមភូមិថ្នាក់ទី៧ដល់ថ្នាក់ទី៩

| ខ្លឹមសារ | ថ្នាក់ទី ៧ | ថ្នាក់ទី ៨ | ថ្នាក់ទី ៩ |
|---|---|---|---|
| ១- សេចក្ដីផ្ដើម<br>២- សារៈសំខាន់នៃការសរសេរតែងសេចក្ដី<br>៣- វិធីសាស្ត្រក្នុងការសរសេរតែងសេចក្ដី<br>៤- ប្រភេទប្រធានតែងសេចក្ដី<br>៥- ការរចនាទម្រង់សំណេរតែងសេចក្ដី | ✓ | ✓ | ✓ |
| ៦- តែងសេចក្ដីបែបពិពណ៌នា និងការសរសេរសំបុត្រ | ✓ | ✓ | |
| ៧- តែងសេចក្ដីបែបអត្ថាធិប្បាយពន្យល់ | ✓ | ✓ | ✓ |
| ៨- តែងសេចក្ដីបែបអត្ថាធិប្បាយប្រៀបធៀប | | | ✓ |
| ៩- ឧទាហរណ៍តែងសេចក្ដីបែបពិពណ៌នា និងការសរសេរសំបុត្រ | | | |
| ៩.១- តែងសេចក្ដីបែបពិពណ៌នា និងការសរសេរសំបុត្រ | ✓ | ✓ | |
| ៩.២- តែងសេចក្ដីបែបអត្ថាធិប្បាយពន្យល់<br>- ប្រធានតែងសេចក្ដីបែបអត្ថាធិប្បាយពន្យល់ទូទៅ (ទស្សនៈ ពំនោលមតិ)<br>- ប្រធានតែងសេចក្ដីបែបអត្ថាធិប្បាយពន្យល់ពាក្យស្លោក<br>- ប្រធានតែងសេចក្ដីបែបអត្ថាធិប្បាយពន្យល់ពាក្យអប់រំ<br>- ប្រធានតែងសេចក្ដីបែបអត្ថាធិប្បាយពន្យល់សុភាសិត<br>- ប្រធានតែងសេចក្ដីបែបអត្ថាធិប្បាយពន្យល់អក្សរសិល្ប៍ | ✓ | ✓ | ✓ |
| ៩.៣- ប្រធានតែងសេចក្ដីបែបអត្ថាធិប្បាយប្រៀបធៀប | | | ✓ |
| ១០- អត្រាកំណែតែងសេចក្ដី | ✓ | ✓ | ✓ |
| ១១- លំនាំបង្រៀនតែងសេចក្ដី | ✓ | ✓ | ✓ |

# ១- សេចក្ដីផ្ដើម

តែងសេចក្ដី គឺជាសំណេរមួយប្រភេទតម្រូវឱ្យអ្នកសរសេរមានកម្រិតពុទ្ធិខ្ពស់ផ្នែកចំណេះដឹងទូទៅ ចំណេះដឹងក្នុងការរស់នៅ ផ្លូវច្បាប់ និងចំណេះដឹងផ្នែកអក្សរសិល្ប៍។ សំណេរតែងសេចក្ដី ជាសំណេរដែលទាមទារនូវភាពត្រឹមត្រូវទៅលើក្បួនខ្នាតនៃសំណេរ ទម្រង់ និងខ្លឹមសារ។ ទម្រង់នៃសំណេរតែងសេចក្ដីខុសគ្នាទៅតាមប្រភេទនីមួយៗនៃតែងសេចក្ដី។ ប្រភេទតែងសេចក្ដីមានច្រើនយ៉ាងដូចជា តែងសេចក្ដីបែបពិពណ៌នា ការនិទាន ការសរសេរសំបុត្រ អត្ថាធិប្បាយពន្យល់ ប្រៀបធៀប ពិភាក្សា។ល។

ដើម្បីសរសេរតែងសេចក្ដីបានល្អ អ្នកតែងគួរតែអនុវត្តតាមការណែនាំមួយចំនួនដូចខាងក្រោមៈ

- ✓សិក្សាប្រធាន ដែលលើកឡើងដោយយកចិត្តទុកដាក់ឱ្យបានច្រើនសា ដើម្បីយល់ពីបំណងរបស់ប្រធានថា គេចោទឡើងពីអ្វី? ចង់ឱ្យយើងធ្វើដូចម្ដេចខ្លះ?
- ✓ធ្វើចំណាត់ប្រភេទប្រធានថា តើជាប្រធានបែបណា? បែបពិពណ៌នា ការនិទាន ការសរសេរសំបុត្រ អត្ថាធិប្បាយពន្យល់ ប្រៀបធៀប ពិភាក្សា។ល។
- ✓ពិនិត្យរកពាក្យគន្លឹះ ឃ្លា ប្រយោគសំខាន់ៗ និងន័យរបស់ប្រធានឱ្យបានច្បាស់លាស់។
- ✓ស្វែងយល់ន័យសេចក្ដីប្រធានឱ្យបានច្បាស់ថា ខ្លឹមសារន័យសេចក្ដីរបស់ប្រធានមានទំនាក់ទំនងទៅនឹងបញ្ហាអ្វីខ្លះ ទាំងក្នុងជីវភាពរស់នៅ និងក្នុងអក្សរសិល្ប៍។
- ✓ប្រមូលគំនិតសំខាន់ៗទៅតាមចំណោទ និងគម្រោងរបស់ប្រធាន។
- ✓រកអំណះអំណាង ឬភស្ដុតាង ឧទាហរណ៍ និងហេតុផលផ្សេងៗ ទាំងជីវភាពជាក់ស្ដែងក្នុងសង្គម ក៏ដូចជាក្នុងអក្សរសិល្ប៍ ដើម្បីបញ្ជាក់លើគំនិតរបស់អ្នកសរសេរ។
- ✓រៀបចំគំនិត និងអំណះអំណាងទៅតាមគម្រោង ដែលអាចចាត់ទុកថាជាសេចក្ដីព្រាងរបស់កិច្ចការមុននឹងសរសេរសម្រេច។
- ✓សរសេរសម្រេចដោយមានលំដាប់លំដោយទៅតាមគម្រោង និងចំណោទរបស់ប្រធាន។
- ✓ពិនិត្យ និងកែលម្អឡើងវិញ សំណេររបស់ខ្លួន តាំងពីអក្ខរាវិរុទ្ធ ឃ្លា ល្បះ ក្បួនខ្នាតវេយ្យាករណ៍ គំនិតយោបល់ត្រឹមត្រូវតាមគម្រោង អំណះអំណាង និងភាពគ្រប់គ្រាន់ពេញលេញនៃតែងសេចក្ដី។

ក្នុងការសរសេរតែងសេចក្ដី អ្នកសរសេរគួរប្រុងប្រយ័ត្ន និងគួរចៀសវាងនូវចំណុចមួយចំនួនដូចជា មិនត្រូវសរសេរជាគម្រោង ឬដាក់ចំណងជើងបែបមេរៀនមិនត្រូវសរសេរអក្សរកាត់ សរសេរជាលេខរ៉ូម៉ាំងឡាតាំង ឬលេខខ្មែរ មិនប្រើសញ្ញាត្រេ សញ្ញាផ្កាយ ឬសញ្ញាផ្សេងៗខុសទម្រង់តែងសេចក្ដី និងមិនត្រូវសរសេរដោយប្រើពាក្យលេបខាយ ផ្ដេះផ្ដង លន្លង់លន្លោច ស្រងេះស្រងោចខ្លោចផ្សាបែបប្រលោមលោកឡើយ។

# ២- ដូចម្ដេចដែលហៅថាតែងសេចក្ដី?

មុននឹងសិក្សាតែងសេចក្ដី យើងគប្បីយល់ថា ដូចម្ដេចដែលហៅថាតែងសេចក្ដី?

តែងសេចក្ដីកើតមកពីពាក្យ **តែង** + **សេចក្ដី**។

**តែង** មានន័យថា តុបតែងធ្វើឱ្យបានល្អ ពេញចិត្ត ទាក់ទាញ ចាប់អារម្មណ៍ជាដើម។ ឧទាហរណ៍: តុបតែងផ្ទះមានន័យថា រៀបចំផ្ទះដោយមានគ្រឿងតុ ទូ រាំងនន រូបចម្លាក់ ផ្ទាំងរូបភាព លាបពណ៌ធ្វើឱ្យផ្ទះស្អាតធ្វើឱ្យផ្ទះមានសោភណភាព ដើម្បីឱ្យអ្នកផងទាំងពួង ពេញចិត្ត ចាប់អារម្មណ៍ កោតសរសើរ។ល។ តុបតែងខ្លួន មានន័យថា រៀបចំខ្លួន ដោយប្រើគ្រឿងអលង្ការ លាបក្រែម ដាត់ម្សៅ ធ្វើសក់ ស្លៀកពាក់ ធ្វើឱ្យស្អាតដើម្បីឱ្យគេចាប់អារម្មណ៍ ពេញចិត្ត ចូលចិត្ត មានចិត្តប្រតិព័ទ្ធជាដើម។

សេចក្ដី មានន័យថា ដំណើរ ហេតុការណ៍ គតិ លំអាន ផ្ទៃរឿង ដំណើរពាក្យ ខ្លឹមសារ។

ដូច្នេះតែងសេចក្ដីមានន័យថា ការរៀបចំតាក់តែងពាក្យពេចន៍ ខ្លឹមសារ ដំណើរហេតុកាណ៍ផ្សេងៗឱ្យបានត្រឹមត្រូវល្អ ប្រកបដោយសោភ័ណ ជាទីចាប់អារម្មណ៍ ពេញចិត្តទៅតាមអ្វីដែលគេលើកមកចោទ។ បើនិយាយឱ្យងាយយល់ តែងសេចក្ដីគឺជាការសរសេរពិពណ៌នា រៀបរាប់អំពីមនុស្ស សត្វ វត្ថុ ទីកន្លែង ព្រឹត្តិការណ៍ បាតុភូតធម្មជាតិ និទានរឿង និងការធ្វើអត្ថាធិប្បាយពី គំនិត ទស្សនៈ មតិឱ្យបានក្បោះក្បាយ ប្រើប្រាស់ពាក្យពេចន៍ពីរោះត្រឹមត្រូវ មានអត្ថន័យគ្រប់គ្រាន់ មានការរចនាតាមទម្រង់បែបបទត្រឹមត្រូវ ដើម្បីធ្វើឱ្យអ្នកអាន អ្នកស្ដាប់ ងាយយល់ មានចំណាប់អារម្មណ៍ និងជាទីពេញចិត្ត។

# ៣- សារៈសំខាន់នៃការសរសេរតែងសេចក្ដី

## ៣.១- ចេះបង្ហាញមតិគំនិត

តែងសេចក្ដីបង្រៀនឱ្យសិស្សចេះយកមតិ គំនិត យោបល់មកបង្ហាញ ពន្យល់ បំភ្លឺ វិភាគ វែកញែកឱ្យបានច្បាស់លាស់ ដោយមានរបៀបរៀបរយតាមវិធីសាស្ត្រត្រឹមត្រូវ ចេះប្រើពាក្យពេចន៍ ឃ្លាប្រយោគ ងាយស្ដាប់ ងាយយល់ស្របតាមក្បួនវេយ្យាករណ៍។ គេអាចមានគំនិតច្រើន យោបល់ល្អ ប្រកបដោយខ្លឹមសារជ្រាលជ្រៅ។ បើពុំដូច្នោះទេ ការធ្វើការពិពណ៌នា ការនិទាន ការសរសេរសំបុត្រ ការធ្វើអធិប្បាយពន្យល់ប្រៀបធៀបនឹងឈានទៅរកភាពច្របូកច្របល់ មិនច្បាស់លាស់ គ្មានសណ្ដាប់ធ្នាប់ គឺឃ្លាប្រយោគ ក៏ពុំបានរចនាឱ្យបានល្អ មតិ ឬគំនិតនោះក៏គ្មានតម្លៃដែរ។ សិស្សមានបំណិនខាងបង្ហាញគំនិត យោបល់ ទស្សនៈរបស់ខ្លួនបានល្អប្រសើរ មានន័យថាមានបំណិនចេះស្រាយបញ្ហា។

## ៣.២- ចេះស្រាយបញ្ហា

គោលបំណងក្នុងការបង្រៀនតែងសេចក្ដី គឺចង់ឱ្យសិស្សចេះបញ្ចេញមតិ គំនិត យោបល់ យល់ស្របតាមប្រធាន។ សិស្សចេះដោះស្រាយបញ្ហាស្មុគស្មាញ ដែលចោទឡើងបានត្រឹមត្រូវសមហេតុផលស្របទៅនឹងការពិតចំពោះមុខ។ ចំណុចសំខាន់ទាំងនេះគឺជាគុណប្រយោជន៍សម្រាប់មនុស្សគ្រប់រូប ព្រោះមនុស្សតែងតែជួបប្រទះបញ្ហាគ្រប់យ៉ាង។ ដូច្នេះ តែងសេចក្ដីបានដឹកនាំមនុស្សឱ្យចៀសផុតពីគុណវិបត្តិដែលមានចំពោះមុខ ចេះរកហេតុផលបានសមស្រប គឺឱ្យយើងចេះពឹងផ្អែកទៅលើចំណេះដឹងទូទៅជាមូលដ្ឋាន។

## ៣.៣- ពង្រីកចំណេះដឹងទូទៅ

ការសរសេរតែងសេចក្ដី ជាការបញ្ជាក់ពីសមត្ថភាពចំណេះដឹងទូទៅរបស់អ្នកសរសេរ ដែលអាចសរសេរស៊ីជម្រៅដល់កម្រិតណា ចេះវិភាគដល់កម្រិតណាក្នុងការពិចារណា ដើម្បីរកអំណះអំណាងយ៉ាងសមស្របនូវអ្វីដែលគេបានសិក្សាកន្លងមក។ វាក៏ជាការវាស់ស្ទង់ឆ្លុះបញ្ចាំងពីស្នាដៃនោះ ដែលបញ្ជាក់ថា អ្នកសរសេរមានចំណេះដឹងផ្សេងៗដូចជាៈ

- ✓ចំណេះដឹងលើផ្នែកភាសាជាតិ និងអក្សរសាស្ត្រជាតិ ចំណូលចិត្តក្នុងការអាន ការចងចាំអក្សរសិល្ប៍ ច្បាប់ទូន្មានផ្សេងៗ ឬសុភាសិតជាដើម។
- ✓ចំណេះដឹងលើផ្នែកពាក្យ កន្សោមពាក្យ ឃ្លា ល្បះ និងវេយ្យាករណ៍ជាដើម។
- ✓ចំណេះដឹងលើមេរៀនផ្សេងៗដូចជាភូមិវិទ្យា ប្រវត្តិវិទ្យា បរិស្ថានវិទ្យា សីលធម៌-ពលរដ្ឋវិជ្ជា...។
- ✓ចំណេះដឹងលើបទពិសោធក្នុងការរស់នៅប្រចាំថ្ងៃ ស្ថានភាពបច្ចុប្បន្ន។ល។

### ៣.៤- ពង្រីកគំនិតប្រាជ្ញា

ការសរសេរតែងសេចក្តី បានអភិវឌ្ឍគំនិតប្រាជ្ញា ឱ្យចេះឆ្លើយ ឬបកស្រាយចំបញ្ហារបស់ប្រធាន ដែលជាមធ្យោបាយសម្រាប់សិក្សាធ្វើឱ្យគំនិតប្រាជ្ញារីកដុះដាល ដោយការចេះគិតពិចារណា ចេះវិនិច្ឆ័យ រិះគន់ឱ្យបានសមហេតុផល ដោយការសង្កេតពិនិត្យ ការសិក្សាស្រាវជ្រាវ។ល។ ដូច្នេះតែងសេចក្តីបានពង្រីកការអប់រំគ្រឿងវិញ្ញាណរបស់មនុស្សឱ្យមានសមត្ថភាពដូចការសិក្សាមុខវិជ្ជាសំខាន់ៗដទៃទៀតដែរ។ មិនតែប៉ុណ្ណោះ ការធ្វើតែងសេចក្តីអាចជាជំនួយដល់ការសិក្សាមុខវិជ្ជាផ្សេងៗទៀតផង។

### ៣.៥- តែងសេចក្តីជួយមុខវិជ្ជាដទៃទៀត

ការសិក្សាតែងសេចក្តី និងការសិក្សាវិជ្ជានានារួមទាំងខាងទស្សនវិជ្ជាផង មានភារៈជួយគ្នាទៅវិញទៅមកដូចជាការសិក្សាវិទ្យាសាស្ត្រធម្មជាតិ ប្រវត្តិវិទ្យា ភូមិវិទ្យា សុទ្ធតែតម្រូវឱ្យសិស្សសង្កេត ពិនិត្យ កត់ត្រាចំណាំ ពណ៌នាពីវត្ថុ ទីកន្លែង មនុស្ស សត្វ ព្រឹត្តិការណ៍ក្នុងសង្គម បាតុភូតធម្មជាតិ។ល។ សិស្សអាចទាញយកផលប្រយោជន៍ពីការសិក្សាមុខវិជ្ជាមួយ ទៅជួយបំពេញមុខវិជ្ជាមួយទៀត។ មិនតែប៉ុណ្ណោះ តែងសេចក្តីក៏មានប្រយោជន៍បំផុតក្នុងជីវភាពរស់នៅ។

### ៣.៦- តែងសេចក្តីផ្សារភ្ជាប់ក្នុងជីវភាពរស់នៅ

ការសិក្សាតែងសេចក្តី មិនមែនមានផលប្រយោជន៍តែនៅក្នុងសាលារៀនប៉ុណ្ណោះទេ តែវាក៏បានផ្តល់ដល់ការរស់នៅក្នុងជីវភាពប្រចាំថ្ងៃផងដែរ។ គេអាចយកវាទៅប្រើប្រាស់ក្នុងកិច្ចប្រជុំសន្និសីទ សន្និបាត ការពិភាក្សា ការឃោសនា សុន្ទរកថា សំបុត្រឆ្លើយឆ្លង ការផ្សព្វផ្សាយជូនដំណឹង ឬលិខិតរដ្ឋបាលផ្សេងៗ។

## ៤- ការត្រៀម និងការរៀបចំដំណើរការសរសេរតែងសេចក្តី

ដើម្បីសរសេរតែងសេចក្តីឱ្យបានល្អ ជាទីចាប់ចិត្ត ចាប់អារម្មណ៍របស់អ្នកអាន ឬអ្នកស្តាប់ អ្នកសរសេរតែងសេចក្តីត្រូវប្រកាន់ជំហរ និងធ្វើការចាំបាច់មួយចំនួនដូចខាងក្រោម៖

### ៤.១- ជំហរសតិអារម្មណ៍ និងចិត្តគំនិតពេលធ្វើតែងសេចក្តី

សតិអារម្មណ៍និងចិត្តគំនិតពេលធ្វើតែងសេចក្តីមានសារៈសំខាន់ណាស់ ដើម្បីសរសេរតែងសេចក្តីបានល្អអ្នកធ្វើតែងសេចក្តីត្រូវមានជំហរម៉ឹងម៉ាត់ មិនតក់ស្លុតញញើញញ័រ មិនបាត់ស្មារតី មិនប្រញាប់ប្រញាល់ពេក ដើម្បីចៀសវាងការបាត់បង់ភាពម្ចាស់ការ និងការភ្លេចភ្លាំង។ អ្នកធ្វើតែងសេចក្តីត្រូវដកដង្ហើមឱ្យស្រួលមួយៗ ផ្ចង់គំនិតបាញ់ឆ្ពោះទៅលើការធ្វើតែងសេចក្តី។ ពោលគឺយើងត្រូវពង្រឹងស្មារតី តាំងអារម្មណ៍ឱ្យស្ងប់ គ្រប់គ្រងអារម្មណ៍ឱ្យបានល្អ ចៀសវាងការបែកអារម្មណ៍ដោយផ្តោតអារម្មណ៍ខ្លាំងលើប្រធានតែងសេចក្តី។ បន្ទាប់ពីរៀបចំខ្លួនបានស្រួលហើយ យើងនឹងចាប់ធ្វើតែងសេចក្តីបានល្អត្រឹមត្រូវមិនខាន។ ក្នុងជំហរដំបូងនេះ អ្នកធ្វើតែងសេចក្តីត្រូវកត់ត្រាប្រធាននៅលើក្រដាសស្អាតដោយសរសេរច្បាស់ៗ ហើយគោរពការដកឃ្លាឬខណ្ឌសញ្ញាទៅតាមប្រធានដែលគ្រូឬសាស្ត្រាចារ្យបានកត់ឱ្យនៅលើក្តារខៀន ព្រមទាំងត្រូវចៀសវាងការបន្ថែមឬបន្ថយពាក្យសម្តីរបស់ខ្លួនទៅលើប្រធានដែលគេបានកត់ឱ្យរួចហើយ។ ការធ្វើដូច្នេះមានសារៈសំខាន់ដល់ជំហានក្រោយទៀត ដែលវានឹងអាចធ្វើឱ្យមានការខុសឆ្គង ឬភាន់ច្រឡំដល់អ្នកធ្វើតែងសេចក្តីក្នុងករណីមិនយកចិត្តទុកដាក់បញ្ហានេះ។

## ៤.២- ការសិក្សាប្រធាន

### តើត្រូវសិក្សាប្រធានដូចម្តេច?

ការសរសេរតែងសេចក្តី អ្នកសរសេរតែងសេចក្តីមិនមែនគ្រាន់តែឃើញប្រធានតែងសេចក្តីភ្លាមចាប់សរសេរភ្លាមនោះទេ។ មានសិស្ស និស្សិត និងបេក្ខជនក្នុងការប្រឡងខ្លះបានស្រងាកចិត្ត និងសោកស្តាយយ៉ាងខ្លាំង ក្រោយពេលខ្លួនសរសេរតែងសេចក្តីចប់។ ការស្រងាកចិត្ត និងសោកស្តាយនេះ បណ្តាលមកពីតែងសេចក្តីរបស់ខ្លួន ដែលបានសរសេរហើយនោះ មានន័យឃ្លាតឆ្ងាយពីប្រធាន ឬបានចាកប្រធានតែម្តង នាំឱ្យទទួលបានពិន្ទុមិនល្អ។ កំហុសនេះដើមបំផុតគឺអ្នកធ្វើតែងសេចក្តីពុំបានសិក្សាប្រធាននិងពុំយល់ប្រធានច្បាស់លាស់។

មុននឹងចាប់ផ្តើមសរសេរ អ្នកសរសេរតែងសេចក្តីត្រូវសិក្សាប្រធានជាមុនសិន គឺត្រូវអានប្រធានឱ្យបានច្រើនដង អានហើយអានទៀត គូសពីក្រោមពាក្យសំខាន់ៗពិបាកយល់ និងពាក្យគន្លឹះរបស់ប្រធាន។ ត្រូវចោទសួរក្នុងចិត្តខ្លួនឯងថា តើប្រធាននេះគេចង់និយាយពីអ្វី? គេចង់សួរពីអ្វី? ប្រធានតែងសេចក្តីនេះជាតែងសេចក្តីប្រភេទអ្វី? តើពាក្យ ឬឃ្លាត្រង់ណាដែលសម្គាល់ប្រធានប្រភេទនោះ? ការស្គាល់ប្រធានបានច្បាស់ អាចឱ្យអ្នកសរសេរតែងសេចក្តី ធ្វើគម្រោងតែងបានត្រឹមត្រូវ ហើយគំនិតដែលត្រូវលើកយកមកបរិយាយក៏សម្បូរបែប និងសមស្រប ឆ្លើយតបនឹងចំណោទបញ្ហារបស់ប្រធាន។

### ការសិក្សាលក្ខណៈសម្គាល់របស់ប្រភេទប្រធានតែងសេចក្តី

ប្រធានតែងសេចក្តីមានច្រើនប្រភេទ ហើយប្រភេទនីមួយៗមានលក្ខណៈដូចគ្នាផង ស្រដៀងគ្នាផង និងមានលក្ខណៈពិសេសដោយឡែកពីគ្នាផង។ តែទោះជាយ៉ាងណា ការសិក្សាប្រធានត្រូវផ្តោតលើលក្ខណៈសម្គាល់សំខាន់ៗដូចខាងក្រោម៖

- ✓ សិក្សាបម្រាប់ប្រធាន
- ✓ សិក្សាឃ្លាសំណួរ
- ✓ សិក្សាពាក្យបង្គាប់បញ្ជា។

## ៤.៣- ការធ្វើគម្រោងប្លង់តែង

ការធ្វើគម្រោងប្លង់តែង ជាការមួយចាំបាច់របស់អ្នកធ្វើតែងសេចក្តីត្រូវធ្វើមុនពេលសរសេរ។ គម្រោងប្លង់តែងមិនខុសពីគម្រោងប្លង់ផ្ទះ ដែលបានគូសវាសទុកជាមុន មុនពេលសង់ផ្ទះនោះឡើយ។ បើយើងត្រូវការផ្ទះមួយ តែយើងពុំមានគម្រោងប្លង់សោះ នោះផ្ទះរបស់យើងពុំអាចសង់បានឡើយ ទោះបីសង់បានក៏សំណង់នោះមិនសូវបានល្អដែរ វានឹងធ្វើឱ្យយើងមិនពេញចិត្តក្រោយពេលសង់រួច ឬវានឹងធ្វើឱ្យយើងខាតបង់ពេលវេលា និងទ្រព្យសម្បត្តិ ប្រាក់កាសយ៉ាងច្រើនទៀតផង។ ក្នុងការធ្វើតែងសេចក្តីក៏ដូច្នោះដែរ បើយើងពុំបានធ្វើគម្រោងតែង នោះការសរសេរតែងសេចក្តីរបស់យើងច្បាស់ជាពុំបានល្អហើយយើងច្បាស់ជានឹងស្តាយក្រោយយ៉ាងខ្លាំង ក្រោយពេលសរសេររួច។ ដូច្នេះការធ្វើគម្រោងប្លង់តែងសេចក្តី ជាការចាំបាច់ខានមិនបានចំពោះអ្នកសរសេរតែងសេចក្តី។

### តើអ្នកសរសេរតែងសេចក្តីត្រូវធ្វើគម្រោងតែងដូចម្តេច?

ក្រោយពីបានសិក្សាប្រធានតែងសេចក្តីរួចមក អ្នកធ្វើតែងសេចក្តីបានយល់ប្រធានរួចហើយ គឺបានយល់ទស្សនៈ ឬបញ្ហាដែលបានលើកឡើងរួច ហើយអ្នកធ្វើតែងសេចក្តីក៏បានយល់ច្បាស់ថា ប្រធានតែងសេចក្តីនេះជាប្រភេទតែងសេចក្តីមួយណារួចហើយដែរ។ ដូច្នេះក្នុងការចាប់ផ្តើមធ្វើគម្រោងបតែង គប្បីនឹក

ទៅដល់គម្រោងតែងនៃប្រភេទតែងសេចក្ដីនីមួយៗ ដែលបានសិក្សារួចហើយ។ តាមធម្មតាតែងសេចក្ដីទោះបីប្រភេទណាក៏ដោយ សុទ្ធតែចែកចេញជាបីផ្នែកសំខាន់ៗគឺ៖

- ✓ សេចក្ដីផ្ដើម
- ✓ តួសេចក្ដី
- ✓ សេចក្ដីបញ្ចប់។

នៅតាមផ្នែកទាំងបីខាងលើនេះ អ្នកធ្វើតែងសេចក្ដីត្រូវចុះនូវចំណុចសំខាន់ៗ និងគំនិតសំខាន់ៗ ដែលត្រូវនិយាយទៅតាមផ្នែកនីមួយៗ តែត្រូវរៀបចំលំដាប់លំដោយឱ្យបានសមស្រប តើគំនិតណាគួរដាក់មុន ហើយគំនិតណាគួរដាក់ក្រោយ។ ពេលធ្វើគម្រោងនៅក្នុងការបកស្រាយចំណុចនីមួយៗ អ្នកធ្វើតែងសេចក្ដីគួរសរសេរអំណះអំណាង ឬភស្តុតាង ឬឧទាហរណ៍ផ្សេងៗ ដែលអាចបញ្ជាក់សង្កត់បន្ថែមទៅលើគំនិតដែលយើងត្រូវសរសេរនៅតាមចំណុចនីមួយៗនោះ។ ការធ្វើយ៉ាងនេះ ដើម្បីកុំឱ្យអ្នកធ្វើតែងសេចក្ដីភ្លេចភ្លាំងក្នុងពេលសរសេរសម្រេច។ ក្នុងគម្រោងប្លង់តែង អ្នកសរសេរតែងសេចក្ដី ពុំគួរសរសេរលម្អិតទាំងស្រុង ឬទាំងមូលរហូតដល់ចប់ រួចកត់ចម្លងជាសម្រេចនោះទេ ព្រោះការធ្វើបែបនេះវានាំឱ្យខាតពេលវេលា ហើយគំនិតគិតឃើញរបស់អ្នកធ្វើតែងសេចក្ដីក៏ពុំអាចទូលំទូលាយ និងគ្រប់ជ្រុងជ្រោយបានឡើយ។ ករណីខ្លះក្នុងពេលប្រឡង មានសិស្ស ឬបេក្ខជនមួយចំនួន ធ្វើគម្រោងប្លង់តែងយ៉ាងគ្រវីសគ្រវាស រួចចាប់សរសេរលើក្រដាសព្រាងរហូតដល់ចប់ ហើយចុងក្រោយទើបចាប់ចម្លងឡើងវិញចូលសន្លឹកកិច្ចការបេក្ខជន។ ការធ្វើបែបនេះនាំឱ្យខាតពេលវេលា ហើយភាគច្រើនគឺសរសេរមិនទាន់ពេលតែម្ដង។

សរុបសេចក្ដីមក គម្រោងប្លង់តែងសេចក្ដី មិនមែនជាការរ៉ាយរ៉ាប់នូវឃ្លា ល្បះទាំងអស់នោះទេ តែវាជាគម្រោងប្លង់តែងមានលក្ខណៈជាគ្រោងឆ្អឹង ដែលមានតែគំនិតសំខាន់ៗ ដែលនឹងត្រូវនិយាយទៅតាមចំណុចនីមួយៗប៉ុណ្ណោះ។

### ក- សេចក្ដីផ្ដើម

សេចក្ដីផ្ដើម គឺជាពាក្យសម្ដីដែលអ្នកធ្វើតែងសេចក្ដីចាប់ផ្ដើមនិយាយ ដើម្បីប្រាប់អ្នកអាន អ្នកស្ដាប់ ឬអ្នកកែដឹងថា ខ្លួនចង់និយាយពីអ្វី? អាចនិយាយម្យ៉ាងទៀតថា សេចក្ដីផ្ដើមគឺជាពាក្យនាំផ្លូវ ឬជាពាក្យអន្ទងអ្នកអានឱ្យតាមដាន ឬទៅជួបអ្វីដែលគេចង់លើកឡើង។ ដូច្នេះសេចក្ដីផ្ដើម មានសារៈសំខាន់សម្រាប់អ្នកធ្វើតែងសេចក្ដី។ តាមធម្មតា អ្នកដែលពូកែសរសេរតែងសេចក្ដី គឺអ្នកដែលពូកែសរសេរសេចក្ដីផ្ដើមនេះឯង។ សេចក្ដីផ្ដើមនៃការធ្វើតែងសេចក្ដីមានច្រើនបែបច្រើនយ៉ាង អាស្រ័យទៅតាមអ្នកសរសេរតែងសេចក្ដី ប្រធានតែងសេចក្ដី និងប្រភេទតែងសេចក្ដី។ គេពុំមានសេចក្ដីផ្ដើមគំរូមួយសម្រាប់គ្រប់ប្រធានតែងសេចក្ដី និងគ្រប់ប្រភេទតែងសេចក្ដីនោះទេ។ ដូច្នេះក្នុងការធ្វើសេចក្ដីផ្ដើម អ្នកសរសេរតែងសេចក្ដី មានសិទ្ធិសេរីភាពគ្រប់គ្រាន់ក្នុងការផ្ដល់គំនិត និងបរិយាយ។ ការនិយាយយ៉ាងនេះពុំមែនមានន័យថា អ្នកសរសេរតែងសេចក្ដីអាចធ្វើតាមទំនើងចិត្តនោះទេ តែការសំខាន់គឺអ្នកធ្វើតែងសេចក្ដីត្រូវចេះសរសេរយ៉ាងណា ឱ្យទាក់ទងទៅនឹងប្រធាន ដើម្បីឱ្យអ្នកអាន អ្នកស្ដាប់ ឬអ្នកកែចាប់អារម្មណ៍ ចង់ដឹង ចង់តាមដាន ទៅលើការបកស្រាយខាងក្រោយទៀត។ អ្នកធ្វើតែងសេចក្ដីមិនត្រូវបកស្រាយប្រធាននៅក្នុងសេចក្ដីផ្ដើមនោះទេ។

ក្នុងការធ្វើសេចក្ដីផ្ដើមមានរបៀបច្រើនយ៉ាងណាស់ តែធ្វើយ៉ាងណាកុំឱ្យចាកប្រធាន។ ជាការងាយស្រួល គេអាចនិយាយពីប្រធាន និងចោទប្រធានឡើងវិញ ធ្វើជាសេចក្ដីផ្ដើមក៏បានដែរ។ ការធ្វើយ៉ាងនេះមិនងាយនឹងចាកប្រធានទេ តែធ្វើរបៀបនេះអ្នកអាន ឬអ្នកកែ គេហាក់ដូចជាយល់ថា អ្នកធ្វើតែងសេចក្ដីពុំសូវមានគំនិតទូលំទូលាយ។ ក្នុងការធ្វើសេចក្ដីសេចក្ដីផ្ដើម អ្នកសរសេរតែងសេចក្ដីគួរចៀសវាង៖

- ចៀសវាងផ្តើមសេចក្តីចេញក្រៅប្រធាន ឬមិនមានទាក់ទងនឹងប្រធាន ទោះបីមតិ គំនិត ដែលអ្នកធ្វើតែងសេចក្តីបានផ្តើមឡើងខ្ពង់ខ្ពស់ សមហេតុផលយ៉ាងណាក៏ដោយ ហើយមិនត្រូវលើកយកបញ្ហាក្រៅប្រធានមកចោទឡើយ។
- មិនគួរគប្បីលើកមតិគំនិតឥតខ្លឹមសារ ឬឥតប្រយោជន៍ដាក់ក្នុងសេចក្តីផ្តើម។
- ចៀសវាងនិយាយដោយប្រើពាក្យបាលី សំស្រ្កឹតជ្រៅៗពេក បើពាក្យនោះពុំមានតម្លៃចាំបាច់ទេ។
- គប្បីកុំផ្តើមសេចក្តីដូចក្នុងរឿងប្រលោមលោក លន្លង់លន្លោចឥតប្រយោជន៍។
- ចៀសវាងការបកស្រាយបញ្ហានៅក្នុងសេចក្តីផ្តើម។ គប្បីគួរកុំលើកយកឃ្លា ប្រយោគដែលត្រូវប្រើនៅក្នុងតួសេចក្តី មកនិយាយនៅក្នុងសេចក្តីផ្តើម ដើម្បីចៀសវាងការស្ទួនពាក្យឥតប្រយោជន៍។
- ចៀសវាងការសរសេរវែងពេក ឬខ្លីពេកនៅក្នុងសេចក្តីផ្តើម។ សេចក្តីផ្តើម តោងមានកម្រិតវែង ឬខ្លីអាស្រ័យទៅតាមទំហំ ឬប្រវែងនៃសេចក្តីអធិប្បាយនៅក្នុងតួសេចក្តី។ តាមធម្មតា សេចក្តីផ្តើម និងតួសេចក្តី ត្រូវស្របគ្នា។ បើសេចក្តីផ្តើមខ្លីពេកនោះគឺពុំសមស្រប ហើយបញ្ជាក់ថាអ្នកសរសេរតែងសេចក្តីគ្មានគំនិត គ្មានពុទ្ធិតែម្តង។ ផ្ទុយទៅវិញ បើសេចក្តីផ្តើមវែងពេកក៏ពុំមានសារៈសំខាន់ប៉ុន្មានដែរ ព្រោះវានាំឱ្យខាតពេលវេលា។

ជាទូទៅនៅក្នុងសេចក្តីផ្តើមនៃប្រភេទតែងសេចក្តីបែបអត្ថាធិប្បាយមានធាតុបីសំខាន់ៗ គឺលំនាំបញ្ហា ចំណូលបញ្ហា និងចំណោទបញ្ហា។

### លំនាំបញ្ហា

លំនាំបញ្ហាគឺជាការនិយាយទូទៅទាក់ទងទៅនឹងខ្លឹមសាររបស់ប្រធាន។ ការនិយាយនៅក្នុងលំនាំបញ្ហាមិនមែនជាការបកស្រាយប្រធាននោះទេ។ ពោលគឺនិយាយយ៉ាងណាដើម្បីទាក់ទាញអារម្មណ៍អ្នកអាន អ្នកកែឱ្យចូលមកបញ្ហារបស់ប្រធាន។

### ចំណូលបញ្ហា

ចំណូលបញ្ហាមិនមានអ្វីស្មុគស្មាញសម្រាប់អ្នកសរសេរតែងសេចក្តីទោះទេ គឺគ្រាន់តែលើកយកបញ្ហារបស់ប្រធានមកសរសេរជាការស្រេច។ ចំណូលបញ្ហាគេច្រើនប្រើឃ្លាភ្ជាប់សេចក្តី និងសរសេរបញ្ហារបស់ប្រធាន នៅក្នុងអព្ភន្តរសញ្ញា។ គេច្រើនសរសេរថា ហេតុនេះហើយទើបមានទស្សនៈលើកឡើងថា «...»។

### ចំណោទបញ្ហា

ដើម្បីភ្ជាប់សេចក្តីផ្តើមទៅនឹងផ្នែកខាងក្រោយទៀតឱ្យទាក់ទង និងស៊ីសង្វាក់គ្នា អ្នកធ្វើតែងសេចក្តី ត្រូវបញ្ចប់សេចក្តីផ្តើមដោយល្បះមួយទៀត គឺល្បះចោទប្រធានជាបញ្ហា ឬយើងហៅថាចំណោទបញ្ហា។ អ្នកអាន ឬអ្នកកែ កាលណាគេបានឃើញល្បះនេះ គេនឹងចង់តាមដាន ចង់ដឹងពីអ្វីៗ ដែលយើងនឹងបរិយាយនៅក្នុងតួសេចក្តីទៀត។ ចំណោទបញ្ហា គឺជាការចោទជាសំណួរទៅលើបញ្ហារបស់ប្រធាន។ ការចោទសួរទៅលើបញ្ហារបស់ប្រធាននេះមានសារៈសំខាន់ណាស់បើអ្នកធ្វើតែងសេចក្តីចោទសួរមិនបានត្រឹមត្រូវទេនោះ នាំឱ្យការសរសេរបកស្រាយក៏មិនបានត្រឹមត្រូវដែរ និងអាចសរសេរបកស្រាយទៅចាកប្រធានតែម្តង។ ខ្លឹមសារចំណោទបញ្ហា គឺមានលក្ខណៈខុសៗគ្នាអាស្រ័យទៅតាមប្រភេទប្រធាន។ ដូច្នេះមុនពេលចោទសួរ អ្នកធ្វើតែងសេចក្តីគប្បីពិនិត្យប្រធានឱ្យបានច្បាស់លាស់ ដើម្បីចៀសវាងចោទសំណួរខុស។ គេច្រើនចោទសួរទៅលើបញ្ហាប្រធានដូចខាងក្រោម៖

- ប្រធានបែបអត្ថាធិប្បាយពន្យល់៖
  - តើប្រធាន...មានអត្ថន័យដូចម្តេច?

- ✓ តើទស្សនៈដែលបានលើក...មានអត្ថន័យយ៉ាងណា?
- ✓ តើពំនោល...មានខ្លឹមសារដូចម្តេច?
- ✓ តើតួអង្គនេះមាន...ដូចម្តេច?

- ប្រធានអត្ថាធិប្បាយប្រៀបធៀបៈ
  - ✓ តើតួអង្គ...មានលក្ខណៈដូចគ្នា និងខុសគ្នាដូចម្តេច?
  - ✓ តើទស្សនៈ...ប្រសើរជាង?
  - ✓ តើតួអង្គ...ប្រសើរជាង។

- ប្រធានបែបអត្ថាធិប្បាយពិភាក្សាៈ
  - ✓ តើ...ខាងលើនេះ ត្រឹមត្រូវដែរឬទេ?
  - ✓ តើ...ទាំងពីរខាងលើមួយណាត្រឹមត្រូវជាង?
  - ✓ តើ...ត្រូវ ឬខុស?
  - ✓ តើ...ត្រឹមត្រូវដែរឬទេ?
  - ✓ តើ...មួយណាត្រឹមត្រូវជាង?
  - ✓ តើ...មួយណាសមហេតុផលជាង?

***ចំណុចគួរចៀសវាង*** : ក្នុងចំណោទបញ្ហានេះ អ្នកធ្វើតែងសេចក្តីចៀសវាងការចោទសួរច្រាសមកវិញ នាំឱ្យចាកប្រធាន ឬប្រើពាក្យបង្គាប់បញ្ជាឡើយ។ ឧទាហរណ៍ៈ

✓តើអ្នកយល់យ៉ាងណា? ចូរស្រាយបំភ្លឺ ដោយលើកឧទាហរណ៍បញ្ជាក់។

✓តើអ្នកយល់ដូចម្តេច? ចូរបកស្រាយ។

✓តើប្រធានមានន័យខ្លឹមសារយ៉ាងណា? ចូរពន្យល់។ល។

### ខ- តួសេចក្តី

តួសេចក្តី អាចហៅម្យ៉ាងទៀតថាសេចក្តីបរិយាយ ដែលប្រៀបបាននឹងខ្លួនរបស់តែងសេចក្តី។ តួសេចក្តីមានលក្ខណៈសំខាន់ណាស់សម្រាប់ការធ្វើតែងសេចក្តី។ តែងសេចក្តីល្អ ឬមិនល្អ ដោះស្រាយបញ្ហាប្រធានបាន ឬមិនបាន យល់ប្រធាន ឬមិនយល់ប្រធាន គឺនៅត្រង់តួសេចក្តីនេះឯង។ ដូច្នេះក្នុងការសរសេរតួសេចក្តីពុំមែនចេះតែសរសេរដោយគ្មានរបៀប ឬឥតបច្ចេកទេសនោះទេ។ អ្នកសរសេរតែងសេចក្តី ត្រូវមានរបៀបបច្ចេកទេសគួបផ្សំជាមួយនឹងពុទ្ធិទូទៅរបស់ខ្លួន ទាំងពុទ្ធិភាសា អក្សរសាស្ត្រ អក្សរសិល្ប៍ និងទិដ្ឋភាពសង្គមទូទៅថែមទៀត ដើម្បីធ្វើឱ្យការបរិយាយរបស់ខ្លួននៅក្នុងតួសេចក្តីបានល្អប្រសើរ។

វត្ថុបំណងរបស់អ្នកធ្វើតែងសេចក្តី គឺចង់បាននូវការរៀបរាប់ ការពន្យល់ ការបកស្រាយមួយសមស្របទៅតាមចំណោទរបស់ប្រធានដែលបានលើកឡើង។ ដើម្បីសម្រេចវត្ថុបំណងនេះ អ្នកធ្វើតែងសេចក្តីគួរយល់ដឹងពីចំណុចសំខាន់ៗមួយចំនួនដែលជាគ្រោងឆ្អឹងនៃតួសេចក្តីដូចខាងក្រោមៈ

### ឃ្លាភ្ជាប់សេចក្តី

អ្នកធ្វើតែងសេចក្តីដែលចេះសរសេរសេចក្តីផ្តើមបានល្អត្រឹមត្រូវពុំទាន់គ្រប់គ្រាន់ទេ តែត្រូវចេះសរសេរឃ្លាភ្ជាប់សេចក្តីថែមទៀត។ ឃ្លាភ្ជាប់សេចក្តី គឺជាឃ្លាសម្រាប់ភ្ជាប់ន័យសេចក្តីពីគំនិត មតិ ទស្សនៈ ឬពីវគ្គមួយទៅមួយ ឬពីកថាខណ្ឌមួយទៅកថាខណ្ឌមួយទៀត ដើម្បីធ្វើឱ្យអត្ថបទមួយមានតម្លៃទាំងអត្ថរូប និងអត្ថន័យ។ ឃ្លាភ្ជាប់សេចក្តីចែកចេញជាច្រើនផ្នែកគឺ ឃ្លាភ្ជាប់សេចក្តីសម្រាប់ភ្ជាប់ពីសេចក្តីផ្តើមទៅតួសេចក្តី

ឃ្លាភ្ជាប់សេចក្ដីសម្រាប់ភ្ជាប់ពីការពន្យល់ន័យប្រធានទៅការបកស្រាយប្រធាន និងឃ្លាភ្ជាប់សេចក្ដីភ្ជាប់ពីកថាខណ្ឌមួយទៅកថាខណ្ឌមួយទៀត ឬការបកស្រាយគំនិតមួយ ឬការបកស្រាយគំនិតមួយទៀត នៅក្នុងចំណុចការបកស្រាយប្រធានដើម្បីធ្វើឱ្យអត្ថបទមួយមានតម្លៃទាំងអត្ថរូប និងអត្ថន័យ។

ឃ្លាភ្ជាប់សេចក្ដីសំខាន់ៗ ដែលគេច្រើនប្រើនៅដើមឃ្លាមានដូចជា៖

- **ឃ្លាភ្ជាប់សេចក្ដីសម្រាប់ភ្ជាប់ពីសេចក្ដីផ្ដើមទៅតួសេចក្ដី៖**
  - ✓ ដើម្បីបកស្រាយប្រធាន...យើងគប្បីយល់នូវអត្ថន័យនៃពាក្យគន្លឹះរបស់ប្រធានជាមុនសិន។
  - ✓ ដើម្បីយល់អត្ថន័យរបស់ប្រធាន...យើងគប្បីយល់អត្ថន័យនៃពាក្យគន្លឹះរបស់ប្រធានជាមុនសិន។
  - ✓ មុននឹងបកស្រាយប្រធាន...យើងគប្បីយល់នូវអត្ថន័យនៃពាក្យគន្លឹះរបស់ប្រធានជាមុនសិន។ល។
- **ឃ្លាភ្ជាប់សេចក្ដីសម្រាប់ភ្ជាប់ពីពន្យល់ន័យប្រធានទៅការបកស្រាយប្រធាន៖**
  - ✓ ឆ្លងតាមអត្ថន័យនៃប្រធាន...យើងយល់ថា...។
  - ✓ ជាការពិតណាស់ ឆ្លងតាមអត្ថន័យនៃប្រធានខាងលើ...យើងឃើញថា... ។
  - ✓ តាមរយៈន័យនៃប្រធាន...យើងអាចបកស្រាយ...។ល។
- **ឃ្លាភ្ជាប់សេចក្ដីសម្រាប់ភ្ជាប់ពីកថាខណ្ឌមួយទៅកថាខណ្ឌមួយទៀតនៅក្នុងចំណុចការបកស្រាយប្រធាន៖**
  - ✓ រួចមកហើយយើងបានអត្ថាធិប្បាយពី... តទៅនេះយើងនឹងលើកយក...មកបកស្រាយ.... ។
  - ✓ យើងទើបនឹងនិយាយអំពី... ឥឡូវយើងនិយាយពី... ។
  - ✓ កន្លងមកហើយ យើងបានឃើញ... ពេលនេះយើងនឹងលើកយក... មកបង្ហាញបញ្ជាក់... ។ល។
  - ✓ ដើម្បីបញ្ជាក់ឱ្យកាន់តែច្បាស់ថែមទៀត យើងនឹងលើកយក... មកបញ្ជាក់បន្ថែម។

ឃ្លាភ្ជាប់សេចក្ដីត្រឹមត្រូវ លុះត្រាតែយើងខិតខំរៀបចំពាក្យពេចន៍ ឃ្លា ល្បះឱ្យមានន័យ មានខ្លឹមសារបង្ហាញទំនាក់ទំនងរវាងគំនិតមួយនិងគំនិតមួយទៀត ឬកថាខណ្ឌមួយនិងកថាខណ្ឌមួយទៀត ដើម្បីកុំឱ្យអ្នកអានភ្ញាក់ផ្អើលដោយពុំបានដឹងខ្លួនជាមុន ឬពុំយល់ថា ពីព្រោះអ្វីបានជាយើងលើកយកគំនិតថ្មីទៀតមកអត្ថាធិប្បាយ។

ក្នុងភាសាខ្មែរយើងក៏ដូចជាភាសាដទៃទៀតដែរ ឃ្លា ល្បះនៅក្នុងកថាខណ្ឌ ឬការបកស្រាយគំនិតនីមួយៗ ត្រូវស៊ីសង្វាក់គ្នាផ្ទៃក្នុងថែមទៀត ដោយប្រើពាក្យភ្ជាប់សេចក្ដីដូចជា មាន តែ ប៉ុន្តែ យ៉ាងណាមិញ ម្យ៉ាងទៀត ទោះបីយ៉ាងណាក៏ដោយ ប្រសិនបើ ប្រសិនជា គួរគប្បី ល្គឹកណា ជាទូទៅ យ៉ាងហោចណាស់ ជាធម្មតា អាស្រ័យហេតុនេះ ដូច្នេះ យ៉ាងដូច្នេះ មួយវិញទៀត។ល។

## ពាក្យគន្លឹះរបស់ប្រធាន

បើមានពាក្យពិបាកជាបាលី ឬសំស្ក្រឹត ដែលជាពាក្យគន្លឹះរបស់ប្រធាន អ្នកសរសេរតែងសេចក្ដីគប្បីពន្យល់ពាក្យនោះជាមុនសិន តែគួរលើកយកពាក្យមួយ ឬពីរ ឬបីបានហើយ ចៀសវាងការលើកយកពាក្យច្រើនមកពន្យល់។ ការពន្យល់ពាក្យពិបាកនេះ មានសំណូមពរចង់ឱ្យអ្នកអានបានយល់មួយកម្រិតពីគំនិតរបស់ប្រធាន ជាមួយអ្នកធ្វើតែងសេចក្ដី។ ចំពោះអ្នកកែតែងសេចក្ដីវិញ ពេលគេឃើញអ្នកធ្វើតែងសេចក្ដីពន្យល់ពាក្យបានច្បាស់លាស់ គេអាចយល់បានថា មានពុទ្ធិ និងយល់ប្រធានបាន។

តែសូមបញ្ជាក់ថា ការពន្យល់ពាក្យនៅក្នុងជំហានទីមួយនៃតែងសេចក្ដីនេះ មិនមែនជាការមួយត្រូវធ្វើគ្រប់តែតែងសេចក្ដីនោះទេ គឺចាំបាច់ ឬមិនចាំបាច់អាស្រ័យលើប្រធានដែលមានពាក្យពិបាក ឬមិនមាន ឬ

អាស្រ័យទៅលើភាពជាក់ស្តែងនៃការធ្វើតែងសេចក្តី។ យើងសង្កេតឃើញអ្នកធ្វើតែងសេចក្តីមួយចំនួនបាន ខិតខំពន្យល់ពាក្យនៅគ្រប់តែងសេចក្តី ទោះបីជាប្រធានតែងសេចក្តីនោះពុំមានពាក្យពិបាកក៏ដោយ។ ការធ្វើ បែបនេះនាំឱ្យអស់តម្លៃនៃការធ្វើតែងសេចក្តីទៅវិញទេ ហើយគេអាចវាយតម្លៃថាអ្នកធ្វើតែងសេចក្តី មាន គំនិតគម្ពីរនិយម គំនិតទាប គិតតាំងពីគំនិតកំប៉ិកកំប៉ុកឡើងទៅ ហើយអ្នកអានឬអ្នកកែពុំចង់ដឹងផង ពីព្រោះ ពាក្យពន្យល់ទាំងអស់នោះជាពាក្យងាយ គេបានយល់គ្រប់គ្នាហើយ។ យើងសង្កេតឃើញអ្នកធ្វើតែងសេចក្តី មួយចំនួនទៀត បានខិតខំពន្យល់ពាក្យស្អេកស្កះចេញពីពាក្យមួយទៅពាក្យមួយទៀត គឺធ្វើយ៉ាងណាឱ្យតែ បានវែង។ ការធ្វើបែបនេះពុំសមរម្យដែរ វាបានក្លាយទៅជាការធ្វើតែងសេចក្តីអំពីការពន្យល់ពាក្យទៅវិញ។

### ការពន្យល់ន័យប្រធាន

ការពន្យល់ន័យប្រធាន គឺជាការបង្ហាញអត្ថន័យរួមរបស់ប្រធាន ដោយផ្អែកលើការពន្យល់ពាក្យគន្លឹះ។ ដូច្នេះអ្នកធ្វើតែងសេចក្តី ត្រូវចេះសំយោគអត្ថន័យនៃខ្លឹមសារពន្យល់ពាក្យគន្លឹះរបស់ប្រធាន។ ការពន្យល់ ន័យប្រធាន មិនទាមទារឱ្យធ្វើការបកស្រាយអត្ថន័យលម្អិតនោះទេពោលគឺនិយាយសរុបខ្លឹមសារពន្យល់ ពាក្យគន្លឹះឱ្យស្របតាមខ្លឹមសារប្រធាន។

### ការបកស្រាយប្រធាន

- **ការបកស្រាយ៖**

ក្រោយពីបានពន្យល់ន័យប្រធានរួចហើយ អ្នកធ្វើតែងសេចក្តីត្រូវបកស្រាយពន្យល់ឬដោះស្រាយបញ្ហា ទៅតាមចំណុចនីមួយៗរហូតដល់ចប់។ នៅចំណុចនេះមានសារៈសំខាន់អាចចាត់ទុកជាខ្លឹមក៏បានដែរ។ អ្នក ធ្វើតែងសេចក្តីត្រូវមានឧទាហរណ៍ អំណះអំណាង ភស្តុតាង ឱ្យបានច្បាស់ដើម្បីបញ្ជាក់លើចំណុចនីមួយៗ។ ត្រូវចៀសវាងការនិយាយក្បែរៗប្រធាន ឬការនិយាយចាកប្រធាន។ ជានិច្ចកាលអ្នកធ្វើតែងសេចក្តីត្រូវមាន ការប្រុងប្រយ័ត្ននិងក្តាប់បញ្ហាប្រធានឱ្យបានច្បាស់លាស់ ដើម្បីចៀសវាងសរសេរចាកប្រធាន។ គំនិតណា ឬ ល្បះណាដែលល្អៀងឃ្លាតចេញពីប្រធាន ឬមិនច្បាស់លាស់ត្រូវដកចេញ។

ការបរិយាយរបស់អ្នកសរសេរតែងសេចក្តីត្រូវច្បាស់លាស់ដែលបញ្ជាក់នូវចំណេះដឹងទូលំទូលាយ របស់ខ្លួន។ ដូច្នេះមុនចាប់ផ្តើមសរសេរ ឬក្នុងពេលសរសេរ អ្នកធ្វើតែងសេចក្តីត្រូវប្រមែប្រមូលចំណេះដឹង គួបផ្សំនឹងការត្រិះរិះពិចារណារបស់ខ្លួនមកបរិយាយបញ្ជាក់។ ការផ្តល់គំនិតច្បោលៗគ្មានមូលដ្ឋានច្បាស់ លាស់គួរចៀសវាង។ ការបកស្រាយប្រធានត្រូវគោរពគម្រោងតែងសេចក្តីដែលបានរៀបចំរួច។ ការធ្វើបែប នេះគឺដើម្បីឱ្យន័យសេចក្តីនៃការបរិយាយរបស់យើងស៊ីសង្វាក់គ្នា មានលំដាប់លំដោយ មានរបៀបរៀបរយ និងចៀសវាងការនិយាយច្រំដែលៗ ឬភាពច្របូកច្របល់ និយាយសាចុះសាឡើង។

យើងសង្កេតឃើញថាក្នុងការបកស្រាយនេះមានអ្នកសរសេរតែងសេចក្តីជាច្រើនសរសេរដោយគ្មាន គម្រោង ឬមានអ្នកខ្លះមានគម្រោងដែរ តែមិនគ្រប់គ្រាន់ ពុំទាន់រៀបន័យសេចក្តីឱ្យស៊ីសង្វាក់គ្នា ហើយចាប់ សរសេររហូតពាក់កណ្តាលទៅហើយទើបចាប់ធ្វើគម្រោងតែងក៏មានដែរ។ ទាំងនេះជាការខុសឆ្គងមួយគួរ ចៀសវាង អាចអនុញ្ញាតឱ្យសរសេរបានក្រោយពេលសរសេរគម្រោងលម្អិតរួចហើយ។

- **ការលើកឧទាហរណ៍ និងសេចក្តីដកស្រង់មកបញ្ជាក់:** ក្នុងការសរសេរតែងសេចក្តី យើងត្រូវការគំនិត ច្បាស់លាស់ និងសុភវិនិច្ឆ័យ ដែលទាមទារឱ្យបញ្ជាក់អំណះអំណាងផ្សេងៗ។ បើគ្មានអំណះអំណាង បញ្ជាក់ទេ ការបរិយាយរបស់យើងស្ថិតក្នុងភាពពុំច្បាស់លាស់។ ដូច្នេះក្នុងការបញ្ជាក់លើគោលគំនិត ឬយោបល់ណាមួយឱ្យច្បាស់លាស់ អ្នកសរសេរតែងសេចក្តីត្រូវប្រមែប្រមូលលើកយកឧទាហរណ៍ ឬសេចក្តីដកស្រង់ណាមួយមកបញ្ជាក់បន្ថែមទៀត។

- **ការលើកឧទាហរណ៍មកបញ្ជាក់:** បើអ្នកសរសេរតែងសេចក្តីកំពុងសរសេរចំណុចណាមួយ គួររិះរកលើកឧទាហរណ៍ឱ្យបានប្លែកៗមកបញ្ជាក់បន្ថែមចំណុចនោះ។ ការធ្វើបែបនេះដើម្បីឱ្យអ្នកអាន ឬអ្នកកែកាន់តែពេញចិត្ត និងយល់ថាការបរិយាយរបស់យើងកាន់តែច្បាស់លាស់។ ការលើកឧទាហរណ៍ត្រូវមានមូលដ្ឋានដូចខាងក្រោមនេះ៖
  - ✓ ឧទាហរណ៍ដែលត្រូវលើកយកមកបញ្ជាក់ គប្បីមានលក្ខណៈប្លែកៗ តែត្រូវឱ្យស៊ីគ្នានឹងចំណុចត្រង់ណាមួយ ឬកថាខណ្ឌណាមួយដែលយើងកំពុងពន្យល់។ គួរចៀសវាងលើកឧទាហរណ៍ដែលពុំសូវមានន័យច្បាស់លាស់ ដែលនឹងអាចឱ្យការបរិយាយរបស់យើងក្លាយទៅជាមិនច្បាស់លាស់ជាមួយដែរ។
  - ✓ ឧទាហរណ៍លើកយកមកត្រូវប្រើសម្រាប់តែបញ្ជាក់គំនិតសំខាន់ៗ។ ក្នុងកថាខណ្ឌមួយ អាចលើកឧទាហរណ៍បានមួយ ឬពីរជាការគ្រប់គ្រាន់។ គួរចៀសវាងការលើកឧទាហរណ៍ស្អេកស្កះពេកដែលអាចនាំឱ្យអស់តម្លៃនៃតែងសេចក្តីរបស់យើង។
  - ✓ ចៀសវាងការលើកយករឿងណាមួយទាំងមូលមកធ្វើជាឧទាហរណ៍។ បើចង់លើកយករឿងណាមួយមកធ្វើជាឧទាហរណ៍ គួរលើកយកគំនិតសំខាន់ៗនៃរឿង។ សកម្មភាពត្រង់ណាមួយរបស់តួអង្គណាមួយធ្វើជាឧទាហរណ៍ តែគួរចេះនិយាយឱ្យបានខ្លីបំផុត។ ជាការល្អ គួរស្រង់យកមកធ្វើជាឧទាហរណ៍ តែរឿងណានៅក្នុងកម្មវិធីសិក្សា ឬរឿងដទៃទៀតណា ដែលសាធារណជនធ្លាប់ស្គាល់គ្រប់ៗគ្នា។

- **សេចក្តីដកស្រង់៖**

សេចក្តីដកស្រង់ គឺជាពន្លឺ ឬជាភស្តុតាងសម្រាប់បញ្ជាក់ ឬពន្យល់បន្ថែមលើគោលគំនិតណាមួយ ឬកថាខណ្ឌណាមួយដែលជាការចាំបាច់។ សេចក្តីដកស្រង់អាចជាសុភាសិត ឬជាពាក្យសម្តីរបស់អ្នកប្រាជ្ញកវីនិពន្ធ ទស្សនវិទូ ឬជាពាក្យសម្តីរបស់តួអង្គក្នុងស្នាដៃអក្សរសិល្ប៍ណាមួយ។ បើប្រធានតែងសេចក្តីជាប្រធានទូទៅ គេច្រើនស្រង់សុភាសិត ឬជាពាក្យសម្តីរបស់អ្នកប្រាជ្ញ ទស្សនវិទូសំខាន់ៗយកមកបញ្ជាក់។ ចំពោះប្រធានអក្សរសិល្ប៍ គេតែងដកស្រង់សម្តីរបស់អ្នកនិពន្ធ ឬសម្តីរបស់តួអង្គមកបញ្ជាក់ជាភស្តុតាង។

សេចក្តីដកស្រង់ដែលយើងលើកយកមកដាក់ក្នុងតែងសេចក្តី គប្បីសរសេរដាក់ក្នុងអព្ភន្តរ «...» ឬ "..." តែពុំតម្រូវឱ្យកាត់បន្ថយពាក្យ និងបាត់ន័យសេចក្តីរបស់គេឡើយ។ ពោលគឺអ្នកសរសេរតែងសេចក្តី ត្រូវរក្សាសេចក្តីដកស្រង់ទាំងស្រុងឱ្យនៅគង់វង្សដូចដើម។ ប៉ុន្តែបើយើងចាំពាក្យសម្តីគេមិនច្បាស់ យើងអាចរក្សាទុកគំនិតដើមក៏បានដែរ។ ចំណែកឯពាក្យសម្តីឃ្លា ល្បះ យើងអាចកែប្រែកាត់បន្ថយតាមចំណូលចិត្តយើងបានខ្លះដែរ។ ក៏ប៉ុន្តែនៅក្នុងករណីបែបនេះ យើងមិនត្រូវសរសេរពាក្យស្រង់ដាក់ក្នុងអព្ភន្តរសញ្ញាឡើយ ដើម្បីចៀសវាងកុំឱ្យអ្នកអាន ឬអ្នកកែយល់ច្រឡំនឹងពាក្យសម្តីដើមពិតប្រាកដ។

អ្នកសរសេរតែងសេចក្តី ត្រូវចៀសវាងសេចក្តីដកស្រង់ណា ដែលយើងយល់គំនិតដើមរបស់គេពុំច្បាស់ជាពិសេសសេចក្តីដកស្រង់ណាមិនទាក់ទង និងមិនស៊ីគ្នាជាមួយសេចក្តីអត្ថាធិប្បាយរបស់យើង។ បើយើងចេះតែស្រង់សេចក្តីដែលមិនស៊ីគ្នានឹងសេចក្តីអត្ថាធិប្បាយ វានឹងអាចឱ្យគំនិតរបស់យើងឃ្លាតចេញពីប្រធាន ហើយក៏អាចនឹងបញ្ជាក់ថា យើងយល់ប្រធានពុំច្បាស់លាស់ទៀតផង។ សេចក្តីដកស្រង់មានឃ្លាច្រើន ហើយមានឃ្លាខ្លះឥតប្រយោជន៍ យើងត្រូវកាត់វាចោល គឺយកតែចំណុចណាដែលសមស្រប ស៊ីសង្វាក់គ្នាជាមួយនឹងសេចក្តីអត្ថាធិប្បាយបានហើយ។

ត្រូវចេះជ្រើសរើសយកមកប្រើចំពោះសេចក្ដីដកស្រង់ណាដែលមានលក្ខណៈច្បាស់លាស់ ស្រួលយល់ ស្រួលអាន ខ្លីល្មម។ គួរចៀសវាងសេចក្ដីដកស្រង់ណាដែលមានពាក្យសម្ដីច្រើន មានឃ្លាប្រយោគវែងៗ ព្រោះវានឹងអាចធ្វើឱ្យមតិ គំនិតផ្ទាល់របស់ខ្លួនដែលបានបរិយាយត្រូវកប់បាត់ក្នុងសេចក្ដីដកស្រង់នោះ ឬត្រូវក្លាយទៅជាកម្រងអត្ថបទទៅវិញ។ ការធ្វើរបៀបនេះ អាចឱ្យការសរសេរតែងសេចក្ដីអស់តម្លៃ។

ដូច្នេះបញ្ហាសំខាន់បំផុតគឺអ្នកសរសេរតែងសេចក្ដីត្រូវចេះពិចារណាចំពោះការជ្រើសរើសសេចក្ដីដកស្រង់សម្រាប់ប្រើ។ ពោលគឺសេចក្ដីដកស្រង់ណា ពាក្យសម្ដីដកស្រងណាដែលល្អសឹមប្រើ។ ចំពោះមតិរាយរង ពុំចាំបាច់ស្រង់សេចក្ដីយកមកបញ្ជាក់នៅក្នុងតែងសេចក្ដីទេ។

### ការសរុបសេចក្ដី

សរុបសេចក្ដី គឺជាការសរសេរដោយឡើងវិញពីខ្លឹមសារនៃការបកស្រាយប្រធាន។ ក្នុងចំណុចនេះមិនទាមទារឱ្យអ្នកធ្វើតែងសេចក្ដីបកស្រាយ និងលើកឧទាហរណ៍នោះទេ។ ពោលគឺគប្បីលើកយកតែគំនិតសំខាន់ៗដែលមាននៅក្នុងការបកស្រាយប្រធានមកធ្វើការបូកសរុបប៉ុណ្ណោះ។ ប្រធានតែងបែបអត្ថាធិប្បាយពិភាក្សា គេប្រើមតិរួម ឬសំយោគ ឬពិភាក្សា ដើម្បីសរុបមតិស្រប និងមតិផ្ទុយ និងអាចមានមតិបន្ថែមទៀតដើម្បីបំពេញបន្ថែមទៅលើមតិទាំងពីរ។

### គ- សេចក្ដីបញ្ចប់

សេចក្ដីបញ្ចប់គេអាចហៅបានច្រើនយ៉ាងគឺ យោបល់បញ្ចប់ យោបល់រួម សេចក្ដីបង្ហើយ និងសេចក្ដីសន្និដ្ឋាន។ តែងសេចក្ដីមួយអាចប្រៀបធៀបទៅនឹងខ្លួនមនុស្សមានបី ផ្នែកគឺ ក្បាល ដងខ្លួន និងអវយវៈ។ សេចក្ដីផ្ដើមប្រៀបដូចជាក្បាល តួសេចក្ដីប្រៀបដូចជាដងខ្លួន ហើយសេចក្ដីបញ្ចប់ប្រៀបដូចជាអវយវៈ។ ផ្នែកទាំងបីរបស់មនុស្សយើង ត្រូវសមស្របគ្នាពីផ្នែកមួយទៅផ្នែកមួយទៀត ទើបធ្វើឱ្យរូបរាងមនុស្សមានរូបសម្បត្តិល្អប្រសើរ។ តែងសេចក្ដីក៏ដូច្នោះដែរ ផ្នែកទាំងបីរបស់វាត្រូវស៊ីសង្វាក់គ្នាតាំងពីដើមរហូតដល់ចប់ ពោលគឺតួសេចក្ដី ត្រូវស៊ីសង្វាក់គ្នាជាមួយសេចក្ដីផ្ដើម និងសេចក្ដីបញ្ចប់។ ដូច្នេះការសរសេរសេចក្ដីបញ្ចប់នៃតែងសេចក្ដី ក៏ជាការមួយចាំបាច់មិនអាចអត់បានដែរ។ បើខ្វះផ្នែកនេះ មានន័យថាការធ្វើតែងសេចក្ដីមិនបានចប់សព្វគ្រប់ឡើយ ហើយបើតែងសេចក្ដីមិនទាន់ចប់ធ្វើឱ្យអ្នកអានពិបាកយល់ អ្នកកែក៏ពិបាកដាក់ពិន្ទុ។

ជាទូទៅសេចក្ដីបញ្ចប់មានចំណុចសំខាន់ៗពីរគឺ វាយតម្លៃប្រធាន និងយោបល់ផ្ទាល់ខ្លួន ឬមតិផ្ទាល់ខ្លួន ឬចំណាប់អារម្មណ៍ផ្ទាល់ខ្លួន។

**វាយតម្លៃប្រធាន** គឺជាការសរសេរពីតម្លៃអប់រំរបស់ប្រធានតែងសេចក្ដី។ ដូច្នេះចំណុចនេះអ្នកសរសេរតែងសេចក្ដីមិនទាមទារឱ្យសរសេរបកស្រាយ ឬសរសេរវែងឆ្ងាយពេកនោះទេ។ ការវាយតម្លៃប្រធាន គឺគប្បីសរសេរដោយឆ្លើយនឹងសំណួរថា តើប្រធាននេះមានតម្លៃអប់រំដូចម្ដេច? និងតើតម្លៃអប់រំនោះមានសារៈសំខាន់ដូចម្ដេច?

**យោបល់ផ្ទាល់ខ្លួន** គឺជាគំនិតផ្ទាល់ខ្លួន ដែលអ្នកសរសេរតែងសេចក្ដី ត្រូវសរសេរពីចំណាប់អារម្មណ៍របស់ខ្លួនទៅលើប្រធាន និងសរសេរពីការប្ដេជ្ញាចិត្តរបស់ខ្លួនថានឹងធ្វើឱ្យខ្លួនឯង ឬបញ្ហាទាំងនោះមានលក្ខណៈវិជ្ជមាន។

ការសរសេរសេចក្ដីបញ្ចប់ អ្នកសរសេរតែងសេចក្ដីគួរគោរពតាមគោលការណ៍មួយចំនួនដូចខាងក្រោម៖

- ✓ សេចក្ដីបញ្ចប់ ត្រូវទាក់ទងនឹងសេចក្ដីអត្ថាធិប្បាយតាំងពីដើមរហូតដល់ចុងបញ្ចប់ ពោលគឺតាំងពីសេចក្ដីផ្ដើមរហូតដល់សេចក្ដីបញ្ចប់ខ្លួនឯងនេះ។

- ជូនកាលជាមេរៀនទូទៅសម្រាប់អប់រំមនុស្ស ដែលទាញចេញពីការបរិយាយខាងលើ។
- សេចក្តីបញ្ចប់ គឺជាយោបល់រួមបំផុតនៃសេចក្តីបរិយាយខាងលើ ពុំមែនជាការអធិប្បាយ ឬការបកស្រាយបញ្ហាឡើងវិញឡើយ។
- នៅក្នុងសេចក្តីបញ្ចប់ អ្នកសរសេរតែងសេចក្តីគួរចៀសវាងបញ្ចប់សេចក្តីដោយលើកបញ្ហាថ្មីមួយទៀតមកចោទជាបញ្ហា ដែលអាចធ្វើឱ្យមានបញ្ហានៅសល់នោះឡើយ ពីព្រោះវានាំឱ្យខូចអស់នូវឯកភាពនៃការបរិយាយរបស់យើង ដែលសរសេររួចហើយ។ ម្យ៉ាងទៀត បើអ្នកសរសេរតែងសេចក្តីបានចោទបញ្ហាមួយទៀត វានឹងបញ្ជាក់ថាតែងសេចក្តីរបស់យើងពុំទាន់ចប់ ហាក់ដូចជានៅមានតទៅទៀត។

## ៤.៤- ចំណុចមួយចំនួនដែលអ្នកសរសេរតែងសេចក្តីគួរយកចិត្តទុកដាក់

ខាងលើនេះយើងបានបង្ហាញពីរបៀបសំខាន់ៗនៃការសរសេរតែងសេចក្តីរួចហើយ។ ខាងក្រោមនេះយើងនឹងលើកយកចំណុចមួយចំនួនទៀតដែលអ្នកសរសេរតែងសេចក្តីគួរយកចិត្តទុកដាក់។ ចំណុចទាំងអស់នេះពុំមែនជាបញ្ហាធំប៉ុន្មានទេ ប៉ុន្តែបើអ្នកសរសេរតែងសេចក្តីមិនយកចិត្តទុកដាក់ ឬបើមានការធ្វេសប្រហែសមើលស្រាលនោះ វានឹងធ្វើឱ្យតែងសេចក្តីរបស់ខ្លួនពុំមានតម្លៃ ឬពុំសមស្របនឹងការនិយម ឬពុំបានទទួលពិន្ទុខ្ពស់។ ចំណុចទាំងនោះរួមមានៈ

### ៤.៤.១- ការសរសេរ

ការសរសេរអក្សរនៅក្នុងតែងសេចក្តីត្រូវស្អាត មានសណ្តាប់ធ្នាប់ ច្បាស់ៗមិនត្រូវសរសេរខ្វីខ្វា ក្រវេមក្រវាម ដែលធ្វើឱ្យអ្នកអាន ឬអ្នកកែពុញទ្រាន់នោះទេ។ ការនិយាយយ៉ាងនេះពុំមែនមានន័យថា ទាមទារឱ្យសរសេរអក្សរស្អាតទាំងអស់គ្នានោះទេ ព្រោះមានអ្នកខ្លះសរសេរពុំបានស្អាតតាំងពីកំណើត ទោះបីខិតខំពត់ដៃយ៉ាណាក៏ដោយក៏នៅតែសរសេរពុំបានស្អាតដែរ។ បញ្ហានោះគឺទាមទារឱ្យអ្នកសរសេរតែងសេចក្តីខិតខំផ្ចិតផ្ចង់លើការសរសេររបស់ខ្លួនឱ្យមានរបៀបរៀបរយត្រឹមត្រូវ ដោយមិនខ្មៀក មានសក់ ឬជើងច្រងេងច្រងាងធាក់គ្នាទៅវិញទៅមក ឬមានស្នាមប្រឡាក់ កោសលុបៗល។ ការសរសេរកខ្វក់ ខ្វីខ្វាបង្ហាញថា អ្នកសរសេរតែងសេចក្តីមិនយកចិត្តទុកដាក់។ កិច្ចការមិនស្អាត មិនគ្រាន់តែធ្វើឱ្យអ្នកអាន ឬអ្នកកែពុញទ្រាន់ និងខាតពេលវេលាប៉ុណ្ណោះទេ តែថែមទាំងធ្វើឱ្យចាប់សេចក្តីពុំបានច្បាស់ទៀតផង។ ជាការល្អគប្បីប្រិតប្រៀងការសរសេរតួអក្សរ ហើយធ្វើឱ្យកិច្ចការទាំងមូលបានស្អាតល្អតាំងពីដើមដល់ចប់។

កិច្ចការតែងសេចក្តីអាចជាកញ្ចក់ឆ្លុះមើលពីគុណសម្បត្តិ ឬពីគុណវិបត្តិរបស់អ្នកសរសេរតែងសេចក្តី ពុំមែនតែខាងផ្លូវប្រាជ្ញាស្មារតី ចំណេះដឹងប៉ុណ្ណោះទេ ថែមទាំងអាចឆ្លុះបញ្ចាំងខាងផ្លូវចិត្ត កាយវិកា អាកប្បកិរិយា និងចរិយាសម្បត្តិទៀតផង។ ដូច្នេះអ្នកសរសេរតែងសេចក្តី ជាពិសេសសិស្ស ឬនិស្សិតដែលកំពុងរៀននៅសាលា គប្បីប្រុងប្រយ័ត្នរៀបចំខ្លួនឱ្យបានល្អប្រសើរ ដោយគិតចាប់ពីការសរសេរអក្សរ រៀបចំសណ្តាប់ធ្នាប់ឡើងទៅ ដើម្បីក្លាយជាជនមួយរូបមានតម្លៃទាំងចំណេះដឹងនិងចរិយា។

### ៤.៤.២- ការប្រើពាក្យពេចន៍

ការគោរពតាមគោលគំនិតខាងលើនៅពុំទាន់គ្រប់គ្រាន់នៅឡើយទេអ្នកសរសេរតែងសេចក្តីត្រូវយកចិត្តទុកដាក់លើបញ្ហាមួយចំនួនទៀត ដើម្បីធ្វើឱ្យតែងសេចក្តីរបស់ខ្លួនកាន់តែបានល្អ។ ដំបូងអ្នកសរសេរតែងសេចក្តីគួរយល់ថា អត្ថបទនីមួយៗកើតឡើងដោយសារពាក្យពេចន៍ និងឃ្លា ល្បះទាំងឡាយ។ អត្ថបទតែងសេចក្តីដែលល្អនិងមានតម្លៃ គឺអត្ថបទដែលមានពាក្យពេចន៍ ឃ្លា ល្បះសមស្រប ព្រមទាំងស៊ីសង្វាក់គ្នាទៀត

ផង។ ទោះបីមានគំនិតល្អយ៉ាងណាក៏ដោយ បើសរសេរពាក្យពេចន៍ ឃ្លា ល្បះមិនល្អ អត្ថបទនោះក៏មិនសូវមានតម្លៃល្អឡើយ។

តាមធម្មតាភាសាខ្មែរយើង មានពាក្យដែលមានដើមកំណើតមកពីបាលី សំស្រ្កឹត និងពាក្យខ្មែរសុទ្ធរបស់ខ្លួន។ សព្វថ្ងៃនេះមានពាក្យបច្ចេកទេសថ្មីៗបន្ថែមទៀតជាច្រើនបានបង្កើតឡើង ហើយពាក្យទាំងនោះពុំទាន់មាននៅក្នុងវចនានុក្រមឡើយ។ ដូច្នេះខ្មែរយើង ក៏មានពាក្យសម្បូរបែបសម្រាប់សម្គាល់ពាក្យសម្តីរបស់ខ្លួន និងបច្ចេកទេសសម័យទំនើប។

- **ការប្រើពាក្យបាលី-សំស្រ្កឹត:** ពាក្យបាលី-សំស្រ្កឹតខ្មែរយើងនិយមហៅថា ពាក្យវប្បធម៌ គឺពាក្យមានតម្លៃ។ ការប្រើពាក្យបាលី-សំស្រ្កឹតនេះជាការប្រសើរណាស់ តែត្រូវយល់ន័យពាក្យនោះឱ្យបានច្បាស់លាស់។ បើយើងយល់ន័យពាក្យនោះពុំបានច្បាស់លាស់ទេ នោះការបរិយាយរបស់យើងត្រឡប់ជាពុំបានល្អទៅវិញ។ ម្យ៉ាងទៀត បើយើងប្រើពាក្យបាលី-សំស្រ្កឹតស្អេកស្កះពេក ក៏ពុំមែនជាការល្អប្រសើរឡើយ ព្រោះមនុស្សទូទៅពុំមែនសុទ្ធតែចេះពាក្យបាលី-សំស្រ្កឹតទាំងអស់គ្នានោះទេ។ ដូច្នេះការប្រើប្រាស់ពាក្យប្រភេទនេះ គប្បីប្រើក្នុងករណីសមស្រប គឺត្រូវគិតដល់បរិយាកាសសង្គម និងចំណេះដឹងទូទៅរបស់មនុស្សក្នុងសង្គមផងដែរ។
- **ការប្រើពាក្យដែលធម្មតា និងសាមញ្ញពេក:** តាមធម្មតានៅក្នុងភាសារបស់ជនជាតិនីមួយៗនៅលើសកលលោកយើងនេះ មានភាសាសរសេរ និងភាសានិយាយ ដែលមានសភាពប្លែកពីគ្នា គឺពាក្យខ្លះសម្រាប់ប្រើក្នុងការនិយាយ ហើយពាក្យខ្លះទៀតសម្រាប់ប្រើក្នុងការសរសេរ។ សភាពប្លែកនេះមិនមែនមានន័យថា ពាក្យដែលប្រើក្នុងភាសានិយាយ និងភាសាសរសេរពុំមានទំនាក់ទំនងគ្នា ឬត្រូវតែដាច់ពីគ្នានោះទេ។ តាមការពិតភាសានិយាយ គឺជាមូលដ្ឋានសម្រាប់ភាសាសរសេរនេះឯង។ អ្នកសរសេរតែងសេចក្តីគួរចៀសវាងពាក្យអាសគ្រាម ឬពាក្យសាមញ្ញធម្មតាពេកយកមកប្រើក្នុងការសរសេរតែងសេចក្តី ដែលវានឹងអាចឱ្យតែងសេចក្តីរបស់យើងអស់តម្លៃ។
- **ការប្រើប្រាស់ពាក្យដែលសមស្របនឹងកាលៈទេសៈ វណ្ណៈ និងឋានៈ:** : ជនជាតិខ្មែរយើងក៏ដូចជាជនជាតិដទៃទៀតដែរ មានភាសាសម្រាប់និយាយស្តី និងសរសេរដើម្បី បញ្ជាក់មនោសញ្ចេតនារបស់ខ្លួនក្នុងកាលៈទេសៈ ឬទំនាក់ទំនងជាមួយមនុស្សផ្សេងៗ។ ដូច្នេះ ការសរសេរតែងសេចក្តី អ្នកសរសេរគួរប្រើពាក្យឱ្យបានសមស្របទៅតាមកាលអាកាស ឬប្រើពាក្យឱ្យសមស្របជាមួយស្រទាប់មនុស្សផ្សេងៗដូចជា ព្រះសង្ឃ រាជវង្សានុវង្ស អ្នកមានគោរមងារផ្សេងៗ មន្ត្រីរាជការ ចាស់ព្រឹទ្ធាចារ្យ ប្រជាជនសាមញ្ញ។ល។ បញ្ហានេះបើមិនបានយកចិត្តទុកដាក់នោះទេ ចិត្ត គំនិត ឬអាកប្បកិរិយារបស់អ្នកសរសេរតែងសេចក្តី ដែលជាសមាសភាពមួយរបស់សង្គមនឹងក្លាយទៅជាមនុស្សគ្មានសីលធម៌ និងមានអាកប្បកិរិយាពុំសមសួនជាពលរដ្ឋម្នាក់។ អ្នកសរសេរតែងសេចក្តីត្រូវចៀសវាងការប្រើពាក្យដដែលៗច្រើនពេក ធ្វើឱ្យអ្នកអាន ឬអ្នកកែធុញទ្រាន់។

### ៤.៤.៣- ការប្រើឃ្លា ល្បះក្នុងការសរសេរតែងសេចក្តី

តែងសេចក្តី គឺជាមុខវិជ្ជាអនុវត្តមួយដែលឆ្លុះបញ្ចាំងចំណេះដឹងអ្នកសរសេរតែងសេចក្តី។ បើសរសេរតែងសេចក្តីបានល្អ គេវាយតម្លៃថាអ្នកសរសេរតែងសេចក្តីពូកែ មានគំនិតទូលំទូលាយ។ ផ្ទុយទៅវិញ បើសរសេរតែងសេចក្តីពុំបានល្អ គេវាយតម្លៃថាអ្នកសរសេរនោះខ្សោយ មានពុទ្ធិចង្អៀតចង្អល់។ល។

ដូច្នេះ ក្នុងការសរសេរតែងសេចក្តីត្រូវយកចិត្តទុកដាក់ក្នុងការប្រើឃ្លា ល្បះ ឱ្យបានត្រឹមត្រូវតាមក្បួនវេយ្យាករណ៍។ ក្នុងរយៈកាលកន្លងមកនេះយើងសង្កេតឃើញថា មានអ្នកសរសេរតែងសេចក្តីមិនតិចទេ ដែលសរសេរតែងសេចក្តីដោយការប្រើប្រាស់ឃ្លា ល្បះពុំបានត្រឹមត្រូវ ឬពុំទាន់បានចែកដាច់រវាងឃ្លា ល្បះសម្រាប់និយាយជាមួយនឹងឃ្លា ល្បះសម្រាប់សរសេរ។ តាមធម្មតាឃ្លា ល្បះសម្រាប់និយាយពុំសូវគិតពីក្បួនវេយ្យាករណ៍ តែឃ្លា ល្បះសម្រាប់សរសេរត្រូវគោរពតាមក្បួនវេយ្យាករណ៍ត្រឹមត្រូវច្បាស់លាស់។ មិនតែប៉ុណ្ណោះឃ្លា ល្បះត្រូវមានន័យត្រឹមត្រូវ និងពីរោះស្តាប់ សម្រាប់អ្នកអាន ឬអ្នកកែ។ ចៀសវាងការប្រើប្រាស់ឃ្លា ល្បះដដែលៗនាំឱ្យបាត់តម្លៃតែងសេចក្តី និងធ្វើឱ្យអ្នកអាន ឬអ្នកកែធុញទ្រាន់។ ដូច្នេះអ្នកសរសេរតែងសេចក្តី គប្បីចេះប្រើឃ្លា ល្បះប្លែកៗ ដើម្បីចៀសវាងការធុញពីសំណាក់អ្នកអាន។

### ៤.៤.៤- អំពីការដកឃ្លា ការប្រើសញ្ញាខណ្ឌ ការប្រើវណ្ណយុត្ត និងការប្រើវណ្ណវាទ

- **ការដកឃ្លា:** ការសរសេរដកឃ្លាមានសារៈសំខាន់ក្នុងការសរសេរអក្សរខ្មែរយើង គឺការធ្វើឱ្យគំនិតនៅតពីគ្នាបន្តិចកុំឱ្យជាប់គ្នារដឹកស្តាប់មិនបាន។ ចំពោះការសរសេរភាសាអង់គ្លេស និងភាសាបារាំង ការដកឃ្លាគេមានសញ្ញាសម្គាល់មួយ គឺសញ្ញាក្បៀស។ ចំណែកអក្សរខ្មែរយើង គេពុំចាំបាច់ក្បៀសទេ គឺគ្រាន់តែដកឃ្លាជាការស្រេច។ រយៈកាលកន្លងមកនេះមានអ្នកសរសេរតែងសេចក្តីមួយចំនួនបានសរសេរដកឃ្លាដោយប្រើសញ្ញាក្បៀសជំនួស ប្រៀបបាននឹងការសរសេរភាសាអង់គ្លេស និងភាសាបារាំងដែរ។ ករណីនេះអ្នកសរសេរតែងសេចក្តីគួរតែចៀសវាង។

- **ការប្រើសញ្ញាខណ្ឌ:** សញ្ញាខណ្ឌ «។» ត្រូវប្រើនៅពេលបញ្ចប់ល្បះនីមួយៗ ដើម្បីកុំឱ្យគំនិតឆ្លងពីល្បះមួយទៅល្បះមួយទៀត។ គេអាចប្រើសញ្ញាខណ្ឌនៅលើឃ្លា ប្រយោគ ឬល្បះ ដែលមានន័យគ្រប់គ្រាន់សមស្របតាមទម្រង់ល្បះ ពោលគឺមានប្រធាន មានកិរិយា និងមានកម្មបទ។ ការសរសេរតែងសេចក្តី គួរគោរពសញ្ញាដកឃ្លា និងការប្រើសញ្ញាខណ្ឌបានត្រឹមត្រូវ។ គប្បីចៀសវាងការសរសេរជាប់គ្នារដឹក ដោយមិនបានដកឃ្លាពីឃ្លាមួយទៅឃ្លាមួយ និងមិនប្រើសញ្ញាខណ្ឌពីល្បះមួយទៅល្បះមួយទៀត។ ការសរសេររបៀបនេះ ធ្វើឱ្យអ្នកអាន ឬអ្នកកែពុំអាចយល់ន័យសេចក្តីរបស់អ្នកសរសេរចង់និយាយ។

- **ការប្រើវណ្ណយុត្ត និងវណ្ណវាទ:** ការសរសេរ អ្នកសរសេរតែងសេចក្តីត្រូវសរសេរវណ្ណយុត្ត និងវណ្ណវាទឱ្យបានច្បាស់ ចៀសវាងការសរសេរច្រឡំគ្នាដូចជា៖
  - ✓ យុគ្គលពិន្ទុឬចុចពីរ «ៈ»
  - ✓ វិសជ្ជនីឬរះមុខ «ះ»
  - ✓ អព្ភន្តរ «...» ឬ "..."
  - ✓ វង់ក្រចក (...)។

រយៈកាលកន្លងមកនេះ ក៏ឃើញមានស្មេរមួយចំនួនបានសរសេរច្រឡំគ្នារវាងយុគ្គលពិន្ទុ និងវិសជ្ជនីដូចជា៖

- ពាក្យ ខណៈ សរសេរជា ខណះ
- ពាក្យ នោះ នេះ សរសេរជា នោៈ នេៈ ជាដើម។

ករណីខាងលើនេះ យើងគួរចៀសវាង ពុំគួរឱ្យមានការភាន់ច្រឡំរវាងវណ្ណយុត្ត និងវណ្ណវាទទាំងនេះទេ។ បើពាក្យណាសរសេរនឹងយុគលពិន្ទុត្រូវសរសេរដោយប្រើយុគ្គលពិន្ទុ តែបើពាក្យណាសរសេរនឹងវិសជ្ជនីត្រូវសរសេរដោយប្រើវិសជ្ជនី។

- **ការសរសេរចុះបន្ទាត់:** ការសរសេរចុះបន្ទាត់ មានប្រយោជន៍សម្រាប់បញ្ជាក់ឱ្យឃើញច្បាស់ពីការបែងចែករវាងគំនិតមួយទៅគំនិតមួយ ឬរវាងកថាខណ្ឌមួយទៅកថាខណ្ឌមួយទៀត។ តាមធម្មតាកាលណាសរសេរអស់គំនិតទី១ ឬកថាខណ្ឌទី១ ត្រូវចុះបន្ទាត់ដើម្បីឈានចូលទៅគំនិតទី២ ឬកថាខណ្ឌទី២ រួចកាលណាចប់គំនិតទី២ ឬកថាខណ្ឌទី២ត្រូវចុះបន្ទាត់ដើម្បីឈានចូលទៅគំនិតទី៣ ឬកថាខណ្ឌទី៣ទៀត។ គប្បីធ្វើដូច្នេះរហូតអស់គំនិត។

 ការសរសេរចុះបន្ទាត់មានសារៈសំខាន់ឱ្យអ្នកអានងាយយល់ ងាយចាប់សេចក្តីបាន មានពេលឈប់សម្រាក មានពេលគិត កាលណាគេចង់អានកថាខណ្ឌត្រង់ណាមួយនៃតែងសេចក្តី។ ការសរសេរចុះបន្ទាត់ យើងត្រូវគោរពប្លង់គម្រោងតែងសេចក្តី ដែលយើងបានរៀបចំរួចហើយ។ ការសរសេរចុះបន្ទាត់តាមកថាខណ្ឌបានបញ្ជាក់ថា អ្នកសរសេរបានយល់ប្រធានច្បាស់ ហើយចេះរៀបចំគំនិតជាលំដាប់លំដោយ។ ចំពោះអត្ថបទខ្លះ យើងបានលើកយកបញ្ហា ឬទស្សនៈមកបរិយាយតែមួយក៏ដោយ ក៏យើងអាចចែកជាកង់ៗ ឬជាផ្នែកៗដែលយើងត្រូវតែសរសេរចុះបន្ទាត់។

 ប៉ុន្តែការសរសេរចុះបន្ទាត់ ពុំមែនអនុញ្ញាតឱ្យយើងចេះតែសរសេរចុះបន្ទាត់ញឹកញាប់ពេក មួយបន្ទាត់ ឬពីរបន្ទាត់ចុះម្តង ឬចេះតែចុះតាមទំនើងចិត្តនោះឡើយ។ ការសរសេរចុះបន្ទាត់ត្រូវឱ្យសមហេតុផល ឱ្យស្របនឹងគំនិតក្នុងកថាខណ្ឌដែលខ្លួនបានសរសេរ។

- **ការប្រើអក្សរកាត់:** ការសរសេរអក្សរកាត់ ត្រូវហាមឃាត់ទាំងស្រុង ពុំអនុញ្ញាតឱ្យសរសេរនៅក្នុងតែងសេចក្តីឡើយ ព្រោះការសរសេរអក្សរកាត់អាចឱ្យអ្នកអាន ឬអ្នកកែយល់មិនច្បាស់អំពីន័យ និងអក្ខរាវិរុទ្ធរបស់ពាក្យ។ ម្យ៉ាងទៀតអ្នកអាន ឬអ្នកកែក៏ចង់ត្រួតពិនិត្យចំណេះដឹងផ្នែកភាសា និងសំណេររបស់អ្នកសរសេរតែងសេចក្តីផងដែរ។ អាស្រ័យហេតុនេះ បានជាគេពុំអនុញ្ញាតឱ្យសរសេរអក្សរកាត់ឡើយ។

- **ការដាក់ចំណងជើងតូច ឬធំ និងសញ្ញាគូសមួយ «-»:** ការដាក់ចំណងជើងតូច ធំក្នុងការសរសេរតែងសេចក្តី ពុំអនុញ្ញាតឱ្យសរសេរទេ ព្រោះថាតែងសេចក្តីមិនមែនជាមេរៀនឡើយ។ តែងសេចក្តីទាមទារឱ្យអ្នកសរសេរត្រូវតែបរិយាយឱ្យស៊ីសង្វាក់គ្នាតាំងពីដើមដល់ចប់។ ការដាក់ចំណងជើងតូចធំ វាអាចធ្វើឱ្យន័យសេចក្តីពីកថាខណ្ឌមួយទៅកថាខណ្ឌមួយពុំស៊ីសង្វាក់គ្នា ដាច់ពីគ្នា ដែលពុំមែនជាតែងសេចក្តី។ ម្យ៉ាងទៀត ការគូសសញ្ញាគូសមួយ «-» នៅមុខឃ្លា ល្បះ វគ្គ ឬកថាខណ្ឌណាមួយត្រូវហាមឃាត់។ ការគូសសញ្ញានេះក៏ធ្វើឱ្យន័យសេចក្តីពីចំណុចមួយទៅចំណុចមួយទៀតដាច់ៗពីគ្នាដូចជាការប្រើចំណងជើងតូច ឬធំដែរ។

- **ការគូសបន្ទាត់ក្រោមពាក្យណាមួយ ឬឃ្លាណាមួយ:** ការគូសបន្ទាត់ក្រោមពាក្យណាមួយ ឬឃ្លាណាមួយពុំអនុញ្ញាតឱ្យគូសបានឡើយ ទោះបីពាក្យនោះមានសារៈសំខាន់យ៉ាងណាក៏ដោយ ពីព្រោះការគូសវាសហាក់ដូចជាបង្គាប់ឱ្យអ្នកកែ ចាប់អារម្មណ៍យល់តាមខ្លួន។ តាមធម្មតាអ្នកកែតែងសេចក្តីគេមានចំណេះដឹងជ្រៅជ្រះអាចយល់ និងវាយតម្លៃកិច្ចការរបស់យើងសព្វគ្រប់ យើងពុំចាំបាច់ព្រួយបារម្ភឡើយ។ ម្យ៉ាងវិញទៀត តែងសេចក្តីពុំមែនជាមេរៀនដែលត្រូវការគូសបញ្ជាក់លើពាក្យណាមួយ ឬចំណងជើងណាមួយឡើយ។ ការងារសំខាន់របស់អ្នកធ្វើតែងសេចក្តី គឺត្រូវតែចេះលើកយកពុទ្ធិ ចំណេះដឹងទូទៅរបស់ខ្លួនមកបរិយាយរ៉ាយរ៉ាប់ឱ្យគេយល់ទៅតាមបញ្ហាដែលគេបានលើកឡើងតែប៉ុណ្ណោះ។

- **ការសរសេរលេខនៅក្នុងតែងសេចក្តី:** នៅក្នុងតែងសេចក្តី គេពុំនិយមឱ្យសរសេរជាតួលេខសុទ្ធៗទេ តែត្រូវសរសេរជាអក្សរជំនួសវិញ។ ឧទាហរណ៍ មនុស្សពីរនាក់ ប្រទេសមួយ ប្រជាជនដប់បីលាននាក់ ឆ្នាំពីរពាន់ដប់ប្រាំពីរជាដើម។
- **ការសរសេរពីបញ្ហាផ្សេងៗ :** នៅក្នុងតែងសេចក្តីមិនត្រូវសរសេរពីរឿងរ៉ាវផ្ទាល់ខ្លួនក្នុងគ្រួសារ និងលើកសរសើរបញ្ចើចបញ្ចើបុគ្គលឥស្សរជនហួសពីការពិតឡើយ។

# ៥- វិធីសាស្ត្រក្នុងការសរសេរតែងសេចក្តី

តែងសេចក្តី ជាសំណេរមួយប្រភេទតម្រូវឱ្យអ្នកសរសេរ មានកម្រិតពុទ្ធិខ្ពស់ផ្នែកចំណេះដឹងទូទៅ ចំណេះដឹងក្នុងការរស់នៅ ផ្លូវច្បាប់ និងចំណេះដឹងផ្នែកអក្សរសិល្ប៍។ ការសរសេរតែងសេចក្តី អ្នកសរសេរមានសេរីភាពគ្រប់គ្រាន់ក្នុងការពណ៌នា ការបកស្រាយ ការពន្យល់ ការបញ្ចេញមតិ ការប្រៀបធៀប... តែសេរីភាពនេះស្ថិតក្រោមក្របខណ្ឌនៃប្រធានតែងសេចក្តី។

ដូច្នេះដើម្បីសរសេរតែងសេចក្តីឱ្យបានល្អត្រឹមត្រូវ ពីរោះក្បោះក្បាយ និងជាទីចាប់អារម្មណ៍របស់អ្នកអាន អ្នកស្តាប់នោះ  អ្នកសរសេរគប្បីអនុវត្តតាមជំហានដូចខាងក្រោម៖

## ៥.១- ការតាំងចិត្ត និងការប្រមូលគំនិត

ការតាំងចិត្ត និងប្រមូលអារម្មណ៍ជាបម្រុងប្រយ័ត្នដ៏សំខាន់មួយ មុននឹងចាប់ផ្តើមសរសេរតែងសេចក្តី មានន័យថា យើងមិនត្រូវប្រញាប់ប្រញាល់ ឬតក់ក្រហល់ពេក មិនត្រូវភ័យខ្លាច ឬញាប់ញ័រ ខ្លាំងពេកនាំឱ្យយើងភ្លេចភ្លាំងបាត់បង់ភាពម្ចាស់ការនោះទេ។ ពោលគឺយើងត្រូវពង្រឹងស្មារតី តាំងអារម្មណ៍ឱ្យស្ងប់ គ្រប់គ្រងអារម្មណ៍ឱ្យបានល្អចៀសវាងការបែកអារម្មណ៍។ ផ្តោតអារម្មណ៍ខ្លាំងលើប្រធានតែងសេចក្តី។ បន្ទាប់ពីរៀបចំខ្លួនបានស្រួលហើយ យើងនឹងចាប់សរសេរតែងសេចក្តីបានល្អត្រឹមត្រូវមិនខាន។

## ៥.២- ការសិក្សាប្រធាន

មុននឹងចាប់ផ្តើមសរសេរត្រូវសិក្សាប្រធានឱ្យបានច្បាស់លាស់ និងល្អិតល្អន់ជាមុនសិន។ ដំបូងយើងត្រូវអានប្រធានឱ្យបានច្រើនសា កត់ចំណាំពាក្យគន្លឹះ និងចំណោទសួររបស់ប្រធានថា តើប្រធាននោះជាប្រធានបែបណា? ប្រធានបែបពិពណ៌នា ការនិទាន ការសរសេរសំបុត្រ អត្ថាធិប្បាយពន្យល់ ប្រៀបធៀបពិភាក្សា។ល។ តើចំណុចត្រង់ណាខ្លះ ដែលបញ្ជាក់ថាជាប្រធានបែបនេះ ឬប្រភេទនោះ? បន្ទាប់ពីស្គាល់ប្រធានច្បាស់លាស់ប្រាកដហើយ ទើបអ្នកអាចចាប់ផ្តើមធ្វើប្លង់ ឬគម្រោងតែងសេចក្តី។

## ៥.៣- ការធ្វើគម្រោងតែងសេចក្តី

ក្រោយពីសិក្សា និងចំណាត់ប្រភេទប្រធានច្បាស់លាស់ហើយ  អ្នកសរសេរតែងសេចក្តីត្រូវធ្វើប្លង់ ឬគម្រោងតែងទៅតាមប្រភេទរបស់ប្រធាននោះ។ តែងសេចក្តី ទោះជាប្រធានបែបណាក្តី ក៏ត្រូវឈរលើផ្នែកសំខាន់៣គឺ៖

- សេចក្តីផ្តើម
- តួសេចក្តី
- សេចក្តីបញ្ចប់។

ក្នុងផ្នែកសំខាន់ទាំងបីខាងលើ អ្នកសរសេរតែងសេចក្ដីត្រូវប្រមូលគំនិត យោបល់ អំណះអំណាង ដែលជាធាតុចូលសម្រាប់បំពេញទៅតាមតម្រូវការខ្លឹមសារនៃផ្នែកទាំងបីខាងលើ។ ក្នុងគម្រោងតែង ឬប្លង់ មិនតម្រូវឱ្យយើងសរសេរគំនិត យោបល់ ពេញលេញគ្រប់ជ្រុងជ្រោយនោះទេ។ ក្នុងគម្រោងតែង យើងគ្រាន់តែព្រាងគំនិតចម្បងៗ និងអំណះអំណាងតាមលំដាប់លំដោយប៉ុណ្ណោះ។

### ៥.៤- ការសរសេរពេញលេញ

ក្នុងដំណាក់នេះ អ្នកសរសេរត្រូវសរសេរគំនិត យោបល់ទៅតាមចំណុចតូចៗ បញ្ចូលទៅក្នុងផ្នែកទាំងបីនៃតែងសេចក្ដី។ នៅពេលនេះ អ្នកសរសេរត្រូវសរសេរយ៉ាងពេញលេញ គ្រប់ជ្រុងជ្រោយ ឱ្យឆ្លើយតបនឹងបញ្ហារបស់ប្រធាន និងទៅតាមគម្រោងដែលបានគិតរួចមកហើយ។ ការសរសេរនោះ ត្រូវគិតទៅលើគំនិត យោបល់ ខ្លឹមសារនៅក្នុងសេចក្ដីផ្ដើម តួសេចក្ដី និងសេចក្ដីបញ្ចប់ ឱ្យឆ្លើយតបគ្រប់ចំណុច ភ្ជាប់ជាមួយនឹងអំណះអំណាង ឬឧទាហរណ៍បញ្ជាក់ច្បាស់លាស់។ ក្រៅពីអត្ថន័យ និងខ្លឹមសារ អ្នកសរសេរក៏ត្រូវគិតទៅលើអក្ខរាវិរុទ្ធ ឃ្លា ល្បះ និងលំដាប់លំដោយគំនិត ខ្លឹមសារផងដែរ។

### ៥.៥- ការកែលម្អ

ដំណាក់ចុងក្រោយនេះ អ្នកសរសេរតែងសេចក្ដីត្រូវពិនិត្យឡើងវិញទៅលើចំណុចសំខាន់ៗមួយចំនួនដូចខាងក្រោម៖

- ✓ ភាពត្រឹមត្រូវទៅតាមប្រធានដែលបានចោទ (កុំឱ្យចាកប្រធាន)។
- ✓ មានខ្លឹមសារគ្រប់គ្រាន់ឆ្លើយតបនឹងផ្នែកធំៗទាំងបីនៃតែងសេចក្ដី (សេចក្ដីផ្ដើម តួសេចក្ដី សេចក្ដីបញ្ចប់) ហើយ ឬនៅ?
- ✓ ខ្លឹមសារ និងគំនិតមានលំដាប់លំដោយទៅតាមគម្រោង ឬប្លង់ និងស្របទៅតាមចំណោទ របស់ប្រធានហើយឬនៅ?
- ✓ មានអំណះអំណាង និងឧទាហរណ៍ (ជីវភាពជាក់ស្ដែង និងក្នុងអក្សរសិល្ប៍) មកបញ្ជាក់ច្បាស់លាស់ និងត្រឹមត្រូវគ្រប់ជ្រុងជ្រោយហើយឬនៅ?
- ✓ សំណេររបស់ខ្លួនមានកំហុសអក្ខរាវិរុទ្ធ ឃ្លា ល្បះដែរឬទេ?
- ✓ តើសំណេរតែងសេចក្ដីរបស់យើងមានឃ្លា ល្បះ ខ្លឹមសារមានលំដាប់ណែងណង ស៊ីចង្វាក់គ្នាជាទីចាប់អារម្មណ៍របស់អ្នកអាន អ្នកស្ដាប់ដែរឬទេ?

នៅពេលពិនិត្យបានហ្មត់ចត់ច្បាស់លាស់រួចហើយនោះ យើងកែលម្អបំពេញបន្ថែមចំណុចដែលមានកំហុស និងខ្វះខាតទាំងនោះឱ្យបានត្រឹមត្រូវឡើងវិញជាការស្រេច។

## ៦- ប្រភេទនៃប្រធានតែងសេចក្ដី

### ៦.១- តែងសេចក្ដីបែបពណ៌នា

តែងសេចក្ដីបែបពិពណ៌នាមាន៖

- ✓ ពណ៌នាអំពីមនុស្ស
- ✓ ពណ៌នាអំពីសត្វ
- ✓ ពណ៌នាអំពីវត្ថុ
- ✓ ពណ៌នាអំពីរុក្ខជាតិ
- ✓ ពណ៌នាអំពីទីកន្លែង

- ✓ ពណ៌នាអំពីទេសភាព
- ✓ ពណ៌នាអំពីព្រឹត្តិការណ៍
- ✓ ពណ៌នាអំពីបាតុភូតធម្មជាតិ
- ✓ ពណ៌នាអំពីឧបទ្ទវហេតុ
- ✓ ពណ៌នាអំពីសកម្មភាព
- ✓ ពណ៌នាតួអង្គក្នុងរឿង
- ✓ ពណ៌នាទេសភាពក្នុងរឿង
- ✓ ពណ៌នាអំពីពិធីផ្សេងៗ។

## ៦.២- តែងសេចក្ដីបែបនិទានកថា ឬវណ្ណនាកថា

- ✓ ពណ៌នាអំពីបាតុភូតធម្មជាតិ
- ✓ ពណ៌នាអំពីឧបទ្ទវហេតុ
- ✓ ពណ៌នាអំពីសកម្មភាព
- ✓ ពណ៌នាអំពីព្រឹត្តិការណ៍។

## ៦.៣- តែងសេចក្ដីបែបនិទានរឿង

- ✓ ពណ៌នាអំពីការនិទានរឿង។

## ៦.៤- តែងសេចក្ដីបែបសរសេរសំបុត្រ

- ✓ ការសរសេរសំបុត្រសួរសុខទុក្ខ
- ✓ ការសរសេរសំបុត្រសូមអភ័យទោស
- ✓ ការសរសេរសំបុត្រចូលរួមរំលែកទុក្ខ។ល។

## ៦.៥- តែងសេចក្ដីបែបពណ៌នាពីសត្វនិងរុក្ខជាតិសម្រាប់ជានិមិត្តសញ្ញាជាតិ

- ✓ ពណ៌នាពីប្រភេទរុក្ខជាតិ «ដើមត្នោត»
- ✓ ពណ៌នាពីប្រភេទផ្កាឈើ «ផ្ការំដួល»
- ✓ ពណ៌នាពីប្រភេទផ្លែ «ចេកពងមាន់»
- ✓ ពណ៌នាពីប្រភេទសត្វចតុប្បាទ «គោព្រៃ»
- ✓ ពណ៌នាពីប្រភេទបក្សី «ត្រយងយក្ស»
- ✓ ពណ៌នាពីប្រភេទឧរង្គសត្វ «អណ្ដើកហ្លួង ឬអណ្ដើកសរសៃ»
- ✓ ពណ៌នាពីប្រភេទមច្ឆជាតិ «ត្រីគល់រាំង»។

## ៦.៦- តែងសេចក្ដីបែបអត្ថាធិប្បាយ

- ✓ តែងសេចក្ដីបែបអត្ថាធិប្បាយពន្យល់
- ✓ តែងសេចក្ដីបែបអត្ថាធិប្បាយប្រៀបធៀប
- ✓ តែងសេចក្ដីបែបអត្ថាធិប្បាយពិភាក្សា
- ✓ តែងសេចក្ដីបែបអត្ថាធិប្បាយស្រាយបំភ្លឺ ឬនិទស្សន៍។ល។

*សម្គាល់:* នៅកម្រិតមធ្យមសិក្សាបឋមភូមិថ្នាក់ទី៧-៩ យើងសិក្សាតែងសេចក្ដីបែបពណ៌នា ការសរសេរសំបុត្រ អត្ថាធិប្បាយពន្យល់ និងអត្ថាធិប្បាយប្រៀបធៀបតែប៉ុណ្ណោះ។

# ៧- ការរចនាទម្រង់សំណេរតែងសេចក្តី

ការសរសេរតែងសេចក្តី ត្រូវរចនាឱ្យបានល្អទៅតាមទម្រង់ និងប្រភេទនៃតែងសេចក្តីនីមួយៗ។ អ្នកសរសេរគប្បីរៀបចំទម្រង់ និងរចនាដូចខាងក្រោម៖

## ៧.១- ការរចនាទម្រង់សំណេរតែងសេចក្តីបែបពណ៌នា និទានកថាឬខណ្ឌនាកថា ការនិទានរឿង និងនិមិត្តសញ្ញាជាតិ

- **សេចក្តីផ្តើម**: សរសេរដោយចាប់ផ្តើមបន្ទាត់ម្តង ក្នុងទម្រង់សំណេរមួយគំនិត (មួយកថាខណ្ឌ) សម្រាប់សេចក្តីផ្តើមទាំងមូល។
- **តួសេចក្តី**: សរសេរដោយចាប់ផ្តើមបន្ទាត់ច្រើនដង អាស្រ័យលើចំនួនគំនិតដែលត្រូវលើកយកមកពណ៌នា ពោលគឺក្នុងមួយគំនិតត្រូវចុះបន្ទាត់ម្តង។ មួយគំនិតមានន័យថា មានគំនិតសំខាន់មួយ ដូច្នេះទម្រង់សំណេរមួយគំនិត គឺដូចមួយកថាខណ្ឌដែរ។
- **សេចក្តីបញ្ចប់**: សរសេរដោយចាប់ផ្តើមបន្ទាត់ម្តង ក្នុងទម្រង់សំណេរមួយគំនិត (មួយកថាខណ្ឌ) សម្រាប់សេចក្តីបញ្ចប់ទាំងមូល។

**ទម្រង់សំណេរតែងសេចក្តីបែប**
**ពណ៌នា និទានកថាឬខណ្ឌនាកថា ការនិទានរឿង និងនិមិត្តសញ្ញាជាតិ**

**សេចក្តីពណ៌នា**

សេចក្តីផ្តើម

__________________________________________

__________________________________________

__________________________________________។

តួសេចក្តី

*(គំនិតទី១)* __________________________________

__________________________________________

__________________________________________។

*(គំនិតទី២)* __________________________________

__________________________________________

__________________________________________។

*(គំនិតទី៣)* __________________________________

__________________________________________

__________________________________________។

សេចក្តីបញ្ចប់

__________________________________________

__________________________________________

__________________________________________។

## ៧.២- ការរចនាទម្រង់សំណេរតែងសេចក្តីបែបសរសេរសំបុត្រ

- **កាខ្ទង់សំបុត្រ**: សរសេរឈ្មោះ និងអាសយដ្ឋានអ្នកផ្ញើនៅផ្នែកខាងឆ្វេង។ សរសេរឈ្មោះ និងអាសយដ្ឋានអ្នកទទួលនៅផ្នែកខាងស្តាំ។
- **ក្បាលសំបុត្រ**: សរសេរទីកន្លែង និងកាលបរិច្ឆេទមួយបន្ទាត់នៅផ្នែកខាងស្តាំ។ សរសេរចំណងជើងសំបុត្រនៅចំកណ្តាលបន្ទាត់។
- **តួសំបុត្រ**: សរសេរដោយចាប់ផ្តើមបន្ទាត់ម្តង ឬច្រើនដង អាស្រ័យលើចំនួនគំនិតដែលត្រូវលើកយកមកពណ៌នា ពោលគឺក្នុងមួយគំនិតត្រូវចុះបន្ទាត់ម្តង។ មួយគំនិតមានន័យថា មានគំនិតសំខាន់មួយ ដូច្នេះទម្រង់សំណេរមួយគំនិត គឺដូចមួយកថាខណ្ឌដែរ។
- **ការបញ្ចប់សំបុត្រ**៖
  - ✓ ខ្លឹមសារបញ្ចប់សំបុត្រ: សរសេរដោយចាប់ផ្តើមបន្ទាត់ម្តង ក្នុងទម្រង់សំណេរមួយគំនិត (មួយកថាខណ្ឌ)
  - ✓ ឃ្លាបញ្ចប់សំបុត្រ: សរសេរនៅផ្នែកខាងក្រោម និងខាងស្តាំ
  - ✓ ហត្ថលេខា: នៅខាងក្រោមឃ្លាបញ្ចប់សំបុត្រ
  - ✓ ឈ្មោះ: សរសេរនៅខាងក្រោមហត្ថលេខា។

### ទម្រង់សំណេរតែងសេចក្តីបែបសរសេរសំបុត្រ

- **ផ្នែកខាងក្រៅ (ស្រោមសំបុត្រ)**

*(ឈ្មោះអ្នកផ្ញើ)* ______________

*(អាសយដ្ឋាន)* ______________

**គោរពជូន ឬជូនចំពោះ**

*(ឈ្មោះអ្នកទទួល)* ________________

*(អាសយដ្ឋាន)* ____________________

- **ផ្នែកខាងក្នុង (សំបុត្រ)**

*ថ្ងៃចន្ទ ១២រោច ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១*

*រាជធានីភ្នំពេញ ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៨*

*(ចំណងជើងសំបុត្រ)*

__________________________

**តួសំបុត្រ**

*(គំនិតទី១)* ________________________________________________________

________________________________________________________________

________________________________________________________________។

*(គំនិតទី២)* ________________________________________
________________________________________
________________________________________។
*(គំនិតទី៣)* ________________________________________
________________________________________
________________________________________។

បញ្ចប់សំបុត្រ

*(ខ្លឹមសារបញ្ចប់សំបុត្រ)* ________________________________________
________________________________________
________________________________________។
*(ឃ្លាបញ្ចប់សំបុត្រ)* ________________________________________។

ហត្ថលេខា

ឈ្មោះ ____________

## ៧.៣- ការរចនាទម្រង់សំណេរតែងសេចក្តីបែបអត្ថាធិប្បាយពន្យល់

- **សេចក្តីផ្តើម**
  - ✓ លំនាំបញ្ហា និងចំណូលបញ្ហា(បង្ហាញបញ្ហា) សរសេរដោយចាប់ផ្តើមបន្ទាត់ម្តង ក្នុងទម្រង់
  - ✓ សំណេរមួយគំនិត(មួយកថាខណ្ឌ)
  - ✓ ចំណោទបញ្ហា សរសេរដោយចាប់ផ្តើមបន្ទាត់ម្តង។
- **តួសេចក្តី**
  - ✓ ឃ្លាភ្ជាប់សេចក្តី ពន្យល់ពាក្យគន្លឹះ និងពន្យល់ន័យប្រធានៈ សរសេរដោយចាប់ផ្តើមបន្ទាត់ម្តងក្នុងទម្រង់សំណេរមួយគំនិត (មួយកថាខណ្ឌ)
  - ✓ បកស្រាយប្រធានៈ សរសេរដោយចាប់ផ្តើមបន្ទាត់ម្តង ឬច្រើនដង អាស្រ័យលើចំនួនគំនិតដែលត្រូវលើកយកមកធ្វើការបកស្រាយ ពោលគឺក្នុងមួយគំនិតត្រូវចុះបន្ទាត់ម្តង។ មួយគំនិតមានន័យថា មានគំនិតសំខាន់មួយ ដូច្នេះទម្រង់សំណេរមួយគំនិត គឺដូចមួយកថាខណ្ឌដែរ
  - ✓ សរុបសេចក្តីៈ សរសេរដោយចាប់ផ្តើមបន្ទាត់ម្តង ក្នុងទម្រង់សំណេរមួយគំនិត (មួយកថាខណ្ឌ) សម្រាប់សរុបសេចក្តី។
- **សេចក្តីបញ្ចប់ៈ** សរសេរដោយចាប់ផ្តើមបន្ទាត់ម្តង ក្នុងទម្រង់សំណេរមួយគំនិត (មួយកថាខណ្ឌ) សម្រាប់ការវាយតម្លៃប្រធាន និងយោបល់ផ្ទាល់ខ្លួន។

## ទម្រង់សំណេរតែងសេចក្តីបែបពន្យល់

**សេចក្តីអត្ថាធិប្បាយ**

សេចក្តីផ្តើម

*(លំនាំបញ្ហា)* ____________________

____________________។ *(ចំណូលបញ្ហា)* ____________________

____________________។

*(ចំណោទបញ្ហា)* ____________________

____________________?

តួសេចក្តី

*(ឃ្លាភ្ជាប់សេចក្តី)* ____________________។

*(ពន្យល់ពាក្យគន្លឹះ)* ____________________។

*(ពន្យល់ន័យប្រធាន)* ____________________

____________________។

បកស្រាយន័យប្រធាន

*(គំនិតទី១ និងឧទាហរណ៍)* ____________________

____________________

____________________។

*(គំនិតទី២ និងឧទាហរណ៍)* ____________________

____________________

____________________។

*(គំនិតទី៣ និងឧទាហរណ៍)* ____________________

____________________

____________________។

សេចក្តីបញ្ចប់

*(វាយតម្លៃប្រធាន)* ____________________។

*(យោបល់ផ្ទាល់ខ្លួន)* ____________________

____________________។

## ៧.៤- ការរចនាទម្រង់សំណេរតែងសេចក្តីបែបអត្ថាធិប្បាយប្រៀបធៀប

- សេចក្តីផ្តើម
  - ✓ លំនាំបញ្ហា និងចំណូលបញ្ហា (បង្ហាញបញ្ហា) : សរសេរដោយចាប់ផ្តើមបន្ទាត់ម្តង ក្នុងទម្រង់សំណេរមួយគំនិត (មួយកថាខណ្ឌ)។
  - ✓ ចំណោទបញ្ហា: សរសេរដោយចាប់ផ្តើមបន្ទាត់ម្តង។

- **តួសេចក្តី**
  - ✓ ឃ្លាភ្ជាប់សេចក្តី ពន្យល់ពាក្យគន្លឹះ និងពន្យល់ន័យប្រធាន: សរសេរដោយចាប់ផ្តើមបន្ទាត់ម្តងក្នុងទម្រង់សំណេរមួយគំនិត(មួយកថាខណ្ឌ)។
  - ✓ បកស្រាយប្រធានៈ
    - លក្ខណៈដូចគ្នាតួអង្គ "ក" និងតួអង្គ "ខ" សរសេរដោយចាប់ផ្តើមបន្ទាត់ម្តងឬច្រើនដង អាស្រ័យលើចំនួនគំនិតដែលត្រូវលើកយកមកធ្វើការបកស្រាយ ពោលគឺក្នុងមួយគំនិតត្រូវចុះបន្ទាត់ម្តង។ មួយគំនិតមានន័យថា មានគំនិតសំខាន់មួយ ដូច្នេះទម្រង់សំណេរមួយគំនិត គឺដូចមួយកថាខណ្ឌដែរ។
    - លក្ខណៈខុសគ្នាតួអង្គ «ក» សរសេរដោយចាប់ផ្តើមបន្ទាត់ម្តងឬច្រើនដង អាស្រ័យលើចំនួនគំនិតដែលត្រូវលើកយកមកធ្វើការបកស្រាយ ពោលគឺក្នុងមួយគំនិតត្រូវចុះបន្ទាត់ម្តង។ មួយគំនិតមានន័យថា មានគំនិតសំខាន់មួយ ដូច្នេះទម្រង់សំណេរមួយគំនិត គឺដូចមួយកថាខណ្ឌដែរ។
    - លក្ខណៈខុសគ្នាតួអង្គ «ខ» សរសេរដោយចាប់ផ្តើមបន្ទាត់ម្តងឬច្រើនដង អាស្រ័យលើចំនួនគំនិតដែលត្រូវលើកយកមកធ្វើការបកស្រាយ ពោលគឺក្នុងមួយគំនិតត្រូវចុះបន្ទាត់ម្តង។ មួយគំនិតមានន័យថា មានគំនិតសំខាន់មួយ ដូច្នេះទម្រង់សំណេរមួយគំនិត គឺដូចមួយកថាខណ្ឌដែរ។
  - ✓ សរុបសេចក្តី: សរសេរដោយចាប់ផ្តើមបន្ទាត់ម្តង ក្នុងទម្រង់សំណេរមួយគំនិត (មួយកថាខណ្ឌ)។

- **សេចក្តីបញ្ចប់**

សរសេរដោយចាប់ផ្តើមបន្ទាត់ម្តង ក្នុងទម្រង់សំណេរមួយគំនិត (មួយកថាខណ្ឌ) សម្រាប់ការវាយតម្លៃប្រធាន និងយោបល់ផ្ទាល់ខ្លួន។

## ទម្រង់សំណេរតែងសេចក្តីបែបអត្ថាធិប្បាយប្រៀបធៀប

**សេចក្តីអត្ថាធិប្បាយ**

**សេចក្តីផ្តើម**

*(លំនាំបញ្ហា)* ________________________________________________។

*(ចំណូលបញ្ហា)* ________________________________________________

________________________________________________________________។

*(ចំណោទបញ្ហា)* ________________________________________________

____________________________________________?

**តួសេចក្តី**

*(ឃ្លាភ្ជាប់សេចក្តី)* ________________________________________________។

*(ពន្យល់ពាក្យគន្លឹះ)* ________________________________________________។

*(ពន្យល់ន័យប្រធាន)* ________________________________________________

________________________________________________________________។

បកស្រាយន័យប្រធាន

លក្ខណៈដូចគ្នាតួអង្គ "ក" និងតួអង្គ "ខ"

*(គំនិតទី១ និងឧទាហរណ៍)* ____________________

____________________។

*(គំនិតទី២ និងឧទាហរណ៍)* ____________________

____________________។

*(គំនិតទី៣ និងឧទាហរណ៍)* ____________________

____________________។

លក្ខណៈខុសគ្នាតួអង្គ "ក"

*(គំនិតទី១ និងឧទាហរណ៍)* ____________________

____________________។

*(គំនិតទី២ និងឧទាហរណ៍)* ____________________

____________________។

*(គំនិតទី៣ និងឧទាហរណ៍)* ____________________

____________________។

លក្ខណៈខុសគ្នាតួអង្គ "ខ"

*(គំនិតទី១ និងឧទាហរណ៍)* ____________________

____________________។

*(គំនិតទី២ និងឧទាហរណ៍)* ____________________

____________________។

*(គំនិតទី៣ និងឧទាហរណ៍)* ____________________

____________________។

*(សរុបសេចក្តី)* ____________________

____________________។

សេចក្តីបញ្ចប់

*(វាយតម្លៃប្រធាន)* ____________________។

*(យោបល់ផ្ទាល់ខ្លួន)* ____________________

____________________។

# ៨- តែងសេចក្តីបែបពិពណ៌នា និងការសរសេរសំបុត្រ

## ៨.១- លក្ខណៈទូទៅនៃតែងសេចក្តីបែបពណ៌នា និងការសរសេរសំបុត្រ

ការធ្វើតែងសេចក្តីបែបពណ៌នា តម្រូវឱ្យយើងលើកយកមកបង្ហាញឡើងវិញនូវអ្វីៗ ដែលបានឃើញ បានឮ បានស្រង់ក្លិន បានភ្លក្ស ពោលគឺអ្វីៗដែលមានទំនាក់ទំនងទៅនឹងធម្មជាតិខាងក្រៅ និងឥន្ទ្រិយរបស់យើង។ ប្រធានតែងសេចក្តីបែបនេះតម្រូវឱ្យយើងសង្កេត ពិនិត្យ និងចងចាំជាងការត្រិះរិះពិចារណា ឬវិភាគ។ ការសង្កេត ពិនិត្យ កត់ចំណាំនោះទៀតសោត ត្រូវមានបំណិនប្រសប់ជ្រើសរើសតែលក្ខណៈពិសេសៗនៃ

មនុស្ស សត្វ វត្ថុ រុក្ខជាតិ ទីកន្លែង ព្រឹត្តិការណ៍ ទេសភាពជាដើម មកធ្វើការពណ៌នាឡើងវិញដើម្បីឱ្យគេបានដឹង បានឮ បានឃើញផ្ទាល់នឹងភ្នែកពិតៗ។ ការពណ៌នាបានល្អ ជាក់ស្តែង និងរស់រវើក គឺការប្រើវិញ្ញាណគួបផ្សំដូចជាការប្រើភ្នែក ត្រចៀក ដៃ ច្រមុះ អណ្តាត និងបំណិនប្រសប់ជ្រើសរើសទិដ្ឋភាពឬលក្ខណៈពិសេសៗមកពណ៌នាតាមកាលអាកាស តាមលំដាប់លំដោយគំនិតប្រកបដោយភាពទាក់ទាញ (សិល្បវិធី)។

## ៨.២- សារៈសំខាន់នៃតែងសេចក្តីបែបពណ៌នា និងការសរសេរសំបុត្រ

តែងសេចក្តីបែបពណ៌នាមានគោលបំណង និងសារៈសំខាន់បំផុតចំពោះសិស្សានុសិស្សនៅកម្រិតបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ ព្រោះថាសំណេរតែងសេចក្តីបែបពណ៌នានេះ គឺជាមូលដ្ឋានគ្រឹះដំបូងបំផុតដែលសិស្សត្រូវចេះ មុននឹងបន្តទៅធ្វើតែងសេចក្តីបែបអត្ថាធិប្បាយពន្យល់ ប្រៀបធៀប និងពិភាក្សានៅកម្រិតមធ្យមសិក្សា។ ពិសេសគឺបង្កើនបំណិនសរសេររបស់សិស្ស ឱ្យបានកាន់តែខ្ពស់ និងមានប្រសិទ្ធភាព។ ពោលគឺបណ្តុះទម្លាប់សិស្សឱ្យចេះសង្កេត ពិនិត្យលើលក្ខណៈមនុស្ស សត្វ វត្ថុ រុក្ខជាតិ ព្រឹត្តិការណ៍ ឬសកម្មភាពផ្សេងៗដោយយកចិត្តទុកដាក់ ចេះរៀបរាប់បង្ហាញអ្វីដែលបានឃើញ បានឮ នៅជុំវិញខ្លួន និងក្នុងសង្គមរហូតឈានទៅមានគំនិតចេះវិភាគ ពិចារណាថ្លឹងថ្លែង ដឹងខុសត្រូវ សខ្មៅ ខ្ពស់ ទាប ល្អ អាក្រក់ ហើយចេះវាយតម្លៃបានត្រឹមត្រូវគ្រប់ជ្រុងជ្រោយ ដោយមានអំណះអំណាងហេតុផលបញ្ជាក់ច្បាស់លាស់ និងចេះប្រើប្រាស់ចំណេះដឹងទាំងនេះក្នុងជីវភាពរស់នៅប្រចាំថ្ងៃបានយ៉ាងល្អប្រសើរទៀតផង។

## ៨.៣- ប្រភេទតែងសេចក្តីបែបពណ៌នា និងការសរសេរសំបុត្រ

តែងសេចក្តីបែបពណ៌នាមានច្រើនប្រភេទ គឺពណ៌នាអំពីមនុស្ស សត្វ វត្ថុ រុក្ខជាតិ ទីកន្លែង ទេសភាព ព្រឹត្តិការណ៍ បាតុភូតធម្មជាតិ ឧបទ្ទវហេតុ សកម្មភាព ពិធីផ្សេងៗ ការនិទានរឿង សត្វនិងរុក្ខជាតិសម្រាប់ជានិមិត្តសញ្ញាជាតិ និងការសរសេរសំបុត្រជាដើម។

*សម្គាល់:* នៅកម្រិតមធ្យមសិក្សាបឋមភូមិ យើងសិក្សាតែងសេចក្តីបែបពិពណ៌នាអំពីទេសភាព ក្នុងរឿង បាតុភូតុធម្មជាតិ ឧបទ្ទវហេតុ សកម្មភាព ព្រឹត្តិការណ៍ ពិធីផ្សេងៗ និងការសរសេរសំបុត្រ។

## ៨.៤- លក្ខណៈសម្គាល់ប្រធានតែងសេចក្តីបែបពណ៌នា និទានកថា និងការសរសេរសំបុត្រ

**លក្ខណៈសម្គាល់ប្រធានតែងសេចក្តីបែបពណ៌នាមានដូចជា៖**

- ចូរអ្នកសរសេរពណ៌នាពី...ឱ្យបានក្បោះក្បាយ។
- ចូរប្អូនសរសេររៀបរាប់ពី...ឱ្យបានច្បាស់លាស់។
- ចូរប្អូនសរសេរតែងសេចក្តីពណ៌នាពី...។ ឧទាហរណ៍: តែងសេចក្តីបែបពណ៌នាអំពីទេសភាពក្នុងរឿង។

**ប្រធាន:** ក្នុងរឿងផ្កាស្រពោន អ្នកនិពន្ធបានសរសេររៀបរាប់ពីទេសភាពនៅប្រាសាទនានាក្នុងខេត្តសៀមរាប។ ចូរប្អូនៗសរសេរពណ៌នាពីទេសភាពនៅទីនោះឱ្យបានក្បោះក្បាយ។

**លក្ខណៈសម្គាល់តែងសេចក្តីបែបនិទានកថា ឬវណ្ណនាកថាមានដូចជា៖**

- ចូរប្អូនសរសេររៀបរាប់ឡើងវិញ...ឱ្យបានក្បោះក្បាយ។
- ចូរប្អូននិទានឡើងវិញ...ឱ្យបានច្បាស់លាស់។ *ឧទាហរណ៍៖*
  - ✓ តែងសេចក្តីបែបពណ៌នាអំពីបាតុភូតធម្មជាតិ ឬឧបទ្ទវហេតុ។

ប្រធាន: រៀងរាល់ឆ្នាំ ក្នុងប្រទេសកម្ពុជាយើងតែងជួបប្រទះនូវគ្រោះធម្មជាតិខ្យល់កន្ត្រាក់។ ចូរប្អូនសរសេរតែងសេចក្តីពណ៌នាពីបាតុភូតនេះឱ្យបានក្បោះក្បាយ។

- ✓ តែងសេចក្តីបែបពណ៌នាអំពីសកម្មភាព
  ប្រធាន: សាលារៀនប្អូនបានរៀបចំការប្រកួតកីឡាជារៀងរាល់ឆ្នាំ។ ចូរប្អូនសរសេរពណ៌នាពីសកម្មភាពប្រកួតកីឡាណាមួយឱ្យបានក្បោះក្បាយ។
- ✓ តែងសេចក្តីបែបពណ៌នាអំពីព្រឹត្តិការណ៍
  ប្រធាន: នៅក្នុងសហគមន៍អ្នកធ្លាប់កើតមានព្រឹត្តិការណ៍គ្រោះថ្នាក់ចរាចរណ៍ជារឿយៗ។ ចូរអ្នកសរសេរតែងសេចក្តីពណ៌នាពីព្រឹត្តិការណ៍នេះឱ្យបានក្បោះក្បាយ។
- ✓ តែងសេចក្តីបែបពណ៌នាអំពីពិធីផ្សេងៗ
  ប្រធាន: ប្រជាជននៅក្នុងភូមិប្អូនតែងរៀបចំប្រារព្ធធ្វើពិធីបុណ្យផ្សេងៗ។ ចូរប្អូនសរសេរតែងសេចក្តីពណ៌នាពីពិធីបុណ្យអ្វីមួយឱ្យបានក្បោះក្បាយ។
- ✓ តែងសេចក្តីបែបពណ៌នាអំពីនិមិត្តសញ្ញជាតិ
  ប្រធាន : ចូរប្អូនពណ៌នាអំពីផ្ការំដួលដែលជានិមិត្តសញ្ញាជាតិខ្មែរឱ្យបានក្បោះក្បាយ។

លក្ខណៈសម្គាល់ប្រធានបែបសរសេរសំបុត្រមានដូចជាៈ

- ចូរអ្នកសរសេរសំបុត្រផ្ញើទៅ...។
- ចូរប្អូនសរសេរសំបុត្ររៀបរាប់ពី...ឱ្យបានក្បោះក្បាយ។ ឧទាហរណ៍ៈ
  - ✓ ការសរសេរសំបុត្រសួរសុខទុក្ខ
    ប្រធាន : ប្អូនបានឃ្លាតឆ្ងាយពីមិត្តភក្តិរបស់ប្អូនជាយូរមកហើយ។ ចូរប្អូនសរសេរសំបុត្រមួយច្បាប់ ដើម្បីសួរសុខទុក្ខជាមួយមិត្តភក្តិប្អូនឱ្យបានក្បោះក្បាយ។
  - ✓ ការសរសេរសំបុត្រសុំអភ័យទោស
    ប្រធាន : ថ្ងៃមួយប្អូនបានប្រព្រឹត្តខុសចំពោះមិត្តភក្តិរបស់ប្អូន។ ចូរប្អូនសរសេរសំបុត្រមួយច្បាប់ដើម្បីសុំអភ័យទោសមិត្តភក្តិប្អូនឱ្យបានក្បោះក្បាយ។

## ៨.៥- គម្រោងតែងសេចក្តីបែបពណ៌នា និទានកថាឬវណ្ណនាកថា និងការសរសេរសំបុត្រ

### ៨.៥.១- គម្រោងតែងសេចក្តីបែបពណ៌នាពីទេសភាពក្នុងរឿង

#### គម្រោងតែង

**ក- សេចក្តីផ្តើម**

- ចំណងជើងរឿង ...
- ឈ្មោះអ្នកនិពន្ធ ...
- កាលកំណត់តែង...។

**ខ- តួសេចក្តី**

- ឃ្លាភ្ជាប់សេចក្តី...
- ដកស្រង់សេចក្តីពណ៌នាទេសភាពក្នុងរឿង ...។

**គ- សេចក្តីបញ្ចប់**
- វាយតម្លៃលើស្នាដៃអ្នកនិពន្ធ ...
- ចំណាប់អារម្មណ៍ផ្ទាល់ខ្លួន...។

### ៨.៥.២- គម្រោងតែងសេចក្តីបែបបែបនិទានកថា ឬវណ្ណនាកថា

**គម្រោងតែងសេចក្តីបែបនិទានកថា ឬវណ្ណនាកថាទាក់ទងនឹងបាតុភូតធម្មជាតិ**

**ក- សេចក្តីផ្តើម**
- ពេលវេលាកើតមានបាតុភូតធម្មជាតិ...
- ទីកន្លែងកើតមានបាតុភូតធម្មជាតិ...
- ឈ្មោះបាតុភូតធម្មជាតិ...។

**ខ- តួសេចក្តី**

*មុនពេលកើតមានបាតុភូតធម្មជាតិៈ*
- ទិដ្ឋភាពទូទៅ...
- សកម្មភាពមុនពេលកើតមានបាតុភូតធម្មជាតិ... ។

*ពេលកើតមានបាតុភូតធម្មជាតិៈ*
- ទិដ្ឋភាពពេលបាតុភូតធម្មជាតិចាប់ផ្តើមកើតឡើង...
- ទិដ្ឋភាពពេលបាតុភូតធម្មជាតិកំពុងកើតឡើង...
- ទិដ្ឋភាពចុងបញ្ចប់នៃការកើតមានបាតុភូតធម្មជាតិ... ។

*ក្រោយពេលកើតមានបាតុភូតធម្មជាតិៈ*
- ទិដ្ឋភាពក្រោយពេលកើតមានបាតុភូតធម្មជាតិ...
- សកម្មភាពអ្នកស្រុកក្រោយពេលកើតមានបាតុភូតធម្មជាតិ...
- សកម្មភាពអាជ្ញាធរមូលដ្ឋាន ឬអង្គការមនុស្សធម៌ផ្សេងៗ... ។

**គ- សេចក្តីបញ្ចប់**
- វាយតម្លៃបាតុភូត...
- ចំណាប់អារម្មណ៍ : បង្ហាញពីចំណាប់អារម្មណ៍ចំពោះបាតុភូតធម្មជាតិនោះ...។

### ៨.៥.៣- គម្រោងតែងសេចក្តីនិទានកថា ឬវណ្ណនាកថាទាក់ទងនឹងសកម្មភាព

**ក- សេចក្តីផ្តើម**
- ពណ៌នាទូទៅទាក់ទងនឹងសកម្មភាព...
- ពេលវេលាកើតសកម្មភាព...
- ទីកន្លែងកើតសកម្មភាព...
- ឈ្មោះសកម្មភាព... ។

**ខ- តួសេចក្តី**

*មុនពេលកើតសកម្មភាពៈ*
- ការរៀបចំទីកន្លែង...
- ការរៀបចំអ្នកចូលរួម... ។

*ពេលកើតសកម្មភាព៖*

- ទិដ្ឋភាពពេលចាប់ផ្តើមសកម្មភាព...
- ទិដ្ឋភាពពេលកំពុងធ្វើសកម្មភាព...
- ទិដ្ឋភាពចុងបញ្ចប់នៃសកម្មភាព... ។

*ក្រោយពេលកើតសកម្មភាព៖*

- លទ្ធផលនៃសកម្មភាព...
- សកម្មភាពអ្នកចូលរួម... ។

**គ- សេចក្តីបញ្ចប់**

- វាយតម្លៃ...
- បង្ហាញពីចំណាប់អារម្មណ៍របស់អ្នក ឬមនុស្សទូទៅចំពោះសកម្មភាពនោះ... ។

### ៨.៥.៤- គម្រោងតែងសេចក្តីនិទានកថា ឬវណ្ណនាកថាទាក់ទងនឹងព្រឹត្តិការណ៍

**ក- សេចក្តីផ្តើម**

- ✓ ពេលវេលាកើតព្រឹត្តិការណ៍...
- ✓ ទីកន្លែងកើតព្រឹត្តិការណ៍...
- ✓ ឈ្មោះព្រឹត្តិការណ៍... ។

**ខ- តួសេចក្តី**

*មុនពេលកើតព្រឹត្តិការណ៍៖*

- ទិដ្ឋភាពទូទៅ... ។
- សកម្មភាពមុនពេលកើតព្រឹត្តិការណ៍... ។

*ពេលកើតព្រឹត្តិការណ៍៖*

- ទិដ្ឋភាពពេលព្រឹត្តិការណ៍ចាប់ផ្តើមកើតឡើង... ។
- ទិដ្ឋភាពពេលព្រឹត្តិការណ៍កំពុងកើតឡើង...។
- ទិដ្ឋភាពចុងបញ្ចប់នៃព្រឹត្តិការណ៍...។

*ក្រោយពេលកើតព្រឹត្តិការណ៍៖*

- ទិដ្ឋភាពនៃការខូចខាត...។
- សកម្មភាពអ្នកស្រុកក្រោយពេលកើតហេតុ...។
- សកម្មភាពអាជ្ញាធរមូលដ្ឋាន ឬ អង្គការមនុស្សធម៌ផ្សេងៗ...។

**គ- សេចក្តីបញ្ចប់**

- វាយតម្លៃ...
- ចំណាប់អារម្មណ៍ : បង្ហាញពីចំណាប់អារម្មណ៍ចំពោះព្រឹត្តិការណ៍... ។

### ៨.៥.៥- គម្រោងតែងសេចក្តីបែបពណ៌នាពីពិធីផ្សេងៗ

**ក- សេចក្តីផ្តើម**

- ពណ៌នាទូទៅទាក់ទងនឹងពិធី...
- ពេលវេលាធ្វើពិធី...
- ទីកន្លែងធ្វើពិធី...

- ឈ្មោះពិធី និងគោលបំណងនៃការធ្វើពិធី... ។

**ខ- តួសេចក្តី**

*មុនពេលប្រារព្ធពិធី ៖*

- ការរៀបចំទីកន្លែង... ។
- ការរៀបចំអ្នកចូលរួម... ។

*ពេលប្រារព្ធពិធី ៖*

- ទិដ្ឋភាពពេលចាប់ផ្តើមប្រារព្ធពិធី... ។
- ទិដ្ឋភាពពេលកំពុងប្រារព្ធពិធី... ។
- ទិដ្ឋភាពចុងបញ្ចប់នៃការប្រារព្ធពិធី...។

*ក្រោយពេលប្រារព្ធពិធី៖*

- ការថ្លែងអំណរគុណចំពោះអ្នកចូលរួម...។
- ការរៀបចំសម្អាតទីកន្លែង...។

**គ- សេចក្តីបញ្ចប់**

- វាយតម្លៃ...
- បង្ហាញពីចំណាប់អារម្មណ៍របស់អ្នក ឬមនុស្សទូទៅចំពោះពិធីនោះ...។

### ៨.៥.៦- គម្រោងតែងសេចក្តីបែបពណ៌នាពីសត្វនិងរុក្ខជាតិសម្រាប់ជានិមិត្តសញ្ញាជាតិ

**ក- សេចក្តីផ្តើម**

- ឈ្មោះ...
- ទីកន្លែង...
- កាលបរិច្ឆេទ...។

**ខ- តួសេចក្តី**

- រូបរាង...
- ការរស់នៅ...
- ការថែរក្សា...
- ផលប្រយោជន៍... ។

**គ- សេចក្តីបញ្ចប់**

- វាយតម្លៃ...
- បង្ហាញពីចំណាប់អារម្មណ៍របស់អ្នក...។

## ៨.៦- គម្រោងការសរសេរសំបុត្រសួរសុខទុក្ខ

### ៨.៦.១- ផ្នែកខាងក្រៅ (ស្រោមសំបុត្រ)

**កាខ្នងសំបុត្រ៖**

- ចេញពី(ឈ្មោះអ្នកផ្ញើ) ...
- អាសយដ្ឋាន ...
- គោរពជូន ឬជូនចំពោះ(ឈ្មោះអ្នកទទួល) ...
- អាសយដ្ឋាន ...។

### ៨.៦.២- ផ្នែកខាងក្នុង (តួសំបុត្រ)

ក្បាលសំបុត្រ៖

- ចុះទីន្លែង ចុះកាលបរិច្ឆេទនៃការសរសេរ...
- ចំណាងជើងសំបុត្រ... ។

តួសំបុត្រ៖

- រៀបរាប់ពីសុខទុក្ខអ្នកសរសេរ...
- សួរសុខទុក្ខអ្នកដែលទទួលសំបុត្រ...
- សរសេររៀបរាប់រឿងរ៉ាវផ្សេងៗមានដូចជា ដំណឹង ការសប្បាយ ទុក្ខព្រួយ ដំបូន្មាន សេចក្ដីនឹករឭក សកម្មភាពផ្សេងៗ... ។

ការបញ្ចប់សំបុត្រ៖

- ជូនពរ(ត្រូវប្រើពាក្យឱ្យសមស្របតាមកាលៈទេសៈ) ...
- ជូនកាលអាចភ្ជាប់ឃ្លាបញ្ចប់សំបុត្រដូចជា ពីកូនកម្សត់របស់ម៉ែ នឹកជានិរន្តរ៍ ពីមិត្តសម្លាញ់ដែលមិនអាចបំភ្លេចបាន ពីបណ្ដូលចិត្តរបស់អ្នក...
- ទីបញ្ចប់ត្រូវចុះហត្ថលេខា និងចុះឈ្មោះអ្នកសរសេរ... ។

## ៨.៧- គម្រោងការសរសេរសំបុត្រសុំអភ័យទោស

### ៨.៧.១- ផ្នែកខាងក្រៅ (ស្រោមសំបុត្រ)

កាខ្នងសំបុត្រ៖

- ចេញពី (ឈ្មោះអ្នកផ្ញើ) ...
- អាសយដ្ឋាន ...
- គោរពជូន ឬជូនចំពោះ (ឈ្មោះអ្នកទទួល) ...
- អាសយដ្ឋាន ... ។

### ៨.៧.២- ផ្នែកខាងក្នុង(តួសំបុត្រ)

ក្បាលសំបុត្រ៖

- ទីន្លែង ចុះកាលបរិច្ឆេទនៃការសរសេរ ...
- ចំណាងជើងសំបុត្រ ...។

តួសំបុត្រ៖

- សម្ដែងសេចក្ដីសោកស្ដាយ ...
- រៀបរាប់រឿងរ៉ាវផ្សេងៗ ដែលខ្លួនបានប្រព្រឹត្តិខុស និងប្រាប់ពីមូលហេតុដែលនាំឱ្យខ្លួនប្រព្រឹត្តអំពើនោះ ... ។

ការបញ្ចប់សំបុត្រ

- ជូនពរ (ត្រូវប្រើពាក្យឱ្យសមស្របតាមកាលៈទេសៈ)
- ជូនកាលអាចភ្ជាប់ឃ្លាបញ្ចប់សេចក្ដីដូចជា ពីកូនរបស់ម៉ែ ពីមិត្តអមតៈ ពីមិត្តជាទីរាប់អាន...
- ចុងក្រោយចុះហត្ថលេខា និង ចុះឈ្មោះអ្នកសរសេរ... ។

# ៩- តែងសេចក្តីបែបអត្ថាធិប្បាយពន្យល់

តែងសេចក្តីអត្ថាធិប្បាយពន្យល់ជាប្រធានតម្រូវឱ្យអ្នកសិក្សា ឬអ្នកសរសេរបកស្រាយ ពន្យល់ ណែនាំ បង្ហាញភ្ជាប់ជាមួយនឹងភស្តុតាង អំណះអំណាងច្បាស់លាស់ ធ្វើយ៉ាងណាឱ្យគេយល់ស្របតាមចំណោទរបស់ប្រធានដែលចោទឡើង។ ប្រធានតែងសេចក្តីប្រភេទនេះ តម្រូវឱ្យអ្នកសរសេរប្រមែប្រមូលពុទ្ធិរបស់ខ្លួនទាំងក្នុងសង្គមជាក់ស្តែង ទាំងក្នុងការសិក្សា មកពន្យល់បង្ហាញ លាតត្រដាងទៅតាមគំនិត បញ្ហា ឬទស្សនៈរបស់ប្រធានដែលចោទឡើង។ ប្រធានតែងសេចក្តីបែបអត្ថាធិប្បាយពន្យល់ ច្រើនតែមានលក្ខណៈជឿនលឿន សកម្មរួចជាស្រេចទៅហើយ ដោយពុំសូវមានមតិយោបល់ណាមួយមកជំទាស់នឹងអត្ថន័យ ឬទស្សនៈដើមបានឡើយ។

ប្រធានតែងសេចក្តីបែបអត្ថាធិប្បាយពន្យល់មាន៖

- ពន្យល់ទស្សនៈ គំនិត ពំនោល មតិ ...
- ពន្យល់ពាក្យស្លោក ពាក្យអប់រំ សុភាសិត
- ពន្យល់បែបអក្សរសិល្ប៍។

## ៩.១- តែងសេចក្តីបែបអត្ថាធិប្បាយពន្យល់ទូទៅ ( ទស្សនៈ គំនិត ពំនោល មតិ... )

### ៩.១.១- លក្ខណៈសម្គាល់ប្រធានតែងសេចក្តីបែបអត្ថាធិប្បាយពន្យល់

ក្នុងការធ្វើតែងសេចក្តី ជាដំបូងអ្នកធ្វើចាំបាច់ត្រូវដឹងថាជាប្រធានបែបណា? តែងសេចក្តីបែបអត្ថាធិប្បាយពន្យល់មានលក្ខណៈសម្គាល់មួយចំនួនដូចតទៅ៖

- **ឃ្លាបញ្ចេញយោបល់** (ឃ្លាខាងដើមនៃប្រធាន)

  *ឧទាហរណ៍៖*

  - សុភាសិតមួយចែងថា «...»
  - មុនស្លាប់តាចឹមផ្តាំកូនថា «...»
  - ពាក្យស្លោកមួយបានចែងថា «...»
  - ក្នុងរឿងកុលាបប៉ៃលិនបញ្ជាក់ថា «...»
  - អ្នកប្រាជ្ញជនជាតិបារាំងម្នាក់ពោលទុកថា «...»។ល។

- **ឃ្លាចោទសួរ**

  *ឧទាហរណ៍៖*

  - តើសុភាសិតនេះមានអត្ថន័យយ៉ាងណា?
  - តើពំនោលនេះមានខ្លឹមសារដូចម្តេចដែរ?
  - តើ... មានអត្ថន័យបែបណាដែរ?
  - តើប្រធាននេះ អប់រំយើងដូចម្តេចខ្លះ?

- **ឃ្លាបង្គាប់បញ្ជា**

  *ឧទាហរណ៍៖*

  - ចូរពន្យល់ ដោយលើកឧទាហរណ៍មកបញ្ជាក់។
  - ចូរបកស្រាយ...។
  - ចូរស្រាយបំភ្លឺ...ដោយលើកភស្តុតាងមកបញ្ជាក់ឱ្យបានច្បាស់លាស់។

- ចូរបង្ហាញឱ្យឃើញ... ។
- ចូរបញ្ជាក់... ។

## ៩.១.២- គម្រោងទូទៅប្រធានតែងសេចក្តីបែបអត្ថាធិប្បាយពន្យល់

### គម្រោងតែង

**ក- សេចក្តីផ្តើម**

- **លំនាំបញ្ហា:** ជាខ្លឹមសារ គំនិត យោបល់ដែលជាលំនាំដើម ឬជាស្ថានភាពដើមមានន័យផ្សារភ្ជាប់ទៅនឹងគំនិត ឬខ្លឹមសាររបស់ប្រធាន។
- **ចំណូលបញ្ហា (បង្ហាញបញ្ហា)**: ជាបញ្ហារបស់ប្រធាន ដែលត្រូវបញ្ចូលផ្សារភ្ជាប់នឹងខ្លឹមសារគំនិតដែលចងក្រងបានក្នុងលំនាំបញ្ហា។
- **ចំណោទបញ្ហា:** ក្រោយពីផ្សារភ្ជាប់គ្នារវាងខ្លឹមសារក្នុងលំនាំបញ្ហា និងបញ្ហារបស់ប្រធានក្នុងចំណូលបញ្ហារួចហើយ ត្រូវចោទជាបញ្ហាដែលបានជាទឡ្ហីករណ៍សម្រាប់ការបកស្រាយពន្យល់ក្នុងតួសេចក្តី។

➢ **ចំណុចគួរចៀសវាង:** ក្នុងចំណោទបញ្ហានេះ អ្នកធ្វើតែងសេចក្តីចៀសវាងការចោទសួរប្រាសមកវិញ នាំឱ្យចាកប្រធាន ឬប្រើពាក្យបង្គាប់បញ្ហាឡើយ។ *ឧទាហរណ៍៖*
  - ✓ តើអ្នកយល់យ៉ាងណា? ចូរស្រាយបំភ្លឺ ដោយលើកឧទាហរណ៍បញ្ជាក់។
  - ✓ តើអ្នកយល់ដូចម្តេចខ្លះ? ចូរបកស្រាយ។
  - ✓ តើប្រធានមានន័យខ្លឹមសារយ៉ាងណា? ចូរពន្យល់។ល។

**ខ- តួសេចក្តី**

- **ឃ្លាភ្ជាប់សេចក្តី:** ឃ្លាសម្រាប់ជាកិច្ចចាប់ផ្តើម ដើម្បីភ្ជាប់ពីសេចក្តីផ្តើមទៅនឹងការពន្យល់ពាក្យគន្លឹះ ឬកន្សោមពាក្យគន្លឹះរបស់ប្រធាន។
- **ពន្យល់ពាក្យគន្លឹះ**: ក្នុងចំណុចនេះ អ្នកធ្វើតែងសេចក្តីត្រូវស្រង់យកពាក្យគន្លឹះ កន្សោម ឬឃ្លាដែលជាគន្លឹះនៃប្រធាន មកពន្យល់បង្ហាញដោយមិនប្រើគូសត្រេ ឬប្រាប់ថ្នាក់ពាក្យដូចពន្យល់ពាក្យធម្មតាក្នុងវចនានុក្រមទាំងស្រុងនោះទេ ហើយករណីខ្លះក៏មិនត្រូវពន្យល់តាមន័យធម្មតាដូចក្នុងវចនានុក្រមទាំងស្រុងនោះដែរ គឺអាស្រ័យនឹងបរិបទនៃប្រធាន។
- **ពន្យល់ន័យប្រធាន:** ជាការបញ្ចូលគ្នាឡើងវិញនូវន័យរបស់ពាក្យគន្លឹះ ឬកន្សោមពាក្យតាមន័យប្រធានខាងលើឱ្យបានសមរម្យ។
- **បកស្រាយប្រធាន:** ចំណុចនេះអ្នកធ្វើតែងសេចក្តីត្រូវស្រាយបំភ្លឺទៅតាមចំណោទរបស់ប្រធាន ឬបំណងរបស់ប្រធានចង់ដឹង ដោយភ្ជាប់នឹងអំណះអំណាង ឬឧទាហរណ៍បញ្ជាក់ច្បាស់លាស់។
- **សរុប:** ជាការសង្ខេប ឬប្រមូលបញ្ចូលគ្នានូវគំនិត ដែលបានស្រាយបំភ្លឺរួចហើយ ដើម្បីគាំទ្រគំនិត ទស្សនៈរបស់ប្រធានឱ្យកាន់តែប្រាកដឡើង។

**គ- សេចក្ដីបញ្ចប់**

- **វាយតម្លៃប្រធាន:** ជាការបញ្ជាក់ម្ដងទៀតទៅលើអត្ថន័យ និងតម្លៃរបស់ប្រធានថា មានន័យ មានប្រយោជន៍ទៅតាមគោលបំណងរបស់ប្រធាន។
- **យោបល់ផ្ទាល់ខ្លួន:** ជាចំណាប់អារម្មណ៍ផ្ទាល់ខ្លួន របស់អ្នកសរសេរតែងសេចក្ដី ចំពោះប្រធានដែលចោទឡើងខាងលើ និងយោបល់ផ្ទាល់ខ្លួនតាមរយៈបទពិសោធ ឬគោលគំនិតរបស់ប្រធាន។

# ១០- តែងសេចក្ដីបែបអត្ថាធិប្បាយពន្យល់សុភាសិត

## ១០.១- និយមន័យ : អ្វីហៅថាសុភាសិត?

សុភាសិត គឺកម្រងពាក្យដែលអ្នកប្រាជ្ញ កវី បណ្ឌិត បុព្វបុរស បានចងក្រងឡើងដោយប្រមូលយកអត្ថន័យ អត្ថរូប និងអត្ថរសដ៏ទូលំទូលាយល្អៗ បង្កប់ទុកក្នុងពាក្យទាំងនោះ។ បើពោលតាមរយៈសព្ទនិយមថា គឺជាពាក្យល្អ ការពោលត្រឹមត្រូវ សម្ដីមានខ្លឹមសារ វាចាផ្អែមល្ហែម វាចាពីរោះគួរឱ្យជាប់ចិត្ត ដំបូន្មានដ៏ល្អ គឺសម្ដីខ្លីៗតែមានសម្ផស្សបរិបូណ៌គួរឱ្យចាប់ចិត្ត។ សុភាសិត គឺជាដំបូន្មាន ជាកំណត់ចំណាំរបស់អ្នកប្រាជ្ញ កវី បណ្ឌិត បុព្វបុរស បញ្ញវន្ត ដែលបានសិក្សាស្រាវជ្រាវ ពិនិត្យ ពិចារណាកត់សម្គាល់នូវហេតុការណ៍ផ្សេងៗក្នុងជីវភាពក្នុងសង្គមនាសម័យកាលដែលខ្លួនរស់នៅ ទុកជាគ្រឿងសម្គាល់ ជាប្រដាប់សម្រាប់ចំណាំចរិតលក្ខណៈចរិយារបស់មនុស្សនេះឯង។ កំណត់ចំណាំបែបនេះ ជាបំណងរបស់បុព្វបុរសដែលចង់ទុកឱ្យជនន្នានុជនយកមកធ្វើជាឧបករណ៍ឆ្លុះបញ្ចាំងពីបទពិសោធនៃការរស់នៅក្នុងជីវភាពសង្គមមនុស្សតៗមក ដើម្បីបានស្គាល់ និងយល់ហេតុការណ៍ផ្សេងៗ។ បទពិសោធទាំងនោះជួយឱ្យបានជាទុនក្នុងការពិចារណាថា គួរយកមកអនុវត្តតាម ឬគួរចៀសវាង ដើម្បីរស់នៅប្រកបដោយសុភមង្គល។

ទោះបីសុភាសិតមិនមានតម្លៃគ្រប់សម័យកាល គ្រប់ពេលវេលា និងគ្រប់បុគ្គល ឬមនុស្សទូទៅឬគ្រប់ហេតុការណ៍ក៏ដោយក៏ ជាពន្លឺមួយសម្រាប់ឱ្យអ្នកសិក្សាយកទៅធ្វើជាគ្រឿងត្រិះរិះពិចារណា ដើម្បីស្វែងរកអ្វីដែលជាការត្រឹមត្រូវ សមហេតុផលនោះដែរ។ យ៉ាងណាមិញសុភាសិតខ្លះស្របនឹងកាលៈទេសៈ ការអនុវត្តក្នុងជីវិត ចិត្តគំនិតរបស់សង្គមមនុស្សក្នុងសម័យមុន តែដល់មកសម័យនេះគឺមិនសូវសមស្រប។

## ១០.២- ន័យនៃសុភាសិត

តាមបែបទូទៅ សុភាសិតតែងមានន័យពីរយ៉ាងដែលច្បាស់លាស់គឺ៖

- ន័យជាអត្ថានុរូប (ន័យត្រង់) ន័យបែបនេះខ្មែរយើងហៅថាន័យផ្ទាល់ ព្រោះជាដំបូន្មាន ការអប់រំ ឬពំនោលជាបែបផ្ទាល់ត្រង់ៗតែម្ដងដូចឃ្លាថា "ចេះពីរៀន មានពីរក" ឬ "កុំធ្វើស្រែប្រវាស់ កុំសង់ផ្ទះចូលគ្នា" ឬក៏ "ធ្វើស្រែនឹងទឹក ធ្វើសឹកនឹងបាយ" ជាដើម។
- ន័យជាអត្ថបដិរូប(ន័យធៀប) ន័យបែបនេះខ្មែរយើងហៅថាន័យប្រយោល ព្រោះចាស់បុរាណ បញ្ញវន្ត កវី បណ្ឌិត អ្នកប្រាជ្ញខ្មែរយើងបានទូន្មានអប់រំកូនចៅដោយប្រើវិធីប្រយោល ដោយការប្រៀបធៀប ដូចពាក្យចាស់បានពោលថា "ឱនដាក់គ្រាប់ ងើយស្កក" ឬ "សាច់មិនបានស៊ីយកឆ្អឹងព្យួរក" ឬក៏ "ទំពក់ទៅទើបញ្ចៀវាមក" ជាដើម។

## ១០.៣- លក្ខណៈរបស់សុភាសិត

សុភាសិតទាំងអស់ ពិសេសគឺសុភាសិតខ្មែរយើងនេះឯងតែងមានលក្ខណៈ៣យ៉ាងគឺៈ

- **សុភាសិតមានន័យជាអត្ថបដិរូប (ន័យធៀប) សុទ្ធ:** សុភាសិតប្រភេទនេះ ចែកចេញជាពីរគឺៈ
  - សុភាសិតបែបន័យធៀបសុទ្ធខ្លះ អាចមានមួយឃ្លា ឬពីរឃ្លា ហើយដែលឃ្លានីមួយៗសុទ្ធតែមានន័យជាអត្ថបដិរូប (ន័យធៀប) ទាំងអស់។ *ឧទាហរណ៍:* "កុំអង្គុយលើឈើពុក" "កុំយកកទៅលអន្ទាក់" "ខិនដាក់គ្រាប់ ដើយស្អក" "ទូកទៅ កំពង់នៅ" ជាដើម។ ការធ្វើអត្ថាធិប្បាយពន្យល់សុភាសិតប្រភេទនេះ ត្រូវពន្យល់ន័យជាអត្ថានុរូប (ន័យត្រង់ )តាមន័យដើមរបស់ឃ្លានីមួយៗនៃសុភាសិតផង និងត្រូវពន្យល់ន័យជាអត្ថបដិរូប (ន័យធៀប) របស់ឃ្លានីមួយៗនៃសុភាសិតផង។
  - សុភាសិតបែបន័យធៀបសុទ្ធខ្លះទៀត ក៏អាចមានមួយឃ្លា ឬពីរឃ្លា ហើយដែលឃ្លានីមួយៗសុទ្ធតែមានន័យជាអត្ថបដិរូប (ន័យធៀប) ទាំងអស់ដែរ។ *ឧទាហរណ៍:* "ទឹកត្រជាក់ត្រីកុំ" "ត្រីងៀតឆ្លៀតពង" "កុំហែកទ្រូងឱ្យក្អែកចឹក" ជាដើម។ ការធ្វើអត្ថាធិប្បាយពន្យល់សុភាសិតប្រភេទនេះ មិនទាមទារឱ្យពន្យល់ន័យជាអត្ថានុរូប (ន័យត្រង់) តាមន័យដើមរបស់ឃ្លានីមួយៗនៃសុភាសិតនោះទេ ពោលគឺត្រូវពន្យល់តែន័យជាអត្ថបដិរូប (ន័យធៀប) របស់ឃ្លានីមួយៗនៃសុភាសិតផងប៉ុណ្ណោះ។
- **សុភាសិតមានន័យជាអត្ថបដិរូប (ន័យធៀប) ផង និងន័យជាអត្ថានុរូប (ន័យត្រង់) ផង:** ជាទូទៅ យើងច្រើនសង្កេតឃើញសុភាសិតប្រភេទនេះមានពីរឃ្លា ដែលឃ្លាទីមួយនៃសុភាសិតមានន័យជាអត្ថបដិរូប (ន័យធៀប)។ ចំណែកឃ្លាទីពីរមានន័យជាអត្ថានុរូប (ន័យត្រង់) ស្របគ្នានឹងអត្ថន័យរបស់ឃ្លាទីមួយ។ *ឧទាហរណ៍:* «កុំពត់ស្រឡៅ កុំប្រដៅមនុស្សខូច» «ក្របីបាត់ទើបធ្វើរបងជិតប្រឡងទើបខំរៀន» «ដំដែកទាន់នៅក្តៅ ប្រដៅមនុស្សទាន់នៅក្មេង»...។ ការធ្វើអត្ថាធិប្បាយសុភាសិតប្រភេទនេះ ត្រូវពន្យល់ន័យជាអត្ថានុរូប (ន័យត្រង់) សម្រាប់ឃ្លាទីមួយនៃសុភាសិត និងយកឃ្លាទីពីរនៃសុភាសិតមកពន្យល់ធ្វើជាន័យអត្ថបដិរូប (ន័យធៀប) របស់ឃ្លាទីមួយតែម្តង។
- **សុភាសិតមានន័យជាអត្ថានុរូប (ន័យត្រង់) សុទ្ធ:** សុភាសិតប្រភេទនេះ យើងច្រើនសង្កេតឃើញមានពីរឃ្លា ហើយឃ្លាទាំងពីរសុទ្ធតែមានន័យជាអត្ថានុរូប (ន័យត្រង់) ទាំងអស់។ *ឧទាហរណ៍:* "ធ្វើស្រែនឹងទឹក ធ្វើសឹកនឹងបាយ" "កុំធ្វើស្រែប្រវាស់ កុំសង់ផ្ទះចូលគ្នា" ជាដើម។ ក្នុងការធ្វើអត្ថាធិប្បាយពន្យល់សុភាសិតប្រភេទនេះ ទាមទារឱ្យពន្យល់តែន័យជាអត្ថានុរូប (ន័យត្រង់) គ្រប់ឃ្លាទាំងអស់។

## ១០.៤- គម្រោងតែងសេចក្តីបែបអត្ថាធិប្បាយពន្យល់សុភាសិត

### ក- សេចក្តីផ្តើម

- **លំនាំបញ្ហា:** ជាខ្លឹមសារ គំនិត យោបល់ដែលជាលំនាំដើម ឬជាស្ថានភាពដើមមានន័យផ្សារភ្ជាប់ទៅនឹងគំនិត ឬខ្លឹមសាររបស់ប្រធាន។
- **ចំណូលបញ្ហា (បង្ហាញបញ្ហា):** ជាបញ្ហារបស់ប្រធាន ដែលត្រូវបញ្ចូលផ្សារភ្ជាប់នឹងខ្លឹមសារគំនិតដែលចង ក្រងបានក្នុងលំនាំបញ្ហា។ ចំណុចនេះត្រូវលើកយកបញ្ហារបស់ប្រធានមកសរសេរតែម្តង។ ចំណុចគន្លឹះសំខាន់ៗ ដែលគប្បីយកមកសរសេរនៅក្នុងនេះមានដូចជា ហេតុដូច្នេះហើយទើបមានសុភាសិតមួយពោលថា "..." ។

- **ចំណោទបញ្ហា:** ក្រោយពីផ្សារភ្ជាប់គ្នារវាងខ្លឹមសារក្នុងលំនាំបញ្ហា និងបញ្ហារបស់ប្រធានក្នុងចំណូលបញ្ហារួចហើយត្រូវចោទប្រធានជាបញ្ហា ដើម្បីបានជាទឡ្ហីករណ៍សម្រាប់ការ បកស្រាយ ពន្យល់ក្នុងតួសេចក្តី។ ការចោទតាមបែបប្រធានពន្យល់គឺ ការចោទសួរទៅលើអត្ថន័យរបស់ប្រធាន: តើសុភាសិតនេះមានអត្ថន័យដូចម្តេច? ឬតើប្រធានខាងលើមានអត្ថន័យយ៉ាងណា?
  - ➢ **ចំណុចគួរចៀសវាង:** ក្នុងចំណោទបញ្ហានេះ អ្នកធ្វើតែងសេចក្តីចៀសវាងការចោទសួរច្រាសមកវិញនាំឱ្យចាកប្រធាន ឬប្រើពាក្យបង្គាប់បញ្ជាឡើយ។ *ឧទាហរណ៍៖*
    - ✓ តើអ្នកយល់យ៉ាងណា? ចូរស្រាយបំភ្លឺ ដោយលើកឧទាហរណ៍បញ្ជាក់ ឬផ្តល់អំណះអំណាងឱ្យបានច្បាស់លាស់។
    - ✓ តើអ្នកយល់ដូចម្តេច? ចូរបកស្រាយ។
    - ✓ តើប្រធានមានន័យខ្លឹមសារយ៉ាងណា? ចូរពន្យល់។ល។

## ខ- តួសេចក្តី

- **ឃ្លាភ្ជាប់សេចក្តី:** ឃ្លាសម្រាប់ជាកិច្ចចាប់ផ្តើម ដើម្បីភ្ជាប់ពីសេចក្តីផ្តើមទៅនឹងការពន្យល់ពាក្យគន្លឹះ ឬកន្សោមពាក្យគន្លឹះក្នុងប្រធាន។
- **ពន្យល់ពាក្យគន្លឹះ:** ក្នុងចំណុចនេះ អ្នកធ្វើតែងសេចក្តីត្រូវស្រង់យកពាក្យគន្លឹះ កន្សោមពាក្យគន្លឹះ ឬឃ្លាដែលជាគន្លឹះនៃប្រធានមកពន្យល់បង្ហាញ ដោយមិនប្រើគូសគ្រេ ឬប្រាប់ថ្នាក់ពាក្យដូចពន្យល់ពាក្យធម្មតាក្នុងវចនានុក្រមទាំងស្រុងនោះទេ ហើយករណីខ្លះក៏មិនត្រូវពន្យល់តាមន័យធម្មតាដូចក្នុងវចនានុក្រមទាំងស្រុងនោះដែរ គឺអាស្រ័យនឹងបរិបទនៃប្រធាន។
- **ពន្យល់ន័យប្រធាន:** ជាការបញ្ចូលគ្នាឡើងវិញនូវន័យរបស់ពាក្យ ឬកន្សោមពាក្យគន្លឹះតាមន័យប្រធានខាងលើឱ្យបានសមស្រប។
- **បកស្រាយប្រធាន:** ចំណុចនេះ អ្នកធ្វើតែងសេចក្តីត្រូវស្រាយបំភ្លឺ ទៅតាមចំណោទរបស់ប្រធាន ឬគោលបំណងរបស់ប្រធានចង់ដឹងដោយភ្ជាប់ជាមួយនឹងអំណះអំណាងឬឧទាហរណ៍បញ្ជាក់ឱ្យបានច្បាស់លាស់។ ការបកស្រាយអត្ថន័យរបស់ប្រធានចែកចេញជាពីរផ្នែក៖
  - ✓ បកស្រាយន័យអត្ថានុរូប (ន័យត្រង់): អ្នកធ្វើតែងសេចក្តីត្រូវបកស្រាយពីខ្លឹមសារត្រង់ៗរបស់ប្រធានដែលបានលើកមកនិយាយតែម្តង ដោយភ្ជាប់នឹងអំណះអំណាង ឬឧទាហរណ៍បញ្ជាក់។
  - ✓ បកស្រាយន័យអត្ថបដិរូប (ន័យធៀប): ចំណុចនេះ អ្នកធ្វើតែងសេចក្តីត្រូវស្រាយបំភ្លឺពីន័យបង្កប់ ឬន័យប្រៀបប្រដូចរបស់ប្រធាន ដោយភ្ជាប់នឹងអំណះអំណាងឬឧទាហរណ៍បញ្ជាក់ឱ្យបានច្បាស់លាស់។
- **សរុប:** ជាការសង្ខេប ឬប្រមូលបញ្ចូលគ្នានូវគំនិត ដែលបានស្រាយបំភ្លឺរួចហើយ ដើម្បីគាំទ្រ គំនិត ទស្សនៈរបស់ប្រធានឱ្យកាន់តែប្រាកដឡើង។ ការសរុបត្រូវបញ្ចូលអត្ថន័យទាំងពីរផ្នែកគឺ ន័យអត្ថានុរូប និងន័យអត្ថបដិរូប។

**គ- សេចក្ដីបញ្ចប់**

- **វាយតម្លៃប្រធាន:** ជាការបញ្ជាក់ម្ដងទៀតទៅលើអត្ថន័យ និងឱ្យតម្លៃរបស់ប្រធានថា មានន័យ មានប្រយោជន៍ទៅតាមគោលបំណងរបស់ប្រធាន។
- **យោបល់ផ្ទាល់ខ្លួន:** ជាចំណាប់អារម្មណ៍ផ្ទាល់ខ្លួនរបស់អ្នកសរសេរតែងសេចក្ដី ចំពោះប្រធានដែលចោទឡើងខាងលើ និងយោបល់ផ្ទាល់ខ្លួនតាមរយៈបទពិសោធ ឬគោលគំនិតរបស់ប្រធាន។

# ១១- តែងសេចក្ដីបែបអត្ថាធិប្បាយពន្យល់អក្សរសិល្ប៍

## ១១.១- ប្រធានតែងសេចក្ដីបែបអត្ថាធិប្បាយពន្យល់អក្សរសិល្ប៍

តែងសេចក្ដីបែបអត្ថាធិប្បាយពន្យល់អក្សរសិល្ប៍ គឺតម្រូវឱ្យលើកយកបញ្ហាក្នុងអក្សរសិល្ប៍មកចោទ ដើម្បីធ្វើការបកស្រាយទៅតាមខ្លឹមសាររឿងនីមួយៗ។ គម្រោង និងលំនាំនៃការបកស្រាយមានលក្ខណៈប្រហាក់ប្រហែលនឹងតែងសេចក្ដីអត្ថាធិប្បាយពន្យល់ទូទៅដែរ។ ការបកស្រាយត្រូវផ្អែកទៅតាមសាច់រឿង និងមានអំណះអំណាងពីក្នុងសាច់រឿងច្បាស់លាស់។

## ១១.២- លក្ខណៈសម្គាល់ប្រធានតែងសេចក្ដីបែបអត្ថាធិប្បាយពន្យល់អក្សរសិល្ប៍

ក្នុងការធ្វើតែងសេចក្ដី ជាដំបូងអ្នកធ្វើចាំបាច់ត្រូវដឹងថាជាប្រធានបែបណា? តែងសេចក្ដីបែបអត្ថាធិប្បាយពន្យល់អក្សរសិល្ប៍មានលក្ខណៈសម្គាល់មួយចំនួនដូចតទៅ៖

- **ឃ្លាបញ្ចេញយោបល់** (ឃ្លាខាងដើមនៃប្រធាន) *ឧទាហរណ៍៖*
  - «ភាពជោគជ័យក្នុងជីវិតរបស់តួអង្គចៅចិត្រ កើតឡើងពីសមត្ថភាពផ្ទាល់ខ្លួន»។...។
  - មុនស្លាប់តាចឹមផ្ដាំកូនថា «អត្តាហិ អត្តនោ នាថោ»។...។
  - រឿងផ្កាស្រពោនរបស់អ្នកនិពន្ធ នូ ហាច បានបង្ហាញឱ្យឃើញពី: «អន្តរាយ បណ្ដាលមកពីជំនឿមិនសមហេតុផល»។...។
  - ក្នុងអក្សរសិល្ប៍ខ្មែររឿងមាលាដួងចិត្ត គេនិយាយថា «ទីឃាវុធ ជាមន្ត្រីស្មោះត្រង់»។...។
  - ពំនោលមួយពោលថា «ការស្រឡាញ់ឧត្ដមគតិតួអង្គទីឃាវុធ គឺជាការលះបង់»។...។
  - ទស្សនៈមួយថា «ធនញ្ជ័យ ជាតួអង្គដែលមានឧត្ដមគតិស្នេហាជាតិ»។...។ល។

- **ឃ្លាចោទសួរ:** *ឧទាហរណ៍៖*
  - តើប្រធាននេះមានអត្ថន័យយ៉ាងណា?
  - តើពំនោលនេះមានខ្លឹមសារដូចម្ដេច?
  - តើ... មានអត្ថន័យបែបណា?
  - តើប្រធាននេះ អប់រំយើងដូចម្ដេចខ្លះ?

- **ឃ្លាបង្គាប់បញ្ជា:** *ឧទាហរណ៍៖*
  - ចូរពន្យល់ដោយលើកឧទាហរណ៍មកបញ្ជាក់។
  - ចូរបកស្រាយពំនោលខាងលើឱ្យបានក្បោះក្បាយ ដោយលើកឧទាហរណ៍ក្នុងកុលាបប៉ៃលិនមកបញ្ជាក់។
  - ចូរស្រាយបំភ្លឺ...ដោយលើកឧទាហរណ៍ក្នុងអក្សរសិល្ប៍ខ្មែរមកបញ្ជាក់ឱ្យបានច្បាស់លាស់។

- ចូរពន្យល់គំនិតខាងលើ ដោយបញ្ជាក់ពីតម្លៃអប់រំនៃអត្ថបទប្រលោមលោកនេះ។
- ចូរបង្ហាញ...ឱ្យបានក្បោះក្បាយ។
- ចូរបកស្រាយទស្សនៈខាងលើឱ្យបានក្បោះក្បាយ ដោយឧទាហរណ៍ក្នុងអក្សរសិល្ប៍រឿង ធនញ្ជ័យមកបញ្ជាក់។
- ចូរបង្ហាញដោយលើកអំណះអំណាងមកបញ្ជាក់។

## ១១.៣- គម្រោងទូទៅប្រធានតែងសេចក្តីបែបអត្ថាធិប្បាយពន្យល់អក្សរសិល្ប៍

# គម្រោងតែង

### ក- សេចក្តីផ្តើម

- **លំនាំបញ្ហា:** ជាខ្លឹមសារ គំនិត យោបល់ដែលជាលំនាំដើម ឬជាស្ថានភាពដើមមានន័យផ្សារភ្ជាប់ទៅនឹងគំនិត ឬខ្លឹមសាររបស់ប្រធាន។
- **ចំណូលបញ្ហា (បង្ហាញបញ្ហា):** ជាបញ្ហារបស់ប្រធាន ដែលត្រូវបញ្ចូលផ្សារភ្ជាប់នឹងខ្លឹមសារគំនិតដែលចងក្រងបានក្នុងលំនាំបញ្ហា។
- **ចំណោទបញ្ហា:** ក្រោយពីផ្សារភ្ជាប់គ្នារវាងខ្លឹមសារក្នុងលំនាំបញ្ហា និងបញ្ហារបស់ប្រធានក្នុងចំណូលបញ្ហារួចហើយ ត្រូវចោទប្រធានជាបញ្ហា ដើម្បីបានជាទឡ្ហីករណ៍សម្រាប់ការបកស្រាយពន្យល់ក្នុងតួសេចក្តី។
  - ➢ **ចំណុចគួរចៀសវាង:** ក្នុងចំណោទបញ្ហានេះ អ្នកធ្វើតែងសេចក្តីចៀសវាងការចោទសួរប្រាសមកវិញ នាំឱ្យចាកប្រធាន ឬប្រើពាក្យបង្គាប់បញ្ហាឡើយ។ *ឧទាហរណ៍៖*
    - ✓ តើអ្នកយល់យ៉ាងណា? ចូរស្រាយបំភ្លឺ ដោយលើកឧទាហរណ៍បញ្ជាក់។
    - ✓ តើអ្នកយល់ដូចម្តេច? ចូរបកស្រាយ។
    - ✓ តើប្រធានមានន័យខ្លឹមសារយ៉ាងណា? ចូរពន្យល់។ល។

### ខ- តួសេចក្តី

- **ឃ្លាភ្ជាប់សេចក្តី:** ឃ្លាសម្រាប់ជាកិច្ចចាប់ផ្តើម ដើម្បីភ្ជាប់ពីសេចក្តីផ្តើមទៅនឹងការពន្យល់ពាក្យគន្លឹះ ឬកន្សោមពាក្យគន្លឹះរបស់ប្រធាន។
- **ពន្យល់ពាក្យគន្លឹះ:** ក្នុងចំណុចនេះ អ្នកធ្វើតែងសេចក្តីត្រូវស្រង់យកពាក្យគន្លឹះ កន្សោម ឬឃ្លាដែលជាគន្លឹះរបស់ប្រធាន មកពន្យល់បង្ហាញដោយមិនប្រើគូសគ្រេ ឬប្រាប់ថ្នាក់ពាក្យដូចពន្យល់ពាក្យធម្មតាក្នុងវចនានុក្រមទាំងស្រុងនោះទេ ហើយករណីខ្លះក៏មិនត្រូវពន្យល់តាមន័យធម្មតាដូចក្នុងវចនានុក្រមទាំងស្រុងនោះដែរ គឺអាស្រ័យនឹងបរិបទនៃប្រធាន។
- **ពន្យល់ន័យប្រធាន:** ជាការបញ្ចូលគ្នាឡើងវិញនូវន័យរបស់ពាក្យគន្លឹះ ឬកន្សោមពាក្យតាមន័យប្រធានខាងលើឱ្យបានសមរម្យ។
- **បកស្រាយប្រធាន:** ចំណុចនេះអ្នកធ្វើតែងសេចក្តីត្រូវស្រាយបំភ្លឺទៅតាមចំណោទរបស់ប្រធាន ឬបំណងរបស់ប្រធានចង់ដឹង ដោយភ្ជាប់នឹងអំណះអំណាង ឬឧទាហរណ៍បញ្ជាក់ឱ្យបានច្បាស់លាស់។

- **សរុប:** ជាការសង្ខេប ឬប្រមូលបញ្ចូលគ្នានូវគំនិត ដែលបានស្រាយបំភ្លឺរួចហើយ ដើម្បីគាំទ្រ គំនិត ទស្សនៈរបស់ប្រធានឱ្យកាន់តែប្រាកដឡើង។

**គ- សេចក្តីបញ្ចប់**

- **វាយតម្លៃប្រធាន:** ជាការបញ្ជាក់ម្តងទៀតទៅលើអត្ថន័យនិងតម្លៃរបស់ប្រធានថា មានន័យ មានប្រយោជន៍ទៅតាមគោលបំណងរបស់ប្រធាន។
- **យោបល់ផ្ទាល់ខ្លួ:** ជាចំណាប់អារម្មណ៍ផ្ទាល់ខ្លួនរបស់អ្នកសរសេរតែងសេចក្តី ចំពោះប្រធានដែលចោទឡើងខាងលើ និងយោបល់ផ្ទាល់ខ្លួនតាមរយៈបទពិសោធ ឬគោលគំនិតរបស់ប្រធាន។

# ១២- តែងសេចក្តីបែបអត្ថាធិប្បាយប្រៀបធៀប

អត្ថាធិប្បាយប្រៀបធៀប គឺជាប្រភេទតែងសេចក្តីអត្ថាធិប្បាយមួយ តម្រូវឱ្យអ្នកធ្វើតែងសេចក្តី ខិតខំរកចំណុចដូចគ្នា និងចំណុចខុសគ្នា រួចវាយតម្លៃរួមលើការប្រៀបធៀបនោះ។ ប្រធានបែបអត្ថាធិប្បាយប្រៀបធៀប គេអាចឱ្យធ្វើការប្រៀបធៀបរវាងមតិមួយទៅនឹងមតិមួយទៀត រវាងតួអង្គ និងតួអង្គ រវាងស្នាដៃមួយទៅនឹងស្នាដៃមួយទៀត។ល។ ប្រធានបែបអត្ថាធិប្បាយប្រៀបធៀប គេអាចឱ្យអ្នកសរសេរធ្វើការប្រៀបធៀប មនុស្ស សត្វ ទីកន្លែង វត្ថុ ធម្មជាតិ សកម្មភាព ព្រឹត្តិការណ៍ មតិ យោបល់ ទស្សនៈ តួអង្គក្នុងរឿង ស្នាដៃអក្សរសិល្ប៍ជាដើម ដែលមានលក្ខណៈចាប់ពីងាយស្រួលរហូតដល់ស៊ីជម្រៅ។

## ១២.១- លក្ខណៈសម្គាល់ប្រធានតែងសេចក្តីបែបអត្ថាធិប្បាយប្រៀបធៀប

ប្រធានតែងសេចក្តីបែបអត្ថាធិប្បាយប្រៀបធៀប យើងអាចសម្គាល់តាមរយៈលក្ខណៈមួយចំនួនដូចខាងក្រោម៖

- **ឃ្លាបញ្ចេញយោបល់** (ឃ្លាខាងដើមនៃប្រធាន): *ឧទាហរណ៍៖*
  - អ្នកខ្លះថា «តួអង្គ... មានលក្ខណសម្បត្តិល្អជាងតួអង្គ ...»
  - មតិមួយលើកឡើងថា «...» មតិមួយទៀតលើកឡើងថា «...»
  - មតិមួយចំនួនលើកឡើងថា «... »។ល។
- **ឃ្លាចោទសួ:** *ឧទាហរណ៍៖*
  - តើតួអង្គទាំងពីរនេះ តួអង្គណាមានលក្ខណសម្បត្តិល្អជាង?
  - តើមតិទាំងពីរនេះដូចគ្នាចំណុចណាខ្លះ? មិនដូចគ្នាត្រង់ចំណុចណាខ្លះ?
  - តើសត្វទាំងពីរនេះមានលក្ខណៈដូចគ្នា និងខុសគ្នាត្រង់ណាខ្លះ?
- **ឃ្លាបង្គាប់បញ្ជា:** *ឧទាហរណ៍៖*
  - ចូរប្រៀបធៀបទស្សនៈទាំងពីរ ដោយលើកយកឧទាហរណ៍មកបញ្ជាក់។
  - ចូរប្រៀបធៀបលក្ខណសម្បត្តិនៃតួអង្គទាំងពីរ។
  - ចូរបង្ហាញថាតើបុគ្គលទាំងពីរនាក់នោះមួយណាល្អជាងមួយណា?

## ១២.២- គម្រោងទូទៅនៃប្រធានតែងសេចក្តីបែបអត្ថាធិប្បាយប្រៀបធៀប

### គម្រោងតែង

**ក- សេចក្តីផ្តើម**

- **លំនាំបញ្ហា:** ជាខ្លឹមសារ គំនិត យោបល់ដែលជាលំនាំដើម ឬជាស្ថានភាពដើមមានន័យផ្សារភ្ជាប់ទៅនឹងគំនិត ឬខ្លឹមសាររបស់ប្រធានប្រៀបធៀប។
- **ចំណូលបញ្ហា (បង្ហាញបញ្ហា):** ជាបញ្ហារបស់ប្រធាន ដែលត្រូវបញ្ចូលផ្សារភ្ជាប់នឹងខ្លឹមសារគំនិតដែលចងក្រងបានក្នុងលំនាំបញ្ហា។
- **ចំណោទបញ្ហា:** ក្រោយពីផ្សារភ្ជាប់គ្នារវាងខ្លឹមសារក្នុងលំនាំបញ្ហា និងបញ្ហារបស់ប្រធានក្នុងចំណូលបញ្ហារួចហើយ ត្រូវចោទប្រធានជាបញ្ហា ដើម្បីបានជាទឡ្ហីករណ៍សម្រាប់ការប្រៀបធៀបក្នុងតួសេចក្តី។
  - ➢ **ចំណុចគួរចៀសវាង:** ក្នុងចំណោទបញ្ហានេះ អ្នកធ្វើតែងសេចក្តីចៀសវាងការចោទសួរប្រាសមកវិញ នាំឱ្យចាកប្រធាន ឬប្រើពាក្យបង្គាប់បញ្ជាឡើយ។ ឧទាហរណ៍៖
    - ✓ តើអ្នកយល់ដូចម្តេច? ចូរប្រៀបធៀបមតិទាំងពីរ។
    - ✓ តើប្រធានមានន័យខ្លឹមសារយ៉ាងណា? ចូរប្រៀបធៀប។
    - ✓ ចូរអ្នកធ្វើការប្រៀបធៀបតួអង្គទាំងពីរនេះ ដោយលើកឧទាហរណ៍មកបញ្ជាក់។
    - ✓ តើអ្នកយល់ថា ទស្សនៈទាំងពីរនេះមានលក្ខណៈដូចគ្នា និងខុសគ្នាយ៉ាងណាខ្លះ?

**ខ- តួសេចក្តី**

- **ឃ្លាភ្ជាប់សេចក្តី** : ឃ្លាសម្រាប់ជាកិច្ចចាប់ផ្តើម ដើម្បីភ្ជាប់ពីសេចក្តីផ្តើម ទៅនឹងការពន្យល់ពាក្យគន្លឹះ ឬកន្សោមពាក្យគន្លឹះរបស់ប្រធាន។
- **ពន្យល់ពាក្យគន្លឹះ** : ក្នុងចំណុចនេះ អ្នកធ្វើតែងសេចក្តីត្រូវស្រង់យកពាក្យគន្លឹះ ឬកន្សោមពាក្យគន្លឹះ ឬឃ្លាដែលជាគន្លឹះនៃប្រធានមកពន្យល់បង្ហាញ ដោយមិនប្រើគូសត្រេ ឬប្រាប់ថ្នាក់ពាក្យដូចពន្យល់ ពាក្យធម្មតាក្នុងវចនានុក្រមនោះទេ ហើយក៏មិនត្រូវពន្យល់តាមន័យធម្មតាដូចក្នុងវចនានុក្រមនោះដែរ គឺអាស្រ័យនឹងបរិបទនៃប្រធាន។
- **ពន្យល់ន័យប្រធាន** : ជាការបញ្ចូលគ្នាឡើងវិញនូវន័យរបស់ពាក្យគន្លឹះ ឬកន្សោមពាក្យគន្លឹះតាមន័យប្រធានខាងលើឱ្យបានសមស្របតាមបែបប្រធានប្រៀបធៀប។
- **បកស្រាយប្រធាន** : ចំណុចនេះ អ្នកធ្វើតែងសេចក្តីត្រូវប្រៀបធៀបទៅតាមចំណោទរបស់ប្រធាន ឬបំណងរបស់ប្រធានចង់ដឹង ដោយភ្ជាប់នឹងអំណះអំណាង ឬឧទាហរណ៍បញ្ជាក់ឱ្យបានច្បាស់លាស់។
- **លក្ខណៈដូចគ្នា** : អ្នកសរសេរត្រូវបង្ហាញលក្ខណៈដូចគ្នា ឬប្រហាក់ប្រហែលគ្នាត្រង់ចំណុចណាខ្លះទៅតាមចំណោទរបស់ប្រធាន។
- **លក្ខណៈខុសគ្នា** : អ្នកសរសេរត្រូវបង្ហាញពីចំណុចខុសគ្នា ឬប្រឈមគ្នានៃចំណោទរបស់ប្រធានដែលបានចោទ ។

- សរុប : ជាការសរុបឡើងវិញនូវលក្ខណៈដូចគ្នា និងខុសគ្នាពីក្នុងបំណកស្រាយខាងលើ និងទាញរកចំណុចពិសេសដោយឡែក ឬទំហៀបផ្តាច់របស់ផ្នែកណាមួយ។

**គ- សេចក្តីបញ្ចប់**

- **វាយតម្លៃប្រធាន** : ជាការបញ្ជាក់ម្តងទៀតទៅលើការបកស្រាយ ការប្រៀបធៀបតាមន័យរបស់ប្រធាន និងការឱ្យតម្លៃប្រធានថា មានអត្ថន័យជ្រាលជ្រៅជាដើម។
- **យោបល់ផ្ទាល់ខ្លួន** : ជាចំណាប់អារម្មណ៍ផ្ទាល់ខ្លួនរបស់អ្នកសរសេរតែងសេចក្តី ចំពោះអង្គទំហៀប និងយោបល់ផ្ទាល់ខ្លួនតាមរយៈការប្រៀបធៀបខាងលើ។

# ១៣- ឧទាហរណ៍តែងសេចក្តីបែបពណ៌នា និងការសរសេរសំបុត្រ

## ១៣.១- តែងសេចក្តីបែបពណ៌នា

### ១៣.១.១- តែងសេចក្តីបែបពណ៌នាពីទេសភាពក្នុងរឿង

ប្រធានៈ ក្នុងរឿងផ្កាស្រពោន អ្នកនិពន្ធនូ ហាច បានសរសេររៀបរាប់ពីទេសភាពនៃប្រាសាទនានាក្នុងខេត្តសៀមរាប។ ចូរប្អូនៗសរសេរពណ៌នាពីទេសភាពនៅទីនោះឱ្យបានក្បោះក្បាយ។

**គម្រោងតែង**

**ក- សេចក្តីផ្តើម**

- ចំណងជើងរឿង ...
- ឈ្មោះអ្នកនិពន្ធ ...
- កាលកំណត់តែង ... ។

**ខ- តួសេចក្តី**

- ឃ្លាភ្ជាប់សេចក្តី ...
- ដកស្រង់សេចក្តីពណ៌នាទេសភាពក្នុងរឿងផ្កាស្រពោន ... ។

**គ- សេចក្តីបញ្ចប់**

- វាយតម្លៃលើស្នាដៃអ្នកនិពន្ធក្នុងការពណ៌នាពីទេសភាព ...
- ចំណាប់អារម្មណ៍ចំពោះសេចក្តីពណ៌នាទេសភាព...។

**សេចក្តីពណ៌នា**

រឿងផ្កាស្រពោនជាប្រលោមលោកមួយ ដែលជាស្នាដៃតែងនិពន្ធរបស់លោក នូ ហាច។ រឿងនេះគាត់តែងឡើងនៅក្នុងឆ្នាំមួយពាន់ប្រាំបួនរយសែសិបប្រាំពីរ។ រឿងផ្កាស្រពោន ត្រូវបានអ្នកនិពន្ធសរសេររៀបរាប់ពីទេសភាពយ៉ាងល្អ។ តួយ៉ាងដូចជាអ្នកនិពន្ធ បានរៀបរាប់ពីទេសភាពនៃប្រាសាទនានាក្នុងខេត្តសៀមរាប។

នៅក្នុងព្រៃដែលដុះព័ទ្ធបុរាណប្រាសាទនានា មានរបស់ពីរយ៉ាង ដែលនាំបង្កើតដួងចិត្តទេសចរឱ្យរឹតតែស្រងេះស្រងោចខ្លោចផ្សា ដោយសេចក្តីសោកស្តាយអាល័យដល់កេរស្នាដៃនៃបុព្វបុរសខ្មែរ។ វត្ថុនោះហាក់ដូចជាខ្យល់ព្រលឹង និងសំឡេងនៃប្រវត្តិមាតុភូមិយើង។

ពេលរសៀល វេលាដែលព្រះសុរិយាកំពុងដុតចំហុយអស់ទាំងធម្មជាតិ រៃកណ្តឹងយំទម្លាក់សំឡេងពីចុងស្រឡៅ ឬចុងឈើទាល ដែលខ្ពស់ត្រដែតក្នុងអាកាសវេហា។ សព្ទតូរ្យតន្ត្រីចម្លែកនេះ បានជ្រាបចូលសព្វសព៌ាង្គកាយ ហើយមកកុំស្រោបបេះដូង នាំឱ្យអ្នកដំណើរទាំងឡាយយន់ចិត្តអាសូរដល់ស្រុកកំណើតដែលធ្លាប់ចុំថ្កើង។

នៅខែចេត្រ និងពិសាខ តាមផ្លូវពីក្រុងសៀមរាបទៅអង្គរ ផ្ការំដួលបញ្ចេញរំភើយពិដោរក្រអូបឈ្ងុយឈ្ងប់។ បើជួនជាមានវាយោបក់បន្តិចៗផង អ្នកដែលដើរយកខ្យល់អាកាសពេលល្ងាចតាមថ្នល់នេះ នឹងមានចិត្តរសាយ អណ្តែតអណ្តូង ប្រហែលជានឹងលាន់មាត់ថា ទោះជាឋានតុសិតក៏មិនសប្បាយជាងនេះដែរមើលទៅ។

ឱក្លិនរំដួល! ឱសំឡេងរៃ! កម្លាំងអ្នកដូចជាទិព្វឱសថ ដែលអាចចូលមករំសាយសេចក្តីសោកសង្រេងមួយគ្រាបាន។

តាមរយៈខ្លឹមសារនៃការពណ៌នានេះបង្ហាញថា អ្នកនិពន្ធមានការប៉ិនប្រសប់ក្នុងការប្រើប្រាស់ពាក្យពេចន៍មករៀបជាឃ្លាល្បះបានល្អឥតខ្ចោះ ធ្វើឱ្យអ្នកអានជក់ចិត្តជិតអារម្មណ៍។ អ្នកបានអានសេចក្តីពណ៌នានេះ ស្លុងអារម្មណ៍ហាក់កំពុងឃើញទិដ្ឋភាពទាំងនោះនៅជាប់នឹងភ្នែក។ ក្នុងនាមយើងជាអ្នកសិក្សាមានមោទនភាពក្រៃលែងចំពោះស្នាដៃនេះ ហើយយើងនឹងខិតខំសិក្សាស្នាដៃផ្សេងៗទៀត ដើម្បីទទួលបានចំណេះដឹងកាន់តែទូលំទូលាយ ព្រមទាំងចូលរួមអភិរក្ស និងអភិវឌ្ឍអក្សរសិល្ប៍ខ្មែរយើងឱ្យបានគង់វង្ស និងរីកចម្រើន។

### ១៣.១.២- តែងសេចក្តីបែបពណ៌នាពីបាតុភូតធម្មជាតិ

---

ប្រធាន: រៀងរាល់ឆ្នាំក្នុងប្រទេសកម្ពុជាយើង តែងជួបប្រទះនូវគ្រោះធម្មជាតិខ្យល់កន្ត្រាក់។ ចូរប្អូនសរសេរតែងសេចក្តីពណ៌នាពីបាតុភូតនេះឱ្យបានក្បោះក្បាយ។

---

## គម្រោងតែង

**ក- សេចក្តីផ្តើម**

- ពេលវេលា និងទីកន្លែងកើតមានខ្យល់កន្ត្រាក់...
- ឈ្មោះខ្យល់កន្ត្រាក់...។

**ខ- តួសេចក្តី**

*មុនពេលកើតមានខ្យល់កន្ត្រាក់៖*

- ទិដ្ឋភាពទូទៅនៃអាកាសធាតុ....
- ទិដ្ឋភាពខ្យល់កន្ត្រាក់មុនពេលកើតឡើង...។

*ពេលកើតមានបាតុភូតធម្មជាតិ៖*

- ទិដ្ឋភាពពេលខ្យល់កន្ត្រាក់ចាប់ផ្តើមកើតឡើង...

- ទិដ្ឋភាពពេលខ្យល់កន្ត្រាក់កំពុងកើតឡើង ...
- ទិដ្ឋភាពចុងបញ្ចប់នៃការកើតមានខ្យល់កន្ត្រាក់ ... ។

*ក្រោយពេលកើតមានខ្យល់កន្ត្រាក់៖*

- ទិដ្ឋភាពក្រោយពេលកើតមានខ្យល់កន្ត្រាក់ ...
- សកម្មភាពអ្នកស្រុកក្រោយពេលកើតមានខ្យល់កន្ត្រាក់ ...
- សកម្មភាពអាជ្ញាធរមូលដ្ឋាន ឬអង្គការមនុស្សធម៌ផ្សេងៗ...។

**គ- សេចក្តីបញ្ចប់**

- ការប្រមូលសរុបនិងវាយតម្លៃលើការខូចខាត...
- ចំណាប់អារម្មណ៍ចំពោះខ្យល់កន្ត្រាក់នោះ.. ។

## សេចក្តីពណ៌នា

រដូវប្រាំងកន្លងផុតទៅ រដូវវស្សាក៏ឈានចូលមកដល់។ ខ្យល់ចាប់ផ្តើមផ្លាស់ទិសបក់មកពីទិសនិរតីវិញម្តង។ ដើមរដូវវស្សានេះ តែងកើតមានខ្យល់កន្ត្រាក់ជារឿយៗ។ ដូចជាកាលពីវេលាម៉ោងបីរសៀល ថ្ងៃសុក្រ ដប់រោច ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ពុទ្ធសករាជពីរពាន់ប្រាំរយហុកសិបពីរ ត្រូវនឹងថ្ងៃទីប្រាំបី ខែមិថុនា ឆ្នាំពីរពាន់ដប់ប្រាំបី មានខ្យល់កន្ត្រាក់ដ៏ធំមួយបានកើតឡើងនៅក្នុងស្រុកមេសាង ខេត្តព្រៃវែង។

មុនពេលកើតមានព្រឹត្តិការណ៍នេះ យើងសង្កេតឃើញផ្ទៃមេឃដែលកំពុងស្រឡះ ស្រាប់តែប្រែជាមានដុំពពកពណ៌ខ្មៅដូចមររសាត់មីរដេរដាសងងឹងឈ្លប់ពាសពេញពួដ៏វេហា។ សូរសន្ធឹកខ្យល់លាន់ឮគគ្រឹកខ្ទរធរណី ពពកខ្មៅខ្មួលខ្មាញ់ប្រែជាទម្លាក់កន្ទុយនាគពីចម្ងាយហោះសំដៅឆ្ពោះមកលើភូមិដែលមានប្រជាជនកំពុងរស់នៅ។ នេះជាសញ្ញាខ្យល់កន្ត្រាក់រៀបនឹងចូលមកដល់។ អ្នកស្រុកដែលឃើញទិដ្ឋភាពនេះ ភិតភ័យស្រឡាំងកាំងមិនដឹងថាត្រូវធ្វើអ្វី។ អ្នកខ្លះនាំគ្នាជ្រួលច្របល់សម្លឹងឆ្ពោះទៅលើមេឃ មើលកន្ទុយនាគឥតព្រិចភ្នែក។ ចាស់ៗធ្លាប់យល់ដឹងពីហេតុការណ៍នេះ នាំគ្នារត់ឆ្លេឆ្លានាំកូនចៅរត់សំដៅទៅគេហដ្ឋាន និងរកកន្លែងមានសុវត្ថិភាព។ អ្នកខ្លះម្ទីម្ទាយកគោ ក្របី ជ្រូក មាន់ ទា ទៅរកទីជម្រកមានសុវត្ថិភាព។

ពេលកើតហេតុ សន្ធឹកខ្យល់លាន់កក្រើកធរណីជាសញ្ញាប្រាប់ឱ្យដឹងថា ខ្យល់កន្ត្រាក់ឈានចូលមកដល់ហើយ។ សំឡេងក្ទុងក្ទាំង ប្រាវៗ លាយឡំជាមួយសំឡេងទ្រហឹងអឺងកងដទៃទៀត ធ្វើឱ្យការនិយាយគ្នាស្តាប់មិនឮ។ ដើមឈើតូចធំ រងនឹងកម្លាំងខ្យល់យោលយោកទន់ចុង សំយុងចុះស្ទើរដល់ដី។ រុក្ខជាតិខ្លះ ដែលគ្មានឫសកែវរឹងមាំ ត្រូវដួលរលំរណ្ដួករណែលបន្តបន្ទាប់គ្នា។ លំនៅស្ថានខ្លះរបស់អ្នកស្រុករង្គើញ័ររញ្ជួយតាំងពីជើងសសរហូតដល់មេដំបូល។ សត្វចតុប្បាទ សត្វស្លាប ក្រាបចុះដើម្បីការពារខ្លួនពីគ្រោះមហន្តរាយនេះ។ មនុស្សម្នាទាំងឡាយអង្គុយក្រសោបឱបគ្នាភ័យរន្ធត់ស្លន់ស្លោញ័រទទ្រើក។ សន្ទុះខ្យល់កាន់តែបង្កើនកម្លាំងខ្លាំងឡើងៗ។ ដើមឈើតូចធំខ្លះ រយះមែកបាក់ធ្លាក់ដល់ដី ខ្លះសណ្តកឫសដួលរលំចង្ក្រាងៗ។ លំនៅស្ថានតូចៗ ផើតប៉ើងតាមកម្លាំងខ្យល់។ លំនៅស្ថានធំៗខ្លះបាក់ស្រុត ខ្លះខ្ទាតធ្លាក់ចុះពីលើជើងតាង និងខ្លះទៀតត្រូវដួលរលំរាបដល់ដី។ សត្វខ្លះត្រូវផើតតាមខ្យល់ ខ្លះត្រូវរបួស និងខ្លះទៀតស្លាប់ដោយដើមឈើ ឬផ្ទះរលំកិន។ អ្នកស្រុកខ្លះ ស្រែកឆោឡោសុំឱ្យគេជួយ។ អ្នក

ខ្លះស្រែកទ្រហោយំ ដោយសេចក្តីភ័យខ្លាច និងការឈឺចាប់ក្នុងការរងរបួស។ ព្យុះសង្ឃរាបាន ថយឥទ្ធិពលរបស់ខ្លួនបន្តិចម្តងៗ រហូតឈានទៅដល់ទីអវសាន។

ក្រោយពេលកើតហេតុខ្យល់កន្ត្រាក់នេះបានបន្សល់ទុកនូវវិនាសកម្មយ៉ាងធ្ងន់ធ្ងរ សាលារៀន មន្ទីរពេទ្យ លំនៅស្ថានខ្លះសណ្តកសសរដួលរលំបាក់បែកអស់រាប់រយខ្នង។ សត្វជាច្រើនក្បាលត្រូវរងរបួស និងបាត់បង់ជីវិត។ ប្រជាពលរដ្ឋមួយចំនួនបានទទួលរងរបួស។ គ្រាអាសន្ននេះបានកន្លងផុតទៅ ប្រជាជនក្នុងភូមិទាំងអស់រួមសាមគ្គីគ្នាជួយរុះរើផ្ទះបាក់បែក ដើម្បីរៀបចំសាងសង់ឡើងវិញ។ អ្នកខ្លះធ្វើរោងដោល ដើម្បីស្នាក់នៅបណ្តោះអាសន្ន។ អ្នកខ្លះទៀតជួយដឹកជញ្ជូនអ្នករបួសទៅមន្ទីរពេទ្យ។ អាជ្ញាធរមូលដ្ឋាន បានចាត់ចែងកម្លាំងចុះជួយប្រជាជនរងគ្រោះយ៉ាងសស្រោកសស្រាំ។ ព័ត៌មានអំពីគ្រោះមហន្តរាយដោយព្យុះសង្ឃរាត្រូវបានផ្សព្វផ្សាយ។ រាជរដ្ឋាភិបាល បានអំពាវនាវដល់អង្គការមនុស្សធម៌ជាតិ អន្តរជាតិ សប្បុរសជនឱ្យជួយដល់ជនរងគ្រោះ។ កាកបាទក្រហមកម្ពុជាស្ម័គ្រចិត្ត ស្ទុះស្ទាដឹកស្បៀងអាហារ សម្ភារៈប្រើប្រាស់ ដើម្បីឧបត្ថម្ភដល់ជនរងគ្រោះ។

តាមការវាយតម្លៃបឋមខ្យល់កន្ត្រាក់នេះ បង្កការខូចខាតធ្ងន់ធ្ងរក្នុងនោះមាន មនុស្សរបួសធ្ងន់ ស្រាល សត្វពាហនៈបាត់បង់ជីវិត និងរបួស លំនៅស្ថានតូចធំរបស់ប្រជាពលរដ្ឋត្រូវដួលរលំ និងបាក់បែករាប់រយខ្នង សាលារៀន មន្ទីរពេទ្យ និងវត្តអារាមត្រូវរងការខូចខាតយ៉ាងដំណំ។ ខ្យល់កន្ត្រាក់ ជាបាតុភូតធម្មជាតិបង្កគ្រោះមហន្តរាយយ៉ាងខ្លាំងដល់មនុស្ស សត្វ រុក្ខជាតិ ធ្វើឱ្យប៉ះពាល់ដល់សេដ្ឋកិច្ចទៀតផង។

## ១៣.១.៣- តែងសេចក្តីបែបពណ៌នាពីសកម្មភាព

ប្រធាន: នៅខេត្តប្អូនតែងរៀបចំការប្រកួតកីឡាបាល់ទាត់ជារៀងរាល់ឆ្នាំ។ ចូរប្អូនសរសេរតែងសេចក្តីពិណនាពីសកម្មភាពប្រកួតកីឡានោះឱ្យបានក្បោះក្បាយ។

### គម្រោងតែង

**ក- សេចក្តីផ្តើម**

- ពណ៌នាទូទៅទាក់ទងនឹងការប្រកួតកីឡា...
- ពេលវេលា...
- ទីកន្លែង...
- ឈ្មោះសកម្មភាព... ។

**ខ- តួសេចក្តី**

*មុនពេលប្រកួត៖*

- រៀបចំទីលានប្រកួត...
- រៀបចំទីកន្លែងគណៈកម្មការ...
- កីឡាកររកម្តៅសាច់ដុំ...
- ពិធីប្រកាសបើកការប្រកួត... ។

*ពេលប្រកួត៖*

- ការចាប់ផ្តើមប្រកួត...
- កីឡាករទាំងពីរក្រុមប្រឹងប្រែងប្រកួត...
- ការប្រើបច្ចេកទេសរបស់កីឡាករ...
- ការពិន័យកីឡាករ...
- ការផ្លាស់ប្តូរកីឡាករ...
- ការទាត់បញ្ចូលទី...
- អ្នកទស្សនា និងអ្នកគាំទ្រក្រុមនីមួយៗអបអរសាទរ...
- ការឈប់សម្រាក...
- សកម្មភាពការប្រកួតបន្ត...
- លទ្ធផលនៃការប្រកួត...។

*ក្រោយពេលប្រកួត៖*

- ពិធីប្រកាសបិទការប្រកួត...
- ការប្រគល់ជ័យលាភី...។

**គ- សេចក្តីបញ្ចប់**

- បង្ហាញពីចំណាប់អារម្មណ៍របស់អ្នក ឬមនុស្សទូទៅចំពោះការប្រកួតនោះ...
- បង្ហាញពីសារប្រយោជន៍នៃការលេងកីឡា និងការប្រកួតកីឡា...។

## សេចក្តីពណ៌នា

រៀងរាល់ឆ្នាំ នៅខេត្តខ្ញុំតែងមានរៀបចំការប្រកួតកីឡាបាល់ទាត់រវាងសាលារៀននៅតាមក្រុង ស្រុក នីមួយៗទូទាំងខេត្ត ដើម្បីដណ្តើមជ័យលាភីប្រចាំឆ្នាំ។ ជាក់ស្តែងឆ្នាំនេះ កាលពីថ្ងៃអាទិត្យ បីរោច ខែផល្គុន ឆ្នាំរកា នព្វស័ក ពុទ្ធសករាជពីពាន់ប្រាំរយហុកសិបមួយ ត្រូវនឹងថ្ងៃទីបួន ខែមីនា ឆ្នាំពីរពាន់ដប់ប្រាំបី នៅពហុកីឡដ្ឋានខេត្តព្រៃវែង មានការរៀបចំការប្រកួតកីឡាបាល់ទាត់ប្រចាំខេត្ត។ នោះជាការប្រកួតផ្តាច់ព្រ័ត្ររវាងកីឡាករក្រុមហនុមាន និងកីឡាករក្រុមសេនាមឿង ដើម្បីយកជ័យលាភីប្រចាំឆ្នាំ។

មុនពេលប្រកួត គេបានរៀបចំឈូសឆាយដី គូសទីលានបាល់ទាត់ទៅតាមលក្ខណៈបច្ចេកទេស។ មន្ទីរអប់រំ យុវជន និងកីឡាខេត្ត បានរៀបចំការប្រជុំដើម្បីបង្កើតគណៈកម្មការសម្រាប់ការប្រកួតនេះ។ ថ្ងៃប្រកួតចូលមកដល់ នារសៀលម៉ោងបី មានក្រុមកីឡាករ អ្នកគាំទ្រមកពីសាលារៀននានា និងមហាជនចូលរួមទស្សនាយ៉ាងច្រើនកុះករ។ កីឡាករតាមក្រុមនីមួយៗ បានធ្វើការកម្តៅសាច់ដុំនៅតាមទីកន្លែងខុសៗគ្នា។ គ្រូបង្វឹកតាមក្រុមបានយកចិត្តទុកដាក់ពិនិត្យតាមដាន និងផ្តល់ដំបូន្មានបច្ចេកទេសដល់កីឡាករក្រុមខ្លួន។ បន្ទាប់មក គេបានប្រារព្ធធ្វើពិធីបើកតាមលំដាប់ លំដោយក្រោមអធិបតីភាពប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត។ ចុងបញ្ចប់នៃពិធីនេះ ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត បានប្រកាសបើកការប្រកួតចាប់ពីពេលនោះតទៅ។

ពេលប្រកួតឈានចូលមកដល់ កីឡាករទាំងពីរក្រុមបានដើរចូលក្នុងទីលានប្រកួត។ កីឡាករទាំងពីរក្រុមស្លៀកពាក់ឯកសណ្ឋានកីឡាខុសៗគ្នា។ បន្ទាប់ពីអាជ្ញាកណ្តាល ផ្លុំកញ្ចែចាប់ផ្តើមការប្រកួត កីឡាករម្នាក់ៗរត់ចល័តទាត់បាល់ ទៅតាមលក្ខណៈបច្ចេកទេសរបស់

ខ្លួន។ ពួកគេម្នាក់ៗ រត់បណ្តើរបាល់ ចែកបាល់ឱ្យគ្នាទៅវិញទៅមក ដើម្បីបញ្ឆោតគូប្រកួតរបស់ខ្លួន។ កីឡាករខំប្រឹងរត់ច្រវាត់ចុះឡើងៗក្នុង ទីលានប្រកួត ដើម្បីបណ្តើរបាល់ និងដណ្តើមបាល់គ្នា។ យូរៗម្តង គេឃើញគ្រូបង្វឹកស្នើផ្លាស់ប្តូរកីឡាករ។ ការប្រកួតបានរយៈពេលម្ភៃនាទី ក្រុមសេនាមឿងទាត់បញ្ចូលទីក្រុមហនុមានបានមួយគ្រាប់ ធ្វើឱ្យអ្នកទស្សនា និងអ្នកគាំទ្រហើបខ្លួនឡើងពីទីអង្គុយដោយមិនដឹងខ្លួន ទះដៃស្រែកហ៊ោកញ្ជ្រៀវលាន់ឮទ្រហឹងអឹងកង។ ការប្រកួតកំពុងបន្តទៅកាន់តែស្វិតស្វាញ។ ក្រុមហនុមាន ព្យាយាមទាត់បញ្ចូលទីក្រុមសេនាមឿងវិញជាច្រើនលើកតែមិនបានសម្រេច។ ផ្ទុយទៅវិញនៅនាទីទីសាមសិបប្រាំ ក្រុមសេនាមឿងបានទាត់បញ្ចូលទីក្រុមហនុមានបានមួយគ្រាប់ទៀត។ អ្នកទស្សនា និងអ្នកគាំទ្រទះដៃស្រែកហ៊ោកាន់តែខ្លាំងឡើងៗ។ សំឡេងទះដៃ សម្រែកហ៊ោកញ្ជ្រៀវញ៉ាំងឱ្យពិធីប្រកួតកាន់តែអធឹកអធមក្រៃលែង។

រយៈពេលសែសិបប្រាំនាទីកន្លងផុតទៅ ជាកាលកំណត់វេលាចុងបញ្ចប់នៃការប្រកួតវគ្គទីមួយ។ នេះជាពេលកីឡាករត្រូវសម្រាកដប់ប្រាំនាទី។ ជាលទ្ធផលបណ្តោះអាសន្ន ក្រុមសេនាមឿងឈ្នះក្រុមហនុមានពីរគ្រាប់ទល់នឹងសូន្យគ្រាប់។ ក្រុមសេនាមឿង និងអ្នកគាំទ្រក្រុមខ្លួនកំពុងមានទឹកមុខញញឹមញញែមប្រកបដោយមោទនភាពក្នុងក្តីសង្ឃឹមថា នឹងទទួលបានជ័យលាភីជាមិនខាន។ បន្ទាប់ពីឈប់សម្រាក អាជ្ញាកណ្តាលបានផ្លុំកញ្ចែចាប់ផ្តើមប្រកួតវគ្គទីពីរ។ ក្រុមកីឡាករនីមួយៗ សម្រុកទាត់បាល់បញ្ចូលទីរៀងៗខ្លួន។ ក្នុងវគ្គនេះកីឡាករក្រុមហនុមានបានផ្លាស់បច្ចេកទេសប្រកួត ដោយវាយលុកយ៉ាងខ្លាំង ធ្វើឱ្យពួកក្រុមនេះមានប្រៀបយ៉ាងខ្លាំងលើកីឡាករក្រុមសេនាមឿង។ កីឡាករក្រុមសេនាមឿង ក៏បានខិតខំប្រឹងប្រែងទប់ទល់អស់ពីសមត្ថភាពវិញដែរ។ ប្រមាណជាម្ភៃប្រាំនាទីក្រោយមក កីឡាករក្រុមហនុមានធ្វើបានសម្រេច ដោយទាត់បញ្ចូលទីបានមួយគ្រាប់។ ការប្រកួតនៅតែបន្តយ៉ាងស្វិតស្វាញ រហូតដល់ទីបញ្ចប់។ ជាលទ្ធផលក្រុមសេនាមឿងឈ្នះក្រុមហនុមានពីរគ្រាប់ទល់នឹងមួយគ្រាប់។

ពេលបញ្ចប់ការប្រកួត គេបានរៀបចំធ្វើពិធីប្រកាសបិទការប្រកួត ក្រោមអធិបតីភាពប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត។ បន្ទាប់ពីប្រកាសបិទការប្រកួតរួចមក ប្រធានមន្ទីរអប់រំ យុវជន និងកីឡាស្រុកបានប្រគល់ជ័យលាភីប្រចាំឆ្នាំដល់ក្រុមកីឡាករសេនាមឿង ដែលទទួលជ័យជម្នះក្នុងការប្រកួត។ កីឡាក្រុមសេនាមឿង និងអ្នកគាំទ្របង្ហាញភាពសប្បាយរីករាយនឹងលទ្ធផលនៃការប្រកួតនេះ។

ខ្ញុំពេញចិត្តនឹងការប្រកួតកីឡានេះណាស់ ព្រោះវាមានសារប្រយោជន៍យ៉ាងខ្លាំងដូចជាផ្តល់បទពិសោធដល់គ្នាទៅវិញទៅមក បង្កើនចំណងមិត្តភាព សាមគ្គីភាព មានសហការល្អ និងជួយលើកកម្ពស់វិស័យកីឡានៅក្នុងប្រទេសកម្ពុជាយើងថែមទៀតផង។ លើសពីនេះ ការលេងកីឡានាំឱ្យមានសុខភាពល្អ។ ដូច្នេះសិស្សានុសិស្សទាំងឡាយ ចូរអ្នកចៀសវាងឱ្យឆ្ងាយពីគ្រឿងញៀន ព្រោះគ្រឿងញៀនធ្វើឱ្យប្រើប្រាស់ខូចសុខភាព បាត់បង់សតិ ក្លាយខ្លួនជាអ្នកប្រព្រឹត្តបទល្មើសលួច ឆក់ ប្លន់ បង្កអំពើហិង្សា ខូចអនាគតខ្លួនឯង បំផ្លាញទ្រព្យសម្បត្តិ បំផ្លាញសុភមង្គលក្នុងគ្រួសារ បង្កអសន្តិសុខក្នុងសង្គមជាដើម។ សូមប្អូនៗនាំគ្នាលេងកីឡាឱ្យបានគ្រប់ៗគ្នា ព្រោះកីឡានាំមកនូវសុខភាព សាមគ្គីភាព មិត្តភាព និងសហការគ្នាល្អ។

## ១៣.១.៤- តែងសេចក្តីបែបពណ៌នាពីព្រឹត្តិការណ៍

ប្រធាន: នៅក្នុងសហគមន៍អ្នកតែងជួបប្រទះនូវព្រឹត្តិការណ៍គ្រោះថ្នាក់ចរាចរណ៍ជារឿយៗ។ ចូរអ្នកសរសេរតែងសេចក្តីពណ៌នាពីព្រឹត្តិការណ៍នេះឱ្យបានក្បោះក្បាយ។

### គម្រោងតែង

**ក- សេចក្តីផ្តើម**

- ពេលវេលា...
- ទីកន្លែង...
- ឈ្មោះព្រឹត្តិការណ៍... ។

**ខ- តួសេចក្តី**

*មុនពេលកើតព្រឹត្តិការណ៍៖*

- ទិដ្ឋភាពទូទៅ...
- សកម្មភាពមុនពេលកើតគ្រោះថ្នាក់ចរាចរណ៍... ។

*ពេលកើតព្រឹត្តិការណ៍៖*

- ទិដ្ឋភាពពេលគ្រោះថ្នាក់ចរាចរណ៍ចាប់ផ្តើមកើតឡើង...
- ទិដ្ឋភាពពេលគ្រោះថ្នាក់ចរាចរណ៍កំពុងកើតឡើង ...
- ទិដ្ឋភាពចុងបញ្ចប់នៃព្រឹត្តិការណ៍គ្រោះថ្នាក់ចរាចរណ៍... ។

*ក្រោយពេលកើតព្រឹត្តិការណ៍៖*

- ទិដ្ឋភាពនៃការខូចខាត ...
- សកម្មភាពអ្នកស្រុកក្រោយពេលកើតហេតុ...
- សកម្មភាពអាជ្ញាធរមូលដ្ឋាន ... ។

**គ- សេចក្តីបញ្ចប់**

- វាយតម្លៃ...
- ចំណាប់អារម្មណ៍ផ្ទាល់ខ្លួនចំពោះគ្រោះថ្នាក់ចរាចរណ៍... ។

### សេចក្តីពណ៌នា

ព្រះទិនករ បានបន្ទាបខ្លួនលាចាកភពផែនដីយើងនេះទៅហើយ។ ស្បៃរាត្រីដ៏ងងឹតឈឹងបានចូលមកជំនួសវិញម្តង។ នៅតាមដងផ្លូវនានា មានទោចក្រយានយន្ត រថយន្តកំពុងធ្វើចរាចរណ៍យ៉ាងប្រសេកប្រសាច។ ក្នុងចំណោមអ្នកធ្វើដំណើរ មានអ្នកខ្លះគោរពច្បាប់ចរាចរណ៍បានល្អ ចំណែកអ្នកខ្លះទៀតមិនបានគោរពច្បាប់ចរាចរណ៍ឡើយ។ កត្តានេះហើយ ដែលធ្វើឱ្យគ្រោះចរាចរណ៍ងាយនឹងកើតឡើង។ ជាក់ស្តែង កាលពីវេលាម៉ោងប្រាំបួនយប់ថ្ងៃអាទិត្យ ដប់បួនរោច ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ពុទ្ធសករាជពីរពាន់ប្រាំរយហុកសិបពីរ ត្រូវនឹងថ្ងៃទីដប់បី ខែឧសភា ឆ្នាំពីរពាន់ដប់ប្រាំបី មានគ្រោះថ្នាក់ចរាចរណ៍មួយបានកើតឡើងដោយមានការបុកគ្នារវាងម៉ូតូ និងរថយន្តធុនតូច នៅតាមបណ្តោយមហាវិថីព្រះនរោត្តម ស្ថិតក្នុងសង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

មុនពេលកើតហេតុ សាក្សីនៅកន្លែងកើតហេតុបានបញ្ជាក់ថា មានយុវជនពីរនាក់ជិះម៉ូតូម៉ាកសេមួយរយម្ភៃប្រាំ ពណ៌ខ្មៅ ស៊េរីឆ្នាំពីរពាន់ដប់ប្រាំមួយ ឌុបគ្នាតាមបណ្តោយមហាវិថីព្រះនរោត្តមពីជើងទៅត្បូង ដោយបើកបរក្នុងល្បឿនយ៉ាងលឿន ជិះរេពេញផ្លូវក្នុងអាការៈស្រវឹងជោកជាំបាត់បង់ភាពម្ចាស់ការ។

ពេលកើតហេតុ គេឃើញអ្នកជិះម៉ូតូមកដល់កន្លែងកើតហេតុក៏បានរេចង្កូតទៅបុករថយន្តធុនតូចម៉ាកការីបាឡៃស៊េរីឆ្នាំពីរពាន់ពីរមួយគ្រឿង ដែលកំពុងបើកបរបញ្ច្រាស់ទិសគ្នា ចំពីមុខយ៉ាងពេញទំហឹងឮសូរខ្លាំងគួរឱ្យរន្ធត់ក្រៃលែង។ ព្រឹត្តិការណ៍បុកគ្នានេះ ធ្វើឱ្យអ្នកជិះខាងក្រោយហោះផ្លោងរំលងរថយន្តទៅខាងក្រោយ រមៀលប្រមាណជាដប់ត្រឡប់ទើបឈប់។ ចំណែកអ្នកបើកបរម៉ូតូវិញបានខ្ទាតជាមួយម៉ូតូអូសកកិតនឹងផ្លូវបែកផ្កាភ្លើងព្រាកៗប្រហែលបួនម៉ែត្រ របូតមួកសុវត្ថិភាពចេញពីក្បាល។ រីឯអ្នកបើកបររថយន្ត ភិតភ័យតក្កមា មុខប្រែស្លេកស្លាំងស្ទើររកឈាមគ្មាន។ គាត់បើកទ្វាររថយន្ត ចុះមកទាំងញញីញញ័រមកជួយជនរងគ្រោះ។ ហេតុការណ៍ដ៏រន្ធត់នេះ បណ្តាលឱ្យអ្នកធ្វើដំណើរតាមដងមហាវិថីជាមួយភិតភ័យតក់ស្លុតយ៉ាងខ្លាំង។ ចំណែកអ្នករស់នៅជិតខាងមានការភ្ញាក់ផ្អើលឈូឆរ ស្ទុះរត់មីម្នាមកកន្លែងកើតហេតុ ដើម្បីពិនិត្យមើលស្ថានការណ៍។ ក្នុងហេតុការណ៍នេះ អ្នកធ្វើដំណើរតាមដងមហាវិថីមួយចំនួន និងអ្នកដែលរស់នៅជិតខាងនាំគ្នាមកចោមរោមមើល។ អ្នកខ្លះនិយាយទូរស័ព្ទហៅឡានពេទ្យ និងអ្នកខ្លះទៀតជួយធ្វើសង្គ្រោះបឋមដល់ជនរងគ្រោះ។

ក្រោយពេលកើតហេតុ ទាំងអ្នកបើកបរម៉ូតូ និងអ្នកជិះពីក្រោយបានសន្លប់ស្តូកស្តឹង។ អ្នកបើកបរ ម៉ូតូរងរបួសធ្ងន់ធ្ងរ គឺបែកមុខមាត់ មានឈាមហូរតាមត្រចៀក និងបាក់ដៃខាងឆ្វេង។ ចំណែកអ្នកជិះខាងក្រោយរងរបួសធ្ងន់ធ្ងរដូចគ្នា គឺដាច់រលាត់ហូរឈាមពេញខ្លួន និងបាក់ជើងទាំងពីរ។ រីឯអ្នកបើកបររថយន្ត មិនមានរងរបួសអ្វីទេ។ ម៉ូតូរបស់ជនរងគ្រោះ ត្រូវខូចខាតទាំងស្រុង។ ចំណែករថយន្តរងការខូចខាតផ្នែកខាងមុខយ៉ាងដំណំ ព្រមទាំងបែកកញ្ចក់ខាងមុខទាំងស្រុង។ បន្តិចក្រោយមក ប៉ូលីសចរាចរណ៍មូលដ្ឋានក៏បានចុះមកដល់ ធ្វើការវាស់វែង និងធ្វើរបាយការណ៍អំពីគ្រោះថ្នាក់នេះ។ ជនរងគ្រោះ ត្រូវបានរថយន្តសង្គ្រោះបន្ទាន់ដឹកយកទៅសង្គ្រោះនៅឯមន្ទីរពេទ្យ។ ចំណែករថយន្ត និងម៉ូតូត្រូវកម្លាំងសមត្ថកិច្ចយកទៅរក្សាទុកនៅអធិការដ្ឋាននគរបាលខណ្ឌ ដើម្បីរង់ចាំធ្វើការដោះស្រាយតាមផ្លូវច្បាប់។

ខ្ញុំមានអារម្មណ៍រន្ធត់ក្រៃលែង នៅពេលឃើញហេតុការណ៍គ្រោះថ្នាក់ចរាចរណ៍នេះ។ គ្រោះថ្នាក់ចរាចរណ៍ បង្កសេចក្តីអន្តរាយធំធេងណាស់។ វាអាចធ្វើឱ្យយើងខូចខាតទ្រព្យសម្បត្តិ ខាតបង់ពេលវេលា របួស ពិការ ខូចអនាគត និងអាចរហូតបាត់បង់អាយុជីវិតថែមទៀតផង។ ដូច្នេះដើម្បីមានសុវត្ថិភាពពេលបើកបរ យើងទាំងអស់ត្រូវមានការប្រុងប្រយ័ត្ន មានការយោគយល់អធ្យាស្រ័យគ្នា និងត្រូវគោរពច្បាប់ចរាចរណ៍ជានិច្ច។

## ១៣.១.៥- តែងសេចក្តីបែបពណ៌នាពីពិធីផ្សេងៗ

**ប្រធាន:** ប្រជាជនខ្មែរយើងតែងរៀបចំប្រារព្ធធ្វើពិធីបុណ្យផ្សេងៗទៅតាមប្រពៃណីជាតិខ្លួន »។ ចូរអ្នកសរសេរតែងសេចក្តីពណ៌នាពីពិធីបុណ្យខួបគម្រប់ប្រាំពីរថ្ងៃ ដែលគេនិយមប្រារព្ធធ្វើនៅក្នុងសហគមន៍ប្អូនឱ្យបានក្បោះក្បាយ។

# គម្រោងតែង

**ក- សេចក្តីផ្តើម**

- ពណ៌នាទូទៅទាក់ទងនឹងពិធីបុណ្យ ...
- ពេលវេលាប្រារព្ធធ្វើពិធីបុណ្យ...
- ទីកន្លែងប្រារព្ធធ្វើពិធីបុណ្យ...
- ឈ្មោះពិធីបុណ្យ និងគោលបំណងនៃការធ្វើពិធីបុណ្យ... ។

**ខ- តួសេចក្តី**

*មុនពេលប្រារព្ធពិធីបុណ្យ៖*

- ការអញ្ជើញភ្ញៀវ...
- ការរៀបចំបោសសម្អាតផ្ទះ...
- ការរៀបចំតុបតែងផ្ទះ...
- ការសង់រោង...
- ការត្រៀមរៀបចំម្ហូបចំណី គ្រឿងសក្ការបូជា... ។

*ពេលប្រារព្ធពិធីបុណ្យ៖*

✓ ពេលរសៀល និងយប់ថ្ងៃទីមួយ

- ការជួបជុំគ្នា...
- ការទទួលភ្ញៀវ...
- ការចូលបុណ្យ...
- ការពិសាភោជនាហារ...
- ការសូត្រមន្តចម្រើនព្រះបរិត្ត...
- ការសម្តែងធម្មទេសនា...
- ការសម្តែងសិល្បៈ ... ។

✓ ពេលព្រឹកថ្ងៃទីពីរ

- ការវេរចង្ហាន់ប្រគេនព្រះសង្ឃ...
- ការបង្សុកូលឧទ្ទិសកុសល... ។

*ក្រោយពេលប្រារព្ធពិធីបុណ្យ៖*

- ការត្រឡប់ទៅវិញរបស់ភ្ញៀវ...
- ការថ្លែងអំណរគុណចំពោះអ្នកបានចូលរួម... ។

**គ- សេចក្តីបញ្ចប់**

- វាយតម្លៃ...
- ចំណាប់អារម្មណ៍ចំពោះពិធីបុណ្យ...។

# សេចក្តីពណ៌នា

ពិធីបុណ្យ គឺជាទំនៀមទម្លាប់ ប្រពៃណីខ្មែរយើងតាំងពីបុរាណកាលមក។ ជាក់ស្តែងកាលពីថ្ងៃសៅរ៍ ពីររោច ខែផល្គុន ឆ្នាំរកា នព្វស័ក ពុទ្ធសករាជពីពាន់ប្រាំរយសុកសិបមួយ ត្រូវនឹងថ្ងៃទីបី ខែមីនា ឆ្នាំពីរពាន់ដប់ប្រាំបី នៅផ្ទះអ្នកជិតខាងខ្ញុំ មានរៀបចំប្រារព្ធពិធីបុណ្យខួបគម្រប់ប្រាំពីរថ្ងៃ ដើម្បីឧទ្ទិសកុសលជូនដល់វិញ្ញាណក្ខន្ធឧបាសក មាស ៣៧ ដែលទើបនឹងទទួលអនិច្ចកម្មទៅថ្មីៗក្នុងជន្មាយុកៅសិបប្រាំឆ្នាំ ដោយជរាពាធ។

មុនពេលចាប់ផ្តើមប្រារព្ធពិធីបុណ្យ អ្នកផ្តើមបុណ្យបានអញ្ជើញភ្ញៀវជិតឆ្ងាយឱ្យមកចូលរួមក្នុងពិធីបុណ្យ។ អ្នកខ្លះទៀតរូតរះម្ទីម្នាទៅទិញសម្ភារៈ និងគ្រឿងសក្ការបូជាផ្សេងៗសម្រាប់ប្រើប្រាស់ក្នុងពិធីបុណ្យ។ លុះដល់ព្រឹកនៃថ្ងៃចាប់ផ្តើមពិធី បងប្អូនញាតិសន្តាន សាច់សាលោហិតមកជួយរៀបចំផ្ទះ សង់រោង បោសសម្អាត និងតុបតែងកន្លែងរៀបចំពិធីយ៉ាងស្អាត។

ពេលចាប់ផ្តើមប្រារព្ធពិធីបុណ្យ លុះវេលារសៀលមកដល់ ជាពេលប្រារព្ធពិធីបុណ្យ។ ពេលនេះ មានបងប្អូនញាតិសន្តាន សាច់សាលោហិត មិត្តភក្តិធ្វើដំណើរហូរហែសំដៅមកចូលរួមក្នុងពិធីបុណ្យ។ នៅខាងមុខរោង មានភ្ញៀវយ៉ាងច្រើនកុះករកំពុងឈរកកកុញ ប្រកបដោយសម្លៀកបំពាក់សមរម្យតាមទំនៀមទម្លាប់ប្រពៃណីខ្មែរ។ អ្នកផ្តើមបុណ្យចេញមកឈរខាងក្រៅរោង ដើម្បីទទួលស្វាគមន៍ភ្ញៀវជិតឆ្ងាយ ដែលបានអញ្ជើញមកដល់ប្រកបដោយតរិយាបថទន់ភ្លន់។ ពេលមកដល់ ភ្ញៀវទៅចូលបច្ច័យជាហូរហែបន្តបន្ទាប់គ្នាមិនដាច់។ លោកអាចារ្យកំពុងមមាញឹកក្នុងការឱ្យពរជ័យដល់ភ្ញៀវដែលបានអញ្ជើញមកចូលបច្ច័យបុណ្យ។ អ្នកផ្តើមបុណ្យអញ្ជើញភ្ញៀវទាំងអស់ឱ្យចូលអង្គុយតាមតុក្នុងរោងដើម្បីពិសាភោជនាហារ។ ក្រោយពីពិសាភោជនាហាររួច ភ្ញៀវខ្លះបានត្រឡប់ទៅលំនៅស្ថានវិញ ចំណែកភ្ញៀវខ្លះទៀតអង្គុយជជែកគ្នាលេងរង់ចាំចូលរួមក្នុងពិធីសូត្រមន្តចម្រើនព្រះបរិត្ត និងស្តាប់ធម៌ទេសនា។ វេលាព្រលប់ ព្រះសង្ឃនិមន្តមកដល់ គេចាប់ផ្តើមធ្វើពិធីសូត្រមន្តចម្រើនព្រះបរិត្ត និងសម្តែងធម្មទេសនា។ លុះវេលាយប់បន្តិចមានការសម្តែងសិល្បៈចាប៉ីដងវែងចែកជូនបងប្អូនញាតិមិត្ត ដែលអញ្ជើញចូលរួមក្នុងពិធីបុណ្យទាំងអស់ ស្តាប់កម្សាន្តរហូតដល់យប់ជ្រៅ។ ព្រឹកឡើងជាថ្ងៃបង្ហើយបុណ្យ គេរៀបចំចង្ហាន់វេរប្រគេនព្រះសង្ឃ ធ្វើពិធីបង្សុកូលឧទ្ទិសកុសលជូនដល់វិញ្ញាណក្ខន្ធអ្នក ដែលបានស្លាប់ទៅ។

នៅចុងបញ្ចប់នៃពិធីបុណ្យ បងប្អូន ញាតិសន្តាន មិត្តភក្តិទាំងអស់បានវិលត្រឡប់ទៅលំនៅដ្ឋានវិញ។ ម្ចាស់ដើមបុណ្យបានថ្លែងអំណរគុណដល់ភ្ញៀវទាំងអស់ដែលបានអញ្ជើញមកចូលរួម។ ពិធីនេះ ប្រព្រឹត្តទៅក្រោមបរិយាកាសអធឹកអធមក្រៃលែង តាមគន្លងទំនៀមទម្លាប់ប្រពៃណីខ្មែរយើងតាំងពីបុរាណកាលមក។

ខ្ញុំមានអារម្មណ៍សប្បាយរីករាយក្រៃលែងដែលបានចូលរួមក្នុងពិធីនេះ ព្រោះពិធីបុណ្យនេះជាប្រពៃណីទំនៀមទម្លាប់របស់ខ្មែរយើង។ លើសពីនេះទៀត ខ្ញុំបានយល់ដឹងច្រើន ព្រមទាំងបានកត់ត្រាទុកពីការរៀបចំកម្មវិធីផ្សេងៗក្នុងពិធីបុណ្យនេះ។

## ១៣.១.៦- តែងសេចក្ដីបែបពណ៌នាពីសត្វនិងរុក្ខជាតិជានិមិត្តសញ្ញាជាតិ

ប្រធាន: ចូរប្អូនពណ៌នាអំពីសត្វនិងរុក្ខជាតិដែលជានិមិត្តសញ្ញាជាតិខ្មែរយើងឱ្យបានក្បោះក្បាយ។

### គម្រោងតែង

**ក- សេចក្ដីផ្ដើម**

- កំណត់ដោយមន្ត្រីរាជរដ្ឋាភិបាលមានសត្វនិងរុក្ខជាតិប្រាំពីរប្រភេទសម្រាប់ជានិមិត្តសញ្ញាជាតិ
- ខ្មែរយើង...
- ប្រជុំនៅទីស្ដីការគណៈរដ្ឋមន្ត្រី...
- ថ្ងៃទីម្ភៃប្រាំ ខែមករាឆ្នាំពីរពាន់ប្រាំ...។

**ខ- តួសេចក្ដី**

- ប្រភេទសត្វចតុប្បាទ«គោព្រៃ»
- ប្រភេទបក្សី«ត្រយងយក្ស»
- ប្រភេទឧរង្គសត្វ«អណ្ដើកហ្លួង ឬអណ្ដើកសរសៃ»
- ប្រភេទមច្ឆជាតិ «ត្រីគល់រាំង»
- ប្រភេទរុក្ខជាតិ«ដើមត្នោត»
- ប្រភេទផ្កាឈើ«ផ្ការំដួល»
- ប្រភេទផ្លែ១«ចេកពងមាន់»
- ទាំងនេះ ចង់ឱ្យយើងស្គាល់អំពីអត្តសញ្ញាណជាតិខ្មែរ។ យើងជាកូនខ្មែរត្រូវតែរក្សាសត្វនិងរុក្ខជាតិទាំងនេះឱ្យបានគង់វង្សក៏ដូចជារួមចំណែកថែរក្សាអត្តសញ្ញាណជាតិ និងបរិស្ថានជាតិយើងឱ្យស្រស់បំព្រង។

**គ- សេចក្ដីបញ្ចប់**

- វាយតម្លៃ សត្វនិងរុក្ខជាតិទាំងប្រាំពីរនេះ ពិតជា...
- ចំណាប់អារម្មណ៍ ដូច្នេះយើង...។

### សេចក្ដីពណ៌នា

នៅតាមភូមិស្រុករបស់យើងនីមួយៗ ក៏ដូចជាទូទាំងរាជធានីខេត្តដែរ តែងតែមានសត្វស្រុក សត្វព្រៃ ព្រមទាំងរុក្ខជាតិនានា។ សត្វនិងរុក្ខជាតិមួយចំនួនក៏បានក្លាយជានិមិត្តសញ្ញារបស់ជាតិខ្មែរយើង ដែលគេបានកំណត់ជាផ្លូវការច្បាប់ទៀតផង។ សត្វនិងរុក្ខជាតិទាំងនោះត្រូវបានរាជរដ្ឋាភិបាលអាណត្តិទីបី បើកកិច្ចប្រជុំអនុម័តនៅទីស្ដីការគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទីម្ភៃប្រាំ ខែមករាឆ្នាំពីរពាន់ប្រាំ បានសម្រេចយកសត្វនិងរុក្ខជាតិចំនួនប្រាំពីរមុខមកធ្វើជានិមិត្តសញ្ញាជាតិ។

សត្វនិងរុក្ខជាតិដែលជានិមិត្តសញ្ញារបស់ជាតិខ្មែរយើងមានដូចជា ប្រភេទសត្វចតុប្បាទគឺ«គោព្រៃ» ប្រភេទបក្សីគឺ «ត្រយងយក្ស» ប្រភេទឧរង្គសត្វគឺ «អណ្ដើកហ្លួងឬអណ្ដើកសរសៃ»

ប្រភេទមច្ឆជាតិគឺ «ត្រីគល់រាំង» ប្រភេទរុក្ខជាតិគឺ «ដើមត្នោត» ប្រភេទផ្កាឈើគឺ «ផ្ការំដួល» និង ប្រភេទផ្លែគឺ «ចេកពងមាន់»។ យើងជាកូនខ្មែរ ត្រូវតែស្គាល់ហើយថែរក្សាការពារសត្វនិង រុក្ខជាតិទាំងនេះឱ្យគង់វង្សជាដរាប។ ជាពិសេសដើមត្នោត ជារុក្ខជាតិដ៏មានសារប្រយោជន៍នៅ តាមភូមិស្រុកយើង។ ដូច្នេះយើងមិនត្រូវកាប់បំផ្លាញវាទេ ព្រោះវាបានផ្ដល់នូវគុណតម្លៃច្រើន ឥតគណនា។ ការចូលរួមអភិរក្សរបស់យើងទាំងអស់គ្នា គឺមិនត្រឹមតែថែរក្សាបាននូវអត្តសញ្ញាណ ជាតិប៉ុណ្ណោះទេ ពោលគឺថែមទាំងបានរួមចំណែកថែរក្សាបរិស្ថានឱ្យស្រស់បំព្រងថែមទៀត ផង។ កិច្ចការទាំងអស់នេះ យើងម្នាក់ៗសុទ្ធតែអាចធ្វើបានទាំងអស់គ្នា។

សត្វនិងរុក្ខជាតិនៅក្នុងស្រុកយើង ពិតជាមានតម្លៃមិនអាចកាត់ថ្លៃបាន។ ក្រៅពីនេះ វាក៏ បានជួយទាក់ទាញភ្ញៀវទេសចរជាតិ អន្តរជាតិឱ្យមកទស្សនា ហើយធ្វើគេបានស្គាល់ខ្មែរយើង កាន់តែច្បាស់។ ដូច្នេះយើងទាំងអស់គ្នាត្រូវចូលរួមថែរក្សាការពារឱ្យបានគង់វង្ស។

---

ប្រធាន: ចូរប្អូនពណ៌នាអំពីផ្ការំដួលដែលជានិមិត្តសញ្ញាជាតិខ្មែរឱ្យបានក្បោះក្បាយ។

---

## គម្រោងតែង

### ក- សេចក្ដីផ្ដើម

- ឈ្មោះសត្វនិងរុក្ខជាតិប្រាំពីរប្រភេទដែលកំណត់ដោយមន្ត្រីរាជរដ្ឋាភិបាលសម្រាប់ជា និមិត្តសញ្ញា
- ជាតិខ្មែរយើង...
- ប្រជុំនៅទីស្ដីការគណៈរដ្ឋមន្ត្រី...
- ថ្ងៃទីម្ភៃប្រាំ ខែមករាឆ្នាំពីរពាន់ប្រាំ...។

### ខ- តួសេចក្ដី

- ដើមរំដួលជាប្រភេទឈើ... មានផ្កា... ផ្លែ... ស្រដៀងផ្លែព្រីងអាហ្វប... គ្រាប់ដាំដុះ... ស្លឹកវា មានពណ៌ខៀវចាស់ មានរាងស្រួចចុង...។ ផ្កាមានបីត្របក ស្រដៀងនឹងផ្កាក្រវ៉ាន់មានក្លិន ក្រអូប... ដូចចេកនួន ទុំ...។ អ្នកនិពន្ធរឿងផ្កាស្រពោន... ប្រៀបទៅនឹងទិព្វឱសថ...។
- ប្រជាជនខ្មែរនិយមដាំដុះលម្អនៅមុខផ្ទះ សួន...
- អត្ថប្រយោជន៍ដើមរំដួល... ម្លប់ ... ក្លិន... ផ្លែ ... តំណាង...
- ផ្ការំដួលនេះ ត្រូវបានយកទៅតំណាងខេត្តដែលសេវាកម្មទេសចរណ៍តាមការប្រកួត ប្រជែងដូចជាឆ្នាំពីរពាន់ដប់ប្រាំពីកន្លងទៅ...។

### គ- សេចក្ដីបញ្ចប់

- វាយតម្លៃ...
- ចំណាប់អារម្មណ៍ ដូច្នេះយើងជាកូនខ្មែរ... ដាំដុះនៅតាមសាលា... ទីសាធារណៈ ដើម្បី...។

## សេចក្ដីពណ៌នា

ទឹកដីខ្មែរយើងមានអំណោយផលល្អ ដល់រុក្ខជាតិច្រើនប្រភេទដុះលូតលាស់ស្រស់បំព្រង ជាលម្អបរិស្ថាន។ រំដួលជារុក្ខជាតិមួយប្រភេទដែលដុះនៅតាមភូមិស្រុកខ្មែរយើង ស្ទើរពាស ពេញផ្ទៃប្រទេស។ ផ្ការំដួល បានក្លាយជានិមិត្តសញ្ញារបស់ជាតិខ្មែរយើងតាមការកំណត់ជាផ្លូវ

ការច្បាប់ទៀតផង។ ផ្កានេះ ត្រូវបានរាជរដ្ឋាភិបាលអាណត្តិទីបី បើកកិច្ចប្រជុំអនុម័តនៅទីស្តីការគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទីម្ភៃប្រាំ ខែមករាឆ្នាំពីរពាន់ប្រាំ បានសម្រេចយកមកធ្វើជាប្រភេទផ្កាឈើជានិមិត្តសញ្ញាជាតិ។

រំដួល ជាប្រភេទដើមឈើមួយប្រភេទមានមែកសាខា ចោលម្លប់ត្រឈឹងត្រឈៃគ្រប់រដូវកាល ហើយមានផ្កា ផ្លែ ព្រមទាំងដុះបន្តពូជដោយសារគ្រាប់។ ដើមរំដួលជារុក្ខជាតិដុះលូតលាស់យឺតជាងឈើហូបផ្លែក្នុងស្រុកដទៃទៀត ហើយវាមានអាយុវែង។ ស្លឹករបស់វាមានពណ៌ខៀវចាស់ ចុងស្រួចស្រដៀងនឹងស្លឹកក្រវាន់ដែរតែតូចជាង ហើយមិនងាយរង្គោះជ្រុះដូចឈើហូបផ្លែដទៃទៀតឡើយ។ រំដួលច្រើនចេញផ្កានារដូវប្រាំងក្នុងខែផល្គុន ចេត្រ។ ផ្កាវាមានត្របកបីស្រដៀងផ្កាក្រវាន់ ហើយមានក្លិនក្រអូបឈ្ងុយស្រដៀងផ្លែចេកទុំ។ ចំណែកផ្លែរំដួលមានលក្ខណៈជាចង្កោម ច្រើនទុំនៅខែចេត្រ ពិសាខ ហើយមានពណ៌ក្រមៅអាចបរិភោគបាន។ លោក នូ ហាច អ្នកនិពន្ធប្រលោមលោករឿងផ្កាស្រពោន បានយកក្លិនក្រអូបនៃផ្ការំដួលប្រៀបធៀបទៅនឹងទិព្វឱសថ ធ្វើឱ្យសេចក្តីសោកសង្រេងរលាយបាត់បានមួយគ្រា។

ដើមរំដួលជាប្រភេទរុក្ខជាតិម្យ៉ាង ច្រើនដុះនៅតាមតំបន់ដែលមានសំណើមខ្ពស់ មានដីខ្សាច់ ល្បាយខ្សាច់តាមមាត់ស្ទឹង ទន្លេជាដើម។ ទឹកដីស្រុកខ្មែរយើងមានស្ទឹង បឹង បួរ ម្ល៉ោះ ហើយក៏សម្បូររុក្ខជាតិដើមរំដួល។ ប្រជាជនខ្មែរ និយមដាំដើមឈើនេះដើម្បីលម្អនៅមុខផ្ទះ មុខហាង និងសួនសាធារណៈជាដើម។

ដើមរំដួលមានអត្ថប្រយោជន៍ជាច្រើនដូចជា ម្លប់ ក្លិន ផ្កា ផ្លែ។ ដើម មែកវា អាចយកមកធ្វើជាសម្ភារៈផ្សេងៗដូចជា ដងកាំបិត ដងចបជាដើម។ ផ្ការំដួល អាចយកមកក្រងជាកម្រងផ្កាអនុស្សាវរីយ៍សម្រាប់ជូនអ្នកផង និងក៏អាចយកទៅថ្វាយព្រះបានដែរ។ ផ្ការំដួល គឺជាតំណាងជាតិខ្មែរដែលមានក្លិនក្រអូបប្រកបដោយ កិត្តិនាមល្បីល្បាញនៅលើឆាកអន្តរជាតិដោយសារសិល្បៈ វប្បធម៌ ខ្លួនយ៉ាងនោះ។

ផ្ការំដួលក៏ត្រូវបានគេយកមកធ្វើជាតំណាងខេត្ត ដែលមានសេវាកម្មទេសចរណ៍ដោយប្រើពាក្យថា «រំដួលបីទង» គឺតំណាងថ្នាក់ទាំងបីប្រចាំឆ្នាំនីមួយៗ។ ការប្រកួតប្រជែងតាមខេត្តទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាកម្មល្អ នាឆ្នាំពីរពាន់ដប់ប្រាំពីរកន្លងទៅ រំដួលបីទង បានទៅខេត្តឧត្តរមានជ័យគឺក្រុងសំរោង ខេត្តបាត់ដំបងគឺក្រុងបាត់ដំបង និងខេត្តកំពត។

ដូច្នេះយើងជាកូនខ្មែរ កំពុងរស់នៅលើទឹកដីខ្មែរ ត្រូវតែដឹងនិងស្គាល់ឱ្យបានច្បាស់អំពីផ្កាឈើតំណាងឱ្យជាតិខ្មែរ។ យើងត្រូវតែដាំដើមឈើនេះឱ្យបានច្រើននៅតាមផ្ទះ សាលារៀន វត្តអារាម ទីសាធារណៈជាដើម ព្រោះវាជារុក្ខជាតិមានប្រយោជន៍ និងជានិមិត្តសញ្ញាជាតិខ្មែរយើង។ ទង្វើនេះពិតជាមានតម្លៃ ក៏ដូចជាបានចូលរួមថែរក្សាបរិស្ថាននោះដែរ។

ប្រធានៈ នៅក្នុងសហគមន៍ប្អូនមានដើមត្នោតជាច្រើន។ ចូរប្អូនសរសេរតែងសេចក្តីពណ៌នាអំពីដើមត្នោតដែលជានិមិត្តសញ្ញាជាតិខ្មែរឱ្យបានក្បោះក្បាយ។

## គម្រោងតែង

**ក- សេចក្តីផ្តើម**

- ឈ្មោះសត្វនិងរុក្ខជាតិប្រាំពីរប្រភេទដែលកំណត់ដោយមន្ត្រីរាជរដ្ឋាភិបាលសម្រាប់ជានិមិត្តសញ្ញាជាតិខ្មែរយើង...
- ប្រជុំនៅទីស្តីការគណៈរដ្ឋមន្ត្រី...
- ថ្ងៃទីម្ភៃប្រាំ ខែមករាឆ្នាំពីរពាន់ប្រាំ...។

**ខ- តួសេចក្តី**

- ទិដ្ឋភាពមើលពីចម្ងាយ...
- ទិដ្ឋភាពពេលចូលទៅដល់...
- រូបលក្ខណៈ ៈរូបរាង ពណ៌ ដើម មែកធាង ស្លឹក ផ្លែ...
- ការដាំដុះ...
- ការថែទាំ...
- ផលប្រយោជន៍...។

**គ- សេចក្តីបញ្ចប់**

- វាយតម្លៃ...
- ចំណាប់អារម្មណ៍ ដូច្នេះយើងជាកូនខ្មែរ... ដាំដុះនៅតាមសាលា... ទីសាធារណៈ ដើម្បី...។

## សេចក្តីពណ៌នា

ប្រទេសកម្ពុជាយើង សម្បូរដើមត្នោតណាស់។ ស្ទើរតែគ្រប់គ្រួសារនៅតាមជនបទសុទ្ធតែមានកេរមរតកដើមត្នោត។ ដើមត្នោត ដុះរាយប៉ាយស្ទើរពាសពេញទឹកដីនៃមាតុភូមិយើង។ ត្នោតមានប្រភេទផ្សេងៗគ្នាដូចជា ត្នោតទ្រាំង ត្នោតសេះ និងត្នោតដែលមានដើមខ្ពស់ៗគេហៅថាត្នោតលៃ។ ដើមត្នោត បានក្លាយជានិមិត្តសញ្ញារបស់ជាតិខ្មែរយើងតាមការកំណត់ជាផ្លូវការច្បាប់ទៀតផង។ ផ្កានេះ ត្រូវបានរាជរដ្ឋាភិបាលអាណត្តិទីបី បើកកិច្ចប្រជុំអនុម័តនៅទីស្តីការគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទីម្ភៃប្រាំ ខែមករាឆ្នាំពីរពាន់ប្រាំ បានសម្រេចយកមកធ្វើជាប្រភេទផ្កាឈើជានិមិត្តសញ្ញាជាតិ។

មើលពីចម្ងាយ ដើមត្នោតដុះច្រូងច្រាងពាសពេញទីវាល។ ដើមត្នោត មានរាងមូលខ្ពស់ត្រដែតហាក់ដូចជាឆត្រកំពុងបើកចោលកណ្តាលឰដ៍អាកាស។ ពេលចូលទៅជិត ដើមត្នោតមានរាងមូលទ្រសំណុំស្លឹក។ ត្នោតគ្មានឫសកែវទេ គឺមានតែឫសតូចៗចាក់ស្រេះគ្នាទ្រទប់ដើមយ៉ាងរឹងមាំមិនឱ្យដួល ដោយងាយៗទេ។ ដើមត្នោត មានពណ៌ប្រផេះគគ្រើមគន្លាក់តិចៗដែលជាស្នាមគាវចាស់របេះជ្រុះជាបណ្តើរៗតាំងពីនៅតូចរហូតដល់ធំ។ នៅផ្នែកខាងចុងមានគាវទ្រទប់ធាងបែកសាខាបុរកបដោយស្លឹកពណ៌បៃតងចាស់។ តាមចន្លោះធាងមានផ្កា និងផ្លែរយោងរយាង។

ដើមត្នោតជារុក្ខជាតិមួយប្រភេទ ដែលមានអាយុយ៉ាងវែងហើយងាយក្នុងការដាំដុះ។ គ្រួសារខ្មែរតាំងពីដូនតាបុរាណកាលមកនិយមដាំដើមត្នោតតាមភ្លឺស្រែ ដីទីទួល ដីភូមិចាស់ៗ និងតាមរបងផ្ទះជាដើម។ ដើមត្នោតខ្លះទៀត ដុះឡើងឯកឯងដោយសារផ្លែវាទុំជ្រុះ ឬដោយសារគេបោះគ្រាប់ទុំចោល។ ក្រៅពីនេះ វាជារុក្ខជាតិដែលមិនលំបាកក្នុងការថែទាំទេ។ រៀងរាល់ឆ្នាំ យើងគ្រាន់តែកាប់តាវចាស់ចេញឱ្យស្រឡះដើមជាការស្រេច។

ដើមត្នោតមានប្រយោជន៍ច្រើនណាស់។ នៅតូចគេកាប់តាវរស់ យកមកដំបូតយកជក់។ គេអាចយកជក់ទៅផ្លុញវិញជាកន្ទុះ ខ្សែជាដើម។ ខ្សែជក់មានគុណភាពល្អជាងខ្សែជ័រ។ ពេលត្នោតចាស់ មានចេញផ្កា គេគាបផ្កាវាត្រងយកទឹកមករំងាស់បានជាស្ករមានរសជាតិផ្អែមឈ្ងុយឆ្ងាញ់។ ផ្លែត្នោតនៅខ្ចី គេកាប់យកស្លែបសាច់ ដែលមានរសជាតិឈ្ងុយឆ្ងាញ់។ បច្ចុប្បន្នមានប្រជាពលរដ្ឋយើងខ្លះកាប់ផ្លែត្នោត យកមកលក់បានប្រាក់សម្រាប់ផ្គត់ផ្គង់គ្រួសារ។ ផ្លែត្នោតទុំ តែងរបេះធ្លាក់ជ្រុះមកដីដោយឯកឯង។ ខ្មែរយើង និយមយកផ្លែត្នោតទុំទៅធ្វើចាហួយ និងនំផ្សេងៗសម្រាប់បរិភោគ។ ធាងត្នោត អាចពុះច្រៀងយកពោះវាមកធ្វើជាខ្សែចំណងផ្សេងៗ។ គេកាប់ស្លឹកត្នោត មកក្រងសម្រាប់ប្រក់ដំបូលផ្ទះ រោង និងលំនៅផ្សេងៗទៀត។ ដើមវា គេអាចពុះច្រៀងយកមកធ្វើជាគ្រឿងសំណង់លំនៅដ្ឋាន សំណង់ផ្សេងៗ និងធ្វើទូកបានទៀតផង។ បច្ចុប្បន្ន នៅតាមសិប្បកម្មកែច្នៃសម្ភារៈមួយចំនួនបានយក ដើមត្នោតមកធ្វើជាវត្ថុប្រើប្រាស់ និងវត្ថុតាំងលម្អផ្សេងៗដែលជាទីពេញនិយមសម្រាប់ភ្ញៀវទេសចរបរទេស។

ដើមត្នោតមានតម្លៃណាស់ខ្មែរយើង ព្រោះវាជាសម្បត្តិតាំងពីដូនតាមក និងជានិមិត្តសញ្ញាជាតិខ្មែរយើង។ ដូច្នេះ ប្រជាជនខ្មែរគ្រប់រូបមិនត្រូវកាប់បំផ្លាញដើមត្នោតនោះទេ។ យើងត្រូវថែរក្សានិងដាំដើមត្នោតបន្ថែមឱ្យបានច្រើននៅតាមលំនៅដ្ឋាន សាលារៀន និងតាមទីសាធារណៈជាដើម។

## ១៣.១.៧- ការសរសេរសំបុត្រសួរសុខទុក្ខ

ប្រធាន: ប្អូនបានឃ្លាតឆ្ងាយពីមិត្តភក្តិរបស់ប្អូនជាយូរមកហើយ។ ចូរប្អូនសរសេរសំបុត្រមួយច្បាប់ ដើម្បីសួរសុខទុក្ខ មិត្តភក្តិប្អូនឱ្យបានក្បោះក្បាយ។

### គម្រោងតែង

**ក- ផ្នែកខាងក្រៅ (ស្រោមសំបុត្រ)**

- ការកាខ្នងសំបុត្រ
  - ចេញពី(ឈ្មោះអ្នកផ្ញើ) ...
  - អាសយដ្ឋាន ...
  - គោរពជូន ឬជូនចំពោះ(ឈ្មោះអ្នកទទួល) ...
  - អាសយដ្ឋាន....។

**ខ- ផ្នែកខាងក្នុង (សំបុត្រ)**

- ក្បាលសំបុត្រ
  - ចុះទីកន្លែង ចុះកាលបរិច្ឆេទនៃការសរសេរ(ចន្ទគតិ សុរិយគតិ...

- ចំណាងជើងសំបុត្រ...។

- **តួសំបុត្រ**
  - រៀបរាប់ពីសុខទុក្ខអ្នកសរសេរ...
  - សួរសុខទុក្ខអ្នកដែលទទួលសំបុត្រ...
  - សរសេររៀបរាប់រឿងរ៉ាវផ្សេងៗមានដូចជា ដំណឹង ការសប្បាយរីករាយ អនុស្សាវរីយ៍ ទុក្ខព្រួយ ដំបូន្មាន សេចក្តីនឹករឭក សកម្មភាពផ្សេងៗ...។

- **ការបញ្ចប់សំបុត្រ**
  - ជូនពរ (ត្រូវប្រើពាក្យឱ្យសមស្របតាមកាលៈទេសៈ ... )
  - ជូនកាលអាចភ្ជាប់ឃ្លាបញ្ចប់សំបុត្រដូចជា ពីកូនកម្សត់របស់ម៉ែ នឹកជានិរន្តរ៍ ពីមិត្តកម្សត់ ពីកល្យាណមិត្តដែលមិនអាចបំភ្លេចបាន...
  - ទីបញ្ចប់ត្រូវចុះហត្ថលេខា និងចុះឈ្មោះអ្នកសរសេរ...។

## ការសរសេរសំបុត្រ

ចេញពី ស៊ាន សេដ្ឋាមុនីរាជ
អាសយដ្ឋាន ផ្ទះលេខ២៥៥ ភូមិក្រសាំងកន្ទ្រៃ
ឃុំជីផុច ស្រុកមេសាង ខេត្តព្រៃវែង

**ជូនចំពោះ ស៊ីដា សុរិយពង្ស**
អាសយដ្ឋាន ផ្ទះលេខ៩ ផ្លូវលេខ២៨២
ភូមិបឹងសាឡាង សង្កាត់ឫស្សីកែង ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ

ថ្ងៃពុធ ៨កើត ខែមាឃឆ្នាំរកា នព្វស័ក ព.ស ២៥៦១
មេសាង ថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៨

**មកដល់សុរិយពង្សជាទីនឹករឭក**!

សុរិយពង្ស! រយៈពេលជាច្រើនខែមកហើយ ដែលខ្ញុំបានឃ្លាតឆ្ងាយពីមិត្ត។ ក្នុងរយៈពេលនេះ ខ្ញុំតែងតែនឹកមមែមកដល់សម្លាញ់ជានិច្ច។ រាត្រីនេះ ខ្ញុំគេងមិនលក់សោះទើបខ្ញុំខិតខំផ្ចង់អារម្មណ៍ រិះរកពាក្យពេចន៍មកសរសេរជាសំបុត្រនេះ។ សម្លាញ់! តើឯងមាននឹករឭកមកដល់ខ្ញុំទេ? តើឯងមានសេចក្តីសុខដែរ ឬយ៉ាងណា? បើឯងមានសេចក្តីសុខ ខ្ញុំពិតជាត្រេកអររកអ្វីមកប្រៀបផ្ទឹមគ្មាន។ ចំណែកខ្ញុំវិញនៅឯនេះ មានសេចក្តីសុខជាធម្មតាទេ ហើយតែងនឹកមកដល់ឯងជានិច្ច។ ខ្ញុំមិនអាចរកពាក្យអ្វីមកសរសេររៀបរាប់ ឱ្យត្រូវនឹងទំហំនៃការនឹករឭករបស់ខ្ញុំចំពោះឯងបានឡើយ។

សុរិយពង្ស! អនុស្សាវរីយ៍របស់យើងទាំងពីរកំពុងដិតនៅជាប់នឹងដួងវិញ្ញាណខ្ញុំជានិច្ច។ យើងធ្លាប់អានសៀវភៅជាមួយគ្នា ធ្វើលំហាត់ជាមួយគ្នា។ យើងទៅណាមកណាពីរនាក់ជានិច្ច។ ឯងឆ្លាតណាស់ឆាប់ចេះ ឆាប់យល់ រហ័សចាំ ហើយឧស្សាហ៍ទៀតផង។ ខ្ញុំមិនដឹងថា សម្លាញ់

នៅចាំរឿងរ៉ាវទាំងនេះដែរ ឬទេ? អូ! ខ្ញុំភ្លេចនិយាយប្រាប់ឯង សព្វថ្ងៃក្រៅពីរៀននៅសាលារដ្ឋ ខ្ញុំរៀនភាសាអង់គ្លេស និងកំព្យូទ័របន្ថែមទៀតនៅសាលារៀនឯកជន។ ឥឡូវខ្ញុំអាចប្រើអ៊ីនធឺណែតបានខ្លះៗហើយ។ ខ្ញុំជឿថា ឯងក៏ចេះប្រើប្រាស់វាដែរនៅពេលខាងមុខ ហើយឆាប់ចេះប្រើជាងខ្ញុំប្រសិនបើឯងបានរៀន។

យប់ជ្រៅណាស់ហើយ ខ្ញុំសូមបញ្ចប់ការចារអក្ខរានេះចុះ។ តាមរយៈសំបុត្រដ៏ខ្លីនេះ ខ្ញុំសូមផ្ញើសេចក្តីនឹករឭកដល់មិត្តភក្តិទាំងអស់ និងអ្នកភូមិយើងផង។ ចុងបញ្ចប់នេះ ខ្ញុំសូមបួងសួងដល់វត្ថុស័ក្តិសិទ្ធិក្នុងលោកតាមជួយថែរក្សាសម្លាញ់ និងក្រុមគ្រួសារឱ្យបានជួបតែសេចក្តីសុខគ្រប់ទិវារាត្រី។

**ពីមិត្តជានិរន្តរ៍**
**សេដ្ឋាមុនីរាជ**

## ១៣.១.៨- ការសរសេរសំបុត្រសុំអភ័យទោស

ប្រធានៈ ថ្ងៃមួយ ប្អូនបានប្រព្រឹត្តខុសចំពោះមិត្តភក្តិរបស់ប្អូន។ ចូរប្អូនសរសេរសំបុត្រមួយច្បាប់ ដើម្បីសុំអភ័យទោសពីមិត្តភក្តិប្អូនឱ្យបានក្បោះក្បាយ។

### គម្រោងតែង

**ក- ផ្នែកខាងក្រៅ (ស្រោមសំបុត្រ)**

- ការកាខ្នងសំបុត្រ
  - ចេញពី(ឈ្មោះអ្នកផ្ញើ) ...
  - អាសយដ្ឋាន ...
  - គោរពជូន ឬជូនចំពោះ(ឈ្មោះអ្នកទទួល) ...
  - អាសយដ្ឋាន ... ។

**ខ- ផ្នែកខាងក្នុង (សំបុត្រ)**

- ក្បាលសំបុត្រ
  - ទីកន្លែង ចុះកាលបរិច្ឆេទនៃការសរសេរ (ចន្ទគតិ សុរិយគតិ...)
  - ចំណងជើងសំបុត្រ ... ។
- តួសំបុត្រ
  - សម្តែងសេចក្តីសោកស្តាយ ...
  - រៀបរាប់រឿងរ៉ាវផ្សេងៗ ដែលខ្លួនបានប្រព្រឹត្តខុស និងប្រាប់ពីមូលហេតុដែលនាំឱ្យខ្លួនប្រព្រឹត្តអំពើនោះ រៀបរាប់ពីអនុស្សាវរីយ៍ និងការយល់ចិត្តគ្នា ... ។
- ការបញ្ចប់សំបុត្រ
  - ជូនពរ(ត្រូវប្រើពាក្យឱ្យសមស្របតាមកាលៈទេសៈ... )
  - ជួនកាលអាចភ្ជាប់ឃ្លាបញ្ចប់សេចក្តីដូចជា ពីកូនរបស់ម៉ែ ពីមិត្តអមតៈ ពីមិត្តជាទីរាប់អាន ពីកល្យាណមិត្តដែលមិនអាចបំភ្លេចបាន សូមមិត្តទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ...
  - ចុងក្រោយចុះហត្ថលេខា និងចុះឈ្មោះអ្នកសរសេរ...។

# ការសរសេរសំបុត្រ

ចេញពី **កែវ មនោរីទ្ធ**
អាសយដ្ឋាន ផ្ទះលេខ៨៥ ផ្លូវលេខ៥៥
ភូមិតាង៉ូវ សង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ

**ជូនចំពោះ យ៉ង់ សន្តិការិកា**
អាសយដ្ឋាន ផ្ទះលេខ២៥ ផ្លូវលេខ០១
ភូមិបឹងឈូក សង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ

ថ្ងៃពុធ៨កើតខែមាឃឆ្នាំរកា នព្វស័ក ព.ស២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៨

**មកដល់សន្តិការិកា ជាទីរាប់អាន**!

សន្តិការិកា! នៅពេលដែលមិត្តលើកសំបុត្រនេះអាន ខ្ញុំពិតជាមានសេចក្តីអៀនខ្មាស ចំពោះមិត្តយ៉ាងខ្លាំង។ ខ្ញុំមានការសោកស្តាយក្រៃលែង ដែលខ្ញុំបានប្រព្រឹត្តខុសឆ្គងមួយមកលើឯងកាលពីម្សិលមិញដោយសារខ្ញុំបានខ្ចីសៀវភៅរបស់ឯង ហើយបានធ្វើឱ្យសៀវភៅនោះបាត់រកមិនឃើញសោះ។

សន្តិការិកា! សូមមិត្តអភ័យទោសឱ្យខ្ញុំផងចុះ ចំពោះកំហុសឆ្គងដោយអចេតនារបស់ខ្ញុំនេះដោយសារខ្ញុំមានការធ្វេសប្រហែស រហូតធ្វើឱ្យបាត់សៀវភៅរបស់ឯងយ៉ាងនេះ។ ខ្ញុំយល់ថា សន្តិការិកាពិតជាអាក់អន់ស្រពន់ចិត្តនឹងខ្ញុំ ខឹងនឹងខ្ញុំ ព្រមទាំងវាយតម្លៃខ្ញុំថា ជាមនុស្សខ្ជីខ្ជា ធ្វេសប្រហែសជាក់ជាមិនខាន។ ទោះបីមិត្តគិតពីខ្ញុំបែបនេះក៏ខ្ញុំព្រមទទួលយកដែរ ព្រោះវាជាកំហុសរបស់ខ្ញុំ។ ខ្ញុំដឹងថាសៀវភៅនោះមានសារៈសំខាន់យ៉ាងខ្លាំងចំពោះមិត្ត ព្រោះមិត្តក៏ធ្លាប់និយាយប្រាប់ខ្ញុំដែរថា វាជារបស់ដែលលោកប៉ារបស់ឯងបានឱ្យ ហើយគាត់បានផ្តាំថា ត្រូវរក្សាវាទុកឱ្យបានល្អ។ ខ្ញុំតែងសង្កេតឃើញថា សន្តិការិកាតែងដាក់សៀវភៅមួយក្បាលនេះតាមខ្លួនជានិច្ច សូម្បីតែពេលគេងក៏ឯងដាក់វាជាប់នឹងខ្លួនដែរ។ លើសពីនេះទៀត សៀវភៅនេះមានខ្លឹមសារល្អណាស់។ វាមានការទាក់ទាញអារម្មណ៍យ៉ាងខ្លាំង ពេលខ្ញុំអានវាម្តងហើយចង់អានម្តងទៀតមិនធុញថប់ឡើយ។ វាជាសៀវភៅដ៏កម្ររកបាន។ ថ្វីត្បិតតែសៀវភៅនេះបានបាត់ទៅ តែវាកំពុងតែស្ថិតនៅនឹងកែវភ្នែកខ្ញុំជានិច្ច។

សៀវភៅបានបាត់ទៅហើយ តែសេចក្តីអាម៉ាស់វាបានចូលមកសណ្ឋិតក្នុងបេះដូងខ្ញុំរហូត។ នេះក៏ព្រោះតែការធ្វេសប្រហែសរបស់ខ្ញុំ។ ខ្ញុំធ្លាប់បានគិតតាំងពីយូរមកហើយថា អ្នកប្រព្រឹត្តខុសត្រូវតែហ៊ានទទួលកំហុសរបស់ខ្លួន។ ដូច្នេះការដែលខ្ញុំធ្វើឱ្យបាត់សៀវភៅនេះ ខ្ញុំក៏ត្រូវតែទទួលខុសត្រូវដែរ ប៉ុន្តែគួរឱ្យស្តាយណាស់បញ្ហានេះ ខ្ញុំមិនមានលទ្ធភាពរកសៀវភៅសងឯងបានវិញឡើយ។ ទោះបីខ្ញុំខំដើររកទិញតាមទីផ្សារ បណ្ណាគារ និងកន្លែងលក់សៀវភៅផ្សេងៗទៀតក៏នៅតែរកមិនបាន។

តាមពិតខ្ញុំចង់ទៅសូមអភ័យទោសពីឯងដោយផ្ទាល់ តែដោយសេចក្តីខ្មាសអៀនធ្វើឱ្យខ្ញុំមិនអាចហាមាត់និយាយផ្ទាល់ចំពោះមុខឯងបានឡើយ។ តាមរយៈសំបុត្រដ៏ខ្លីនេះ ខ្ញុំសូម

សម្តែងការសោកស្តាយចំពោះកំហុសដែលខ្ញុំបានធ្វើ និងសូមមិត្តមេត្តាអភ័យទោសឱ្យខ្ញុំផង ចុះ។ ខ្ញុំសង្ឃឹមជឿជាក់ថា ពេលសន្តិការិកាអានសំបុត្រនេះចប់ ពិតជាអធ្យាស្រ័យដល់ខ្ញុំមិន ខានឡើយ ហើយយើងទាំងពីរនាក់នៅតែជាមិត្តល្អនឹងគ្នាជានិច្ច។ ចុងបញ្ចប់នេះ ខ្ញុំសុំបួងសួង ឱ្យសម្លាញ់ និងក្រុមគ្រួសារបានជួបពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបី ឃ្លៀងឃ្លាតឡើយ។

សូមសន្តិការិកាទទួលនូវការរាប់អានដ៏ស្មោះអំពីខ្ញុំ។

**មនោរឹទ្ធ**

# ១៤- តែងសេចក្តីបែបអត្ថាធិប្បាយពន្យល់

## ១៤.១- ប្រធានអត្ថាធិប្បាយពន្យល់ទូទៅ( ទស្សនៈ ពំនោល មតិ...)

ប្រធានទី១: គេពោលថា «មានវិជ្ជាខ្វះសីលធម៌ នាំឱ្យមានគ្រោះថ្នាក់»។ ចូរបកស្រាយពំនោលខាង លើដោយលើកឧទាហរណ៍មកបញ្ជាក់។

### គម្រោងតែង

**ក- សេចក្តីផ្តើម**

- **លំនាំបញ្ហា:** និយាយទូទៅទាក់ទងនឹងអត្ថប្រយោជន៍នៃចំណេះវិជ្ជានិងការប្រើប្រាស់វិជ្ជាប្រកបដោយ សីលធម៌...
- **ចំណូលបញ្ហា (បង្ហាញបញ្ហា)**: បញ្ចូលខ្លឹមសារប្រធាន... មានវិជ្ជាខ្វះសីលធម៌ នាំឱ្យមានគ្រោះថ្នាក់...
- **ចំណោទបញ្ហា:** ចោទតាមបែបប្រធានពន្យល់... ។

**ខ- តួសេចក្តី**

- **ឃ្លាភ្ជាប់សេចក្តី:** មុននឹងឈានទៅដល់បកស្រាយគំនិតប្រធានឱ្យបានក្បោះក្បាយ យើងគួរយល់ន័យ ពាក្យគន្លឹះជាមុនសិន។
- ពន្យល់ពាក្យគន្លឹះ
  - ✓ **វិជ្ជា:** ចំណេះ ចំណេះដឹងច្បាស់លើផ្នែកផ្សេងៗ។ ចំណេះមានច្រើនដូចជាចំណេះខាងពេទ្យ កសិកម្ម ឧស្សាហកម្ម វិទ្យាសាស្ត្រ។ល។
  - ✓ **សីលធម៌:** ការប្រព្រឹត្តអំពើល្អ  ការមិនប្រមាថ  ដំបូន្មានដែលនាំឱ្យចៀសវាងអំពើអាក្រក់ ការមិន បៀតបៀនជីវិត។ល។
- **ពន្យល់ន័យប្រធាន:** មានចំណេះដឹងច្បាស់លាស់ ជ្រៅជ្រះ បើខ្វះវិចារណញ្ញាណហើយប្រព្រឹត្តអំពើ អាក្រក់នាំឱ្យមានគ្រោះថ្នាក់ ឬជួបមហន្តរាយ។
- បកស្រាយប្រធាន
  - ✓ បើមានចំណេះដឹងជ្រៅជ្រះគ្រប់ជំនាញ ហើយមិនបានប្រកាន់យកវិចារណញ្ញាណ ហើយប្រព្រឹត្តតែ អំពើអាក្រក់នាំឱ្យមានគ្រោះថ្នាក់ ឬជួបមហន្តរាយ។ សមិទ្ធផលនៃវិជ្ជាមានពីរយ៉ាងគឺសមិទ្ធផល បង្កើតឡើងដោយមានក្រមសីលធម៌ និងសមិទ្ធផលបង្កើតឡើងដោយខ្វះក្រមសីលធម៌។

✓សមិទ្ធផលនៃវិជ្ជាប្រកបដោយក្រមសីលធម៌៖ សម្ភារៈបម្រើសេចក្តីត្រូវការរបស់មនុស្ស ថ្នាំពេទ្យ ចំណីអាហារ គ្រឿងកម្សាន្ត បច្ចេកទេសថ្មីៗសម្រាប់បង្កើនចំណេះដឹងរបស់មនុស្ស។ ជាតួយ៉ាង ដូចជាការផលិតឱសថសម្រាប់ព្យាបាលជំងឺ ការផលិតវ៉ាក់សាំងដើម្បីការពារជំងឺ ការផលិតទូរស័ព្ទ សម្រាប់ធ្វើទំនាក់ទំនងគ្នា ការផលិតយន្តហោះសម្រាប់ជាមធ្យាបាយធ្វើដំណើរ។ល។

✓សមិទ្ធផលនៃវិជ្ជាដោយគ្មានក្រមសីលធម៌: ថ្នាំពុល យន្តហោះចម្បាំង អាវុធយុទ្ធភ័ណ្ឌ សម្រាប់ សម្លាប់មនុស្ស ប្រល័យលោក សម្ភារៈបច្ចេកទេសសម្រាប់សម្លាប់មនុស្ស សម្ភារៈ បច្ចេកទេស សម្រាប់បំផ្លាញបរិស្ថាន...។ ជាក់ស្តែងនៅក្នុងសង្គ្រាមលោកលើកទីពីរ អាមេរិចបានទម្លាក់គ្រាប់ បែកនៅហ៊ីរ៉ូស៊ីម៉ា ប្រទេសជប៉ុន បង្កវិនាសកម្មយ៉ាងធំធេង...។

✓សមិទ្ធផលនៃវិជ្ជាដោយគ្មានក្រមសីលធម៌ : ការបង្កើតរោងចក្រផលិតសម្ភារៈ បច្ចេកទេសនាំឱ្យ សម្រាប់បំផ្លាញបរិស្ថាន...។ ជាក់ស្តែងបច្ចុប្បន្នការបញ្ចេញឧស្ម័នពុលពីរោងចក្រ បានធ្វើឱ្យផែនដី ឡើងកម្តៅ មានការប្រែប្រួលអាកាសធាតុ...។

- សរុប: មានវិជ្ជា ខ្វះសីលធម៌នាំឱ្យមានគ្រោះមហន្តរាយ...។

**គ- សេចក្តីបញ្ចប់**

- វាយតម្លៃប្រធាន: ដូច្នេះប្រធាននេះមានន័យជ្រាលជ្រៅ... សម្រាប់អប់រំមនុស្សទូទៅ....។
- យោបល់ផ្ទាល់ខ្លួន: យើងជាសិស្សត្រូវ...។

## សេចក្តីអធិប្បាយ

ដោយសារវិជ្ជា មនុស្សបានក្លាយជាសត្វលោកដ៏អស្ចារ្យជាងសត្វផងទាំងពួងលើពិភពលោកនេះ អាចស្វែងយល់ច្បាស់ពីអាថ៌កំបាំងធម្មជាតិអាចគ្រប់គ្រងពិភពលោកនិងចក្រវាឡបាន។ ប៉ុន្តែវិជ្ជាក៏ អាចធ្វើឱ្យសង្គមមនុស្សមានគ្រោះថ្នាក់ ឬក៏ជួបគ្រោះមហន្តរាយដ៏ធ្ងន់ធ្ងរផងដែរ ព្រោះតែសមិទ្ធផលនៃ វិជ្ជាខ្វះសីលធម៌ ខ្វះវិចារណញ្ញាណ។ ហេតុដូច្នេះហើយ បានជាមានពំនោលមួយពោលថា "មានវិជ្ជាខ្វះ សីលធម៌ នាំឱ្យមានគ្រោះថ្នាក់"។

តើពំនោលនេះមានអត្ថន័យយ៉ាងណា?

មុននឹងឈានទៅដល់ការបកស្រាយគំនិតប្រធានឱ្យបានក្បោះក្បាយ យើងគួរយល់ន័យប្រធានតាម រយៈខ្លឹមសារពាក្យគន្លឹះជាមុនសិនដូចជាពាក្យ វិជ្ជា សីលធម៌។ វិជ្ជាមានន័យថា ចំណេះ ចំណេះដឹងច្បាស់ លើផ្នែកផ្សេងៗ។ ចំណេះមានច្រើនដូចជា ចំណេះខាងពេទ្យ កសិកម្ម ឧស្សាហកម្ម វិទ្យាសាស្ត្រជា ដើម។ ចំណែកសីលធម៌មានន័យថា ការប្រព្រឹត្តអំពើល្អ ការមិនប្រមាថ ដំបូន្មានដែលនាំឱ្យចៀសវាង អំពើអាក្រក់ ការមិនបៀតបៀនជីវិតមនុស្ស សត្វនានា។ ដូច្នេះប្រធានខាងលើមានន័យថា បើមាន ចំណេះដឹងច្បាស់លាស់ជ្រៅជ្រះ ហើយខ្វះវិចារណញ្ញាណ ប្រព្រឹត្តអំពើអាក្រក់នាំឱ្យមានគ្រោះថ្នាក់ ឬ ជួបមហន្តរាយ ដល់ខ្លួនឯង និងអ្នកដទៃ។

ជាការពិតណាស់ បើមនុស្សយើងមានចំណេះដឹងជ្រៅជ្រះគ្រប់ជំនាញ ហើយមិនបានប្រកាន់ យកវិចារណញ្ញាណ ប្រព្រឹត្តតែអំពើអាក្រក់នាំឱ្យមានគ្រោះថ្នាក់ ឬជួបមហន្តរាយមិនខានឡើយ ព្រោះ យើងដឹងហើយថា សមិទ្ធផលនៃវិជ្ជាមានពីរយ៉ាងគឺ សមិទ្ធផលបង្កើតឡើងដោយមានក្រមសីលធម៌ និងសមិទ្ធផលបង្កើតឡើងដោយខ្វះក្រមសីលធម៌។

សមិទ្ធផលនៃវិជ្ជាប្រកបដោយក្រមសីលធម៌ មានការផលិតសម្ភារៈបម្រើឱ្យសេចក្តីត្រូវការរបស់មនុស្សដូចជាម៉ូតូ រថយន្ត យន្តហោះ កប៉ាល់ នាវាដឹកជញ្ជូនអ្នកដំណើរ ម៉ាស៊ីនច្រូត បោកស្រូវ កិនស្រូវ ម៉ាស៊ីនភ្លើង សម្ភារៈពេទ្យ សម្ភារៈសំណង់ សម្ភារៈប្រើប្រាស់ក្នុងផ្ទះជាដើម។ ថ្នាំពេទ្យសម្រាប់ព្យាបាលជំងឺផ្សេងៗ ចំណីអាហារសម្រាប់មនុស្ស សត្វ គ្រឿងកម្សាន្តដូចជា ម៉ាញ៉េ វិទ្យុ ទូរទស្សន៍ ភាពយន្ត វីដេអូ បច្ចេកទេសថ្មីៗ សម្រាប់បង្កើនចំណេះដឹងរបស់មនុស្សក្នុងការរុករក និងស្រាវជ្រាវ។

សមិទ្ធផលនៃវិជ្ជាមួយចំនួន ដែលបានបង្កើតឡើងសម្រាប់បម្រើមហិច្ឆតា អសីលធម៌ ជាគ្រឿងសម្រាប់សម្លាប់សត្វ មនុស្ស និងបំផ្លាញពិភពលោកដូចជា ថ្នាំពុល កាំភ្លើងតូចធំ រថក្រោះ នាវាចម្បាំង យន្តហោះចម្បាំង អាវុធគីមី គ្រាប់មីន គ្រាប់បែកបរមាណូនុយក្លេអ៊ែរជាដើម។ គ្រឿងប្រហារទាំងអស់នេះ សុទ្ធតែកើតឡើងពីចំណេះវិជ្ជានេះឯង។ ជាក់ស្តែងដូចកាលពីនៅក្នុងសង្គ្រាមលោកលើកទីពីរ អាមេរិកបានទម្លាក់គ្រាប់បែកនៅហ៊ីរ៉ូស៊ីម៉ាប្រទេសជប៉ុន បង្កវិនាសកម្មយ៉ាងធំធេង សម្លាប់ជីវិតមនុស្ស បំផ្លាញហេដ្ឋារចនាសម្ព័ន្ធគ្រប់បែបយ៉ាង។ ម្យ៉ាងទៀត ការបង្កើតរោងចក្រផលិតសម្ភារៈបច្ចេកទេស នាំឱ្យសម្រាប់បំផ្លាញបរិស្ថាន។ ជាក់ស្តែងបច្ចុប្បន្នការបញ្ចេញឧស្ម័នពុលពីរោងចក្រ បានធ្វើឱ្យផែនដីឡើងកម្តៅ មានការប្រែប្រួលអាកាសធាតុ។ល។

សរុបមក វិជ្ជានិងសីលធម៌ជាចរន្តពីរ និងជាគុណសម្បត្តិពីរដែលមិនអាចកាត់ផ្តាច់ពីគ្នាបានទេគឺត្រូវដើរទន្ទឹមគ្នា។ បើមានតែវិជ្ជាខ្វះសីលធម៌ គឺពិតជានាំមកនូវគ្រោះថ្នាក់ដល់មនុស្ស សត្វ រុក្ខជាតិ និងពិភពលោកទាំងមូលជាពុំខានឡើយ។

ដូច្នេះប្រធាននេះមានន័យជ្រាលជ្រៅ សម្រាប់អប់រំមនុស្សទូទៅគ្រប់ជាតិសាសន៍លើពិភពលោកនេះឱ្យប្រកាន់ខ្ជាប់នូវតម្លៃសីលធម៌ តម្លៃជីវិត លះបង់មហិច្ឆតាល្មោភសង្គ្រាម បញ្ឈប់ការផលិតអាវុធប្រល័យលោក ពិសេសប្រទេសមហាអំណាចដែលតែងរកលេសបង្កសង្គ្រាមជាមួយប្រទេសទន់ខ្សោយដើម្បីបំពេញមហិច្ឆតាខ្លួន។ យើងជាសិស្សត្រូវ ខិតខំរៀនសូត្រឱ្យមានចំណេះវិជ្ជា និងចូលរួមចំណែកអភិវឌ្ឍសង្គមជាតិ ព្រមទាំងប្រកាន់ខ្ជាប់នូវក្រមសីលធម៌ ដើម្បីឱ្យក្លាយខ្លួនជាពលរដ្ឋល្អ រួមរស់ជាមួយគ្នាប្រកបដោយសុខសន្តិភាព។

---

**ប្រធានទី២:** អ្នកបរិស្ថានវិទ្យាមួយរូបថ្លែងរំឭកថា «ការប្រែប្រួលអាកាសធាតុបានបង្កជាគុណវិបត្តិដល់ជីវិតមនុស្ស»។ តើគុណវិបត្តិនោះ មានលក្ខណៈយ៉ាងណាខ្លះ? ចូរអ្នកបកស្រាយទស្សនៈខាងលើនេះ ដោយរកឧទាហរណ៍បញ្ជាក់។

---

## គម្រោងតែង

### ក- សេចក្តីផ្តើម

- **លំនាំបញ្ហា:** និយាយទាក់ទងនឹងបញ្ហាទូទៅនៃការប្រែប្រួលអាកាសធាតុ.....។
- **ចំណូលបញ្ហា(បង្ហាញបញ្ហា):** បញ្ចូលប្រធាន...ការប្រែប្រួលអាកាសធាតុបានបង្កជាគុណវិបត្តិដល់ជីវិតមនុស្ស... ។
- **ចំណោទបញ្ហា:** ចោទតាមបែបប្រធានពន្យល់ ... តើការប្រែប្រួលអាកាសបង្កជាគុណវិបត្តិម្តេចខ្លះ?

**ខ- តួសេចក្តី**

- **ឃ្លាភ្ជាប់សេចក្តី**: មុននឹងឈានទៅដល់បកស្រាយគំនិតប្រធានឱ្យបានក្បោះក្បាយ យើងគួរយល់ន័យពាក្យគន្លឹះជាមុនសិន... ។
- ពន្យល់ពាក្យគន្លឹះ
  - ✓ ការប្រែប្រួលអាកាសធាតុ: សំដៅទៅលើការខុសប្រក្រតីនៃអាកាសធាតុ គឺជាការប្រែប្រួលសីតុណ្ហភាព របបទឹកភ្លៀង របបខ្យល់ក្នុងរយៈពេលច្រើន សតវត្សរ៍ ឬរយៈពេលវែងជាងនេះ...។
  - ✓ គុណវិបត្តិ: គឺជាផលអាក្រក់ ដែលនាំទៅរកគ្រោះមហន្តរាយ... ។
- ពន្យល់ន័យប្រធានៈ ប្រធានមានន័យថា ការប្រែប្រួលអាកាសធាតុខុសប្រក្រតី បានបង្កជាផលអាក្រក់...។
- បកស្រាយប្រធានៈ
  - ✓ ការរស់នៅរបស់មនុស្ស សត្វ រុក្ខជាតិមិនអាចកាត់ផ្តាច់ចេញពីធម្មជាតិ...។
  - ✓ ការប្រែប្រួលទាំងនេះបណ្តាលមកពីកត្តាមនុស្ស និង...។
  - ✓ ការប្រែប្រួលអាកាសធាតុបង្កឱ្យខូចបរិស្ថាន...។
  - ✓ ការប្រែប្រួលអាកាសធាតុបង្កឱ្យប៉ះពាល់សុខភាព...។
  - ✓ ការប្រែប្រួលអាកាសធាតុបង្កឱ្យមានគ្រោះធម្មជាតិ...។
  - ✓ វិធានការការពារបរិស្ថាន...។
- **សរុប**: ការប្រែប្រួលអាកាសធាតុ ពិតជាបានបង្កជាគុណវិបត្តិដល់ជីវិតមនុស្សប្រាកដមែន...។

**គ- សេចក្តីបញ្ចប់**

- វាយតម្លៃប្រធាន : ... ទស្សនៈប្រធានមានអត្ថន័យអប់រំយ៉ាង វិសេសវិសាលបំផុត ព្រោះបានបំផុស
- ស្មារតីឱ្យយើងគ្រប់គ្នា ចេះប្រមើលមើលពីផលអវិជ្ជមាន...។
- យោបល់ផ្ទាល់ខ្លួន : ដូច្នេះ ក្នុងនាមជាអ្នកសិក្សាយើងគប្បីរួបរួមគ្នាថែរក្សាបរិស្ថានរស់នៅប្រកប
- ដោយអនាម័យ ចេះសន្សំសំចៃថាមពល ជាពិសេសចូលរួមដាំដើមឈើ...។

## សេចក្តីអធិប្បាយ

មនុស្សគ្រប់រូបលើលោកយើងនេះរមែងតែងតែប្រាថ្នាចង់បានសេចក្តីសុខ ប្រកបដោយសុភមង្គលក្នុងគ្រួសារ ហើយខិតខំរកមធ្យោបាយគ្រប់យ៉ាង ដើម្បីបញ្ចៀសពីទុក្ខលំបាកឬគ្រោះមហន្តរាយ ដែលមកយាយីគ្រួសារខ្លួនជាដរាប។ ដោយយល់ពីគោលបំណងដូចខាងលើនេះហើយ ទើបអ្នកបរិស្ថានវិទ្យាមួយរូបថ្លែងរំឭកថា "ការប្រែប្រួលអាកាសធាតុបានបង្កជាគុណវិបត្តិដល់ជីវិតមនុស្ស"។

តើការប្រែប្រួលអាកាសបង្កជាគុណវិបត្តិដូចម្តេចខ្លះ?

ដើម្បីជាជំនួយដល់ការបកស្រាយគំនិតប្រធានខាងលើឱ្យបានក្បោះក្បាយយើងគប្បីស្វែងយល់ន័យនៃកន្សោមពាក្យគន្លឹះរបស់ប្រធានជាមុនសិនគឺពាក្យ "ការប្រែប្រួលអាកាសធាតុគុណវិបត្តិ" នៅពេលនេះគឺសំដៅទៅលើភាពខុសប្រក្រតីនៃអាកាសធាតុ គឺជាការប្រែប្រួលសីតុណ្ហភាព របបទឹកភ្លៀង របបខ្យល់ក្នុងរយៈពេលច្រើន សតវត្សរ៍ ឬរយៈពេលវែងជាងនេះ។ រីឯ "គុណវិបត្តិ" គឺជាផលអាក្រក់

ដែលនាំទៅរកគ្រោះមហន្តរាយ។ ដូច្នេះគំនិតប្រធានមានន័យថា ការប្រែប្រួលអាកាសធាតុខុសប្រក្រតី បានបង្កជាផលអាក្រក់ចំពោះជីវិតមនុស្សដែលងាយរងគ្រោះដោយសារតែធម្មជាតិ។

ជាការពិតណាស់ ការរស់នៅរបស់មនុស្ស សត្វ រុក្ខជាតិមិនអាចកាត់ផ្តាច់ចេញពីបរិស្ថានធម្មជាតិបានទេ។ បរិស្ថានធម្មជាតិ ជាកត្តាកំណត់នូវស្ថិរភាពអាកាសធាតុ របបទឹកភ្លៀង រក្សាសីតុណ្ហភាព របបខ្យល់ជាដើម។ បើសិនជាធម្មជាតិប្រែប្រួលឬមានការផ្លាស់ប្តូរ ពេលនោះអាកាសធាតុក៏ប្រែប្រួល គឺជំរុញឱ្យទាំងរបបខ្យល់ ទឹកភ្លៀង សីតុណ្ហភាពក៏មានការប្រែប្រួលដែរ។

ការប្រែប្រួលអាកាសធាតុ បណ្តាលមកពីកត្តាមនុស្សខ្លួនឯង និងកត្តាធម្មជាតិផងដែរ។ តួយ៉ាង ចំពោះកត្តាមនុស្ស បានកើតចេញតាមរយៈឧស្ម័នផ្ទះកញ្ចក់ ដែលជាសកម្មភាពមនុស្ស ដោយការដុតឥន្ធនៈហ្វូស៊ីល ការកាប់ព្រៃឈើ ការធ្វើកសិកម្ម ការចិញ្ចឹមសត្វ ការចាក់សំរាមចោល និងសកម្មភាពឧស្សាហកម្មជាដើម។ មានន័យថា ដោយសារតែតម្រូវការរបស់មនុស្សពីមួយថ្ងៃទៅមួយថ្ងៃ មនុស្សពុំបានគិតដល់បញ្ហាខាងលើនេះឡើយ។ គេនិយមប្រើឥន្ធនៈជាថាមពលយានយន្តគ្រប់ប្រភេទ ជាពិសេសក្នុងវិស័យឧស្សាហកម្មពុំគិតពីផលប៉ះពាល់ដល់បរិស្ថាន។ ការចោលកាកសំណល់គ្រប់ប្រភេទ ដោយពុំបានបន្សុទ្ធជាមុនៗ និងការបញ្ចេញមកខាងក្រៅនូវកាកសំណល់តាមរោងចក្រនានាការពុំបានញែកសំរាម និងទុកដាក់ឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេសជាដើម។ មិនតែប៉ុណ្ណោះការកាប់ព្រៃឈើដើម្បីរានដីធ្វើកសិកម្ម ឬដើម្បីធ្វើអាជីវកម្ម ដោយពុំបានដាំឡើងវិញ ជាហេតុធ្វើឱ្យបាត់បង់តុល្យភាពអេកូឡូស៊ីក៏បង្កឱ្យខូចបរិស្ថាន គឺធ្វើឱ្យមានការប្រែប្រួលអាកាសធាតុ។ បានសេចក្តីថា ដោយសារតែសកម្មភាពរបស់មនុស្ស បានបង្កជាគុណវិបត្តិចំពោះខ្លួនឯងនាំឱ្យកើតជាជំងឺផ្សេងៗដូចជាមហារីកស្បែក រោគកន្ទួយថ្លែនភ្នែក ជំងឺគ្រុនចាញ់ ជំងឺគ្រុនឈាមជាដើម។

ជាមួយគ្នានេះដែរ ការប្រែប្រួលអាកាសធាតុក៏បណ្តាលមកពីកត្តាធម្មជាតិដូចជា បន្ទុះភ្នំភ្លើង ការប្រែប្រួលចរន្តខ្យល់ ការប្រែប្រួលថាមពលព្រះអាទិត្យ ការប្រែប្រួលឃឹតៗនៅក្នុងគន្លងផែនដីជុំវិញព្រះអាទិត្យ និងការប្រែប្រួលចរន្តទឹកសមុទ្រជាដើម។ កត្តាខាងលើនេះក៏ជាមូលហេតុមួយទៀតដែលកាន់តែបង្កផលអាក្រក់ចំពោះជីវិតមនុស្សថែមទៀតផង។ បើសិនជាមនុស្សពុំមានការទទួលខុសត្រូវ ឬគ្មានវិធានការការពារបរិស្ថានឱ្យទាន់ពេលវេលានោះទេ ផលវិបាកដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ ដោយការបំផ្លាញបរិស្ថាន នឹងកាន់តែមានសភាពធ្ងន់ធ្ងរថែមទៀត ដោយជៀសមិនរួចឡើយនាពេលបច្ចុប្បន្ន និងនាពេលអនាគត។

សរុបសេចក្តីមកការប្រែប្រួលអាកាសធាតុ ពិតជាបានបង្កជាគុណវិបត្តិដល់ជីវិតមនុស្សប្រាកដមែន។

ឆ្លងតាមការបកស្រាយខាងលើនេះបានបញ្ជាក់ថា ទស្សនៈប្រធានមានអត្ថន័យអប់រំយ៉ាងវិសេសវិសាលបំផុត ព្រោះបានបំផុសស្មារតីឱ្យយើងគ្រប់គ្នាចេះប្រមើលមើលពីផលអវិជ្ជមាននៃការប្រែប្រួលអាកាសធាតុចំពោះជីវិតមនុស្ស។ ដូច្នេះក្នុងនាមជាអ្នកសិក្សា យើងគប្បីរួបរួមគ្នាថែរក្សាបរិស្ថានរស់នៅប្រកបដោយអនាម័យ ចេះសន្សំសំចៃថាមពល ជាពិសេសចូលរួមដាំដើមឈើដើម្បីជាគុណប្រយោជន៍ដល់ជីវិតយើងទាំងអស់គ្នា។

**ប្រធានទី៣:** មានទស្សនៈមួយពោលថា៖ «ការគោរពខ្លួនឯង ជាការកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍»។ ចូរអ្នកពន្យល់ទស្សនៈខាងលើនេះដោយរកឧទាហរណ៍មកបញ្ជាក់។

## គម្រោងតែង

### ក- សេចក្ដីផ្ដើម

- **លំនាំបញ្ហា**: និយាយទាក់ទងនឹងបញ្ហាទូទៅនៃស្ថានភាពចរាចរណ៍...គ្រោះថ្នាក់ចរាចរណ៍...។
- **ចំណូលបញ្ហា(បង្ហាញបញ្ហា)**: បញ្ចូលប្រធាន ...ការគោរពខ្លួនឯង ជាការកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍... ។
- **ចំណោទបញ្ហា**: ចោទតាមបែបប្រធានពន្យល់...តើទស្សនៈខាងលើនេះមានអត្ថន័យយ៉ាងណាខ្លះ?

### ខ- តួសេចក្ដី

- ឃ្លាភ្ជាប់សេចក្ដី: ... ដើម្បីជំនួយដល់ការបកស្រាយគំនិតប្រធានខាងលើឱ្យបានក្បោះក្បាយ យើងគប្បីស្វែងយល់ន័យនៃកន្សោមពាក្យគន្លឹះរបស់ប្រធានជាមុនសិន...។
- ពន្យល់ពាក្យគន្លឹះ
  - ✓ ការគោរពខ្លួនឯង: មានន័យថា ជាការទទួលខុសត្រូវលើខ្លួន ឯងប្រកបដោយមនសិការ និងវិចារណ:...។
  - ✓ គ្រោះថ្នាក់ចរាចរណ៍: ជាគ្រោះថ្នាក់ដែលបង្កឡើងដោយសារតែយានយន្ត និងយានយន្ត ឬយានយន្តនឹងអ្នកដំណើរលើទ្រូងផ្លូវប៉ះទង្គិចគ្នាដោយចៃដន្យណាមួយ...។
- ពន្យល់ន័យប្រធាន: ប្រធានមានន័យថា ការទទួលខុសត្រូវលើខ្លួនឯងជាការកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ក្នុងពេលធ្វើដំណើរនៅលើទ្រូងផ្លូវ...។
- បកស្រាយប្រធាន៖
  - ✓ គ្រោះថ្នាក់ចរាចរណ៍ តែងតែកើតឡើងដោយចៃដន្យ...។
  - ✓ គ្រោះថ្នាក់ចរាចរណ៍ កើតឡើងដោយការបើកបរខ្វះការប្រុងប្រយ័ត្ន ...។
  - ✓ ការគោរពខ្លួនឯងអាចកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ ...។
  - ✓ ការគោរពច្បាប់អាចកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ ...។
- **សរុប**: ការគោរពខ្លួនឯងពិតជាការកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ប្រាកដមែន។ បើសិនជាមនុស្សម្នាក់ៗ ចេះគោរពខ្លួនឯង គឺចេះប្រុងប្រយ័ត្នក្នុងពេលបើកបរ ឬចេះគោរពច្បាប់ចរាចរណ៍នោះ គ្រោះថ្នាក់ចរាចរណ៍នឹងត្រូវកាត់បន្ថយជាមិនខាន។

### គ- សេចក្ដីបញ្ចប់

- វាយតម្លៃប្រធាន: ឆ្លងតាមការបកស្រាយខាងលើនេះ បានបង្ហាញឱ្យឃើញថា ទស្សនៈប្រធានពិតជាមានអត្ថន័យជ្រាលជ្រៅក្នុងការអប់រំព្រោះបានរំឭកដាសតឿនដល់អ្នកបើកបរ...។
- យោបល់ផ្ទាល់ខ្លួន : ...ដូច្នេះក្នុងនាមជាយុវជន គប្បីចូលរួមគោរពច្បាប់ចរាចរណ៍ទាំងអស់គ្នា ដើម្បីជៀសផុតពីគ្រោះថ្នាក់ផ្សេងៗ ដែលបណ្ដាលមកពីការបើកបររបស់ខ្លួន ដែលធ្វើឱ្យសង្គមជាតិទាំងមូលបាត់បង់សណ្ដាប់ធ្នាប់...។

# សេចក្ដីអធិប្បាយ

គ្រោះថ្នាក់ចរាចរណ៍ជាប្រការមួយគួរឱ្យចាប់អារម្មណ៍បំផុតពីសំណាក់មនុស្សគ្រប់រូបក្នុងសង្គម។ វាតែងតែកើតមានឡើងជាញឹកញាប់នៅតាមដងវិថីនានា។ ដោយមានការចាប់អារម្មណ៍និងចង់រំឭកដល់មនុស្សគ្រប់រូប ឱ្យចេះប្រុងប្រយ័ត្នក្នុងការធ្វើដំណើរបែបនេះហើយទើបមានទស្សនៈមួយពោលថា "ការគោរពខ្លួនឯង ជាការកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍"។

តើទស្សនៈខាងលើនេះមានអត្ថន័យយ៉ាងណាខ្លះ?

ដើម្បីជាជំនួយដល់ការបកស្រាយគំនិតប្រធានខាងលើនេះឱ្យបានក្បោះក្បាយ យើងគប្បីស្វែងយល់នូវន័យនៃកន្សោមពាក្យគន្លឹះជាមុនសិនដូចជាពាក្យ "ការកោរពខ្លួនឯង គ្រោះថ្នាក់ចរាចរណ៍"។ "ការគោរពខ្លួនឯង" នៅពេលនេះមានន័យថា ជាការទទួលខុសត្រូវលើខ្លួនឯងប្រកបដោយមនសិការនិងវិចារណញ្ញាណ។ រីឯ "គ្រោះថ្នាក់ចរាចរណ៍" ជាគ្រោះថ្នាក់ដែលបង្កឡើងដោយសារតែយានយន្តនិងយានយន្ត ឬយានយន្តនឹងអ្នកដំណើរលើទ្រូងផ្លូវប៉ះទង្គិចគ្នាដោយចៃដន្យណាមួយ។ ដូច្នេះតាមគំនិតប្រធានមានន័យថា ការទទួលខុសត្រូវលើខ្លួនឯង ជាការកាត់បន្ថយគ្រោះថ្នាក់ក្នុងពេលធ្វើដំណើរនៅលើដងផ្លូវ។

ជាការពិតណាស់ មនុស្សគ្រប់រូបតែងតែមានចេតនាចង់បញ្ចៀសគ្រប់គ្រោះថ្នាក់ទាំងឡាយឱ្យរួចផុត សូមកុំឱ្យខ្លួនជួបប្រទះសោះឡើយ។ ប៉ុន្តែគ្រោះថ្នាក់ វាតែងតែកើតឡើងដោយចៃដន្យ គ្មានគ្រោងទុកជាមុនទេ គួបផ្សំនឹងយើងមានការធ្វេសប្រហែសនោះ វាអាចកើតឡើងក្នុងរយៈពេលតែមួយប៉ព្រិចភ្នែកប៉ុណ្ណោះ។ ដោយឡែកចំពោះគ្រោះថ្នាក់ចរាចរណ៍ បើសិនជាម្នាក់ៗបើកបរដោយមានការប្រុងប្រយ័ត្ន កុំធ្វេសប្រហែស ជាពិសេសគឺចេះគោរពខ្លួនឯងនោះ គ្រោះថ្នាក់ចរាចរណ៍ពិតជាអាចកាត់បន្ថយបានយ៉ាងច្រើនបំផុត។ ជាក់ស្ដែងក្នុងការបើកបរសព្វថ្ងៃ គេសង្កេតឃើញមានបុគ្គលមួយចំនួនពុំចេះគោរពខ្លួនឯងនូវក្រមសីលធម៌ជាអ្នកបើកបរនោះឡើយ។ ដោយបុគ្គលទាំងនោះ ធ្វើយ៉ាងណាឱ្យតែខ្លួនឆាប់បានទៅដល់គោលដៅតាមបំណងរបស់ខ្លួនតែប៉ុណ្ណោះ។ យ៉ាងនេះហើយបានជាក្នុងពេលបើកបរ គេឃើញមានបុគ្គលខ្លះច្រើនតែពុំសូវយកចិត្តទុកដាក់ឬពិនិត្យស្ថានការណ៍ចំពោះមុខនោះឡើយ ទោះបីផ្លូវខាងមុខចង្អៀតមានអ្នកថ្មើរជើងច្រើនយ៉ាងណាក៏ដោយ ក៏មិនបង្អង់ល្បឿនស្របតាមស្ថានភាពនោះដែរ។ បុគ្គលខ្លះទៀតពេលបើកបរយានយន្តបណ្ដើរ ឆ្លៀតនិយាយទូរស័ព្ទបណ្ដើរដោយពុំគិតដល់អារម្មណ៍អ្នកបើកបរ ឬអ្នកដំណើរលើទ្រូងផ្លូវជាមួយគ្នានោះឡើយ។ ដោយហេតុថាការនិយាយទូរស័ព្ទក្នុងពេលបើកបរនេះ មានផលអាក្រក់ដោយសារតែអ្នកបើកបរធ្វេសប្រហែសដោយការប្រើល្បឿនពុំសមស្របអាចលឿនជ្រុល ឬអាចយឺតជ្រុលរំខានដល់ពេលវេលាអ្នកដំណើរដទៃទៀត។ ជាងនេះទៅទៀត មានបុគ្គលមួយចំនួនពុំចេះខ្មាសអៀន ឬចេះគោរពខ្លួនឯងនោះ ព្រោះពុំបានគោរពផ្លាកសញ្ញាចរាចរណ៍ ភ្លើងសញ្ញាចរាចរណ៍។ ដូចជានៅតាមតំបន់ប្រជុំជន មានផ្លូវខ្វែងជាច្រើនផ្លូវ ក្នុងករណីដែលពុំមានភ្នាក់ងារចរាចរណ៍ គេបែរជាមិនបង្អង់ល្បឿនឬបញ្ឈប់យានយន្តរង់ចាំភ្លើងសញ្ញាអាទិភាពឱ្យខ្លួនចេញដំណើរនោះទេ។ ឥរិយាបថនេះបានធ្វើឱ្យខូចសណ្ដាប់ធ្នាប់ចរាចរណ៍ ជាពិសេសអាចបង្កគ្រោះថ្នាក់ដល់អ្នកឯទៀតរហូតត្រូវបាត់បង់អាយុជីវិតក៏មានដែរ។

បុគ្គលខ្លះទៀតពុំមានការទទួលខុសត្រូវ ចតយានយន្តគ្មានសណ្ដាប់ធ្នាប់នៅលើទ្រូងផ្លូវសាធារណៈបង្កការលំបាកធ្វើឱ្យរាំងស្ទះចរាចរណ៍។ ពេលខ្លះទៀត គេពុំបានប្រុងប្រយ័ត្នក្នុងការប្រើ

ភ្លើងសញ្ញាយានយន្តរបស់ខ្លួនទេ គឺប្រើខាងឆ្វេងតែបែរទៅជាបត់ខាងស្តាំដៃទៅវិញ។ ទង្វើបែបនេះនាំឱ្យងាយរងទទួលគ្រោះថ្នាក់ចំពោះអ្នកបើកបរ និងអ្នកជិះជាមួយនៅខាងក្រោយខ្លួន។ ទន្ទឹមនឹងនេះ មានបុគ្គលខ្លះទៀតបាត់បង់វិចារណញ្ញាណពុំគោរពខ្លួនឯង គឺបើកបរទាំងខ្លួនកំពុងស្រវឹងទៅបុកនឹងជញ្ជាំងខណ្ឌចែកទ្រូងផ្លូវ ឬទៅបុកបង្គោលភ្លើងបំភ្លឺ ឬក៏បើកបរចូលបន្ទាត់អាទិភាពនៃយានយន្តដទៃទៀត បង្កឱ្យមានគ្រោះថ្នាក់ចំពោះខ្លួនឯងរួមទាំងអ្នកធ្វើដំណើរជាមួយគ្នាទៀតផង។ ទោះជាយ៉ាងនេះក្តី នៅតាមទីសាធារណៈគេតែងសង្កេតឃើញមានយុវវ័យយើងមួយចំនួនដែលពុំចេះគោរពខ្លួនឯង។ ពួកគេតែងជួបជុំគ្នាដើម្បីប្រណាំងម៉ូតូ ឬរថយន្ត ជួនកាលទៀតពួកគេនាំគ្នាបង្ហោះម៉ូតូនៅលើផ្លូវសាធារណៈដែលអាចបង្កគ្រោះថ្នាក់ដល់អ្នកដទៃ។ ក្រៅពីនេះទៀត គេនាំគ្នាបើកជែងរហូតត្រូវធ្លាក់ផ្លូវទៀតផងក៏មានដែរ ព្រមទាំងនាំគ្នាជាច្រើនបើកបរម៉ូតូដោយមិនពាក់មួកសុវត្ថិភាព ហើយជិះស្រែកហ៊ោកញ្ជៀវធ្វើឱ្យបាត់បង់សណ្តាប់ធ្នាប់សាធារណៈទៀតផង។

សរុបសេចក្តីមកការគោរពខ្លួនឯង ពិតជាការកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ប្រាកដមែន។ បើសិនជាមនុស្សម្នាក់ៗ ចេះគោរពខ្លួនឯងគឺចេះប្រុងប្រយ័ត្នក្នុងពេលបើកបរ ឬចេះគោរពច្បាប់ចរាចរណ៍នោះគ្រោះថ្នាក់ចរាចរណ៍នឹងត្រូវកាត់បន្ថយជាមិនខាន។

ឆ្លងតាមការបកស្រាយខាងលើនេះ បានបង្ហាញឱ្យឃើញថា ទស្សនៈប្រធានពិតជាមានអត្ថន័យជ្រាលជ្រៅក្នុងការអប់រំ ព្រោះបានរំឭកដាស់តឿនដល់អ្នកបើកបរយានយន្តនៅលើទ្រូងផ្លូវទាំងអស់ឱ្យចេះគោរពច្បាប់ចរាចរណ៍នៅពេលបើកបរ មានការអធ្យាស្រ័យគ្នាក្នុងពេលបើកបរ។ ដូច្នេះក្នុងនាមជាយុវជនគប្បីចូលរួមគោរពច្បាប់ចរាចរណ៍ទាំងអស់គ្នាដើម្បីជៀសផុតពីគ្រោះថ្នាក់ចរាចរណ៍ផ្សេងៗ ដែលបណ្តាលមកពីការបើកបររបស់ខ្លួននិងធ្វើឱ្យសង្គមជាតិទាំងមូលបាត់បង់សណ្តាប់ធ្នាប់ដោយសារតែខ្លួនពុំគោរពច្បាប់នោះ។

---

**ប្រធាន៩:** មានមតិមួយពោលថា «ការសេពគ្រឿងញៀននាំមកនូវសេចក្តីវិនាសដល់ខ្លួន»។ ចូរពន្យល់ឱ្យបានក្បោះក្បាយ និងលើកឧទាហរណ៍មកបញ្ជាក់។

---

## គម្រោងតែង

### ក- សេចក្តីផ្តើម

- **លំនាំបញ្ហា:** និយាយពីបញ្ហាទូទៅទាក់ទងនឹងស្ថានភាពគ្រឿងញៀននៅប្រទេសកម្ពុជាយើងសព្វថ្ងៃ...។
- **ចំណូលបញ្ហា(បង្ហាញបញ្ហា):** បញ្ចូលប្រធាន...ការសេពគ្រឿងញៀននាំមកនូវសេចក្តីវិនាសដល់ខ្លួន...។
- **ចំណោទបញ្ហា:** ចោទតាមបែបប្រធានពន្យល់ (តើការសេពគ្រឿងញៀនបាននាំមកនូវសេចក្តីវិនាសដល់ខ្លួនដូចម្តេចខ្លះ ?

### ខ- តួសេចក្តី

- **ឃ្លាភ្ជាប់សេចក្តី:** ...ជាដំបូងដើម្បីជាជំនួយដល់ការបកស្រាយប្រធានឱ្យកាន់តែក្បោះក្បាយថែមទៀតនោះ យើងគប្បីយល់នូវន័យនៃពាក្យគន្លឹះមួយចំនួនជាមុនសិន...។
- **ពន្យល់ពាក្យគន្លឹះ**
  - ✓ ការសេព : ... ជាការប្រើប្រាស់ ប៊ឺត ហិត ជក់...។

- ✓ គ្រឿងញៀន : ...គឺជាសារធាតុញៀន ឬថ្នាំញៀនខុសច្បាប់ ធ្វើឱ្យមនុស្សដែលបានសាកល្បង ឬប្រើប្រាស់វាញៀនញ៉ាម...។
- ✓ វិនាស : គឺការបាត់បង់ សាបសូន្យ អន្តរាយ...។

- **ពន្យល់ន័យប្រធាន:** ដូច្នេះប្រធានមានន័យថា ... ការប្រើប្រាស់សារធាតុញៀន ឬថ្នាំញៀនខុសច្បាប់ ធ្វើឱ្យមនុស្សដែលបានសាកល្បង ឬប្រើប្រាស់វាញៀនញ៉ាម រហូតបណ្ដាលឱ្យមានការបាត់បង់ភាពសាបសូន្យ និងសេចក្ដីអន្តរាយដល់ខ្លួន...។
- **បកស្រាយប្រធានៈ**
  - ✓ គ្រឿងញៀន បានធ្វើឱ្យអ្នកប្រើប្រាស់បាត់បង់ស្មារតី ប៉ះពាល់សុខភាព... ។
  - ✓ គ្រឿងញៀន បានធ្វើឱ្យអ្នកប្រើប្រាស់ខូចអនាគត... ។
  - ✓ គ្រឿងញៀន បានធ្វើឱ្យអ្នកប្រើប្រាស់បាត់បង់អ្វីៗគ្រប់យ៉ាង រួមទាំងជីវិតទៀតផង...។
  - ✓ ឧទាហរណ៍ជាក់ស្ដែងដែលកើតមានក្នុងសង្គម...។
- **សរុបសេចក្ដី:** ...គ្រឿងញៀនវាបានបំផ្លាញដល់អ្នកដែលប្រើប្រាស់ជក់ សេពវានូវសុខភាពរូបរាងកាយ អនាគត កិត្តិយស បាត់បង់សុភមង្គល ត្រូវអ្នកជិតខាងស្អប់ខ្ពើម គ្រួសារកាត់កាលចោលទៀតផង។ ពេលយើងប្រើប្រាស់វា នាំយើងឈានទៅរកក្ដីវិនាសគ្រប់បែបយ៉ាង សូម្បីតែជីវិតរបស់ខ្លួន...។

**គ- សេចក្ដីបញ្ចប់**

- **វាយតម្លៃប្រធាន:** ប្រធានខាងលើបាន...ផ្ដល់តម្លៃអប់រំយ៉ាងល្អឱ្យយើងដឹងនូវគុណវិបត្តិនៃការប្រើប្រាស់គ្រឿងញៀន ផលប៉ះពាល់នៃការប្រើប្រាស់គ្រឿងញៀន និងសេចក្ដីវិនាសអន្តរាយរបស់អ្នកសេពគ្រឿងញៀន... ។
- **យោបល់ផ្ទាល់ខ្លួន:** ដូច្នេះក្នុងនាមយើងជាអ្នកសិក្សា ត្រូវតែជៀសឱ្យឆ្ងាយពីគ្រឿងញៀនត្រូវឆ្លើយថា ទេចំពោះគ្រឿងញៀន យើងមិនត្រូវឱ្យគ្រឿងញៀនមកបំផ្លាញអនាគត ធ្វើឱ្យយើងជួបនូវក្ដីអន្តរាយនោះឡើយ។ យើងត្រូវជួយពន្យល់ណែនាំមិត្តភក្តិ បងប្អូន អ្នកជិតខាង ឱ្យជៀសឆ្ងាយពីគ្រឿង...។

## សេចក្ដីអធិប្បាយ

មនុស្សណាក៏ដោយឱ្យតែចង់ប៉ះពាល់ ស្គាល់រសជាតិនៃគ្រឿងញៀន ហើយយកវាមកសេព ឬជក់នោះប្រាកដណាស់ថា ខ្លួនរបស់គេនឹងបាត់បង់អ្វីៗគ្រប់យ៉ាង ដែលជាហេតុនាំទៅរកក្ដីវិនាសនាពេលខាងមុខជាក់ជាពុំខាននោះឡើយ។ ហេតុដូច្នេះហើយទើបបានជាមានមតិមួយលើកឡើងថា "ការសេពគ្រឿងញៀននាំមកនូវសេចក្ដីវិនាសដល់ខ្លួន"។

តើការសេពគ្រឿងញៀននាំមកនូវសេចក្ដីវិនាសដល់ខ្លួនដូចម្ដេចខ្លះ?

ជាដំបូងដើម្បីជាជំនួយដល់ការបកស្រាយប្រធានឱ្យកាន់តែក្បោះក្បាយថែមទៀតនោះ យើងគប្បីយល់នូវន័យនៃពាក្យគន្លឹះមួយចំនួនជាមុនសិនគឺពាក្យ " ការសេព វិនាស "។ ការសេពមានន័យថា ជាការប្រើប្រាស់ ប៊ឺត ហិត ជក់។ គ្រឿងញៀនគឺជាសារធាតុញៀនឬថ្នាំញៀនខុសច្បាប់ ធ្វើឱ្យអ្នកដែលបានសាកល្បង ឬប្រើប្រាស់វាញៀនញ៉ាម។ ឯពាក្យវិនាសមានន័យថា គឺការបាត់បង់ ភាពសាបសូន្យ សេចក្ដីអន្តរាយ។ ដូច្នេះប្រធានមានន័យថា ការប្រើប្រាស់ ប៊ឺត ហិត ជក់នូវសារធាតុញៀន ឬថ្នាំញៀនខុសច្បាប់ ធ្វើឱ្យមនុស្សដែលបានសាកល្បង ឬប្រើប្រាស់វាញៀនញ៉ាម រហូតបណ្ដាលឱ្យមានការបាត់បង់ ភាពសាបសូន្យ និងសេចក្ដីអន្តរាយដល់ខ្លួនជាក់ជាពុំខានឡើយ។

ជាការពិតណាស់គ្រឿងញៀន គឺជាសារធាតុញៀនឬថ្នាំញៀនខុសច្បាប់។ ប្រសិនបើមាននរណាម្នាក់ហ៊ានប្រើប្រាស់វាយូរៗទៅ វានឹងបណ្តាលឱ្យអ្នកនោះជួបនូវសេចក្តីវិនាសអន្តរាយជាក់ជាពុំខាន។ វាបានធ្វើឱ្យអ្នកប្រើប្រាស់ខូចសុខភាព គឺបានធ្វើឱ្យរាងកាយមានសភាពទ្រុឌទ្រោម ស្លេកស្លាំង ខ្សោយអស់កម្លាំង។ អ្វីដែលធ្ងន់ធ្ងរជាងនេះទៅទៀតនោះគឺ វាបានទៅបំផ្លាញប្រព័ន្ធប្រាសាទ ធ្វើឱ្យបាត់បង់ការចងចាំយូរៗទៅខូចសតិអារម្មណ៍ទៅជាឆ្កួតលីលាថែមទៀតផង។ សេចក្តីវិនាសផ្សេងទៀតនោះគឺធ្វើឱ្យជនដែលប្រើប្រាស់គ្រឿងញៀននោះខូចអនាគត ព្រោះពួកគេមិនចូលរៀនមានបក្សពួកដើរលេងបងធំ បងតូច ជាដើម។ បើនៅក្នុងថ្នាក់រៀនវិញគេមិនស្តាប់គ្រូពន្យល់ គេលែងគិតពីការរៀនសូត្រ លែងនិយាយរកមិត្តភក្តិបន្តិចម្តងៗគេឈប់រៀន បោះបង់ការសិក្សា ជាហេតុនាំឱ្យគេគ្មានចំណេះក្នុងខ្លួនគ្មានការងារធ្វើដើរប៉ោឡែជាដើម។ ចំណែកមិត្តភក្តិក៏គេឈប់រាប់អាន អ្នកជិតខាងមានការរើសអើងលែងនិយាយរាប់រកបាត់បង់ភាពស្និតស្នាលដូចមុន។ នោះធ្វើឱ្យអ្នកញៀនមានភាពឯកោ ចូលមិនចុះជាមួយគេឯងរស់នៅលាក់មុខលាក់មាត់។ ការវិនាសមួយផ្នែកទៀតនោះគឺគេបាត់បង់សុភមង្គលគ្មានភាពកក់ក្តៅដោយសារសមាជិកគ្រួសារនីមួយៗខឹង ស្អប់ ឬអាចកាត់កាលចោលផងក៏ថាបាន។ មួយវិញទៀតនោះ ពេលអស់លុយទិញថ្នាំញៀន គេអាចទៅលួច ឆក់ ប្លន់ ប្រសិនណាគេចាប់បានគេវាយដំ ប្តឹងប៉ូលីស ជាប់គុកជាប់ច្រវាក់។ ម៉្យាងទៀត មិនយូរមិនឆាប់សារធាតុញៀននឹងធ្វើទុក្ខរហូតដល់អ្នកជក់ អ្នកប្រើប្រាស់គ្រឿងញៀននោះបាត់បង់ជីវិត។ភស្តុតាងជាក់ស្តែងនៃអ្នកសេពគ្រឿងញៀន គឺយើងតែងតែបានឮ ឬដឹងព័ត៌មានតាមវិទ្យុ ទូរទស្សន៍ កាសែតជាដើមផ្សាយថា ចាប់បានអ្នកគ្រឿងញៀន ឬចាប់បានចោរឆក់ ចោរលួចដោយមានពាក់ព័ន្ធនឹងគ្រឿងញៀន ព័ត៌មានខ្លះផ្សាយថា ដោយសេចក្តីត្រូវការគ្រឿងញៀន អ្នកញៀនថ្នាំហ៊ានធ្វើអ្វីៗគ្រប់យ៉ាង រហូតក្លាយជាឃាតកសម្លាប់មនុស្ស។ ខ្លះទៀតផ្សាយថា ដោយសារការទ្រាំមិនបាននូវការឈឺចាប់ពេលគ្រឿងញៀនធ្វើទុក្ខម្តងៗ ពួកគេបានសម្រេចចិត្តធ្វើអត្តឃាតខ្លួនឯងក៏មាន។

សរុបសេចក្តីមក គ្រឿងញៀនវាបានបំផ្លាញដល់អ្នកដែលប្រើប្រាស់យ៉ាងធ្ងន់ធ្ងរដូចជា ប៉ះពាល់សុខភាព រូបរាងកាយទ្រុឌទ្រោម ខូចអនាគត បាត់បង់កិត្តិយស បាត់បង់សុភមង្គល ត្រូវអ្នកជិតខាងស្អប់ខ្ពើម គ្រួសារកាត់កាលចោលទៀតផង។ អ្នកប្រើប្រាស់គ្រឿងញៀន តែងតែរងនូវសេចក្តីវិនាសគ្រប់បែបយ៉ាង ហើយអាចឈានទៅដល់បាត់អាយុជីវិតថែមទៀតផង។

ឆ្លងតាមការបកស្រាយខាងលើយើងឃើញថា ប្រធាននេះមានអត្ថន័យដ៏ជ្រាលជ្រៅបំផុតដោយបានផ្តល់នូវតម្លៃអប់រំយ៉ាងល្អៗសម្រាប់ធ្វើឱ្យយើងដឹងពីគុណវិបត្តិនៃការប្រើប្រាស់គ្រឿងញៀន ផលប៉ះពាល់នៃការប្រើប្រាស់គ្រឿងញៀន និងសេចក្តីវិនាសអន្តរាយរបស់អ្នកសេពគ្រឿងញៀន។ ដូច្នេះក្នុងនាមយើងជាអ្នកសិក្សា ត្រូវតែជៀសវាងឱ្យឆ្ងាយពីគ្រឿងញៀន ត្រូវឆ្លើយថាទេចំពោះគ្រឿងញៀន យើងមិនត្រូវឱ្យគ្រឿងញៀនមកបំផ្លាញអនាគតធ្វើឱ្យយើងជួបនូវក្តីអន្តរាយនោះឡើយ។ យើងត្រូវជួយពន្យល់ណែនាំមិត្តភក្តិ បងប្អូន អ្នកជិតខាង ឱ្យជៀសឆ្ងាយពីគ្រឿងញៀន និងត្រូវខិតខំរៀនសូត្រដើម្បីអភិវឌ្ឍខ្លួនឯង គ្រួសារ និងសង្គមជាតិ។

ប្រធាន៥: មានមតិមួយពោលឡើងថា «ការអប់រំ គឺជាកាតព្វកិច្ចរបស់យើងទាំងអស់គ្នា»។ ចូរពន្យល់ពំនោលនេះឱ្យបានក្បោះក្បាយ។

## គម្រោងតែង

### ក- សេចក្តីផ្តើម

- **លំនាំបញ្ហា:** និយាយទូទៅទាក់ទងនឹងការអប់រំ គឺជាតួនាទីរបស់យើងគ្រប់គ្នា ដើម្បីកូនចៅជំនាន់ក្រោយរបស់យើង...
- **ចំណូលបញ្ហា(បង្ហាញបញ្ហា):** បញ្ចូលប្រធាន...ការអប់រំ គឺជាកាតព្វកិច្ចរបស់យើងទាំងអស់គ្នា...
- **ចំណោទបញ្ហា:** ...ចោទតាមបែបប្រធានពន្យល់...តើប្រធានខាងលើមានអត្ថន័យដូចម្តេច...។

### ខ- តួសេចក្តី

- **ឃ្លាភ្ជាប់សេចក្តី** ...មុននឹងឈានចូលដល់ការបកស្រាយប្រធានខាងលើនេះ ឱ្យកាន់តែពិស្តារថែមទៀតនោះ យើងគួរយល់ន័យនៃពាក្យមួយចំនួនសិន... ។
- ពន្យល់ពាក្យគន្លឹះ៖
  - ✓ ការអប់រំ : គឺការផ្តល់ចំណេះដឹង ការបណ្តុះបណ្តាល ការទូន្មានប្រៀនប្រដៅ...
  - ✓ កាតព្វកិច្ច : ការងារ ឬកិច្ចការដែលត្រូវតែធ្វើកិច្ចដែលគួរធ្វើ... ។
- **ពន្យល់ន័យប្រធាន:** ដូច្នេះប្រធាន... ការផ្តល់ចំណេះដឹង ការបណ្តុះបណ្តាល ការទូន្មានប្រៀនប្រដៅ គឺជាការងាររបស់យើងទាំងអស់គ្នា.. ។
- បកស្រាយប្រធាន៖
  - ✓ ការអប់រំរបស់គ្រួសារ...
  - ✓ ការអប់រំរបស់សាលា....
  - ✓ ការអប់រំរបស់សហគមន៍...
  - ✓ ឧទាហរណ៍ជាក់ស្តែងដែលកើតមានក្នុងសង្គម....។
- **សរុបសេចក្តី:** មនុស្សគ្រប់រូបត្រូវមានតួនាទីអប់រំមនុស្សទាំងអស់គ្នា តាំងពីពួកគេកើតមករហូតធំដឹងក្តី ដើម្បីឱ្យគេចេះរស់នៅក្នុងសង្គមបានយ៉ាងស្រួល...។

### គ- សេចក្តីបញ្ចប់

- **វាយតម្លៃប្រធាន:** ប្រធានខាងលើនេះបានអប់រំ...ដែលបានបង្ហាញពីតួនាទីដ៏សំខាន់របស់យើងទាំងអស់គ្នាក្នុងការទទួលខុសត្រូវ លើការអប់រំកុលបុត្រកុលធីតាជំនាន់ក្រោយឱ្យមានចំណេះដឹងខ្ពស់ មានសមត្ថភាពខ្ពស់...
- **យោបល់ផ្ទាល់ខ្លួន:** ដូច្នេះក្នុងនាមយើងជាអ្នកសិក្សាត្រូវខិតខំរៀនសូត្រ ... ដើម្បីយកចំណេះដឹងទាំងនោះមកជួយអប់រំមនុស្សជំនាន់...ក្រោយឱ្យមានចំណេះដឹងអាចរស់នៅក្នុងសង្គម...។

## សេចក្តីអធិប្បាយ

ក្នុងសង្គមមនុស្ស ដើម្បីឱ្យអ្នកជំនាន់ក្រោយមានចំណេះដឹង នោះវាជាតួនាទីរបស់មនុស្សជំនាន់មុនជួយផ្តល់ចំណេះដឹងដល់ពួកគាត់។ ម្យ៉ាងទៀត មនុស្សគ្រប់រូបត្រូវការចំណេះដឹងជាចាំបាច់ក្នុងជីវិតរស់នៅប្រចាំថ្ងៃ។ ទាំងនេះវាជាកាតាព្វកិច្ចរបស់យើងទាំងអស់គ្នាក្នុងការផ្តល់ចំណេះដឹងដល់ពួកគេទាំង

នោះ។ អាស្រ័យដោយមានការយល់ឃើញដូចនេះហើយទើបមានមតិមួយពោលឡើងថា "ការអប់រំ គឺជាកាតព្វកិច្ចរបស់យើងទាំងអស់គ្នា"។

តើប្រធានខាងលើនេះមានខ្លឹមសារយ៉ាងដូចម្តេច?

មុននឹងឈានចូលដល់ការបកស្រាយប្រធានខាងលើនេះឱ្យកាន់តែពិស្តារថែមទៀតនោះ យើងគួរយល់ន័យនៃពាក្យគន្លឹះមួយចំនួនសិនគឺពាក្យ "ការអប់រំ កាតព្វកិច្ច"។ ការអប់រំ គឺការផ្តល់ចំណេះដឹង ការបណ្តុះបណ្តាល ការបង្ហាត់បង្ហាញ ការទូន្មានប្រៀនប្រដៅ។ ឯពាក្យ កាតព្វកិច្ច ក្នុងន័យនេះ គឺមានន័យថា ការងារឬកិច្ចការដែលត្រូវតែធ្វើ កិច្ចដែលគួរធ្វើ។ ដូច្នេះន័យរបស់ប្រធាន គឺការផ្តល់ចំណេះដឹង ការបណ្តុះបណ្តាល ការទូន្មានប្រៀនប្រដៅ ដល់កូនចៅជំនាន់ក្រោយឱ្យមានចំណេះដឹង គឺជាការងារឬកិច្ចការដែលយើងទាំងអស់គ្នាត្រូវតែធ្វើ។

ជាការពិតណាស់មនុស្សយើងគ្រប់រូបកើតមក គឺត្រូវការចំណេះដឹង មានអ្នកបង្ហាត់បង្ហាញ តម្រែតម្រង់ពួកគេតាំងតែពីតូចក្រូចឆ្មាររហូតដល់ធំពេញវ័យ។ ការផ្តល់ចំណេះដឹងដល់មនុស្ស គឺក្នុងគោលបំណងឱ្យមនុស្សអាចរស់នៅក្នុងសង្គមបានប្រកបដោយសុខសន្តិភាព។ ក្នុងការផ្តល់ចំណេះដឹងដល់ពួកគេ វាជាតួនាទីរបស់យើងគ្រប់ៗគ្នា។ ពេលមនុស្សទើបកើតមក គឺរស់នៅក្រោមការចិញ្ចឹមបីបាច់ថែរក្សាពីឪពុកម្តាយ។ នេះហើយគឺជាតួនាទីរបស់ឪពុកម្តាយក្នុងការអប់រំកូនខ្លួន។ ដូចជាឪពុកម្តាយបង្រៀនកូនឱ្យចេះនិយាយ ឱ្យចេះដើរ ចេះស្គាល់ចាស់ទុំ បងប្អូន មានសីលធម៌ និងសុជីវធម៌ជាដើម។ ក្រៅពីការអប់រំតាមគ្រួសារ សាលារៀនក៏មានតួនាទីអប់រំសំខាន់ណាស់ដែរ។ ពេលកូនធំដឹងក្តីឡើងកាលណា ឪពុកម្តាយឬអ្នកអាណាព្យាបាលបានបញ្ជូនកូនទៅចូលសាលារៀន ដែលត្រូវឱ្យលោកគ្រូ អ្នកគ្រូ គណៈគ្រប់គ្រងសាលាជួយហាត់ពត់ លត់ដំបន្ត និងផ្តល់ចំណេះដឹងដូចជាភាសាខ្មែរ ប្រវត្តិវិទ្យា ភូមិវិទ្យា រូបវិទ្យា គីមីវិទ្យា គណិតវិទ្យា ភាសាអង់គ្លេស បច្ចេកវិទ្យាទំនាក់ទំនងព័ត៌មាន និងបំណិនជីវិតជាដើម ដើម្បីឱ្យសិស្សយកទៅប្រើប្រាស់ពេលពួកគេចេញពីសាលាទៅរស់នៅប្រចាំថ្ងៃក្នុងសង្គម។

ការអប់រំ មិនមែនមានតួនាទីត្រឹមតែឪពុកម្តាយឬអ្នកអាណាព្យាបាលនិងលោកគ្រូ អ្នកគ្រូប៉ុណ្ណោះទេ។ សង្គមក៏មានតួនាទីយ៉ាងសំខាន់ សម្រាប់អប់រំមនុស្សផងដែរ។ គេថាសង្គមបែបណា ប្រជាពលរដ្ឋក្នុងសង្គមនោះក៏ទៅជាបែបនោះ។ ដូច្នេះសង្គមត្រូវជួយគិតគូរពីការអប់រំពលរដ្ឋរបស់ខ្លួនឱ្យមានដូចជាការជួយលើកទឹកចិត្ត ការជួយសាងសង់អគារសិក្សាជាដើម។ ក្រៅពីនេះសង្គម ត្រូវរៀបចំរចនាសម្ព័ន្ធគ្រប់គ្រង រៀបចំបង្កើតប្រព័ន្ធច្បាប់ សម្រាប់គ្រប់គ្រងប្រជាពលរដ្ឋ ក៏ដូចជាអប់រំប្រជាពលរដ្ឋឱ្យចេះគោរពច្បាប់ជាដើម។ ជាក់ស្តែងបើសង្គមបំផុសបំផុលឱ្យពលរដ្ឋចេះចូលរួម ចេះជួយគ្នាទៅវិញទៅមក មានសាមគ្គីភាព នោះពលរដ្ឋក្នុងសង្គមនោះរស់នៅមានភាពសុខសាន្ត។

សរុបសេចក្តីមកការអប់រំមនុស្សគ្រប់រូបគឺជាតួនាទីរបស់យើងទាំងអស់គ្នាមានម្តាយឪពុកឬអ្នកអាណាព្យាបាល សាលារៀន និងសង្គម តាំងពីពួកគេកើតមករហូតធំដឹងក្តី ដើម្បីឱ្យគេចេះរស់នៅក្នុងសង្គមបានសុខស្រួល។

ប្រធានខាងលើមានអត្ថន័យអប់រំយ៉ាងជ្រាលជ្រៅ ដែលបានបង្ហាញពីតួនាទីដ៏សំខាន់របស់យើងទាំងអស់គ្នាក្នុងការទទួលខុសត្រូវ លើការអប់រំកុលបុត្រកុលធីតាជំនាន់ក្រោយ ឱ្យមានចំណេះដឹងខ្ពស់ មានសមត្ថភាពខ្ពស់។ ដូច្នេះក្នុងនាមយើងជាអ្នកសិក្សា ត្រូវខិតខំរៀនសូត្រដើម្បីយកចំណេះទាំងនោះមក ជួយអប់រំមនុស្សជំនាន់ក្រោយ ឱ្យមានចំណេះដឹងអាចរស់នៅក្នុងសង្គមប្រកបដោយភាពសុខដុមរមនា។

**ប្រធានបទទី៦:** ទស្សនៈមួយលើកឡើងថា «ស្មារតីរឹងប៉ឹងនិងការតស៊ូជាមូលដ្ឋាននៃសុភមង្គល»។ ចូរពន្យល់ដោយលើកឧទាហរណ៍ក្នុងសង្គម និងស្នាដៃអក្សរសិល្ប៍មកបញ្ជាក់។

## គម្រោងតែង

### ក- សេចក្តីផ្តើម

- **លំនាំបញ្ហា:** និយាយទូទៅទាក់ទងនឹងជីវភាពជាក់ស្តែង... ប្រភពនៃសុភមង្គលរបស់យើងគ្រប់គ្នា...
- **ចំណូលបញ្ហា(បង្ហាញបញ្ហា):** បញ្ចូលប្រធាន... ស្មារតីរឹងប៉ឹង និងការតស៊ូជាមូលដ្ឋាននៃសុភមង្គល...
- **ចំណោទបញ្ហា:** ...ចោទតាមបែបប្រធានពន្យល់... តើទស្សនៈខាងលើមានអត្ថន័យដូចម្តេច?

### ខ- តួសេចក្តី

- **ឃ្លាភ្ជាប់សេចក្តី:** ...មុននឹងឈានចូលដល់ការបកស្រាយប្រធានខាងលើនេះឱ្យកាន់តែពិស្តារថែមទៀតនោះ យើងគួរយល់ន័យនៃពាក្យមួយចំនួនសិន...។
- **ពន្យល់ពាក្យគន្លឹះ៖**
  - ✓ ស្មារតីរឹងប៉ឹង: មានន័យថា ភាពរឹងមាំខាងផ្លូវចិត្ត ភាពរឹងមាំខាងផ្លូវអារម្មណ៍ ភាពម៉ឺងម៉ាត់ ការមានលំនឹងល្អផ្នែកស្មារតី...
  - ✓ ការតស៊ូ: គឺសំដៅយកការអត់ធ្មត់ ការពុះពារ ការខិតខំប្រឹងប្រែង...
  - ✓ សុភមង្គល: សម្គាល់លើសេចក្តីសុខ សេចក្តីសប្បាយចិត្ត...។
- **ពន្យល់ន័យប្រធាន:** ដូច្នេះទស្សនៈខាងលើមានន័យថា អ្នកដែលមានភាពរឹងមាំ ខាងផ្លូវចិត្ត ភាពរឹងមាំខាងផ្លូវអារម្មណ៍ប្រកបដោយការអត់ធ្មត់ ការពុះពារ ការប្រឹងប្រែង ដែលជាប្រភពនៃសេចក្តីសុខកាយសប្បាយចិត្ត...។
- **បកស្រាយប្រធាន៖**
  - ✓ ស្មារតីរឹងប៉ឹង និងការតស៊ូជាមូលដ្ឋាននៃសុភមង្គល...
  - ✓ ឧទាហរណ៍ក្នុងសង្គម : សិស្សតស៊ូរៀនសូត្រ...
  - ✓ ឧទាហរណ៍ ក្នុងអក្សរសិល្ប៍ : រឿងកុលាបប៉ៃលិន តួអង្គចៅចិត្រ...
  - ✓ ឧទាហរណ៍ ក្នុងអក្សរសិល្ប៍ : រឿងគ្រូពេទ្យជើងបួន តួអង្គកុម្ភៈកុមារ....................។
- **សរុបសេចក្តីមក** ការលើកបង្ហាញតាមរយៈសង្គមជាក់ស្តែងក្តី ...បញ្ជាក់បានថាស្មារតីរឹងប៉ឹងនិងការតស៊ូពិតជាមូលដ្ឋាននៃសុភមង្គលប្រាកដមែន។

### គ- យោបល់បញ្ចប់

- **វាយតម្លៃប្រធាន:** ទស្សនៈមួយឃ្លានេះ មានអត្ថន័យល្អប្រសើរណាស់ក្នុងគំនិតអប់រំឱ្យមានស្មារតីរឹងប៉ឹងគួបផ្សំនឹងការតស៊ូដើម្បីសុភមង្គលខ្លួនឯង គ្រួសារ និងសង្គមជាតិ...
- **យោបល់ផ្ទាល់ខ្លួន:** ដូច្នេះសិស្សគ្រប់រូប ត្រូវបំពាក់គោលជំហរឱ្យបានរឹងប៉ឹងក្នុងការតស៊ូស្វែងរកចំណេះដឹង និងចំណេះធ្វើមកជាទុនសម្រាប់ជីវិតខ្លួនឈានទៅរកសុភមង្គល... ។

## សេចក្តីអធិប្បាយ

មនុស្សគ្រប់រូបដែលរស់នៅក្នុងលោកសន្និវាសយើងនេះតែងមានបំណងប្រាថ្នាដូចៗគ្នាគឺចង់ឱ្យជីវិតរស់នៅរបស់ខ្លួនប្រកបដោយសុភមង្គល។ ដើម្បីទទួលបានសុភមង្គល អ្នកប្រាជ្ញក្តី អ្នកនិពន្ធក្តី កវី

ក្តី តែងផ្តល់នូវដំបូន្មាន គំនិត យោបល់ និងទស្សនៈប្លែកៗពីគ្នា។ ក្នុងចំណោមនោះក៏មានទស្សនៈមួយបានលើកឡើងថា "ស្មារតីរឹងប៉ឹង និងការតស៊ូជាមូលដ្ឋាននៃសុភមង្គល"។

តើទស្សនៈខាងលើនេះ មានអត្ថន័យយ៉ាងដូចម្តេចខ្លះ?

ដើម្បីជាជំនួយដល់ការបកស្រាយទស្សនៈខាងលើឱ្យបានក្បោះក្បាយ យើងគប្បីយល់នូវន័យនៃពាក្យ"ស្មារតីរឹងប៉ឹង ការតស៊ូ និងសុភមង្គល"ជាមុនសិន។ ពាក្យ ស្មារតីរឹងប៉ឹង មានន័យថា ភាពរឹងមាំខាងផ្លូវចិត្ត ភាពរឹងមាំខាងផ្លូវអារម្មណ៍ ភាពម៉ឺងម៉ាត់ ការមានលំនឹងល្អផ្នែកស្មារតី។ ឯពាក្យ ការតស៊ូ មានន័យសំដៅយកការអត់ធ្មត់ ការពុះពារ ការខិតខំប្រឹងប្រែង។ ចំណែកឯពាក្យសុភមង្គលមានន័យថា សេចក្តីសុខកាយសេចក្តីសប្បាយចិត្ត។ ដូច្នេះទស្សនៈខាងលើមានន័យថា អ្នកដែលមានភាពរឹងមាំខាងផ្លូវចិត្តភាពរឹងមាំខាងផ្លូវ អារម្មណ៍ប្រកបដោយការអត់ធ្មត់ ការពុះពារ ការខិតខំប្រឹងប្រែង ដែលជាប្រភពនៃសេចក្តីសុខកាយសប្បាយចិត្តដែលជាមូលដ្ឋាននៃសុភមង្គល។

ជាការពិតណាស់ហើយដែលទស្សនៈខាងលើបានលើកឡើងថា ស្មារតីរឹងប៉ឹង និងការតស៊ូជាមូលដ្ឋាននៃសុភមង្គល ព្រោះថាបើយើងធ្វើការអង្កេតក្នុងសង្គមបរិយាកាសបច្ចុប្បន្ន អ្នកមានស្មារតីរឹងប៉ឹងប្រកបដោយមានការតស៊ូតែងតែជួបនូវសុភមង្គលពិតៗ។ ករណីសិស្សទាំងឡាយដែលបានខិតខំប្រឹងប្រែងព្យាយាមរៀនសូត្រយ៉ាងម៉ឺងម៉ាត់តាមកម្មវិធីសិក្សា ដែលក្រសួងអប់រំបានដាក់ឱ្យអនុវត្តដោយពុំមានងាករេ ស្ទាក់ស្ទើរ រវើរវាយតាមការអូសទាញទៅរកផ្លូវខុសនៃជនដទៃ សិស្សនោះរមែងទទួលបាននូវលទ្ធផលល្អក្នុងការសិក្សា។ ការខិតខំប្រឹងប្រែងសិក្សារៀនសូត្រនឹងទទួលបានចំណេះដឹង អាចប្រកបរបរចិញ្ចឹមជីវិត មានអនាគតភ្លឺស្វាង។ កត្តានេះហើយ ដែលធ្វើឱ្យមនុស្សរស់នៅប្រកបដោយសុភមង្គល។

បើពិនិត្យក្នុងស្នាដៃអក្សរសិល្ប៍វិញម្តង ឃើញថារឿងកុលាបប៉ៃលិនក៏បានបង្ហាញពីតួអង្គចៅចិត្រថ្វីត្បិតតែខ្លួនជួបនឹងភាពកំព្រាឪពុកនិងភាពក្រីក្រ ប៉ុន្តែចៅចិត្រនៅតែមានស្មារតីរឹងប៉ឹងនិងការតស៊ូធ្វើការងារជាកម្មករជីកត្បូង ទោះបីត្រូវជួបប្រទះនឹងការងារជីកត្បូងក្នុងមួយថ្ងៃប្រាំទៅប្រាំមួយម៉ោងក្រោមកម្តៅថ្ងៃ ភ្លៀង ខ្យល់យ៉ាងណាក៏ដោយ ក៏ចៅចិត្រប្រឹងប្រែងបំពេញដោយឥតរួញរា។ លើសពីនេះទៀតចៅចិត្រមានភាពរឹងមាំតស៊ូទប់ទល់ជាមួយក្រុមចោរមួយជាពីរលើកដើម្បីជួយលោកហ្លួងរតនសម្បត្តិដែលជាចៅហ្វាយនាយ ដោយទឹកចិត្តស្មោះត្រង់ មិនខ្លាចនឿយហត់ឬបាត់បង់ជីវិតឡើយ។ ស្មារតីរឹងប៉ឹងនិងការតស៊ូយ៉ាងខ្លាំងក្លារបស់ចៅចិត្រនេះហើយ ដែលធ្វើឱ្យចៅចិត្រត្រូវបានឃុននារី និងហ្លួងរតនសម្បត្តិជ្រើសរើសជាគូអនាគត និងកូនប្រសា។ បើនិយាយទៅក្នុងរឿងគ្រូពេទ្យជើងបួន ឃើញថាតួអង្គកុម្ភៈកុមារ ថ្វីត្បិតតែជាកុមារនេះពិការជើងតែដោយកុមារនេះ មានស្មារតីរឹងប៉ឹងក្នុងការតស៊ូខិតខំរៀនសូត្ររហូតដល់ប្រឡងជាប់ជាគ្រូពេទ្យបានទទួលការទុកចិត្តពីព្រះរាជា បានប្រគល់អ្នកសែងពីរនាក់ដើម្បីសែងកុម្ភៈកុមារទៅព្យាបាលជំងឺប្រជារាស្ត្រ នៅតាមភូមិជនបទនានា។

សរុបសេចក្តីមក ការលើកបង្ហាញតាមរយៈសង្គមជាក់ស្តែងក្តីតាមរយៈស្នាដៃអក្សរសិល្ប៍ក្តីអាចបញ្ជាក់បានថាស្មារតីរឹងប៉ឹង និងការតស៊ូពិតជាមូលដ្ឋាននៃសុភមង្គលប្រាកដមែន។

យោងតាមការបកស្រាយខាងលើឃើញថា ទស្សនៈរបស់ប្រធានខាងលើនេះពិតជាមានអត្ថន័យប្រសើរណាស់ក្នុងគំនិតអប់រំមនុស្សគ្រប់រូប គ្រប់វ័យឱ្យបំពាក់ស្មារតីរឹងប៉ឹង និងមានស្មារតីតស៊ូ ដើម្បីទទួលបាននូវសុភមង្គលរបស់ខ្លួន។ ដូច្នេះសិស្សគ្រប់រូប ត្រូវបំពាក់គោលជំហរឱ្យបានរឹងប៉ឹងក្នុងការតស៊ូ ស្វែងរកចំណេះដឹង និងចំណេះធ្វើមកជាទុនសម្រាប់ជីវិតខ្លួនឈានទៅរកសុភមង្គល។

## ១៤.២- ប្រធានបែបអត្ថាធិប្បាយពន្យល់ពាក្យស្លោក

ប្រធានទី១: ពាក្យស្លោកមួយបានលើកឡើងថា «សេចក្តីព្យាយាមគង់បានសម្រេច»។ ចូរប្អូនពន្យល់ពាក្យស្លោកនេះឱ្យបានក្បោះក្បាយ និងលើកឧទាហរណ៍មកបញ្ជាក់ផង។

### គម្រោងតែង

**ក- សេចក្តីផ្តើម**

- **លំនាំបញ្ហា:** និយាយទូទៅទាក់ទងនឹងបញ្ហាប្រធាន... គោលបំណងរបស់ពាក្យស្លោក ការព្យាយាម
- **ចំណូលបញ្ហា(បង្ហាញបញ្ហា):** ការលើកយកប្រធានមកបង្ហាញ...សេចក្តីព្យាយាមគង់បានសម្រេច...
- **ចំណោទបញ្ហា:** ការចោទសួរទៅលើប្រធាន...តើពាក្យស្លោកនេះ មានអត្ថន័យដូចម្តេច...។

**ខ- តួសេចក្តី**

- **ឃ្លាភ្ជាប់សេចក្តី:** ដើម្បីជាជំនួយដល់... គប្បីយល់នូវន័យនៃពាក្យគន្លឹះរបស់ប្រធាន...។
- **ពន្យល់ពាក្យគន្លឹះ៖**
  - ✓ ព្យាយាម : ...ព្យាយាម គឺខិតខំប្រឹងប្រែង សង្វាត...
  - ✓ សម្រេច : ... គឺធ្វើឱ្យរួចស្រេច ធ្វើឱ្យហើយស្រេច ធ្វើឱ្យបានដាច់ស្រេច...។
- **ពន្យល់ន័យប្រធាន:** ដូច្នេះប្រធានខាងលើមានន័យថា ការខិតខំ ការប្រឹងប្រែង ការសង្វាត ធ្វើកិច្ចការអ្វីមួយនឹងធ្វើឱ្យកិច្ចការនោះបានសម្រេច...។
- **បកស្រាយប្រធាន៖**
  - ✓ ព្យាយាមដោយកម្លាំងកាយ... គឺមានន័យថាការខិតខំប្រឹងប្រែងដោយប្រើប្រាស់កម្លាំងកាយក្នុងការធ្វើកិច្ចការផ្សេងៗឱ្យបានសម្រេច។ ការងារខ្លះធ្ងន់ធ្ងរត្រូវធ្វើដោយកម្លាំងកាយទើបអាចសម្រេចបាន...
  - ✓ ឧទាហរណ៍...ដូចជាក្នុងរឿងចចក និងកំពឹស នៅពេលក្រុមរបស់ចចក បាចទឹកជិតរីងត្រីក្រាញ់ខំននៀលទៅរកព្រះឥន្ទ្រជួយ...
  - ✓ ព្យាយាមដោយកម្លាំងចិត្ត... គឺមានន័យថា ការមានទឹកចិត្តមោះមុត មានការប្តេជ្ញាចិត្តខ្ពស់ក្នុងការធ្វើកិច្ចការផ្សេងៗឱ្យបានសម្រេច។ ការងារខ្លះលំបាក ប្រឈមនឹងគ្រោះទាមទារឱ្យអ្នកធ្វើមានការតាំងចិត្តមោះមុត ក្លាហាន...
  - ✓ ឧទាហរណ៍...ដូចជាក្នុងរឿងកុលាបប៉ៃលិន តួអង្គចៅចិត្រមានទឹកចិត្តក្លាហានប្រយុទ្ធតទល់នឹងចោរប្លន់...
  - ✓ ព្យាយាមដោយកម្លាំងប្រាជ្ញា... គឺមានន័យថា ការខិតខំត្រិះរិះ គិតពិចារណារិះរកវិធីផ្សេងៗក្នុងការធ្វើកិច្ចការផ្សេងៗឱ្យបានសម្រេច។ កិច្ចការឬបញ្ហាខ្លះអាចធ្វើឱ្យសម្រេចបានអាស្រ័យដោយបញ្ញា...
  - ✓ ឧទាហរណ៍...តួយ៉ាងដូចជាសិស្សានុសិស្សគ្រប់រូបត្រូវខិតខំព្យាយាមរៀនសូត្រដុសខាត់ប្រាជ្ញាដោយយកចិត្តទុកដាក់តាំងពីតូចក្រូចឆ្មាររហូតដល់ធំទើបទទួលបានចំណេះវិជ្ជា...។
- **សរុបសេចក្តី:** ...ការសិក្សារៀនសូត្រ ការធ្វើកិច្ចការអ្វីមួយ ការដោះស្រាយបញ្ហាគ្រប់បែបយ៉ាងទាំងអស់កាលណាយើងខិតខំប្រឹងប្រែង សង្វាតទាំងផ្លូវកាយ ទាំងផ្លូវចិត្ត និងទាំងផ្លូវប្រាជ្ញា នោះទើបបានសម្រេច...។

**គ- សេចក្តីបញ្ចប់**

- **វាយតម្លៃប្រធាន:** ...ពាក្យស្លោកដែលបានពោលខាងលើពិតជាមានអត្ថន័យអប់រំជ្រាលជ្រៅសម្រាប់អប់រំទូន្មានកូនចៅខ្មែរយើងគ្រប់រូប...
- **យោបល់ផ្ទាល់ខ្លួន:** ...ដូច្នេះក្នុងនាមជាសិស្ស ត្រូវខិតខំព្យាយាមរៀនសូត្រ ដើម្បីសម្រេចបានគោលដៅជីវិតគឺទទួលបានចំណេះវិជ្ជានិងវិជ្ជាជីវៈសម្រាប់ប្រកបរបរចិញ្ចឹមជីវិត...។

## សេចក្តីអធិប្បាយ

អ្នកប្រាជ្ញ បណ្ឌិត អ្នកនិពន្ធ កវី និងបុព្វបុរសដូនតាខ្មែរយើងតាំងពីបុរាណកាលមក តែងយកចិត្តទុកដាក់អប់រំ ទូន្មានប្រៀនប្រដៅកូនចៅគ្រប់ជំនាន់ ប្រាថ្នាចង់ឱ្យកូនចៅទាំងអស់រស់នៅប្រកបដោយសុភមង្គលនៅក្នុងជីវិត។ ដូច្នេះហើយទើបមានពាក្យស្លោកមួយបានលើកឡើងថា "សេចក្តីព្យាយាមគង់បានសម្រេច"។

តើពាក្យស្លោកខាងលើមានអត្ថន័យដូចម្តេច?

ដើម្បីជាជំនួយដល់ការបកស្រាយឱ្យកាន់តែក្បោះក្បាយថែមទៀតនោះ យើងគប្បីយល់នូវន័យនៃពាក្យគន្លឹះក្នុងពាក្យស្លោកនេះជាមុនសិន។ ព្យាយាម គឺខិតខំប្រឹងប្រែង សង្វាត។ ចំណែកឯពាក្យសម្រេច គឺធ្វើឱ្យរួចស្រេច ធ្វើឱ្យហើយស្រេច ធ្វើឱ្យបានដាច់ស្រេច។ ដូច្នេះប្រធានខាងលើមានន័យថា ការខិតខំប្រឹងប្រែង ការសង្វាត ក្នុងការធ្វើកិច្ចការអ្វីមួយ នឹងធ្វើឱ្យកិច្ចការនោះ បានសម្រេចជាក់ជាមិនខាន។

ជាការពិតណាស់សេចក្តីព្យាយាមជាគុណធម៌មួយដ៏ថ្លៃថ្លាលើសលប់។ សេចក្តីព្យាយាម តែងនាំមកនូវសេចក្តីសុខ និងវឌ្ឍនភាព។ ជនណាប្រកាន់ខ្ជាប់នូវការតស៊ូអំណត់ព្យាយាម ប្រឹងប្រែងក្នុងការងារជននោះពិតជាសម្រេចបានជោគជ័យដ៏ប្រសើរក្នុងជីវិត។ ដូច្នេះដើម្បីធ្វើកិច្ចការអ្វីមួយឱ្យបានសម្រេចយើងគប្បីព្យាយាម ទាំងផ្លូវកាយ ទាំងផ្លូវចិត្ត និងផ្លូវប្រាជ្ញា។

ការព្យាយាមតាមផ្លូវកាយ គឺមានន័យថា ការខិតខំប្រឹងប្រែងដោយប្រើប្រាស់កម្លាំងកាយក្នុងការធ្វើកិច្ចការផ្សេងៗឱ្យបានសម្រេច។ ការងារខ្លះធ្ងន់ធ្ងរត្រូវធ្វើដោយកម្លាំងកាយទើបអាចសម្រេចបាន។ កិច្ចការខ្លះទៀតលំបាកខ្លាំងណាស់ ត្រូវប្រើកម្លាំងខ្លាំង ប្រើរយៈពេលយូរទៀតទើបសម្រេចបាន។ ការងារដូច្នេះទាមទារឱ្យអ្នកធ្វើខិតខំប្រឹងប្រែងមិនខ្លាចនឿយហត់ ពុះពារការលំបាក តស៊ូទើបអាចសម្រេចបាន។ ដូចជាក្នុងរឿងចចកនិងកំពឹស នៅពេលក្រុមរបស់ចចកបាចទឹកជិតរីងត្រីក្រាញ់ខំនៀលទៅរកព្រះឥន្ទ្រជួយ។ ត្រីក្រាញ់តស៊ូអំណត់អត់ធន់ ខំប្រឹងប្រែងនៀលដីមិនគិតពីភាពនឿយហត់កាត់ថ្ងៃក្តៅហែង ក្រៀមស្រកាអស់រហូតបានជួបទេវតាយមកជួយសង្គ្រោះពួកខ្លួន។ ដោយការព្យាយាមរបស់ត្រីក្រាញ់ ទើបជួយសង្គ្រោះជីវិតពួកខ្លួនបាន។ សត្វចាប ខិតខំប្រឹងប្រែងចឹកហែកស្លឹកស្មៅឬស្លឹកឈើពាំហើយយកមក ម្តងមួយសរសៃៗមកចាក់ក្រងបន្តិចម្តងៗ រហូតធ្វើជាសំបុកដ៏ស្អុកស្អម្ភបាន។ នេះដោយសារអំណាចនៃសេចក្តីព្យាយាម។

ក្រៅពីសេចក្តីព្យាយាមខាងផ្លូវកាយ មនុស្សត្រូវមានការព្យាយាមខាងផ្លូវចិត្តបន្ថែមទៀតទើបប្រសើរ។ ការព្យាយាមខាងផ្លូវចិត្តគឺមានន័យថាការមោនទឹកចិត្តមោះមុត មានការប្តេជ្ញាចិត្តខ្ពស់ក្នុងការធ្វើកិច្ចការផ្សេងៗឱ្យបានសម្រេច។ ការងារខ្លះលំបាក ប្រឈមនឹងគ្រោះថ្នាក់យ៉ាងខ្លាំង ដូច្នេះទាមទារឱ្យអ្នកធ្វើមានការតាំងចិត្តមោះមុត ក្លាហានទើបអាចសម្រេចបាន។ ការងារខ្លះទៀតលំបាក ស្មុគស្មាញ

ទាមទារឱ្យអ្នកធ្វើមានចិត្តខិតខំប្រឹងប្រែង តស៊ូ អត់ធ្មត់ គ្រប់បែបយ៉ាងទើបទទួលបានលទ្ធផលល្អ។ ដូចជាក្នុងរឿងកុលាបប៉ៃលិន តួអង្គចៅចិត្រមានស្មារតីតស៊ូមោះមុតក្នុងការធ្វើការងារ។ លើសពីនេះទៀតចៅចិត្រពោរពេញទៅដោយទឹកចិត្តក្លាហាន ហ៊ានប្រយុទ្ធតទល់នឹងក្រុមចោរប្លន់នៅក្នុងព្រៃតាមផ្លូវ ពេលធ្វើដំណើរពីបាត់ដំបងទៅប៉ៃលិននិងប្រយុទ្ធជាមួយក្រុមចោរប្លន់នៅផ្ទះឃ្លាំងរតនសម្បត្តិ រហូតទទួលបានជោគជ័យ។

សេចក្តីព្យាយាមខាងផ្លូវកាយ និងការព្យាយាមខាងផ្លូវចិត្ត ជាគុណសម្បត្តិពីរយ៉ាងល្អប្រពៃណាស់ទៅហើយ។ ដើម្បីឱ្យកាន់តែប្រសើរជាងនេះទៅទៀត មនុស្សយើងគប្បីមានសេចក្តីព្យាយាមខាងប្រាជ្ញាថែមទៀត។ ការព្យាយាមតាមផ្លូវប្រាជ្ញា គឺមានន័យថាការខិតខំត្រិះរិះ គិតពិចារណារិះរកវិធីផ្សេងៗក្នុងការធ្វើកិច្ចការឱ្យបានសម្រេច។ កិច្ចការឬបញ្ហាខ្លះអាចធ្វើឱ្យសម្រេចបានអាស្រ័យដោយបញ្ញា។ ការមានប្រាជ្ញាក៏មិនសុទ្ធតែអាចដោះស្រាយ ឬធ្វើកិច្ចការបានសម្រេចនោះដែរ ប្រសិនបើខ្វះការព្យាយាម។ កិច្ចការឬបញ្ហាខ្លះត្រូវធ្វើឬដោះស្រាយដោយមានការលំបាកយ៉ាងខ្លាំង ហើយប្រើពេលវេលាយូរទៀតផង។ ភារកិច្ចបែបនេះអាចធ្វើឱ្យសម្រេចបាន ឬដោះស្រាយបាន លុះត្រាតែអ្នកធ្វើនោះខិតខំត្រិះរិះគិតហើយគិតទៀតប្រកបដោយភាពអំណត់។ តួយ៉ាងដូចជាសិស្សានុសិស្សគ្រប់រូបត្រូវខិតខំព្យាយាមរៀនសូត្រ ដុសខាត់ប្រាជ្ញា ដោយយកចិត្តទុកដាក់តាំងពីតូចក្រូចឆ្មាររហូតដល់ធំ ទើបទទួលបានចំណេះវិជ្ជានិងវិជ្ជាជីវៈសម្រាប់ប្រកបរបរចិញ្ចឹមជីវិត។ ការនេះត្រូវប្រើប្រាស់ប្រាជ្ញាធ្វើប្រកបដោយសេចក្តីព្យាយាមទើបអាចសម្រេចបាន។ ប្រសិនបើខ្វះសេចក្តីព្យាយាមនោះ នឹងមិនអាចសិក្សារៀនសូត្របានចប់ចុងចប់ដើមនោះទេ។

សរុបសេចក្តីមក ការសិក្សារៀនសូត្រ ការធ្វើកិច្ចការអ្វីមួយ ការដោះស្រាយបញ្ហាគ្រប់បែបយ៉ាងទាំងអស់កាលណាយើងខិតខំប្រឹងប្រែង សង្វាតទាំងផ្លូវកាយ ទាំងផ្លូវចិត្ត និងទាំងផ្លូវប្រាជ្ញា នោះទើបបានសម្រេចដូចបំណងប្រាថ្នា។

ពាក្យស្លោកដែលបានពោលខាងលើពិតជាមានអត្ថន័យអប់រំជ្រាលជ្រៅ សម្រាប់អប់រំទូន្មានកូនចៅខ្មែរយើងគ្រប់រូប ឱ្យបានយល់ដឹងពីអំណាចសេចក្តីព្យាយាម។ ដូច្នេះក្នុងនាមជាសិស្ស ត្រូវខិតខំព្យាយាមរៀនសូត្រ ដើម្បីសម្រេចបានគោលដៅជីវិត គឺទទួលបានចំណេះវិជ្ជា និងវិជ្ជាជីវៈសម្រាប់ប្រកបរបរចិញ្ចឹមជីវិតរស់នៅប្រកបដោយសុភមង្គល។

---

**ប្រធានទី២:** ពាក្យស្លោកមួយបានលើកឡើងថាៈ «សាមគ្គីរស់ បាក់បែកសាមគ្គីស្លាប់»។ ចូរពន្យល់ពាក្យស្លោកនេះឱ្យបានក្បោះក្បាយ និងលើកឧទាហរណ៍មកបញ្ជាក់ផង។

---

## គម្រោងតែង

### ក- សេចក្តីផ្តើម

- **លំនាំបញ្ហា:** និយាយទូទៅទាក់ទងនឹងបញ្ហារបស់ប្រធាន... គោលបំណងពាក្យស្លោក សាមគ្គីភាព...
- **ចំណូលបញ្ហា(បង្ហាញបញ្ហា):** ការបង្ហាញប្រធាន... សាមគ្គីរស់ បាក់បែកសាមគ្គីស្លាប់...
- **ចំណោទបញ្ហា:** ការចោទសួរទៅលើប្រធាន...តើពាក្យស្លោកនេះ មានអត្ថន័យដូចម្តេច.. ។

### ខ- តួសេចក្តី

- **ឃ្លាភ្ជាប់សេចក្តី:** ដើម្បីជាជំនួយដល់... គប្បីយល់នូវន័យនៃពាក្យគន្លឹះរបស់ប្រធាន... ។

- **ពន្យល់ពាក្យគន្លឹះ៖**
  - ✓ សាមគ្គី: មានន័យថាសេចក្តីព្រមព្រៀង សេចក្តីព្រមព្រៀងជាមួយគ្នា ដំណើរស្រុះគ្នា...
  - ✓ រស់: ក្នុងពាក្យស្លោកនេះមានន័យថា មានជីវិត ទទួលបានជោគជ័យ ធ្វើបានសម្រេច...
  - ✓ ស្លាប់: ស្លាប់ ក្នុងពាក្យស្លោកនេះមានន័យថា បាត់បង់ជីវិត បរាជ័យ ធ្វើមិនបានសម្រេច... ។
- **ពន្យល់ន័យប្រធាន:** ...ដូច្នេះពាក្យស្លោកខាងលើមានន័យថា ក្នុងគ្រាអាសន្នណាមួយ ឬការធ្វើអ្វីមួយ ប្រសិនបើមានសេចក្តីព្រមព្រៀង សេចក្តីព្រមព្រៀងជាមួយគ្នា ដំណើរស្រុះគ្នាគឺនឹងធ្វើឱ្យមានជីវិតរស់នៅ ទទួលបានជោគជ័យ ធ្វើការបានសម្រេច...។
- **បកស្រាយប្រធាន៖**

***សាមគ្គីរស់៖***

- ✓ សាមគ្គីនាំឱ្យជីវិតរស់មានន័យថា...គ្រាអាសន្នខ្លះ គេអាចសង្គ្រោះជីវិតបានដោយសារការចេះរួបរួមសាមគ្គីគ្នា...
- ✓ ឧទាហរណ៍...ដូចជាក្នុងរឿងនាយល្អ ឬព្រាបជាប់លប់ ពេលព្រាបមួយហ្វូងជាប់លប់ព្រាន មេហ្វូងបានឱ្យពួកព្រាបទាំង អស់រួមសាមគ្គីស្រុះកម្លាំងគ្នា ហើរឡើង...
- ✓ សាមគ្គីនាំឱ្យទទួលបានជ័យជម្នះ...សាមគ្គីភាពក៏ជាកត្តាសំខាន់នាំទៅរកជ័យជម្នះគ្រប់បែបយ៉ាងផងដែរ...
- ✓ ឧទាហរណ៍ ...កាលពីឆ្នាំពីរពាន់ប្រាំពីរ ពួកសៀមបាន លើកទ័ពមកឈ្លានពានយកប្រាសាទព្រះវិហារ តែត្រូវបរាជ័យដោយសារកងទ័ពខ្មែរយើងមានសាមគ្គីភាព រួមកម្លាំងគ្នា...
- ✓ សាមគ្គីនាំឱ្យសម្រេចកិច្ចការបាន... ការមានសាមគ្គីភាពធ្វើឱ្យគេអាចធ្វើអ្វីៗបានសម្រេច...
- ✓ ឧទាហរណ៍...ដូចជាសត្វកណ្តៀរជាសត្វតូចល្អិត តែអាចជញ្ជូនដីពូនបានជាដំបូកដ៏ធំបាន...។

***បាក់បែកសាមគ្គីស្លាប់៖***

- ✓ គ្មានសាមគ្គីនាំឱ្យបាត់បង់ជីវិត...បាក់បែកសាមគ្គីស្លាប់មានន័យថា គ្រាអាសន្នខ្លះបើមិនចេះរួបរួមសាមគ្គីគ្នាទេនឹងអាចធ្វើ ឱ្យមានគ្រោះថ្នាក់ អន្តរាយ...។
- ✓ ឧទាហរណ៍... ដូចជាក្នុងរឿងចាបស្រុក និងចាបព្រៃ នៅពេលទំលើដើមត្រែងខាងលើនិងខាងក្រោម ធ្វើឱ្យមែកត្រែងបាក់ធ្លាក់លើក៏បង្កជាជម្លោះ...
- ✓ គ្មានសាមគ្គីនាំឱ្យបរាជ័យ...ការបាក់បែកសាមគ្គីភាពក៏ជាកត្តាសំខាន់នាំទៅរកបរាជ័យគ្រប់បែបយ៉ាង...
- ✓ ឧទាហរណ៍ ...រឿងចចកនិងកំពឹសពួកសត្វជំរី ខ្លា ពស់ ថ្លាន់ អក កុក ក្រសារ ត្រុំ ដំបូងឡើយមានសាមគ្គីគ្នា រួមកម្លាំងគ្នាបាចទឹកបឹងស្ទើរតែរីងទៅហើយ គ្រាន់តែឮទន្សាយប្រើកលល្បិចអានសាររបស់ព្រះឥន្ទ្រក៏ភ័យស្លន់ស្លោ បាត់បង់សាគ្គីភាព...
- ✓ គ្មានសាមគ្គីនាំឱ្យធ្វើកិច្ចការមិនបានសម្រេច... បាក់បែកសាមគ្គីភាពនាំឱ្យការធ្វើការងារមិនបានសម្រេច...
- ✓ ឧទាហរណ៍...ដូចជាក្នុងការប្រកួតបាល់ទាត់ ប្រសិនបើក្រុមកីឡាកណាមិនចេះសាមគ្គីគ្នា ខ្វះភាពសហការគ្នាក្រុមនោះនឹងទទួលបរាជ័យ...។

- **សរុបសេចក្តី:** ...មានសាគ្គីភាពនាំឱ្យមានជីវិត ទទួលជោគជ័យ ធ្វើការបានសម្រេចជាមិនខាន។ ផ្ទុយទៅវិញប្រសិនបើបាក់បែកសាមគ្គីនាំឱ្យបាត់បង់ជីវិត ទទួលបរាជ័យ ធ្វើការមិនបានសម្រេច...។

**គ- សេចក្ដីបញ្ចប់**

- **វាយតម្លៃប្រធាន**: ពាក្យស្លោកដែលបានពោលខាងលើពិតជាមានអត្ថន័យអប់រំជ្រាលជ្រៅ សម្រាប់អប់រំទូន្មានកូនចៅខ្មែរយើង...
- **យោបល់ផ្ទាល់ខ្លួន**: ដូច្នេះក្នុងនាមយើងជាកុលបុត្រកុលធីតាខ្មែរទាំងអស់គ្នា ត្រូវចេះរួបរួមសាមគ្គីគ្នាវេញជាធ្លុងមួយ ដើម្បី...។

## សេចក្ដីអធិប្បាយ

ខ្មែរយើងសម្បូរពាក្យស្លោក សុភាសិត ច្បាប់ផ្សេងៗណាស់។ អ្នកប្រាជ្ញ បណ្ឌិត កវី អ្នកនិពន្ធ បុព្វបុរសដូនតាខ្មែរយើងតាំងពីបុរាណកាលមក បានតាក់តែងឡើងសម្រាប់អប់រំ ទូន្មានប្រៀនប្រដៅកូនចៅគ្រប់ជំនាន់ ប្រាថ្នាចង់ឱ្យកូនចៅទាំងអស់រស់នៅប្រកបដោយសុភមង្គល។ ដូច្នេះហើយទើបមានពាក្យស្លោកមួយបានលើកឡើងថា "សាមគ្គីរស់ បាក់បែកសាមគ្គីស្លាប់"។

តើពាក្យស្លោកនេះមានអត្ថន័យដូចម្ដេច?

ដើម្បីជាជំនួយដល់ការបកស្រាយឱ្យកាន់តែក្បោះក្បាយថែមទៀតនោះ យើងគប្បីយល់នូវន័យនៃពាក្យគន្លឹះក្នុងពាក្យស្លោកនេះជាមុនសិនដូចជាពាក្យ" សាមគ្គី រស់ ស្លាប់ "។ សាមគ្គីមានន័យថា សេចក្ដីព្រមព្រៀង សេចក្ដីព្រមព្រៀងជាមួយគ្នា ដំណើរស្រុះគ្នា។ រស់ក្នុងពាក្យស្លោកនេះមានន័យថា មានជីវិតទទួលបានជោគជ័យ ធ្វើបានសម្រេចជាដើម។ ស្លាប់ ក្នុងពាក្យស្លោកនេះមានន័យថា បាត់បង់ជីវិត ទទួលបរាជ័យធ្វើមិនបានសម្រេចជាដើម។ ដូច្នេះពាក្យស្លោកខាងលើមានន័យថា ក្នុងគ្រាអាសន្នណាមួយឬការធ្វើអ្វីមួយ ប្រសិនបើមានសេចក្ដីព្រមព្រៀង សេចក្ដីព្រមព្រៀងជាមួយគ្នា ដំណើរស្រុះគ្នា គឺនឹងធ្វើឱ្យមានជីវិតរស់នៅទទួលបានជោគជ័យ ធ្វើការបានសម្រេចជាមិនខាន។ ផ្ទុយទៅវិញ ប្រសិនបើក្នុងគ្រាអាសន្នណាមួយឬការធ្វើអ្វីមួយដោយគ្មានសេចក្ដីព្រមព្រៀង មិនមានសេចក្ដីព្រមព្រៀងជាមួយគ្នា ដំណើរមិនស្រុះគ្នានឹងធ្វើឱ្យបាត់បង់ជីវិត ទទួលបរាជ័យ ធ្វើការមិនបានសម្រេចជាមិនខាន។

ជាកាពិតណាស់សាមគ្គីភាព គឺជាការរួមកម្លាំងគ្នាជាធ្លុងមួយ ឬការព្រមព្រៀងគ្នា ដោយឯកច្ឆន្ទក្នុងការធ្វើអ្វីមួយឱ្យសម្រេចបានជោគជ័យដោយមិនប្រកាន់ វណ្ណៈ ឋានៈតួនាទី សាសនា ជាតិសាសន៍ ពណ៌សម្បុរឬភេទ។ សាមគ្គីភាពអាចកើតឡើងដោយទឹកចិត្តស្រឡាញ់ ការជឿជាក់ ស្មោះស្ម័គ្រ យោគយល់អធ្យាស្រ័យ និងចេះអនុគ្រោះគ្នាទៅវិញទៅមក។ ទឹកដី ភាសា ជាតិសាសន៍ វប្បធម៌ប្រពៃណីព្រមទាំងសមិទ្ធផលផ្សេងៗទៀតក្នុងសង្គមអាចស្ថិតស្ថេរគង់វង្ស និងរីកចម្រើនបានអាស្រ័យដោយមានសាមគ្គីភាព។

សាមគ្គីរស់មានន័យថាគ្រាអាសន្នខ្លះគេអាចសង្គ្រោះជីវិតបានដោយការចេះរួបរួមសាមគ្គីគ្នា។ ដូចជាក្នុងរឿងនាយល្អ ឬព្រាបជាប់លប់ ពេលព្រាបមួយហ្វូងជាប់លប់ព្រាន មេហ្វូងបានឱ្យពួកព្រាបទាំងអស់រួមសាមគ្គីស្រុះកម្លាំងគ្នា ហើរឡើងនាំទាំងលប់ទៅជាមួយផង ទើបអាចរួចផុតពីសេចក្ដីស្លាប់បាន។ ម្យ៉ាងទៀត សាមគ្គីភាពក៏ជាកត្តាសំខាន់នាំទៅរកជ័យជម្នះគ្រប់បែបយ៉ាងផងដែរ។ ដូចជាកាលពីឆ្នាំពីរពាន់ប្រាំពីរ ពួកសៀមបានលើកទ័ពមកឈ្លានពានយកប្រាសាទព្រះវិហារ តែត្រូវបរាជ័យដោយសារកងទ័ពខ្មែរយើងមានសាមគ្គីភាព រួមកម្លាំងគ្នាប្រយុទ្ធតតាំង វាយបណ្ដេញទ័ពសៀមឈ្លានពានរត់ខ្ចាត់ខ្ចាយ។ លើសពីនេះទៀត ការមានសាមគ្គីភាពធ្វើឱ្យគេអាចធ្វើអ្វីៗបានសម្រេច។ ដូចជាសត្វ

កណ្តៀរជាសត្វតូចល្អិត តែអាចជញ្ជូនដីពូនបានជាដំបូកដ៏ធំបាន។ នេះដោយសារសត្វកណ្តៀរ ចេះសាមគ្គីគ្នាស្រុះគ្នាក្នុងការធ្វើការងារ។

បាក់បែកសាមគ្គីស្លាប់មានន័យថា គ្រាអាសន្នខ្លះ បើមិនចេះរួបរួមសាមគ្គីគ្នាទេនឹងអាចធ្វើឱ្យមានគ្រោះថ្នាក់ អន្តរាយ ឬអាចឈានដល់បាត់បង់ជីវិតទៀតផង។ ដូចជាក្នុងរឿងចាបស្រុកនិងចាបព្រៃនៅពេលទំលើដើមត្រែងខាងលើ និងខាងក្រោម ធ្វើឱ្យមែកត្រែងបាក់ធ្លាក់លើចាបព្រៃនៅខាងក្រោម ក៏បង្កជាជម្លោះស្រែកចេចចចាច រហូតឮដល់ព្រាន។ ព្រានក៏មកវាយលប់ជាប់ទាំងអស់គ្នា យកទៅពិឃាតអស់ទៅ។ នេះដោយសារ ចាបទាំងពីរក្រុមមិនចេះសាមគ្គីភាពគ្នា មិនចេះយោគយល់អធ្យាស្រ័យគ្នា។ ម្យ៉ាងទៀត ការបែកបាក់សាមគ្គីភាពក៏ជាកត្តាសំខាន់នាំទៅរកបរាជ័យគ្រប់បែបយ៉ាងផងដែរ។ ជាក់ស្តែងក្នុងរឿងចចកនិងកំពីសពួកសត្វជំរី ខ្លា ពស់ ថ្លាន់ អក កុក ក្រសារ ត្រុំ ដំបូងឡើយមានសាមគ្គីរួមកម្លាំងគ្នាបាចទឹកបឹងស្ទើរតែរីងទៅហើយ គ្រាន់តែឮទន្សាយប្រើកលល្បិចអានសាររបស់ព្រះឥន្ទ្រក៏ភ័យស្លន់ស្លោ បាត់បង់សាគ្គីភាពរត់ខ្ចាត់ខ្ចាយអស់។ លើសពីនេះទៀត ការបាក់បែកសាមគ្គីភាពនាំឱ្យការធ្វើការងារមិនបានសម្រេច។ ដូចជាក្នុងការប្រកួតបាល់ទាត់ ប្រសិនបើក្រុមកីឡាករណាមិនចេះសាមគ្គីគ្នា ខ្វះភាពសហការគ្នាក្រុមនោះនឹងទទួលបរាជ័យជាក់ជាមិនខាន។

សរុបសេចក្តីមក មានសាមគ្គីភាពនាំឱ្យមានជីវិត ទទួលបានជោគជ័យ ធ្វើការបានសម្រេចជាមិនខាន។ផ្ទុយទៅវិញប្រសិនបើបាក់បែកសាមគ្គីនាំឱ្យបាត់បង់ជីវិត ទទួលបរាជ័យ ធ្វើការមិនបានសម្រេចជាមិនខាន។

ពាក្យស្លោកដែលបានពោលខាងលើពិតជាមានអត្ថន័យអប់រំជ្រាលជ្រៅ សម្រាប់អប់រំទូន្មានកូនចៅខ្មែរយើងគ្រប់រូបឱ្យបានយល់ដឹងពីតម្លៃនៃសាមគ្គីភាព និងសេចក្តីអន្តរាយផ្សេងៗដែលកើតឡើងដោយការបាក់បែកសាមគ្គីភាព។ ដូច្នេះក្នុងនាមយើងជាកុលបុត្រកុលធីតាខ្មែរទាំងអស់គ្នាត្រូវចេះរួបរួមសាមគ្គីគ្នាវេញជាធ្លុងមួយ ដើម្បីការពារទឹកដីកម្ពុជាយើងឱ្យបានគង់វង្ស និងសាមគ្គីគ្នាចូលរួមក្នុងការអភិវឌ្ឍប្រទេសជាតិយើងឱ្យបានរីកចម្រើនរុងរឿងល្បីល្បាញនៅលើឆាកអន្តរជាតិ។

---

**ប្រធានទី៣:** អ្នកអប់រំលើកឡើងថា «សាលារៀន ជាថ្នាលបណ្តុះចំណេះវិជ្ជា»។ ចូរពន្យល់ពាក្យស្លោកនេះឱ្យបានក្បោះក្បាយ និងលើកឧទាហរណ៍មកបញ្ជាក់។

---

## គម្រោងតែង

**ក- សេចក្តីផ្តើម**

- **លំនាំបញ្ហា:** និយាយទូទៅទាក់ទងនឹងបញ្ហារបស់ប្រធាន គោលបំណងពាក្យស្លោក តួនាទីរបស់សាលារៀន ...
- **ចំណូលបញ្ហា(បង្ហាញបញ្ហា):** ការលើកយកប្រធានមកបង្ហាញ...សាលារៀន ជាថ្នាលបណ្តុះចំណេះវិជ្ជា...
- **ចំណោទបញ្ហា:** ការចោទសួរទៅលើប្រធាន...តើពាក្យស្លោកនេះមានអត្ថន័យដូចម្តេច...។

**ខ- តួសេចក្តី**

- **ឃ្លាភ្ជាប់សេចក្តី:** ដើម្បីជាជំនួយដល់.... គប្បីយល់នូវន័យនៃពាក្យគន្លឹះរបស់ប្រធាន...។
- ពន្យល់ពាក្យគន្លឹះ ៖

- ✓ ថ្នាល: មានន័យថា គឺជាកន្លែង ទីដីសម្រាប់សាបព្ធជស្រូវ ឬព្រោះពូជរុក្ខជាតិ...
- ✓ បណ្តុះ: គឺធ្វើឱ្យដុះ ធ្វើឱ្យរីកដុះដាល...
- ✓ ចំណេះវិជ្ជា: សេចក្តីដឹងច្បាស់ ការចេះដឹង...។

- **ពន្យល់ន័យប្រធាន:** ដូច្នេះពុំនោលអប់រំខាងលើមានន័យថា សាលារៀនជាកន្លែងសម្រាប់បណ្តុះ បណ្តាលធ្វើឱ្យរីកដុះដាលនូវការចេះដឹង ឬការយល់ដឹងច្បាស់ពីបំណិន និងឥរិយាបថ... ។
- **បំណកស្រាយប្រធាន៖**
  - ✓ រៀនឱ្យមានចំណេះដឹង...សាលារៀនជាកន្លែងសម្រាប់បង្រៀនសិស្សានុសិស្សទាំងឡាយ។ បច្ចុប្បន្ន លាសារៀនមានគ្រប់កម្រិតគឺ បឋមសិក្សា អនុវិទ្យាល័យ...។ ការរៀនឱ្យមានចំណេះដឹង មានន័យថា សិស្សានុសិស្សត្រូវរៀនអំពីចំណេះដឹងទូទៅ។ ចំណេះដឹងទូទៅមានមុខវិជ្ជាគណិត វិទ្យា ភាសាខ្មែរ សិក្សាសង្គម វិទ្យាសាស្ត្រ...
  - ✓ ឧទាហរណ៍...ជាតួយ៉ាងសិស្សានុសិស្ស ដែលបានខិតខំរៀនសូត្រមានចំណេះដឹងច្បាស់លាស់ តែងប្រឡងជាប់ និងទទួលបាននិទ្ទេស...
  - ✓ រៀនឱ្យមានចំណេះធ្វើ...ការរៀនឱ្យមានចំណេះធ្វើមានន័យថា អ្នកសិក្សាត្រូវរៀនពីវិជ្ជាជីវៈផ្សេងៗ សម្រាប់យកទៅប្រើប្រាស់ និងប្រកបរបរចិញ្ចឹមជីវិត...
  - ✓ ឧទាហរណ៍...តួយ៉ាងការរៀនជំនាញពេទ្យសត្វ អ្នកសិក្សាត្រូវរៀនទ្រឹស្តីឱ្យបានចេះចាំស្ទាត់តាម រយៈការបង្ហាញរបស់គ្រូ ឬការអានឯកសារជាមុនសិនដូចជា របៀបចាក់ថ្នាំសត្វ...
  - ✓ រៀនឱ្យមានសីលធម៌ល្អ ...ការរៀនឱ្យមានសីលធម៌ល្អ ជាការសំខាន់ណាស់សម្រាប់ការរស់នៅក៏ ដូចជាការប្រកបរបរចិញ្ចឹមជីវិត។ សីលធម៌ ជាមាគ៌ាសម្រាប់នាំផ្លូវមនុស្សទៅរកសេចក្តីថ្លៃថ្នូរ...
  - ✓ ឧទាហរណ៍: ...អ្នករៀនបង្កើតអាវុធជាតិផ្ទុះបានចេះស្ទាត់ជំនាញហើយ ប៉ុន្តែគ្មានសីលធម៌អ្នកអាច នឹងបង្កគ្រោះថ្នាក់ដល់មនុស្សជាតិ...
  - ✓ រៀនឱ្យចេះរួមរស់ជាមួយគ្នាប្រកបដោយសុខសន្តិភាព...មនុស្សត្រូវចេះរួមរស់ជាមួយគ្នាប្រកប ដោយសុខសន្តិភាពបន្ថែមទៀតទើបប្រសើរ។ ការរៀនឱ្យចេះរួមរស់ជាមួយគ្នាប្រកបដោយសុខ សន្តិភាព ជាបំណងប្រាថ្នាទូទៅ...
  - ✓ ឧទាហរណ៍...ជាក់ស្តែងដូចជាប្រទេសកម្ពុជាបច្ចុប្បន្ន ប្រជាពលរដ្ឋយើង គោរពសាសនាផ្សេងៗ គ្នាមានព្រះពុទ្ធសាសនា ឥស្លាមសាសនា គ្រិស្តសាសនា និងមានជនជាតិខ្មែរដើមភាគតិច មាន ជំនឿលើដូនតា អារក្ស...។
- **សរុបសេចក្តី:** សាលារៀនជាកន្លែងបណ្តុះបណ្តាលមនុស្សឱ្យមានចំណេះដឹង មានចំណេះធ្វើ មានសីលធម៌ និងចេះរួមរស់ជាមួយគ្នាប្រកបដោយសុខសន្តិភាព...។

**គ- សេចក្តីបញ្ចប់**

- **វាយតម្លៃប្រធាន:** ពុំនោលដែលបានពោលខាងលើពិតជាមានអត្ថន័យជ្រាលជ្រៅ សម្រាប់អប់រំទូន្មាន យើងគ្រប់រូបឱ្យបានយល់ដឹងពីតម្លៃដ៏ពិសិដ្ឋរបស់ចំណេះវិជ្ជា ...
- **យោបល់ផ្ទាល់ខ្លួន:** ដូច្នេះក្នុងនាមយើងជាសិស្សានុសិស្ស ត្រូវខិតខំប្រឹងប្រែងព្យាយាមរៀនសូត្រឱ្យ បានហ្មត់ចត់តាំងពីតូច រហូតដល់ធំ ដើម្បីទទួលបាននូវចំណេះវិជ្ជា...។

# សេចក្តីអធិប្បាយ

បុព្វបុរសខ្មែរយើងបានបន្សល់ទុកនូវពាក្យស្លោក សុភាសិតជាច្រើន ដើម្បីទុកអប់រំ ទូន្មាន ប្រៀនប្រដៅកូនចៅជំនាន់ក្រោយប្រាថ្នាចង់ឱ្យកូនចៅទាំងអស់រស់នៅប្រកបដោយសុភមង្គល។ ដូច្នេះហើយ ទើបមានពុំនោលមួយបានលើកឡើងថា "សាលារៀន ជាថ្នាលបណ្តុះបណ្តាលចំណេះវិជ្ជា"។

តើសាលារៀនជាថ្នាលបណ្តុះបណ្តាលចំណេះវិជ្ជាដូចម្តេចខ្លះ?

ដើម្បីជាជំនួយដល់ការបកស្រាយឱ្យកាន់តែក្បោះក្បាយនោះយើងគប្បីយល់នូវន័យនៃពាក្យគន្លឹះក្នុងពាក្យស្លោកនេះជាមុនសិនដូចជាពាក្យ " ថ្នាលបណ្តុះចំណេះវិជ្ជា "។ ពាក្យថ្នាល មានន័យថា គឺជាកន្លែង ទីដីសម្រាប់សាបព្រោះពូជស្រូវ ឬព្រោះពូជរុក្ខជាតិមានបន្លែជាដើម។ រីឯពាក្យ បណ្តុះ គឺធ្វើឱ្យដុះ ធ្វើឱ្យរីកដុះដាល។ ចំណែកឯពាក្យ ចំណេះវិជ្ជា មានន័យថាសេចក្តីដឹងច្បាស់ ការចេះដឹង។ ដូច្នេះពុំនោលខាងលើមានន័យថា សាលារៀនជាកន្លែងសម្រាប់ធ្វើឱ្យរីកដុះនូវការចេះដឹង ឬការយល់ដឹងច្បាស់។

ជាការពិតណាស់ សាលារៀនជាកន្លែងសម្រាប់បង្រៀនសិស្សានុសិស្សទាំងឡាយ។ បច្ចុប្បន្នលាសារៀនមានគ្រប់កម្រិតគឺ មត្តេយ្យសិក្សា បឋមសិក្សា អនុវិទ្យាល័យ វិទ្យាល័យ និងមហាវិទ្យាល័យ។ សាលាខ្លះទៀត គេបង្រៀនជំនាញបច្ចេកទេសដូចជាកសិកម្ម អេឡិចត្រូនិច ពាណិជ្ជកម្ម បច្ចេកវិទ្យាព័ត៌មាន គ្រូបង្រៀន ពេទ្យជាដើម។ នៅតាមសាលារៀននីមួយៗ បានរៀបចំកម្មវិធីសិក្សា សម្រាប់បង្រៀនសិស្សដោយផ្តោតទៅលើ ការរៀនឱ្យមានចំណេះដឹង ការរៀនឱ្យមានចំណេះធ្វើ ការរៀនឱ្យមានសីលធម៌ និងការរៀនឱ្យចេះរួមរស់ជាមួយគ្នាប្រកបដោយសុខសន្តិភាព។

ការរៀនឱ្យមានចំណេះដឹងមានន័យថា សិស្សានុសិស្សត្រូវរៀនអំពីចំណេះដឹងទូទៅ។ ចំណេះដឹងទូទៅមានមុខវិជ្ជាគណិតវិទ្យា ភាសាខ្មែរ សិក្សាសង្គម វិទ្យាសាស្ត្រ និងភាសាបរទេសជាដើម។ ដើម្បីទទួលបានចំណេះវិជ្ជាទាំងនេះ អ្នកសិក្សាគ្រប់រូបត្រូវចូលរៀនក្នុងសាលារៀនតាំងពីតូចរហូតដល់ធំ។ អ្នកដែលអាចទទួលបានចំណេះវិជ្ជា លុះត្រាតែខិតខំប្រឹងប្រែងព្យាយាមសិក្សាឱ្យបានហ្មត់ចត់។ ចំណេះដឹងទូទៅ សិស្សត្រូវខិតខំរៀនសូត្រយ៉ាងណាឱ្យមានសមត្ថភាពក្នុងការចងចាំ ការយល់ដឹង ការអនុវត្ត ការវិភាគ និងការសំយោគ ការវាយតម្លៃ និងការបង្កើតថ្មីទៅលើខ្លឹមសារមេរៀននីមួយៗច្បាស់លាស់។ ខ្លឹមសារមេរៀនខ្លះទាមទារឱ្យអ្នកសិក្សាខិតខំហ្វឹកហាត់អាន សរសេរឱ្យចាំស្ទាត់ទើបល្អប្រសើរដូចជាមុខវិជ្ជាប្រវត្តិវិទ្យា ភាសាបរទេស បញ្ញត្តិ និយមន័យ និងរូបមន្តផ្សេងៗជាដើម។ ខ្លឹមសារមេរៀនមួយចំនួនទៀតទាមទារឱ្យអ្នកសិក្សាខិតខំគិតត្រិះរិះពិចារណាឈ្វេងយល់រកចំណុចគន្លឹះ ឬខ្លឹមសារសំខាន់ៗឱ្យបានច្បាស់ទើបមានប្រសិទ្ធភាពដូចជា វិធីសរសេរតែងសេចក្តី វិធីធ្វើលំហាត់ វិធីដោះស្រាយចំណោទ វិធីបកស្រាយរូបមន្តផ្សេងៗជាដើម។ ខ្លឹមសារមេរៀនខ្លះទៀត តម្រូវឱ្យអ្នកសិក្សាអនុវត្តផ្ទាល់ទើបមានប្រសិទ្ធភាពដូចជា ការពិសោធរូបវិទ្យា គីមីវិទ្យា សិល្បៈ កីឡាជាដើម។ ជាតួយ៉ាងសិស្សានុសិស្ស ដែលបានខិតខំរៀនសូត្រមានចំណេះដឹងច្បាស់លាស់ តែងប្រឡងជាប់ និងទទួលបាននិទ្ទេសល្អថែមទៀតផង។

ការរៀនឱ្យមានចំណេះដឹងមិនទាន់គ្រប់គ្រាន់ទេ អ្នកសិក្សាម្នាក់ៗគប្បីរៀនឱ្យមានចំណេះធ្វើទៀតទើបប្រសើរ។ ការរៀនឱ្យមានចំណេះធ្វើមានន័យថា អ្នកសិក្សាត្រូវរៀនពីវិជ្ជាជីវៈផ្សេងៗសម្រាប់យកទៅប្រើប្រាស់និងប្រកបរបរចិញ្ចឹមជីវិត។ វិជ្ជាជីវៈមានគ្រប់ជំនាញដូចជា ការធ្វើនំ ហត្ថកម្ម សិប្បកម្ម

កសិកម្ម ពាណិជ្ជកម្ម ទេសចរណ៍ គ្រូបង្រៀន ពេទ្យ សំណង់ និងបច្ចេកវិទ្យាព័ត៌មាន។ល។ ការសិក្សាជំនាញទាំងនេះ អ្នកសិក្សាត្រូវខិតខំរៀនសូត្រយ៉ាងណាឱ្យមានការចេះចាំស្ទាត់ទាំងផ្នែកទ្រឹស្តី និងការអនុវត្ត។ គំរូយ៉ាងការរៀនជំនាញពេទ្យសត្វ អ្នកសិក្សាត្រូវរៀនទ្រឹស្តីឱ្យបានចេះចាំស្ទាត់តាមរយៈការបង្ហាញរបស់គ្រូឬការអានឯកសារជាមុនសិនដូចជា របៀបចាក់ថ្នាំសត្វ តើត្រូវរៀបចំម្ជុល និងសឺរ៉ាំងដូចម្តេច? តើត្រូវចាក់ត្រង់ណា? តើត្រូវចាក់ដូចម្តេច? ជាដើម។ បន្ទាប់ពីរៀនទ្រឹស្តីរួច អ្នកសិក្សាត្រូវទៅអនុវត្តចាក់ថ្នាំសត្វដោយផ្ទាល់។ មនុស្សមានចំណេះដឹង និងចំណេះធ្វើមិនទាន់ឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់សង្គមបានឡើយ ពោលគឺមនុស្សត្រូវមានសីលធម៌បន្ថែមទៀត។

ការរៀនឱ្យមានសីលធម៌ល្អជាការសំខាន់ណាស់សម្រាប់ការរស់នៅក៏ដូចជាការប្រកបរបរចិញ្ចឹមជីវិត។ សីលធម៌ ជាចន្លុះសម្រាប់នាំផ្លូវមនុស្សទៅរកសេចក្តីថ្លៃថ្នូរ។ សីលធម៌ជួយឱ្យមនុស្សមានឥរិយាបថល្អប្រពៃ ចេះគោរពច្បាប់ គោរពវិន័យ មិនប្រព្រឹត្តអំពើពុករលួយ មិនកេងប្រវ័ញ្ចគ្នា មិនប្រព្រឹត្តអំពើអាក្រក់ជាដើម។ សីលធម៌ប្រៀបដូចជាចង្កូតជួយតម្រង់មនុស្សឱ្យដើរតាមតែផ្លូវល្អ។ មនុស្សដែលគ្មានសីលធម៌ប្រៀបដូចជារថយន្តដាច់ចង្កូត រត់រេវពេញផ្លូវនឹងបង្កគ្រោះថ្នាក់ជាក់ជាមិនខាន។ សីលធម៌កើតចេញពីការចេះគោរពប្រតិបត្តិដំបូន្មានល្អៗ ទំនៀមទម្លាប់ ប្រពៃណី បទបញ្ញត្តិ វិន័យ និងច្បាប់របស់សង្គម។ ឧទាហរណ៍អ្នករៀនបង្កើតអាវុធជាតិផ្ទុះបានចេះស្ទាត់ជំនាញហើយ ប៉ុន្តែគ្មានសីលធម៌ អ្នកអាចនឹងបង្កគ្រោះថ្នាក់ដល់មនុស្សជាតិ ព្រោះគេអាចប្រើប្រាស់ជំនាញរបស់គេទៅសម្លាប់មនុស្សបំផ្លាញហេដ្ឋារចនាសម្ព័ន្ធផ្សេងៗជាដើមដូចជាពួកភេរវកម្មសព្វថ្ងៃនេះ។

មនុស្សត្រូវមានចំណេះដឹង ចំណេះធ្វើ និងមានសីលធម៌ មិនទាន់ឆ្លើយតបទៅនឹងសេចក្តីត្រូវការសង្គមបានទេ ពោលគឺមនុស្សត្រូវចេះរួមរស់ជាមួយគ្នាប្រកបដោយសុខសន្តិភាពថែមទៀតទើបប្រសើរ។ ការរៀនឱ្យចេះរួមរស់ជាមួយគ្នាប្រកបដោយសុខសន្តិភាព ជាបំណងប្រាថ្នាទូទៅរបស់ពិភពលោក។ ដើម្បីសុខសន្តិភាពមនុស្សត្រូវចេះគោរពស្រឡាញ់គ្នា យោគយល់អធ្យាស្រ័យគ្នា ចេះជួយគ្នាទៅវិញទៅមក។ ជាពិសេសមិនត្រូវរើសអើង សាសនា ជាតិសាសន៍ មនោគមវិជ្ជា និន្នាការនយោបាយ វណ្ណៈ និងពណ៌សម្បុរជាដើម។ បើមនុស្សគ្រប់រូបប្រកាន់ខ្ជាប់នូវកត្តាទាំងនេះ នោះប្រទេសនីមួយៗក៏ដូចជាពិភពលោកទាំងមូលនឹងមានសុខសន្តិភាពជាក់ជាមិនខាន។ ជាក់ស្តែងដូចជាប្រទេស កម្ពុជាបច្ចុប្បន្នប្រជាពលរដ្ឋយើង គោរពសាសនាផ្សេងៗគ្នាមានព្រះពុទ្ធសាសនា ឥស្លាមសាសនា គ្រិស្តសាសនា និងមានជនជាតិខ្មែរដើមភាគតិច មានជំនឿលើដូនតា អារក្ស អ្នកតា មេកន្ទ្រាញជាដើម។ ប៉ុន្តែការរស់នៅរបស់ប្រជាជនយើងមានភាពសុខដុមទាំងអស់គ្នា។

សរុបសេចក្តីមក សាលារៀនជាកន្លែងបណ្តុះបណ្តាលមនុស្សឱ្យមានចំណេះដឹង មានចំណេះធ្វើ មានសីលធម៌ និងចេះរួមរស់ជាមួយគ្នាប្រកបដោយសុខសន្តិភាព ហើយដែលកត្តានេះជាបំណងប្រាថ្នារបស់ពិភពលោកទាំងមូល។

ពំនោលដែលបានពោលខាងលើពិតជាមានអត្ថន័យជ្រាលជ្រៅសម្រាប់អប់រំទូន្មានយើងគ្រប់រូបឱ្យបានយល់ដឹងពីតម្លៃដ៏ពិសិដ្ឋរបស់ចំណេះវិជ្ជា ដែលជាគ្រឿងនាំមនុស្សទៅរកសុភមង្គល។ ដូច្នេះក្នុងនាមយើងជាសិស្សានុសិស្សត្រូវខិតខំប្រឹងប្រែងព្យាយាមរៀនសូត្រឱ្យបានហ្មត់ចត់តាំងពីតូចរហូតដល់ធំ ដើម្បីទទួលបាននូវចំណេះវិជ្ជា ដែលជាគ្រឿងដ៏ប្រសើរថ្លៃថ្លារបស់មនុស្សទូទៅក្នុងពិភពលោក។

**ប្រធានទី៤:** ពាក្យស្លោកមួយថែងថា «សាមគ្គីនាំមកនូវជ័យជម្នះ»។ ចូរបកស្រាយពាក្យស្លោកខាងលើ ដោយលើកឧទាហរណ៍បញ្ជាក់ផង។

## គម្រោងតែង

### ក- សេចក្តីផ្តើម

- **លំនាំបញ្ហា:** និយាយទូទៅទាក់ទងនឹងប្រធាន គោលបំណងពាក្យស្លោក និយាយទាក់ទងនឹងសាមគ្គីភាព...
- **ចំណូលបញ្ហា(បង្ហាញបញ្ហា):** ការលើកយកប្រធានមកបង្ហាញ...សាមគ្គីនាំមកនូវជ័យជម្នះ...
- **ចំណោទបញ្ហា:** ការចោទសួរទៅលើប្រធាន...តើពាក្យស្លោកនេះមានអត្ថន័យដូចម្តេច...។

### ខ- តួសេចក្តី

- **ឃ្លាភ្ជាប់សេចក្តី:** ដើម្បីជាជំនួយដល់ការបកស្រាយ.... គប្បីយល់នូវន័យនៃពាក្យគន្លឹះ...។
- **ពន្យល់ពាក្យគន្លឹះ៖**
  - ✓ សាមគ្គី: ...មានន័យថា ការរួបរួមកម្លាំងគ្នា ការស្រុះស្រួលគ្នាដើម្បីសម្រេចកិច្ចការតូចធំ...
  - ✓ ជ័យជម្នះ: ការឈ្នះ...។
- **ពន្យល់ន័យប្រធាន:** ដូច្នេះប្រធាននេះមានន័យថា ការស្រុះស្រួលគ្នា ការរួមកម្លាំងគ្នាគឺនាំឱ្យឈ្នះលើគ្រប់ការងារតូចធំ...។
- **បកស្រាយប្រធាន៖**
  - ✓ ការរួបរួមកម្លាំងគ្នា ការស្រុះស្រួលគ្នាពិតជាអាចយកឈ្នះលើកិច្ចការលំបាកៗបាន...
  - ✓ ការងារសង្គម ...
  - ✓ ក្នុងអក្សរសិល្ប៍ : រឿងចង្កឹះមួយបាច់ ... រឿងព្រាបជាប់លប់ឬនាយល្អ ... រឿងភ្នំប្រុសភ្នំស្រី ...។
- **សរុបសេចក្តី:** និយាយសរុបគំនិតរួមដែលបានបកស្រាយរួចមក.... សាមគ្គីពិតជាកត្តានាំមកនូវជ័យជម្នះ ពិតប្រាកដមែន។

### គ- សេចក្តីបញ្ចប់

- **វាយតម្លៃប្រធាន:** ពាក្យស្លោកខាងលើពិតជាមានអត្ថន័យអប់រំ សម្រាប់មនុស្សទូទៅឱ្យចេះរួមកម្លាំងគ្នាដើម្បីសម្រេចកិច្ចការតូចធំទាំងឡាយ ក្នុងដំណើរជីវិតរស់នៅ...
- **យោបល់ផ្ទាល់ខ្លួន:** ដូច្នេះយើងជាយុវជន ដែលជាសសរទ្រូងនៃប្រទេសជាតិ ត្រូវចេះរួបរួមកម្លាំងគ្នាសាមគ្គីគ្នាចូលរួមកសាងអភិវឌ្ឍជាតិ និងការពារទឹកដីអង្គរដ៏បវររុងរឿង... ។

## សេចក្តីអធិប្បាយ

កិច្ចការខ្លះអាចសម្រេចទៅបានដោយមនុស្សតែម្នាក់ ឬច្រើននាក់។ ប៉ុន្តែកិច្ចការខ្លះទៀតអាចសម្រេច ឬទទួលបានជោគជ័យ លុះត្រាតែមានការចូលរួមពីមនុស្សច្រើននាក់ ឬការរួមគ្នាជាក្រុម។ ហេតុដូច្នេះហើយបានជាមានពាក្យស្លោកមួយថែងថា "សាមគ្គីនាំមកនូវជ័យជម្នះ"។

តើពាក្យស្លោកនេះ មានអត្ថន័យយ៉ាងណាខ្លះ?

មុននឹងឈានដល់ការបកស្រាយអត្ថន័យឱ្យបានច្បាស់លាស់ យើងគួរយល់នូវន័យនៃពាក្យគន្លឹះរបស់ប្រធានជាមុនសិនគឺពាក្យ " សាមគ្គី ជ័យជម្នះ "។ សាមគ្គីមានន័យថា ការរួបរួមកម្លាំងគ្នា ការស្រុះ

ស្រួលគ្នា ដើម្បីសម្រេចកិច្ចការតូចធំទាំងឡាយ។ ចំណែកពាក្យជ័យជម្នះមានន័យថា ការឈ្នះ។ ដូច្នេះ ប្រធានខាងលើមានន័យថា ការស្រុះស្រួលគ្នា ការរួមកម្លាំងគ្នា គឺនាំឱ្យឈ្នះលើគ្រប់ការងារតូចធំទាំងពួង។

ជាការពិតណាស់ ការស្រុះស្រួលគ្នា ការរួមកម្លាំងគ្នា គឺពិតជានាំមកនូវជ័យជម្នះលើគ្រប់ការងារតូចធំទាំងពួងបាន។ ជាក់ស្តែងដូចជាការសម្អាតទីក្រុង ការពារជាតិ ការពារទឹកដីជាដើម មិនអាចមាននរណាម្នាក់ធ្វើតែម្នាក់ឯងបានទេ លុះត្រាតែប្រជាពលរដ្ឋយើងទាំងអស់ ចូលរួមសាមគ្គីគ្នា ជួយគ្នាទាំងកម្លាំងកាយ ចិត្ត ប្រាជ្ញា ស្មារតី និងសម្ភារៈ ទើបទទួលបានជោគជ័យ។

ក្នុងកិច្ចការជាច្រើនទៀតដូចជាការអភិវឌ្ឍវិស័យអប់រំ គឺយើងត្រូវការកម្លាំងធនធានមនុស្សដូចជាបណ្ឌិត វិស្វករ គ្រូបង្រៀន និងមន្ត្រីជំនាញផ្សេងៗជាដើម។ រួមកម្លាំងធ្វើទាំងអស់គ្នា ទើបទទួលបានជោគជ័យ។ ចំណែកនៅក្នុងក្រុមហ៊ុនរកស៊ីវិញក៏ដូច្នោះដែរ មិនអាចមានតែថៅកែម្នាក់ធ្វើការបានជោគជ័យនោះទេ ប៉ុន្តែត្រូវមានបុគ្គលិកជាអ្នកជួយធ្វើថែមទៀតទើបល្អប្រសើរ។ ក្នុងបន្ទប់គ្រូពេទ្យវះកាត់អ្នកជំងឺមិនអាចមានតែដុកទ័រជំនាញវះកាត់ម្នាក់អាចធ្វើការបាននោះទេ ប៉ុន្តែត្រូវមានពេទ្យឯកទេសផ្សេងៗទៀត  ទើបការវះកាត់អាចដំណើរការបាន។

ចំណែកអក្សរសិល្ប៍វិញក៏ដូចគ្នាដែរ។ ក្នុងរឿងនាយល្អ ឬព្រាបជាប់លប់ នៅពេលដែលព្រាបទាំងអស់រួចពីលប់របស់ព្រាននោះ គឺដោយសារតែការស្រុះស្រួលគ្នា សាមគ្គីគ្នា រួមផ្សំនឹងការមានវិន័យល្អ ស្តាប់មេកោយ ធ្វើឱ្យព្រាបទាំងអស់ប្រឹងហើរព្រមៗគ្នា រហូតអាចបំបើងលប់របស់ព្រាន បានរួចជីវិតទាំងអស់គ្នា។ ចំណែករឿងចង្កឹះមួយបាច់ ពេលឪពុកឱ្យចង្កឹះទៅកូនកាច់ម្នាក់មួយបាច់ៗ កូនគ្រប់គ្នាមិនអាចកាច់បាក់ឡើយ។ ប៉ុន្តែពេលឪពុកយកចង្កឹះមួយបាច់មកចែកគ្នាកាច់ កូនគ្រប់គ្នាកាច់ចង្កឹះនោះមិនបាក់។ ក្នុងន័យដូចគ្នានេះដែរ បើមានមនុស្សតែម្នាក់ងាយស្រួលឱ្យគេផ្តួលរំលំ ឬងាយកាច់បំបាក់បានណាស់។ ប៉ុន្តែបើយើងមានគ្នាច្រើន ហើយសាមគ្គីគ្នាមិនមាននរណាងាយធ្វើអ្វីយើងបានឡើយ។ រីឯក្នុងរឿងភ្នំប្រុស ភ្នំស្រី ដោយសារការស្រុះស្រួលគ្នា រួមកម្លាំង សាមគ្គីគ្នារួមផ្សំនឹងប្រាជ្ញាធ្វើឱ្យក្រុមស្រីៗ ពូនភ្នំបានខ្ពស់ជាងប្រុសៗ ទទួលជ័យជម្នះលើក្រុមប្រុសៗហើយអាចកែប្រែទំនៀមទម្លាប់ប្រពៃណីវិញ។

ឆ្លងតាមការបកស្រាយរួចមកហើយ យើងឃើញថា ការរួបរួមកម្លាំងគ្នា ការស្រុះស្រួលគ្នាពិតជានាំមកនូវជ័យជម្នះដ៏ធំធេងប្រាកដមែន។

ពាក្យស្លោកខាងលើពិតជាមានអត្ថន័យអប់រំសម្រាប់មនុស្សទូទៅឱ្យចេះរួមកម្លាំងគ្នាដើម្បីសម្រេចកិច្ចការតូចធំទាំងឡាយ ក្នុងដំណើរជីវិតរស់នៅ។ ដូច្នេះយើងជាយុវជន ដែលជាសសរទ្រូងនៃប្រទេសជាតិត្រូវចេះរួបរួមកម្លាំងគ្នា សាមគ្គីគ្នាចូលរួមកសាងអភិវឌ្ឍជាតិនិងការពារទឹកដីអង្គរដ៏បវររុងរឿងកុំឱ្យមានបរទេសឈ្លានពានបានឡើយ។

**ប្រធានទី៥:** ពាក្យស្លោកមួយបានពោលថា «ការសេពគប់មនុស្សពាលនាំឱ្យអន្តរាយដល់ខ្លួន»។ ចូរពន្យល់បកស្រាយពាក្យស្លោកខាងលើឱ្យបានក្បោះក្បាយនិងលើកឧទាហរណ៍មកបញ្ជាក់ផង។

## គម្រោងតែង

**ក- សេចក្តីផ្តើម**

- **លំនាំបញ្ហា:** និយាយទាក់ទងនឹង គោលបំណងនៃពាក្យស្លោកនេះ...ការរស់នៅ ការទំនាក់ទំនងគ្នា ការសេពគប់...
- **ចំណូលបញ្ហា(បង្ហាញបញ្ហា):** ការលើកយកប្រធានមកបង្ហាញ...ការសេពគប់មនុស្សពាលនាំឱ្យអន្តរាយដល់ខ្លួន...
- **ចំណោទបញ្ហា:** ការចោទសួរទៅលើប្រធាន...តើពាក្យស្លោកនេះមានអត្ថន័យដូចម្តេច?

**ខ- តួសេចក្តី**

- **ឃ្លាភ្ជាប់សេចក្តី:** ដើម្បីជាជំនួយដល់ការបកស្រាយ គប្បីយល់នូវន័យនៃពាក្យគន្លឹះរបស់ប្រធានជាមុនសិន...។
- **ពន្យល់ពាក្យគន្លឹះ៖**
  - ✓ សេព: សេព មានន័យថាអាស្រ័យ រាប់រក រាប់រកយកគ្នា គប់រកគ្នា ប្រព្រឹត្ត ប្រតិបត្តិ ប្រើប្រាស់ បរិភោគ ផឹក...
  - ✓ ពាល: ពាល មានន័យថា ល្ងង់ខ្លៅ មិនឈ្លាសវៃ កាច សាហាវ អាក្រក់...
  - ✓ អន្តរាយ: អន្តរាយ មានន័យថា ការខូចប្រយោជន៍ សេចក្តីវិនាស...។
- **ពន្យល់ន័យប្រធាន:** ដូច្នេះប្រធានខាងលើមានន័យថា ការរាប់រកមនុស្សអាក្រក់ នាំឱ្យវិនាស ខូចខាតខ្លួនឯង...។
- **បកស្រាយប្រធាន៖**
  - ✓ បើសេពគប់មិត្តល្អនាំឱ្យទទួលបាននូវលទ្ធផលល្អ...ការសេពគប់ចំមនុស្សពាលនាំឱ្យយើងទទួលបាននូវលទ្ធផលអាក្រក់...ការសេពគប់មនុស្សទំនើង...នាំឱ្យមានទុក្ខ... ខូចអនាគត...
  - ✓ ឧទាហរណ៍នៅក្នុងសង្គមជាក់ស្តែង...
  - ✓ ការសេពគប់មនុស្សមានល្បិចកល... បោកប្រាស់... នាំឱ្យមានទុក្ខ...
  - ✓ ឧទាហរណ៍នៅក្នុងសង្គមជាក់ស្តែង...
  - ✓ ឧទាហរណ៍នៅក្នុងអក្សរសិល្ប៍រឿង តាបសនិងហិបប្រាក់...
  - ✓ ការសេពគប់អ្នកប្រើប្រាស់គ្រឿងញៀន...នាំឱ្យខូចសុខភាព...
  - ✓ ឧទាហរណ៍នៅក្នុងសង្គមជាក់ស្តែង...
  - ✓ ការសេពគប់អ្នកលេងល្បែង...នាំឱ្យអស់ទ្រព្យសម្បត្តិ...
  - ✓ ឧទាហរណ៍នៅក្នុងសង្គមជាក់ស្តែង...។
- **សរុបសេចក្តី...** ទាំងនៅក្នុងសង្គមជាក់ស្តែងក្តី ក្នុងអក្សរសិល្ប៍ក្តី ការរាប់រកមនុស្សដែលប្រព្រឹត្តអំពើអាក្រក់ដូចជា មនុស្សទំនើង មនុស្សមានល្បិចកល អ្នកលេងល្បែង ចោរ អ្នករកស៊ីខុសច្បាប់... នាំឱ្យខ្លួនវិនាស មានទុក្ខទោស...។

**គ- សេចក្តីបញ្ចប់**

- **វាយតម្លៃប្រធាន**: ពាក្យស្លោកខាងលើពិតជាមានអត្ថន័យអប់រំយ៉ាងជ្រាលជ្រៅ... សម្រាប់កូនខ្មែរគ្រប់រូបយកទៅអនុវត្តក្នុងជីវភាពរស់នៅប្រកបដោយសេចក្តីសុខ...
- **យោបល់ផ្ទាល់ខ្លួន**: ដូច្នេះក្នុងនាមយើងជាអ្នកសិក្សា ត្រូវខិតខំសិក្សាស្រាវជ្រាវពាក្យស្លោកខ្មែរយើងដើម្បីរៀនសូត្រនិងយកមកអនុវត្ត...។

## សេចក្តីអធិប្បាយ

ពាក្យស្លោក សុភាសិត កំណាព្យ រឿងនិទាន និងដំបូន្មានផ្សេងៗជាច្រើនទៀតសុទ្ធតែមានគោលបំណងអប់រំ ទូន្មានប្រៀនប្រដៅមនុស្សទូទៅ ឱ្យចេះរស់នៅប្រកបដោយសេចក្តីសុខ។ ដូចពាក្យស្លោកមួយបានពោលថា "ការសេពគប់មនុស្សពាលនាំឱ្យអន្តរាយដល់ខ្លួន"។

តើពាក្យស្លោកខាងលើនេះ មានអត្ថន័យដូចម្តេច?

ដើម្បីជាជំនួយដល់ការបកស្រាយពាក្យស្លោកខាងលើឱ្យកាន់តែក្បោះក្បាយថែមទៀតនោះ យើងគប្បីយល់នូវន័យនៃពាក្យគន្លឹះជាមុនសិនគឺពាក្យ " សេព ពាល អន្តរាយ "។ សេព មានន័យថា អាស្រ័យ រាប់រក រាប់រកយកគ្នា គប់រកគ្នា ប្រព្រឹត្ត ប្រតិបត្តិ ប្រើប្រាស់ បរិភោគ ផឹក។ ពាល មានន័យថា ល្ងង់ខ្លៅ មិនឈ្លាសវៃ កាចសាហាវ អាក្រក់។ អន្តរាយមានន័យថា ការខូចប្រយោជន៍ សេចក្តីវិនាស ការខូចខាត។ ដូច្នេះប្រធានខាងលើមានន័យថា ការរាប់រកមនុស្សអាក្រក់នាំឱ្យវិនាស ខូចខាតខ្លួនឯង។

ការរស់នៅក្នុងសង្គម មនុស្សម្នាក់ៗតែងមានការទាក់ទងគ្នា រាប់អានគ្នា និងអាចឈានទៅដល់សេពគប់គ្នាជាមិត្តថែមទៀតផង។ ការសេពគប់គ្នាជាមិត្តផ្តល់លទ្ធផលពីរយ៉ាងគឺ បើសេពគប់ចំមិត្តល្អនាំឱ្យយើងទទួលបាននូវលទ្ធផលល្អ ពោលគឺធ្វើឱ្យយើងទទួលបានផលចំណេញ ហើយអាចរស់នៅបានសុខសាន្ត។ ប៉ុន្តែបើការសេពគប់ចំមនុស្សពាលនាំឱ្យយើងទទួលបាននូវលទ្ធផលអាក្រក់ជាច្រើន ដូចជាការសេពគប់មនុស្សទំនើងនាំឱ្យយើងខូចកេរ្តិ៍ឈ្មោះ បាត់កិត្តិយសសេចក្តីថ្លៃថ្នូរ ខូចអនាគត និងអាចធ្វើឱ្យមានទុក្ខទោសថែមទៀតផង ព្រោះមនុស្សប្រភេទនេះតែងមិនសូវគិតពីការរៀនសូត្រ ចូលចិត្តប្រព្រឹត្តអំពើពាលាអាវាសែ អំពើផ្តាំផ្គង អសីលធម៌ធ្វើឱ្យខូចសណ្តាប់ធ្នាប់សង្គម។ លើសពីនេះទៀតពួកគេមានឥរិយាបថច្រងេងច្រងាង ឫកពាពុំសមរម្យ ព្រហើនកោងកាច។ ពេលខ្លះពួកគេបង្កទំនាស់វាយតប់ កាប់ចាក់គ្នាទៀតផង។ ពួកទាំងនេះមិនត្រឹមតែបំផ្លិចបំផ្លាញខ្លួនឯងប៉ុណ្ណោះទេ តែថែមទាំងបំផ្លិចបំផ្លាញគ្រួសារនិងអ្នកដទៃទៀតផង។ មនុស្សទំនើងជាប្រភេទមនុស្សដែលសង្គមស្អប់ខ្ពើម។ ដូចជាក្នុងសង្គមបច្ចុប្បន្នមនុស្សទំនើង ពិសេសក្នុងចំណោមយុវវ័យក្មេងៗតែងវាយតប់ កាប់ចាក់គ្នានៅតាមទីសាធារណៈ ក្នុងពិធីរាំវង់ជាដើម ដោយគ្រាន់ទំនាស់បន្តិចបន្តួចប៉ុណ្ណោះដូចជា រាំប៉ះគ្នា សម្លឹងមុខឌឺដងដាក់គ្នាជាដើម។

ការសេពគប់មនុស្សមានចរិតមិនស្មោះត្រង់មានល្បិចកលឆបោកនាំឱ្យយើងខាតបង់ទ្រព្យសម្បត្តិ និងអាចរងទុក្ខទោសទៀតផង។ មនុស្សប្រភេទនេះ តែងរិះរកគ្រប់មធ្យោបាយដើម្បីធ្វើឱ្យយើងជឿទុកចិត្ត ហើយឆ្លៀតឱកាសនោះបោកប្រាស់យើងតែម្តង។ ករណីខ្លះជនប្រភេទនេះធ្វើជាមករាប់អានយើង ចង់ជួយយើងពេលយើងជឿទុកចិត្តគេក៏មានឱកាសបោកប្រាសតែម្តង។ ករណីខ្លះទៀតពួកគេបានប្រព្រឹត្តកំហុសអ្វីមួយរួចទម្លាក់កំហុសនោះមកឱ្យយើងជាអ្នកទទួល។ តួយ៉ាងនៅក្នុងសង្គមជាក់ស្តែង មានជនខិលខូចខ្លះបានមកស្និទ្ធស្នាលនឹងយើងសុំរាប់អានយើងជាមិត្ត ពេលយើងជឿជាក់ហើយ

គេប្រើកលល្បិចឱ្យយើងដើរឃោសនាថានឹងជួយរកការងារឱ្យធ្វើដោយឱ្យបង់ប្រាក់ជាមុន ពេលបានប្រាក់ហើយគេគេចបាត់ទៅ។ រីឯនៅក្នុងរឿង តាបស និងហិបប្រាក់វិញ យើងឃើញតាបសចូលមកដល់ក្នុងផ្ទះអ្នកស្រុកក៏សម្តែងអាកប្បកិរិយាឱ្យម្ចាស់ផ្ទះជឿថាគាត់ជាមនុស្សមានសីលស្មោះត្រង់។ ពេលម្ចាស់ផ្ទះជឿជាក់ហើយតាបសនោះក៏លួចយកហិបប្រាក់ទៅបាត់។

ការសេពគប់អ្នកប្រើប្រាស់គ្រឿងញៀន ធ្វើឱ្យយើងក្លាយខ្លួនជាអ្នកប្រើប្រាស់ជាក់ជាមិនខាន ព្រោះពួកគេតែងតែបញ្ចុះបញ្ចូល ដាក់សម្ពាធ រកវិធីផ្សេងៗ ឱ្យប្រើប្រាស់ដូចពួកគេដែរ។ យូរៗទៅយើងក៏ក្លាយជាមនុស្សញៀនថ្នាំដែលមិនងាយកែខ្លួនបានឡើយ។ ពេលប្រើប្រាស់យូរៗទៅធ្វើឱ្យយើងញៀនទ្រាំលែងបានឈានទៅដល់បំផ្លិចបំផ្លាញទ្រព្យសម្បត្តិក្នុងផ្ទះ រហូតអាចឈានដល់ទៅប្រព្រឹត្តអំពើអបាយមុខផ្សេងៗទៀតផង។ ការប្រើប្រាស់គ្រឿងញៀនធ្វើឱ្យយើងខូចសុខភាព និងខូចអនាគតថែមផង។ តួយ៉ាងនៅក្នុងប្រទេសកម្ពុជាយើងបច្ចុប្បន្នមានយុវវ័យមួយចំនួនបានក្លាយខ្លួនជាអ្នកប្រើប្រាស់គ្រឿងញៀនដោយសារការអូសទាញពីមិត្តភក្តិ។
អ្នកទាំងនោះក្លាយជាមនុស្សខូចសុខភាពក្លាយជាមនុស្សបំផ្លិចបំផ្លាញទ្រព្យសម្បត្តិក្នុងគ្រួសារ គ្រួសារបាត់បង់សុភមង្គល បង្កអំពើហិង្សា ក្លាយជាជនល្មើស លួច ឆក់ ប្លន់បង្កអសន្តិសុខក្នុងសង្គមជាដើម។ ចុងក្រោយមនុស្សប្រភេទនេះ មានអ្នកខ្លះក្លាយជាអ្នកទោស អ្នកខ្លះក្លាយជាឃាតកនិងអ្នកខ្លះទៀតឈានទៅដល់ធ្វើអត្តឃាតទៀតផង។

ការសេពគប់អ្នកលេងល្បែងយូរៗទៅក៏ធ្វើឱ្យយើងក្លាយខ្លួនជាអ្នកលេងល្បែងដែរ ព្រោះថាកាលណាដើរជាមួយគេហើយត្រូវបានគេបញ្ចុះបញ្ចូលផង នោះនឹងធ្វើឱ្យយើងញៀននឹងល្បែងដូចគេដែរ។ ការលេងល្បែង ធ្វើឱ្យខាតបង់ទ្រព្យសម្បត្តិ ហើយពេលញៀនមែនទែនទៅនឹងលក់ឬបញ្ចាំរបស់របរផ្ទះសម្បែងរហូតអាចធ្លាក់ខ្លួនក្រជាក់ជាមិនខាន។ យ៉ាងណាមិញអ្នកខ្លះមិនចេះលេងល្បែងទេ តែមានមិត្តភក្តិជាអ្នកលេង។ នៅពេលមិត្តភក្តិចេះតែបបួលយូរៗទៅក៏ចេះលេងដែរ។ មុនដំបូងលេងតិចតួចជាមួយគេយូរៗទៅក្លាយជាអ្នកលេងធំចាញ់អស់ទ្រព្យសម្បត្តិ។

សរុបសេចក្តីមក ក្នុងសង្គមជាក់ស្តែងក្តី ក្នុងអក្សរសិល្ប៍ក្តីការរាប់រកមនុស្សដែលប្រព្រឹត្តអំពើអាក្រក់ដូចជា មនុស្សទំនើង មនុស្សពាលាអាវាសែ មនុស្សមានល្បិចកល អ្នកលេងល្បែង នាំឱ្យខ្លួនវិនាស មានទុក្ខទោស កើតសេចក្តីអន្តរាយជាក់ជាពុំខានឡើយ។

ពាក្យស្លោកខាងលើពិតជាមានអត្ថន័យអប់រំយ៉ាងជ្រាលជ្រៅសម្រាប់កូនខ្មែរគ្រប់រូបយកទៅអនុវត្តក្នុងជីវភាពរស់នៅប្រកបដោយសេចក្តីសុខ។ ដូច្នេះអ្នកសិក្សាត្រូវខិតខំសិក្សាស្រាវជ្រាវ រៀនសូត្រ និងយកមកអនុវត្ត ជាពិសេសត្រូវចេះជ្រើសរើសមិត្តល្អដើម្បីរាប់រក សំដៅផ្តល់ប្រយោជន៍ដល់ដំណើរជីវិតរស់នៅប្រកបដោយសេចក្តីសុខ។

**ប្រធានទី៦**: ចូរបកស្រាយពាក្យស្លោក «វិជ្ជាជាទ្រព្យជាប់នឹងប្រាណ ចោរលួចក៏មិនបាន ចាយច្រើនរឹតតែចម្រើនឡើង»។ ចូរបកស្រាយពាក្យស្លោកខាងលើ ដោយលើកឧទាហរណ៍មកបញ្ជាក់។

## គម្រោងតែង

### ក- សេចក្តីផ្តើម

- **លំនាំបញ្ហា**: និយាយទូទៅទាក់ទងនឹងបញ្ហារបស់ប្រធាន និងនិយាយទាក់ទងនឹងអត្ថប្រយោជន៍នៃចំណេះវិជ្ជា ...
- **ចំណូលបញ្ហា(បង្ហាញបញ្ហា)**: បញ្ចូលប្រធាន...វិជ្ជាជាទ្រព្យជាប់នឹងប្រាណ ចោរលួចក៏មិនបានចាយច្រើនរឹតតែចម្រើនឡើង...
- **ចំណោទបញ្ហា**: ចោទតាមបែបប្រធានពន្យល់...តើពាក្យស្លោកនេះមានអត្ថន័យដូចម្តេច...។

### ខ- តួសេចក្តី

- **ឃ្លាភ្ជាប់សេចក្តី**: ...ដើម្បីជាជំនួយដល់ការបកស្រាយ គប្បីយល់នូវន័យនៃពាក្យគន្លឹះរបស់ប្រធានជាមុនសិន...។
- **ពន្យល់ពាក្យគន្លឹះ**៖
  - ✓ វិជ្ជា: មានន័យថា ចំណេះដឹង សេចក្តីដឹងច្បាស់ ការចេះដឹងលើមុខជំនាញផ្សេងៗ ហើយវាកើតឡើងពីការសិក្សារៀនសូត្រ...
  - ✓ ទ្រព្យ: មានន័យថា សម្បត្តិធនធានដែលមានម្ចាស់ដូចជាវត្ថុ ប្រាក់កាស មាស ពេជ្រ ...
  - ✓ ប្រាណ: មានន័យថា ជីវិត ខ្លួនដែលមានដង្ហើមចេញចូល...
  - ✓ ចាយ: មានន័យថា ចំណាយ ឬប្រើប្រាស់...។
- **ពន្យល់ន័យប្រធាន**: ចំណេះដឹង ការចេះដឹងលើមុខជំនាញផ្សេងៗជាសម្បត្តិធនធាននៅជាប់នឹងជីវិត... បើកាលណាយើងចំណាយ ឬប្រើប្រាស់ច្រើន វារឹតតែរីកចម្រើន យល់ដឹងកាន់តែច្រើន ទទួលផលប្រយោជន៍កាន់តែច្រើន... គឺកើនឡើងជាលំដាប់ទាំងចំណេះដឹងថ្មីៗទាំងទ្រព្យសម្បត្តិក្រៅខ្លួន។
- **បកស្រាយប្រធាន**: វិជ្ជា ឬចំណេះដឹង បើកាលណាយើងប្រើប្រាស់កាន់តែច្រើន នាំឱ្យយើង រឹតតែរីកចម្រើន និងទទួលបានផលប្រយោជន៍កាន់តែច្រើន៖
  - ✓ សិស្សានុសិស្ស និងអ្នកសិក្សាទាំងឡាយដែលខិតខំស្រវាស្រទាញ សិក្សាស្រាវជ្រាវរៀនសូត្រគ្រប់ជំនាញដើម្បីទទួលបានការងារ ឬមុខរបរគាប់ប្រសើរសម្រាប់ជីវិត។ គប្បីខំសិក្សាស្រាវជ្រាវរៀនសូត្រកាន់តែខ្លាំងទើបទទួលបានចំណេះដឹងកាន់តែខ្ពស់...
  - ✓ ចំណេះវិជ្ជា ជាទ្រព្យសម្បត្តិដ៏មានតម្លៃបំផុត សម្រាប់មនុស្សគ្រប់រូប។ វិជ្ជាមានលក្ខណៈល្អប្រសើរលើសទ្រព្យសម្បត្តិផងទាំងពួង ពីព្រោះថាបើមានចំណេះវិជ្ជាហើយ ទើបអាចរកទ្រព្យសម្បត្តិបាន តែបើមានទ្រព្យសម្បត្តិវិញ មិនអាចទិញឬដូរ ធ្វើឱ្យយើងកើតមាននូវចំណេះវិជ្ជាបានឡើយ...
  - ✓ ប្រាជ្ញាមនុស្សយើង ប្រៀបដូចជាកាំបិតមុតស្រួច បើកាលណាយើងប្រើប្រាស់វាកាន់តែខ្លាំង ខិតខំសំលៀងវារាល់ថ្ងៃ នោះវាក៏កាន់តែមុតដែរ។ ផ្ទុយទៅវិញ កាំបិតកាលណាយើងទុកវាចោលលែងប្រើប្រាស់ នោះវានឹងមានច្រែះចាប់ ធ្វើឱ្យវាពុករេចរិល ប្រើការលែងកើតជាក់ជាមិនខានឡើយ។ ចំណេះវិជ្ជាក៏ដូច្នោះដែរ បើកាលណាយើងមានចំណេះវិជ្ជា ហើយទុកចោល...

✓ អ្នកប្រកបអាជីវកម្ម... គឺតាំងពីអ្នកលក់ដូរតូចតាចរហូតដល់អ្នកជំនួញធំៗ កាលណាគេចំណាយដើមទុនកាន់តែច្រើន ផលចំណេញក៏ទទួលបានកាន់តែខ្លាំងដែរ។ អ្នករកស៊ីដែលបានប្រើប្រាស់ប្រាជ្ញាកាន់តែខ្លាំង នោះគេរកផលចំណេញក៏កាន់តែបានច្រើន...

✓ គ្រូបង្រៀន... ដែលខិតខំស្រាវជ្រាវដើម្បីបង្រៀន ធ្វើឱ្យពួកគាត់កាន់តែទទួលបានចំណេះដឹងថ្មីៗ បទពិសោធល្អៗ...

✓ អ្នកប្រាជ្ញ អ្នកវិទ្យាសាស្ត្រ ... បានខិតខំរុករក គាស់កកាយរាល់អាថ៌កំបាំងទាំងឡាយនៃធម្មជាតិ ឈានទៅគ្រប់គ្រងលើធម្មជាតិ និងចក្រវាឡ ព្រមទាំងបង្កើតបច្ចេកវិទ្យាបង្កើតសម្ភារៈបានច្រើនឥតគណនា តាំងពីរបស់តូចតាចរហូតដល់សម្ភារៈបច្ចេកទេសទំនើបៗ សម្រាប់បម្រើឱ្យផលប្រយោជន៍មនុស្សទូទៅ។ សមិទ្ធផលទាំងឡាយរបស់មនុស្ស កើតឡើងពីចំណេះវិជ្ជា...។

- **សរុប**: វិជ្ជា ឬចំណេះដឹង បើកាលណាយើងប្រើប្រាស់កាន់តែច្រើន នាំឱ្យយើងកាន់តែរីកចម្រើន និងទទួលបានផលប្រយោជន៍កាន់តែច្រើន គឺកើនឡើងជាលំដាប់ទាំងចំណេះដឹងថ្មីៗ ទាំងទ្រព្យសម្បត្តិក្រៅខ្លួន...។

**គ- សេចក្តីបញ្ចប់**

- **វាយតម្លៃប្រធាន**: ពាក្យស្លោកខាងលើនេះ មានអត្ថន័យទូលំទូលាយ សម្រាប់អប់រំមនុស្សទូទៅឱ្យស្គាល់តម្លៃនៃចំណេះវិជ្ជា ចេះប្រើចំណេះវិជ្ជាក្នុងផ្លូវសុចរិត សីលធម៌ និងមនុស្សធម៌...
- **យោបល់ផ្ទាល់ខ្លួន**: ដូច្នេះយើងជាសិស្ស ត្រូវខិតខំសិក្សារៀនសូត្រយកចំណេះដឹងគ្រប់មុខវិជ្ជា ដើម្បីអនាគតភ្លឺស្វាង...។

## សេចក្តីអធិប្បាយ

វិជ្ជាជាទ្រព្យដ៏មានតម្លៃលើសទ្រព្យសម្បត្តិទាំងឡាយរបស់មនុស្ស។ ដោយសារវិជ្ជា មនុស្សបានក្លាយជាមនុស្សដ៏អស្ចារ្យលើពិភពលោក។ ដោយសារវិជ្ជា មនុស្សអាចស្វែងយល់ច្បាស់ពីអាថ៌កំបាំងធម្មជាតិ។គ្រប់គ្រងពិភពលោក និងចក្រវាឡបាន។ ហេតុដូច្នេះ ហើយបានជាមានពាក្យស្លោកមួយថែងថា«វិជ្ជាជាទ្រព្យជាប់នឹងប្រាណ ចោរលួចក៏មិនបាន ចាយច្រើនរឹតតែចម្រើនឡើង»។

តើពាក្យស្លោកខាងលើ មានអត្ថន័យដូចម្តេចខ្លះ?

មុននឹងឈានចូលដល់ការបកស្រាយប្រធានខាងលើឱ្យបានក្បោះក្បាយ យើងគួរយល់នូវន័យនៃពាក្យគន្លឹះមួយចំនួនជាមុនសិនគឺពាក្យ «វិជ្ជា ទ្រព្យ ប្រាណ ចាយ»។ ពាក្យវិជ្ជា មានន័យថា ចំណេះដឹង សេចក្តីដឹងច្បាស់ ការចេះដឹងលើមុខជំនាញផ្សេងៗ។ ឯពាក្យទ្រព្យមានន័យថា ជាសម្បត្តិ ធនធានទាំងឡាយដែលមានម្ចាស់ដូចជាវត្ថុប្រើប្រាស់ ដីធ្លី ផ្ទះសម្បែង ប្រាក់កាស មាស ពេជ្រ កែវកងជាដើម។ រីឯពាក្យ ប្រាណមានន័យថា ជីវិត ខ្លួន សារពាង្គកាយ ដែលមានដង្ហើមចេញចូលជាដើម។ ចំណែកឯពាក្យ ចាយ មានន័យថា ចំណាយឬប្រើប្រាស់។ ដូច្នេះពាក្យស្លោកនេះមានន័យថា ចំណេះដឹង ការចេះដឹងលើមុខជំនាញផ្សេងៗ ជាសម្បត្តិធនធាននៅជាប់នឹងជីវិត បើកាលណាយើងចំណាយ ឬប្រើប្រាស់ច្រើន វារឹតតែរីកចម្រើន យល់ដឹងកាន់តែច្រើន ទទួលផលប្រយោជន៍កាន់តែច្រើន គឺកើនឡើងជាលំដាប់ទាំងចំណេះដឹងថ្មីៗ ទាំងទ្រព្យសម្បត្តិក្រៅខ្លួនដូចជាវត្ថុប្រើប្រាស់ ដីធ្លី ផ្ទះសម្បែងប្រាក់កាស មាស ពេជ្រ កែវកងជាដើម។

ជាការពិតណាស់ វិជ្ជាឬចំណេះដឹង បើកាលណាយើងប្រើប្រាស់កាន់តែច្រើន នាំឱ្យយើងរឹតតែរីកចម្រើន និងទទួលបានផលប្រយោជន៍កាន់តែច្រើនសម្រាប់ជីវិតមនុស្សម្នាក់ៗ។ សិស្សានុសិស្ស និងអ្នកសិក្សាទាំងឡាយដែលខិតខំស្រវាស្រទេញ សិក្សាស្រាវជ្រាវរៀនសូត្រគ្រប់ជំនាញដើម្បីទទួលបានចំណេះដឹង ជំនាញ ដើម្បីធ្វើការងារ ឬមុខរបរគាប់ប្រសើរសម្រាប់ជីវិត។ ការខិតខំសិក្សាស្រាវជ្រាវរៀនសូត្រកាន់តែខ្លាំង គេទទួលបានចំណេះដឹងកាន់តែខ្ពស់ មានមុខរបរកាន់តែប្រសើរ រកទ្រព្យសម្បត្តិមាសប្រាក់កាន់តែបានច្រើនទ្វេឡើង។

ចំណេះវិជ្ជា គឺប្រៀបដូចជាទ្រព្យសម្បត្តិដ៏មានតម្លៃវិសេសវិសាលបំផុត សម្រាប់មនុស្សយើងម្នាក់ៗ។ ចំណេះវិជ្ជា មានលក្ខណៈល្អប្រសើរ លើសទ្រព្យសម្បត្តិផងទាំងពួង ព្រោះថាបើមានចំណេះវិជ្ជាហើយ ទើបអាចរកទ្រព្យសម្បត្តិបាន តែបើមានទ្រព្យសម្បត្តិវិញ មិនអាចទិញឬដូរ ធ្វើឱ្យយើងកើតមាននូវចំណេះវិជ្ជាបានឡើយ។ ម្យ៉ាងទៀត បើយើងមានចំណេះវិជ្ជានោះយើងនឹងមិនពិបាកទុកដាក់ឬលាក់បាំងឡើយ។ យើងធ្វើដំណើរទៅណាមកណា ក៏យើងអាចយកចំណេះវិជ្ជាទៅជាមួយបានដែរ។ យើងមានចំណេះវិជ្ជា មិនមានការព្រួយបារម្ភភ័យខ្លាចថា មានចោរលួច ឆក់ ប្លន់ឡើយ ព្រោះចំណេះវិជ្ជាវាបង្កប់ជាប់នៅក្នុងខួរក្បាលគ្រឿងវិញ្ញាណរបស់មនុស្ស មិនអាចមានអ្នកណាមើលឃើញ ឬចាប់កាន់វាបានឡើយ។ ដូច្នេះវិជ្ជាជាទ្រព្យជាប់នឹងប្រាណមិនអាចលួច ឆក់ ប្លន់បានឡើយ។

ខួរក្បាលមនុស្សយើង បើកាលណាប្រើប្រាស់កាន់តែច្រើន ប្រឹងគិតកាន់តែខ្លាំង ត្រិះរិះពិចារណាកាន់តែច្រើន នោះសតិបញ្ញាក៏ រីកលូតលាស់កាន់តែខ្លាំងណាស់ដែរ។ ប្រាជ្ញាមនុស្សយើងប្រៀបដូចជាកាំបិតមុតស្រួច បើកាលណាយើងប្រើប្រាស់វាកាន់តែខ្លាំង ខិតខំសំលៀងវាកាន់តែខ្លាំង នោះវាក៏កាន់តែមុតដែរ។ ផ្ទុយទៅវិញ កាំបិតកាលណាយើងទុកវាចោលលែងប្រើប្រាស់ នោះវានឹងមានច្រែះចាប់ធ្វើឱ្យវាពុករេចរិល ប្រើការលែងកើតជាក់ជាមិនខានឡើយ។ ចំណេះវិជ្ជាក៏ដូច្នោះដែរ បើកាលណាយើងមានចំណេះវិជ្ជា ហើយទុកចោលមិនបានយកមកប្រើប្រាស់ នោះវានឹងធ្វើឱ្យមានការភ្លេចភ្លាំងបាត់បង់ការរីកចម្រើនបន្តិចម្ដងៗ រហូតឈានទៅដល់បាត់ទាំងស្រុង ប្រើការលែងកើតតែម្ដង។ ដូច្នេះចំណេះវិជ្ជាដែលយើងមាន បើកាលណាយើងប្រើប្រាស់វាកាន់តែខ្លាំង នោះវានឹងធ្វើឱ្យបញ្ញាកាន់តែកើនឡើងថែមទៀត។

ចំពោះអ្នកប្រកបអាជីវកម្មវិញ គឺតាំងពីអ្នកលក់ដូរតូចតាចរហូតដល់អ្នកជំនួញធំៗ កាលណាគេចំណាយដើមទុនកាន់តែច្រើន នោះផលចំណេញក៏ទទួលបានកាន់តែខ្លាំងដែរ។ អ្នករកស៊ីដែលបានប្រើប្រាស់ប្រាជ្ញាកាន់តែខ្លាំង នោះគេរកផលចំណេញក៏កាន់តែបានច្រើន ហើយទទួលបានបទពិសោធនិងល្បិចរកស៊ីក៏កាន់តែមានកម្រិតខ្ពស់ដែរ។ ការរកផលចំណេញនិងទ្រព្យសម្បត្តិក៏បានកាន់តែបានច្រើនថែមទៀត។ ដូច្នេះការប្រកបមុខរបររកស៊ី កាលណាយើងចំណាយច្រើន នោះធ្វើឱ្យវាកាន់តែបានផលចម្រើនដែរ។

ចំណែកគ្រូបង្រៀន ដែលខិតខំស្រាវជ្រាវដើម្បីបង្រៀន ធ្វើឱ្យពួកគាត់កាន់តែទទួលបានចំណេះដឹងថ្មីៗបទពិសោធល្អៗ ធ្វើឱ្យមុខរបររបស់គាត់កាន់តែមានប្រសិទ្ធភាពនិងរកកម្រៃបានកាន់តែច្រើន។ អ្នកនិពន្ធ កវី បណ្ឌិត ខិតខំស្រាវជ្រាវ គាត់តែងនិពន្ធស្នាដៃល្អៗ ដែលធ្វើឱ្យស្នាដៃកាន់តែមានតម្លៃ និងប្រសិទ្ធភាពខ្ពស់។

អ្នកប្រាជ្ញ អ្នកវិទ្យាសាស្ត្រ បានខិតខំរុករក គាស់កកាយរាល់អាថ៌កំបាំងទាំងឡាយនៃធម្មជាតិ ឈានទៅគ្រប់គ្រងលើធម្មជាតិ និងចក្រវាឡ ព្រមទាំងបង្កើតបច្ចេកវិទ្យា បង្កើតសម្ភារៈបានច្រើនឥត

គណនាតាំងពីរបស់តូចតាចរហូតដល់សម្ភារៈបច្ចេកទេសទំនើបៗសម្រាប់បម្រើឱ្យផលប្រយោជន៍មនុស្សទូទៅ។ សមិទ្ធផលទាំងឡាយរបស់មនុស្សកើតឡើងពីចំណេះវិជ្ជាកើតពីខួរក្បាលរបស់មនុស្ស។ គ្មាននរណាម្នាក់អាចលួច ឆក់ប្លន់ ចំណេះវិជ្ជាពីអ្នកដទៃបានទេ ហើយចំណេះវិជ្ជាក៏គ្មានដាក់លក់នៅលើទីផ្សារដែរ។

សរុបមកវិជ្ជា ជាសម្បត្តិធនធាននៅជាប់នឹងខ្លួន គ្មានអ្នកណាអាចលួច ឆក់ ប្លន់បានឡើយ។ ចំណេះវិជ្ជា កាលណាយើងប្រើប្រាស់វាកាន់ច្រើន វាក៏កាន់តែរីកចម្រើនឡើងនិងទទួលបានទ្រព្យសម្បត្តិក្រៅខ្លួនកាន់តែច្រើន ព្រមទាំងផលប្រយោជន៍កាន់តែច្រើន សម្រាប់ជីវិតរស់នៅរបស់មនុស្សម្នាក់ៗ។

ពាក្យស្លោកខាងលើនេះ មានអត្ថន័យទូលំទូលាយ សម្រាប់អប់រំមនុស្សទូទៅឱ្យស្គាល់តម្លៃនៃចំណេះវិជ្ជា ចេះប្រើចំណេះវិជ្ជាក្នុងផ្លូវសុចរិត សីលធម៌ និងមនុស្សធម៌ ។ ដូចនេះយើងជាសិស្ស ត្រូវខិតខំក្រេបជញ្ជក់យកចំណេះដឹងគ្រប់មុខវិជ្ជា ដុសខាត់ប្រាជ្ញាស្មារតីឱ្យកាន់តែរីកលូតលាស់ ដើម្បីទទួលបានអនាគតភ្លឺស្វាង។

---

**ប្រធានទី៧:** ពាក្យស្លោកមួយចែងថា «យុវជន គឺជាធនធានមនុស្សរបស់ប្រទេសជាតិ»។ តើអ្នកត្រូវមានកាតព្វកិច្ចយ៉ាងណាខ្លះ? ចូរអ្នកបកស្រាយពាក្យស្លោកខាងនេះ ដោយរកឧទាហរណ៍បញ្ជាក់។

---

## គម្រោងតែង

### ក- សេចក្ដីផ្ដើម

- **លំនាំបញ្ហា:** ផ្ដើមដោយនិយាយទូទៅទាក់ទងនឹងបញ្ហារបស់ប្រធានគឺ ធនធានមនុស្សក្នុងសង្គម ...
- **ចំណូលបញ្ហា(បង្ហាញបញ្ហា):** បញ្ចូលប្រធាន...យុវជន គឺជាធនធានមនុស្សរបស់ប្រទេសជាតិ...
- **ចំណោទបញ្ហា:** ...តើពាក្យស្លោកខាងលើ មានអត្ថន័យដូចម្ដេចខ្លះ...។

### ខ- តួសេចក្ដី

- **ឃ្លាភ្ជាប់សេចក្ដី:** ...ដើម្បីជាជំនួយដល់ការបកស្រាយ គប្បីយល់នូវន័យនៃពាក្យគន្លឹះរបស់ប្រធានជាមុនសិន...។
- **ពន្យល់ពាក្យគន្លឹះ៖**
  - ✓ យុវជន គឺសំដៅទៅលើស្រទាប់នៃមនុស្សក្នុងភាពកំលោះ ក្រមុំ ...
  - ✓ ធនធានមនុស្ស គឺជាមនុស្សដែលមានជំនាញ ... ។
- **ពន្យល់ន័យប្រធាន:** ប្រធានមានន័យថា ស្រទាប់យុវវ័យដែលមានថាមពលក្នុងការសិក្សា គឺជាមនុស្សប្រកបទៅដោយសមត្ថភាព...។
- បកស្រាយប្រធាន៖
  - ✓ យុវជន ជាកម្លាំងដ៏ចាំបាច់សម្រាប់សង្គម មានសារប្រយោជន៍ខ្លាំងណាស់ក្នុងពេលប្រទេសជាតិមានវិបត្តិ...ដោយសង្គ្រាមឈ្លានពានពីសំណាក់សត្រូវ ឬមួយក្នុងគ្រាមានអាសន្ន...
  - ✓ យុវជន ជាអ្នកឈានមុខក្នុងការបំពេញកាតព្វកិច្ចជូនជាតិមាតុភូមិ...ដើម្បីស្វែងរកភាពសុខសាន្តជូនប្រជារាស្ត្រ...

- ✓ យុវជនពោរពេញទៅដោយថាមពលក្នុងការសិក្សាស្រាវជ្រាវ ដោយការលះបង់ពេលវេលាសម្រាប់ខ្លួនឯង គឺយកចំណេះវិជ្ជា ឬជំនាញណាមួយដែលខ្លួនមាន មកបង្កើតជាសមិទ្ធផលសង្គម ជាប្រយោជន៍សាធារណៈ។ យុវជនយើង បានលះបង់ទាំងកម្លាំងកាយចិត្ត កម្លាំងស្មារតី ដើម្បីសិក្សាស្រាវជ្រាវរុករកអ្វីៗដែលជាតម្រូវការរបស់សង្គម ...
- ✓ យុវជនយើងដែលជាទំពាំងស្នងឫស្សី ចេះបង្កើនសមត្ថភាពខ្លួនតាមរយៈការសិក្សាក្រេបយកចំណេះវិជ្ជាដែលលោកគ្រូអ្នកគ្រូ បានបង្ហាត់បង្រៀននៅសាលាយកមកអនុវត្តលំហាត់គ្រប់មុខវិជ្ជាមានដូចជាគណិតវិទ្យា គីមីវិទ្យា...
- ✓ យុវជនមិនត្រូវបង្កភាពអសកម្មធ្វើឱ្យសង្គមរីកវរ បាត់បង់សណ្ដាប់ធ្នាប់ដូចជាការបង្ហោះម៉ូតូ ហោះកញ្ច្រៀវ ឡូឡាឬមួយឈានទៅរកការផក់ប្លន់ ក្លាយជាបងធំបងតូច ក្មេងទំនើង...។ ទង្វើបែបនេះ ...ខ្លួនឯងបាត់បង់កិត្តិយសប៉ុណ្ណោះទេ តែវាថែមទាំងបានធ្វើឱ្យម្ដាយឪពុកមានកេរ្ដិ៍ឈ្មោះមិនល្អ ...
- ✓ ឧទាហរណ៍ៈ រឿងកុមារកំព្រា ដោយសារតែកុមារប្អូនបានព្យាយាម ឆ្លៀតយកពេលវេលាមកជាការសិក្សាពីរបៀបធ្វើជុចពីឪពុកខ្លួន ទើបជាហេតុឱ្យធ្វើកុមារប្អូនមានចំណេះ អាចចិញ្ចឹមជីវិតខ្លួនបានក្រោយពីឪពុកខ្លួនស្លាប់ទៅ...។

- **សរុប**: សរុបសេចក្ដីមក... យុវជន គឺពិតជាធនធានមនុស្សរបស់ប្រទេសជាតិប្រាកដមែន។

## គ- សេចក្ដីបញ្ចប់

- **វាយតម្លៃប្រធាន**: ឆ្លងតាមការបកស្រាយមកពីខាងលើបានបង្ហាញឱ្យឃើញថា ...ពាក្យស្លោកខាងលើមានអត្ថន័យសំខាន់ ព្រោះបានអប់រំឱ្យយើងមើលឃើញពីតួនាទីយ៉ាងសំខាន់របស់យុវជន...
- **យោបល់ផ្ទាល់ខ្លួន**: គំនិតប្រធានក៏បានបណ្ដុះស្មារតីរបស់យុវវ័យថែមទៀត ឱ្យស្គាល់ពីកាតព្វកិច្ចខ្លួន ដើម្បីឱ្យចេះប្រែក្លាយខ្លួន ឬអភិវឌ្ឍបុគ្គលិកលក្ខណៈខ្លួនកាន់តែមាន...។

# សេចក្ដីអធិប្បាយ

ភាពរឹងមាំរបស់ផ្ទះគឺអាស្រ័យនៅលើសសរ ភាពរឹងមាំរបស់សង្គមជាតិគឺអាស្រ័យនៅលើយុវជនដែលមានសមត្ថភាពនិងសីលធម៌ខ្ពស់ ។ ដោយមើលឃើញពីកត្តាកំណត់នៃការកសាងសង្គមបែបនេះហើយទើបមានពាក្យស្លោកមួយថែងថា "យុវជនគឺជាធនធានមនុស្សរបស់ប្រទេសជាតិ"។

តើយុវជនត្រូវមានកាតព្វកិច្ចយ៉ាងណាខ្លះ?

ដើម្បីរួមចំណែកក្នុងការបកស្រាយគំនិតពាក្យស្លោកខាងលើនេះឱ្យបានក្បោះក្បាយ យើងគប្បីស្វែងយល់នូវន័យនៃពាក្យគន្លឹះរបស់ប្រធានជាមុនសិនគឺពាក្យ " យុវជន ធនធានមនុស្ស "។ យុវជន គឺសំដៅទៅលើស្រទាប់នៃមនុស្សក្នុងភាពកំលោះ ក្រមុំ ដែលមានថាមពលខ្លាំងក្លាក្នុងការសិក្សា។ រីឯធនធានមនុស្ស គឺជាមនុស្សដែលមានជំនាញសមត្ថភាពពិតប្រាកដ។ ដូច្នេះតាមគំនិតប្រធានមានន័យថាស្រទាប់យុវវ័យដែលមានថាមពលខ្លាំងក្លាក្នុងការសិក្សា គឺជាមនុស្សប្រកបទៅដោយសមត្ថភាពក្នុងការកសាងប្រទេសជាតិឱ្យរឹងមាំ និងរីកចម្រើន។

ជាការពិតណាស់ ទោះបីជាកាលៈទេសៈណាក៏ យុវជនជាកម្លាំងដ៏ចាំបាច់លើសកម្លាំងដទៃទៀតដែលមាននៅក្នុងសង្គម។ កម្លាំងនេះមានសារប្រយោជន៍ខ្លាំងណាស់សម្រាប់ប្រទេសជាតិមានវិបត្តិដោយសង្គ្រាមឈ្លានពានពីសំណាក់សត្រូវឬមួយក្នុងគ្រាមានអាសន្នជាដើម។ ស្ថិតក្នុងសភាពដ៏ចាំបាច់នោះ យុវជនជាអ្នកឈានមុខបំពេញកាតព្វកិច្ចបម្រើប្រទេសជាតិមាតុភូមិរបស់ខ្លួន ដើម្បីស្វែង

រកភាពសុខសាន្តជូនប្រជារាស្ត្រនិងការពារជាតិ។ យុវជនក៏ជាអ្នកមានសមត្ថភាពយ៉ាងសំខាន់ក្នុងការអភិវឌ្ឍជាតិទៀតផង។

យុវជនពោរពេញទៅដោយថាមពលក្នុងការសិក្សាស្រាវជ្រាវ ដោយការលះបង់ពេលវេលាសម្រាប់ខ្លួនឯង គឺយកចំណេះវិជ្ជាឬជំនាញដែលខ្លួនមានមកបង្កើតជាសមិទ្ធផលសង្គម ជាប្រយោជន៍សាធារណៈ។ យុវជនយើង បានលះបង់ទាំងកម្លាំងកាយចិត្ត កម្លាំងស្មារតី ដើម្បីសិក្សាស្រាវជ្រាវរុករកអ្វីៗដែលជាតម្រូវការរបស់សង្គម  ជាពិសេសតម្រូវការរបស់ប្រជារាស្ត្រខ្លួន។ ស្របជាមួយគោលបំណងខាងលើនេះអាស្រ័យដោយយុវជនយើងដែលជាទំពាំងស្នងឫស្សី ចេះបង្កើនសមត្ថភាពខ្លួនតាមរយៈការសិក្សាក្រេបយកចំណេះវិជ្ជាដែលលោកគ្រូអ្នកគ្រូ បានបង្ហាត់បង្រៀននៅសាលាយកមកអនុវត្តលំហាត់គ្រប់មុខវិជ្ជាមានដូចជាគណិតវិទ្យា គីមីវិទ្យា ជីវវិទ្យា រូបវិទ្យាឬអក្សរសាស្ត្រជាដើម។ យុវជនមិនត្រូវព្រងើយកន្តើយ បោះបង់ពេលវេលា សម្រាប់អនាគតខ្លួននោះទៅជាការដើរលេង ស៊ីចាយ ហ៊ឺហា ភ្លើតភ្លើននឹងសម្ភារៈនិយមឬក៏ឈ្លក់វង្វេងនឹងគ្រឿងញៀននោះឡើយ។

មិនតែប៉ុណ្ណោះ យុវជនមិនត្រូវបង្កភាពអសកម្មធ្វើឱ្យសង្គមវឹកវរ បាត់បង់សណ្តាប់ធ្នាប់សាធារណៈ ដូចជាការបង្ហោះម៉ូតូ ហោះរកញៀន ឡូឡាឬមួយឈានទៅរកការឆក់ប្លន់ ក្លាយជាបងធំបងតូចដើរជំរិតគេឯងគឺក្លាយទៅជាក្មេងទំនើងនោះឡើយ។ ទង្វើបែបនេះមិនត្រឹមតែធ្វើឱ្យខ្លួនឯងបាត់បង់កិត្តិយសប៉ុណ្ណោះទេ តែវាថែមទាំងបានធ្វើឱ្យម្តាយឪពុកមានកេរ្តិ៍ឈ្មោះអសោច មិនអាចចូលចុះទៅក្នុងសង្គមពេញមុខមាត់ដូចគេឯងថែមទៀតផង។ មូលហេតុខាងលើនេះ គេតែងសង្កេតឃើញមានជារឿយៗក្នុងសង្គមដោយយុវជនខ្លះត្រូវម្តាយឪពុកតាមដានកូនរហូតមកដល់សាលារៀនដើម្បីស៊ើបសួរព័ត៌មានពីមិត្តរួមថ្នាក់ ពីលោកគ្រូ អ្នកគ្រូអំពីដំណឹង ព្រមទាំងឥរិយាបថរបស់កូនខ្លួនក្នុងការសិក្សា ដែលធ្វើឱ្យខាតបង់ពេលវេលារកស៊ីចិញ្ចឹមជីវិតថែមទៀត។

យ៉ាងណាមិញ បើគេពិចារណាជាមួយនឹងតួអង្គក្នុងរឿងកុមារកំព្រាវិញ ឃើញថា ដោយសារតែកុមារប្អូនបានព្យាយាម ឆ្លៀតយកពេលវេលាមកជាការសិក្សាពីរបៀបធ្វើដុចពីឪពុកខ្លួន ទើបជាហេតុឱ្យធ្វើកុមារប្អូនមានចំណេះ អាចចិញ្ចឹមជីវិតខ្លួនបានក្រោយពីឪពុកខ្លួនស្លាប់ទៅ រហូតមានអនាគតល្អនៅថ្ងៃក្រោយនោះទៀតផង។ ចំណែកកុមារបង ដោយសារខ្លួនពុំបានសន្សំចំណេះដឹងពីរបៀបធ្វើដុចតពីឪពុកនេះហើយ ទើបត្រូវរស់នៅប្រកបដោយសេចក្តីវេទនាក្រោយពីឪពុកស្លាប់ទៅ។ ដូច្នេះ ការអភិវឌ្ឍសង្គមជាតិ មិនអាចខ្វះកម្លាំងយុវជនដែលជាធនធានដ៏សំខាន់បានឡើយ។

សរុបសេចក្តីមក យុវជនគឺអ្នកមានថាមពល សមត្ថភាព ជាកម្លាំងស្នូលដែលជាធនធានមនុស្សរបស់ប្រទេសជាតិប្រាកដមែន។

ឆ្លងតាមការបកស្រាយមកពីខាងលើបានបង្ហាញឱ្យឃើញថា ពាក្យស្លោកខាងលើមានអត្ថន័យសំខាន់ព្រោះបានអប់រំឱ្យយើងមើលឃើញពីតួនាទីយ៉ាងសំខាន់របស់យុវជនយើង ចំពោះការអភិវឌ្ឍសង្គមជាតិ។ គំនិតប្រធានក៏បានបណ្តុះស្មារតីរបស់យុវវ័យថែមទៀតឱ្យស្គាល់ពីកាតព្វកិច្ចខ្លួន ដើម្បីឱ្យចេះប្រែក្លាយខ្លួនឬអភិវឌ្ឍខ្លួនកាន់តែមានប្រយោជន៍ចំពោះគ្រួសារ និងសង្គមជាតិយើង។

## ១៤.៣- ប្រធានអត្ថាធិប្បាយពន្យល់ពាក្យអប់រំ

ប្រធានទី១: កំណាព្យមួយវគ្គបានចែងថា

«ម៉ែឪមានគុណ គុណមានទម្ងន់ ធ្ងន់ដូចប្រឹថពី
គ្មានអ្វីនឹងសង គុណលោកទាំងទ្វី មាសប៉ុនគិរី
ថ្លៃពុំស្មើហោង»។

ចូរពន្យល់វគ្គកំណាព្យនេះឱ្យបានក្បោះក្បាយ។

### គម្រោងតែង

**ក- សេចក្ដីផ្ដើម**

- **លំនាំបញ្ហា:** និយាយទូទៅទាក់ទងនឹងបញ្ហារបស់ប្រធាន និងទាក់ទងនឹងគោលបំណងអ្នកនិពន្ធ គុណម៉ែឪ...
- **ចំណូលបញ្ហា(បង្ហាញបញ្ហា):** ការលើកយកប្រធានមកបង្ហាញ...

ម៉ែឪមានគុណ គុណមានទម្ងន់ ធ្ងន់ដូចប្រឹថពី
គ្មានអ្វីនឹងសង គុណលោកទាំងទ្វី មាសប៉ុនគិរី
ថ្លៃពុំស្មើហោង។

- **ចំណោទបញ្ហា:** ...តើប្រធានខាងលើមាន អត្ថន័យដូចម្ដេច...។

**ខ- តួសេចក្ដី**

- **ឃ្លាភ្ជាប់សេចក្ដី:** ...ដើម្បីជាជំនួយដល់ការបកស្រាយ គប្បីយល់នូវន័យនៃពាក្យគន្លឹះរបស់ប្រធានជាមុនសិន...។
- ពន្យល់ពាក្យគន្លឹះ៖
  - ✓ គុណ: សេចក្ដីចម្រើន សេចក្ដីល្អ ទង្វើដែលគួរគោរពតបស្នងនឹងខានពុំបាន...
  - ✓ ប្រឹថពី: ប្រឹថពី គឺផែនដី...
  - ✓ ទ្វី: ទ្វី គឺពីរ...
  - ✓ គិរី: គិរី គឺភ្នំ...។
- ពន្យល់ន័យប្រធាន: ដូច្នេះប្រធានខាងលើ មានន័យថាម៉ែឪមានគុណធ្ងន់ជាងផែនដី ហើយទោះមាសប៉ុនភ្នំក៏មិនអាចមានតម្លៃស្មើបានដែរ...។
- បំណកស្រាយប្រធាន៖

***ម៉ែឪមានគុណ៖***

- ✓ ម៉ែឪគឺជាអ្នកមានឧបការគុណមហាធំរកអ្វីមកប្រៀបផ្ទឹមពុំបានឡើយ។ តាំងពីកូនមកចាប់កំណើតក្នុងឧទរ ម៉ែឪតែងរិះរកគ្រប់មធ្យោបាយទាំងអស់ ដើម្បីថែរក្សា... ពេលដើរ ដេក ឈរ អង្គុយ ម៉ែតែងមានស្មារតីប្រុងប្រយ័ត្នជានិច្ច មិនធ្វេសប្រហែសបន្តិចសោះឡើយ...ឪពុកខិតខំធ្វើកិច្ចការសព្វសារពើដើម្បីទ្រទ្រង់ជីវភាពគ្រួសារ...
- ✓ ម៉ែឪខិតខំចិញ្ចឹមបីបាច់ថែរក្សាមិនឱ្យមានហ្មង។ គ្រប់ពេលវេលាមិនថាយប់ ឬថ្ងៃ និងទោះជានៅទីណាក្ដីលោកទាំងពីរ តែងតែនឹកគិតមមៃដល់កូនជានិច្ច។ ម្ដាយផ្ចូតទឹក បញ្ចុកអាហារ បបោសអង្អែលមិនឱ្យស្រមោច ឬមូសមួយខាំកូនបានឡើយ...

- ✓ ម៉ែឪបញ្ជូនកូនទៅសាលារៀន ខិតខំផ្គត់ផ្គង់គ្រប់បែបយ៉ាង ដើម្បីឱ្យកូនបានរៀនសូត្រតាំងពីតូចក្រូចឆ្មាររហូតដល់ធំ ធ្វើយ៉ាងណាឱ្យកូនមានចំណេះវិជ្ជា...
- ✓ ម៉ែឪ តែងអប់រំទូន្មានប្រៀនប្រដៅកូនមិនឱ្យប្រព្រឹត្តអំពើអាក្រក់ ឱ្យចៀសវាងឆ្ងាយពីអំពើបាបទាំងពួង។ គាត់ដាស់តឿនជារឿយៗ មិនឱ្យកូនប្រព្រឹត្តិអំពើពាលាអាវាសែ...លោកអ្នកដ៏មានគុណអប់រំកូនឱ្យប្រព្រឹត្តតែអំពើល្អជានិច្ច ពីព្រោះវានាំឱ្យមានភាពថ្លៃថ្នូរគ្មានអ្នកស្អប់ខ្ពើម...
- ✓ កូនប្រុសស្រីធំពេញវ័យ ម្តាយឪពុកតែងរៀបចំទុកដាក់កូនឱ្យមានគូស្រករ ដើម្បីកសាងគ្រួសារឱ្យកូនរស់នៅប្រកបដោយសុភមង្គល...ឪពុកបានចែកទ្រព្យសម្បត្តិកេរមរតក ទៅតាមធនធានដែលគាត់មានដូចជា ផ្ទះសម្បែង ដីស្រែចម្ការ...
- គុណធ្ងន់ដូចផែនដី...មហាឧបការគុណរបស់ឪពុកម្តាយ មានទម្ងន់ដ៏សែនធ្ងន់មិនរកអ្វីមកវាស់ថ្លឹងបានឡើយ។ ហេតុនេះហើយទើបគេប្រៀបធៀបម៉ែឪថា មានគុណធ្ងន់ជាងធរណី...
- មាសប៉ុនភ្នំក៏មិនមានតម្លៃស្មើនឹងគុណម៉ែឪដែរ...ក្នុងពិភពលោកយើងទាំងមូលមិនអាចរកមាសឯណាបានធំប៉ុនភ្នំបានឡើយ... ដូច្នេះបើគុណម៉ែឪមានតម្លៃជាងមាសប៉ុនភ្នំទៀតនោះ មានន័យថា... ពិភពលោកទាំងមូលមិនអាចរកវត្ថុមានតម្លៃអ្វីយកមកផ្ទឹមឱ្យមានតម្លៃស្មើគុណមាតាបិតាបានឡើយ...។

- **សរុបសេចក្តី:** ឪពុកម្តាយបានធ្វើអ្វីៗគ្រប់បែបយ៉ាងចំពោះកូនដូចជាថែទាំ ចិញ្ចឹមបីបាច់ ស្រឡាញ់ថ្នាក់ថ្នម អប់រំទូន្មានមិនឱ្យប្រព្រឹត្តអំពើអាក្រក់ ណែនាំឱ្យប្រព្រឹត្តអំពើល្អ រហូតរៀបការឱ្យកូន និងចែកទ្រព្យសម្បត្តិ...។

**គ- សេចក្តីបញ្ចប់**

- **វាយតម្លៃប្រធាន:** វគ្គកំណាព្យដែលបានពោលខាងលើពិតជាមានអត្ថន័យអប់រំជ្រាលជ្រៅសម្រាប់អប់រំទូន្មានកូនចៅខ្មែរយើងគ្រប់រូបឱ្យបានយល់ដឹងពីមហាឧបការគុណដ៏ធំធេងរបស់ម៉ែឪ...
- **យោបល់ផ្ទាល់ខ្លួន:** ដូច្នេះ ក្នុងនាមកុលបុត្រកុលធីតាគ្រប់រូបត្រូវចងចាំមហាគុណនេះ និងត្រូវតបស្នងសងគុណម៉ែឪវិញកុំបីអាក់ខានឡើយ...។

## សេចក្តីអធិប្បាយ

បុព្វបុរសខ្មែរយើងតាំងពីបុរាណកាលមក បានបន្សល់ទុកនូវស្នាដៃដ៏មានតម្លៃជាច្រើនដូចជាអក្សរសិល្ប៍ កំណាព្យ ច្បាប់ផ្សេងៗ សម្រាប់អប់រំទូន្មានប្រៀនប្រដៅកូនចៅគ្រប់ជំនាន់ ប្រាថ្នាចង់កូនចៅទាំងអស់រស់នៅប្រកបដោយសុភមង្គល។ ដូច្នេះហើយទើបមានកំណាព្យមួយលើកឡើងថា

"ម៉ែឪមានគុណ គុណមានទម្ងន់ ធ្ងន់ដូចប្រឹថពី
គ្មានអ្វីនឹងសង គុណលោកទាំងទ្វី មាសប៉ុនគិរី
ថ្លៃពុំស្មើហោង"។

តើប្រធានខាងលើមានអត្ថន័យដូចម្តេចខ្លះ?

ដើម្បីជាជំនួយដល់ការបកស្រាយឱ្យកាន់តែក្បោះក្បាយថែមទៀតនោះ យើងគប្បីយល់នូវន័យនៃពាក្យគន្លឹះរបស់ប្រធានខាងលើជាមុនសិនគឺពាក្យ "គុណ ប្រតិពី ទ្វី" ។ គុណ គឺជាសេចក្តីចម្រើន សេចក្តីល្អ ទង្វើដែលគួរគោរពតបស្នងនឹងខានពុំបាន។ ប្រឹថពី គឺផែនដី។ ទ្វី គឺពីរ។ គិរី គឺភ្នំ។ ដូច្នេះ ប្រធានខាងលើមានន័យថាម៉ែឪមានគុណធ្ងន់ជាងផែនដី ហើយទោះមាសប៉ុនភ្នំក៏មិនអាចមានតម្លៃស្មើបានដែរ។

ជាការពិតណាស់ ម៉ែឪ គឺជាអ្នកមានឧបការគុណមហាធំរកអ្វីមកប្រៀបផ្ទឹមពុំបានឡើយ។ តាំងពីកូនមកចាប់កំណើតក្នុងឧទរ ម៉ែឪតែងរិះរកគ្រប់មធ្យោបាយទាំងអស់ដើម្បីថែរក្សាយ៉ាងណាឱ្យកូនមានសេចក្ដីសុខ។ ពេលដើរ ដេក ឈរ អង្គុយ ម៉ែតែងមានស្មារតីប្រុងប្រយ័ត្នជានិច្ច មិនធ្វេសប្រហែសបន្តិចសោះឡើយ។ ម្ដាយមិនហ៊ានពិសាចំណីអាហារតាមចិត្តចង់នោះទេ ពីព្រោះខ្លាចប៉ះពាល់ដល់ទារក ឬទារិកាក្នុងផ្ទៃ។ ពេលប្រសូត ម៉ែសែនឈឺចាប់ឥតឧបមា លុះត្រាបុត្រីបុត្រាប្រសូតរួចទើបលោកអ្នកដ៏មានគុណបានធូរស្បើយ។ ពេលកូនកើតមកភ្លាម អ្នកមានគុណសប្បាយចិត្តណាស់ បានដាក់ឈ្មោះយ៉ាងស័ក្តិសមឱ្យកូន។ ឪពុកខិតខំធ្វើកិច្ចការសព្វសារពើដើម្បីទ្រទ្រង់ជីវភាពគ្រួសារ ទោះបីការងារនោះធ្វើឱ្យគាត់នឿយហត់យ៉ាងណាក៏ស៊ូទ្រាំ មិនដែលត្អូញថ្ងូរមួយម៉ាត់ឡើយ។ លោកឪពុក គឺជាអ្នកថែរក្សាការពារក្រុមសារ ឱ្យរស់នៅបានសេចក្ដីសុខ មិនឱ្យគ្រួសារជួបប្រទះនូវការភិតភ័យ សេចក្ដីអន្តរាយ ឬមិនឱ្យមានសត្រូវណាមកបៀតបៀនគ្រួសារបានឡើយ។

ពេលកូនកើតមកហើយ ម៉ែឪខិតខំចិញ្ចឹមបីបាច់ថែរក្សាមិនឱ្យមានហ្មង។ គ្រប់ពេលវេលាមិនថាយប់ឬថ្ងៃនិងទោះជានៅទីណាក្ដីលោកទាំងពីរតែងតែនឹកគិតមមៃដល់កូនជានិច្ច។ ម្ដាយផ្ចូតទឹក បញ្ចុកអាហារ បបោសអង្អែលមិនឱ្យស្រមោច ឬមូសមួយខាំកូនបានឡើយ។ ម្ដាយឪពុក សុខចិត្តអត់អាហារខ្លួនឯង ធ្វើយ៉ាងណាឱ្យតែកូនបានឆ្អែតឆ្អន់។ ពេលកូនយំ  ម៉ែលួងលោម ប្រលែង ច្រៀងបំពេធ្វើឱ្យកូនសប្បាយក្អាកក្អាយរហូតគេងលក់ស្កប់ស្កល់។ ម្ដាយឪពុក សុខចិត្តលះបង់គ្រប់បែបយ៉ាងដោយមិនគិតពីភាពនឿយហត់ឡើយ។ គាត់ស៊ូទ្រាំធ្វើការលំបាក ទោះបីធ្ងន់ធ្ងរយ៉ាងណាក្ដី ដើម្បីចិញ្ចឹមបុត្រភ្វាបានរស់រានមានជីវិត ធំធាត់ និងមានសុខភាពល្អ។

ដល់វ័យសិក្សា ម៉ែឪបញ្ជូនកូនទៅសាលារៀន ខិតខំផ្គត់ផ្គង់គ្រប់បែបយ៉ាង ដើម្បីឱ្យកូនបានរៀនសូត្រតាំងពីតូចក្រូចឆ្មាររហូតដល់ធំធ្វើយ៉ាងណាឱ្យកូនមានចំណេះវិជ្ជា។ គាត់ឱ្យកូនរៀនតាំងពីសាលាចំណេះទូទៅ រហូតដល់សាលាបច្ចេកទេស ប្រាថ្នាចង់ឱ្យកូនមានវិជ្ជាជីវៈសម្រាប់ប្រកបរបរចិញ្ចឹមជីវិតរស់នៅបានសុខស្រួល។

ម៉ែឪតែងអប់រំទូន្មានប្រៀនប្រដៅកូនមិនឱ្យប្រព្រឹត្តអំពើអាក្រក់ឱ្យចៀសវាងឆ្ងាយពីអំពើបាបទាំងពួង។ គាត់ដាសតឿនជារឿយៗមិនឱ្យកូនប្រព្រឹត្តិអំពើពាលាអាវាសែដូចជាដើរប៉ោឡែ ផឹកស៊ី គេចសាលារៀន លេងល្បែងស៊ីសងជាដើម។ លោកបានផ្ដល់ដំបូន្មានដល់កូនមិនឱ្យប្រព្រឹត្តិអំពើល្មើសច្បាប់មានដូចជា ការលួច ឆក់ ប្លន់ជាដើម។ ម៉ែឪហាមកូនដាច់ខាតមិនឱ្យរកស៊ីជួញដូរគ្រឿងញៀន និងប្រើប្រាស់គ្រឿងញៀនឡើយ ព្រោះវានាំឱ្យកើតមានសេចក្ដីអន្តរាយដល់ខ្លួនឯង គ្រួសារ និងសង្គមថែមទៀតផង។ លោកអ្នកដ៏មានគុណតែងអប់រំកូនឱ្យប្រព្រឹត្តតែអំពើល្អជានិច្ច ព្រោះវានាំឱ្យមានភាពថ្លៃថ្នូរគ្មានអ្នកស្អប់ខ្ពើម។ គាត់តែងណែនាំកូនឱ្យមានឥរិយាបថទន់ភ្លន់ ចេះគួរសមគោរពចាស់ទុំ ពោលគឺធ្វើយ៉ាងណាឱ្យអ្នកផងទាំងពួងគោរព ស្រឡាញ់គ្រប់ៗគ្នា។

ដល់ពេលកូនប្រុសស្រីធំពេញវ័យ ម្ដាយឪពុកតែងរៀបចំទុកដាក់កូនឱ្យមានគូស្រករ ដើម្បីកសាងគ្រួសារឱ្យកូនរស់នៅប្រកបដោយសុភមង្គល។ លោកបានជ្រើសរើសកូនប្រសាដែលមានលក្ខណសម្បត្តិល្អតាំងពីរូបសម្បត្តិ ចរិយាសម្បត្តិ និងមានពូជពង្សល្អ។ លើសពីនេះទៀត ម្ដាយឪពុកបានចែកទ្រព្យសម្បត្តិកេរមរតក ទៅតាមធនធានដែលគាត់មានដូចជា ផ្ទះសម្បែង ដីស្រែចម្ការ សត្វពាហនៈ របស់របរប្រើប្រាស់ និងប្រាក់កាសជាដើមឱ្យកូនថែមទៀតផង។ គ្រប់ពេលវេលាម្ដាយឪពុកតែងមានព្រហ្មវិហារធម៌ចំពោះកូនជានិច្ច។

មហាឧបការគុណរបស់ឪពុកម្តាយ មានទម្ងន់ដ៏សែនធ្ងន់មិនរកអ្វីមកវាស់ថ្លឹងបានឡើយ។ ហេតុនេះហើយទើបគេប្រៀបធៀបម៉ែឪថា មានគុណធ្ងន់ជាងធរណី។ កាលពីដើមឡើយ ព្រះធរណីគេមិនអាច វាស់ថ្លឹងបានឡើយ។ ប៉ុន្តែបច្ចុប្បន្ន ដោយសារវិទ្យាសាស្ត្រគេអាចវាស់ថ្លឹងវាបាន។ ដូច្នេះវាកាន់តែបញ្ជាក់ច្បាស់ថា គឺគុណមាតាបិតាពិតជាធ្ងន់ជាងផែនដី ព្រោះមិនមានអ្វីអាចយកមកវាស់ថ្លឹងមហាឧបការគុណរបស់ឪពុកម្តាយបានឡើយ។

គុណឪពុកម្តាយមិនត្រឹមតែធ្ងន់មិនអាចដឹងបានប៉ុណ្ណោះទេ គឺថែមទាំងមានតម្លៃមិនអាចកាត់ថ្លៃបានថែមទៀតផង។ បុព្វបុរសខ្មែរយើងលោកប្រៀបធៀបថា មាសប៉ុនភ្នំក៏មិនមានតម្លៃស្មើនឹងគុណម៉ែឪបានដែរ។ បញ្ហានេះយើងដឹងហើយថា ក្នុងពិភពលោកយើងទាំងមូលមិនអាចរកមាសឯណាបានធំប៉ុនភ្នំបានឡើយ។ ដូច្នេះបើគុណម៉ែឪមានតម្លៃជាងមាសប៉ុនភ្នំទៀតនោះ មានន័យថាពិភពលោកទាំងមូលមិនអាចរកវត្ថុមានតម្លៃអ្វីយកមកថ្លឹមឱ្យមានតម្លៃស្មើគុណមាតាបិតាបានឡើយ។ មាសប៉ុនគិរីថ្លៃពុំស្មើគុណម៉ែឪ មានន័យថាគុណមាតាបិតាមានតម្លៃមិនអាចកាត់ថ្លៃបានឡើយ។

សរុបសេចក្តីមក ឪពុកម្តាយបានធ្វើអ្វីៗគ្រប់បែបយ៉ាងចំពោះកូនដូចជា ថែទាំ ចិញ្ចឹមបីបាច់ស្រឡាញ់ថ្នាក់ថ្នម អប់រំទូន្មានមិនឱ្យប្រព្រឹត្តអំពើអាក្រក់ ណែនាំឱ្យប្រព្រឹត្តអំពើល្អ រហូតរៀបការឱ្យកូន និងចែកទ្រព្យសម្បត្តិឱ្យកូនថែមទៀតផង។ ដូច្នេះឪពុកម្តាយមានគុណធ្ងន់លើសផែនដី មិនអាចមានអ្វីមានតម្លៃស្មើបានឡើយ។

វគ្គកំណាព្យដែលបានពោលខាងលើពិតជាមានអត្ថន័យអប់រំជ្រាលជ្រៅ សម្រាប់អប់រំទូន្មានកូនចៅខ្មែរយើងគ្រប់រូបឱ្យបានយល់ដឹងពីមហាឧបការគុណដ៏ធំធេងរបស់ម៉ែឪ។ ដូច្នេះក្នុងនាមកុលបុត្រកុលធីតាគ្រប់រូបត្រូវចងចាំមហាគុណនេះ និងត្រូវតបស្នងសងគុណម៉ែឪវិញកុំបីអាក់ខានឡើយ។

## ១៤.៤- ប្រធានតែងសេចក្តីបែបអត្ថាធិប្បាយពន្យល់ពាក្យសុភាសិត

ប្រធានទី១: សុភាសិតមួយថែងថា «ចេះមកពីរៀន មានមកពីរក»។ ចូរបកស្រាយសុភាសិតខាងលើឱ្យបានក្បោះក្បាយ ដោយលើកឧទាហរណ៍មកបញ្ជាក់ផង។

### គម្រោងតែង

**ក- សេចក្តីផ្តើម**

- **លំនាំបញ្ហា**: និយាយទូទៅទាក់ទងនឹងទាក់ទងនឹង ចំណេះវិជ្ជា និងទ្រព្យសម្បត្តិ...
- **ចំណូលបញ្ហា(បង្ហាញបញ្ហា)**: ...បញ្ចូលប្រធាន...ចេះមកពីរៀន មានមកពីរក...
- **ចំណោទបញ្ហា**: ...តើប្រធានខាងលើមាន អត្ថន័យដូចម្តេច... ។

**ខ- តួសេចក្តី**

- **ឃ្លាភ្ជាប់សេចក្តី**: ...ដើម្បីជាជំនួយដល់ការបកស្រាយ គប្បីយល់នូវន័យនៃពាក្យគន្លឹះរបស់ប្រធានជាមុនសិន...។
- ពន្យល់ពាក្យគន្លឹះ៖
  - ✓ ចេះ: មានប្រាជ្ញា មានចំណេះដឹង ...
  - ✓ រៀន: សិក្សា ឈ្វេងយល់ ក្រេបយកចំណេះដឹង...

- ✓ មាន: សម្បូរ បរិបូរណ៍ភោគសម្បត្តិនានា ...
- ✓ រក: ប្រកបរបរចិញ្ចឹមជីវិត...។

- **ពន្យល់ន័យប្រធាន**: អ្នកមានប្រាជ្ញា មានចំណេះដឹង គឺដោយសារគេខិតខំសិក្សា ឈ្វេងយល់ ក្រេបយកចំណេះដឹងគ្រប់បែបយ៉ាង។ ចំណែកឯអ្នកសម្បូរឬបរិបូរណ៍ ដោយទ្រព្យសម្បត្តិ គឺអាស្រ័យដោយគេខិតខំប្រឹងប្រែងប្រកបរបរចិញ្ចឹមជីវិតប្រចាំថ្ងៃ... ។
- **បកស្រាយប្រធាន៖**
  - ✓ ចេះមកពីរៀន...ចំណេះវិជ្ជាគ្រប់យ៉ាង សុទ្ធតែបានមកពីការរៀនសូត្រ សន្សំមួយថ្ងៃបន្តិចៗរាប់សិបឆ្នាំ ឬពេញមួយជីវិតទើបទទួលបានលទ្ធផល មិនមាននរណាម្នាក់ចេះឯងដោយមិនបានរៀនសូត្រនោះឡើយ។ ការខិតខំរៀនសូត្ររហូតទទួលបានចំណេះវិជ្ជា ប្រៀបដូចជាសត្វកណ្ដៀរ ដ៏តូចល្អិត ខិតខំពាំជញ្ជូនដីបន្តិចម្ដងៗ រហូតពូនបានជាដំបូក...
  - ✓ ឧទាហរណ៍...ជាក់ស្ដែងសិស្សានុសិស្ស និស្សិតទាំងឡាយ បានខិតខំប្រឹងប្រែងក្រេបជញ្ជក់យកចំណេះវិជ្ជាគ្រប់បែបយ៉ាងពីគ្រូ ដើម្បីជាប្រយោជន៍សម្រាប់ខ្លួនឯង។ អ្នកធ្វើការងាររាជការថ្វីត្បិតតែធ្វើការ បម្រើសង្គមជាតិ ពួកគេក៏នៅតែព្យាយាមសិក្សាបង្កើនចំណេះដឹង...
  - ✓ មានមកពីរក...ទ្រព្យសម្បត្តិវិញ ក៏មិនខុសពីចំណេះវិជ្ជាដែរ គឺលុះត្រាតែមនុស្សម្នាក់ៗប្រឹងប្រែងរក ឬប្រកបរបរផ្សេងៗ សន្សំសំចៃទុកដាក់បន្តិចម្ដងៗ រាប់ខែ រាប់ឆ្នាំ ទើបមានទ្រព្យសម្បត្តិ...
  - ✓ ឧទាហរណ៍...ចៅចិត្រក្នុងរឿងកុលាបប៉ៃលិន ក្រោយពីឪពុកស្លាប់ទៅចៅចិត្រក្លាយជាមនុស្សគ្មានទីពឹង គ្មានទ្រព្យធនអ្វីបន្តិចសោះឡើយ ប៉ុន្តែក្រោយពីខ្លួនបានទៅធ្វើជាកម្មករជីកត្បូងនៅផ្ទះហ្លួងរតនសម្បត្តិ ចៅចិត្របានខិតខំប្រឹងប្រែងធ្វើការងារគ្រប់យ៉ាង...។
- **សរុប**: ចំណេះវិជ្ជានិងទ្រព្យសម្បត្តិសុទ្ធតែកើតឡើងពីការខិតខំប្រឹងប្រែងរបស់មនុស្សយើងម្នាក់ៗ...។

## គ- សេចក្តីបញ្ចប់

- **វាយតម្លៃប្រធាន**: សុភាសិតខាងលើមានអត្ថន័យល្អប្រសើរ សមស្របទៅតាមតថភាពនៃដំណើរជីវិតមនុស្សម្នាក់ៗ។ ដើម្បីញ៉ាំងឱ្យជីវិតយើងម្នាក់ៗទទួលបានសុភមង្គលពិតប្រាកដ ...
- **យោបល់ផ្ទាល់ខ្លួន**: ដូច្នេះយើងជាសិស្សានុសិស្សគ្រប់រូប ត្រូវខិតខំប្រឹងប្រែងតស៊ូ អំណត់ព្យាយាមគ្រប់ឧបសគ្គ ដើម្បីក្រេបយកចំណេះវិជ្ជាគ្រប់បែបយ៉ាង ...។

# សេចក្តីអធិប្បាយ

មនុស្សយើងម្នាក់ៗ តែងប្រាថ្នាចង់បានចំណេះវិជ្ជា និងទ្រព្យសម្បត្តិ។ ប៉ុន្តែរបស់ទាំងពីរនេះ មិនមែនបានមកដោយឯកឯងនោះទេ។ មានន័យថា ប្រសិនបើយើងម្នាក់ៗមិនខិតខំប្រឹងប្រែង ស្វាធ្យាយរិះរកទេគឺយើងមិនបានទទួលសម្បត្តិទាំងពីរនេះឡើយ។ ដូច្នេះបានជាមានសុភាសិតមួយថែងថា "ចេះមកពីរៀន មានមកពីរក"។

តើសុភាសិតនេះមានន័យដូចម្ដេចខ្លះ?

មុននឹងឈានចូលដល់ការបកស្រាយ យើងគួរយល់ពាក្យគន្លឹះមួយចំនួនជាមុនសិនគឺពាក្យ "ចេះ មាន រៀន រក"។ ចេះមានន័យថា មានប្រាជ្ញា មានចំណេះដឹង។ ឯពាក្យរៀន មានន័យថា សិក្សា ឈ្វេងយល់ក្រេបយកចំណេះដឹងគ្រប់បែបយ៉ាង។ រីឯពាក្យ មានមានន័យថា សម្បូរ បរិបូរណ៍ភោគសម្បត្តិ

នានា។ ចំណែកពាក្យ រក មានន័យថា រកស៊ី ប្រកបរបរចិញ្ចឹមជីវិត។ ដូច្នេះប្រធាននេះមានន័យថា អ្នកមានប្រាជ្ញា មានចំណេះដឹង គឺបណ្តាលមកពីគេខិតខំសិក្សាឈ្វេងយល់ ក្រេបយកចំណេះដឹងគ្រប់បែបយ៉ាង។ ចំណែកអ្នកសម្បូរ ឬបរិបូណ៌ដោយទ្រព្យសម្បត្តិ គឺអាស្រ័យដោយគេខិតខំប្រឹងប្រែងប្រកបរបររកស៊ីចិញ្ចឹមជីវិតប្រចាំថ្ងៃ ។

ជាការពិតណាស់ដូចសុភាសិតបានលើកឡើង "ចេះពីរៀន"មានន័យថាអ្វីៗគ្រប់យ៉ាងអាចកើតឡើងបាន អាស្រ័យដោយយើងខិតខំប្រឹងប្រែង តស៊ូ អំណត់ព្យាយាមគ្រប់យ៉ាង និងគ្រប់ពេលវេលា។ ចំណេះវិជ្ជាគ្រប់យ៉ាង សុទ្ធតែបានមកពីការរៀនសូត្រ សន្សំមួយថ្ងៃបន្តិចៗរាប់សិបឆ្នាំ ឬពេញមួយជីវិត ទើបទទួលបានលទ្ធផល មិនមាននរណាម្នាក់ចេះឯងដោយមិនបានរៀនសូត្រនោះឡើយ។ ការខិតខំរៀនសូត្ររហូតទទួលបានចំណេះវិជ្ជា ប្រៀបដូចជាសត្វកណ្តៀរដ៏តូចល្អិត ខិតខំពាំជញ្ជូនដីបន្តិចម្តងៗ រហូតពូនបានជាដំបូកដ៏ធំសម្បើមបាន។ ទឹកត្នោតស្រក់មួយតំណក់ម្តងៗ រហូតអាចបំពេញបំពង់បាន។ ជាក់ស្តែងសិស្សានុសិស្ស និស្សិតទាំងឡាយ បានខិតខំប្រឹងប្រែងក្រេបជញ្ជក់យកចំណេះវិជ្ជាគ្រប់បែបយ៉ាងពីគ្រូ ដើម្បីជាប្រយោជន៍សម្រាប់ខ្លួនឯង។ អ្នកធ្វើការងាររាជការថ្វីត្បិតតែធ្វើការបម្រើសង្គមជាតិ ពួកគេក៏នៅតែព្យាយាមសិក្សាបង្កើនចំណេះដឹងបន្ថែមទៀត ដោយមិនធ្វេសប្រហែសឡើយ។ ការរៀនសូត្រសោតទៀត លុះត្រាតែអ្នកសិក្សាម្នាក់ៗខំប្រឹងប្រែងត្រិះរិះពិចារណា ព្រមទាំងធ្វើការអនុវត្តជាក់ស្តែង និងស្វ័យសិក្សាបន្ថែមទៀត ទើបទទួលបានចំណេះដឹងពិតប្រាកដ។ តួអង្គថៅចិត្រក្នុងរឿងកុលាបប៉ៃលិន បានក្លាយជាអ្នកគ្រប់គ្រងបញ្ជីជំនួសលោកហ្លួងរតនសម្បត្តិ ក៏ដោយសារថៅចិត្រ មានចំណេះវិជ្ជា ហើយគេបានខិតខំរៀនសូត្របន្ថែមទៀតពីការងារជីកត្បូងនេះដែរ។

ចំណែកឃ្លាថា"មានពីរក" ក៏មិនខុសពីចំណេះវិជ្ជាដែរ គឺទ្រព្យសម្បត្តិទាំងឡាយអាចកើតកើនទៅបាន លុះត្រាតែមនុស្សម្នាក់ៗប្រឹងប្រែងរក ឬប្រកបរបរផ្សេងៗ សន្សំសំចៃទុកដាក់បន្តិចម្តងៗ រាប់ខែរាប់ឆ្នាំ ទើបមានទ្រព្យសម្បត្តិ។ ជាក់ស្តែង ថៅចិត្រក្នុងរឿងកុលាបប៉ៃលិន ក្រោយពីឪពុកស្លាប់ទៅថៅចិត្រក្លាយជាមនុស្សគ្មានទីពឹង គ្មានទ្រព្យធនអ្វីបន្តិចសោះឡើយ ប៉ុន្តែក្រោយពីខ្លួនបានទៅធ្វើជាកម្មករជីកត្បូងនៅផ្ទះហ្លួងរតនសម្បត្តិ ថៅចិត្របានខិតខំប្រឹងប្រែងធ្វើការងារគ្រប់យ៉ាង មិនរើសអើងការងារឡើយ។ ការខិតខំប្រឹងប្រែងតស៊ូ អំណត់ព្យាយាម ទីបំផុតថៅចិត្របានក្លាយជាកូនប្រសាហ្លួងរតនសម្បត្តិ គ្រប់គ្រងទ្រព្យសម្បត្តិ ដ៏ច្រើនស្តុកស្តម្ភថែមទៀត។ នេះដោយសារការខិតខំប្រឹងប្រែង តស៊ូ អំណត់គ្រប់ការងាររបស់ថៅចិត្រ។ លោកនិយាយបែបនេះ ចង់ឱ្យយើងខិតខំសិក្សា រៀនសូត្រស្វែងរកចំណេះដឹងជាមុន ហើយសឹមយកចំណេះដឹងទៅអនុវត្ត ស្វែងរកការងារធ្វើ ដើម្បីបានទ្រព្យសម្បត្តិ។ គំនិតស្របនឹងទ្រឹស្តីថា ទ្រឹស្តីផ្សារភ្ជាប់នឹងការអនុវត្ត។ ម្យ៉ាងទៀតអ្វីៗសុទ្ធតែមានហេតុជាបច្ច័យ ពុំមែនកើតដោយឯកឯងឡើយ។ ចំណេះដឹងទាំងឡាយកើតដោយការសិក្សារៀនសូត្រប្រកបដោយសេចក្តីព្យាយាមរីឯទ្រព្យក៏កើតដោយការខិតខំព្យាយាមរកស៊ី ស្គាល់ដឹងខាតចំណេញ ហើយចេះសន្សំទុកទើបមានទ្រព្យនោះដែរ។

សរុបសេចក្តីមកតាមការបកស្រាយមកខាងលើយើងឃើញថា ទាំងចំណេះវិជ្ជា ទាំងទ្រព្យសម្បត្តិ សុទ្ធតែកើតឡើងពីការខិតខំប្រឹងប្រែង តស៊ូព្យាយាមគ្រប់បែបយ៉ាង និងជម្នះគ្រប់ឧបសគ្គ ទើបទទួលបានចំណេះវិជ្ជា និងទ្រព្យសម្បត្តិ ដែលជាកត្តាជំរុញឱ្យជីវិតមានសុភមង្គល។

សុភាសិតខាងលើមានអត្ថន័យល្អប្រសើរ សមស្របទៅតាមតថភាពនៃដំណើរជីវិតមនុស្សម្នាក់ៗ។ ដើម្បីញ៉ាំងឱ្យជីវិតយើងម្នាក់ៗទទួលបានសុភមង្គលពិតប្រាកដ លុះត្រាតែខ្លួនយើងមានចំណេះវិជ្ជា

ហើយបើមានទ្រព្យសម្បត្តិថែមទៀតនោះរឹតតែប្រសើរ។ ដូច្នេះយើងជាសិស្សានុសិស្សគ្រប់រូប ត្រូវខិតខំប្រឹងប្រែងតស៊ូ អំណត់ព្យាយាមគ្រប់ឧបសគ្គ ដើម្បីក្រេបយកចំណេះវិជ្ជាគ្រប់បែបយ៉ាង មិនត្រូវបណ្ដែតបណ្ដោយឱ្យពេលវេលាកន្លងហួសទៅដោយឥតប្រយោជន៍នោះឡើយ។

**ប្រធានទី២**: សុភាសិតមួយចែងថា «ក្របីបាត់ទើបធ្វើរបង ជិតប្រឡងទើបខំរៀន»។ ចូរបកស្រាយសុភាសិតនេះឱ្យបានក្បោះក្បាយ និងលើកឧទាហរណ៍មកបញ្ជាក់ផង។

## គម្រោងតែង

### ក- សេចក្ដីផ្ដើម

- **លំនាំបញ្ហា**: និយាយទូទៅទាក់ទងនឹង បម្រុងប្រយ័ត្នទូទៅ ឬស្ថានភាពជាក់ស្ដែងក្នុងសង្គម...
- **ចំណូលបញ្ហា(បង្ហាញបញ្ហា)**: បញ្ចូលប្រធាន...ក្របីបាត់ទើបធ្វើរបង ជិតប្រឡងទើបខំរៀន...
- **ចំណោទបញ្ហា**: ចោទតាមបែបប្រធានពន្យល់...តើសុភាសិតនេះ មានអត្ថន័យយ៉ាងណា... ។

### ខ- តួសេចក្ដី

- **ឃ្លាភ្ជាប់សេចក្ដី**...ដើម្បីជាជំនួយដល់ការបកស្រាយ គប្បីយល់នូវន័យនៃពាក្យគន្លឹះរបស់ប្រធានជាមុនសិន...។
- ពន្យល់ពាក្យគន្លឹះ៖
  - ✓ របង: ...ក្រោល រនាំងព័ទ្ធជុំវិញ ដើម្បីការពារការបាត់បង់ដោយប្រការផ្សេងៗ...
  - ✓ ប្រឡង: ប្រកួតប្រជែងយកជាប់ប្រណាំងយកឈ្នះ ឬប្រជែងចំណាត់ថ្នាក់...។
- **ពន្យល់ន័យប្រធាន**: កសិករជាម្ចាស់សត្វពាហនៈដែលជាកម្លាំងអូសទាញដ៏សំខាន់សម្រាប់ការ ប្រកបមុខរបរចិញ្ចឹមជីវិតបានបាត់រួចទៅហើយ ទើបធ្វើជាក្រោល ឬរនាំងការពារ នោះគឺមិនបានលទ្ធផលល្អឡើយ...។ ចំណែកឯសិស្សានុសិស្ស ឬនិស្សិតដែលជិតដល់ពេលប្រកួតប្រជែង ចំណេះដឹងយកចំណាត់ថ្នាក់ ឬជាប់ធ្លាក់ទៅហើយ ទើបខំសិក្សាឈ្វេងយល់ក្រេបយកចំណេះដឹង នោះក៏មិនបានលទ្ធផលល្អដែរ...។
- បកស្រាយប្រធាន៖
  - ✓ ក្របីបាត់ទើបធ្វើរបង៖
  - ✓ ការចិញ្ចឹមសត្វពាហនៈ ដូចជាគោ ក្របី សេះ ត្រូវមានក្រោលសម្រាប់ការពារទើបវាមិនមានការបាត់បង់ដោយប្រការផ្សេងៗ...
  - ✓ ប្រសិនបើយើង មិនបានធ្វើក្រោល ឬមិនបានយកចិត្តទុកដាក់ថែរក្សាការពារ នាំឱ្យមានការបាត់បង់ទើបធ្វើរបងការពារនោះ គឺមិនមានប្រយោជន៍អ្វីឡើយ...
  - ✓ ជិតប្រឡងទើបខំរៀន៖
  - ✓ ចំពោះអ្នកសិក្សាវិញ ជិតដល់ថ្ងៃប្រឡងទៅហើយទើបខំរៀន ខំស្រវាស្រទេញ នោះនឹងមិនសូវបានផលល្អទេ...
  - ✓ ដើម្បីប្រឡងជាប់ គេត្រូវខំសន្សំចំណេះបន្តិចម្ដងៗ តាំងពីដើមរៀងមក... ។
- **សរុប**: ...បើម្ចាស់សត្វពាហនៈ ទុកពេលរហូតដល់ក្របីបាត់ទើបធ្វើរបង នោះនឹងមិនមានប្រយោជន៍អ្វីឡើយ។ ដូច្នេះវិធីដែលល្អគឺកសិករដែលចិញ្ចឹមសត្វពាហនៈ ត្រូវធ្វើរបងការពារតាំងពីចាប់ផ្ដើមចិញ្ចឹមទើបប្រសើរ...។ ចំណែកអ្នកសិក្សារៀនសូត្រ ដែលទុកជិតដល់ពេលប្រឡងទើបខំសិក្សារៀនសូត្រ

នោះក៏នឹងមិនបានលទ្ធផលល្អដែរ...។ អ្នកសិក្សាដែលនឹងទទួលបានលទ្ធផលល្អ លុះត្រាតែខិតខំសិក្សាតាំងពីដំបូងទៅ...។

**គ- សេចក្តីបញ្ចប់**

- **វាយតម្លៃប្រធាន:** សុភាសិតខាងលើមានអត្ថន័យល្អសម្រាប់អប់រំឱ្យមនុស្សទូទៅឱ្យមានការប្រុងប្រយ័ត្ន និងព្យាយាមគ្រប់ការងារកុំធ្វេសប្រហែស ទុកពេលវេលាឱ្យកន្លងហួសដោយគ្មានប្រយោជន៍...
- **យោបល់ផ្ទាល់ខ្លួន:** ដូច្នេះការចិញ្ចឹមសត្វនានា យើងត្រូវធ្វើរបងការពារចៀសវាងការបាត់បង់...។ ចំណែកឯការសិក្សាក៏ដូចគ្នាដែរ គឺយើងត្រូវខិតខំសិក្សាសតាំងពីថ្នាក់តូចទាប តាមលំដាប់លំដោយ ទើបទទួលបានលទ្ធផលល្អ... ។

## សេចក្តីអធិប្បាយ

ការធ្វេសប្រហែស ជាប្រការមួយគ្រោះថ្នាក់ និងការខាតបង់។ ការធ្វេសប្រហែសមានច្រើនដូចជា ការការពារទ្រព្យសម្បត្តិ ការរកស៊ី ការការពារសត្វពាហនៈ ការសិក្សាជាដើម។ ហេតុដូច្នេះហើយបានមានសុភាសិតមួយថែងថា "ក្របីបាត់ទើបធ្វើរបង ជិតប្រឡងទើបខំរៀន"។

តើសុភាសិតនេះ មានអត្ថន័យយ៉ាងណា?

មុននឹងឈានចូលដល់ការបកស្រាយសុភាសិតខាងលើឱ្យបានក្បោះក្បាយ យើងគួរយល់នូវអត្ថន័យនៃពាក្យគន្លឹះមួយចំនួនរបស់ប្រធានជាមុនសិនគឺពាក្យ "របង ប្រឡង"។ ឯពាក្យ របង មានន័យថាក្រោលរនាំងព័ទ្ធជុំវិញ ដើម្បីការពារការបាត់បង់ដោយប្រការផ្សេងៗ។ រីឯពាក្យប្រឡង មានន័យថា ការប្រកួតប្រជែងយកជាប់ ប្រណាំងយកចំណាត់ថ្នាក់ល្អ។ ចំណែកឯពាក្យ រៀន មានន័យថា សិក្សាឈ្វេងយល់ ក្រេបយកចំណេះដឹង។ ដូច្នេះប្រធាននេះមានន័យថា សត្វពាហនៈដែលជាកម្លាំងអូសទាញដ៏សំខាន់សម្រាប់ការប្រកបមុខរបររបស់យើងបានបាត់រួចទៅហើយទើបធ្វើជាក្រោលឬរនាំងការពារ នោះនឹងមិនមានប្រយោជន៍អ្វីឡើយ។ ចំណែកឯអ្នកសិក្សាវិញ ជិតដល់ពេលប្រកួតប្រជែងចំណេះដឹង យកចំណាត់ថ្នាក់ល្អឬយកជាប់ជិតដល់ពេលទៅហើយ ទើបខំសិក្សាឈ្វេងយល់ក្រេបយកចំណេះដឹង នោះក៏នឹងមិនបានលទ្ធផលល្អដែរ។

ពិតណាស់ការចិញ្ចឹមសត្វពាហនៈដូចជាគោ ក្របី សេះ ត្រូវមានចំណង ឬត្រូវធ្វើក្រោលសម្រាប់ការពារដើម្បីកុំឱ្យសត្វទាំងនោះដើរចូលលុកទន្ទ្រានស៊ីដំណាំផ្សេងៗរបស់គេ។ ម្យ៉ាងទៀត ការធ្វើក្រោលក៏ជាប្រការល្អសម្រាប់ការពារកុំឱ្យមានចោរឬជនទុច្ចរិតលួច។ ប៉ុន្តែបើយើងធ្វេសប្រហែសចោរមកលួចគោឬក្របីយកបាត់ទៅហើយ ទើបខំស្រវាស្រទេញធ្វើក្រោល របងការពារជាក្រោយនោះ មិនមានប្រយោជន៍អ្វីឡើយ ព្រោះគោ ក្របី បានបាត់អស់ទៅហើយ។ ដូច្នេះវិធីដែលល្អ គឺកសិករដែលចិញ្ចឹមសត្វពាហនៈត្រូវធ្វើក្រោល របងការពារតាំងពីចាប់ផ្តើមចិញ្ចឹមទើបប្រសើរ ព្រោះអាចការពារសត្វចិញ្ចឹមទាំងនោះមិនឱ្យចោរលួចបាន។

ចំណែកឯសិស្សានុសិស្ស ឬនិស្សិតវិញក៏ដូច្នេះដែរ ការសិក្សាយើងត្រូវខិតខំប្រឹងប្រែងសន្សំតាំងពីដើមរហូតដល់ពេលប្រឡងទើបយើងប្រឡងជាប់និងទទួលបាននិទ្ទេសល្អ។ ដូចជាបើយើងរៀននៅមធ្យមសិក្សាបឋមភូមិ យើងនឹងប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិនៅដំណាច់ឆ្នាំសិក្សាថ្នាក់ទីប្រាំបួន គឺយើងត្រូវខិតខំប្រឹងប្រែងរៀនសូត្រគ្រប់មុខវិជ្ជាតាំងពីថ្នាក់ទីប្រាំពីរតទៅតាមលំដាប់លំដោយ

រហូតដល់ពេលប្រឡង។ បើយើងធ្វេសប្រហែស រង់ចាំដល់ពេលជិតប្រឡងទើបខំរៀនក្នុងរយៈពេលដ៏ខ្លីនោះ គឺមិនអាចចេះចាំបានទាំងអស់នោះទេ។ ជួនកាលដោយពេលវេលាខ្លីពេក ហើយយើងខិតខំប្រឹងប្រែងហួសសមត្ថភាពជ្រុលពេកនោះអាចបង្កឱ្យមានជំងឺ ដែលអាចធ្វើឱ្យប៉ះពាល់ដល់ការប្រឡងថែមទៀតផង។

សរុបសេចក្ដីមក បើម្ចាស់សត្វពាហនៈទុកពេលរហូតដល់ក្របីបាត់ទើបធ្វើរបងនោះនឹងមិនមានប្រយោជន៍អ្វីឡើយ។ ដូច្នេះវិធីដែលល្អគឺកសិករដែលចិញ្ចឹមសត្វពាហនៈ ត្រូវធ្វើរបងការពារតាំងពីចាប់ផ្ដើមចិញ្ចឹមទើបប្រសើរ។ ចំណែកអ្នកសិក្សារៀនសូត្រ ដែលទុកជិតដល់ពេលប្រឡងទើបខំសិក្សារៀនសូត្រ នោះក៏នឹងមិនបានលទ្ធផលល្អដែរ។ អ្នកសិក្សាដែលនឹងទទួលបានលទ្ធផលល្អ លុះត្រាតែខិតខំសិក្សាតាំងពីដំបូងទៅ។

សុភាសិតខាងលើមានអត្ថន័យល្អសម្រាប់អប់រំឱ្យមនុស្សទូទៅឱ្យមានការប្រុងប្រយ័ត្ននិងព្យាយាមគ្រប់ការងារកុំធ្វេសប្រហែសទុកពេលវេលាឱ្យកន្លងហួសដោយគ្មានប្រយោជន៍នោះឡើយ។ ដូច្នេះក្នុងការចិញ្ចឹមសត្វនានា យើងត្រូវធ្វើរបងការពារចៀសវាងការបាត់បង់ដោយប្រការផ្សេងៗ។ ចំណែកឯការសិក្សាក៏ដូចគ្នាដែរ គឺយើងត្រូវខិតខំសិក្សាសន្សំតាំងពីថ្នាក់តូចទាប តាមលំដាប់លំដោយ ទើបទទួលបានលទ្ធផលល្អនៅពេលប្រឡង។

---

**ប្រធានទី៣**: សុភាសិតមួយបានចែងថា«ដំដែកក្នុងពេលដែកកំពុងក្ដៅ ប្រដៅមនុស្សទាន់នៅក្មេង»។ ចូរបកស្រាយសុភាសិតនេះឱ្យបានក្បោះក្បាយ ព្រមទាំងលើកឧទាហរណ៍មកបញ្ជាក់ផង។

---

## គម្រោងតែង

### ក- សេចក្ដីផ្ដើម

- **លំនាំបញ្ហា**: គំនិតទូទៅទាក់ទងនឹងប្រភពរបស់សុភាសិត និងគោលបំណងរួមរបស់សុភាសិត...
- **ចំណូលបញ្ហា(បង្ហាញបញ្ហា)**: ហេតុដូច្នេះហើយទើបមានសុភាសិតមួយពោលថា ដំដែកក្នុងពេលដែកកំពុងក្ដៅ ប្រដៅមនុស្សទាន់នៅក្មេង...
- ចំណោទបញ្ហា: ...តើសុភាសិតនេះ មានអត្ថន័យយ៉ាងណា...។

### ខ- តួសេចក្ដី

- **ឃ្លាភ្ជាប់សេចក្ដី**: ...ដើម្បីជាជំនួយដល់ការបកស្រាយ គប្បីយល់នូវន័យនៃពាក្យគន្លឹះរបស់ប្រធានជាមុនសិន...។
- **ពន្យល់ពាក្យគន្លឹះ**៖
  - ✓ ដែក: ដែក ជាលោហធាតុរឹង គេអាចយកវាមកដុតកម្ដៅ ឬស្ល សម្រាប់ធ្វើវត្ថុប្រើប្រាស់ផ្សេងៗ...
  - ✓ ដំ: គឺវាយ សំពង ទូង ច្នៃទៅជាឧបករណ៍អ្វីមួយ...
  - ✓ ប្រដៅ: មានន័យថា ទូន្មាន ឱ្យឱវាទ ក្រើនរំឭក បង្ហឹក...។
- **ពន្យល់ន័យប្រធាន**: ...ដូច្នេះប្រធានមានន័យថា កាលណាគេច្នៃលោហធាតុផ្សេងៗមានដែកជាដើមឱ្យទៅជាវត្ថុប្រើប្រាស់ផ្សេងៗ គេត្រូវវាយសំពងពត់ឬច្នៃនៅពេលវាកំពុងក្ដៅ...។ រីឯការអប់រំ ទូន្មានឱ្យឱវាទ មនុស្សវិញក៏ដូច្នេះដែរ គឺត្រូវធ្វើទាន់មនុស្សនោះនៅក្មេង... ។
- **បកស្រាយប្រធាន**: សុភាសិតនេះមានន័យពីរ គឺន័យចំ និងន័យធៀប៖

- **តាមន័យត្រង់(អត្ថាន្វរូប)** : កាលណាគេត្រូវដំដែកឬលោហធាតុផ្សេងៗដើម្បីយកមកធ្វើគ្រឿងប្រដាប់អ្វីមួយ គេត្រូវដុតដែក ឬលោហធាតុនោះឱ្យក្តៅសិនទើបងាយដំ ព្រោះសាច់ដែកទន់ ស្រួលដំ ឬពត់តាមរាងរៅ និងបំណងដែលយើងចង់បាន...
  - ✓ ឧទាហរណ៍: ...ជាក់ស្តែងដូចជាមុននឹងដំដែក ធ្វើកាំបិត ពូថៅ ចបជាដើម គេត្រូវដុតឬស្លដែកនោះឱ្យក្តៅ ទើបវាមានសាច់ទន់ ងាយដំ ឬពត់ពេនតាមរាងរៅ...
  - ✓ តាមន័យធៀប(អត្ថបដិរូប): ការអប់រំមនុស្ស គេត្រូវអប់រំ ណែនាំ ប្រៀនប្រដៅតាំងពីនៅក្មេង...។ ការអប់រំមនុស្ស ត្រូវអប់រំតាំងពីក្មេង ព្រោះងាយចេះ ងាយចាំ ងាយស្តាប់បង្គាប់ ងាយទទួលបែបបទ....។
- **សរុប**: ការដំដែកធ្វើអ្វីៗគេត្រូវធ្វើទាន់ដែកនោះនៅក្តៅ បើទុកឱ្យវាត្រជាក់នោះវាពិបាកនឹងដំណាស់។ ចំណែកការអប់រំមនុស្ស ក៏គេតែងតែអប់រំ...។

## គ- សេចក្តីបញ្ចប់

- **វាយតម្លៃប្រធាន**: សុភាសិតបានបង្ហាញពីវិធីអប់រំទូន្មានទូលំទូលាយ សម្រាប់អប់រំមនុស្សតាមវ័យដើម្បីឱ្យទទួលបានលទ្ធផលល្អ...
- **យោបល់ផ្ទាល់ខ្លួន**: ដូច្នេះយើងជាសិស្សានុសិស្សត្រូវខិតខំរៀនទាន់ខ្លួននៅក្មេង កុំធ្វេសប្រហែសដើម្បីឱ្យក្លាយជាសិស្សល្អ មិត្តល្អ និងពលរដ្ឋល្អ...។

## សេចក្តីអធិប្បាយ

ខ្មែរយើងសម្បូរ សុភាសិត ពាក្យស្លោក និងច្បាប់ផ្សេងៗច្រើនណាស់ ដែលអ្នកប្រាជ្ញ បណ្ឌិត កវីអ្នកនិពន្ធ បុព្វបុរសដូនតាខ្មែរយើងតាំងពីបុរាណកាលមក បានតាក់តែងសុភាសិត ពាក្យស្លោក និងច្បាប់ផ្សេងៗសម្រាប់អប់រំ ទូន្មានប្រៀនប្រដៅកូនចៅគ្រប់ជំនាន់ ប្រាថ្នាចង់ឱ្យកូនចៅទាំងអស់រស់នៅប្រកបដោយសុភមង្គល។ ដូច្នេះហើយទើបមានសុភាសិតមួយបានលើកឡើងថា "ដំដែកក្នុងពេលដែកកំពុងក្តៅ ប្រដៅមនុស្សទាន់នៅក្មេង"។

តើសុភាសិតនេះមានអត្ថន័យដូចម្តេច?

មុននឹងឈានដល់ការបកស្រាយប្រធានឱ្យបានក្បោះក្បាយ យើងគួរយល់នូវន័យនៃពាក្យមួយចំនួនរបស់ប្រធានជាមុនសិនគឺពាក្យ "ដែក ដំ ប្រដៅ"។ ដែក គឺជាលោហធាតុរឹងគេអាចយកវាមកដុតកម្តៅឬស្លសម្រាប់ធ្វើវត្ថុប្រើប្រាស់ផ្សេងៗ។ ពាក្យ ដំ គឺវាយច្នៃទៅជាឧបករណ៍អ្វីមួយ។ រីឯពាក្យ ប្រដៅមានន័យថា អប់រំ ទូន្មាន ឱ្យឱវាទ ក្រើនរំឭក បង្ហឹក។ ដូច្នេះប្រធានមានន័យថា កាលណាគេវាយសំពងពត់ ឬច្នៃលោហធាតុផ្សេងៗមានដែកជាដើម ឱ្យទៅជាវត្ថុប្រើប្រាស់ផ្សេងៗ គេត្រូវវាយសំពង ពត់ ច្នៃនៅពេលវាកំពុងក្តៅ បើទុកឱ្យវាត្រជាក់វិញវានឹងរឹងដូចដើម ពិបាកក្នុងការច្នៃឱ្យបានដូចបំណង ។ រីឯការអប់រំ ទូន្មាន ឱ្យឱវាទមនុស្សវិញក៏ដូច្នេះដែរ គឺត្រូវធ្វើទាន់មនុស្សនោះនៅក្មេងបើទុកដល់ចាស់នោះនឹងពិបាកអប់រំ ទូន្មានណាស់។

ជាការពិតណាស់ដូចាសុភាសិតបានលើកឡើង ដំដែកទាន់នៅក្តៅមានន័យថា កាលណាគេត្រូវដំដែក ឬលោហធាតុផ្សេងៗ ដើម្បីយកមកធ្វើគ្រឿងប្រដាប់អ្វីមួយ គេត្រូវដុតដែកឬលោហធាតុនោះឱ្យក្តៅសិនទើបងាយដំ ព្រោះសាច់ដែកទន់ស្រួលដំឬពត់តាមរាងរៅ និងបំណងដែលយើងចង់បាន។ បើគេមិនដុតឱ្យក្តៅទន់ទេគេក៏មិនអាចដំ ឬពត់បានតាមបំណងឡើយ។ ជាក់ស្តែងដូចជាមុននឹងដំដែក ធ្វើ

កាំបិត ពូថៅ ចប ត្រូវដុតឬស្លដែកនោះឱ្យក្តៅ ទើបវាមានសាច់ទន់ ងាយដំឬពត់ពេនតាមរាងវត្ថុទាំងនោះបាន។ បើគេពុំដុតឱ្យក្តៅទេ សាច់វានឹងរឹងពិបាកដំ ឬពត់ណាស់។

បើធៀបមកនៅក្នុងសង្គម ការដំដែកមិនខុសអ្វីពីការអប់រំមនុស្សនោះទេ។ ការអប់រំមនុស្សគេត្រូវអប់រំ ណែនាំ ប្រៀនប្រដៅតាំងពីនៅក្មេង មិនរង់ចាំដល់ធំ ឬចាស់ឡើយ។ ការអប់រំមនុស្សជាទូទៅត្រូវអប់រំតាំងពីគេនៅក្មេង ព្រោះងាយចេះ ងាយចាំ ងាយស្តាប់បង្គាប់ ងាយទទួលបែបបទ និងទម្លាប់ល្អក្នុងការអប់រំ។ បើទុកឱ្យហួសពេលវេលារហូតដល់មនុស្សចាស់ហួសវ័យតែងគិតច្រើន មានកង្វល់ច្រើន សតិបញ្ញាក៏ថយចុះ ពិបាកទទួលយកការអប់រំណាស់។ មនុស្សវ័យចាស់ គេអាចអប់រំបានដែរតែតាមមធ្យោបាយ និងវិធីខុសពីការអប់រំមនុស្សក្មេងតូចៗ។

សរុបសេចក្តីមកការដំដែក ឬលោហធាតុដើម្បីយកមកធ្វើអ្វីមួយគេត្រូវដំទាន់ដែកនោះនៅក្តៅ បើទុកឱ្យវាត្រជាក់នោះ វាពិបាកនឹងធ្វើណាស់។ ចំណែកការអប់រំមនុស្សក៏គេតែងតែអប់រំ ប្រៀនប្រដៅពីនៅវ័យក្មេងៗមកដែរ វាងាយស្រួលជាងទុកឱ្យហួសវ័យពិបាកក្នុងការទទួល។

សុភាសិតនេះ បានបង្ហាញពីវិធីអប់រំទូន្មានទូលំទូលាយ សម្រាប់អប់រំមនុស្សតាមវ័យ និងប្រើវិធីឬមធ្យោបាយផ្សេងគ្នាតាមបទពិសោធ ដើម្បីឱ្យទទួលបានលទ្ធផលល្អ។ ដូច្នេះយើងជាសិស្សានុសិស្សត្រូវខិតខំរៀនទាន់ខ្លួននៅក្មេង កុំធ្វេសប្រហែស ដើម្បីឱ្យក្លាយជាសិស្សល្អ មិត្តល្អ និងពលរដ្ឋល្អ។

**ប្រធានទី៤**: សុភាសិតមួយចែងថា «ដើយស្កក ឱនដាក់គ្រាប់»។ ចូរពន្យល់សុភាសិតខាងលើឱ្យបានក្បោះក្បាយ ដោយលើកឧទាហរណ៍ជាក់ស្តែង និងក្នុងអក្សរសិល្ប៍មកបញ្ជាក់ផង។

## គម្រោងតែង

### ក- សេចក្តីផ្តើម

- **លំនាំបញ្ហា**: និយាយគំនិតទូទៅទាក់ទងនឹងប្រភពរបស់សុភាសិតនិងគោលបំណងរួមរបស់សុភាសិត...
- **ចំណូលបញ្ហា(បង្ហាញបញ្ហា)**: ហេតុដូច្នេះហើយទើបមានសុភាសិតមួយពោលថា ដើយស្កក ឱនដាក់គ្រាប់...
- **ចំណោទបញ្ហា**: ចោទតាមបែបប្រធានពន្យល់...តើសុភាសិតនេះមានអត្ថន័យដូចម្តេច?

### ខ- តួសេចក្តី

- **ឃ្លាភ្ជាប់សេចក្តី**: ...ដើម្បីជាជំនួយដល់ការបកស្រាយ គប្បីយល់នូវន័យនៃពាក្យគន្លឹះរបស់ប្រធានជាមុនសិន...។
- **ពន្យល់ពាក្យគន្លឹះ៖**
  - ✓ ដើយ: ឈរប្រាស់ឡើងទៅលើ...
  - ✓ ស្កក: កួរស្រូវដែលមិនមានគ្រាប់...
  - ✓ ឱន: ទន់ចុះក្រោម បន្ទន់ទៅមុខ សំយុងចុះ...
  - ✓ ដាក់គ្រាប់: ស្រូវមានគ្រាប់ពេញ ឬមានគ្រាប់អង្ករ...។
- **ពន្យល់ន័យប្រធាន**: ដូច្នេះប្រធានខាងលើមានន័យថា កួរស្រូវដែលឈរត្រង់ទៅលើគឺមិនមានដាក់គ្រាប់ ប្រៀបដូចមនុស្សមានចរិតអួតក្អេងក្អាង... តែងមិនទទួលបាននូវផលល្អ... ផ្ទុយទៅវិញ កួរស្រូវ

ដែលទន់ចុះ... មានគ្រាប់ពេញ ប្រៀបដូចមនុស្សដែលចេះដាក់ខ្លួនឱ្យទាប... តែងទទួលបាននូវបានផលល្អ...។

- **បកស្រាយប្រធាន៖**
  - ✓ បកស្រាយអត្ថន័យ“ ងើយស្កក”៖
  - ✓ អត្ថានុរូប(ន័យត្រង់)“ងើយស្កក” គឺសំដៅទៅលើកួរស្រូវ ដែលមានទងកួរឈរត្រង់ទៅលើដោយសារផ្លែវាមិន មានដាក់គ្រាប់ ពោលគឺផ្លែមានតែសម្បកគ្មានគ្រាប់។ កួរដែលផ្លែគ្មានគ្រាប់ដូចនេះ គេហៅថា“ស្កក” “ងើយស្កក” គឺសំដៅលើដំណាំស្រូវដែលកួររបស់វាមានផ្លែតែគ្មានដាក់គ្រាប់...
  - ✓ អត្ថបដិរូប(ន័យធៀប): គេចង់ប្រៀបធៀបទៅនឹងមនុស្ស ដែលប្រព្រឹត្តប្រកបដោយអត្តចរិតមិនសមរម្យ ឫកពាអួតក្អេងក្អាង លើកតម្កើងខ្លួនឯងហួសហេតុ។ ពេលខ្លះទៀត គេជាមនុស្សមានកាយវិការច្រងេងច្រងាង មានសម្តី គំរោះគំរើយជាដើម។ មនុស្សបែបនេះ តែងតែមានឥរិយាបថ ដើរ ដេក ឈរ អង្គុយ និងនិយាយស្តី ឆ្គាំឆ្គង...
  - ✓ ឧទាហរណ៍ក្នុងសង្គម មនុស្សមានឫកពាក្អេងក្អាង...មិនទទួលបានផលល្អ...
  - ✓ ឧទាហរណ៍ រឿងកុលាបប៉ៃលិន ...លោកបាឡាត់មានឫកពាក្អេងក្អាង...ទទួលបរាជ័យ...
  - ✓ បកស្រាយអត្ថន័យ“ឱនដាក់គ្រាប់”៖
  - ✓ អត្ថានុរូប(ន័យត្រង់): “ឱនដាក់គ្រាប់” គឺសំដៅទៅលើរុក្ខជាតិដែលមានទងកួរប្រវែងប្រហែលមួយចំអាម ទងកួរនេះ កាលណាផ្លែនៅខ្ចីមិនទាន់ដាក់គ្រាប់វាឈរទៅលើ។ កាលណាផ្លែវាចាស់រហូតដល់ទុំ ដាក់គ្រាប់ពេញធ្វើឱ្យកួរវាធ្ងន់ក៏ឱនចុះ...
  - ✓ ឧទាហរណ៍តួយ៉ាងដូចជាដំណាំស្រូវ កាលណាវាចេញកួរផ្លែវានៅខ្ចីមិនទាន់ដាក់គ្រាប់កួរវាស្រាលហើយស្ថិតនៅឈរទៅលើ។ កាលណាផ្លែវាចាស់រហូតដល់ទុំដាក់គ្រាប់ពេញ ធ្វើឱ្យកួរវាធ្ងន់ក៏ឱនចុះ...
  - ✓ អត្ថបដិរូប(ន័យធៀប): លោកចង់ធ្វើការប្រៀបធៀបកួរស្រូវទៅនឹងការប្រព្រឹត្តរបស់មនុស្ស។ ឃ្លានេះមានន័យថា ការរស់នៅប្រចាំថ្ងៃ ការធ្វើការងារ ក៏ដូចជាការប្រកបរបរចិញ្ចឹមជីវិត មនុស្សគ្រប់រូបត្រូវចេះដាក់ខ្លួនឱ្យទាប ចេះឱនលំទោន ទន់ភ្លន់ ឫកពាសុភាពរាបសា នោះធ្វើឱ្យអ្នកទទួលបានជោគជ័យប្រកបដោយសេចក្តីថ្លៃថ្នូរ...
  - ✓ ឧទាហរណ៍ក្នុងសង្គមជាក់ស្តែង មនុស្សចេះឱនលំទោន...ទទួលបានផលល្អ...
  - ✓ ឧទាហរណ៍ក្នុងរឿងកុលាបប៉ៃលិន... ចៅចិត្រចេះឱនលំទោន... ទទួលបានជោគជ័យ...។
- **សរុប**: កួរដែលងើយឈរត្រង់គឺជាកួរដែលស្កកមិនបានផល ប្រៀបដូចមនុស្សដែលមានចរិតក្អេងក្អាងតែងទទួលរងការរិះគន់... និងមិនទទួលបាននូវលទ្ធផលល្អ...ផ្ទុយពីកួរទន់ចុះគឺ...ដាក់គ្រាប់ទទួលបានផលល្អ ប្រៀបដូចមនុស្សដែលអាកប្បកិរិយាទន់ភ្លន់... តែងទទួលបាននូវសេចក្តីថ្លៃថ្នូរ...។

## គ- សេចក្តីបញ្ចប់

- **វាយតម្លៃប្រធាន**: តាមរយៈការបកស្រាយមកពីខាងលើ សុភាសិតនេះពិតជាមានអត្ថន័យអប់រំយ៉ាងជ្រាលជ្រៅ សម្រាប់អប់រំកូនចៅគ្រប់ជំនាន់ឱ្យប្រព្រឹត្តល្អ...
- **យោបល់ផ្ទាល់ខ្លួន**: ដូច្នេះក្នុងនាមយើង ជាអ្នកសិក្សាក៏ដូចជាកូនចៅជំនាន់ក្រោយត្រូវខិតខំសិក្សាស្វែងយល់ពីសុភាសិតខ្មែរបន្ថែមទៀត...។

# សេចក្ដីអធិប្បាយ

ខ្មែរយើងសម្បូរ សុភាសិត ពាក្យស្លោក និងច្បាប់ផ្សេងៗណាស់។ អ្នកប្រាជ្ញ បណ្ឌិត កវី អ្នកនិពន្ធ បុព្វបុរសដូនតាខ្មែរយើងតាំងពីបុរាណកាលមក បានតាក់តែងសុភាសិត ពាក្យស្លោក និងច្បាប់ផ្សេងៗ ទាំងនោះ សម្រាប់អប់រំ ទូន្មានប្រៀនប្រដៅកូនចៅគ្រប់ជំនាន់ ប្រាថ្នាចង់ឱ្យកូនចៅទាំងអស់រស់នៅ ប្រកបដោយសុភមង្គល។ ដូច្នេះហើយទើបមានសុភាសិតមួយបានលើកឡើងថា "ងើយស្កក ឱនដាក់គ្រាប់"។

តើសុភាសិតនេះ មានអត្ថន័យដូចម្ដេច?

ដើម្បីជាជំនួយដល់ការបកស្រាយប្រធានខាងលើឱ្យកាន់តែក្បោះក្បាយថែមទៀតនោះ យើងគប្បីយល់នូវន័យនៃពាក្យគន្លឹះក្នុងសុភាសិតជាមុនសិនគឺពាក្យ "ងើយ ស្កក ឱន ដាក់គ្រាប់"។ ពាក្យ "ងើយ" តាមន័យត្រង់ គឺសំដៅទៅលើកួរស្រូវដែលឈរទៅលើ។ បើតាមន័យធៀបមានន័យថា ការប្រព្រឹត្ត ប្រកបដោយឫកពាអួតក្អេងក្អាង ឫកពាមិនសមរម្យ ការលើកតម្កើងខ្លួនឯងហួសហេតុ ឈ្លើយ ក្រអើតក្រអោង។ ពាក្យ "ស្កក" តាមន័យត្រង់ គឺសំដៅទៅលើកួរស្រូវមានគ្រាប់ស្រូវជាដើមដែលផ្លែមិនមានដាក់គ្រាប់ ផ្លែមានតែសម្បកគ្មានគ្រាប់ខាងក្នុង។ បើតាមន័យធៀបមានន័យថា ការមិនទទួលបាននូវសេចក្ដីគាប់គួរ ការទទួលរងនូវការរិះគន់ ការទទួលរងនូវការតិះដៀល ការបាត់បង់សេចក្ដីថ្លៃថ្នូរ ការបរាជ័យ និងការមិនទទួលបាននូវលទ្ធផលល្អ។ ពាក្យ "ឱន" តាមន័យត្រង់គឺសំដៅទៅលើកួរស្រូវដែលទន់ចុះ បន្ទន់ទៅមុខ បន្ទន់ទៅរក។ បើតាមន័យធៀបមានន័យថា ការប្រព្រឹត្តប្រកបដោយចេះដាក់ខ្លួនឱ្យទាប ចេះឱនលំទោន ទន់ភ្លន់ ឫកពាសុភាពរាបសា រមទម្យជាដើម។ ពាក្យ "ដាក់គ្រាប់" តាមន័យត្រង់ គឺសំដៅទៅលើកួរស្រូវជាដើមដែលផ្លែវាមានគ្រាប់ពេញ គ្រាប់នោះបើជាផ្លែស្រូវគេហៅថា គ្រាប់អង្ករ។ បើតាមន័យធៀបមានន័យថា ការទទួលបាននូវសេចក្ដីគាប់គួរ ការកោតសរសើរ ការគោរព ការស្រឡាញ់រាប់អាន សេចក្ដីថ្លៃថ្នូរ ការទទួលបានជោគជ័យនិងការទទួលបាននូវលទ្ធផលល្អ។ តាមរយៈអត្ថន័យរបស់ពាក្យគន្លឹះខាងលើប្រធានមានន័យថា កួរស្រូវដែលឈរត្រង់ទៅលើ គឺដោយសារវាមិនមានដាក់គ្រាប់ ចាត់ទុកថាមិនទទួលបានផលឡើយ ប្រៀបដូចមនុស្សដែលប្រព្រឹត្តប្រកបដោយឫកពាអួតក្អេងក្អាង លើកតម្កើងខ្លួនឯងហួសហេតុមិនសមរម្យ ឈ្លើយ ក្រអើតក្រអោង តែងមិនទទួលបាននូវសេចក្ដីគាប់គួរ ទទួលរងនូវការរិះគន់ ទទួលរងនូវការតិះដៀល ការបាត់បង់សេចក្ដីថ្លៃថ្នូរ ការបរាជ័យ និងការមិនទទួលបាននូវលទ្ធផលល្អ។ ផ្ទុយទៅវិញ កួរស្រូវដែលទន់ចុះគឺដោយសារផ្លែវាមានគ្រាប់ពេញលេញចាត់ទុកថាទទួលបានផលល្អ ប្រៀបដូចមនុស្សដែលប្រព្រឹត្តដោយចេះដាក់ខ្លួនឱ្យទាប ចេះឱនលំទោន ឫកពាទន់ភ្លន់ សុភាពរាបសា រមទម្យតែងទទួលបាននូវសេចក្ដីគាប់គួរ ការកោតសរសើរ ការគោរព ការស្រឡាញ់រាប់អាន សេចក្ដីថ្លៃថ្នូរ ការទទួលបានជោគជ័យនិងការទទួលបាននូវលទ្ធផលល្អ។

ពិតហើយដូចសុភាសិតបានលើកឡើងថា"ងើយស្កក ឱនដាក់គ្រប់"គឺសំដៅទៅលើរុក្ខជាតិដែលមានទងកួរឈរត្រង់ទៅលើដោយសារផ្លែវាមិនមានដាក់គ្រាប់ ពោលគឺផ្លែមានតែសម្បកគ្មានគ្រាប់។ កួរដែលផ្លែគ្មានគ្រាប់ដូចនេះ គេហៅថា"ស្កក" "ងើយស្កក"គឺសំដៅលើដំណាំស្រូវដែលកួររបស់វាមានផ្លែតែគ្មានដាក់គ្រាប់ ជាហេតុធ្វើឱ្យកួរនោះស្រាលងើយឈរត្រង់ទៅលើ។ ស្រូវបែបនេះ គេហៅថា ស្រូវស្កក មិនទទួលបានផលឡើយ។ ឃ្លាថា"ងើយស្កក"នេះគេចង់ប្រៀបធៀបទៅនឹងមនុស្ស ដែលប្រព្រឹត្តប្រកបដោយអត្តចរិតមិនសមរម្យ ឫកពាអួតក្អេងក្អាង លើកតម្កើងខ្លួនឯងហួសហេតុ។ ពេលខ្លះ

ទៀតគេជាមនុស្សមានកាយវិការច្រងេងច្រងាង មានសម្តីគំរោះគំរើយជាដើម។ មនុស្សបែបនេះ តែងតែមានឥរិយាបថដើរ ដេក ឈរ អង្គុយ និងនិយាយស្តី ផ្តាំផ្តងមិនសមរម្យ។ មនុស្សប្រភេទនេះគេហៅថា មនុស្សឈ្លើយ។ នៅក្នុងសង្គមជាក់ស្តែង បើបុគ្គលណាម្នាក់មាន ឫកពាអួតក្អេងក្អាងនៅកន្លែងការងារ ឬកន្លែងរកស៊ី នោះនឹងធ្វើឱ្យអ្នកដទៃមិនចូលចិត្ត ស្អប់ខ្ពើម រិះគន់រហូតអាចឈានទៅដល់ការបាត់បង់ការងារ ឬអាចរកស៊ីមិនបានជោគជ័យ។ ម្យ៉ាងទៀត បើបុគ្គលណាម្នាក់មានកាយវិការច្រងេងច្រងាង សម្តីគំរោះគំរើយជាដើមនៅតាមទីសាធារណៈ នៅក្នុងសហគមន៍ និងនៅក្នុងសង្គមទាំងមូលនោះនឹងទទួលរងនូវការរិះគន់ និងបាត់បង់សេចក្តីថ្លៃថ្នូរជាក់ជាមិនខាន។ ចំពោះរឿងកុលាបប៉ៃលិនវិញ តួអង្គបាឡាត់មានអត្តចរិតមិនសមរម្យ ឫកពាអួតក្អេងក្អាងលើកតម្កើងខ្លួនឯងហួសហេតុ ជាហេតុធ្វើឱ្យតួអង្គនេះទទួលរងនូវការស្អប់ខ្ពើមពីឃុននារី ក៏ដូចជាលោកហ្លួងរតនសម្បត្តិ រហូតទទួលរងនូវភាពបរាជ័យ។ ដូច្នេះមនុស្សដែលមានអាកប្បកិរិយា ឫកពាអួតក្អេងក្អាង ឫកពាមិនសមរម្យ ការលើកតម្កើងខ្លួនឯងហួសហេតុ ឈ្លើយជាដើម តែងតែទទួលរងនូវការរិះគន់ ការតិះដៀល បាត់បង់សេចក្តីថ្លៃថ្នូរ ទទួលបរាជ័យ និងមិនទទួល បានលទ្ធផលល្អនៅក្នុងជីវិតឡើយ។

ចំណែកឃ្លាថា"ឱនដាក់គ្រាប់"គឺសំដៅទៅលើរុក្ខជាតិដែលមានទងកួរប្រវែងប្រហែលមួយចំអាមឬលើសបន្តិចនៅខាងចុង ហើយផ្លែតូចៗជាច្រើនស្អេកស្កះជាប់នឹងទងកួរនោះ។ ទងកួរនេះ កាលណាផ្លែនៅខ្ចីមិនទាន់ដាក់គ្រាប់វាឈរទៅលើ។ កាលណាផ្លែវាចាស់រហូតដល់ទុំ ដាក់គ្រាប់ពេញធ្វើឱ្យកួរវាធ្ងន់ក៏ឱនចុះក្រោម។ នេះជាសញ្ញាបញ្ជាក់ថា រុក្ខជាតិនោះមានផ្លែល្អ។ ហេតុដូច្នេះហើយទើបគេនិយាយថា"ឱនដាក់គ្រាប់"។ តួយ៉ាងដូចជាដំណាំស្រូវ កាលណាវាចេញកួរផ្លែវានៅខ្ចីមិនទាន់ដាក់គ្រាប់កួរវាស្រាលហើយស្ថិតនៅឈរទៅលើ។ កាលណាផ្លែវាចាស់រហូតដល់ទុំដាក់គ្រាប់ពេញ ធ្វើឱ្យកួរវាធ្ងន់ក៏ឱនចុះក្រោម។ ផ្លែមានដាក់គ្រាប់ពេញ គេចាត់ទុកថាស្រូវនោះទទួលបានផលល្អ។ ដូច្នេះឃ្លាខាងលើនេះគឺសំដៅលើកួរស្រូវដែលមានគ្រាប់ពេញល្អ ធ្វើឱ្យកួរវាឱនចុះ ហើយគេចាត់ទុកថាស្រូវនោះមានផលល្អ។ តាមពិតចាស់បុរាណខ្មែរយើងចង់អប់រំទូន្មានកូនចៅដោយមិនប្រើពាក្យត្រង់ៗនោះទេ ពោលគឺការអប់រំទូន្មានមួយចំនួនលោកតែងតែប្រើពាក្យ ឬឃ្លាបង្កប់អត្ថន័យ ដើម្បីឱ្យកូនចៅបានគិតត្រិះរិះពិចារណាបង្កើនប្រាជ្ញា រួចសឹមយកទៅអនុវត្ត។ ដូច្នេះឃ្លាថា "ឱនដាក់គ្រាប់"លោកចង់ធ្វើការប្រៀបធៀបកួរស្រូវទៅនឹងការប្រព្រឹត្តរបស់មនុស្ស។ ឃ្លានេះមានន័យថា ការរស់នៅប្រចាំថ្ងៃ ការធ្វើការងារ ក៏ដូចជាការប្រកបរបរចិញ្ចឹមជីវិត មនុស្សគ្រប់រូបត្រូវចេះដាក់ខ្លួនឱ្យទាប ចេះឱនលំទោន ទន់ភ្លន់ ឫកពាសុភាពរាបសា នោះធ្វើឱ្យអ្នកទទួលបានជោគជ័យប្រកបដោយសេចក្តីថ្លៃថ្នូរ។ មនុស្សនៅក្នុងសង្គមទាំងមូលតែងមានវ័យ តួនាទី ភារកិច្ច និងឋានៈខុសៗគ្នា ហើយតែងតែមានទំនាក់ទំនងគ្នាទៅវិញទៅមក។ ក្នុងការទំនាក់ទំនងគ្នា ក៏ដូចជាក្នុងការធ្វើការងារ និងការប្រកបរបររកស៊ីជាដើម មនុស្សយើងត្រូវចេះប្រតិបត្តិឱ្យបានល្អដូចជាការចេះដាក់ខ្លួនឱ្យទាប ការចេះឱនលំទោន ការចេះគោរពគ្នាជាដើម នោះយើងនឹងទទួលបានទាំងកិត្តិយស និងលាភសក្ការៈទៀតផង។ ការរស់នៅប្រចាំថ្ងៃទាំងនៅក្នុងគ្រួសារតាមទីសាធារណៈក៏ដូចជាក្នុងសហគមន៍ ត្រូវប្រកាន់ឥរិយាបថ ដើរ ដេក ឈរ អង្គុយ និងនិយាយស្តីជាដើម ឱ្យបានល្អប្រសើរ នោះអ្នកនឹងទទួលបាននូវការគោរព ការស្រឡាញ់រាប់អាន និងការសរសើរជាដើម។ តួយ៉ាងដូចជានៅក្នុងសង្គមជាក់ស្តែង ពេលជួបជាមួយចាស់ទុំ យើងចេះគោរពឱនលំទោននោះអ្នកផងនឹងសរសើរយើង ឱ្យតម្លៃយើង។ ការធ្វើទំនាក់ទំនងជាមួយអ្នកមានឋានៈធំក្នុងការងារ ត្រូវចេះរៀបចំឫកពាឱ្យបានសមរម្យ ត្រូវចេះគោរពឱនលំទោន នោះគេនឹងអាណិតស្រឡាញ់យើង គាំទ្រយើង ជួយយើងជាដើម។ ដូចកវីក្រមង៉ុយពោលថា "បុណ្យសក្តិទ្រព្យផង កើតដោយប្រណិប័តន៍"។

ចំពោះនៅក្នុងអក្សរសិល្ប៍រឿងកុលាបប៉ៃលិន តួអង្គចៅចិត្រចេះដាក់ខ្លួនឱ្យទាប ចេះឱនលំទោន ប្រកាន់ឫកពាទន់ភ្លន់ សុភាពរាបសា និយាយស្ដីសមរម្យ ធ្វើឱ្យលោកហ្លួងរតនសម្បត្តិចូលចិត្ត ស្រឡាញ់ ពេញចិត្ត មានការទុកចិត្ត រហូតប្រគល់មុខរបរ និងកូនស្រីមកធ្វើជាប្រពន្ធ នេះគឺចាត់ទុកថាចៅចិត្រ ទទួលបានជោគជ័យក៏ដូចជាការទទួលបានលទ្ធផលល្អក្នុងជីវិតផងដែរ។ ដូច្នេះមនុស្សគ្រប់រូបត្រូវចេះ ដាក់ខ្លួនឱ្យទាប ចេះឱនលំទោន មានឫកពាទន់ភ្លន់ សុភាពរាបសា សម្ដីផ្អែមល្ហែម ទាំងនៅក្នុងការងារ ការប្រកបរបររកស៊ី និងការរស់នៅប្រចាំថ្ងៃ។ អ្នកប្រព្រឹត្តដូច្នេះបានល្អមែងតែងតែបានទទួលនូវ ការកោតសរសើរ ការគោរព ការស្រឡាញ់រាប់អាន សេចក្តីថ្លៃថ្នូរ ភាពជោគជ័យ និងការទទួលបាននូវ លទ្ធផលល្អនៅក្នុងជីវិត។

សរុបសេចក្តីមក កួរផ្លែស្រូវស្កក គឺជាកួរផ្លែដែលមិនដាក់គ្រាប់ មិនបានផល ប្រៀបដូចមនុស្ស ដែលមានអត្តចរិតអួតក្អេងក្អាង ឫកពាច្រងេងច្រងាង តែងទទួលរងការរិះគន់ ការស្អប់ខ្ពើម ទទួល បរាជ័យ និងមិនទទួលបាននូវលទ្ធផលល្អឡើយ។ ផ្ទុយពីកួរផ្លែដែលឱនចុះ គឺជាកួរផ្លែដាក់គ្រាប់ពេញ ល្អ មានផលល្អ ប្រៀបដូចមនុស្សដែលមានអាកប្បកិរិយាទន់ភ្លន់ ចេះឱនលំទោន សុភាពរាបសា តែង តែទទួលបាននូវសេចក្តីថ្លៃថ្នូរ និងទទួលបានជោគជ័យក្នុងជីវិត។

តាមរយៈការបកស្រាយមកពីខាងលើ សុភាសិតនេះពិតជាមានអត្ថន័យអប់រំយ៉ាងជ្រាលជ្រៅ សម្រាប់អប់រំកូនចៅគ្រប់ជំនាន់ឱ្យប្រព្រឹត្តល្អដើម្បីរស់នៅប្រកបដោយសុភមង្គល។ ដូច្នេះក្នុងនាមយើង ជាអ្នកសិក្សាក៏ដូចជាកូនចៅជំនាន់ក្រោយ ត្រូវខិតខំសិក្សាស្វែងយល់ពីខ្លឹមសារសុភាសិតខ្មែរបន្ថែម ទៀត ព្រោះវាជាមរតកដ៏មានតម្លៃ សម្រាប់ទូន្មានយើងឱ្យក្លាយជាមនុស្សល្អ រស់នៅប្រកបដោយ សុភមង្គល ហើយយើងត្រូវថែរក្សាសុភាសិតទាំងអស់ឱ្យនៅគង់វង្ស សម្រាប់ទូន្មានមនុស្សបច្ចុប្បន្នក៏ ដូចជាមនុស្សជំនាន់ក្រោយទៀត។

---

**ប្រធានទី៥:** សុភាសិតមួយចែងថា «ធ្វើស្រែនឹងទឹក ធ្វើសឹកនឹងបាយ»។ ចូរពន្យល់បកស្រាយ សុភាសិតខាងលើឱ្យបានក្បោះក្បាយ និងលើកឧទាហរណ៍មកបញ្ជាក់ផង។

---

## គម្រោងតែង

### ក- សេចក្តីផ្តើម

- **លំនាំបញ្ហា:** និយាយទូទៅទាក់ទងនឹងគោលបំណងនៃសុភាសិតនេះ គឺមុននឹងធ្វើអ្វីមួយត្រូវចេះគិត គូរ រៀបចំគ្រឿងសម្ភារៈ ឬរៀបចំកម្លាំង ឬយុទ្ធវិធីផ្សេងៗ...
- **ចំណូលបញ្ហា(បង្ហាញបញ្ហា):** ការលើកយកប្រធានមកបង្ហាញ...ធ្វើស្រែនឹងទឹក ធ្វើសឹកនឹងបាយ...
- **ចំណោទបញ្ហា:** ការចោទសួរទៅលើប្រធាន...តើសុភាសិតនេះមានអត្ថន័យដូចម្ដេច...។

### ខ- តួសេចក្តី

- **ឃ្លាភ្ជាប់សេចក្តី:** ...ដើម្បីជាជំនួយដល់ការបកស្រាយ គប្បីយល់នូវន័យនៃពាក្យគន្លឹះរបស់ប្រធាន ជាមុនសិន...
- **ពន្យល់ពាក្យគន្លឹះ៖**
  - ✓ ធ្វើស្រែ: មានន័យថាសកម្មភាពប្រកបរបរកសិកម្មមានដក ស្ទូង ភ្ជួរ រាស់...
  - ✓ សឹក: មានន័យថា ចម្បាំង ការធ្វើសង្គ្រាម ការប្រយុទ្ធគ្នា ការច្បាំងគ្នា...។

- **ពន្យល់ន័យប្រធាន:** ...ការធ្វើស្រែត្រូវពឹងផ្អែកទៅលើទឹកទើបអាចទទួលបានផលល្អ។ រីឯការធ្វើសឹកវិញ គឺត្រូវមានស្បៀងអាហារគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់កងទ័ព ទើបអាចធ្វើសង្គ្រាមបាន... ។
- **បកស្រាយប្រធាន៖**
  - ✓ ការធ្វើស្រែចម្ការត្រូវពឹងផ្អែកលើទឹក...ការធ្វើស្រែចម្ការដាំដំណាំផ្សេងៗ ត្រូវពឹងផ្អែកលើកត្តាជាច្រើនដូចជាជី ពូជ ដីស្រែ និងបច្ចេកទេសជាដើម។ កត្តាទាំងនេះ គ្រាន់តែជាការរួមផ្សំប៉ុណ្ណោះ។ អ្វីដែលសំខាន់បំផុតនោះគឺ ការធ្វើស្រែចម្ការ ការដាំដំណាំផ្សេងៗគឺត្រូវពឹងលើទឹក ដែលជាកត្តាសំខាន់បំផុត...
  - ✓ ឧទាហរណ៍...ឧទាហរណ៍ដូចជា សព្វថ្ងៃនៅប្រទេសកម្ពុជាយើង មានតំបន់ខ្លះខ្វះទឹកធ្វើឱ្យដំណាំស្រូវខូចខាតអស់។ ដូច្នេះហើយទើបនៅពេលជួបគ្រោះរាំងស្ងួត ប្រជាជនយើងតែងខ្នះខ្នែងរកវិធីបូមទឹកដាក់ដើម្បីកុំឱ្យស្រូវងាប់...
  - ✓ ការធ្វើសឹកសង្គ្រាម...គឺត្រូវការពឹងផ្អែកលើកត្តាជាច្រើនដូចជា កម្លាំងទ័ព យុទ្ធវិធីគ្រឿងសព្វាវុទ្ធ និងគ្រឿងបរិក្ខារជាច្រើនទៀត។ ក្នុងនោះអ្វីដែលសំខាន់ជាងគេនោះ គឺស្បៀងអាហារ...
  - ✓ ឧទាហរណ៍...ដូចជានៅក្នុងឆ្នាំពីរពាន់ប្រាំបី គ្រាដែលកងទ័ពសៀមឈ្លានពានចូលប្រាសាទព្រះវិហាររបស់ខ្មែរយើង បង្កឱ្យមានសង្គ្រាមកើតឡើងរវាងប្រទេសកម្ពុជាជាមួយប្រទេសថៃ។ នៅក្នុងចម្បាំងនេះ យើងសួរថាបើគ្មានស្បៀងអាហារគ្រប់គ្រាន់ទេ តើយើងអាចធ្វើសង្គ្រាមកើតឬក៏អត់...។
- **សរុបសេចក្ដី:** ... ការធ្វើស្រែចម្ការត្រូវពឹងផ្អែកទៅលើទឹកជាសំខាន់ ទើបអាចទទួលបានផលល្អ។ រីឯការធ្វើសង្គ្រាមវិញ គឺត្រូវមានស្បៀងអាហារគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់កងទ័ព ទើបអាចធ្វើសង្គ្រាម និងអាចទទួលជោគជ័យបាន...។

**គ- សេចក្ដីបញ្ចប់**

- **វាយតម្លៃប្រធាន:** សុភាសិតខាងលើពិតមាអត្ថន័យជ្រាលជ្រៅ សម្រាប់អប់រំមនុស្សទូទៅក្នុងសង្គមឱ្យចេះត្រៀមលក្ខណសម្បត្តិបានគ្រប់ជ្រុងជ្រោយមុននឹងធ្វើអ្វីមួយ...
- **យោបល់ផ្ទាល់ខ្លួន:** ដូច្នេះយើងជាសិស្សានុសិស្ស ត្រូវខិតខំប្រឹងប្រែងសិក្សារៀនសូត្រឱ្យមានចំណេះដឹងខ្ពស់ និងខិតខំសិក្សាស្រាវជ្រាវរកដំបូន្មានល្អៗបន្ថែមទៀត ដើម្បីយកមកប្រតិបត្តិតាម...។

## សេចក្តីអធិប្បាយ

ឆ្លងកាត់បទពិសោធជាច្រើនជំនាន់ ដូនតាខ្មែរយើងបានរិះរកមធ្យោបាយផ្សេងៗ សម្រាប់អប់រំទូន្មានប្រៀនប្រដៅកូនចៅ។ តាមរយៈគតិអប់រំល្អៗមានដូចជាសុភាសិត ពាក្យស្លោក និងគំនិតអប់រំជាច្រើនទៀត សម្រាប់ជួយតម្រង់ទិសទូន្មានប្រៀនប្រដៅកូនចៅជំនាន់ក្រោយ។ ហេតុដូច្នេះហើយទើបមានពាក្យសុភាសិតមួយចែងថា"ធ្វើស្រែនឹងទឹក ធ្វើសឹកនឹងបាយ"។

តើសុភាសិតនេះ មានអត្ថន័យដូចម្ដេច?

មុននឹងបកស្រាយយើងគួរយល់នូវន័យរបស់ពាក្យគន្លឹះជាមុនសិនគឺពាក្យ"ធ្វើស្រែធ្វើសឹក។ ចំពោះពាក្យធ្វើស្រែ គឺជាសកម្មភាពភ្ជួររាស់ សាបព្រោះ ដកស្ទូង ដើម្បីទទួលបានផលស្រូវ។ ពាក្យ ធ្វើសឹកមានន័យថាធ្វើចម្បាំង ធ្វើសង្គ្រាម ប្រយុទ្ធគ្នា ។ ដូច្នេះប្រធានមានន័យថា ការធ្វើស្រែចម្ការត្រូវពឹងផ្អែកទៅលើទឹក ទើបអាចទទួលបានផលល្អ។ រីឯការធ្វើសង្គ្រាមវិញ គឺត្រូវមានស្បៀងអាហារគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់កងទ័ព ទើបអាចធ្វើសង្គ្រាមបានទទួលជោគជ័យ។

ជាការពិតដូចសុភាសិតលើកឡើង "ធ្វើស្រែនឹងទឹកធ្វើសឹកនឹងបាយ"។ ធ្វើស្រែនឹងទឹកមានន័យថា ការធ្វើស្រែចម្ការដាំដំណាំផ្សេងៗ ត្រូវពឹងផ្អែកលើកត្តាជាច្រើនដូចជាជី ពូជ ដី និងបច្ចេកទេសដែលជាកត្តារួមផ្សំប៉ុណ្ណោះ។ អ្វីដែលសំខាន់បំផុតនោះគឺ ការធ្វើស្រែចម្ការ ការដាំដំណាំផ្សេងៗគឺត្រូវពឹងលើទឹក កត្តាសំខាន់ជាងគេ។ ស្រូវក៏ដូចជាដំណាំដទៃទៀតដែរ លុះត្រាតែមានទឹកគ្រប់គ្រាន់ទើបអាចលូតលាស់បានល្អ។ ប្រសិនបើយើងធ្វើស្រែដោយគ្មានទឹក នោះស្រូវក៏ពុំលូតលាស់ល្អដែរ។ មិនតែប៉ុណ្ណោះ បើខ្វះទឹកយូរពេក ស្រូវអាចក្រៀមស្វិត ឬងាប់ខូចខាតទាំងស្រុងតែម្តង។ ជាក់ស្តែងដូចជា សព្វថ្ងៃនៅប្រទេសកម្ពុជាយើង មានតំបន់ខ្លះខ្វះទឹកធ្វើឱ្យដំណាំស្រូវខូចខាតអស់។ ដូច្នេះហើយទើបនៅពេលជួបគ្រោះរាំងស្ងួត ប្រជាជនយើងតែងខ្នះខ្នែងរកវិធីបូមទឹកដាក់ដើម្បីកុំឱ្យស្រូវងាប់។ បច្ចុប្បន្ននេះ នៅតាមតំបន់មួយចំនួនគេបានអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រដើម្បីយកទឹកមកធ្វើស្រែ។ ដូច្នេះ ការធ្វើស្រែត្រូវពឹងផ្អែកទៅលើទឹកជាកត្តាសំខាន់បំផុត។ ចំណែកឯការធ្វើសឹកសង្គ្រាមវិញ គឺត្រូវការពឹងផ្អែកលើកត្តាជាច្រើនដូចជា កម្លាំងទ័ព យុទ្ធវិធី គ្រឿងសព្វាវុធនិងគ្រឿងបរិក្ខារជាច្រើនទៀត។ ក្នុងនោះអ្វីដែលសំខាន់ជាងគេនោះ គឺស្បៀងអាហារគ្រប់គ្រាន់។ ក្នុងការធ្វើសង្គ្រាម ប្រសិនយើងមានកងទ័ពច្រើនមានអាវុធយុទ្ធភ័ណ្ឌគ្រប់គ្រាន់ មានយុទ្ធវិធីល្អ តែគ្មានស្បៀងអាហារនោះ ក៏យើងមិនអាចធ្វើសង្គ្រាមបានដែរ។ កងទ័ពត្រូវការស្បៀងអាហារហូបចុកឆ្អែតគ្រប់គ្រាន់ទើបមានកម្លាំងអាចប្រយុទ្ធគ្នាបាន។ បើមិនដូច្នោះទេ ការធ្វើសង្គ្រាមនឹងត្រូវបរាជ័យជាក់ជាពុំខាន។ យ៉ាងណាមិញដូចជានៅក្នុងឆ្នាំពីរពាន់ប្រាំបីគ្រាដែលកងទ័ពសៀមឈ្លានពានយកប្រាសាទព្រះវិហាររបស់ខ្មែរយើងបង្កឱ្យមានសង្គ្រាមកើតឡើងរវាងប្រទេសកម្ពុជាជាមួយប្រទេសថៃ។ នៅក្នុងចម្បាំងនេះ យើងសួរថាបើគ្មានស្បៀងអាហារគ្រប់គ្រាន់ទេតើយើងអាចធ្វើសង្គ្រាមកើត ឬក៏អត់។ ជាការពិតណាស់ប្រសិនគ្មានស្បៀងអាហារគ្រប់គ្រាន់ទេកងទ័ពមិនអាចធ្វើសង្គ្រាមបានឡើយ តែប្រសិនបើអាចធ្វើបានក៏នឹងត្រូវទទួលបរាជ័យដែរ ព្រោះគ្មានទាហានណាខ្វះអាហារហូបចុក ហើយអាចចេញច្បាំងបានឡើយ។ ដូច្នេះក្នុងការធ្វើសង្គ្រាម គឺត្រូវមានស្បៀងអាហារគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់កងទ័ពទើបអាចធ្វើសង្គ្រាម និងអាចទទួលជោគជ័យបាន។

សរុបមកការធ្វើស្រែចម្ការត្រូវពឹងផ្អែកទៅលើទឹកជាសំខាន់ ទើបអាចទទួលបានផលល្អ។ រីឯការធ្វើសង្គ្រាមវិញ គឺត្រូវមានស្បៀងអាហារគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់កងទ័ពទើបអាចធ្វើសង្គ្រាម និងអាចទទួលជោគជ័យបាន។

សុភាសិតខាងលើពិតជាមានអត្ថន័យជ្រាលជ្រៅ សម្រាប់អប់រំមនុស្សទូទៅក្នុងសង្គម ឱ្យចេះត្រៀមលក្ខណៈសម្បត្តិបានគ្រប់ជ្រុងជ្រោយមុននឹងធ្វើអ្វីមួយ។ ដូច្នេះយើងជាសិស្សានុសិស្សត្រូវខិតខំប្រឹងប្រែងសិក្សារៀនសូត្រឱ្យមានចំណេះដឹងខ្ពស់និងខិតខំសិក្សាស្រាវជ្រាវរកដំបូន្មានល្អៗបន្ថែមទៀតដើម្បីយកមកប្រតិបត្តិតាមធ្វើឱ្យខ្លួនក្លាយជាមនុស្សល្អមានប្រយោជន៍សម្រាប់សង្គម។

**ប្រធានទី៦:** ទស្សនៈពុទ្ធនិយមបានអប់រំថា «ការធ្វើអំពើល្អរមែងទទួលបាននូវផលល្អ ការធ្វើអំពើអាក្រក់រមែងទទួលបាននូវផលអាក្រក់»។ ចូរពន្យល់បកស្រាយសុភាសិតខាងលើឱ្យបានក្បោះក្បាយ និងលើកឧទាហរណ៍មកបញ្ជាក់ផង។

## គម្រោងតែង

**ក- សេចក្តីផ្តើម**

- **លំនាំបញ្ហា:** និយាយទូទៅទាក់ទងនឹងគោលបំណងនៃសុភាសិតនេះ...ការប្រព្រឹត្តអំពើល្អការប្រព្រឹត្តអំពើអាក្រក់...
- **ចំណូលបញ្ហា(បង្ហាញបញ្ហា):** ការលើកយកប្រធានមកបង្ហាញ...ការធ្វើអំពើល្អរមែងទទួលបាននូវផលល្អ ការធ្វើអំពើអាក្រក់រមែងទទួលបាននូវផលអាក្រក់...
- **ចំណោទបញ្ហា:** ...តើសុភាសិតនេះមានអត្ថន័យដូចម្តេច...។

**ខ- តួសេចក្តី**

- **ឃ្លាភ្ជាប់សេចក្តី:** ដើម្បីជាជំនួយដល់ការបកស្រាយ គប្បីយល់នូវន័យនៃពាក្យគន្លឹះរបស់ប្រធានជាមុនសិន...។
- ពន្យល់ពាក្យគន្លឹះ៖
  - ✓ អំពើ: ...មានន័យថា ការធ្វើ ការប្រព្រឹត្ត...
  - ✓ ផល: ...មានន័យថា ផ្លែ សេចក្តីចម្រើន លាភ ចំណេញ រង្វាន់ សេចក្តីរុងរឿង អ្វីៗដែលកើតមកអំពីហេតុ សុខទុក្ខដែលកើតពីអំពើ...។
- **ពន្យល់ន័យប្រធាន:** ពន្យល់ន័យរួមរបស់ប្រធាន តើប្រធានចង់និយាយពីអ្វី(ប្រធានខាងលើមានន័យថា ការធ្វើអំពើល្អតែងតែទទួលបាននូវសេចក្តីសុខ សេចក្តីចម្រើន...។ រីឯការធ្វើអំពើអាក្រក់តែងតែទទួលបាននូវទុក្ខ...។
- បកស្រាយប្រធាន៖
  - ✓ ការធ្វើអំពើល្អតែងទទួលបានផលល្អនៅក្នុងសង្គមជាក់ស្តែង ... អ្នកធ្វើអំពើល្អតែងតែទទួលបាននូវផលល្អជានិច្ចដូចជានៅក្នុងសង្គមជាក់ស្តែងមានមនុស្សជាច្រើនខិតខំប្រព្រឹត្តតែអំពើល្អជានិច្ច។ ពួកគេតែងមានព្រហ្មវិហារធម៌បួនយ៉ាងគឺ ទីមួយគឺ"មេត្តា"មានន័យថា រាប់អានអ្នកដទៃដោយមិនរើសអើង។ ទីពីរគឺ"ករុណា" មានន័យថា អាណិតស្រឡាញ់អ្នកដទៃគ្រប់ៗគ្នា។ ទីបីគឺ"មុទិតា"មានន័យថា ត្រេកអរនឹងអ្នកដទៃដែលបានសេចក្តីសុខចម្រើន។ ទីបួនគឺ"ឧបេក្ខា"មានន័យថា មានសេចក្តីស្មោះត្រង់ និងស្មើភាពជាមួយអ្នកដទៃ...
  - ✓ ឧទាហរណ៍នៅក្នុងសង្គមជាក់ស្តែង...ឧទាហរណ៍នៅពេលអ្នកជិតខាងមានទុក្ខធុរៈដូចជាការជួបគ្រោះថ្នាក់ផ្សេងៗ ការមានជំងឺ ការសង់ផ្ទះ ការធ្វើបុណ្យ ការរៀបអាពាហ៍ពិពាហ៍ជាដើម ហើយយើងចូលជួយនោះនៅពេលដែលយើងជួបទុក្ខធុរៈដែរ គេនឹងជួយវិញ...
  - ✓ ឧទាហរណ៍នៅក្នុងអក្សរសិល្ប៍... យើងសង្កេតឃើញតួអង្គដែលធ្វើអំពើល្អ ហើយបានទទួលផលល្អដូចជានៅក្នុងរឿង"លលក និងស្រមោច"។ ថ្ងៃមួយ ស្រមោចឃើញព្រានកំពុងលើកស្នាតម្រង់បាញ់លលក ក៏នាំគ្នាជួយយកអាសាលលកដោយនាំគ្នាទៅខាំជើងព្រាន ធ្វើឱ្យព្រានភ្ញាក់ទន្រ្ទាំជើង លលកដឹងខ្លួនក៏ស្ទុះហើរបានរួចជីវិតទៅ...

- ✓ ការធ្វើអំពើល្អតែងទទួលបានផលល្អនៅក្នុងព្រះពុទ្ធសាសនា... នៅក្នុងព្រះពុទ្ធសាសនាវិញ ការធ្វើអំពើល្អតែងទទួលផលល្អទាំងនៅក្នុងជាតិនេះ និងទាំងនៅជាតិខាងមុខ...
- ✓ ឧទាហរណ៍នៅក្នុងទស្សនៈព្រះពុទ្ធសាសនា...ឧទាហរណ៍ បើយើងបានធ្វើបុណ្យដាក់ទាន ជួយសង្គ្រោះអ្នកដទៃ ជួយកសាងសាលារៀន វត្តអារាមជាដើម នោះយើងនឹងបានទទួលនូវកុសលផលបុណ្យអាចបាននៅក្នុងជាតិនេះឬនៅជាតិខាងមុខដូចជា ទទួលបានភព្វវាសនាល្អ ជាតិក្រោយអាចទៅកើតនៅឋានសួគ៌...
- ✓ ឧទាហរណ៍នៅក្នុងអក្សរសិល្ប៍...នៅក្នុងរឿងព្រះវេស្សន្តរដោយសារការធ្វើទានបារមី ទើបធ្វើឱ្យជាតិក្រោយបានត្រាស់ដឹងជាព្រះពុទ្ធ...
- ✓ ការធ្វើអំពើអាក្រក់តែងទទួលបានផលអាក្រក់នៅក្នុងសង្គមជាក់ស្តែង...ប្រសិនបើអ្នកហ៊ាន លួច ឆក់ ប្លន់ ជួញដូរគ្រឿងញៀន ឬការប្រកបរបរល្មើសច្បាប់ផ្សេងៗទៀត នោះអ្នកនឹងត្រូវមានទោសជាក់ជាពុំខាន...
- ✓ ឧទាហរណ៍នៅក្នុងសង្គមជាក់ស្តែង...នៅក្នុងសង្គមខ្មែរបច្ចុប្បន្នជាពិសេស ពេលមានពិធីរាំវែកតាមភូមិ គេសង្កេតឃើញថា តែងមានក្រុមយុវជន បង្កជម្លោះទាស់ទែងវាយតប់គ្នាជារឿយៗ។ ទីបញ្ចប់អ្នកទាំងនោះ ខ្លះរងរបួសព្យាបាលអស់ប្រាក់កាស ខ្លះត្រូវចាប់ខ្លួនជាប់ទោស...
- ✓ ឧទាហរណ៍នៅក្នុងអក្សរសិល្ប៍...ក្នុងរឿ"ក្រពើនិងអ្នកបររទេះ"។ តាបររទេះខំប្រឹងជួយយកអាសាក្រពើ បែរជាក្រពើរមីលគុណចង់ស៊ីតានោះទៅវិញ។ ដោយបានសុភាទន្សាយជួយធ្វើឱ្យ តាបររទេះសម្លាប់ក្រពើនោះទៅ...
- ✓ ការធ្វើអំពើអាក្រក់តែងទទួលបានផលអាក្រក់នៅក្នុងព្រះពុទ្ធសាសនា...ការធ្វើអំពើអាក្រក់តែងតែទទួលបាននូវផលអាក្រក់...
- ✓ ឧទាហរណ៍នៅក្នុងទស្សនៈព្រះពុទ្ធសាសនា...បើអ្នកប្រព្រឹត្តអំពើអាក្រក់ដូចជា ធ្វើបាបគេ សម្លាប់សត្វ សម្លាប់មនុស្ស លួច ឆក់ ប្លន់ជាដើម។ អ្នកទាំងនោះនឹងត្រូវទទួលរងនូវបាបកម្ម អាចនៅក្នុងជាតិនេះ ឬនៅជាតិខាងមុខ...
- ✓ ឧទាហរណ៍នៅក្នុងអក្សរសិល្ប៍...ក្នុងរឿង"ពុទ្ធិសែននាងកង្រី"យើងឃើញថានាងទាំងដប់ពីរ ត្រូវយក្សចាប់យកទៅខ្វេះភ្នែកចេញ ហើយរស់នៅយ៉ាងវេទនា...។

- **សរុបសេចក្តី:** ... នៅក្នុងសង្គមជាក់ស្តែងក៏ដូចជានៅក្នុងព្រះពុទ្ធសាសនាដែរ គឺការធ្វើអំពើល្អតែងទទួលបានផលល្អ រីឯការធ្វើអំពើអាក្រក់ តែងទទួលបានផលអាក្រក់...។

**គ- សេចក្តីបញ្ចប់**

- **វាយតម្លៃប្រធាន:** ...សុភាសិតដែលបានចែងមកខាងលើនេះ ពិតជាមានអត្ថន័យអប់រំជ្រាលជ្រៅសម្រាប់អប់រំទូន្មានកូនចៅខ្មែរយើងគ្រប់រូបឱ្យបានយល់ដឹង...
- **យោបល់ផ្ទាល់ខ្លួន:** ...ដូច្នេះក្នុងនាមជាសិស្សានុសិស្ស ត្រូវខិតខំព្យាយាមរៀនសូត្រ និងសិក្សាស្រាវជ្រាវបន្ថែមទៀត ដើម្បីស្វែងយល់ឱ្យបានទូលំទូលាយអំពីសុភាសិតខ្មែរ ក៏ដូចជាដំបូន្មានផ្សេងៗ...។

## សេចក្តីអធិប្បាយ

បុព្វបុរសដូនតាខ្មែរយើងតាំងពីបុរាណកាលមកតែងយកចិត្តទុកដាក់ចងក្រង ពាក្យស្លោក សុភាសិត កំណាព្យ រឿងនិទានផ្សេងៗជាច្រើនសម្រាប់អប់រំ ទូន្មានប្រៀនប្រដៅកូនចៅគ្រប់ជំនាន់ ប្រាថ្នាចង់ឱ្យកូនចៅទាំងអស់រស់នៅប្រកបដោយសេចក្តីសុខសុភមង្គល។ ដោយហេតុដូច្នេះហើយ

ទើបមានទ្រឹស្តីពុទ្ធសាសនាមួយចែងថា "ការធ្វើអំពើល្អរមែងទទួលបាននូវផលល្អ ការធ្វើអំពើអាក្រក់រមែងទទួលបាននូវផលអាក្រក់"។

តើសុភាសិតខាងលើនេះ មានអត្ថន័យដូចម្តេច?

ដើម្បីជាជំនួយដល់ការបកស្រាយឱ្យកាន់តែក្បោះក្បាយថែមទៀតនោះ យើងគប្បីយល់នូវន័យនៃពាក្យគន្លឹះក្នុងសុភាសិតនេះជាមុនសិនគឺពាក្យ"អំពើ ផល"។ ពាក្យអំពើមានន័យថា ការធ្វើ ការប្រព្រឹត្ត។ រីឯពាក្យ ផល មានន័យថា ផ្លែ សេចក្តីចម្រើន លាភ ចំណេញ រង្វាន់ សេចក្តីរុងរឿង អ្វីៗដែលកើតមកអំពីហេតុ សុខទុក្ខដែលកើតអំពីអំពើដែលយើងធ្វើ។ ដូច្នេះប្រធានខាងលើមានន័យថា ការធ្វើអំពើល្អតែងតែទទួលបាននូវសេចក្តីសុខ សេចក្តីចម្រើន លាភ ចំណេញ រង្វាន់ សេចក្តីរុងរឿង។ រីឯការធ្វើអំពើអាក្រក់តែងតែទទួលបាននូវទុក្ខដែលបណ្តាលមកពីអំពើដែលយើងបានធ្វើនោះ។

ពិតណាស់ដូចពុទ្ធទ្រឹស្តីខាងលើបានលើកឡើង"ធ្វើអំពើល្អទទួលបានផលល្អ"មានន័យថា មនុស្សកើតមកមិនដូចគ្នាទេ អ្នកខ្លះមានទឹកចិត្តល្អ ឯអ្នកខ្លះទៀតមានចិត្តអាក្រក់។ អ្នកមានទឹកចិត្តល្អឆ្លុះបញ្ចាំងឱ្យយើងឃើញតាមរយៈទង្វើ ឬសកម្មភាព ឬការប្រព្រឹត្តនូវអំពើល្អ។ អ្នកធ្វើអំពើល្អតែងតែទទួលបាននូវផលល្អជានិច្ច។ ដូចជានៅក្នុងសង្គមជាក់ស្តែង មានមនុស្សជាច្រើនខិតខំប្រព្រឹត្តតែអំពើល្អជានិច្ច។ ពួកគេតែងមានព្រហ្មវិហារធម៌បួនយ៉ាងគឺ ទីមួយគឺ"មេត្តា"មានន័យថា រាប់អានអ្នកដទៃដោយមិនរើសអើង។ ទីពីរគឺ"ករុណា" មានន័យថា អាណិតស្រឡាញ់អ្នកដទៃគ្រប់ៗគ្នា។ ទីបីគឺ"មុទិតា" មានន័យថា ត្រេកអរនឹងអ្នកដទៃដែលបានសេចក្តីសុខចម្រើន។ ទីបួនគឺ"ឧបេក្ខា"មានន័យថា មានសេចក្តីស្មោះត្រង់ និងស្មើភាពជាមួយអ្នកដទៃ។ ធម៌ទាំងបួនយ៉ាងនេះ នឹងធ្វើឱ្យអ្នកប្រព្រឹត្តរស់នៅប្រកបទៅដោយភាពសុខសាន្ត។ ម្យ៉ាងទៀត ការរស់នៅក្នុងសង្គមខ្មែរយើង អ្នកដែលចេះយកអាសាអ្នកដទៃ ចេះជួយដោះស្រាយទុក្ខធុរៈអ្នកដទៃនោះអ្នកដទៃនឹងតបស្នងមកវិញនៅពេលណាមួយជាក់ជាមិនខាន។ ដើម្បីជាតឹកតាងបញ្ជាក់នៅពេលអ្នកជិតខាងមានទុក្ខធុរៈដូចជាការជួបគ្រោះថ្នាក់ផ្សេងៗ ការមានជំងឺ ការសង់ផ្ទះ ការធ្វើបុណ្យ ការរៀបអាពាហ៍ពិពាហ៍ជាដើម ហើយយើងចូលជួយនោះនៅពេលដែលយើងជួបទុក្ខធុរៈដែរ គេនឹងជួយវិញមិនខាន។ លើសពីនេះបើយើងចេះគោរពស្រឡាញ់រាប់អានអ្នកដទៃ នោះអ្នកដទៃក៏នឹងគោរពស្រឡាញ់រាប់អានយើងវិញដែរ។ អ្នកប្រព្រឹត្តល្អ តែងតែរស់នៅប្រកបទៅដោយសេចក្តីថ្លៃថ្នូរដែលធ្វើឱ្យគេគោរពស្រឡាញ់និងតបស្នងសងគុណវិញពុំខាន។ ចំណែកនៅក្នុងអក្សរសិល្ប៍វិញ យើងសង្កេតឃើញតួអង្គដែលធ្វើអំពើល្អ ហើយបានទទួលផលល្អដូចជានៅក្នុងរឿង "លលក និងស្រមោច"។ ថ្ងៃមួយស្រមោចឃើញព្រានកំពុងលើកស្នាតម្រង់បាញ់លលក ក៏នាំគ្នាជួយយកអាសាលលកដោយនាំគ្នាទៅខាំជើងព្រាន ធ្វើឱ្យព្រានភ្ញាក់ទន្ទ្រាំជើង លលកដឹងខ្លួនក៏ស្ទុះហើរបានរួចជីវិតទៅ។ ក្រោយមកថ្ងៃមួយ ពេលលលកកំពុងហើររកចំណី ក៏ប្រទះឃើញហ្វូងស្រមោចកំពុងលង់ទឹក លលកក៏ពាំមែកឈើយកទៅចម្លងស្រមោចបានរួចផុតពីសេចក្តីស្លាប់។ ទាំងនេះបញ្ជាក់ថា ការចេះយកអាសាអ្នកដទៃ ពេលណាមួយអ្នកនោះនឹងជួយយកអាសាវិញមិនខាន។

នៅក្នុងព្រះពុទ្ធសាសនាវិញ ការធ្វើអំពើល្អតែងទទួលផលល្អទាំងនៅក្នុងជាតិនេះ និងទាំងនៅជាតិខាងមុខ។ ជាក់ស្តែងបើយើងបានធ្វើបុណ្យដាក់ទាន ជួយសង្គ្រោះអ្នកដទៃ ជួយកសាងសាលារៀន វត្តអារាមជាដើម នោះយើងនឹងបានទទួលនូវកុសលផលបុណ្យអាចបាននៅក្នុងជាតិនេះ ឬនៅជាតិខាងមុខដូចជាទទួលបានភព្វវាសនាល្អ ជាតិក្រោយអាចទៅកើតនៅឋានសួគ៌ជាដើម។ ចំណែក

នៅក្នុងអក្សរសិល្ប៍វិញដូចជា នៅក្នុងរឿងព្រះវេស្សន្តរដោយសារការធ្វើទានបារមី ទើបធ្វើឱ្យជាតិក្រោយបានត្រាស់ដឹងជាព្រះពុទ្ធ។

ចំណែកឃ្លាថា "ធ្វើអំពើអាក្រក់ទទួលបានផលអាក្រក់" ក្រៅពីការធ្វើអំពើល្អ ក៏មានអ្នកខ្លះបានធ្វើអំពើអាក្រក់ដែរ។ អំពើអាក្រក់ឆ្លុះបញ្ចាំងឱ្យយើងឃើញតាមរយៈទង្វើ ឬសកម្មភាព ឬការប្រព្រឹត្តនូវអំពើអាក្រក់។ អ្នកធ្វើអំពើអាក្រក់តែងតែទទួលបាននូវផលអាក្រក់ដូចជា នៅក្នុងសង្គមជាក់ស្ដែង ប្រសិនបើអ្នកហ៊ាន លួច ឆក់ ប្លន់ ជួញដូរគ្រឿងញៀន ឬការប្រកបរបរល្មើសច្បាប់ផ្សេងៗទៀតនោះ អ្នកនឹងត្រូវមានទោសជាក់ជាពុំខាន។ ម្យ៉ាងទៀត បើអ្នកលេងល្បែងស៊ីសងនោះអ្នកនឹងអន្តរាយទ្រព្យសម្បត្តិ។ ការបង្កជម្លោះទាស់ទែង វាយតប់ កាប់ចាក់គ្នាជាដើម អាចធ្វើឱ្យខ្លួនរងរបួសស្នាម អាចស្លាប់ ឬអាចមានទោសជាដើម។ ឧទាហរណ៍ នៅក្នុងសង្គមខ្មែរបច្ចុប្បន្នជាពិសេស ពេលមានពិធីរាំវង់តាមភូមិគេសង្កេតឃើញថា តែងមានក្រុមយុវជន បង្កជម្លោះទាស់ទែង វាយតប់គ្នាជារឿយៗ។ ជាលទ្ធផល អ្នកទាំងនោះ ខ្លះរងរបួសព្យាបាលអស់ប្រាក់កាស ខ្លះត្រូវចាប់ខ្លួនជាប់ទោសនិងខ្លះអាចឈានទៅដល់បាត់បង់ជីវិតទៀតផង។ ចំណែកនៅក្នុងអក្សរសិល្ប៍វិញ យើងឃើញតួអង្គដែលធ្វើអំពើអាក្រក់តែងទទួលផលអាក្រក់មកវិញ។ ដូចជាក្នុងរឿង "ក្រពើនិងអ្នកបររទេះ"។ តាបររទេះខំប្រឹងជួយយកអាសាក្រពើបែរជាក្រពើរមឹលគុណចង់ស៊ីតានោះទៅវិញ។ ដោយបានសុភាទន្សាយជួយ ធ្វើឱ្យតាបររទេះសម្លាប់ក្រពើនោះទៅ។

នៅក្នុងព្រះពុទ្ធសាសនា ការធ្វើអំពើអាក្រក់តែងតែទទួលបាននូវផលអាក្រក់។ ភស្តុតាងជាក់ស្ដែង បើអ្នកប្រព្រឹត្តអំពើអាក្រក់ដូចជាធ្វើបាបគេ សម្លាប់សត្វ សម្លាប់មនុស្ស លួច ឆក់ ប្លន់ជាដើម។ អ្នកទាំងនោះនឹងត្រូវទទួលរងនូវបាបកម្មអាចនៅក្នុងជាតិនេះឬនៅជាតិខាងមុខ។ បាបកម្មទាំងនោះមានដូចជា មានទុក្ខទោស ចុះនរក រស់នៅលំបាកវេទនា កើតមកមានកាយសម្បទាមិនពេញលក្ខណៈ។ ចំណែកនៅក្នុងអក្សរសិល្ប៍វិញដូចជាក្នុងរឿង"ពុទ្ធិសែននាងកង្រី" យើងឃើញថានាងទាំងដប់ពីរត្រូវយក្សចាប់យកទៅខ្វេះភ្នែកចេញ ហើយរស់នៅយ៉ាងវេទនា។ នេះបណ្ដាលមកពីពួកនាងកាលពីជាតិមុន បានចាប់ត្រីមកដោតទម្លុះភ្នែក ទើបបាបកម្មមានមកជាតិនេះ។

សរុបសេចក្ដីមក ទោះបីនៅក្នុងសង្គមជាក់ស្ដែងក្ដី នៅក្នុងអក្សរសិល្ប៍ក្ដី នៅក្នុងព្រះពុទ្ធសាសនាក្ដី ការធ្វើអំពើល្អតែងតែទទួលបាននូវផលល្អ ទាំងនៅក្នុងការរស់នៅជាក់ស្ដែង ទាំងនៅក្នុងអក្សរសិល្ប៍ ព្រមទាំងនៅក្នុងព្រះពុទ្ធសាសនាមិនថាជាតិនេះ ឬជាតិខាងមុខ។ រីឯការធ្វើអំពើអាក្រក់ តែងតែទទួលបាននូវផលអាក្រក់ឬបាបកម្មទាំងនៅក្នុងការរស់នៅជាក់ស្ដែង ទាំងនៅក្នុងអក្សរសិល្ប៍ ព្រមទាំងនៅក្នុងព្រះពុទ្ធសាសនាមិនថាជាតិនេះ ឬជាតិខាងមុខ។

យោងតាមការបកស្រាយបំភ្លឺខាងលើទ្រឹស្ដីពុទ្ធសាសនាមួយឃ្លានេះពិតជាមានអត្ថន័យអប់រំជ្រាលជ្រៅ សម្រាប់អប់រំទូន្មានកូនចៅខ្មែរយើងគ្រប់រូបឱ្យបានយល់ដឹងពីលទ្ធផលនៃការធ្វើអំពើល្អនិងលទ្ធផលនៃការធ្វើអំពើអាក្រក់។ ដូច្នេះក្នុងនាមជាសិស្សានុសិស្ស ត្រូវខិតខំព្យាយាមរៀនសូត្រនិងសិក្សាស្រាវជ្រាវបន្ថែមទៀត ដើម្បីស្វែងយល់ឱ្យបានទូលំទូលាយអំពីសុភាសិតខ្មែរ ក៏ដូចជាដំបូន្មានផ្សេងៗទៀត។ ក្នុងនោះដែរយើងខ្ញុំប្ដេជ្ញាថា នឹងប្រព្រឹត្តតែអំពើល្អជានិច្ច។

**ប្រធានទី៧** : សុភាសិតមួយលើកឡើងថា "ដឹងឆ្វើយត្បិតដង កូនឆ្គងព្រោះមេបា"។ ចូរពន្យល់សុភាសិតឱ្យបានក្បោះក្បាយដោយលើកឧទាហរណ៍បញ្ជាក់ផង។

## គម្រោងតែង

**ក- សេចក្តីផ្តើម**

- **លំនាំបញ្ហា**: និយាយទូទៅទាក់ទងនឹងគោលបំណងនៃសុភាសិតនេះ...ដឹងឆ្វើយ...ការចិញ្ចឹមកូន...
- **ចំណូលបញ្ហា(បង្ហាញបញ្ហា)**: ការលើកយកប្រធានមកបង្ហាញ...ដឹងឆ្វើយត្បិតដង កូនឆ្គងព្រោះមេបា...
- **ចំណោទបញ្ហា**: ការចោទសួរទៅលើប្រធាន...តើសុភាសិតនេះមានអត្ថន័យដូចម្តេច...។

**ខ- តួសេចក្តី**

- **ឃ្លាភ្ជាប់សេចក្តី**: ដើម្បីជាជំនួយដល់ការបកស្រាយ គប្បីយល់នូវន័យនៃពាក្យគន្លឹះជាមុនសិន... ។
- **ពន្យល់ពាក្យគន្លឹះ៖**
  - ✓ ដឹង: ...មានន័យថា ជាឧបករណ៍មានលក្ខណៈប្រើប្រាស់ស្រដៀងនឹងពូថៅដែរ គេប្រើប្រាស់ដឹងសម្រាប់កាប់ក្របៃលឈើ...
  - ✓ ឆ្វើយ: ...មានន័យថា ដែលងើយឆ្គង ដែលឆ្វេងឥតសណ្តាប់ ឥតសម ឥតបែបបទ...
  - ✓ មេបា: ...ម៉ែឪ អាណាព្យាបាល អ្នកគ្រប់គ្រងចិញ្ចឹម ថែរក្សា ទូន្មានប្រៀនប្រដៅកូនចៅ...។
- **ពន្យល់ន័យប្រធាន**: ដូច្នេះសុភាសិតខាងលើមានន័យថា ដឹងបើកាលណាយើងដាក់ដងមិនត្រូវឃុំវាទេ នោះវានឹងងើយឡើង ឆ្គង មិនសម ... រីឯកូនវិញ កាលណាម៉ែឪ ឬអាណាព្យាបាលអប់រំទូន្មានប្រៀនប្រដៅមិនបានល្អ...។
- **បកស្រាយប្រធាន៖**
  - ✓ ដឹងឆ្វើយត្បិតដង...ជាទូទៅឧបករណ៍ដឹងធ្វើឡើងដោយមានផ្លែ និងដងជាដើម។ ឧបករណ៍នេះបើកាលយើងដាក់ដងមិនត្រូវឃុំវាទេ វានឹងងើយឡើង មើលទៅមិនសមមិនស្អាត...
  - ✓ កូនឆ្គងព្រោះឪពុកម្តាយ...កំហុសនេះ ពុំមែនជាកំហុសរបស់កុមារ ឬយុវជនទាំងស្រុងនោះទេ។ ប៉ុន្តែគេត្រូវបន្ទោសទៅលើអ្នកទទួលខុសត្រូវមានម៉ែឪ ឬអាណាព្យាបាល...
  - ✓ ឧទាហរណ៍ក្នុងសង្គមជាក់ស្តែង...យ៉ាងណាមិញនៅក្នុងសង្គមគេតែងតែជួបប្រទះឃើញកុមារ និងយុវជនមួយចំនួនតូចជាសិស្សានុសិស្ស មានអាកប្បកិរិយាខិលខូច ខ្ជិលច្រអូស គេចវេះពីសាលារៀន ក្លាយជាក្មេងទំនើងព្រហើនកោងកាច...
  - ✓ ឧទាហរណ៍ក្នុងស្នាដៃអក្សរសិល្ប៍... រឿងចាបពូក និងចាបដង្កូវរបស់លោកសុត្តន្តប្រីជាឥន្ទវិញ បានបញ្ជាក់ប្រាប់យើងឱ្យដឹងថា ចាបដង្កូវដែលជាអ្នកបង្កទំនាស់រករឿងរកហេតុជាមួយចាបពូក គឺបណ្តាលមកពីក្រុមចាបនេះ មេបាមិនបានប្រដៅ...។
- **សរុបសេចក្តី**: បើដឹងឆ្វើយឆ្គង មិនសម គឺដោយសារការដាក់ដងមិនបានត្រឹមត្រូវល្អ...។ បើកូនមានការខុសឆ្គងដោយប្រការណាមួយ គឺដោយសារ ឪពុកម្តាយ មិនបានអប់រំទូន្មានប្រៀនប្រដៅកូនឱ្យបានល្អ...។

## គ- សេចក្តីបញ្ចប់

- **វាយតម្លៃប្រធាន**: យោងតាមការបកស្រាយខាងលើឃើញថា សុភាសិតខាងលើមានអត្ថន័យល្អណាស់សម្រាប់ជាគំនិតអប់រំកូនខ្មែរគ្រប់រូប ឱ្យប្រកាន់ឬកពាល្អ ខិតខំកសាងខ្លួនពិសេសស្ដាប់តាមដំបូន្មានឪពុកម្ដាយ ព្រមទាំងជាដំបូន្មាដ៏ល្អសម្រាប់ឪពុកម្ដាយ...
- **យោបល់ផ្ទាល់ខ្លួន**: ដូច្នេះកុលបុត្រកុលធីតាគ្រប់រូប ត្រូវខិតខំរៀនសូត្រយកគំរូល្អៗពីឪពុកម្ដាយ ពីគ្រូ ពីកូនដែលល្អៗ ដើម្បីឱ្យអនាគតខ្លួនប្រកបដោយភាពភ្លឺស្វាង...។

## សេចក្តីអធិប្បាយ

គ្រួសារនីមួយៗតែងមានឪពុកម្ដាយ និងកូនដែលប្រៀបដូចជាមនុស្សតែម្នាក់ ពីព្រោះថាបើកូនខុសគេបន្ទោសឪពុកម្ដាយតែបើកូនធ្វើត្រូវល្អវិញគេក៏សរសើរឪពុកម្ដាយដែរ។ ហេតុនេះហើយបានជាមានសុភាសិតខ្មែរមួយលើកឡើងថា"ដឹងឆ្វើយត្បិតដង កូនឆ្គងព្រោះមេបា"។

តើសុភាសិតនេះមានអត្ថន័យយ៉ាងដូចម្ដេចខ្លះ?

ដើម្បីជាជំនួយដល់ការបកស្រាយសុភាសិតខាងលើឱ្យបានស៊ីជម្រៅ យើងគប្បីយល់នូវអត្ថន័យនៃពាក្យគន្លឹះរបស់ប្រធានជាមុនសិនគឺពាក្យ "ដឹង ឆ្វើយ មេបា"។ ពាក្យ "ដឹង" មានន័យថា ជាឧបករណ៍មានលក្ខណៈប្រើប្រាស់ស្រដៀងនឹងពូថៅដែរ គេប្រើប្រាស់ដឹងសម្រាប់កាប់ក្របែលឈើ។ ពាក្យ "ឆ្វើយ" មានន័យថា ដែលងើយឆ្គង ដែលឆ្វេងឥតសណ្ដាប់ ឥតសម ឥតបែបបទ។ ចំណែកពាក្យ "មេបា" មានន័យថា ម៉ែឪ អាណាព្យាបាល អ្នកគ្រប់គ្រងចិញ្ចឹម ថែរក្សា ទូន្មានប្រៀនប្រដៅកូនចៅ។ ដូច្នេះសុភាសិតខាងលើមានន័យថា ដឹងបើកាលណាយើងដាក់ដងមិនត្រូវង៉ាំវាទេ នោះវានឹងងើយឡើង ឆ្គងមិនសម នាំឱ្យយើងប្រើប្រាស់មិនស្រួល ឬប្រើការមិនកើតតែម្ដង។ រីឯកូនវិញ កាលណាម៉ែឪ ឬអាណាព្យាបាលអប់រំទូន្មានប្រៀនប្រដៅមិនបានល្អ ឬក៏ម៉ែឪ ឬអាណាព្យាបាល មិនបានអប់រំទូន្មានប្រៀនប្រដៅមិនបានទេនោះ កូននោះនឹងមានកំហុសឆ្គង មានឥរិយាបថមិនសមរម្យ មិនទន់ភ្លន់ សុភាពរាបសាមិនប្រព្រឹត្តអំពើល្អជាដើម។

ជាការពិតណាស់ហើយដែលសុភាសិតខាងលើលើកឡើង ដឹងឆ្វើយត្បិតដង ព្រោះថាជាទូទៅឧបករណ៍ដឹងធ្វើឡើងដោយមានផ្លែ និងដងជាដើម។ ឧបករណ៍នេះបើកាលយើងដាក់ដងមិនត្រូវង៉ាំវាទេវានឹងងើយឡើង មើលទៅមិនសមមិនស្អាតជាដើម។ ដឹងបែបនេះពិបាកប្រើប្រាស់ កាប់ចាំងឈើមិនស្រួល និងជួនកាលមិនអាចប្រើការបានតែម្ដង។ នេះដោយសារតែដងដឹងមិនល្អ ឬការបញ្ចូលដងមិនបានណែនមាំល្អ ធ្វើឱ្យដឹងប្រើការមិនកើតហើយក្លាយជារបស់គ្មានតម្លៃទៅវិញ។

កូនឆ្គងព្រោះមេបា មានន័យថា រាល់កំហុសឆ្គងទាំងឡាយ ពុំមែនជាកំហុសរបស់កុមារ ឬយុវជនទាំងស្រុងនោះទេ។ ប៉ុន្តែគេត្រូវបន្ទោសទៅលើអ្នកទទួលខុសត្រូវមានម៉ែឪ ឬអាណាព្យាបាលរបស់កុមារ និងយុវជនទាំងនោះផងដែរ។ ភាពខ្វះខាតនូវសីលធម៌នេះ បណ្ដាលមកពីភាពធូររលុងរបស់អ្នកទទួលខុសត្រូវមានម៉ែឪឬអាណាព្យាបាលជាដើម មិនបានអប់រំ ទូន្មាន ប្រៀនប្រដៅកូនឱ្យបានល្អ។ ពេលខ្លះកូនចៅប្រព្រឹត្តឆ្គង មិនសមរម្យ ដោយសារម៉ែឪ ឬអាណាព្យាបាល ពុំបានពន្យល់ប្រាប់ពីកំហុសរបស់គេឱ្យបានយល់ដឹងច្បាស់ នាំឱ្យគេយល់ច្រលំថា អំពើដែលគេធ្វើនេះជាការត្រឹមត្រូវទៅវិញ។ ការប្រព្រឹត្តឆ្គាំឆ្គងយូរៗទៅហើយគ្មានអ្នកណាជួយណែនាំ ក៏ក្លាយជាទម្លាប់កែលែងកើត។ ជាតួយ៉ាងនៅក្នុងសង្គម គេតែងតែជួបប្រទះឃើញកុមារនិងយុវជនមួយចំនួនតូចជាសិស្សានុសិស្ស

ប្រកាន់អាកប្បកិរិយាខិលខូច ខ្ជិលច្រអូស គេចវេះពីសាលារៀន ក្លាយជាក្មេងទំនើងព្រហើនកោងកាច។ បើពិនិត្យក្នុងអត្ថបទ រឿងកុលាបប៉ៃលិនរបស់អ្នកនិពន្ធ ញ៉ុក ថែម ថាអាកប្បកិរិយាឆ្មើងឆ្មៃរបស់នាងយុននារី បានឆ្លុះបញ្ចាំងឱ្យឃើញពីការមិនយកចិត្តទុកដាក់អប់រំកូនរបស់លោកហ្លួងរតនសម្បត្តិដែលជាឪពុក។ នេះមកពីគាត់ជាប់រវល់នឹងមុខរបរលក់ត្បូង ហើយថែមទាំងមានកូនស្រីតែមួយទៀតនោះ នាំឱ្យគាត់ទំយើកូនរហូតធ្វើឱ្យយុននារីក្លាយជាមនុស្សឆ្មើងឆ្មៃ ហ៊ាននិយាយមើលងាយថៅចិត្រ។ ចំណែកឯរឿងចាបពូក និងចាបដង្កូវរបស់ឧកញ៉ាសុត្តន្តប្រីជាឥន្ទវិញ បានបញ្ជាក់ ដឹងថា ចាបដង្កូវដែលជាអ្នកបង្កទំនាស់រករឿងរកហេតុជាមួយចាបពូក គឺបណ្តាលមកពីក្រុមចាបនេះ មេបាមិនបានប្រដៅ។

រួមសេចក្តីមក បើដឹងឆ្លើយឆ្លង មិនសម គឺដោយសារការដាក់ដងមិនបានត្រឹមត្រូវល្អ ហើយគេប្រាកដជាបន្ទោសទៅលើដងហើយ។ បើកូនមានការខុសឆ្គងដោយប្រការណាមួយ គឺដោយសារឪពុកម្តាយ ឬអ្នកអាណាព្យាបាល មិនបានអប់រំ ទូន្មាន ប្រៀនប្រដៅកូនឱ្យបានល្អ ហើយគេនឹងបន្ទោសអ្នកទទួលខុសត្រូវមានឪពុកម្តាយ ឬអាណាព្យាបាលជាដើមនោះ ខ្លាំងជាងគេជាក់ជាមិនខាន។

យោងតាមការបកស្រាយខាងលើឃើញថា សុភាសិតខាងលើមានអត្ថន័យល្អប្រសើរណាស់សម្រាប់ជាគំនិតជួយអប់រំកូនខ្មែរគ្រប់រូបឱ្យប្រកាន់ឫកពាល្អ ឱ្យខិតខំកសាងខ្លួនពិសេសស្តាប់តាមដំបូន្មានឪពុកម្តាយ ព្រមទាំងជាដំបូន្មានដ៏ល្អសម្រាប់ឪពុកម្តាយ ឬអាណាព្យាបាលយកចិត្តទុកដាក់ក្នុងការអប់រំកូនជាប្រចាំតាំងពីតូចរហូតដល់ធំ។ ដូច្នេះកុលបុត្រកុលធីតាគ្រប់រូប ត្រូវខិតខំរៀនសូត្រយកគំរូល្អៗពីឪពុកម្តាយ ពីគ្រូ ពីកូនដែលល្អៗ ដើម្បីឱ្យអនាគតខ្លួនប្រកបដោយភាពភ្លឺស្វាង។

## ១៤.៥- ប្រធានតែងសេចក្តីបែបអត្ថាធិប្បាយពន្យល់អក្សរសិល្ប៍

**ប្រធានទី១:** ពំនោលមួយពោលថា "ភាពជោគជ័យក្នុងជីវិតរបស់តួអង្គថៅចិត្រ កើតឡើងពីសមត្ថភាពផ្ទាល់ខ្លួន"។ ចូរបកស្រាយពំនោលខាងលើនេះឱ្យបានក្បោះក្បាយ ដោយលើកឧទាហរណ៍ក្នុងរឿងកុលាបប៉ៃលិនមកបញ្ជាក់ផង។

### គម្រោងតែង

**ក- សេចក្តីផ្តើម**

- **លំនាំបញ្ហា:** និយាយទូទៅទាក់ទងនឹងស្នាដៃអក្សរសិល្ប៍ខ្មែរ រឿងកុលាបប៉ៃលិន សមត្ថភាពរបស់តួអង្គថៅចិត្រ...
- **ចំណូលបញ្ហា(បង្ហាញបញ្ហា):** ហេតុដូចនេះបានជាមានពំនោលមួយពោលថា "ជោគជ័យក្នុងជីវិតរបស់តួអង្គថៅចិត្រកើតឡើងពីសមត្ថភាពផ្ទាល់ខ្លួន"។
- **ចំណោទបញ្ហា:** ...តើពំនោលខាងលើ មានខ្លឹមសារយ៉ាងណា?

**ខ- តួសេចក្តី**

- **ឃ្លាភ្ជាប់សេចក្តី:** មុននឹងបកស្រាយប្រធាន យើងគួរយល់ន័យពាក្យមួយចំនួនជាមុនសិន...។
- **ពន្យល់ពាក្យគន្លឹះ៖**
  - ✓ ជោគជ័យ: ...សេចក្តីសមប្រកប ភាពឈ្នះ ជ័យជម្នះ សេចក្តីសុខ...

✓ សមត្ថភាព: ... ភាពដែលអាចធ្វើបាន ការចេះដឹង សេចក្តីហានសេចក្តីមោះមុត... ។

- **ពន្យល់ន័យប្រធាន**: ...សេចក្តីសុខ សេចក្តីសមប្រកប ជ័យជម្នះ ក្នុងជីវិតរបស់តួអង្គចៅចិត្រ កើតឡើងពីភាពដែលចៅចិត្តអាចធ្វើបាន ការចេះដឹង សេចក្តីមោះមុតផ្ទាល់ខ្លួន...។
- **បកស្រាយប្រធាន**: តួអង្គចៅចិត្រក្នុងរឿងកុលាបប៉ៃលិន ទទួលបាននូវសុភមង្គលដោយសារសមត្ថភាពផ្ទាល់ខ្លួនដូចតទៅ៖

✓ សមត្ថភាពផ្នែកប្រាជ្ញា៖

✓ ចំណេះវិជ្ជា: ជាអ្នកបានរៀនសូត្រចេះដឹង មានប្រកាសនីយបត្រ ...

✓ បំណិនជីវិត៖

✓ បើកបររថយន្ត ជួសជុលរថយន្ត ...

✓ ឆ្នៃប្រឌិត ដោះស្រាយបញ្ហា(រកឆ្នាំង ដាំបាយ ស្ល...)

✓ គ្រប់គ្រងកម្មករ កាន់បញ្ជីត្បូង...

✓ ចេះប្រើកាំភ្លើងបាញ់តទល់ជាមួយចោរ ...

✓ សមត្ថភាពផ្លូវកាយ៖

✓ មានកម្លាំងមាំមួន មានសុខភាពល្អ(ធ្វើកម្មករជីកត្បូង ...)

✓ ប្រយុទ្ធជាមួយចោរ ក្រុមបាឡាត់ស្រុក ...

✓ សមត្ថភាពផ្លូវចិត្ត៖

✓ តស៊ូ អំណត់ ព្យាយាម(ខិតខំប្រឹងជីកត្បូង ជម្នះគ្រប់ការលំបាក ...)

✓ ស្មោះត្រង់ ភក្តីភាព (គ្មានគំនិតទុច្ចរិត ស្មោះត្រង់ចំពោះយុននារី...)

✓ ក្លាហាន ទទួលខុសត្រូវ(ប្រយុទ្ធជាមួយចោរ ...)

- **សរុប**:... ភាពជោគជ័យនិងសុភមង្គលរបស់តួអង្គចៅចិត្រពិតជាទទួលបានមកដោយពឹងលើសមត្ថភាពផ្ទាល់ខ្លួនផ្នែកចំណេះដឹង ប្រាជ្ញាស្មារតី ចំណេះដឹងជំនាញ អត្តចរិតល្អ និងមានសីលធម៌ល្អ... ។

### គ- សេចក្តីបញ្ចប់

- **វាយតម្លៃប្រធាន**: ប្រធានដែលពោលមកខាងលើនេះ ពិតជាមានគុណតម្លៃល្អប្រពៃ សម្រាប់អប់រំមនុស្សទូទៅឱ្យជឿជាក់លើកម្លាំង និងសមត្ថភាពផ្ទាល់ខ្លួន...
- **យោបល់ផ្ទាល់ខ្លួន**: ដូច្នេះយើងជាសិស្សានុសិស្ស ត្រូវខិតខំសិក្សារៀនសូត្រយកចំណេះដឹង ដើម្បីធ្វើឱ្យជីវិតមានប្រយោជន៍ សម្រាប់ខ្លួនឯង គ្រួសារ និងសង្គមជាតិ...។

## សេចក្តីអធិប្បាយ

តាមរយៈវណ្ណកម្មរឿងកុលាបប៉ៃលិនរបស់អ្នកនិពន្ធ ញ៉ុក ថែម បានបង្ហាញពីដំណើរជីវិតរបស់តួអង្គចៅចិត្រ ដែលបានផ្លាស់ប្តូរវាសនារបស់ខ្លួនពីភាពគោកយ៉ាកខ្វះទីពំនឹងក្លាយជាមនុស្សដែលទទួលបាននូវសុភមង្គលក្នុងជីវិត។ ហេតុដូច្នេះហើយបានជាមានពំនោលមួយពោលថា "ភាពជោគជ័យក្នុងជីវិតរបស់តួអង្គចៅចិត្រ កើតឡើងពីសមត្ថភាពផ្ទាល់ខ្លួន"។

តើចៅចិត្រមានសមត្ថភាពដូចម្តេចខ្លះ ទើបទទួលបាននូវភាពជោគជ័យក្នុងជីវិតយ៉ាងដូច្នេះ?

មុននឹងឈានចូលដល់ការបកស្រាយប្រធានខាងលើឱ្យបានក្បោះក្បាយ យើងគួរយល់នូវអត្ថន័យនៃពាក្យគន្លឹះមួយចំនួនជាមុនសិនដូចជាពាក្យ "ភាពជោគជ័យ សមត្ថភាព"។ ពាក្យ ភាពជោគ

ជ័យមានន័យថា សេចក្ដីសមប្រកប ភាពឈ្នះ ជ័យជម្នះ សេចក្ដីសុខ។ ចំណែកឯពាក្យសមត្ថភាព មានន័យថាភាពដែលអាចធ្វើបាន ការចេះដឹង សេចក្ដីក្លាហាន សេចក្ដីមោះមុត។ ដូច្នេះប្រធាននេះមានន័យថា សេចក្ដីសុខ ការទទួលជ័យជម្នះក្នុងជីវិតរបស់តួអង្គថៅចិត្រកើតឡើងពីការចេះដឹង សេចក្ដីមោះមុតផ្ទាល់ខ្លួន។

ជាការពិតណាស់ តួអង្គថៅចិត្រក្នុងរឿងកុលាបប៉ៃលិនទទួលបានសុភមង្គលដោយសារសមត្ថភាពផ្ទាល់របស់គេពិតប្រាកដដូចជាសមត្ថភាពផ្នែកប្រាជ្ញាស្មារតី ព្រោះថៅចិត្រជាអ្នកមានចំណេះវិជ្ជា បានសិក្សារៀនសូត្រចេះដឹងដោយទទួលបានប្រកាសនីយបត្រ។ លើសពីចំណេះដឹងនេះថៅចិត្រនៅមានជំនាញ ឬបំណិនជីវិតជាច្រើនថែមទៀតដូចជា នៅពេលដែលតាសុនជាអ្នកបើកបររថយន្តមានធុរៈថៅចិត្រអាចបើករថយន្តជូនថៅហ្វាយមកបាត់ដំបងជំនួសតាសុនបាន។ ពេលរថយន្តខូចកណ្ដាលផ្លូវ ថៅចិត្រអាចជួសជុលរថយន្ត រកមធ្យោបាយច្នៃប្រឌិតក្នុងការដាំស្លនៅពេលដែលគ្មានឆ្នាំង។ ថៅចិត្រមានជំនាញអាចបាញ់កាំភ្លើងតទល់ជាមួយចោរ ពេលមានឧបទ្ទវហេតុ ចោរប្លន់នៅកណ្ដាលផ្លូវ។ លើសពីនេះទៅទៀត ថៅចិត្រមានបំណិនផ្នែកកាន់ការបញ្ជីត្បូង និងគ្រប់គ្រងកម្មករជំនួសហ្លួងរតនសម្បត្តិបានទៀតផង។

ដោយឡែកសមត្ថភាពខាងផ្លូវកាយ ថៅចិត្រក៏មិនចាញ់កម្មករត្បូងជើងចាស់ឯទៀតដែរ ដូចសម្ដីថៅចិត្រឆ្លើយតបនឹងការមាក់ងាយរបស់យុវនារីៈ "...មនុស្សស្គម មិនប្រាកដថាគ្មានកម្លាំងឯណា... មនុស្សស្គមយ៉ាងខ្ញុំនេះ មានកម្លាំងគ្រប់គ្រាន់..."។ ជាក់ស្ដែងថៅចិត្រមានកម្លាំងអាចប្រយុទ្ធជាមួយចោរនិងបក្សពួករបស់បាឡាត់ស្រុកជាដើម។

ក្រៅពីចំណេះដឹងនិងបំណិន ថៅចិត្រក៏ជាយុវជនមួយរូបដែលមានអត្តចរិតល្អ មានចិត្តអំណត់ព្យាយាមតស៊ូជម្នះឧបសគ្គគ្រប់បែបយ៉ាង មិនរើសអើង ស្រឡាញ់ការងារ ពិសេសការងារជីកត្បូងនេះឯង។ ថៅចិត្រជាមនុស្សមានសីធម៌ល្អមាន ភាពស្មោះត្រង់ មានភក្ដីភាពចំពោះថៅហ្វាយនាយ និងអ្នកដែលខ្លួនស្រឡាញ់ គឺយុវនារីមានចិត្តក្លាហាន និងការទទួលខុសត្រូវ។ គុណសម្បត្តិកើតឡើងពីការខិតខំរបស់ថៅចិត្រ ទើបហ្លួងរតនសម្បត្តិទទួលយកថៅចិត្រធ្វើជាកូនប្រសានិងផ្ទេរការងារគ្រប់គ្រងបញ្ជីត្បូងជំនួសលោក ទទួលបាននូវសុភមង្គលដ៏ត្រចះត្រចង់ក្នុងជីវិត។

សរុបសេចក្ដីមក ភាពជោគជ័យនិងសុភមង្គលរបស់តួអង្គថៅចិត្រពិតជាទទួលបានមកពឹងលើសមត្ថភាពផ្ទាល់ខ្លួនផ្នែកចំណេះដឹង ប្រាជ្ញាស្មារតី ចំណេះដឹងជំនាញ អត្តចរិតល្អ និងមានសីលធម៌ល្អយ៉ាងពិតប្រាកដមែន។

ប្រធានដែលពោលមកខាងលើនេះ ពិតជាមានគុណតម្លៃល្អប្រពៃ សម្រាប់អប់រំមនុស្សទូទៅឱ្យជឿជាក់លើកម្លាំងនិងសមត្ថភាពផ្ទាល់ខ្លួន មិនត្រូវពឹងផ្អែកតែលើអ្នកដទៃឬកម្លាំងក្រៅខ្លួនឡើយ។ ដូច្នេះយើងជាសិស្សានុសិស្ស ត្រូវខិតខំសិក្សារៀនសូត្រយកចំណេះដឹង ដើម្បីធ្វើឱ្យជីវិតមានប្រយោជន៍ សម្រាប់ខ្លួនឯង គ្រួសារ និងសង្គមជាតិ។

**ប្រធានទី២:** ក្នុងស្នាដៃអក្សរសិល្ប៍រឿងផ្កាស្រពោនបានបង្ហាញឱ្យឃើញពី «សេចក្តីអន្តរាយបណ្តាលមកពីជំនឿមិនសមហេតុផល»។ ចូរធ្វើការបកស្រាយបង្ហាញឱ្យបានក្បោះក្បាយ។

## គម្រោងតែង

### ក- សេចក្តីផ្តើម

- **លំនាំបញ្ហា:** និយាយទូទៅទាក់ទងទៅនឹងស្នាដៃអក្សរសិល្ប៍ខ្មែរ និងបញ្ហាជំនឿនៅក្នុងរឿងផ្កាស្រពោន...
- **ចំណូលបញ្ហា(បង្ហាញបញ្ហា):** ដូច្នេះហើយទើបមានប្រធានមួយលើកឡើងថា... ភាពអន្តរាយ បណ្តាលមកពីជំនឿមិនសមហេតុផល...
- **ចំណោទបញ្ហា:** ...តើជំនឿមិនសមហេតុផលបែបណាខ្លះ ដែលនាំឱ្យមានសេចក្តីអន្តរាយ?

### ខ- តួសេចក្តី

- **ឃ្លាភ្ជាប់សេចក្តី:** ដើម្បីងាយស្រួលក្នុងការបកស្រាយប្រធានលើឱ្យបានក្បោះក្បាយ យើងគប្បីស្គាល់នូវន័យនៃពាក្យគន្លឹះមួយចំនួនសិន...
- **ពន្យល់ពាក្យគន្លឹះ៖**
  - ✓ សេចក្តីអន្តរាយ: គឺសំដៅលើការវិនាស ការបាត់បង់ ការខូចខាត...
  - ✓ ជំនឿមិនសមហេតុផល: គឺជាការជឿជាក់លើអ្វីមួយដោយមិនមានឆ្លងកាត់ការគិតពិចារណាត្រឹមត្រូវ មិនមានកើតឡើងច្បាស់លាស់ មើលមិនឃើញ មានលក្ខណៈអរូបីយ៍ មិនអាចឈ្វេងយល់ដឹងបាន គ្មានលក្ខណៈវិទ្យាសាស្ត្រ...។
- **ពន្យល់ន័យប្រធាន:** ដូច្នេះយោងតាមអត្ថន័យនៃពាក្យគន្លឹះ មតិប្រធានបានសេចក្តីថា គឺជាការជឿជាក់លើអ្វីមួយដែលមិនមានឆ្លងកាត់ការគិតពិចារណាត្រឹមត្រូវ មិនមានកើតឡើងច្បាស់លាស់ មើលមិនឃើញ មានលក្ខណៈអរូបីយ៍ មិនអាចឈ្វេងយល់ដឹងបាន គ្មានលក្ខណៈវិទ្យាសាស្ត្រ ជាកត្តានាំឱ្យមានសេចក្តីវិនាសបាត់បង់...។
- **បកស្រាយប្រធាន៖**
  - ✓ ជំនឿមិនសមហេតុផលមាននៅក្នុងសង្គមខ្មែរ...ជំនឿទាំងនោះមានដូចជា ការជឿលើខ្មោចព្រាយបិសាច អារក្សអ្នកតា មន្តអាគម អំពើអាបធ្មប់ជាដើម។ ជំនឿទាំងនេះ បានចាក់ឫសយ៉ាងជ្រៅនៅក្នុងផ្នត់គំនិតខ្មែរយើង។ ប្រជាជនខ្មែរយើងពេលជួបគ្រោះចង្រៃផ្សេងៗមានជំងឺ គ្រោះថ្នាក់កើតឡើងចៃដន្យជាដើម គេតែងអុជធូបបន់ស្រន់ លៀងអារក្ស សូត្រមន្តរំដោះគ្រោះ...
  - ✓ តាមទស្សនៈវិទ្យាសាស្ត្រគេហៅជំនឿបែបនេះថា អបីយ៍ជំនឿដែលគួរចៀសវាង។ អ្នកមានគំនិតជឿនលឿន ចាត់ទុកជំនឿបែបនេះថា ជាជំនឿមិនសមហេតុផល។ ការជឿលើជំនឿបែបនេះ... តែពេលខ្លះថែមទាំងនាំមកនូវសេចក្តីវិនាសធ្ងន់ធ្ងរ...
  - ✓ តាមរយៈដំណើររឿងផ្កាស្រពោន បានឆ្លុះបញ្ចាំងឱ្យឃើញពីជីវភាពសង្គមខ្មែរ ប្រកាន់យកជំនឿមិនសមហេតុផលមួយចំនួនតៗគ្នាមក៖
    - ជឿលើព្រះសង្ឃ(ការស្រោចទឹកមន្ត ប្រស់ព្រំលើអ្នកជំងឺគ្រុនក្តៅ...)
    - ជឿលើការទស្សន៍ទាយគន់គូរ មើលក្រាំង គម្ពីរ...មើលជតារាសី...
    - ជឿលើការសូត្ររំដោះគ្រោះ...

- ជឿលើគ្រូមេមត់...។

- **សរុបសេចក្តី**: ការជឿមិនសមហេតុផលជាកត្តាមួយដែលនាំឱ្យគ្រោះថ្នាក់បំផុត គឺធ្វើឱ្យខាតបង់ពេលវេលា ទ្រព្យសម្បត្តិ បាត់បង់នូវអ្វីៗដែលជាទីស្រឡាញ់របស់ខ្លួន និងឈានទៅជួបគ្រោះថ្នាក់ធំធេង គឺបាត់បង់អាយុជីវិតទៀតផង...។

## គ- សេចក្តីបញ្ចប់

- **វាយតម្លៃប្រធាន**: ...យោងតាមការអធិប្បាយពីខាងលើរួចមក មតិប្រធានបានចូលរួមក្នុងការអប់រំមនុស្សឱ្យយល់ដឹងពីផលវិបាកនៃការជឿដោយគ្មានហេតុផល ពខ្វះការពិចារណា...
- **យោបល់ផ្ទាល់លើខ្លួន**: ដូច្នេះយើងទាំងអស់គ្នាត្រូវខិតខំសិក្សារៀនសូត្រឱ្យបានជ្រៅជ្រះ ដើម្បីបានជាទុនក្នុងការគិត ត្រិះរិះពិចារណាឱ្យបានច្បាស់លាស់មុននឹងធ្វើ ឬជឿជាក់លើអ្វីមួយៗ...។

## សេចក្តីអធិប្បាយ

រឿងផ្កាស្រពោន គឺជាអក្សរសិល្ប៍បែបប្រលោមលោកដែលជាស្នាដៃរបស់អ្នកនិពន្ធ នូ ហាច និពន្ធនៅឆ្នាំមួយពាន់ប្រាំបួនរយសាមសិបប្រាំបួន និងបោះពុម្ពនៅឆ្នាំមួយពាន់ប្រាំបួនរយសែសិបប្រាំពីរបានបង្ហាញឱ្យឃើញនូវបញ្ហា និងផ្នត់គំនិតសំខាន់ៗនៅក្នុងសង្គមខ្មែរជាច្រើន។ អាស្រ័យហេតុនេះហើយបានជាក្រោយពីការសិក្សារឿងនេះរួចយើងសង្កេតឃើញថា"សេចក្តីអន្តរាយបណ្តាលមកពីជំនឿមិនសមហេតុផល"។

តើជំនឿមិនសមហេតុផលបែបណាខ្លះ ដែលនាំឱ្យមានសេចក្តីអន្តរាយ?

ដើម្បីជាប្រទីបក្នុងការអធិប្បាយឱ្យបានក្បោះក្បាយ យើងគប្បីយល់នូវអត្ថន័យនៃពាក្យគន្លឹះមួយចំនួនរបស់ប្រធានជាមុនសិនគឺពាក្យ " សេចក្តីអន្តរាយ ជំនឿមិនសមហេតុផល "។ សេចក្តីអន្តរាយ គឺសំដៅលើការវិនាស ការបាត់បង់ ការខូចខាត។ ចំណែកពាក្យជំនឿមិនសមហេតុផល គឺជាការជឿជាក់លើអ្វីមួយដែលមិនមានឆ្លងកាត់ការគិតពិចារណាត្រឹមត្រូវ មិនមានកើតឡើងច្បាស់លាស់ មើលមិនឃើញមានលក្ខណៈអរូបីយ៍ មិនអាចឈ្វេងយល់ដឹងបាន គ្មានលក្ខណៈវិទ្យាសាស្ត្រជាដើម។ ដូច្នេះយោងតាមអត្ថន័យនៃពាក្យគន្លឹះ មតិប្រធានបានសេចក្តីថា គឺជាការជឿជាក់លើអ្វីមួយដែលមិនមានឆ្លងកាត់ការគិតពិចារណាត្រឹមត្រូវ មិនមានកើតឡើងច្បាស់លាស់ មើលមិនឃើញ មានលក្ខណៈអរូបីយ៍ មិនអាចឈ្វេងយល់ដឹងបាន មិនមានលក្ខណៈវិទ្យាសាស្ត្រ ជាកត្តានាំឱ្យមានសេចក្តីវិនាសបាត់បង់។

ជាទូទៅនៅក្នុងសង្គមខ្មែរ តាំងពីបុរាណរហូតដល់បច្ចុប្បន្ន តែងប្រកាន់ភ្ជាប់នូវជំនឿរបស់ខ្លួនទោះបីជាជំនឿនោះមានលក្ខណៈបែបណាក៏ដោយ។ ជំនឿទាំងនោះមានដូចជា ការជឿលើខ្មោចព្រាយបិសាច អារក្សអ្នកតា មន្តអាគម អំពើអាបធ្មប់ជាដើម។ ជំនឿទាំងនេះ បានចាក់ឫសយ៉ាងជ្រៅនៅក្នុងផ្នត់គំនិតខ្មែរយើង។ យើងសង្កេតឃើញថា ប្រជាជនខ្មែរយើងពេលជួបគ្រោះចង្រៃផ្សេងៗមានជំងឺ គ្រោះថ្នាក់កើតឡើងចៃដន្យជាដើម គេតែងអុជធូបបន់ស្រន់ លៀងអារក្ស សូត្រមន្តរំដោះគ្រោះ រកគ្រូទស្សន៍ទាយ។ល។ ជំនឿបែបនេះ កើតឡើងតាំងពីយូរលង់ណាស់មកហើយ ដែលមនុស្សយើងនៅមានការយល់ដឹងទាប ហើយវិទ្យាសាស្ត្រមិនទាន់មានការរីកចម្រើននៅឡើយ។

តាមទស្សនវិទ្យាសាស្ត្រគេហៅជំនឿបែបនេះថាជាជំនឿដែលគួរចៀសវាង។ ជំនឿមិនសមហេតុផល។ ការជឿលើជំនឿបែបនេះ មិនត្រឹមតែខាតបង់តិចតួចប៉ុណ្ណោះទេតែពេលខ្លះថែមទាំងនាំមកនូវ

សេចក្តីវិនាស ធ្ងន់ធ្ងរទៀតផង។ ដោយសារការជឿសិប់ ខ្លាំងពេក អាចធ្វើឱ្យជួបគ្រោះថ្នាក់ធ្ងន់ធ្ងរ រហូតដល់បាត់បង់ជីវិតមនុស្សថែមទៀតផង។

តាមរយៈដំណើររឿងផ្កាស្រពោន បានឆ្លុះបញ្ចាំងឱ្យឃើញពីជីវភាពសង្គមខ្មែរនាសម័យកាលមួយ ដែលប្រជាជនមិនទាន់យល់ដឹងខ្ពស់ ខ្វះការពិចារណាតាមបែបវិទ្យាសាស្ត្រ ធ្វើឱ្យអ្នកទាំងនោះប្រកាន់យកជំនឿមិនសមហេតុផលមួយចំនួនតៗគ្នាមក។ ដោយសារជំនឿបែបនេះហើយ ទើបធ្វើឱ្យមានការវិនាសបាត់បង់ដូចជាទ្រព្យសម្បត្តិ និងអាយុជីវិតទៀតផង។ ជាក់ស្តែងពេលនាងវិធាវី កំពុងមានជំងឺគ្រុនក្តៅ យាយនួនជាម្តាយបានទៅនិមន្តព្រះសង្ឃ ដើម្បីស្រោចទឹកប្រស់ព្រំលើអ្នកជំងឺក្នុងបំណងឱ្យជាសះស្បើយ។ ប៉ុន្តែបែរជាធ្វើឱ្យនាងវិធាវី កាន់តែមានជំងឺធ្ងន់ធ្ងរជាលំដាប់។ មិនតែប៉ុណ្ណោះនៅពេលដែលឃើញកូនមានជំងឺកាន់តែខ្លាំង យាយនួនបានទៅនិមន្តលោកគ្រូអានឱ្យគន់គូរទស្សន៍ទាយមើលពីជោគជាតារាសី។ក្នុងនោះយាយនួនបានធ្វើពិធីសូត្រមន្តរំដោះគ្រោះ តាមការទស្សន៍ទាយរបស់លោកគ្រូអានថែមទៀត។ លើសពីនេះទៅទៀតយាយនួនបានអញ្ជើញម៉ែអេង ដែលជាគ្រូមេមត់ដើម្បីធ្វើពិធីសែនព្រេន មានទៀន ធូប ចេក អង្ករជាដើម ដើម្បីអន្ទងព្រលឹងក្នុងបំណងឱ្យនាងវិធាវីបានជាសះស្បើយ។ តែផ្ទុយទៅវិញជំងឺនាងកាន់តែដុនដាបទៅៗ ចុងក្រោយនាងវិធាវីទទួលមរណភាពទាំងវ័យនៅក្មេងខ្ចី។ កត្តាខាងលើនេះហើយ ដែលបញ្ជាក់ឱ្យឃើញថា ការជឿមិនសមហេតុផលខ្វះការពិចារណា ខ្វះលក្ខណៈវិទ្យាសាស្ត្រនាំឱ្យមនុស្សជួបនូវទុក្ខ ជួបផលវិបាក ពោលគឺធ្វើឱ្យវិនាសបាត់បង់។

សរុបសេចក្តីមក ការជឿមិនសមហេតុផលជាកត្តាមួយដែលនាំឱ្យគ្រោះថ្នាក់បំផុត គឺធ្វើឱ្យខាតបង់ពេលវេលា ទ្រព្យសម្បត្តិ បាត់បង់នូវអ្វីៗដែលជាទីស្រឡាញ់របស់ខ្លួន និងជួបគ្រោះថ្នាក់ធំធេង គឺបាត់បង់អាយុជីវិតទៀតផង។

យោងតាមការអធិប្បាយពីខាងលើរួចមកយើងអាចសន្និដ្ឋានបានថា មតិប្រធានបានចូលរួមក្នុងការអប់រំមនុស្សឱ្យយល់ដឹងពីផលវិបាកនៃការជឿដោយគ្មានហេតុផល ខ្វះការពិចារណា។ ដូច្នេះយើងទាំងអស់គ្នា ត្រូវខិតខំសិក្សារៀនសូត្រឱ្យបានជ្រៅជ្រះ ដើម្បីបានជាទុនក្នុងការគិត ត្រិះរិះពិចារណាឱ្យបានច្បាស់លាស់មុននឹងធ្វើ ឬជឿជាក់លើអ្វីមួយៗ។

**ប្រធានទី៣** : ពំនោលមួយពោលថា «ការស្រឡាញ់ឧត្តមគតិរបស់តួអង្គទីឃាវុធ គឺជាការលះបង់»។ ចូរបកស្រាយពំនោលខាងលើនេះឱ្យបានក្បោះក្បាយ ដោយលើកឧទាហរណ៍ក្នុងរឿងមាលាដួងចិត្តមកបញ្ជាក់ផង។

## គម្រោងតែង

### ក- សេចក្តីផ្តើម

- **លំនាំបញ្ហា**: និយាយទូទៅទាក់ទងទៅនឹងស្នាដៃអក្សរសិល្ប៍ខ្មែរ... និងបង្ហាញពីគុណសម្បត្តិតួអង្គទីឃាវុធនៅក្នុងរឿងមាលាដួងចិត្ត...
- **ចំណូលបញ្ហា(បង្ហាញបញ្ហា)**: ហេតុដូច្នេះហើយ ទើបមានពំនោលមួយពោលថា... ការស្រឡាញ់ឧត្តមគតិរបស់តួអង្គទីឃាវុធ គឺជាការលះបង់...
- **ចំណោទបញ្ហា**: ...តើពំនោលខាងលើនេះមានខ្លឹមសារយ៉ាងណា...។

**ខ- តួសេចក្ដី**

- **ឃ្លាភ្ជាប់សេចក្ដី**: ដើម្បីងាយស្រួលដល់ការបកស្រាយប្រធានខាងលើឱ្យបានក្បោះក្បាយ យើងគប្បីស្គាល់នូវន័យរបស់ពាក្យគន្លឹះមួយចំនួនជាមុនសិន...។
- **ពន្យល់ពាក្យគន្លឹះ៖**
  - ✓ ឧត្ដមគតិ: មានន័យថា គំនិតល្អ ថ្លៃថ្លា ប្រសើរ ខ្ពង់ខ្ពស់ ឧត្ដុង្គឧត្ដម...
  - ✓ លះបង់: មានន័យថា បូជា ពលី...
- **ពន្យល់ន័យប្រធាន**: ការស្រឡាញ់នូវគំនិតល្អត្រូវហ៊ានពលី បូជាទាំងកម្លាំងកាយចិត្តដើម្បីប្រយោជន៍សម្ហូហភាព និងដើម្បីជាតិ...។
- **បកស្រាយប្រធាន៖**
  - ✓ តួអង្គទីឃាវុធ ជាយុវជនដែលប្រកាន់យកភាពយុត្តិធម៌ ស្រឡាញ់ឧត្ដគតិតាំពីនៅសាលារៀនមកម្ល៉េះ...
  - ✓ លះបង់សេចក្ដីសុខខាងផ្លូវកាយ: មិនគិតពីអាកាសធាតុក្ដៅ រងាក្នុងការដើរត្រួតពិនិត្យប្រមូលពន្ធ...
  - ✓ លះបង់ឋានៈតួនាទី: សុខចិត្តបោះបង់មុខតំណែងផ្ទាល់ខ្លួនពីបាឡាត់ ដើម្បីទាមទារភាពយុត្តិធម៌ឱ្យប៉ូលិស...
  - ✓ មិនលោភលន់នឹងទ្រព្យសម្បត្តិ: មិនព្រមទទួលសំណូកពីថៅកែហុងឈើក្នុងការដេញថ្លៃកាត់ដេរសម្លៀកបំពាក់ប៉ូលិស... សុខចិត្តក្រីក្រ...
  - ✓ ពេលវេលាផ្ទាល់ខ្លួនដើម្បីសម្ហូហភាព...
  - ✓ ហ៊ានប្រឆាំងជាមួយថៅហ្វាយខេត្ត រហូតត្រូវដកតំណែង...
  - ✓ លះបង់អាយុជីវិត: ទីឃាវុធមានឧត្ដមគតិស្នេហាជាតិ ហ៊ានធ្វើពលិកម្មគ្រប់បែបយ៉ាង មិនគិតពេលវេលាផ្ទាល់ខ្លួន ដោយសុខចិត្តស្ម័គ្រខ្លួនធ្វើកងជាទ័ព ដើម្បីប្រយុទ្ធការពារទឹកដី...។
- **សរុប**: តួអង្គទីឃាវុធ ពិតជាតួអង្គស្រឡាញ់ឧត្ដគតិ ជាជនស្នេហាជាតិ ដោយហ៊ានលះបង់នូវអ្វីៗគ្រប់យ៉ាង ដើម្បីសម្ហូហភាព ដើម្បីប្រទេសជាតិប្រាកដមែន...។

**គ- សេចក្ដីបញ្ចប់**

- **វាយតម្លៃប្រធាន**: ពំនោលខាងលើនេះពិតជាមានតម្លៃអប់រំយ៉ាងជ្រាលជ្រៅ សម្រាប់អប់រំមនុស្សគ្រប់រូបឱ្យប្រកាន់យកឧត្ដមគតិល្អ ចេះគិតពីប្រយោជន៍ជាតិ ...
- **យោបល់ផ្ទាល់ខ្លួន**: ដូច្នេះក្នុងនាមយើងជាសិស្សានុសិស្ស ត្រូវខិតខំសិក្សារៀនសូត្រ និងយកគំរូតាមតួអង្គទីឃាវុធ ស្អប់ខ្ពើមអំពើពុករលួយការប្រកាន់បក្សពួកនិយម...។

## សេចក្ដីអធិប្បាយ

តាមរយៈវណ្ណកម្មរឿងមាលាដួងចិត្តរបស់អ្នកនិពន្ធ នូ ហាច បានបង្ហាញឱ្យឃើញពីដំណើរជីវិតតួអង្គទីឃាវុធ ដែលបានប្រកាន់អំពើយុត្តិធម៌ ស្អប់អំពើពុករលួយតាំងពីនៅសាលារៀនមកម្ល៉េះ។ ហេតុដូច្នេះហើយទើបមានពំនោលមួយពោលថា"ការស្រឡាញ់ឧត្ដមគតិរបស់តួអង្គទីឃាវុធ គឺជាការលះបង់"។

តើពំនោលខាងលើនេះ មានខ្លឹមសារយ៉ាងណា?

ដើម្បីងាយស្រួលក្នុងការបកស្រាយប្រធានខាងលើឱ្យបានក្បោះក្បាយ យើងគប្បីយល់នូវន័យរបស់ពាក្យគន្លឹះមួយចំនួនជាមុនសិនគឺពាក្យ "ឧត្តមគតិ លះបង់"។ ពាក្យ ឧត្តមគតិ មានន័យថា គំនិតល្អ ថ្លៃថ្លា ប្រសើរ ខ្ពង់ខ្ពស់ ឧត្តុង្គឧត្តម។ ចំណែកឯពាក្យលះបង់ មានន័យថា បូជា ពលី។ ដូច្នេះប្រធានខាងលើមានន័យថា ការចូលចិត្តប្រកាន់យកនូវគំនិតល្អ ថ្លៃថ្លា ប្រសើរ ខ្ពង់ខ្ពស់ គឺត្រូវហ៊ានបូជាគ្រប់បែបយ៉ាង ទាំងកម្លាំងកាយ កម្លាំងចិត្ត ដើម្បីបម្រើឱ្យប្រយោជន៍សមូហភាព និងប្រទេសជាតិ។

ជាការពិតណាស់តួអង្គទីយារុធ ជាយុវជនមួយរូបដែលបានសម្រេចចិត្តតាំងពីនៅសាលារៀន គឺស្អប់អំពើពុករលួយ អយុត្តិធម៌ និងអាក្រក់គ្រប់បែបយ៉ាង។ ដើម្បីការពារប្រយោជន៍ជាតិ និងយុត្តិធម៌ ទីយារុធហ៊ានលះបង់អ្វីៗគ្រប់យ៉ាងដូចជាសេចក្ដីសុខខាងផ្លូវកាយនិងផ្លូវចិត្ត គឺមិនត្អូញត្អែរពីភាពនឿយហត់និងអាកាសធាតុក្ដៅរងាក្នុងការបំពេញបេសកកម្មដើរត្រួតពន្ធតាមស្រុកនោះទេ។ ម្យ៉ាងទៀតតួអង្គទីយារុធ សុខចិត្តរស់នៅក្នុងជីវភាពខ្វះខាតក្រីក្រ មិនលោភលន់នឹងទ្រព្យសម្បត្តិដែលបានមកពីការស៊ីសំណូកសូកប៉ាន់របស់ថៅកែហុងឈីដោយលក់កិត្តិយសរបស់ខ្លួនឡើយ គឺសុខចិត្តលះបង់តំណែងជាបាឡាត់ខេត្តពោធិ៍សាត់ ចេញមកធ្វើប៉ូលិសធម្មតា ដើម្បីរក្សាភាពយុត្តិធម៌ក្នុងការដេញថ្លៃដេរសម្លៀកបំពាក់ប៉ូលិស។ ជាងនេះទៀត ទីយារុធហ៊ានប្រឆាំងជាមួយចៅហ្វាយខេត្តដែលជំរុញឱ្យខ្លួនព្រមទទួលឱ្យថៅកែហុងឈីដេញថ្លៃដេរសម្លៀកបំពាក់ឱ្យប៉ូលិស ដោយសារសាច់កំណាត់ផុយអន់ៗ។ ទន្ទឹមនឹងនេះដែរទីយារុធមានឧត្តមគតិស្នេហាជាតិ ហ៊ានធ្វើពលិកម្មគ្រប់បែបយ៉ាង មិនគិតពេលវេលាផ្ទាល់ខ្លួន ដោយសុខចិត្តស្ម័គ្រខ្លួនធ្វើកងជាទ័ព ដើម្បីប្រយុទ្ធការពារទឹកដីប្រទេសកម្ពុជាយើងពីការឈ្លានពានរបស់ពួកសៀម និងជួយឱ្យប្រជាជនខ្មែររស់នៅក្នុងសុខសន្តិភាព។

រួមសេចក្ដីមក ទីយារុធ ពិតជាតួអង្គស្រឡាញ់ឧត្តមគតិ ជាជនស្នេហាជាតិ ដោយហ៊ានលះបង់នូវអ្វីៗគ្រប់យ៉ាង ដើម្បីសមូហភាព ដើម្បីប្រទេសជាតិប្រាកដមែន។

ពំនោលខាងលើនេះពិតជាមានតម្លៃអប់រំយ៉ាងជ្រាលជ្រៅ សម្រាប់អប់រំមនុស្សគ្រប់រូបឱ្យប្រកាន់យកឧត្តមគតិល្អ ចេះគិតពីប្រយោជន៍ជាតិ មិនគិតពីប្រយោជន៍ផ្ទាល់ខ្លួន។ ក្នុងនាមយើងជាសិស្សានុសិស្ស ត្រូវខិតខំសិក្សារៀនសូត្រ និងយកគំរូតាមទីយារុធ ស្អប់ខ្ពើមអំពើពុករលួយ និងការប្រកាន់បក្សពួកនិយម ដែលជាប្រភពបំផ្លាញប្រទេសជាតិ។

---

**ប្រធានទី៤:** ទស្សនៈមួយបានលើកឡើងថា «ធនញ្ជ័យជាតួអង្គដែលមានឧត្តមគតិស្នេហាជាតិ»។ ចូរបកស្រាយទស្សនៈខាងលើឱ្យបានក្បោះក្បាយ។

---

## គម្រោងតែង

### ក- សេចក្ដីផ្ដើម

- **លំនាំបញ្ហា:** និយាយទូទៅទាក់ទងទៅនឹងស្នាដៃអក្សរសិល្ប៍ខ្មែរ... និងបង្ហាញពីគុណសម្បត្តិរបស់តួអង្គធនញ្ជ័យ...
- **ចំណូលបញ្ហា(បង្ហាញបញ្ហា):** ហេតុនេះទើបមានទស្សនៈមួយលើកឡើងថា...ធនញ្ជ័យជាតួអង្គដែលមានឧត្តមគតិស្នេហាជាតិ...
- **ចំណោទបញ្ហា:** ...តើប្រធានខាងលើមានអត្ថន័យដូចម្ដេចខ្លះ...។

**ខ- តួសេចក្តី**

- **ឃ្លាភ្ជាប់សេចក្តី** : មុននឹងឈានចូលដល់ការបកស្រាយប្រធាន យើងគប្បីយល់ន័យនៃពាក្យមួយចំនួនជាមុនសិន...។
- **ពន្យល់ពាក្យគន្លឹះ**៖
  - ✓ ឧត្តមគតិ: មានន័យថា គំនិតល្អ ថ្លៃថ្លា ប្រសើរ ខ្ពង់ខ្ពស់ ឧត្តុង្គឧត្តម...
  - ✓ ស្នេហាជាតិ: ស្រឡាញ់ជាតិ....ហ៊ានលះបង់គ្រប់យ៉ាងដើម្បីជាតិ...។
- **ពន្យល់ន័យប្រធាន**: តាមន័យនេះប្រធានខាងលើមានន័យថា ធនញ្ជ័យជាតួអង្គដែលមានគំនិតខ្ពង់ខ្ពស់ ល្អប្រសើរ ស្រឡាញ់ប្រជាជន និងប្រទេសជាតិ ដោយហ៊ានលះបង់...។
- **បកស្រាយប្រធាន**: ធនញ្ជ័យមានឧត្តមគតិស្នេហាជាតិត្រង់៖
  - ✓ ដោះស្រាយប្រស្នាទីមួយជាមួយអ្នកប្រាជ្ញចិន ដោយសុខចិត្តលោតទឹកសម្លាប់ខ្លួន ដើម្បីស្រោចស្រង់ប្រទេសជាតិ...
  - ✓ ចេញមុខមកដោះស្រាយប្រស្នាទីពីរ លះបង់ប្រយោជន៍ផ្ទាល់ខ្លួន ដើម្បីប្រយោជន៍ជាតិ...
  - ✓ ធនញ្ជ័យដៀលស្តេចចិន និងលើកតម្កើងស្តេចខ្មែរ លើកតម្កើងប្រទេសខ្មែរ...
  - ✓ ធនញ្ជ័យផ្តាំស្តេចឱ្យយកចិត្តទុកដាក់ចំពោះសុខទុក្ខរបស់ប្រជាជន និងប្រទេសជាតិ...។
- **សរុប**: គ្រប់សកម្មភាពគឺបានបង្ហាញឱ្យឃើញថា តួអង្គធនញ្ជ័យគឺជាវីរជនស្នេហាជាតិ ដែលបានលះបង់គ្រប់បែបយ៉ាង ដើម្បីអនាគតប្រជាជន និងប្រទេសជាតិ បានគង់វង្ស...។

**គ- សេចក្តីបញ្ចប់**

- **វាយតម្លៃប្រធាន**: ឆ្លងតាមការបកស្រាយខាងលើយើងឃើញថា ប្រធានមានអត្ថន័យយ៉ាងជ្រាលជ្រៅ ស្តែងចេញតាមរយៈតួអង្គធនញ្ជ័យដែលមានឧត្តមគតិស្នេហាជាតិខ្ពង់ខ្ពស់បំផុត ផ្តល់នូវតម្លៃអប់រំ...
- **មតិផ្ទាល់ខ្លួន**: ដូច្នេះក្នុងនាមយើងជាកុលបុត្រកុលធីតាខ្មែរ ត្រូវខិតខំប្រឹងប្រែងរៀនសូត្រឱ្យមានចំណេះដឹងខ្ពស់ ចូលរួមក្នុងកិច្ចការពារ និងកសាងប្រទេសជាតិរបស់ខ្លួន...។

## សេចក្តីអធិប្បាយ

ក្រោយពីបានសិក្សារឿងធនញ្ជ័យដែលជាអក្សរសិល្ប៍ប្រជាប្រិយរបស់ខ្មែរយើងរួចមក យើងសង្កេតឃើញថាដំណើររឿងទាំងមូលបានបង្ហាញពីសកម្មភាពលេចធ្លោរបស់តួអង្គធនញ្ជ័យដែលពោរពេញទៅដោយភាពឈ្លាសវៃ ក្លាហាន និងមានមនសិការស្នេហាជាតិខ្ពស់។ អាស្រ័យហេតុនេះហើយទើបមានទស្សនៈមួយបានលើកឡើងថា «ធនញ្ជ័យជាតួអង្គដែលមានឧត្តគតិស្នេហាជាតិ»។

តើធនញ្ជ័យមានឧត្តគតិស្នេហាជាតិដូចម្តេចខ្លះ?

ដើម្បីជាគុណប្រយោជន៍ក្នុងការបកស្រាយប្រធានខាងលើឱ្យបានក្បោះក្បាយនោះយើងគប្បីយល់នូវអត្ថន័យពាក្យគន្លឹះរបស់ប្រធានមួយចំនួនជាមុនសិនគឺពាក្យ «ឧត្តមគតិ ស្នេហាជាតិ»។ ពាក្យឧត្តមគតិ មានន័យថា គំនិតល្អ ថ្លៃថ្លា ប្រសើរ ខ្ពង់ខ្ពស់ ឧត្តុង្គឧត្តម។ រីឯពាក្យ ស្នេហាជាតិ មានន័យថា ស្រឡាញ់ប្រជាជននិងប្រទេសជាតិ សុខចិត្តលះបង់ប្រយោជន៍ផ្ទាល់ខ្លួនដើម្បីប្រយោជន៍ប្រជាជន និងប្រទេសជាតិ។ ដូច្នេះប្រធានខាងលើមានន័យថា ធនញ្ជ័យជាតួអង្គដែលមានគំនិតខ្ពង់ខ្ពស់ ស្រឡាញ់ប្រជាជន និងប្រទេសជាតិ ដោយហ៊ានលះបង់គ្រប់បែបយ៉ាងដើម្បីប្រទេសជាតិមាតុភូមិ។

ជាការពិតណាស់តាមរយៈសកម្មភាពធនញ្ជ័យយើងឃើញថា ធនញ្ជ័យគឺជាតួអង្គមួយរូបដែលមានមនសិការជាតិខ្ពស់ហ៊ានលះបង់គ្រប់បែបយ៉ាងដើម្បីជាតិមាតុភូមិ រហូតដល់ហ៊ានលះបង់ទាំងអាយុជីវិតទៀតផង។ ប្រស្នាទីមួយ ដែលចិនចោទសួរតម្រូវឱ្យខ្មែរជាអ្នកដោះស្រាយ ដោយមានលក្ខខណ្ឌថា បើទាយមិនត្រូវទេ នគរខ្មែរត្រូវប្រគល់ឱ្យចិនជាអ្នកគ្រប់គ្រង។ ចំពោះបញ្ហានេះ ធនញ្ជ័យបានរិះរកគ្រប់មធ្យោបាយដើម្បីដោះស្រាយប្រស្នាក្នុងន័យការពារទឹកដីរបស់ខ្លួន។ ប្រការដែលគួរឱ្យស្ងើចសរសើរនោះគឺធនញ្ជ័យបានសម្រេចចិត្តយ៉ាងក្លាហានបំផុត ហ៊ានលះបង់អាយុជីវិតខ្លួន ដើម្បីកុំឱ្យប្រទេសជាតិធ្លាក់ក្នុងកណ្តាប់ដៃរបស់ចិនបានរិះរកវិធីដោះស្រាយប្រស្នាចិនរួចការពារប្រទេសឱ្យរួចផុតពីអាណានិគមចិន ហើយត្រូវបានប្រជាជនចាត់ទុកជាអ្នកប្រាជ្ញ។

ការដោះស្រាយប្រស្នាជាលើកទីពីរឃើញថា ធនញ្ជ័យថ្វីបើកំពុងតែជ្រកក្រោមម្លប់ព្រះពុទ្ធសាសនាយ៉ាងសុខសាន្តយ៉ាងណាក្តី ពេលដឹងថាប្រទេសជាតិមានគ្រោះថ្នាក់ ធនញ្ជ័យបានសម្រេចចិត្តលាចាកសិក្ខាបទដើម្បីចេញមុខមកជួយដោះស្រាយប្រស្នាជាមួយអ្នកប្រាជ្ញចិន។ ក្នុងការដោះប្រស្នានេះធនញ្ជ័យបានប្រឹងប្រែងអស់ពីសមត្ថភាព ដោយប្រើប្រាជ្ញារិះរកមធ្យោបាយយ៉ាងណាដើម្បីដណ្តើមជ័យជម្នះជូនជាតិមាតុភូមិ។ ទោះបីត្រូវលះបង់ប្រយោជន៍ផ្ទាល់ខ្លួនធំធេងបែបណាក៏ដោយ ក៏ធនញ្ជ័យមិនសោកស្តាយដែរ សំខាន់ឱ្យតែប្រទេសជាតិមិនធ្លាក់ក្នុងកណ្តាប់ដៃរបស់ប្រទេសចិន នោះ គឺជាបំណងប្រាថ្នាដែលធនញ្ជ័យចង់បាន។ នៅទីបំផុតធញ្ជ័យក៏ដណ្តើមបានជ័យជម្នះជូនជាតិមាតុភូមិជាលើកទីពីរ។

នៅពេលធនញ្ជ័យទៅដល់ស្រុកចិននៅតែនឹកគិតមកដល់ប្រទេសជាតិរបស់ខ្លួនជានិច្ច មិនដែលភ្លេចពីមហិច្ឆតារបស់ប្រទេសចិន មកលើប្រទេសខ្មែរយើងឡើយ។ ដោយសារការស្អប់នូវគំនិតឈ្លានពានរបស់ចិន និងចង់លើកតម្កើងខ្មែរនេះហើយ ទើបធនញ្ជ័យបានដៀលស្តេចចិននៅចំពោះមុខហើយលើកសរសើរស្តេចខ្មែរគឺក្នុងន័យផ្តល់តម្លៃលើកតម្កើងប្រទេសជាតិរបស់ខ្លួនទាំងមូលផងដែរ។ ស្មារតីស្នេហាជាតិរបស់ធនញ្ជ័យតែងតែផ្តល់នូវក្តីស្រឡាញ់ ផ្តល់នូវកិត្តិយសក្នុងការការពារប្រទេសរបស់ខ្លួនជានិច្ច ទោះបីខ្លួនគេស្ថិតនៅទីណាក៏ដោយ។ លើសពីនេះទៅទៀតនៅពេលដែលធ្លាក់ខ្លួនឈឺ ធនញ្ជ័យក៏នៅតែមិនភ្លេចគិតដល់វាសនារបស់ប្រទេសជាតិខ្លួនដែរគឺមុនពេលស្លាប់ ធនញ្ជ័យបានផ្តាំស្តេចនូវបណ្តាំប្រកបដោយអត្ថន័យខ្ពង់ខ្ពស់ក្នុងន័យគិតគូរដល់សុខទុក្ខប្រជារាស្ត្រក៏ដូចប្រទេសជាតិទាំងមូលផងដែរ។

សរុបសេចក្តីមក គ្រប់សកម្មភាពគឺបានបង្ហាញឱ្យឃើញថា តួអង្គធនញ្ជ័យគឺជាវីរជនស្នេហាជាតិដែលបានលះបង់គ្រប់បែបយ៉ាង ដើម្បីអនាគតប្រជាជន និងប្រទេសជាតិ បានគង់វង្ស សុខសាន្ត និងរីកចម្រើនរុងរឿង។

ឆ្លងតាមការបកស្រាយខាងលើយើងឃើញថា ប្រធានមានអត្ថន័យយ៉ាងជ្រាលជ្រៅ ដែលស្តែងចេញតាមរយៈតួអង្គធនញ្ជ័យពិតជាមានឧត្តមគតិស្នេហាជាតិខ្ពង់ខ្ពស់បំផុត ផ្តល់នូវតម្លៃអប់រំដែលជាគំរូដ៏ល្អមួយ សម្រាប់មនុស្សជំនាន់ក្រោយ។ ដូច្នេះក្នុងនាមយើងជាកុលបុត្រកុលធីតាខ្មែរ ត្រូវខិតខំប្រឹងប្រែងរៀនសូត្រឱ្យមានចំណេះដឹងខ្ពស់ ចូលរួមក្នុងកិច្ចការពារ និងកសាងប្រទេសជាតិរបស់ខ្លួនឱ្យមានការអភិវឌ្ឍដូចបណ្តាប្រទេសជឿនលឿននៅលើសកលលោក។

**ប្រធានទី៥:** ក្នុងស្នាដៃអក្សរសិល្ប៍ខ្មែររឿងមាលាដួងចិត្តអ្នកសិក្សាបានបញ្ចេញទស្សនថា «ទីឃាវុធជាមន្ត្រីស្មោះត្រង់»។ ចូរធ្វើការបកស្រាយបង្ហាញឱ្យបានក្បោះក្បាយ ដោយលើកអំណះអំណាងមកបញ្ជាក់ឱ្យបានច្បាស់លាស់។

## គម្រោងតែង

### ក- សេចក្តីផ្តើម

- **លំនាំបញ្ហា:** ...អក្សរសិល្ប៍ជាវិទ្យាស្បង់ ជាកញ្ចក់សម្រាប់ឆ្លុះបញ្ចាំង...វណ្ណកម្មរបស់លោក នូ ហាច... ក្រោយពីបានសិក្សារឿងនេះចប់...
- **ចំណូលបញ្ហា(បង្ហាញបញ្ហា):** អាស្រ័យហេតុនេះហើយ ទើបអ្នកសិក្សាបញ្ចេញទស្សនថា "ទីឃាវុធជាមន្ត្រីស្មោះត្រង់"...
- **ចំណោទបញ្ហា:** ... តើចំណុចត្រង់ណាខ្លះដែលបង្ហាញថា ទីឃាវុធជាមន្ត្រីស្មោះត្រង់...។

### ខ- តួសេចក្តី

- **ឃ្លាភ្ជាប់សេចក្តី:** ដើម្បីជាស្ពានឈានទៅរកការបកស្រាយ យើងគប្បីយល់នូវអត្ថន័យនៃពាក្យគន្លឹះរបស់ប្រធានជាមុនសិន...។
- ពន្យល់ពាក្យគន្លឹះ៖
  - ✓ មន្ត្រី មានន័យថាគឺជាអ្នកធ្វើការងារនៅក្នុងរាជការ ដើម្បីបម្រើប្រជាពលរដ្ឋ ទទួលប្រាក់បៀវត្សរ៍ប្រចាំខែពីរាជរដ្ឋាភិបាល...
  - ✓ ស្មោះត្រង់ ស្ម័គ្រស្មោះ គ្មានគំនិតវៀចវេរ កឺបកេងប្រវ័ញ្ចបន្លំគេ ឬមានគំនិតអគតិទៅលើបញ្ហាអ្វីមួយ...។
- **ពន្យល់ន័យប្រធាន:** តាមរយៈការពន្យល់ពាក្យគន្លឹះទស្សនខាងលើមានន័យថា តួអង្គទីឃាវុធក្នុងរឿងមាលាដួងចិត្ត ជាមនុស្សម្នាក់ដែលប្រកាន់ភ្ជាប់នូវសច្ចធម៌ ស្រឡាញ់យុត្តិធម៌ មិនលុះក្រោមអំពើពុករលួយ...។
- បកស្រាយប្រធាន៖
  - ✓ រឿងមាលាដួងចិត្ត បានបង្កប់នូវអត្ថន័យ និងខ្លឹមសារអប់រំ បណ្តុះគំនិត...សិស្សានុសិស្ស គប្បីប្រព្រឹត្តអំពើល្អទាំងកាយ វាចា ចិត្ត កុំសាងអំពើអាក្រក់ ក្បត់ឧត្តមគតិ មានគំនិតលោភលន់...
  - ✓ សិស្សានុសិស្សទាំងឡាយ បានសិក្សារឿងនេះចប់ត្រូវប្រតិបត្តិខ្លួនធ្វើយ៉ាងណាត្រូវចេះស្រឡាញ់ជាតិមាតុភូមិ ប្រកាន់ភ្ជាប់នូវភាពយុត្តិធម៌ ព្រហ្មវិហារធម៌ សន្តានចិត្តសន្ដោសប្រោសប្រណីកុំឱ្យសេចក្តីលោភលន់មកបិទបាំង...
  - ✓ ឧទាហរណ៍ តួអង្គទីឃាវុធក្នុងរឿងមាលាដួងចិត្ត។ យុវជនកម្លោះនេះ ជាមន្ត្រីរាជការដ៏ស្អាតស្អំម្នាក់។ ទោះបីប្រាក់ខែតិចតួច ខ្វះខាត មិនគ្រប់គ្រាន់ក្តី ក៏គេប្រកាន់ខ្ជាប់នូវភាពយុត្តិធម៌ជានិច្ច មិនលុះក្រោមអំពើពុករលួយស៊ីសំណូកសូកប៉ាន់...
  - ✓ ទោះបីឈ្មួញទុច្ចរិត ថៅកែហុងឈី យកលុយមកសូកប៉ាន់ទីឃាវុធ បដិសេធ...ហុងឈីខឹងថៅហ្វាយខេត្តដកតំណែង...
  - ✓ ទីឃាវុធប្រកាន់ភ្ជាប់ជានិច្ចនូវយុត្តិធម៌ លះបង់ប្រយោជន៍ផ្ទាល់ខ្លួន...។

- **សរុបសេចក្តី**: តាមការបរិយាយ និងអំណះអំណាងខាងលើនេះ បានស្តែងឱ្យឃើញថា តួអង្គទីឃារុធ ពិតជាយុវជនដ៏ឆ្នើម មានភាពស្មោះត្រង់ ស្រឡាញ់ជាតិ មិនគិតពីប្រយោជន៍ផ្ទាល់ខ្លួន ស្រឡាញ់សម្ងហាភាព សុខចិត្តលះបង់សេចក្តីសុខផ្ទាល់ខ្លួនដើម្បីប្រយោជន៍រួម...។

**គ- បញ្ចប់សេចក្តី**

- **វាយតម្លៃប្រធាន**: ឆ្លងតាមការអធិប្បាយទស្សនៈរបស់ប្រធាន បានបង្កប់នូវអត្ថន័យ នងខ្លឹមសារយ៉ាងជ្រាលជ្រៅសម្រាប់បណ្តុះស្មារតីអប់រំទូន្មានប្រៀនប្រដៅមនុស្សកុំឱ្យមានគំនិតអាត្មានិយម លោភលន់...
- **យោបល់ផ្ទាល់ខ្លួន**: ដូច្នេះក្នុងនាមយើងជាសិស្សានុសិស្សត្រូវខិតខំប្រឹងប្រែងស្វះស្វែងរៀនសូត្រក្រេបយកចំណេះដឹងឱ្យបានខ្ពង់ខ្ពស់ទូលំទូលាយ មានសមត្ថភាពគ្រប់គ្រាន់ឱ្យក្លាយជាធនធានមនុស្សពិតប្រាកដ ដើម្បីចូលរួមចំណែកអភិវឌ្ឍប្រទេសជាតិឱ្យបានរុងរឿង លុបបំបាត់នូវអំពើពុករលួយ...។

## សេចក្តីអធិប្បាយ

អក្សរសិល្ប៍ជាវិទ្យាស្យង់មួយ ហើយក៏ជាកញ្ចក់សម្រាប់ឆ្លុះបញ្ចាំងពីតថភាពនៃសង្គមរស់នៅដែរ។ បើសង្គមបែបណាអក្សរសិល្ប៍ក៏លាតត្រដាងពីបញ្ហាក្នុងសង្គមបែបនោះដែរ។ យ៉ាងណាមិញ រឿងមាលាដួងចិត្ត ជាវណ្ណកម្មរបស់លោក នូ ហាច ដែលប្រតិស្ឋឡើងនៅឆ្នាំមួយពាន់ប្រាំបួនរយសាមសិបប្រាំបួន ស្ថិតក្នុងចលនាអក្សរសិល្ប៍បែបខេមរនិយម។ ក្រោយពីបានសិក្សារឿងនេះចប់ ដំណើររឿងបានលាតត្រដាងឱ្យឃើញថា តួអង្គឯកទីឃារុធជាកម្លោះម្នាក់ដ៏ស្រស់សង្ហាប្រកបដោយចំណេះដឹងនិងសមត្ថភាព ហើយក៏ជាមន្ត្រីរាជាការម្នាក់ដែលមានលក្ខណៈល្អប្រពៃ មានសន្តានចិត្តល្អប្រកបដោយព្រហ្មវិហារធម៌ និងប្រកាន់ភ្ជាប់នូវយុត្តិធម៌ជានិច្ច។ អាស្រ័យហេតុនេះហើយទើបអ្នកសិក្សាទាំងអស់នាំគ្នានិយាយថា "ទីឃារុធជាមន្ត្រីស្មោះត្រង់"។

តើចំណុចត្រង់ណាខ្លះដែលបង្ហាញថា ទីឃារុធជាមន្ត្រីស្មោះត្រង់?

ដើម្បីជាស្ពានឈានទៅរកការបកស្រាយ នូវចំណោទបញ្ហារបស់ប្រធានឱ្យកាន់តែក្បោះក្បាយច្បាស់លាស់មានអត្ថន័យជ្រាលជ្រៅ និងពិស្តារថែមទៀតនោះ យើងគប្បីស្វែងយល់ន័យនូវអត្ថន័យនៃពាក្យគន្លឹះរបស់ប្រធានជាមុនសិនគឺពាក្យ " មន្ត្រី ស្មោះត្រង់ "។ ពាក្យ មន្ត្រី គឺជាអ្នកធ្វើការងារនៅក្នុងរាជការដើម្បីបម្រើប្រជាពលរដ្ឋទទួលប្រាក់បៀវត្សរ៍ប្រចាំខែពីរាជរដ្ឋាភិបាល។ រីឯពាក្យស្មោះត្រង់ មានន័យថា ស្មុគ្រស្មោះគ្មានគំនិតវៀចវេរ កឺបកេងប្រវញ្ចបន្លំគេឬមានគំនិតអគតិទៅលើបញ្ហាអ្វីមួយ។ តាមរយៈការពន្យល់ពាក្យគន្លឹះទស្សនខាងលើមានន័យថា តួអង្គទីឃារុធ ជាមនុស្សម្នាក់ដែលប្រកាន់ភ្ជាប់នូវសច្ចធម៌ ស្រឡាញ់យុត្តិធម៌ មិនលុះក្រោមអំពើពុករលួយ មិនបង្កផលវិបាកដល់អ្នកដទៃ ឬធ្វើឱ្យអ្នកដទៃរស់នៅវេទុក្ខវេទនាដោយសារខ្លួនឡើយ។

ជាការពិតណាស់ រឿងមាលាដួងចិត្តជារឿងប្រឌិតបែបមនោសញ្ចេតនាដែលប្រជាជនខ្មែរពេញនិយមចូលចិត្តអានដោយហេតុថា រឿងនេះបានបង្កប់នូវអត្ថន័យនិងខ្លឹមសារអប់រំយ៉ាងជ្រាលជ្រៅបំផុត ហើយត្រូវបានក្រសួងអប់រំ យុវជន និងកីឡាជ្រើសរើសបញ្ចូលក្នុងកម្មវិធីសិក្សាដើម្បីតម្រង់ទិសបណ្តុះស្មារតី ពុទ្ធិសិស្សានុសិស្សទាំងអស់ឱ្យចេះវិភាគ វិនិច្ឆ័យនូវទង្វើអ្វីដែលគួរធ្វើឬមិនគួរធ្វើឱ្យស្គាល់ច្បាស់នូវអ្វីដែលខុស អ្វីដែលត្រូវ គប្បីប្រព្រឹត្តខ្លួនឱ្យត្រូវទាំងកាយ វាចា ចិត្ត កុំសាងនូវអំពើអាក្រក់ ក្បត់ឧត្តម

គតិ មានគំនិតលោភលន់ គិតតែប្រយោជន៍ផ្ទាល់ខ្លួន ដែលជះឥទ្ធិពលដ៏អាក្រក់ទៅដល់អ្នកដទៃធ្វើឱ្យពួកគេជួបនូវវិបត្តិសេដ្ឋកិច្ច ក៏ដូចជាវិបត្តិផ្លូវចិត្តផងដែរ។

កន្លងមកសិស្សានុសិស្សទាំងឡាយ បានសិក្សារឿងនេះចប់ត្រូវប្រតិបត្តិខ្លួនធ្វើយ៉ាងណាត្រូវចេះស្រឡាញ់ជាតិមាតុភូមិ ប្រកាន់ភ្ជាប់នូវភាពយុត្តិធម៌ ព្រហ្មវិហារធម៌ សន្តានចិត្តសន្តោសប្រោសប្រណីកុំឱ្យសេចក្តីលោភលន់មកបិទបាំង ឬដឹកនាំមុខបានឱ្យសោះ។

ជាក់ស្តែងបើយើងពិចារណាលើដំណើរនេះផ្ទាល់យុវជនទីឃាវុធជាមន្ត្រីរាជការដ៏ស្អាតស្អំម្នាក់។ ទោះបីប្រាក់ខែតិចតួច ខ្វះខាត មិនគ្រប់គ្រាន់ក្តី ក៏គេប្រកាន់ខ្ជាប់នូវភាពយុត្តិធម៌ជានិច្ច មិនលុះក្រោមអំពើពុករលួយស៊ីសំណូកសូកប៉ាន់ពីឈ្មួញទុច្ចរិតឡើយ។ ជាប្រត្យក្សថៅកែហុងឈីបានយកលុយប្រាំរយរៀលមកសូកប៉ាន់ទីឃាវុធ ក្នុងរឿងដាក់ដេញថ្លៃឯកសណ្ឋានប៉ូលិស ត្រូវទីឃាវុធបដិសេធយ៉ាងដាច់អហង្ការ ធ្វើឱ្យថៅកែហុងឈីមិនពេញចិត្ត ខឹងនិងមានគំនុំយ៉ាងខ្លាំង ព្រមទាំងបោះពាក្យសម្តីអសុរោះ ហើយទៅសូកប៉ាន់ប្តឹងចៅហ្វាយខេត្តឱ្យដកទីឃាវុធចេញពីតំណែង។ ទោះបីឈ្មួញទុច្ចរិតនិងចៅហ្វាយខេត្តធ្វើបែបនេះមកលើខ្លួន ក៏ទីឃាវុធមិនផ្លាស់ប្តូរជំហររបស់ខ្លួនដែរ គឺប្រកាន់ខ្ជាប់នូវឆន្ទៈមោះមុត ភាពយុត្តិធម៌ ស្មោះត្រង់ក្នុងការបម្រើជាតិ មិនឱ្យជនមួយក្តាប់តូចមកឆ្លៀតឱកាសទិញឧត្តមគតិរបស់ខ្លួនឬបំផ្លិចបំផ្លាញជាតិឱ្យវិនាសដោយសារចិត្តអប្រិយមហិច្ឆតារបស់ពួកគេបានឡើយ។ លើសពីនេះទៅទៀត ទីឃាវុធធ្វើបែបនេះ គឺដោយសារមិនចង់ក្បត់នឹងឧត្តមគតិខ្លួនឯងដែល គេបានតាំងចិត្តកាលពីនៅរៀនម្ល៉េះគឺស្អប់ខ្ពើមបំផុតអំពើអយុត្តិធម៌ ស៊ីសំណូក។ ម្យ៉ាងទៀតគេមិនចង់ឱ្យប៉ូលិសជួបនូវភាពអត់ឃ្លាន ខ្វះខាត និងរងទុក្ខលំបាក បែកគំនិតទៅប្រព្រឹត្តអំពើផ្តេសផ្តាសខុសច្បាប់បង្កភាពវឹកវរ ចលាចល អនាធិបតេយ្យនាំឱ្យកើតសេចក្តីមហន្តរាយដល់ប្រទេសជាតិ។

សរុបសេចក្តីមក តាមការបរិយាយនិងអំណះអំណាងខាងលើនេះបានស្តែងឱ្យឃើញថា តួអង្គទីឃាវុធពិតជាយុវជនដ៏ឆ្នើមមានភាពស្មោះត្រង់ ស្រឡាញ់ជាតិ ស្រឡាញ់សម្ភាភាព ស្រឡាញ់យុត្តិធម៌ មិនគិតពីប្រយោជន៍ផ្ទាល់ខ្លួន សុខចិត្តលះបង់សេចក្តីសុខផ្ទាល់ខ្លួនដើម្បីប្រយោជន៍រួម។

ឆ្លងតាមការអធិប្បាយទស្សនរបស់ប្រធានខាងលើបានបង្កប់នូវអត្ថន័យនិងខ្លឹមសារយ៉ាងជ្រាលជ្រៅ សម្រាប់បណ្តុះស្មារតីអប់រំទូន្មានប្រៀនប្រដៅមនុស្ស កុំឱ្យមានគំនិតអាត្មានិយម លោភលន់ ចេះវិភាគវិនិច្ឆ័យឱ្យបានច្បាស់មុននឹងសម្រេចចិត្តធ្វើអ្វីមួយ ត្រូវគិតប្រយោជន៍រួមជាធំ មានជំហររឹងមាំប្រកាន់គំនិតសុទិដ្ឋនិយម។ ដូច្នេះក្នុងនាមយើងជាសិស្សានុសិស្ស ត្រូវខិតខំប្រឹងប្រែងស្វះស្វែងក្នុងការរៀនសូត្រក្រេបយកចំណេះដឹងឱ្យបានខ្ពង់ខ្ពស់ទូលំទូលាយ មានសមត្ថភាពគ្រប់គ្រាន់ឱ្យក្លាយជាធនធានមនុស្សពិតប្រាកដដើម្បីចូលរួមចំណែកអភិវឌ្ឍប្រទេសជាតិឱ្យបានរុងរឿងលុបបំបាត់នូវអំពើពុករលួយស្រឡាញ់យុត្តិធម៌ មានភាពស្មោះត្រង់ដូចតួអង្គទីឃាវុធជាភស្តុតាង។

**ប្រធានទី៦:** ខ្មែរមានទំនៀមទន្លាប់រៀបចំទុកដាក់កូនចៅឱ្យមានគូស្រករទៅតាមប្រពៃណី។ ចូរពន្យល់ពី «ការទុកដាក់កូនស្រីឱ្យមានគូស្រកររបស់យាយនួនក្នុងរឿងផ្កាស្រពោន»។

## គម្រោងតែង

### ក- សេចក្តីផ្តើម

- **លំនាំបញ្ហា:** និយាយទូទៅទាក់ទងទៅនឹងស្នាដៃអក្សរសិល្ប៍ខ្មែរ... និងបង្ហាញពីទំនៀមទម្លាប់ទុកដាក់កូនចៅ...
- **ចំណូលបញ្ហា(បង្ហាញបញ្ហា):** ហេតុនេះហើយបានជាមានករណីលើកឡើងថា...ការទុកដាក់កូនស្រីឱ្យមានគូស្រកររបស់យាយនួនក្នុងរឿងផ្កាស្រពោន...
- **ចំណោទបញ្ហា:** ...តើប្រធានខាងលើមានអត្ថន័យដូចម្តេចខ្លះ...។

### ខ- តួសេចក្តី

- **ឃ្លាភ្ជាប់សេចក្តី:** មុននឹងឈានចូលដល់ការបកស្រាយប្រធាន យើងគប្បីយល់ន័យនៃពាក្យមួយចំនួនជាមុនសិន...។
- **ពន្យល់ពាក្យគន្លឹះ៖**
  - ✓ ការទុកដាក់កូនស្រី: មានន័យថា ការរៀបមង្គលការ ឬការរៀបអាពាហ៍ពិពាហ៍កូនស្រីឱ្យមានប្តី...
  - ✓ គូស្រករ: ... មានន័យថា ប្តីប្រពន្ធ...។
- **ពន្យល់ន័យប្រធាន:** ដូច្នេះអត្ថន័យរបស់ប្រធានចង់បង្ហាញថា តួអង្គយាយនួនដែលជាម្តាយនាងវិធាវីក្នុងរឿងផ្កាស្រពោន មានភារកិច្ចជាអ្នករៀបការ ឬរៀបអាពាហ៍ពិពាហ៍កូនស្រីរបស់គាត់ឱ្យមានប្តី ឬមានគូស្រករ...។
- បកស្រាយប្រធាន៖
  - ✓ ការរៀបចំកូនឱ្យមានគូស្រករជាកាតព្វកិច្ចរបស់ម្តាយឪពុកគ្រប់រូប...
  - ✓ ចំណុចទីមួយនោះគឺ គោលបំណងរបស់យាយនួន មានភាពត្រឹមត្រូវដូចឪពុកម្តាយទូទៅដែរពីព្រោះតាមធម្មតាឪពុកម្តាយក្នុងលោកតែងតែចង់ឱ្យកូនប្រុសស្រី និងក្រុមគ្រួសារមានទ្រព្យសម្បត្តិ មានកេរ្តិ៍ឈ្មោះ មានកិត្តិយសឧត្តុង្គឧត្តម...
  - ✓ ចំណុចទីពីរនោះគឺ បើយើងគិតមួយផ្នែកទៀតឃើញថា គំនិតរបស់យាយនួននេះជាការខុសឆ្គងធ្ងន់ណាស់ ពីព្រោះតែពុំបានយល់ពីសេចក្តីស្នេហា...
  - ✓ ការបំបែកបំបាក់គូស្នេហ៍បែបនេះ គឺជាការលំបាកបំផុត ហើយថែមទាំងជួបគ្រោះអន្តរាយថែមទៀតផង។ ហេតុដូច្នេះហើយបានជាយាយនួន ជួបគ្រោះអន្តរាយយ៉ាងធំធេង រហូតដល់បាត់ជីវិតកូនស្រីជាទីស្រឡាញ់...។
- **សរុបសេចក្តី:** ការទុកដាក់កូនស្រីឱ្យមានគូស្រកររបស់យាយនួនក្នុងរឿងផ្កាស្រពោន បើគិតតាមគំនិតមាតាទូទៅ ក្នុងការរកសុភមង្គលឱ្យកូនស្រីឃើញថា ជាការត្រឹមត្រូវសមហេតុផល។ តែបើគិតថា គាត់ជាអ្នកមិនស្គាល់ពីទំហំនៃសេចក្តីស្នេហាគ្រាដំបូងរបស់មនុស្សគ្រប់រូបវិញនោះឃើញថា គាត់ជាអ្នកមានកំហុស...។

## គ- សេចក្តីបញ្ចប់

- **វាយតម្លៃប្រធាន**: ឆ្លងតាមការបកស្រាយខាងលើឃើញថាប្រធាននេះ មានបំណងចង់អប់រំដល់មាតាបិតា ឬអាណាព្យាបាលទូទៅ ឱ្យចេះគិតគូរពិចារណាវែងឆ្ងាយគ្រប់ជ្រុងជ្រោយក្នុងការរៀចំទុកដាក់កូនចៅឱ្យមានគូស្រករ...
- **យោបល់ផ្ទាល់ខ្លួន**: ដូច្នេះក្នុងនាមយើងជាអ្នកសិក្សា ត្រូវខិតខំរៀនសូត្រ ស្រាវជ្រាវវិភាគស្នាដៃអក្សរសិល្ប៍ ដើម្បីស្រង់យកមេរៀនបទពិសោធ...។

## សេចក្តីអធិប្បាយ

ឪពុកម្តាយទាំងឡាយសុទ្ធតែមានកាតព្វកិច្ចក្នុងការរៀបចំទុកដាក់កូនចៅប្រុសស្រី ឱ្យមានគូស្រករគ្រប់ៗគ្នា។ ដូចគ្នានេះរឿងផ្កាស្រពោនតួអង្គយាយនួនដែលជាម្តាយនាងវិធាវី ក៏មានភារកិច្ចក្នុងការរៀបចំកូនរបស់គាត់ឱ្យមានគូស្រករនឹងគេដែរ។ ហេតុនេះហើយបានជាមានករណីលើកឡើងថា "ការទុកដាក់កូនស្រីឱ្យមានគូស្រកររបស់យាយនួនក្នុងរឿងផ្កាស្រពោន"។

តើការរៀបចំទុកដាក់កូនស្រីឱ្យមានគូស្រកររបស់យាយនួនមានលក្ខណៈដូចម្តេច?

ដើម្បីជាជំនួយដល់ការបកស្រាយឱ្យកាន់តែច្បាស់លាស់នោះ យើងគប្បីយល់នូវន័យនៃពាក្យគន្លឹះរបស់ប្រធានជាមុនសិនគឺពាក្យ" ការទុកដាក់កូនចៅ គូស្រករ "។ ចំណែកពាក្យការទុកដាក់កូនស្រីមានន័យថា ការរៀបមង្គលការ ឬការរៀបអាពាហ៍ពិពាហ៍កូនស្រីឱ្យមានប្តី។ ពាក្យ គូស្រករ មានន័យថា ប្តីប្រពន្ធ។ ដូច្នេះអត្ថន័យរបស់ប្រធានចង់បង្ហាញថា តួអង្គយាយនួនដែលជាម្តាយនាងវិធាវីក្នុងរឿងផ្កាស្រពោន មានភារកិច្ចជាអ្នករៀបការ ឬរៀបអាពាហ៍ពិពាហ៍កូនស្រីរបស់គាត់ឱ្យមានប្តី ឬមានគូស្រករទៅតាមគន្លងទំនៀមទម្លាប់ប្រពៃណី។

ក្នុងរឿងផ្កាស្រពោនតួអង្គយាយនួន ជាស្ត្រីមេម៉ាយម្នាក់ដែលបានទទួលរងនូវសេចក្តីវិនាសក្នុងការរៀបចំទុកដាក់កូនស្រីឱ្យមានគូស្រករ ពីព្រោះគាត់ពុំបានសម្រេចតាមបំណងដូចដែលគាត់បានប៉ងប្រាថ្នានោះទេ។ បើយើងយករឿងរបស់គាត់មកពិនិត្យ វិភាគ ត្រិះរះពិចារណាឱ្យបានល្អិតល្អន់នោះយើងនឹងឃើញថាគាត់ជាស្ត្រីលោភលន់ យកបាតដៃជាខ្នងដៃ មិនគោរពពាក្យសន្យា មានកំហុសមួយយ៉ាងធំក្នុងឆាកជីវិត។ សកម្មភាពរបស់យាយនួនមានពីរចំណុចផ្សេងគ្នា សម្រាប់យកមកធ្វើជាមេរៀនបទពិសោធៈ

ចំណុចទីមួយនោះគឺ គោលបំណងរបស់យាយនួន មានភាពត្រឹមត្រូវដូចឪពុកម្តាយទូទៅដទៃទៀតដែរ ពីព្រោះតាមធម្មតាឪពុកម្តាយក្នុងលោកតែងតែចង់ឱ្យកូនប្រុសស្រី និងក្រុមគ្រួសារមានទ្រព្យសម្បត្តិ មានកេរ្តិ៍ឈ្មោះ មានកិត្តិយសឧត្តុង្គឧត្តម។ បើអ្នកមានកូនក្រមុំ តែងតែសម្លឹងមើលយុវជនណាដែលមានទ្រព្យសម្បត្តិ សមត្ថភាព ចំណេះវិជ្ជា ឋានៈខ្ពង់ខ្ពស់ ហើយចង់បានយុវជនមានសមត្ថភាពមកធ្វើជាកូនប្រសា ដែលអាចផ្ញើក្តីសង្ឃឹមកូនស្រីរបស់គេឱ្យរស់នៅជាមួយទទួលបានសុភមង្គល។ ចំណែកអ្នកមានកូនកំលោះវិញ ក៏មិនខុសពីអ្នកមានកូនក្រមុំដែរ គេចង់បានយុវនារីដែលមានលក្ខណសម្បត្តិល្អដូចយុវជនខាងលើដែរ ទោះបីកូនរបស់ខ្លួនពុំទាន់មានសមត្ថភាព ចំណេះដឹង ឬឋានៈក៏ដោយ។ គោលបំណងនេះ តែងតែមាននៅក្នុងសន្តានចិត្តឪពុកម្តាយទាំងពួង។ ប៉ុន្តែអ្នកខ្លះក៏សមតាមបំណងឯអ្នកខ្លះទៀតក៏មិនសម្រេចតាមបំណងដែរ។ កាលបើកូនចៅបានគ្នាជាគូស្រករហើយ រកស៊ីចិញ្ចឹមជីវិតមិនប្រសើរ រស់នៅវេទនា ខ្វះមុខខ្វះក្រោយ គ្មានទ្រព្យសម្បត្តិ គ្មានញាតិមិត្ត គ្មានឋានៈ

គ្មានកិត្តិយស ម្តាយឪពុកតែងតែព្រួយបារម្ភ តូចចិត្តតឹងទ្រូងខ្លាំងណាស់។ ឪពុកម្តាយគ្រប់រូប មិនចង់ឱ្យកូនស្រីរបស់ខ្លួនជួបប្រទះនឹងហេតុការណ៍ទាំងនេះទេ។ ហេតុនេះហើយបានជាយាយនួន សម្រេចចិត្តឱ្យកូនស្រីរបស់គាត់ផ្តាច់ពាក្យពី ប៊ុន ធឿន ដែលជាគូភ្ជាប់ពាក្យតាំងពីក្មេង ហើយគាត់ចង់ឱ្យនាងវិធាវីកូនស្រីគាត់រៀបការជាមួយ ណៃស៊ិតវិញ ព្រោះគាត់បានឃើញថា គ្រួសាររបស់ប៊ុនធឿនធ្លាក់ខ្លួនក្រដោយសារមុខរបររកស៊ីជួបគ្រោះលិចទូកធ្វើឱ្យខាតលិចលង់អស់អស់ដើមទុនទៅហើយ។ ដូច្នេះយាយនួនយល់ថា បើកាលណាឱ្យកូនស្រីគាត់រៀបការជាមួយ ប៊ុនធឿន ទៅនឹងនាំឱ្យកូនស្រីគាត់ជួបការលំបាកគ្រប់បែបយ៉ាងជាក់ជាមិនខាន។

ចំណុចទីពីរនោះគឺ គំនិតរបស់យាយនួននេះជាការខុសឆ្គងធ្ងន់ណាស់ ព្រោះតែពុំបានយល់ពីជម្រៅសេចក្តីស្នេហា ដែលកំពុងកើតឡើងមកលើនាងវិធាវី និងប៊ុនធឿនដែលបានផ្សំផ្គុំតាំងពីនៅតូចក្រូចឆ្មារបាន។ វាជិតជាមជាប់ក្នុងក្រឪបេះដូងរបស់គេទាំងពីរមិនងាយរលប់បាត់ឡើយ សូម្បីតែយាយនួនខ្លួនឯងក៏នៅមានស្លាកស្នាមដែរ។ យាយនួន មិនបានយល់ពីអារម្មណ៍ស្នេហាពិតប្រាកដរបស់ ប៊ុនធឿន និងវិធាវីឡើយ។ គាត់ធ្វើតាមតែគំនិតរបស់គាត់ ដែលគាត់យល់ថាត្រឹមត្រូវ។ យាយនួនមិនបានយល់ច្បាស់ពីសេចក្តីស្នេហាឡើយ។ ហេតុនេះហើយទើបគាត់ត្រូវជួបគ្រោះមហន្តរាយ រហូតដល់កូនស្រីជាទីស្រឡាញ់ត្រូវបាត់បង់ជីវិត។ បញ្ហានេះកើតឡើងដោយសារយាយនួន បំបែកបំបាក់សេចក្តីស្នេហា ដែលកើតឡើងតាមគន្លងទំនៀមទម្លាប់ប្រពៃណីរបស់កូនគាត់។ សេចក្តីស្នេហារបស់ប៊ុនធឿន និងវិធាវីគឺជាស្នេហាគ្រាដំបូងនៃយុវភាពទាំងពីរ។ ស្នេហាគ្រាដំបូង តែងកើតមានចំពោះយុវវ័យគ្រប់រូប ហើយមនុស្សគ្រប់រូបចងចាំវាអស់មួយជីវិត ទោះបីបានជួបគ្នា ឬព្រាត់គ្នាក៏ដោយ។ ស្នេហាបែបនេះមានលក្ខណៈងប់ងល់ ហើយមានអត្ថន័យជ្រាលជ្រៅជិតជាប់ក្នុងបេះដូង និងមានតម្លៃណាស់សម្រាប់គូស្នេហ៍ទាំងពីរ។ គូស្នេហ៍បែបនេះ គេចាត់ទុកថា នៅក្នុងពិភពលោកនេះ គ្មានអ្វីធំជាងសេចក្តីស្នេហារបស់ពួកគេឡើយ គេស្រឡាញ់គ្នាប្តូរផ្តាច់រហូតហ៊ានលះបង់ជីវិត ប្រសិនបើមានអ្នកមកបំបែកបំបាក់។ ការបំបែកបំបាក់គូស្នេហ៍បែបនេះ គឺជាការលំបាកបំផុត ហើយថែមទាំងជួបគ្រោះអន្តរាយថែមទៀតផង។ យាយនួនបាត់បង់ជីវិតកូនស្រីជាទីស្រឡាញ់ ដោយសារគាត់បានបំបែកបំបាក់គូស្នេហ៍គ្រាដំបូងរបស់ពួកគេ។ យាយនួនជាអ្នកមានកំហុសដ៏ធ្ងន់ ព្រោះគាត់ពុំបានពិនិត្យពិចារណាហេតុការណ៍ច្បាស់លាស់ ។

សរុបសេចក្តីមក ការទុកដាក់កូនស្រីឱ្យមានគូស្រកររបស់យាយនួនក្នុងរឿងផ្កាស្រពោន បើគិតតាមគំនិតមាតាទូទៅ ក្នុងការរកសុភមង្គលឱ្យកូនស្រីឃើញថា ជាការត្រឹមត្រូវសមហេតុផល។ តែបើគិតថា គាត់ជាអ្នកមិនស្គាល់ពីទំហំនៃសេចក្តីស្នេហាគ្រាដំបូងរបស់មនុស្សគ្រប់រូបវិញនោះឃើញថាគាត់ជាអ្នកមានកំហុស ព្រោះគាត់មិនបានដោះស្រាយបញ្ហាក្នុងក្រុមគ្រួសារឱ្យបានជោគជ័យ។

ឆ្លងតាមការបកស្រាយខាងលើឃើញថាប្រធាននេះ មានបំណងចង់អប់រំដល់មាតាបិតា ឬអាណាព្យាបាលទូទៅ ឱ្យចេះគិតគូរពិចារណាវែងឆ្ងាយគ្រប់ជ្រុងជ្រោយក្នុងការរៀបចំទុកដាក់កូនចៅឱ្យមានគូស្រករ មិនត្រូវធ្វើតាមតែចិត្តខ្លួនចង់បាននោះឡើយ។ ដូច្នេះក្នុងនាមយើងជាអ្នកសិក្សា ត្រូវខិតខំរៀនសូត្រ ស្រាវជ្រាវវិភាគស្នាដៃអក្សរសិល្ប៍ ដើម្បីស្រង់យកមេរៀនបទពិសោធមកច្នៃប្រឌិតអនុវត្តក្នុងជីវិតរស់នៅប្រកបដោយសុភមង្គល។

## ១៤.៦- ប្រធានតែងសេចក្តីអត្ថាធិប្បាយប្រៀបធៀប

ប្រធានទី១: តាមរយៈការសិក្សារឿងកុមារកំព្រា ចូរអ្នកធ្វើការប្រៀបធៀបលក្ខណៈដូចគ្នានិងខុសគ្នានៃលក្ខណសម្បត្តិ និងសកម្មភាពរបស់កុមារប្អូន និងកុមារបងឱ្យបានច្បាស់លាស់។

### គម្រោងតែង

**ក- សេចក្តីផ្តើម**

- **លំនាំបញ្ហា**: និយាយទូទៅទាក់ទងទៅនឹងស្នាដៃអក្សរសិល្ប៍ខ្មែរ... និងរឿងកុមារកំព្រា...
- **ចំណូលបញ្ហា(បង្ហាញបញ្ហា)**: ហេតុដូច្នេះហើយទើបប្រធានខាងលើតម្រូវឱ្យយើងធ្វើការប្រៀបធៀបសកម្មភាព និងចិត្តគំនិតតួអង្គកុមារទាំងពីរក្នុងរឿងកុមារកំព្រា...
- **ចំណោទបញ្ហា**: តើសកម្មភាពនិងចិត្តគំនិតកុមារទាំងពីរមានលក្ខណៈដូច និងខុសគ្នាដូចម្តេចខ្លះ...។

**ខ- តួសេចក្តី**

- **ឃ្លាភ្ជាប់សេចក្តី**: មុននឹងឈានចូលដល់ការបកស្រាយប្រធាន យើងគប្បីយល់ន័យនៃពាក្យមួយចំនួនជាមុនសិន...។
- ពន្យល់ពាក្យគន្លឹះ៖
  - ✓ ប្រៀបធៀប: មានន័យថាផ្ទៀងផ្ទាត់ ប្រដូចគ្នា ប្រៀបផ្ទឹមអ្វីៗចាប់ពីពីរឡើងទៅ ដើម្បីរកឱ្យឃើញពីលក្ខណៈដូចគ្នា លក្ខណៈខុសគ្នា និងលក្ខណៈល្អប្រសើរ...
  - ✓ លក្ខណសម្បត្តិ: ...ភាពគ្រប់គ្រាន់ បរិបូរណ៍ ភាពសមប្រកប...ទាំងផ្លូវកាយចិត្តគំនិត សតិអារម្មណ៍ប្រាជ្ញាស្មារតី និងជីវភាពរស់នៅ...
  - ✓ សកម្មភាព: គឺកិច្ចការដែលធ្វើប្រចាំថ្ងៃ ធ្វើជារឿយៗ...។
  - ✓ ពន្យល់ន័យប្រធាន: ចង់បង្ហាញពីការប្រៀបធៀបប្រដូចគ្នា ប្រៀបផ្ទឹមអ្វីៗចាប់ពីពីរឡើងទៅ ដើម្បីរកឱ្យឃើញពីលក្ខណៈដូចគ្នា លក្ខណៈខុសគ្នា និងលក្ខណៈល្អប្រសើរជាងគ្នានៃភាពគ្រប់គ្រាន់ភាពបរិបូរណ៍ ភាពសមប្រកបទាំងផ្លូវកាយ ចិត្តគំនិត សតិអារម្មណ៍ ប្រាជ្ញាស្មារតី និងជីវភាពរស់នៅរវាងកុមារបង និងកុមារប្អូននៅក្នុងរឿងកុមារកំព្រា...។
- បកស្រាយប្រធាន៖
  - ✓ លក្ខណៈដូចគ្នា: កុមារទាំងពីររស់ក្នុងត្រកូលដូចគ្នា ឪពុកចែកឋានចោលទៅកុមារបង និងកុមារប្អូនត្រូវរស់នៅយ៉ាងលំបាកគ្មានអ្នកទីពឹងដូចគ្នា...មានកាយសម្បទាគ្រប់គ្រាន់ដូចគ្នា...
  - ✓ លក្ខណៈខុសគ្នា: កុមារបងខ្ជិល...ចង់ប្រកបរបរដើរសុំទានគេ...។ រីឯកុមារប្អូន ឧស្សាហ៍...មានគំនិតច្នៃប្រឌិត...ចង់ប្រកបរបរធ្វើជុចចាប់ត្រីបន្តពីឪពុក...។
- **សរុប**: ...តួអង្គកុមារទាំងពីរមានលក្ខណៈដូចគ្នាត្រង់ រស់ក្នុងគ្រួសារតែមួយ កំព្រាខ្វះភាពកក់ក្តៅ មានកាយសម្បទាមាំមួន ទទួលការបង្ហាត់បង្រៀនពីឪពុកខ្លួនដូចគ្នា។ ចំណុចខុសគ្នាត្រង់ កុមារប្អូនឧស្សាហ៍ព្យាយាម រីឯកុមារបងខ្ជិលមិនយកចិត្តទុកដាក់។ កុមារបងចង់ដើរសុំទានគេ ចំណែកកុមារប្អូនមានសមត្ថភាពប្រកបរបរចិញ្ចឹមជីវិតដោយខ្លួនឯងបាន។ ដូច្នេះយើងអាចវិនិច្ឆ័យបានថា កុមារប្អូនមានលក្ខណសម្បត្តិល្អប្រសើរជាងកុមារបង...។

**គ- សេចក្ដីបញ្ចប់**

- **វាយតម្លៃប្រធាន**: ប្រធានខាងលើពិតជាមានអត្ថន័យគ្រប់គ្រាន់ សម្រាប់ផ្ដល់ជាគតិដល់អ្នកសិក្សាគ្រប់រូបយកទៅគិតពិចារណាក្នុងការរស់នៅ...
- **យោបល់ផ្ទាល់ខ្លួន**: ដូច្នេះក្នុងនាមជាអ្នកសិក្សា ត្រូវខិតខំរៀនសូត្រ ដើម្បីស្រូបយកចំណេះដឹង ពង្រីកការគិត និងយកចំណេះដឹងទៅប្រើប្រាស់ក្នុងការរស់នៅ...។

## សេចក្ដីអធិប្បាយ

ការរស់នៅរបស់មនុស្សនៅក្នុងសង្គម តែងមានមុខរបរ និងវិធីរកចំណូលផ្សេងៗគ្នាប្រកបដោយភាពសុចរិតត្រឹមត្រូវ ថ្លៃថ្នូរតាមរយៈសកម្មភាព និងចិត្តគំនិតរបស់បុគ្គលម្នាក់ៗ។ ហេតុដូច្នេះហើយទើបប្រធានខាងលើតម្រូវឱ្យយើងធ្វើការប្រៀបធៀប សកម្មភាព និងចិត្តគំនិតតួអង្គកុមារទាំងពីរក្នុងរឿងកុមារកំព្រា។

តើសកម្មភាព និងចិត្តគំនិតកុមារទាំងពីរមានលក្ខណៈដូច និងខុសគ្នាដូចម្ដេចខ្លះ?

មុននឹងចូលដល់ការបកស្រាយប្រធានខាងលើឱ្យបានក្បោះក្បាយ យើងគួរយល់នូវអត្ថន័យនៃពាក្យគន្លឹះមួយចំនួនរបស់ប្រធានជាមុនសិនគឺពាក្យ "ប្រៀបធៀបលក្ខណៈសម្បត្តិ សមត្ថភាព"។ ពាក្យប្រៀបធៀប មានន័យថាផ្ទៀងផ្ទាត់ ប្រដូចគ្នា ប្រៀបផ្ទឹមអ្វីៗចាប់ពីពីរឡើងទៅដើម្បីរកឱ្យឃើញពីលក្ខណៈដូចគ្នា និងលក្ខណៈខុសគ្នា និងលក្ខណៈល្អប្រសើរ។ ចំណែកឯពាក្យលក្ខណសម្បត្តិមានន័យថា ជាភាពគ្រប់គ្រាន់ ភាពបរិបូរណ៍ សមស្របទាំងកាយ វាចា សតិអារម្មណ៍ ប្រាជ្ញាស្មារតី និងជីវភាពរស់នៅ។ ចំណែកពាក្យ សកម្មភាព គឺកិច្ចការអ្វីៗដែលធ្វើប្រចាំថ្ងៃ ធ្វើជារឿយៗ។ ប្រធានខាងលើនេះមានន័យថា ចង់ឱ្យយើងផ្ទៀងផ្ទាត់ ប្រដូច ប្រៀបផ្ទឹម ដើម្បីរកឱ្យឃើញពីលក្ខណៈដូចគ្នា លក្ខណៈខុសគ្នា និងលក្ខណៈល្អប្រសើរនៃភាពគ្រប់គ្រាន់ ភាពបរិបូរណ៍ ភាពសមប្រកបទាំងកាយវាចា ចិត្ត គំនិតសតិអារម្មណ៍ ប្រាជ្ញាស្មារតី និងជីវភាពរស់នៅរវាងកុមារបង និងកុមារប្អូននៅក្នុងរឿងកុមារកំព្រា។

ជាការពិតកុមារទាំងពីរនៅក្នុងរឿងកុមារកំព្រា រស់នៅក្រោមដំបូលតែមួយក្រោមការគ្រប់គ្រងរបស់ឪពុកជាកសិករ ហើយមានវ័យជរា មានជំងឺជាប់ខ្លួនថែមទៀត។ ក្រោយពីឪពុកចែកឋានចោលទៅកុមារបង និងកុមារប្អូនត្រូវរស់នៅយ៉ាងលំបាក ព្រោះគ្មានអ្នកទីពឹងដូចគេឡើយ។ កុមារទាំងពីរមានកាយសម្បទាគ្រប់គ្រាន់ និងមានកម្លាំងមាំមួនសម្រាប់ធ្វើការងារបានដូចគ្នា។ លើសពីនេះពួកគេបានទទួលការបង្ហាត់បង្រៀនដូចគ្នាពីឪពុកខ្លួន ពីរបៀបធ្វើជុចសម្រាប់ចាប់ត្រី តាំងពីពេលដែលឪពុកពួកគេនៅមានជីវិត។

ប៉ុន្តែការទទួលនូវចំណេះពីឪពុកមិនបានដូចគ្នានោះទេដោយសារការព្យាយាមយកចិត្តទុកដាក់របស់កុមារទាំងពីរមានភាពខុសៗគ្នា។ កុមារបងជាមនុស្សខ្ជិល មិនយកចិត្តទុកដាក់នឹងការងារទេ។ កាលពីឪពុកនៅរស់ វាមិនបានខិតខំប្រឹងប្រែងជួយធ្វើកិច្ចការរបស់ឪពុកខ្លួនទេ លុះដល់អត់ពីឪពុកទៅវាមិនចេះធ្វើអ្វីទាំងអស់ ហើយក៏មិនដឹងធ្វើដូចម្ដេច ដើម្បីបានប្រាក់សម្រាប់ចិញ្ចឹមជីវិត គឺមានតែបបួលប្អូនដើរសុំទានគេតែប៉ុណ្ណោះ។

ដោយឡែកកុមារជាប្អូនវិញ ជាមនុស្សឧស្សាហ៍ព្យាយាម មានចំណេះដឹងផ្នែកជំនាញអាចធ្វើជុច ចាប់ត្រីបាន មិនព្រមដើរសុំទានគេតាមការបបួលរបស់បងខ្លួនឡើយ។ កុមារប្អូនគិតថាខ្លួនមានដៃជើង គ្រប់គ្រាន់ មានកម្លាំងបរិបូរណ៍ និងមានចំណេះដឹងផ្នែកជំនាញធ្វើជុច ដែលជាមរតកពីឪពុករបស់ខ្លួន អាចប្រកបមុខរបរចិញ្ចឹមជីវិតខ្លួនឯង និងបងប្រុសបាន។ គិតឃើញដូច្នេះហើយ ទើបកុមារប្អូនតស៊ូ ក្រាញននៀលក្នុងជីវិតកំព្រារបស់គេ រហូតទទួលបានជោគជ័យ ដោយមិនពឹងផ្អែកលើកម្លាំងអ្នកដទៃ ឡើយ។

សរុបសេចក្តីមក តាមការរៀបរាប់មកពីខាងលើឃើញថា តួអង្គកុមារទាំងពីរមានលក្ខណៈដូចគ្នា ត្រង់ រស់ក្នុងគ្រួសារតែមួយ កំព្រាខ្វះភាពកក់ក្តៅ មានកាយសម្បទាមាំមួន ទទួលការបង្ហាត់បង្រៀនពី ឪពុកខ្លួនដូចគ្នា។ ចំណុចខុសគ្នាត្រង់កុមារប្អូនឧស្សាហ៍ព្យាយាម រីឯកុមារបងខ្ជិលមិនយកចិត្តទុក ដាក់។ កុមារបងចង់ដើរសុំទានគេ ចំណែកកុមារប្អូនមានសមត្ថភាពប្រកបរបរចិញ្ចឹមជីវិតដោយខ្លួនឯង បាន។ ដូច្នេះយើងអាចវិនិច្ឆ័យបានថា កុមារប្អូន មានលក្ខណសម្បត្តិល្អប្រសើរជាងកុមារបង។

ប្រធានខាងលើពិតជាមានអត្ថន័យគ្រប់គ្រាន់ សម្រាប់ផ្តល់ជាគតិដល់អ្នកសិក្សាគ្រប់រូបយកទៅ គិតពិចារណាក្នុងការរស់នៅប្រកបដោយភាពជោគជ័យនៅក្នុងជីវិត។ ដូច្នេះក្នុងនាមជាអ្នកសិក្សា ត្រូវ ខិតខំរៀនសូត្រ ដើម្បីស្រូបយកចំណេះដឹង ពង្រីកការគិតទៅប្រើប្រាស់ក្នុងការរស់នៅ ដោយមិនពឹង ផ្អែកលើកម្លាំងញើសឈាមអ្នកដទៃឡើយ។

---

**ប្រធានទី២:** ចូរអ្នកប្រៀបធៀបលក្ខណសម្បត្តិរបស់តួអង្គសូផាតក្នុងរឿងសូផាតនិងតួអង្គថៅចិត្រ ក្នុងរឿងកុលាបប៉ៃលិន ដោយលើកយកអំណះអំណាងមកបញ្ជាក់ឱ្យបានច្បាស់លាស់។

---

## គម្រោងតែង

### ក- សេចក្តីផ្តើម

- **លំនាំបញ្ហា:** និយាយទូទៅទាក់ទងទៅនឹងស្នាដៃអក្សរសិល្ប៍ខ្មែរ... តួអង្គក្នុងរឿងសូផាត និងតួអង្គក្នុង រឿងកុលាបប៉ៃលិន ...
- **ចំណូលបញ្ហា(បង្ហាញបញ្ហា):** បញ្ចូលប្រធាន...ប្រៀបធៀបលក្ខណសម្បត្តិរបស់តួអង្គសូផាតក្នុងរឿង សូផាត និងតួអង្គថៅចិត្រក្នុងរឿងកុលាបប៉ៃលិន...
- **ចំណោទបញ្ហា:** ...តើតួអង្គទាំងពីរមានលក្ខណសម្បត្តិដូចគ្នា និងខុសគ្នាយ៉ាងណាខ្លះ...។

### ខ- តួសេចក្តី

- **ឃ្លាភ្ជាប់សេចក្តី:** មុននឹងឈានចូលដល់ការបកស្រាយប្រធាន យើងគប្បីយល់ន័យនៃពាក្យមួយចំនួន ជាមុនសិន...។
- **ពន្យល់ពាក្យគន្លឹះ៖**
  - ✓ លក្ខណសម្បត្តិ: ...ភាពគ្រប់គ្រាន់ បរិបូរណ៍ សមប្រកប...ទាំងផ្លូវកាយចិត្តគំនិត សតិអារម្មណ៍ ប្រាជ្ញាស្មារតី និងជីវភាពរស់នៅ...
  - ✓ ប្រៀបធៀប: មានន័យថាផ្ទៀងផ្ទាត់ ប្រដូចគ្នា ប្រៀបផ្ទឹមអ្វីៗចាប់ពីពីរឡើងទៅ ដើម្បីរកឱ្យឃើញពី លក្ខណៈដូចគ្នា លក្ខណៈខុសគ្នា និងលក្ខណៈល្អប្រសើរ...។

- **ពន្យល់ន័យប្រធាន:** ចង់បង្ហាញពីការប្រៀបធៀប ប្រដូចគ្នា ប្រៀបផ្ទឹមអ្វីៗចាប់ពីពីរឡើងទៅ ដើម្បីរកឱ្យឃើញពីលក្ខណៈដូចគ្នា លក្ខណៈខុសគ្នា និងលក្ខណៈល្អប្រសើរជាងគ្នានៃភាពគ្រប់គ្រាន់ ភាពបរិបូរណ៍ ភាពសមប្រកបទាំងផ្លូវកាយ ចិត្តគំនិត សតិអារម្មណ៍ ប្រាជ្ញាស្មារតី និងជីវភាពរស់នៅរវាងតួអង្គសូផាតក្នុងរឿងសូផាត និងតួអង្គចៅចិត្រក្នុងរឿងកុលាបប៉ៃលិន...។
- បកស្រាយប្រធានៈ
  - លក្ខណៈដូចគ្នាៈ

*ជាក្មេងកំព្រា*

- ✓ សូផាត ក្រោយពីម្ដាយស្លាប់ចោលទៅរស់នៅជាមួយអ្នកជិតខាង ជាមួយព្រះសង្ឃក្នុងវត្តនៅខេត្តបាត់ដំបង វត្តឧណ្ណាលោម លោកអធិបតី...
- ✓ ចៅចិត្រ ក្រោយពីឪពុកស្លាប់ទៅ បានធ្វើដំណើរទៅប៉ៃលិនធ្វើជាកម្មករនៅផ្ទះហ្លួងរតនសម្បត្តិតាមការណែនាំរបស់លោកគ្រូពេទ្យស្អាត...

*ជាអ្នកមានអត្តចរិតនិងសីលធម៌ល្អ*

- ✓ សូផាត ជាមនុស្សល្អសុភាពរាបសា ជាទីស្រឡាញ់ និងអាណិតរបស់អ្នកភូមិ ព្រះសង្ឃ ក្រុមគ្រួសារលោកអធិបតី ក្រុមគ្រួសារមេស្រុកសុខ...
- ✓ ចៅចិត្រ ជាមនុស្សជាទីពេញចិត្តរបស់អ្នកផងដូចគ្នា តាំងពីលោកគ្រូពេទ្យស្អាត ក្រុមគ្រួសារហ្លួងរតនសម្បត្តិ ពិសេសនាងយុននារី និងក្រុមកម្មករជីកត្បូង...

*ជាមនុស្សឧស្សាហ៍ព្យាយាម តស៊ូ អត់ធ្មត់នឹងការលំបាក*

- ✓ សូផាត ជាក្មេងឧស្សាហ៍ព្យាយាម ពេលរស់នៅផ្ញើប្រាណជាមួយព្រះសង្ឃនៅវត្ត ខិតខំសិក្សារៀនសូត្រ និងធ្វើកិច្ចការបម្រើព្រះសង្ឃឥតឆ្អែង។ នៅពេលទៅរស់នៅផ្ទះលោក អធិបតី សូផាតខិតខំបំពេញការងារគ្រប់បែបយ៉ាង មិនឱ្យទាស់ចិត្តឡើយ។ សូផាតក្លាយជាអ្នករាជការ ស្មៀនឃុំដំចំណានរបស់មេឃុំសុខ។ ចំណែកចៅចិត្រ បានអត់ធ្មត់នឹងការលំបាកក្នុងការធ្វើកម្មករជីកត្បូង ទទួលរងការមាក់ងាយពីយុននារី... ។

*ជាអ្នកមានចំណេះដឹងដូចគ្នា*

- ✓ សូផាត មានសញ្ញាបត្របឋមសិក្សាវិជ្ជាបារាំងខ្មែរ ក្លាយជាស្មៀនឃុំ...
- ✓ ចៅចិត្រមានប្រកាសនីយបត្រ .. អាចកាន់ការជាអ្នកគ្រប់គ្រងបញ្ជីត្បូង...។

*ចេះឈឺឆ្អាល និងជួយយកអាសាអ្នកដទៃ*

- ✓ សូផាត ជួយយកអាសាណារិនពីក្មេងធំៗដែលព្រួតគ្នាធ្វើបាប...
- ✓ ចៅចិត្រ ជួយបើកឡានតាសុន ជួយរកមធ្យោបាយដាំស្លនៅពេលឈប់កណ្ដាលព្រៃ ជួយប្រយុទ្ធជាមួយក្រុមចោរ និងក្រុមបាលដ្ឋស្រុក ...។

*ជាអ្នកទទួលបាននូវសុភមង្គលក្នុងជីវិតដូចគ្នា*

- ✓ សូផាត បានជួបឪពុកជាអ្នកមានបុណ្យសក្តិ និងទ្រព្យសម្បត្តិស្តុកស្តម្ភ ព្រមទាំងបានទទួលម៉ានយ៉ានជាគូអនាគត ...
- ✓ ចៅចិត្រ ជាអ្នកកាន់ការងារគ្រប់គ្រងបញ្ជីត្បូងជំនួសហ្លួងរតនសម្បត្តិ ព្រោះខ្លួនទទួលបានយុននារីជាភរិយា ...

- **លក្ខណៈខុសគ្នា៖**
  - ✓ សូផាត និងថៅចិត្រនៅមានចំណុចខុសគ្នាខ្លះៗដូចជា សូផាតកំព្រាឪពុកម្ដាយតាំងពីខ្លួនកើតមកភ្លាម...។ ចំណែកថៅចិត្រវិញ ធ្លាក់ខ្លួនកំព្រានៅពេលខ្លួនពេញវ័យទៅហើយ ព្រមទាំងមានលទ្ធភាពប្រកបមុខរបរគ្រប់គ្រាន់ ...
  - ✓ សូផាតមិនហ៊ានប្រឈមមុខដោះស្រាយបញ្ហាទេ តែថៅចិត្រហ៊ានប្រឈមមុខដោះស្រាយបញ្ហាគ្រប់បែបយ៉ាង...។

- **សរុប:** ...តួអង្គសូផាត និងតួអង្គថៅចិត្រ មានលក្ខណសម្បត្តិដូចគ្នាច្រើនដូចជា ភាពកំព្រា ស្មារតីឧស្សាហ៍ព្យាយាមតស៊ូ អត្តចរិត សីលធម៌ សន្ដានចិត្ត ចំណេះដឹង និងទទួលបាននូវសុភមង្គលរុងរឿងដូចគ្នា។ ចំណែកលក្ខណៈខុសគ្នាវិញគឺ សូផាតកំព្រាតាំងពីកើតមកភ្លាម ឯថៅចិត្រកំព្រាពេលធំពេញវ័យហើយ។ សូផាតមិនហ៊ានប្រឈមមុខនឹងបញ្ហា ឯថៅចិត្រហ៊ានប្រឈមមុខនឹងបញ្ហា។ តួអង្គថៅចិត្រ មានលក្ខណសម្បត្តិល្អប្រសើរជាងតួអង្គសូផាត...។

### គ- សេចក្ដីបញ្ចប់

- **វាយតម្លៃប្រធាន:** ប្រធានខាងលើពិតជាបានបង្ហាញឱ្យឃើញពីលក្ខណៈដូចគ្នា និងខុសគ្នា ខ្លះៗរបស់តួអង្គទាំងពីរយ៉ាងច្បាស់លាស់ ...
- **យោបល់ផ្ទាល់ខ្លួន:** ក្នុងនាមយើងជាសិស្សានុសិស្ស ត្រូវខិតខំរៀនសូត្រក្រេបយកចំណេះដឹងសិក្សាឱ្យបានស៊ីជម្រៅទៅលើអក្សរសិល្ប៍ ដើម្បីបានជាគំនិតគតិសម្រាប់ជាបទពិសោធក្នុងការរស់នៅរបស់យើង ...។

## សេចក្ដីអធិប្បាយ

រឿងសូផាតរបស់អ្នកនិពន្ធរីម គិន និងរឿងកុលាបប៉ៃលិនរបស់អ្នកនិពន្ធ ញ៉ុក ថែម គឺជាវណ្ណកម្មអក្សរសិល្ប៍ទំនើប ហើយបានប្រសូតឡើងក្នុងទសវត្សទីសាមសិប ជាជំណាក់កាលដំបូងអក្សរសាស្ត្រជាតិដែលមានការរីកចម្រើន។ តាមរយៈការសិក្សារឿងទាំងពីរយើងឃើញថា តួអង្គឯកក្នុងរឿងទាំងពីរនេះ សុទ្ធតែបានឆ្លងកាត់ជីវិតដ៏លំបាកវេទនាគ្រប់បែបយ៉ាង ប៉ុន្តែនៅទីបំផុតពួកគេទទួលបាននូវសុភមង្គលត្រចះត្រចង់ក្នុងជីវិត។ ហេតុដូច្នេះហើយបានជាមានប្រធានមួយលើកឡើងដោយតម្រូវឱ្យធ្វើការ "ប្រៀបធៀបលក្ខណសម្បត្តិរបស់តួអង្គសូផាតក្នុងរឿងសូផាត និងតួអង្គថៅចិត្រក្នុងរឿងកុលាបប៉ៃលិន"។

តើតួអង្គទាំងពីរមានលក្ខណសម្បត្តិដូចគ្នា និងខុសគ្នាយ៉ាងណាខ្លះ?

មុននឹងឈានចូលដល់ការបកស្រាយប្រធានខាងលើឱ្យបានក្បោះក្បាយ យើងគួរយល់នូវន័យនៃពាក្យគន្លឹះមួយចំនួនរបស់ប្រធានជាមុនសិនគឺពាក្យ "ប្រៀបធៀប លក្ខណសម្បត្តិ"។ ពាក្យប្រៀបធៀបមានន័យថាផ្ទៀងផ្ទាត់ ប្រដូចគ្នា ប្រៀបផ្ទឹមអ្វីៗចាប់ពីពីរឡើងទៅ ដើម្បីរកឱ្យឃើញពីលក្ខណៈដូចគ្នា លក្ខណៈខុសគ្នា និងលក្ខណៈល្អប្រសើរ។ ចំណែកឯពាក្យលក្ខណសម្បត្តិ មានន័យថា គឺជាភាពគ្រប់គ្រាន់ ភាពបរិបូរណ៍ សមស្របទាំងកាយ វាចា សតិអារម្មណ៍ ប្រាជ្ញាស្មារតី និងជីវភាពរស់នៅ។ ប្រធានខាងលើនេះមានន័យថា ចង់ឱ្យយើងផ្ទៀងផ្ទាត់ ប្រដូច ប្រៀបផ្ទឹម ដើម្បីរកឱ្យឃើញពីលក្ខណៈដូចគ្នា លក្ខណៈខុសគ្នា និងលក្ខណៈល្អប្រសើរនៃភាពគ្រប់គ្រាន់ ភាពបរិបូរណ៍ ភាពសម

ប្រកបទាំងកាយ វាចា ចិត្ត គំនិតសតិអារម្មណ៍ ប្រាជ្ញាស្មារតី និងជីវភាពរស់នៅរវាងតួអង្គសូផាតក្នុងរឿងសូផាត និងតួអង្គថៅចិត្រក្នុងរឿងកុលាបប៉ៃលិន។

ពិតហើយបើផ្អែកតាមដំណើររឿងទាំងពីរយើងឃើញថា តួអង្គសូផាត និងថៅចិត្រមានលក្ខណៈដូចគ្នាត្រង់ តួអង្គទាំងពីរនាក់នេះ ជាក្មេងកំព្រាដូចគ្នា។ បន្ទាប់ពីលោកបាល័ដ្ឋសួនបានចាកចោលនាងសូយ៉ាទាំងមានផ្ទៃពោះមកបម្រើការងារកន្លែងថ្មីនៅភ្នំពេញ នាងរស់នៅតែម្នាក់ឯងជាមួយកូនក្នុងពោះតែប៉ុណ្ណោះ។ ក្រោយមកនាងក៏ប្រសូតបានសូផាត ហើយប៉ុន្មានខែក្រោយមកនាងក៏បានស្លាប់ចោលសូផាត ព្រោះគ្រាំគ្រាចិត្តនៅពេលឮដំណឹងថាបាល័ដ្ឋសួនមានប្រពន្ធថ្មីនៅឯភ្នំពេញ។ សូផាតក្លាយជាក្មេងកំព្រារស់នៅបានដោយចិត្តសប្បុរសធម៌របស់អ្នកស្រុករហូតអាយុប្រាំបីឆ្នាំមករស់នៅផ្ញើខ្លួនជាមួយព្រះសង្ឃនៅវត្តក្នុងខេត្តបាត់ដំបងរហូតមកនៅភ្នំពេញក្នុងវត្តឧណ្ណាលោមនិងនៅផ្ទះលោកអធិបតី។ ចំណែកថៅចិត្រវិញ ក្រោយពីឪពុកស្លាប់ទៅ គេបានក្លាយជាមនុស្សគ្មានទីពឹង តែលតោលសមដូចសម្តីថៅចិត្រ "...ឱ! ខ្លួនអញអើយ កណ្តោចកណ្តែងខ្លោចផ្សាតែម្នាក់ឯងហើយ បើងាកវេទៅពឹងបងប្អូនញាតិមិត្ត សាច់សាលោហិត ជិតខាងឯណាក៏គ្មាន..." រួចក៏ធ្វើដំណើរទៅប៉ៃលិនធ្វើជាកម្មករនៅផ្ទះហ្លួងរតនសម្បត្តិ តាមការណែនាំរបស់លោកគ្រូពេទ្យស្អាត។

សូផាត និងថៅចិត្រជាអ្នកមានអត្តចរិត និងសីលធម៌ល្អដូចគ្នា។ សូផាត ជាមនុស្សល្អសុភាពរាបសាជាទីស្រឡាញ់ និងអាណិតរបស់អ្នកភូមិ ព្រះសង្ឃ ក្រុមគ្រួសារលោកអធិបតី ក្រុមគ្រួសារមេស្រុកសុខថៃមទៀត។ ចំណែកឯថៅចិត្រ ជាមនុស្សជាទីពេញចិត្តរបស់អ្នកផងដូចគ្នាតាំងពីលោកគ្រូពេទ្យស្អាត ក្រុមគ្រួសារហ្លួងរតនសម្បត្តិ ពិសេសនាងឃុននារី និងក្រុមកម្មករជីកត្បូង។

សូផាត និងថៅចិត្រជាមនុស្សឧស្សាហ៍ព្យាយាម តស៊ូ អត់ធ្មត់ ជម្នះការលំបាកគ្រប់បែបយ៉ាងក្នុងជីវិតដូចគ្នា។ សូផាត ជាក្មេងឧស្សាហ៍ព្យាយាម ពេលរស់នៅផ្ញើប្រាណជាមួយព្រះសង្ឃនៅក្នុងវត្តគេខិតខំសិក្សារៀនសូត្រ និងធ្វើកិច្ចការបម្រើព្រះសង្ឃឥតឆ្អំឆ្អង។ ដូចសម្តីអ្នកនិពន្ធ "...កិច្ចដែលបម្រើលោកទាំងប៉ុន្មាន សូផាត ប្រព្រឹត្តឥតឆ្គងកន្លែងណាសោះ។ ការសិក្សាទាំងប៉ុន្មាន កុមារឧស្សាហ៍ព្យាយាម មិនចេះខ្លាចនឿយ មិនចេះខ្លាចហត់..."។ នៅពេលរូបគេទៅរស់នៅផ្ទះលោកអធិបតី គេខិតខំបំពេញការងារគ្រប់បែបយ៉ាង មិនឱ្យគេទាស់ចិត្តឡើយ"... អ្នកប្រឹងតែដងទឹកស្រោចដំណាំ លុះស្រោចរួច ហើយអ្នកយកចបកាប់មកតម្រឹមផ្លូវបែកញើសខ្វាយ..."។ សូផាត បានក្លាយជាអ្នករាជការស្មៀនឃុំដ៏ចំណានរបស់មេឃុំសុខ។ ចំណែកថៅចិត្រក៏មិនខុសពីសូផាតដែរ គេបានតាំងចិត្តជាស្រេចក្នុងដំណើរជីវិតរបស់គេ។ ក្រោយពីឮសម្តីហ្លួងរតនសម្បត្តិសួរប្រាប់ពីស្ថានភាពការងារជីកត្បូង ថៅចិត្របានធ្វើការប្តេជ្ញាចិត្តប្រឈមនឹងការលំបាកជាស្រេចទៅហើយ "...មនុស្សដទៃគេទ្រាំធ្វើបានយ៉ាងណាឯខ្ញុំបាទ គង់តែធ្វើបានដូចជាគេដែរសូមព្រះតេជព្រះគុណកុំព្រួយឱ្យសោះ..."។

លើសពីនេះទៅទៀត ថៅចិត្របានខិតខំព្យាយាម តស៊ូ អត់ធ្មត់នឹងការលំបាកក្នុងការធ្វើជាកម្មករ ជីកត្បូងនិងការប្រើសម្តីមាក់ងាយពីឃុននារីជាដើម។ ម្យ៉ាងទៀតសូផាតនិងថៅចិត្រជាអ្នកមានចំណេះដឹងដូចគ្នាគឺសូផាតមានសញ្ញាបត្របឋមសិក្សាវិជ្ជា បារាំង ខ្មែរ ហើយគេបានក្លាយជាស្មៀនឃុំទៀតផង។ ចំណែកថៅចិត្រមានប្រកាសនីយបត្រ ព្រោះគេបានសិក្សាពីសាលាទំនើបដែរហើយមានសមត្ថភាពអាចកាន់ការជាអ្នកគ្រប់គ្រងកម្មករ គ្រប់គ្រងបញ្ជីត្បូងជំនួសហ្លួងរតនសម្បត្តិបាន។ បន្ថែមលើបញ្ហានេះសូផាត និងថៅចិត្រជាអ្នកចេះឈឺឆ្អាល និងជួយយកអាសាអ្នកដទៃដូចគ្នា។ សូផាត បានជួយយកអាសាណារិនពីក្មេងធំៗដែលព្រួតគ្នាធ្វើបាបណារិនជាដើម។

រីឯថៅចិត្រវិញក៏ចេះជួយទុក្ខធុរៈអ្នកដទៃដែរ ទោះជាខុសភារកិច្ចខ្លួនក៏ដោយ ដូចជាជួយបើកឡានតាសុន ជួយរកមធ្យោបាយដាំស្លនៅពេលឈប់កណ្តាលព្រៃ ជួយប្រយុទ្ធជាមួយក្រុមចោរ និងក្រុមបាលដ្ឋស្រុក។ ចុងបញ្ចប់នៃរឿងតួអង្គឯកទាំងពីរសុទ្ធតែជាអ្នកទទួលបាននូវសុភមង្គលក្នុងជីវិតដូចគ្នា។ សូផាត បានជួបឪពុកជាអ្នកមានបុណ្យសក្តិនិងទ្រព្យសម្បត្តិស្តុកស្តម្ភ ព្រមទាំងបានទទួលម៉ានយ៉ាន ជាគូអនាគត។ ចំណែកឯថៅចិត្រវិញបានក្លាយជាអ្នកកាន់ការងារគ្រប់គ្រងបញ្ជីត្បូងជំនួសហ្លួងរតនសម្បត្តិព្រោះខ្លួនបានទទួលបានយុននារីធ្វើជាភរិយា។

ទន្ទឹមនឹងលក្ខណសម្បត្តិដូចគ្នាជាច្រើនដូចបានរៀបរាប់ខាងលើសូផាតនិងថៅចិត្រក៏នៅមានចំណុចខុសគ្នាខ្លះៗដែរ។ សូផាត ជាក្មេងកំព្រាឪពុកម្តាយតាំងពីខ្លួនកើតមកភ្លាម។ គេបានឆ្លងកាត់ការលំបាកតាំងពីរស់នៅជាមួយអ្នកស្រុក ជាមួយព្រះសង្ឃ រស់នៅជាមួយលោកអធិបតី ដែលខ្លួនមិនទាន់ស្គាល់ថាជាឪពុកផង និងរស់នៅជាមួយអ្នកដទៃច្រើនកន្លែងទៀតរហូតរស់នៅលាក់មុខនិងឈ្មោះពិតប្រាកដរបស់ខ្លួនទៀត។ ចំណែកថៅចិត្រវិញ ធ្លាក់ខ្លួនកំព្រានៅពេលដែលខ្លួនធំពេញវ័យទៅហើយព្រមទាំងមានលទ្ធភាពគ្រប់គ្រាន់ក្នុងការប្រកបមុខរបរចិញ្ចឹមជីវិតបាន។ ដោយឡែកសូផាត មិនសូវហ៊ានប្រឈមមុខនឹងបញ្ហា ដោះស្រាយបញ្ហានោះឡើយ។ ដូចជានៅពេលនាងម៉ានយ៉ាន យល់ច្រឡំលើខ្លួន សូផាតបែរជារត់គេច មិនហ៊ានប្រឈមមុខដោះស្រាយឡើយ។ នៅពេលខ្លួនទៅធ្វើជាស្មៀនលោកមេឃុំ សុខក៏សូផាតរត់គេចដែរនៅពេលដែលដឹងថា គ្រួសារនាងម៉ានយ៉ានទៅទីនោះ។ ចំណែកថៅចិត្រវិញ ហ៊ានប្រឈមមុខនឹងបញ្ហាគ្រប់បែបយ៉ាងដែលកើតឡើងដូចជា ហ៊ានតទល់ជាមួយការមាក់ងាយរបស់យុននារី ប្រឈមមុខនឹងសេចក្តីស្នេហា និងការតស៊ូជាមួយក្រុមចោរជាដើមរហូតធ្វើឱ្យនាងយុននារីឆ្លើយពាក្យព្រមទទួលថៅចិត្តដោយសុទ្ធចិត្តហើយហ្លួងរតនៈសម្បត្តិសុខចិត្តទទួលថៅចិត្រជាកូនប្រសា។

សរុបមកឆ្លងតាមការស្វែងរកលក្ខណៈដូចគ្នានិងខុសគ្នាខាងលើឃើញថាតួអង្គសូផាតក្នុងរឿងសូផាតរបស់អ្នកនិពន្ធ រីម គិន និងតួអង្គថៅចិត្រក្នុងរឿងកុលាបប៉ៃលិនរបស់អ្នកនិពន្ធញ៉ុក ថែម មានលក្ខណសម្បត្តិដូចគ្នាច្រើនដូចជាភាពកំព្រា ស្មារតីឧស្សាហ៍ព្យាយាមតស៊ូ អត្តចរិត សីលធម៌ សន្តានចិត្ត ចំណេះដឹង និងទទួលបាននូវសុភមង្គលរុងរឿងដូចគ្នា។ ចំណែកលក្ខណៈខុសគ្នាវិញគឺ សូផាតជាក្មេងកំព្រាតាំងពីខ្លួនកើតមកភ្លាម ចំណែកថៅចិត្រកំព្រានៅពេលដែលខ្លួនធំពេញវ័យទៅហើយ។ សូផាតមិនហ៊ានប្រឈមមុខនឹងបញ្ហា ឯថៅចិត្រវិញ ហ៊ានប្រឈមមុខនឹងបញ្ហាគ្រប់បែបយ៉ាង។ ដូច្នេះយើងអាចវិនិច្ឆ័យបានថា តួអង្គថៅចិត្រក្នុងរឿងកុលាបប៉ៃលិន មានលក្ខណសម្បត្តិល្អប្រសើរជាងតួអង្គសូផាតក្នុងរឿងសូផាត។

ប្រធានខាងលើពិតជាមានអត្ថន័យល្អ ព្រោះបានបង្ហាញឱ្យឃើញពីលក្ខណៈដូចគ្នា និងខុសគ្នារបស់តួអង្គក្នុងរឿងយ៉ាងច្បាស់លាស់ ធ្វើឱ្យអ្នកសិក្សាយល់កាន់តែស៊ីជម្រៅទៅលើអត្ថន័យនៃស្នាដៃអក្សរសិល្ប៍ខ្មែរយើងហើយធ្វើឱ្យអ្នកអាន អ្នកសិក្សាបណ្តុះឆន្ទៈចេះទទួលខុសត្រូវ ចេះឈឺឆ្អាល ហ៊ានប្រឈមមុខនឹងស្ថានភាពជាក់ស្តែង ដើម្បីអនាគតរុងរឿង។ ដូច្នេះក្នុងនាមយើងជាសិស្សានុសិស្ស ត្រូវខិតខំរៀនសូត្រក្រេបយកចំណេះដឹងសិក្សាឱ្យបានស៊ីជម្រៅទៅលើអក្សរសិល្ប៍ ដើម្បីបានជាគំនិតសម្រាប់ជាបទពិសោធក្នុងការរស់នៅរបស់យើងទាំងពេលបច្ចុប្បន្នក៏ដូចជាទៅថ្ងៃអនាគត។

**ប្រធានទី៣:** ចូរអ្នកប្រៀបធៀបលក្ខណសម្បត្តិរបស់តួអង្គប៊ុនធឿនក្នុងរឿងផ្កាស្រពោន និងតួអង្គថៅចិត្រក្នុងរឿងកុលាបប៉ៃលិន ដោយលើកយកអំណះអំណាងមកបញ្ជាក់ឱ្យបានច្បាស់លាស់។

## គម្រោងតែង

### ក- សេចក្ដីផ្ដើម

- **លំនាំបញ្ហា:** និយាយទូទៅទាក់ទងទៅនឹងស្នាដៃអក្សរសិល្ប៍ខ្មែរ... ទាក់ទងនឹងតួអង្គក្នុងរឿងផ្កាស្រពោន និងតួអង្គក្នុងរឿងកុលាបប៉ៃលិន ...
- **ចំណូលបញ្ហា(បង្ហាញបញ្ហា):** បញ្ចូលប្រធាន ...ប្រៀបធៀបលក្ខណសម្បត្តិរបស់តួអង្គប៊ុនធឿនក្នុងរឿងផ្កាស្រពោន និងតួអង្គថៅចិត្រក្នុងរឿងកុលាបប៉ៃលិន...
- **ចំណោទបញ្ហា:** ...តើតួអង្គទាំងពីរមានលក្ខណសម្បត្តិដូចគ្នា និងខុសគ្នាយ៉ាងណាខ្លះ...។

### ខ- តួសេចក្ដី

- **ឃ្លាភ្ជាប់សេចក្ដី:** មុននឹងឈានចូលដល់ការបកស្រាយប្រធាន យើងគប្បីយល់ន័យនៃពាក្យមួយចំនួនជាមុនសិន...។
- **ពន្យល់ពាក្យគន្លឹះ៖**
  - ✓ ប្រៀបធៀប: មានន័យថាផ្ទៀងផ្ទាត់ ប្រដូចគ្នា ប្រៀបផ្ទឹមអ្វីៗចាប់ពីពីរឡើងទៅ ដើម្បីរកឱ្យឃើញពីលក្ខណៈដូចគ្នា លក្ខណៈខុសគ្នា និងលក្ខណៈល្អប្រសើរ...
  - ✓ លក្ខណសម្បត្តិ: ភាពគ្រប់គ្រាន់ បរិបូរណ៍ ភាពសមប្រកប ទាំងផ្លូវកាយចិត្តគំនិត សតិអារម្មណ៍ ប្រាជ្ញាស្មារតី និងជីវភាពរស់នៅ...។
- **ពន្យល់ន័យប្រធាន:** ចង់បង្ហាញពីការប្រៀបធៀប ប្រដូចគ្នា ប្រៀបផ្ទឹមអ្វីៗចាប់ពីពីរឡើងទៅ ដើម្បីរកឱ្យឃើញពីលក្ខណៈដូចគ្នា លក្ខណៈខុសគ្នា និងលក្ខណៈល្អប្រសើរជាងគ្នានៃភាពគ្រប់គ្រាន់ ភាពបរិបូរណ៍ ភាពសមប្រកបទាំងផ្លូវកាយ ចិត្តគំនិត សតិអារម្មណ៍ ប្រាជ្ញាស្មារតី និងជីវភាពរស់នៅ រវាងតួអង្គប៊ុនធឿនក្នុងរឿងផ្កាស្រពោន និងតួអង្គថៅចិត្រក្នុងរឿងកុលាបប៉ៃលិន...។
- **បកស្រាយប្រធាន៖**
  - ▪ **លក្ខណៈដូចគ្នា៖**
  - ✓ ប៊ុនធឿន និងថៅចិត្រជាកូនប្រុសខិតខំរៀនសូត្រ ស្មោះហាមានឧបសគ្គ រស់នៅក្នុងខេត្តបាត់ដំបងដូចគ្នា។ តួអង្គទាំងពីរកើតក្នុងត្រកូលកសិករដូចគ្នា ហើយមានជីវភាពគ្រួសារប្រហាក់ប្រហែលគ្នាដែរ...
  - ✓ ប៊ុនធឿនមានគ្រួសារមានវិបត្តិធ្លាក់ខ្លួនក្រ... ចំណែកថៅចិត្រវិញ កំព្រាឪពុកម្ដាយស្លាប់ចោល ថៅចិត្រខំប្រឹងរស់ដោយខ្លួនឯង។ ប៊ុនធឿនបានរៀនសូត្រនៅភ្នំពេញ រីឯថៅចិត្រវិញ រៀននៅខេត្តបាត់ដំបង ដែលជាស្រុកកំណើត...
  - ▪ **លក្ខណៈខុសគ្នា៖**
  - ✓ ប៊ុនធឿនខំជួយការងារឪពុក ចង់ឈប់រៀនតែឪពុកមិនព្រម... ថៅចិត្រ ...ទៅស្រុកបរប៉ៃលិនធ្វើជាកម្មករជីកត្បូងនៅបរប៉ៃលិន... ដើម្បីចិញ្ចឹមជីវិត...

- ✓ អំពីបុគ្គលភាពរវាងតួអង្គប៊ុនធឿន និងចៅចិត្រប៊ុនធឿន...គេចចេញមិនហ៊ានប្រឈមនឹងឧបសគ្គ ...មិនចេះដោះស្រាយបញ្ហា...។ តួអង្គចៅចិត្រ... ក្លាហានហ៊ានប្រឈមនឹងឧបសគ្គ...ចេះដោះស្រាយ ពេលជួបបញ្ហា...
- ✓ ស្នេហារបស់តួអង្គប៊ុនធឿន ត្រូវម្ដាយនាងវិធាវីប្រកាន់វណ្ណៈថា ក្រមិនឱ្យនាងវិធាវីរៀបការជាមួយប៊ុនធឿន...
- ✓ ស្នេហារបស់ចៅចិត្រ ជាស្នេហាផ្អែមល្ហែម មិនប្រកាន់វណ្ណៈតួអង្គនាងយុននារីរស់ ចំណែកតួអង្គនាងវិធាវីវិញត្រូវស្លាប់ទាំងក្មេងខ្ចីគួរឱ្យសង្វេគពន់ពេក...។

- **សរុបសេចក្ដី:** ...ប៊ុនធឿនមានលក្ខណៈដូចគ្នា...ចៅចិត្រត្រង់ស្ថានភាពគ្រួសារ ការរស់នៅ ការសិក្សា។ តួអង្គទាំងពីរ មានចំណុចខុសគ្នាត្រង់ស្នេហាប៊ុនធឿនត្រូវព្រាត់ស្លាប់ ស្នេហាចៅចិត្រជួបជុំ។ ប៊ុនធឿនមិនហ៊ានប្រឈមមុខជាមួយនឹងឧបសគ្គ ចៅចិត្រហ៊ានប្រឈមមុខនឹងឧបសគ្គ។ ...ចៅចិត្រមានលក្ខណសម្បត្តិល្អប្រសើរជាងប៊ុនធឿន...។

## គ- សេចក្ដីបញ្ចប់

- **វាយតម្លៃប្រធាន:** ប្រធានខាងលើពិតជាមានអត្ថន័យល្អ ព្រោះបានបង្ហាញឱ្យឃើញពីលក្ខណៈដូចគ្នា និងខុសគ្នារបស់តួអង្គក្នុងរឿងយ៉ាងច្បាស់ ធ្វើឱ្យអ្នកសិក្សាយល់កាន់តែស៊ីជម្រៅ...
- **យោបល់បញ្ចប់:** ដូច្នេះក្នុងនាមយើងជាសិស្សានុសិស្ស ត្រូវខិតខំរៀនសូត្រក្រេបយកចំណេះដឹងឱ្យបានស៊ីជម្រៅទៅលើអក្សរសិល្ប៍ ដើម្បីបានជាគំនិតសម្រាប់ជាមេរៀនបទពិសោធ...។

## សេចក្ដីអធិប្បាយ

តាមរយៈស្នាដៃរឿងនីមួយៗរបស់អ្នកនិពន្ធ សុទ្ធតែបានបង្ហាញពីដំណើរជីវិតរបស់តួអង្គ។ នៅក្នុងរឿងផ្កាស្រពោន បានបង្ហាញពីសកម្មភាពលេចធ្លោរបស់តួអង្គប៊ុនធឿន។ ចំណែកនៅក្នុងរឿងកុលាបប៉ៃលិនបានបង្ហាញពីសកម្មភាពលេចធ្លោរបស់តួអង្គចៅចិត្រ។ ដោយសារលក្ខណៈពិសេសដូច្នេះហើយ ទើបបានជាមានប្រធានតម្រូវឱ្យធ្វើការ "ប្រៀបធៀបលក្ខណសម្បត្តិតួអង្គចៅចិត្រក្នុងរឿងកុលាបប៉ៃលិននិងតួអង្គប៊ុនធឿនក្នុងរឿងផ្កាស្រពោន"។

តើតួអង្គទាំងពីរនេះ មានលក្ខណសម្បត្តិដូចគ្នា និងលក្ខណៈខុសគ្នាត្រង់ចំណុចណាខ្លះ?

ដើម្បីជាប្រទីបឈានចូលដល់ការបកស្រាយប្រៀបធៀប នូវប្រធានខាងលើនេះឱ្យបានច្បាស់លាស់នោះ យើងគប្បីយល់នូវន័យនៃពាក្យគន្លឹះរបស់ប្រធានជាមុនសិនគឺពាក្យ "ប្រៀបធៀបលក្ខណសម្បត្តិ"។ ពាក្យ ប្រៀបធៀប មានន័យថាផ្ទៀងផ្ទាត់ ប្រដូចគ្នា ប្រៀបផ្ទឹមអ្វីៗចាប់ពីពីរឡើងទៅដើម្បីរកឱ្យឃើញពីលក្ខណៈដូចគ្នា លក្ខណៈខុសគ្នា និងលក្ខណៈល្អប្រសើរ។ ចំណែកឯពាក្យ លក្ខណសម្បត្តិ មានន័យថា គឺជាភាពគ្រប់គ្រាន ភាពបរិបូរណ៍ សមស្របទាំងកាយ វាចា សតិអារម្មណ៍ ប្រាជ្ញាស្មារតី និងជីវភាពរស់នៅ។ ប្រធានខាងលើនេះមានន័យថា ចង់ឱ្យយើងផ្ទៀងផ្ទាត់ ប្រដូច ប្រៀបផ្ទឹមដើម្បីរកឱ្យឃើញពីលក្ខណៈដូចគ្នា លក្ខណៈខុសគ្នា និងលក្ខណៈល្អប្រសើរនៃភាពគ្រប់គ្រាន់ភាពបរិបូរណ៍ ភាពសមប្រកបទាំងកាយ វាចា ចិត្ត គំនិតសតិអារម្មណ៍ ប្រាជ្ញាស្មារតី និងជីវភាពរស់នៅរវាងតួអង្គប៊ុនធឿនក្នុងរឿងផ្កាស្រពោន និងតួអង្គចៅចិត្រក្នុងរឿងកុលាបប៉ៃលិន។

ពិតមែនហើយបើផ្អែកតាមដំណើររឿងតួអង្គទាំងពីរនេះមានលក្ខណៈដូចគ្នាត្រង់ប៊ុនធឿននិងចៅចិត្រ សុទ្ធតែជាកូនប្រុសកើតក្នុងត្រកូលកសិករ រស់នៅក្នុងខេត្តបាត់ដំបងដូចគ្នា។ ស្ថានភាពជីវភាព

គ្រួសារទាំងពីរមានលក្ខណៈប្រហាក់ប្រហែលគ្នាដែរ។ គេទាំងពីរនាក់ ជួបប្រទះការលំបាកក្នុងការរស់នៅដូចគ្នា។ ប៊ុនធឿន ជួបវិបត្តិរឿងគ្រួសាររកស៊ីខាតបង់ទ្រព្យសម្បត្តិអស់គ្មានសល់ ធ្លាក់ខ្លួនក្រដោយសារទូកដឹកទំនិញត្រូវលិចលង់។ ចំណែកថៅចិត្រវិញជួបវិបត្តិយ៉ាងធ្ងន់ធ្ងរដោយសារឪពុកស្លាប់ចោលរស់នៅតែឯងគ្មានទីពឹង។ អ្នកទាំងពីរសុទ្ធតែបានសិក្សារៀនសូត្រនៅសាលាដូចគ្នា។ ប៊ុនធឿនបានមករៀនសូត្រនៅភ្នំពេញ។ ចំណែកថៅចិត្រវិញ ក៏បានរៀនសូត្រជ្រៅជ្រះដែរ គឺទទួលបានប្រកាសនីយបត្រ។

បើប្រៀបធៀបលក្ខណៈខុសគ្នារវាងប៊ុនធឿន និងថៅចិត្រវិញ យើងឃើញថាទោះបីធ្លាក់ខ្លួនក្រពិតមែន តែប៊ុនធឿនបានរស់នៅជួបជុំគ្រួសារ។ ចំណែកថៅចិត្រវិញ កំព្រាឪពុកស្លាប់ចោលខំប្រឹងប្រែងរស់ដោយខ្លួនឯង។ ប៊ុនធឿនចង់ឈប់រៀនដើម្បីជួយការងារឪពុក តែឪពុកមិនព្រមក៏បានរៀនសូត្របន្តនៅវិទ្យាល័យព្រះស៊ីសុវត្ថិក្រុងភ្នំពេញ។ ចំណែកតួអង្គថៅចិត្រវិញ បានទៅរស់នៅស្រុកបប៉ៃលិន ធ្វើជាកម្មករជីកត្បូងដើម្បីរកប្រាក់ចិញ្ចឹមជីវិត។

អំពីបុគ្គលភាពរវាងតួអង្គប៊ុនធឿន និងថៅចិត្រគឺ ប៊ុនធឿនខ្វះសេចក្តីក្លាហាន មិនហ៊ានប្រឈមមុខនឹងឧបសគ្គផ្ទាល់ខ្លួន នៅពេលមានវិបត្តិកើតឡើងបែរជាគេចវេះ មិនហ៊ានចេញមុខដោះស្រាយ។ ជាក់ស្តែងក្នុងពេលមានវិបត្តិស្នេហាគឺនៅពេលយាយនួនផ្តាច់ពាក្យមិនឱ្យវិធាវីរៀបការជាមួយប៊ុនធឿន មិនបានចេញមុខដោះស្រាយឡើយ។ ប៊ុនធឿន បានគេចវេះពីបញ្ហា ហើយចេញទៅដើរកម្សាន្តក្នុងព្រៃនោម សប្បាយនឹងភ្លើងឆេះព្រៃទៅវិញ មិនគិតរកវិធីដោះស្រាយបញ្ហាឡើយ ទុកឱ្យបញ្ហាស្នេហារបស់ខ្លួនត្រូវព្រាត់ប្រាស់ ធ្វើឱ្យនាងវិធាវីឈឺចាប់រហូតដល់ស្លាប់។ ចំណែកតួអង្គថៅចិត្រវិញ ក្លាហានហ៊ានប្រឈមមុខជាមួយនឹងឧបសគ្គ គ្រប់បែបយ៉ាង ដើម្បីឱ្យស្នេហារបស់ខ្លួនបានសម្រេចដូចបំណង។ ថៅចិត្រទោះបីបានដឹងថា ខ្លួនមានវណ្ណៈទាប ហើយលួចស្រឡាញ់យុននារីដែលមានវណ្ណៈខ្ពស់ ពិតជាពិបាកសង្ឃឹមណាស់។ ដូចសម្តីពោលថា "...ខ្លួនទាបកុំគោងដៃខ្លីកុំឈោងស្រវាឱបភ្នំ..."។ ប៉ុន្តែថៅចិត្រមិនចុះចាញ់បញ្ហានេះទេ បែរជាខិតខំតស៊ូ ពុះពារការលំបាកគ្រប់ឧបសគ្គជាច្រើន រហូតធ្វើឱ្យយុននារីទន់ចិត្តប្រគល់បេះដូងឱ្យ។ ថៅចិត្រស៊ូទ្រាំធ្វើជាកម្មករជីកត្បូង ត្រូវយុននារីប្រើឱ្យយកអីវ៉ាន់មានម្ហូបអាហារជាដើម ដោយយួរផង លីផងនៅក្នុងផ្សារ ដែលកិច្ចការនេះបុរសខ្មែរយើងមិនងាយធ្វើទេ ហើយបើមានធ្វើគឺគេគិតថាជារឿងគួរឱ្យខ្មាសអៀន។ ក្នុងគ្រាអាសន្ន ថៅចិត្រហ៊ានប្តូរជីវិតប្រយុទ្ធជាមួយក្រុមចោរនៅក្នុងព្រៃ និងក្រុមចោរប្លន់នៅផ្ទះហ្លួងរតនសម្បត្តិ។

ស្នេហារបស់ប៊ុនធឿន និងវិធាវី ជួបវិបត្តិស្នេហាធ្ងន់ធ្ងរ ដោយសារម្តាយរបស់នាងវិធាវីប្រកាន់វណ្ណៈ មិនគោរពពាក្យសន្យា ពេលឃើញជីវភាពគ្រួសារប៊ុនធឿនធ្លាក់ខ្លួនក្រីក្រ លែងរាប់អាន ហើយក៏ផ្តាច់នាងវិធាវីមិនឱ្យរៀបការជាមួយប៊ុនធឿន និងចុងក្រោយបានក្លាយជាស្នេហាព្រាត់ស្លាប់ គឺតួអង្គនាងវិធាវីវិញត្រូវស្លាប់ទាំងក្មេងខ្ចីគួរឱ្យសង្វេគពន់ពេកណាស់។ ចំណែកឯសេចក្តីស្នេហារបស់ថៅចិត្រនិងយុននារីវិញ គឺជាស្នេហាផ្អែមល្ហែម មិនប្រកាន់វណ្ណៈ និងចុងក្រោយបានជួបជុំគ្នារស់នៅប្រកបដោយសុភមង្គល។

សរុបសេចក្តីមក តាមការបកស្រាយប្រៀបធៀបមកពីខាងលើនេះ តួអង្គប៊ុនធឿនមានលក្ខណៈដូចគ្នាជាមួយតួអង្គថៅចិត្រត្រង់ ស្ថានភាពគ្រួសារ ការរស់នៅ ការសិក្សា។ តួអង្គទាំងពីរ មានចំណុចខុសគ្នាត្រង់ ស្នេហារបស់ប៊ុនធឿនត្រូវព្រាត់ស្លាប់ ចំណែកស្នេហាថៅចិត្រត្រូវជួបជុំ។ ប៊ុនធឿនមិនហ៊ានប្រឈមមុខជាមួយនឹងឧបសគ្គ រីឯថៅចិត្រហ៊ានប្រឈមមុខគ្រប់បែបយ៉ាងជាមួយនឹងឧបសគ្គ។

ដូច្នេះយើងអាចវិនិច្ឆ័យបានថា តួអង្គចៅចិត្រក្នុងរឿងកុលាបប៉ៃលិន មានលក្ខណសម្បត្តិល្អប្រសើរជាងតួអង្គប៊ុនធឿនក្នុងរឿងផ្កាស្រពោន។

ប្រធានខាងលើពិតជាមានអត្ថន័យល្អ ព្រោះបានបង្ហាញឱ្យឃើញពីលក្ខណៈដូចគ្នា និងខុសគ្នារបស់តួអង្គក្នុងរឿងយ៉ាងច្បាស់លាស់ ធ្វើឱ្យអ្នកសិក្សាយល់កាន់តែស៊ីជម្រៅថែមទៀតទៅលើអត្ថន័យនៃស្នាដៃអក្សរសិល្ប៍ខ្មែរយើង។ ដូច្នេះក្នុងនាមយើងជាសិស្សានុសិស្សត្រូវខិតខំរៀនសូត្រក្រេបយកចំណេះដឹងឱ្យបានស៊ីជម្រៅទៅលើអក្សរសិល្ប៍ដើម្បីបានជាគំនិតសម្រាប់ជាមេរៀនបទពិសោធក្នុងការរស់នៅរបស់យើងបច្ចុប្បន្នក៏ដូចជាទៅថ្ងៃអនាគត។

---

**ប្រធានទី៤:** ចូរប្រៀបធៀបលក្ខណសម្បត្តិរបស់តួអង្គសូផាតក្នុងរឿងសូផាត និងតួអង្គប៊ុនធឿនក្នុងរឿងផ្កាស្រពោន ដោយលើកយកអំណះអំណាងមកបញ្ជាក់ឱ្យបានច្បាស់លាស់។

---

## គម្រោងតែង

### ក- សេចក្តីផ្តើម

- **លំនាំបញ្ហា:** និយាយទូទៅទាក់ទងទៅនឹងស្នាដៃអក្សរសិល្ប៍ខ្មែរ... ទាក់ទងនឹងតួអង្គក្នុងរឿងសូផាត និងតួអង្គក្នុងរឿងផ្កាស្រពោន ...
- **ចំណូលបញ្ហា(បង្ហាញបញ្ហា):** បញ្ចូលប្រធាន ...ប្រៀបធៀបលក្ខណសម្បត្តិរបស់តួអង្គសូផាតក្នុងរឿងសូផាត និងតួអង្គប៊ុនធឿនក្នុងរឿងផ្កាស្រពោន...
- **ចំណោទបញ្ហា:** ...តើតួអង្គទាំងពីរមានលក្ខណសម្បត្តិដូចគ្នា និងខុសគ្នាយ៉ាងណាខ្លះ...។

### ខ- តួសេចក្តី

- **ឃ្លាភ្ជាប់សេចក្តី:** មុននឹងឈានចូលដល់ការបកស្រាយប្រធាន យើងគប្បីយល់ន័យនៃពាក្យមួយចំនួនជាមុនសិន...។
- **ពន្យល់ពាក្យគន្លឹះ៖**
  - ✓ ប្រៀបធៀប: មានន័យថាផ្ទៀងផ្ទាត់ ប្រដូចគ្នា ប្រៀបផ្ទឹមអ្វីៗចាប់ពីពីរឡើងទៅ ដើម្បីរកឱ្យឃើញពីលក្ខណៈដូចគ្នា លក្ខណៈខុសគ្នា និងលក្ខណៈល្អប្រសើរ...
  - ✓ លក្ខណសម្បត្តិ: ភាពគ្រប់គ្រាន់ បរិបូរណ៍ ភាពសមប្រកប... ទាំងផ្លូវកាយចិត្តគំនិត សតិអារម្មណ៍ ប្រាជ្ញាស្មារតី និងជីវភាពរស់នៅ...។
- **ពន្យល់ន័យប្រធាន:** ចង់បង្ហាញពីការប្រៀបធៀប ប្រដូចគ្នា ប្រៀបផ្ទឹមអ្វីៗចាប់ពីពីរឡើងទៅ ដើម្បីរកឱ្យឃើញពីលក្ខណៈដូចគ្នា លក្ខណៈខុសគ្នា និងលក្ខណៈល្អប្រសើរជាងគ្នានៃភាពគ្រប់គ្រាន់ ភាពបរិបូរណ៍ ភាពសមប្រកបទាំងផ្លូវកាយ ចិត្តគំនិត សតិអារម្មណ៍ ប្រាជ្ញាស្មារតី និងជីវភាពរស់នៅរវាងតួអង្គសូផាតក្នុងរឿងសូផាត និងតួអង្គប៊ុនធឿនក្នុងរឿងផ្កាស្រពោន...។
- បកស្រាយប្រធាន៖
  - ▪ **លក្ខណៈដូចគ្នា៖**
  - ➢ តួអង្គសូផាត និងតួអង្គប៊ុនធឿន ជាអ្នកមានអត្តចរិត និងសីលធម៌ល្អ៖

- ✓ សូផាត ជាមនុស្សល្អ សុភាពរាបសារជាទីស្រឡាញ់ និងអាណិតរបស់អ្នកភូមិ ព្រះសង្ឃ ក្រុមគ្រួសារលោកសេនបតី ក្រុមគ្រួសារមេស្រុកសុខ...
- ✓ ប៊ុនធឿន ជាមនុស្សជាទីពេញចិត្តរបស់អ្នកភូមិផងជាមួយគ្នាតាំងពីលោកគ្រូ អ្នកគ្រូ ពិសេសគឺនាងវិធាវី...
- ➢ តួអង្គសូផាត និងតួអង្គប៊ុនធឿន ជាមនុស្សឧស្សាហ៍ព្យាយាមតស៊ូអត់ធ្មត់នឹងការលំបាកៈ
- ✓ សូផាត ជាក្មេងឧស្សហ៍ព្យាយាមខិតខំរៀនសូត្រ និងធ្វើកិច្ចការបម្រើព្រះសង្ឃ។ នៅពេលរស់នៅផ្ទះលោកសេនាបតីគេខំធ្វើការងារមិនឱ្យទាស់ចិត្តឡើយ...
- ✓ ប៊ុនធឿន តស៊ូព្យាយាមក្នុងការរៀនសូត្រ ទោះបីឪពុកម្តាយរបស់គេធ្លាក់ខ្លួនក្រក្នុងការធ្វើជំនួញក៏ដោយ ក៏គេនៅតែតស៊ូក្នុងជីវិត...
- ✓ តួអង្គសូផាត និងតួអង្គប៊ុនធឿន ចេះឈឺឆ្អាល និងជួយអ្នកដទៃ
- ✓ សូផាត ជួយយកអាសារណារិន ពីក្មេងធំៗដែលធ្វើបាបណារិន...
- ✓ ប៊ុនធឿន ជួយអ្នកស្រុកក្នុងការបណ្តេញចោរព្រៃ និងជួយពន្លត់ភ្លើងឆេះព្រៃ...
- ✓ តួអង្គសូផាត និងតួអង្គប៊ុនធឿន មានបុគ្គលភាពដូចគ្នាមិនហ៊ានប្រឈមមុខនឹងបញ្ហា មិនបានដោះស្រាយបញ្ហាពេលជួបឧបសគ្គ...

- ▪ **លក្ខណៈខុសគ្នាៈ**
- ✓ សូផាត ជាក្មេងកំព្រាឪពុកម្តាយ រស់នៅត្រាច់ចរគ្មានទីជម្រកច្បាស់លាស់។ ចំណែកប៊ុនធឿនរស់នៅជាមួយឪពុកម្តាយតាំពីតូចរហូតដល់ធំ...
- ✓ សូផាត ទទួលរងទុក្ខវេទនា តែទីបញ្ចប់ទទួលបានសុភមង្គល លោកសេនាបតីសារភាពប្រាប់ថាលោកជាឪពុករបស់ខ្លួន...
- ✓ ប៊ុនធឿន ចុងបញ្ចប់មិនបានទទួលសុភមង្គល សម្បីតែនារីដែលជាទីស្រឡាញ់របស់ខ្លួនក៏ត្រូវលាចាកលោកឆ្ងាយពីខ្លួនដែរ...
- ✓ ស្នេហារបស់សូផាត និងប៊ុនធឿនក៏នៅមានលក្ខណៈខុសគ្នាខ្លះដែរ។ ស្នេហារបស់ប៊ុនធឿន ...ចុងក្រោយត្រូវព្រាត់ស្លាប់...។ ចំណែកស្នេហារបស់សូផាតវិញ...ចុងក្រោយបានជួបជុំគ្នារស់នៅប្រកបដោយសុភមង្គល...។

- **សរុបសេចក្តីមក** តាមការបកស្រាយប្រៀបធៀបមកពីខាងលើនេះ តួអង្គសូផាត និងតួអង្គប៊ុនធឿន ពិតជាមានលក្ខណសម្បត្តិដូចគ្នាច្រើនតាំងពីស្ថានភាពគ្រួសារ ជីវភាពរស់នៅ អត្តចរិក ... ការឧស្សាហ៍ព្យាយាម ការសិក្សា  និងបុគ្គលភាព។ ចំណែកឯការរស់នៅ និងស្ថានភាពគ្រួសារមានលក្ខណៈខុសគ្នាបន្តិចបន្តួចតែប៉ុណ្ណោះ។ រីឯសេចក្តីស្នេហាវិញមានលក្ខណៈខុសគ្នា...។ ដូច្នេះតួអង្គទាំងពីរ... តែសូផាតមានអនាគតល្អជាង...។

## គ- សេចក្តីបញ្ចប់

- **វាយតម្លៃប្រធាន**: ដូច្នេះប្រធានខាងលើពិតជាមានអត្ថន័យល្អ ព្រោះបានបង្ហាញឱ្យឃើញពីលក្ខណៈដូចគ្នា និងខុសគ្នារបស់តួអង្គទាំងពីរបានច្បាស់លាស់ ធ្វើឱ្យយើងកាន់តែយល់ច្បាស់...
- **មតិផ្ទាល់ខ្លួន**: ក្នុងនាមយើងជាសិស្ស ត្រូវខិតខំរៀនសូត្រដើម្បីយកចំណេះដឹងពីអក្សរសិល្ប៍ទៅបម្រើសង្គម និងជីវភាពរស់នៅឱ្យកាន់តែមានភាពល្អប្រសើរ...។

# សេចក្តីអធិប្បាយ

មនុស្សរស់នៅក្នុងសង្គម តែងតែមានលក្ខណៈខុសៗគ្នា អ្នកខ្លះទទួលបានសុភមង្គលនិងសេចក្តីថ្លៃថ្នូរពេញមួយជីវិត។ ចំណែកឯអ្នកខ្លះទៀត ត្រូវទទួលរងទុក្ខវេទនាគ្មានថ្ងៃបញ្ចប់។ អាស្រ័យហេតុដូច្នេះហើយក្រោយពីបានសិក្សារឿងសូផាតដែលជាស្នាដៃរបស់លោក រីម គិន និងរឿងផ្កាស្រពោនដែលជាស្នាដៃរបស់លោក នូ ហាច រួចមក ទើបគេតម្រូវឱ្យយើង៖ "ប្រៀបធៀបលក្ខណសម្បត្តិរបស់តួអង្គសូផាតក្នុងរឿងសូផាត និងតួអង្គប៊ុនធឿនក្នុងរឿងផ្កាស្រពោន"។

តើតួអង្គទាំងពីរមានលក្ខណសម្បត្តិដូចគ្នា និងខុសគ្នាដូចម្តេចខ្លះ?

ដើម្បីជាជំនួយដល់ការបកស្រាយប្រធានខាងលើឱ្យបានក្បោះក្បាយ និងស៊ីជម្រៅនោះ ដំបូងយើងត្រូវពន្យល់ពាក្យគន្លឹះរបស់ប្រធានជាមុនសិនគឺពាក្យ "ប្រៀបធៀប លក្ខណសម្បត្តិ"។ ពាក្យប្រៀបធៀបមានន័យថាផ្ទៀងផ្ទាត់ ប្រដូចគ្នា ប្រៀបធ្ធឹមអ្វីៗចាប់ពីពីរឡើងទៅ ដើម្បីរកឱ្យឃើញពីលក្ខណៈដូចគ្នា លក្ខណៈខុសគ្នា និងលក្ខណៈល្អប្រសើរ។ ចំណែកឯពាក្យ លក្ខណសម្បត្តិ មានន័យថា គឺជាភាពគ្រប់គ្រាន់ ភាពបរិបូរណ៍ សមស្របទាំងកាយ វាចា សតិអារម្មណ៍ ប្រាជ្ញាស្មារតី និងជីវភាពរស់នៅ។ ប្រធានខាងលើនេះមានន័យថា ចង់ឱ្យយើងផ្ទៀងផ្ទាត់ ប្រដូច ប្រៀបធ្ធឹម ដើម្បីរកឱ្យឃើញពីលក្ខណៈដូចគ្នា លក្ខណៈខុសគ្នា និងលក្ខណៈល្អប្រសើរនៃភាពគ្រប់គ្រាន់ ភាពបរិបូរណ៍ ភាពសមប្រកបទាំងកាយ វាចា ចិត្ត គំនិតសតិអារម្មណ៍ ប្រាជ្ញាស្មារតី និងជីវភាពរស់នៅរបស់តួអង្គសូផាតក្នុងរឿងសូផាតនិងប៊ុនធឿនក្នុងរឿងផ្កាស្រពោន។

ពិតមែនហើយ បើវិភាគតាមដំណើររឿងយើងឃើញថា តួអង្គសូផាតនិងប៊ុនធឿនមានលក្ខណៈដូចគ្នាត្រង់គេទាំងពីរមានប្រវត្តិជូរចត់ក្នុងជីវិតដូចគ្នា។ សូផាតមានឪពុកជាអភិជន ហើយតែខ្លួនមិនស្គាល់ដោយសារតែគេត្រូវម្តាយស្លាប់ចោល ពុំបានរៀបរាប់ប្រាប់ការពិតដល់ខ្លួន ម្ល៉ោះហើយធ្វើឱ្យគេរស់នៅក្នុងជីវភាពលំបាកបំផុត។ ចំណែកឯប៊ុនធឿនវិញ ដំបូងឡើយក៏រស់នៅក្នុងត្រកូលអភិជនដែរ តែដោយសារឪពុករបស់ខ្លួនធ្វើជំនួញបរាជ័យ ត្រូវក្ស័យធនធ្លាក់ខ្លួនក្រ ធ្វើឱ្យយាយនួនដែលជាម្តាយនាងវិធាវីផ្តាច់ពាក្យចំណងអាពាហ៍ពិពាហ៍ពីពួកគេ។ ប៊ុនធឿនត្រូវជួបប្រទះគ្រោះកង្វះខាតសម្ភារៈសិក្សា បាត់បង់ស្មារតីសិក្សា និងសេចក្តីស្នេហារបស់ខ្លួន។

សូផាត និងប៊ុនធឿនជាក្មេងមានអត្តចរិត និងសីលធម៌ល្អដូចគ្នា។ សូផាតជាមនុស្សឧស្សាហ៍ ជាទីស្រឡាញ់និងក្តីអាណិតអាសូរពីអ្នកភូមិផងរបងជាមួយគ្នាដូចជាព្រះសង្ឃ ក្រុមគ្រួសារលោកសេនាបតីនិងមេស្រុកសុខថែមទៀត។ ចំណែកឯប៊ុនធឿនក៏ជាមនុស្ស ដែលជាទីពេញចិត្តរបស់អ្នកភូមិ ដែលរស់នៅជិតគ្នា។ ប៊ុនធឿនតែងតែជួយដល់អ្នកជិតខាង ជាពិសេសគេធ្វើឱ្យលោកគ្រូ អ្នកគ្រូពេញចិត្តចំពោះរូបខ្លួនថែមទៀតផង។

សូផាត និងប៊ុនធឿនជា មនុស្សឧស្សាហ៍ព្យាយាម តស៊ូ អត់ធ្មត់ ជម្នះរាល់ការលំបាកគ្រប់បែបយ៉ាងក្នុងជីវិតដូចគ្នា។ សូផាតជាក្មេងឧស្សាហ៍ណាស់ ពេលរស់នៅចេះផ្ញើប្រាណជាមួយព្រះសង្ឃក្នុងវត្តខិតខំរៀនសូត្រ និងធ្វើកិច្ចការបម្រើព្រះសង្ឃឥតឆ្អែង។ ចំណែកការសិក្សាវិញ កុមារនេះឧស្សាហ៍ព្យាយាមមិនខ្ជិចនឿយហត់។ ដោយសារតែការខិតខំប្រឹងប្រែងរៀនសូត្រនេះហើយទើប សូផាតក៏បានក្លាយទៅជាស្មៀនឃុំដ៏ចំណានរបស់មេឃុំសុខ។ ចំណែកឯប៊ុនធឿនវិញក៏មិនខុសគ្នាដែរ គេតស៊ូព្យាយាមរៀនសូត្រគ្រប់បែបយ៉ាងទោះបីស្ថានភាពគ្រួសារនេះ ត្រូវបានផ្លាស់ប្តូរពីមានមកក្រលំបាកក៏

ដោយ តែចិត្តតស៊ូព្យាយាមរបស់គេមិនរាថយឡើយ។ ប៊ុនធឿនមានបំណងរៀនដល់ថ្នាក់បញ្ចប់ដើម្បីជួយដោះស្រាយស្ថានភាពគ្រួសារឱ្យមានលក្ខណៈល្អប្រសើរឡើងវិញ។

សូផាតនិងប៊ុនធឿនជាមនុស្សចេះឈឺឆ្អាល និងជួយយកអាសាអ្នកដទៃដូចគ្នា។ សូផាតជួយយកអាសាណារិនពីក្មេងធំៗ ដែលព្រួតគ្នាធ្វើបាបណារិន។ ចំណែកឯប៊ុនធឿន ជាមនុស្សចេះជួយទុក្ខធុរៈអ្នកដទៃ ទោះបីការងារនោះត្រូវប្រឈមនិងគ្រោះថ្នាក់ក៏ដោយ។ ប៊ុនធឿនបានជួយបណ្តេញពួកចោរដែលមានបំណងចង់លួចគោអ្នកបរទេះ ព្រមទាំងជួយពន្លត់ភ្លើងឆេះព្រៃដើម្បីរក្សាធម្មជាតិឱ្យនៅខ្ចី និងស្រស់បំព្រង។

អំពីបុគ្គលភាពរវាងតួអង្គសូផាតនិងប៊ុនធឿនគឺមានលក្ខណៈប្រហាក់ប្រហែលគ្នា។ តួអង្គសូផាតនិងតួអង្គប៊ុនធឿន ជាមនុស្សខ្វះសេចក្តីក្លាហាន មិនហ៊ានប្រឈមនឹងឧបសគ្គផ្ទាល់ខ្លួន នៅពេលមានវិបត្តិកើតឡើងបែរជាគេចវេះ មិនហ៊ានចេញមុខដោះស្រាយ។ ជាក់ស្តែងក្នុងពេលជួបបញ្ហា សូផាតបានគេចវេះទៅលាក់ខ្លួន មិនបានចេញមុខដោះស្រាយឡើយ។ ចំពោះប៊ុនធឿនវិញក៏ដូច្នេះដែរ ក្នុងពេលមានវិបត្តិស្នេហា គឺនៅពេលយាយទួនផ្តាច់ពាក្យ មិនឱ្យវិធាវីរៀបការជាមួយ ប៊ុនធឿនមិនបានចេញមុខដោះស្រាយឡើយ គឺបានគេចវេះពីបញ្ហា ហើយចេញទៅដើរកម្សាន្តក្នុងព្រៃរនាម។

ទន្ទឹមនឹងមានលក្ខណសម្បត្តិជាច្រើនដូចគ្នាក៏ដោយ សូផាតនិងប៊ុនធឿនក៏នៅមានលក្ខណៈខុសគ្នាខ្លះៗដែរ។ សូផាត ជាក្មេងកំព្រាឪពុកតាំងពីកើតមកភ្លាម។ គេបានឆ្លងកាត់ការលំបាកគ្រប់បែបយ៉ាង តាំងពីរស់នៅជាមួយអ្នកស្រុក ព្រះសង្ឃ រស់នៅជាមួយលោកសេនាបតី ដោយមិនបានស្គាល់ថា ជាឪពុករបស់ខ្លួនផងនិងរស់នៅជាមួយអ្នកដទៃច្រើនទៀតរហូតដល់ទៅលាក់មុខនិងឈ្មោះរបស់ខ្លួនទៀត។ សូផាតកំព្រាឪពុកម្តាយតាំងពីក្មេង រស់នៅដូចចករសាត់តាមទឹក តែទីបញ្ចប់នៃរឿងគេត្រូវបានជួបជុំឪពុក ដែលសារភាពប្រាប់ត្រង់ពីរឿងពិតនៅចំពោះមុខ។ សូផាតជាមនុស្សម្នាក់ចេះកែប្រែស្ថានការណ៍និងមានទំនួលខុសត្រូវខ្ពស់ដូចជារត់គេចមុខពីម៉ានយ៉ានម្នាក់គត់។

ប៊ុនធឿន រស់នៅជាមួយឪពុកម្តាយតាំងពីតូចរហូតដល់ធំ ទោះបីគ្រួសាររបស់ខ្លួនបានធ្លាក់ខ្លួនក្រក៏ដោយ ក៏គេនៅមានឪពុកម្តាយជាទីបង្អែក ជាអ្នកជួយពិគ្រោះយោបល់ដែរ។ ប៊ុនធឿន ជាមនុស្សមិនមានទំនួលខុសត្រូវ  ព្រោះនៅពេលនាងវិធាវីប្រាប់ការពិតដល់ខ្លួនថា ម្តាយនាងលើកនាងឱ្យទៅណៃស៊ិត ស្រាប់តែប៊ុនធឿនរត់គេចមុខពីនាង មិនគិតជួយរកមធ្យោបាយដោះស្រាយជាមួយនាងរហូតទុកឱ្យនាងក្រំចិត្តឈឺស្លាប់តែម្នាក់ឯង។

ស្នេហារបស់សូផាតនិងប៊ុនធឿនក៏នៅមានលក្ខណៈខុសគ្នាខ្លះដែរ។ ស្នេហារបស់ប៊ុនធឿនមានវិបត្តិធ្ងន់ណាស់គឺចុងក្រោយត្រូវព្រាត់ស្លាប់។ ចំណែកស្នេហារបស់សូផាតវិញមានលក្ខណៈល្អប្រសើរចុងក្រោយបានជួបជុំគ្នារស់នៅប្រកបដោយសុភមង្គល។

រួមសេចក្តីមក ការបកស្រាយខាងលើយើងឃើញថាតួអង្គសូផាតក្នុងរឿងសូផាត ដែលជាស្នាដៃរបស់លោក រីម គិន និងតួអង្គប៊ុនធឿនក្នុងរឿងផ្កាស្រពោនជាស្នាដៃរបស់លោក នូ ហាច ពិតជាមានលក្ខណសម្បត្តិដូចគ្នាច្រើនតាំងពីស្ថានភាពគ្រួសារ ជីវភាពរស់នៅ ការឧស្សាហ៍ព្យាយាម អត្តចរិកសីលធម៌ សន្តានចិត្ត ការសិក្សា និងបុគ្គលភាពពិតជាមានលក្ខណៈដូចគ្នា។ ចំណែកឯការរស់នៅ និងស្ថានភាពគ្រួសារមានលក្ខណៈខុសគ្នាបន្តិចបន្តួចតែប៉ុណ្ណោះ។ រីឯសេចក្តីស្នេហាវិញមានលក្ខណៈខុស

គ្នាខ្លាំង។ ដូច្នេះតួអង្គទាំងពីរមានបុគ្គលភាពប្រហាក់ប្រហែលគ្នា តែសូផាតទទួលបានអនាគតប្រសើរជាងប៊ុនធឿន។

ដូច្នេះប្រធានខាងលើពិតជាមានអត្ថន័យល្អ ព្រោះបានបង្ហាញឱ្យឃើញពីលក្ខណៈដូចគ្នា និងខុសគ្នារបស់តួអង្គទាំងពីរបានច្បាស់លាស់ធ្វើឱ្យអ្នកសិក្សាកាន់តែយល់ច្បាស់ស៊ីជម្រៅទៅលើអត្ថន័យអក្សរសិល្ប៍របស់ខ្មែរយើង។ ក្នុងនាមយើងជាសិស្សានុសិស្ស ត្រូវខិតខំរៀនសូត្រដើម្បីយកចំណេះដឹងពីអក្សរសិល្ប៍ទៅបម្រើសង្គម និងជីវភាពរស់នៅឱ្យកាន់តែមានភាពល្អប្រសើរ។

**ប្រធានទី៥:** ចូរសិក្សាប្រៀបធៀបលក្ខណសម្បត្តិរបស់តួអង្គធនញ្ជ័យក្នុងរឿងធនញ្ជ័យនិងតួអង្គទីឃាវុធក្នុងរឿងមាលាដួងចិត្តដែលប្អូនបានសិក្សាកន្លងមកហើយ។

## គម្រោងតែង

### ក- សេចក្ដីផ្ដើម

- **លំនាំបញ្ហា:** និយាយទូទៅទាក់ទងទៅនឹងស្នាដៃអក្សរសិល្ប៍ខ្មែរ... ទាក់ទងនឹងតួអង្គធនញ្ជ័យក្នុងរឿងធនញ្ជ័យ និងតួអង្គទីឃាវុធក្នុងរឿងមាលាដួងចិត្ត...
- **ចំណូលបញ្ហា(បង្ហាញបញ្ហា):** បញ្ចូលប្រធាន ...ប្រៀបធៀបលក្ខណសម្បត្តិរបស់តួអង្គធនញ្ជ័យក្នុងរឿងធនញ្ជ័យ និងតួអង្គទីឃាវុធក្នុងរឿងមាលាដួងចិត្ត...
- **ចំណោទបញ្ហា:** ... តើតួអង្គទាំងពីរមានលក្ខណសម្បត្តិដូចគ្នា និងខុសគ្នាយ៉ាងណាខ្លះ...។

### ខ- តួសេចក្ដី

- **ឃ្លាភ្ជាប់សេចក្ដី:** មុននឹងឈានចូលដល់ការបកស្រាយប្រធាន យើងគប្បីយល់ន័យនៃពាក្យមួយចំនួនជាមុនសិន...។
- **ពន្យល់ពាក្យគន្លឹះ៖**
  - ✓ ប្រៀបធៀប: មានន័យថាផ្ទៀងផ្ទាត់ ប្រដូចគ្នា ប្រៀបផ្ទឹមអ្វីៗចាប់ពីពីរឡើងទៅ ដើម្បីរកឱ្យឃើញពីលក្ខណៈដូចគ្នា លក្ខណៈខុសគ្នា និងលក្ខណៈល្អប្រសើរ...
  - ✓ លក្ខណសម្បត្តិ: ភាពគ្រប់គ្រាន់ បរិបូរណ៍ ភាពសមប្រកប... ទាំងផ្លូវកាយចិត្តគំនិត សតិអារម្មណ៍ ប្រាជ្ញាស្មារតី និងជីវភាពរស់នៅ...។
- **ពន្យល់ន័យប្រធាន:** ចង់បង្ហាញពីការប្រៀបធៀប ប្រដូចគ្នា ប្រៀបផ្ទឹមអ្វីៗចាប់ពីពីរឡើងទៅដើម្បីរកឱ្យឃើញពីលក្ខណៈដូចគ្នា លក្ខណៈខុសគ្នា និងលក្ខណៈល្អប្រសើរជាងគ្នានៃភាពគ្រប់គ្រាន់ ភាពបរិបូរណ៍ ភាពសមប្រកបទាំងផ្លូវកាយ ចិត្តគំនិត សតិអារម្មណ៍ ប្រាជ្ញាស្មារតី និងជីវភាពរស់នៅរវាងតួអង្គធនញ្ជ័យក្នុងរឿងធនញ្ជ័យ និងតួអង្គទីឃាវុធក្នុងរឿងមាលាដួងចិត្ត...។
- បកស្រាយប្រធាន៖
  - ▪ **លក្ខណៈដូចគ្នារវាងធនញ្ជ័យ និងតួអង្គទីឃាវុធ៖**
  - ✓ បុរសស្រឡាញ់សច្ចភាព...
  - ✓ មានឧត្តមគតិស្នេហាជាតិដូចគ្នាធនញ្ជ័យស្អប់ការជិះជាន់...ចិន...មើលមុខ...បូណ៌មី...ជួយដោះស្រាយ...។ ទីឃាវុធស្អប់...ថៃចង់ទាមទារផ្ដាច់ខេត្ត...ជាទាហាន...

- ✓ មានឆន្ទៈតស៊ូព្យាយាម...រៀនសូត្រការងារមិនបោះបង់...សម្រេចដូចប្រាថ្នា។ ធនញ្ជ័យធ្វើការ... លក់នំបញ្ចុក... គុកសំរឹទ្ធ...មកស្រុក។ ...រីឯទិយាវុធដកតំណែងជា...ត្រួតពន្ធតាមស្រុក... ទាហាន...របួស...ចៅហ្វាយខេត្តបាត់ដំបង...
- ✓ ចំពោះបញ្ហាស្នេហា... សុទ្ធតែជ្រើសរើសនារីដែលខ្លួនស្រឡាញ់ដូចគ្នា... ធនញ្ជ័យមិនយកនារីនៅក្នុងវាំង រើសយកនាងសួស្ដី...រីឯទីយាវុធ...នាងច័ន្ទមណី...ថៃ...ជ្រោយស្ពៅប្រលោមលោក...។

- **លក្ខណៈខុសគ្នារវាងធនញ្ជ័យ និងតួអង្គទីយាវុធ៖**

***ធនញ្ជ័យ៖***

- ✓ ចរិតលក្ខណៈប្រកបដោយភាពកំប្លែងបែបចំអក...ចម្លើយផ្សេងគ្នា...
- ✓ ដំណោះស្រាយចំអក កុហក ទ័លច្រក លោតទឹក... ឈ្លាសវៃ...
- ✓ ប្រភពជាកូន...ទៅបម្រើសេដ្ឋី...
- ✓ ជាអ្នកប្រាជ្ញប្រចាំនគរ...
- ✓ ប្រវត្តិធ្លាប់និរទេសទៅប្រទេសចិន ជាប់គុក ធ្វើខ្លែងដាក់ឯក...
- ✓ សម័យកាលនោះមានទំនាក់ទំនងជាមួយចិន...
- ✓ ការរងគ្រោះព្រោះតែមាត់...ជាអាថិកំបាំង...
- ✓ ចុងក្រោយស្លាប់...។

***ទីយាវុធ៖***

- ✓ ប្រាកដប្រជាហ្មត់ចត់...គិតពីសមូហភាព...ខោអាវ...
- ✓ តស៊ូព្យាយាម...ប្រយុទ្ធ...អយុត្តិធម៌...លះបង់...ទាហាន...
- ✓ ជាកូន...បានរៀន...ការងារជាលោកបាល័ដ្ឋ...ចៅហ្វាយស្រុកសសរស្ដម្ភ...
- ✓ ត្រូវចៅហ្វាយខេត្តពោធិ៍សាត់ដកដំណែង...
- ✓ អាណានិគមបារាំង...ប្រយុទ្ធសៀម ជប៉ុន...
- ✓ មិនទទួលសំណូកពីចៅកែហុងឈី...
- ✓ ជោគជ័យដោយកិត្តិយស និងស្នេហា...។

- **សរុប**: តួអង្គធនញ្ជ័យក្នុងរឿងធនញ្ជ័យ និងតួអង្គទីយាវុធក្នុងរឿងមាលាដួងចិត្ត ពិតជាមានលក្ខណសម្បត្តិដូចគ្នាជាច្រើនដូចជា ស្ថានភាពគ្រួសារ ជីវភាពរស់នៅ...ស្មារតីស្នេហាជាតិ...ការលះបង់... ស្រឡាញ់សច្ចភាព យុត្តិធម៌...ស្អប់ខ្ពើមអំពើឈ្លានពាន... បញ្ហាស្នេហា...។ លក្ខណៈខុសគ្នាដូចជា ... ធនញ្ជ័យមានចរិកលក្ខណៈកំប្លែងបែបចំអក ដំណោះស្រាយចំអក... បម្រើសេដ្ឋី ធ្លាប់និរទេសទៅប្រទេសចិនជាប់គុក...គ្រោះព្រោះតែមាត់ អ្នកប្រាជ្ញប្រចាំនគរ ចុងក្រោយស្លាប់...។ ទីយាវុធ... ប្រាកដប្រជាហ្មត់ចត់...គិតពីសមូហភាព... ស្អប់ខ្ពើមអំពើពុករលួយ ស្រឡាញ់យុត្តិធម៌ អ្នកមានចំណេះដឹង ...ចុងក្រោយទទួលជោគជ័យ...។ ដូច្នេះយើងអាចវិនិច្ឆ័យបានថា តួអង្គធនញ្ជ័យក្នុងរឿងធនញ្ជ័យមានលក្ខណៈខ្ពស់ជាងតួអង្គទីយាវុធក្នុងរឿងមាលាដួងចិត្ត។

## គ- សេចក្ដីបញ្ចប់

- **វាយតម្លៃប្រធាន**: ...ការប្រៀបធៀបតួអង្គ...ល្អព្រោះ...ឱ្យចេះវិភាគប្រៀបធៀបស្គាល់...ដើម្បីការរស់នៅប្រកបដោយ...

- **យោបល់ផ្ទាល់ខ្លួនៈ** ...យើងគួរនាំគ្នាស្វ័យសិក្សាបន្ថែមលើមុខវិជ្ជានានា ជាពិសេសស្នាដៃអក្សរសិល្ប៍ជាតិ អន្តរជាតិ ដើម្បីពង្រីកចំណេះដឹងឱ្យកាន់តែទូលំទូលាយ...។

## សេចក្តីអធិប្បាយ

ក្រោយពីបានសិក្សាអត្ថបទអក្សរសិល្ប៍រឿងធនញ្ជ័យរួចមក យើងឃើញថាតួអង្គធនញ្ជ័យជាតួអង្គមានប្រាជ្ញាលេចធ្លោធ្វើមាតុភូមិ។ ទន្ទឹមនឹងគ្នានោះដែររឿងមាលាដួងចិត្តដែលជាវណ្ណកម្មមួយរបស់ លោកនូ ហាច តួអង្គទីឃាវុធ ជាតួអង្គលេចធ្លោផងដែរ។ ដោយសារតែតួអង្គទាំងពីរមានវិសេសភាពនេះហើយ ទើបមានមតិប្រធានមួយបង្គាប់មកឱ្យយើងៈ "ប្រៀបធៀបលក្ខណសម្បត្តិតួអង្គធនញ្ជ័យនិងតួអង្គទីឃាវុធក្នុងរឿងមាលាដួងចិត្ត"។

តើតួអង្គធនញ្ជ័យនិងតួអង្គទីឃាវុធមានលក្ខណសម្បត្តិដូចគ្នានិងដោយឡែកពីគ្នាយ៉ាងណាខ្លះ?

ដើម្បីជាជំនួយក្នុងការបកស្រាយប្រៀបធៀបលើតួអង្គទាំងពីរតាមគំនិតប្រធាន យើងគប្បីយល់អត្ថន័យកន្សោមពាក្យគន្លឹះជាមុនសិនគឺពាក្យ "ប្រៀបធៀប លក្ខណសម្បត្តិ "។ ពាក្យប្រៀបធៀបមានន័យថាផ្ទៀងផ្ទាត់ ប្រដូចគ្នា ប្រៀបផ្ទឹមអ្វីៗចាប់ពីពីរឡើងទៅដើម្បីរកឱ្យឃើញពីលក្ខណៈដូចគ្នា លក្ខណៈខុសគ្នានិងលក្ខណៈល្អប្រសើរ។ ចំណែកឯពាក្យលក្ខណសម្បត្តិមានន័យថាគឺជាភាពគ្រប់គ្រាន់ភាពបរិបូរណ៍ សមស្របទាំងកាយ វាចា សតិអារម្មណ៍ ប្រាជ្ញាស្មារតី និងជីវភាពរស់នៅ។ ប្រធានខាងលើនេះមានន័យថា ចង់ឱ្យយើងផ្ទៀងផ្ទាត់ ប្រដូច ប្រៀបផ្ទឹមដើម្បីរកឱ្យឃើញពីលក្ខណៈដូចគ្នា លក្ខណៈខុសគ្នា និងលក្ខណៈល្អប្រសើរនៃភាពគ្រប់គ្រាន់ ភាពបរិបូរណ៍ ភាពសមប្រកបទាំងកាយ វាចា ចិត្តគំនិតសតិអារម្មណ៍ ប្រាជ្ញាស្មារតី និងជីវភាពរស់នៅរបស់តួអង្គធនញ្ជ័យក្នុងរឿងធនញ្ជ័យ និងតួអង្គទីឃាវុធក្នុងរឿងមាលាដួងចិត្ត។

ជាការពិតណាស់អ្វីក៏ដោយមិនថាវត្ថុ សត្វ មនុស្សនោះទេ គឺសុទ្ធតែមានចំណុចរួមគ្នានិងខុសគ្នាជានិច្ច គ្រាន់តែតិច ឬច្រើន។ យ៉ាងណាមិញតួអង្គឯកក្នុងស្នាដៃអក្សរសិល្ប៍ខ្មែរយើងក៏យ៉ាងនោះដែរ។

តួអង្គធនញ្ជ័យនិងតួអង្គទីឃាវុធមានចំណុចដូចគ្នាត្រង់ អ្នកទាំងពីរសុទ្ធតែជាបុរសដែលស្រឡាញ់សច្ចភាព យុត្តិធម៌ដូចគ្នា។ លើសពីនេះ មានឧត្តមគតិស្នេហាជាតិពុះពោរ ហ៊ានលះបង់អ្វីៗគ្រប់បែបយ៉ាងដូចៗគ្នា។ ធនញ្ជ័យស្អប់ការជិះជាន់របស់ពួកអ្នកមានទ្រព្យសម្បត្តិដូចជាសេដ្ឋី និងពួកអ្នកមានអំណាចជាពិសេសពួកបរទេសដែលចង់យកប្រទេសខ្មែរជាចំណុះ។ ទោះជាទៅនៅបរទេសនៅតែសរសើរជាតិខ្មែរ។ ដូចសម្តីធនញ្ជ័យលើកឡើងថា មើលមុខស្តេចចិនដូចមុខឆ្កែ មើលមុខស្តេចខ្មែរដូចខែពេញបូរណ៌មី។ ចំណែកឯទីឃាវុធវិញ ស្អប់ខ្ពើមអំពើពុករលួយ មិនចង់ឱ្យសៀមទាមទារយកខេត្តជាទីស្រលាញ់ដោយចូលធ្វើទាហានច្បាំងនឹងសៀម។ ទោះបីជាច័ន្ទមណីខាងកាកបាទក្រហមជួយព្យាបាលរបួសជាសះស្បើយនៅក្នុងទឹកដីសៀមហើយក៏ដោយ ក៏នៅតែស្អប់ជាតិសាសន៍នោះដែរ។

តួអង្គទាំងពីរ មានឆន្ទៈព្យាយាមតស៊ូរៀនសូត្រធ្វើការងារជានិច្ច មិនបោះបង់គោលបំណងរបស់ខ្លួននោះទេ ស៊ូទ្រាំនឹងការលំបាកដូចជាធនញ្ជ័យ លក់នំបញ្ចុក ជាប់គុកសំរិទ្ធរហូតបានមកស្រុកខ្មែរវិញដូចពាក្យផ្តាំផ្ញើតាមអ្នកសំពៅឱ្យមកប្រាប់ប្រពន្ធខ្លួននោះ។ ចំណែកទីឃាវុធវិញស៊ូឱ្យគេដកតំណែងជាបាល័ដ្ឋខេត្ត ហើយលះបង់តំណែងជាបន្តបន្ទាប់ចូលធ្វើទាហានរងរបួសនៅពេលប្រយុទ្ធនៅតាមព្រំដែនរហូតបានតំណែងជាចៅហ្វាយស្រុកសសរស្តម្ភ និងក្រោយមកបានជាចៅហ្វាយខេត្តបាត់ដំបង។ ចំពោះបញ្ហាស្នេហាវិញ អ្នកទាំងពីរសុទ្ធតែបានជ្រើសរើសនារីដែលខ្លួនស្រឡាញ់ធ្វើជាភរិយាដោយខ្លួន

ឯង គឺធនញ្ជ័យមិនយកនារីក្នុងវាំងដែលស្តេចប្រទានឱ្យនោះទេ គឺសុខចិត្តដើររើសយកនាងសូស្ដីជាភរិយា។ ចំណែកទីឃាវុធវិញ ក៏ជ្រើសយកនាងច័ន្ទមណីបុត្រីរបស់លោកទេពកោសល្ល ដែលបានមករស់នៅតំបន់មួយក្នុងខេត្តបាត់ដំបងនោះដែរ។

ទន្ទឹមនឹងគ្នានេះ តួអង្គទាំងពីរក៏មានភាពខុសគ្នាមួយចំនួនគួរឱ្យកត់សម្គាល់នោះដែរ ដោយសារធនញ្ជ័យជាតួអង្គក្នុងអក្សរសិល្ប៍ប្រជាប្រិយ ម្ល៉ោះហើយក៏មានលក្ខណៈមួយដោយឡែកពីទីឃាវុធជាតួអង្គឧត្តមគតិនិយម តាមបែបប្រលោមលោកសម័យទំនើបផងដែរ។

លើផ្នែកចរិតលក្ខណៈរបស់ធនញ្ជ័យប្រកបដោយភាពកំប្លែង បង្កើតបានហាសរសក្នុងរឿងតែហាសវិធីនោះបែបចំអកដូចជាការផ្តល់ចម្លើយប្រស្នាជាមួយអ្នកប្រាជ្ញចិន។ រីឯទីឃាវុធមានភាពប្រាកដនិយមប្រកបដោយការពិចារណាដូចជា គិតពីប្រយោជន៍សមូហភាពទាក់ទងនឹងសម្លៀកបំពាក់ឯកសណ្ឋានប៉ូលិសស៊ូមិនយកសំណូករបស់ថៅកែហុងឈីឡើយ។ ចំពោះការដោះស្រាយបញ្ហាធនញ្ជ័យច្រើនប្រើវិធីចំអក កុហក ដោយភាពទាល់ច្រកដូចជាយករបស់ស្រាលៗ លោតទឹកសម្លាប់ខ្លួន ដោយចៃដន្យ ប្រើអក្សរជើងក្ដាមជាដើម។ តែទីឃាវុធវិញ ដោះស្រាយបញ្ហាដោយយកសច្ចភាព ច្បាប់ជាគោល និងចូលប្រយុទ្ធក្នុងការធ្វើសង្គ្រាមនៅសមរភូមិមុខ។ រីឯធនញ្ជ័យ គឺកើតចេញពីកូនអ្នកស្រុកត្រូវបានម្ដាយយកឱ្យទៅនៅបម្រើផ្ទះសេដ្ឋី តាមទំនាយហោរ។ ធនញ្ជ័យ មានតំណែងជាអ្នកប្រាជ្ញប្រចាំនគរ។ រីឯទីឃាវុធបានរៀនសូត្រក្នុងសាលាចេះដឹង មានតំណែងជាបាល័ដ្ឋខេត្ត។ ដោយឡែកប្រវត្តិធនញ្ជ័យ ធ្លាប់ត្រូវព្រះរាជានិរទេសទៅស្រុកចិន ហើយជាប់គុកនៅទីនោះព្រោះតែសម្ដីរបស់ខ្លួន។ ចំណែកទីឃាវុធវិញមិនមែនបែបនោះឡើយ គឺមុខងារតំណែងតួនាទីក្នុងសង្គម ត្រូវផ្លាស់ប្តូរដោយសារស្ថានភាពសង្គម និងសមត្ថភាពទៅវិញ។ រីឯសម័យកាលស្រុកទេស ធនញ្ជ័យរស់នៅក្នុងសម័យមួយដែលខ្មែរមានទំនាក់ទំនងនឹងចិន ហើយចិនចង់យកខ្មែរជាចំណុះ តែត្រូវបានធនញ្ជ័យចេញមុខដោះស្រាយបានរហូតឱ្យផុតពីចំណុះចិន។ ចំណែកទីឃាវុធវិញ រស់ក្នុងសម័យអាណានិគមនិយមបារាំងជាពិសេសចំពេលដែលជប៉ុនចូលស្រុក កាត់ផ្ដាច់ខេត្តប៉ៃកខាងលិចឱ្យទៅសៀមគ្រប់គ្រង។ លុះក្រោយសង្គ្រាមលោកលើកទីពីរបារាំងទាមទារវាយរុញច្រានជប៉ុន ទើបបានខេត្តទាំងបីនោះមកវិញ។ ដោយឡែកលទ្ធផលនៃតួអង្គទាំងពីរនេះក៏ខុសគ្នាដែរ គឺធនញ្ជ័យក្រោយពេលត្រឡប់មកដល់ស្រុកខ្មែរវិញធ្លាក់ខ្លួនឈឺជាទម្ងន់រហូតឱ្យប្រពន្ធទៅទូលស្តេចឱ្យយាងមក ហើយផ្ដាំផ្ញើនូវពាក្យថា «បើសោយត្រីព្រលកុំចោលស្រកា បើសោយត្រីប្រាកុំចោលស្រកី បើស្លម្ជូរក្បាលត្រីត្រូវដាក់ម្ជូរសណ្ដាន់» ដល់ព្រះរាជាមុនពេលស្លាប់ទុកជាប្រស្នាអាថ៌កំបាំងរហូតដល់សព្វថ្ងៃ។ រីឯទីឃាវុធវិញ ចុងបញ្ចប់បានជោគជ័យប្រកបដោយកិត្តិយស ជាចៅហ្វាយខេត្ត និងមានស្នេហារស់នៅដោយសុភមង្គល។

ជារួមមកវិញតួអង្គធនញ្ជ័យ និងតួអង្គទីឃាវុធពិតជាមានចំណុចរួមដូចគ្នា ដែលមានឧត្តមគតិស្នេហាជាតិហ៊ានលះបង់ប្រយោជន៍ខ្លួនដោយឥតស្ដាយស្រណោះ។ ចំណែកឯភាពខុសគ្នាវិញ គឺសម័យកាលនៃការរស់នៅរបស់តួអង្គទាំងពីរដែលនាំឱ្យមានចរិកលក្ខណៈ ការប្រព្រឹត្តនាំឱ្យកើតជាការរងគ្រោះក្នុងដំណើរជិវិត ព្រមទាំងជោគជ័យផងនោះ។

សរុបសេចក្តីមក តួអង្គធនញ្ជ័យក្នុងរឿងធនញ្ជ័យ និងតួអង្គទីឃាវុធក្នុងរឿងមាលាដួងចិត្ត ពិតជាមានលក្ខណសម្បត្តិប្រហាក់ប្រហែលគ្នាជាច្រើនដូចជាស្ថានភាពគ្រួសារ ជីវភាពរស់នៅ ស្មារតីស្នេហាជាតិការលះបង់ ស្រឡាញ់សច្ចភាព យុត្តិធម៌ ស្អប់ខ្ពើមអំពើឈ្លានពាន និងបញ្ហាស្នេហាជាដើម។ ទន្ទឹមនឹងលក្ខណៈដូចក៏នៅមានលក្ខណៈខុសគ្នាខ្លះដែរដូចជា ធនញ្ជ័យមានចរិលក្ខណៈកំប្លែងបែបចំអក

ដំណោះស្រាយចំអក កុហក បម្រើសេដ្ឋី ធ្លាប់និរទេសទៅប្រទេចិន ជាប់គុក គ្រោះព្រោះតែមាត់ អ្នកប្រាជ្ញប្រចាំនគរ និងចុងក្រោយទទួលមរណភាព។ ចំណែកទីឃាវុធវិញ ជាតួអង្គមានលក្ខណៈប្រាកដប្រជា ហ្មត់ចត់ គិតពីសមូហភាព តស៊ូព្យាយាម ស្អប់ខ្ពើមអំពើពុករលួយ ស្រឡាញ់យុត្តិធម៌ អ្នកមានចំណេះដឹង ចុងក្រោយទទួលបានជោគជ័យ រស់នៅប្រកបដោយសុភមង្គល។ ដូច្នេះយើងអាចវិនិច្ឆ័យបានថា តួអង្គធនញ្ជ័យក្នុងរឿងធនញ្ជ័យមានលក្ខណៈខ្ពស់ជាងតួអង្គទីឃាវុធក្នុងរឿងមាលាដួងចិត្ត។

ឆ្លងតាមការបកស្រាយប្រៀបធៀបលើតួអង្គទាំងពីរខាងលើរួចមកធ្វើឱ្យយើងទទួលបានបទពិសោធល្អក្នុងការចេះប្រៀបធៀបតួអង្គក៏ដូចជាបុគ្គល គំនិត ទស្សនៈផ្សេងៗ ដើម្បីជាទុនក្នុងការវិភាគ និងការរស់នៅប្រកបដោយសុភមង្គលបានក្នុងជីវិត។ ទន្ទឹមនឹងគ្នានេះ យើងគួរនាំគ្នាស្វ័យសិក្សាបន្ថែមលើមុខវិជ្ជានានា។ ជាពិសេសស្នាដៃអក្សរសិល្ប៍ជាតិ និងអន្តរជាតិ ដើម្បីពង្រីកចំណេះដឹងឱ្យកាន់តែទូលំទូលាយ ជាសសរទ្រូងរបស់ជាតិ។

# ១៥- អត្ថបទគំរូតែងសេចក្តី

## ១៥.១- អត្ថបទគំរូតែងសេចក្តីបែបពិពណ៌នាពីពិធីផ្សេងៗ

(ពិន្ទុ៦០ រយៈពេល៩០នាទី)

**ក- សេចក្តីផ្តើម** (១០ពិន្ទុ)

- ពណ៌នាទូទៅទាក់ទងនឹងពិធី ...
- ពេលវេលាធ្វើពិធី ...
- ទីកន្លែងធ្វើពិធី ...
- ឈ្មោះពិធី និងគោលបំណងនៃការធ្វើពិធី ...។

**ខ- តួសេចក្តី** (៣៥ពិន្ទុ)

*មុនពេលប្រារព្ធពិធី៖*

- ការរៀបចំទីកន្លែង ...
- ការរៀបចំអ្នកចូលរួម ...

*ពេលប្រារព្ធពិធី៖*

- ទិដ្ឋភាពពេលចាប់ផ្តើមប្រារព្ធពិធី ...
- ទិដ្ឋភាពពេលកំពុងប្រារព្ធពិធី ...
- ទិដ្ឋភាពចុងបញ្ចប់នៃការប្រារព្ធពិធី...

*ក្រោយពេលប្រារព្ធពិធី៖*

- ការថ្លែងអំណរគុណចំពោះអ្នកចូលរួម ...
- ការរៀបចំសម្អាតទីកន្លែង ...។

**គ- សេចក្តីបញ្ចប់** (១០ពិន្ទុ)

- បង្ហាញពីចំណាប់អារម្មណ៍របស់អ្នក ឬមនុស្សទូទៅចំពោះពិធីនោះ ...។

**ឃ- វចនាបថ** (០៥ពិន្ទុ)

(០២ពិន្ទុ)- ទម្រង់តែងសេចក្តី

(០១ពិន្ទុ)- ឃ្លា ល្បះ ខណ្ឌសញ្ញា អក្ខរាវិរុទ្ធ
(០១ពិន្ទុ)- ការចុះបន្ទាត់
(០១ពិន្ទុ)- អក្សរស្អាត។

## ១៥.២- អត្រាកំណែការសរសេរសំបុត្រសួរសុខទុក្ខ

(ពិន្ទុ៦០ រយៈពេល៩០នាទី)

**ក- ផ្នែកខាងក្រៅ** (ស្រោមសំបុត្រ)

*កាខ្នងសំបុត្រ(០៨ពិន្ទុ)*

- ចេញពី(ឈ្មោះអ្នកផ្ញើ) ...
- អាសយដ្ឋាន ...
- គោរពជូន ឬជូនចំពោះ(ឈ្មោះអ្នកទទួល) ...
- អាសយដ្ឋាន ...។

**ខ- ផ្នែកខាងក្នុង** (តួសំបុត្រ)

*ក្បាលសំបុត្រ(០៦ពិន្ទុ)*

- ចុះទីកន្លែង ចុះកាលបរិច្ឆេទនៃការសរសេរ ...
- ចំណងជើងសំបុត្រ ...។

*តួសំបុត្រ(៣៥ពិន្ទុ)*

- រៀបរាប់ពីសុខទុក្ខអ្នកសរសេរ ...
- សួរសុខទុក្ខអ្នកដែលទទួលសំបុត្រ ...
- សរសេររៀបរាប់រឿងរ៉ាវផ្សេងៗមានដូចជា ដំណឹង ការសប្បាយ ទុក្ខព្រួយ ដំបូន្មាន សេចក្តីនឹករឭក សកម្មភាពផ្សេងៗ...។

*ការបញ្ចប់សំបុត្រ(០៦ពិន្ទុ)*

- ជូនពរ(ត្រូវប្រើពាក្យឱ្យបានសមស្របតាមកាលៈទេសៈ) ...
- ជូនកាលអាចភ្ជាប់ឃ្លាបញ្ចប់សំបុត្រដូចជា ពីកូនកម្សត់របស់ម៉ែ នឹកជានិរន្តរ៍ ...
- ទីបញ្ចប់ត្រូវ : ចុះហត្ថលេខា និងចុះឈ្មោះអ្នកសរសេរ ...។

**គ- រចនាបថ** (០៥ពិន្ទុ)

(០២ពិន្ទុ) - ទម្រង់តែងសេចក្តី
(០១ពិន្ទុ) - ឃ្លា ល្បះ ខណ្ឌសញ្ញា អក្ខរាវិរុទ្ធ
(០១ពិន្ទុ) - ការចុះបន្ទាត់
(០១ពិន្ទុ) - អក្សរស្អាត។

## ១៥.៣- អត្រាកំណែតែងសេចក្តីបែបអត្ថាធិប្បាយពន្យល់ទូទៅ

(ពិន្ទុ៦០ រយៈពេល៩០នាទី)

**ក- សេចក្តីផ្តើម** (១០ពិន្ទុ)

(០៤ពិន្ទុ) - លំនាំបញ្ហា ...
(០៣ពិន្ទុ) - ចំណូលបញ្ហា(បង្ហាញបញ្ហា) ...

(០៣ពិន្ទុ) - ចំណោទបញ្ហា ...។

**ខ- តួសេចក្ដី** (៣៥ពិន្ទុ)

(០១ពិន្ទុ) - ឃ្លាភ្ជាប់សេចក្ដី...

(០២ពិន្ទុ) - ពន្យល់ពាក្យគន្លឹះ...

(០២ពិន្ទុ)- ពន្យល់ន័យប្រធាន ...

(២៥ពិន្ទុ) - បំណកស្រាយ ...

(០៥ពិន្ទុ) - សរុប ...។

**គ- សេចក្ដីបញ្ចប់** (១០ពិន្ទុ)

(០៥ពិន្ទុ) - វាយតម្លៃប្រធាន...

(០៥ពិន្ទុ) - យោបល់ផ្ទាល់ខ្លួន ...។

**ឃ- រចនាបថ** (០៥ពិន្ទុ)

(០២ពិន្ទុ) - ទម្រង់តែងសេចក្ដី

(០១ពិន្ទុ) - ឃ្លា ល្បះ ខណ្ឌសញ្ញា អក្ខរាវិរុទ្ធ

(០១ពិន្ទុ) - ការចុះបន្ទាត់

(០១ពិន្ទុ) - អក្សរស្អាត។

## ១៥.៤- អត្រាកំណែតែងសេចក្ដីបែបអត្ថាធិប្បាយពន្យល់ពាក្យស្លោក សុភាសិត (ពិន្ទុ៦០ រយៈពេល៩០នាទី)

**ក- សេចក្ដីផ្ដើម** (១០ពិន្ទុ)

(០៤ពិន្ទុ) - លំនាំបញ្ហា ...

(០៣ពិន្ទុ)- ចំណូលបញ្ហា(បង្ហាញបញ្ហា) ...

(០៣ពិន្ទុ)- ចំណោទបញ្ហា...។

**ខ- តួសេចក្ដី** (៣៥ពិន្ទុ)

(០១ពិន្ទុ) - ឃ្លាភ្ជាប់សេចក្ដី...

(០២ពិន្ទុ) - ពន្យល់ពាក្យគន្លឹះ...

(០២ពិន្ទុ)- ពន្យល់ន័យប្រធាន ...

(២៥ពិន្ទុ) - បំណកស្រាយ...

(០៥ពិន្ទុ) - សរុប ...។

**គ- សេចក្ដីបញ្ចប់** (១០ពិន្ទុ)

(០៥ពិន្ទុ) - វាយតម្លៃប្រធាន...

(០៥ពិន្ទុ) - យោបល់ផ្ទាល់ខ្លួន...។

**ឃ- រចនាបថ** (០៥ពិន្ទុ)

(០២ពិន្ទុ) - ទម្រង់តែងសេចក្ដី

(០១ពិន្ទុ) - ឃ្លា ល្បះ ខណ្ឌសញ្ញា អក្ខរាវិរុទ្ធ

(០១ពិន្ទុ) - ការចុះបន្ទាត់
(០១ពិន្ទុ) - អក្សរស្អាត។

## ១៥.៥- អត្រាកំណែតែងសេចក្តីបែបអត្ថាធិប្បាយពន្យល់អក្សរសិល្ប៍

**(ពិន្ទុ៦០ រយៈពេល៩០នាទី)**

**ក- សេចក្តីផ្តើម** (១០ពិន្ទុ)
(០៤ពិន្ទុ) - លំនាំបញ្ហា...
(០៣ពិន្ទុ) - ចំណូលបញ្ហា(បង្ហាញបញ្ហា)...
(០៣ពិន្ទុ) - ចំណោទបញ្ហា...។

**ខ- តួសេចក្តី** (៣៥ពិន្ទុ)
(០១ពិន្ទុ - ឃ្លាភ្ជាប់សេចក្តី...
(០២ពិន្ទុ) - ពន្យល់ពាក្យគន្លឹះ...
(០២ពិន្ទុ)- ពន្យល់ន័យប្រធាន ...
(២៥ពិន្ទុ) - បំណកស្រាយ...
(០៥ពិន្ទុ) - សរុប...។

**គ- សេចក្តីបញ្ចប់** (១០ពិន្ទុ)
(០៥ពិន្ទុ - វាយតម្លៃប្រធាន ...
(០៥ពិន្ទុ) - យោបល់ផ្ទាល់ខ្លួន ...។

**ឃ- រចនាបថ** (០៥ពិន្ទុ)
(០២ពិន្ទុ) - ទម្រង់តែងសេចក្តី
(០១ពិន្ទុ) - ឃ្លា ល្បះ ខណ្ឌសញ្ញា អក្ខរាវិរុទ្ធ
(០១ពិន្ទុ) - ការចុះបន្ទាត់
(០១ពិន្ទុ) - អក្សរស្អាត។

## ១៥.៦- អត្រាកំណែតែងសេចក្តីអត្ថាធិប្បាយប្រៀបធៀប

**(ពិន្ទុ៦០ រយៈពេល៩០នាទី)**

**ក- សេចក្តីផ្តើម(១០ពិន្ទុ)**
(០៤ពិន្ទុ) - លំនាំបញ្ហា...
(០៣ពិន្ទុ) - ចំណូលបញ្ហា(បង្ហាញបញ្ហា)...
(០៣ពិន្ទុ) - ចំណោទបញ្ហា...។

**ខ- តួសេចក្តី(៣៥ពិន្ទុ)**
(០១ពិន្ទុ) - ឃ្លាភ្ជាប់សេចក្តី...
(០២ពិន្ទុ) - ពន្យល់ពាក្យគន្លឹះ...
(០២ពិន្ទុ)- ពន្យល់ន័យប្រធាន...
(២៥ពិន្ទុ) - បំណកស្រាយ...

(០៥ពិន្ទុ) - សរុប...។

**គ- សេចក្តីបញ្ចប់**(**១០ពិន្ទុ**)

(០៥ពិន្ទុ) - វាយតម្លៃប្រធាន ...

(០៥ពិន្ទុ) - យោបល់ផ្ទាល់ខ្លួន...។

**ឃ- រចនាបថ**(**០៥ពិន្ទុ**)

(០២ពិន្ទុ) - ទម្រង់តែងសេចក្តី

(០១ពិន្ទុ) - ឃ្លា ល្បះ ខណ្ឌសញ្ញា អក្ខរាវិរុទ្ធ

(០១ពិន្ទុ) - ការចុះបន្ទាត់

(០១ពិន្ទុ) - អក្សរស្អាត។

## ១៦- វិញ្ញាសាប្រឡងសិស្សពូកែមធ្យមបឋមភូមិ

---

ប្រធាន: ពំនោលមួយ « បុព្វបុរសខ្មែរបានបន្សល់កេរមតកជាច្រើនដល់កូនខ្មែរជំនាន់ក្រោយ»។ ចូរបង្ហាញដោយលើកយកអំណះអំណាងមកបញ្ជាក់។

---

**សិស្សទី១**

### សេចក្តីអធិប្បាយ

យើងដឹងហើយថា ប្រទេសកម្ពុជាជាប្រទេសមួយក្នុងចំណោមប្រទេសអាស៊ានទាំងដប់។ យ៉ាងណាមិញប្រទេសកម្ពុជាជាប្រទេសមួយដែលសម្បូរទៅដោយសម្បត្តិធម្មជាតិ វប្បធម៌អរិយធម៌ខ្មែរយ៉ាងច្រើនផងដែរ។ ទាំងនេះអាចកើតមានបានក៏ដោយសារតែប្រទេសនេះមាននូវបុព្វបុរសដ៏ច្រើននិងឆ្នើមសម្រាប់បន្សល់ទុកមរតកនេះទៀតផង។ ដោយមើលឃើញលក្ខណៈបែបនេះហើយ ទើបបានជាមានពំនោលមួយបានលើកឡើងថា "បុព្វបុរសខ្មែរបានបន្សល់ទុកនូវកេរមរតកជាច្រើនដល់កូនខ្មែរជំនាន់ក្រោយ"។

តើពំនោលដែលបានលើកឡើងខាងលើនេះ បានបង្កប់នូវអត្ថន័យ និងខ្លឹមសារយ៉ាងដូចម្តេច?

ដើម្បីជាគុណប្រយោជន៍ដល់ការអធិប្បាយស្រាយបំភ្លឺនូវមតិខាងលើ ឱ្យកាន់តែពិស្តារហើយច្បាស់លាស់ថែមទៀតនោះ យើងគប្បីយល់ន័យពាក្យគន្លឹះខ្លះៗជាមុនសិន។ "បុព្វបុរស" គឺជាមនុស្សដែលមាននូវគុណ និងមានស្នាដៃយ៉ាងជ្រាលជ្រៅសម្រាប់ជាតិមាតុភូមិ រីឯពាក្យ "កេរមរតក" មានន័យថា របស់ដែលជាកេរដំណែលដែលបុព្វបុរសយើងបន្សល់ទុកឱ្យ។ ដោយយោងទៅលើន័យនៃពាក្យដែលបានពន្យល់ខាងលើគំនិតរបស់ប្រធានចង់បញ្ជាក់ថា មនុស្សដែលមានគុណនិងស្នាដៃ សម្រាប់ប្រទេសជាតិខ្មែរនោះបានបន្សល់ទុកនូវកេរដំណែលជាច្រើនដល់កូនចៅខ្មែរជំនាន់ក្រោយ ក្នុងការថែរក្សាឱ្យបានគង់វង្សជាបន្តទៀត។ ជាសត្យានុម័ត បុព្វបុរសខ្មែរបានបន្សល់កេរមរតកជាច្រើនដល់កូនខ្មែរជំនាន់ក្រោយពិតប្រាកដមែន ព្រោះកាលពីសម័យបុព្វបុរសយើងបានខិតខំតស៊ូកសាងនូវរបស់របរជាច្រើនដល់កូនខ្មែរដោយខិតខំតស៊ូមិនរួញរា។ ជាពិសេសនោះគឺប្រាសាទអង្គរវត្ត ប្រាសាទបាយ័ន អង្គរធំ អង្គរតូច និងប្រាសាទដទៃទៀតយ៉ាងច្រើន ដោយការនោះជាការងារមួយដែលលំបាកប៉ុន្តែពួកគាត់ទាំងឡាយនៅតែ ខិតខំធ្វើការទាំងនោះដោយមិនគិតពីភាពនឿយហត់លំបាកលំបិននោះឡើយ។ អ្វីដែលគួរឱ្យអស្ចារ្យបំផុតនោះគឺការឆ្លាក់រចនានូវប្រាសាទឱ្យល្អល្បាច់ដាច់គេក្នុងអាស៊ីយើងនេះ។ ថែមទាំងអាចយកនូវកេរមរតកទាំងនេះទៅបញ្ជាក់ក្នុងបេតិកភណ្ឌពិភពលោក

សម្រាប់តំណាងឱ្យប្រទេសកម្ពុជាយើងថែមទៀតផង។ ជាងនេះទៅទៀត គឺការបង្កើតនូវគំនិតច្នៃប្រឌិតថ្មីៗ ដែលបានធ្វើឱ្យបរទេសទាំងឡាយមានការកោតសរសើរជាខ្លាំង ហើយតែងតែចង់ធ្វើដំណើរមកទស្សនកិច្ច នៅប្រទេសកម្ពុជាយើងខ្លាំងណាស់។ គំនិតច្នៃប្រឌិតទាំងនោះមាន ការធ្វើកញ្ជេ ប៉ោត តោក ចង្អេរ កន្ទេល និងរបស់របរផ្សេងៗទៀតដូចជា ផ្តិលស្ពាន់ មាស ប្រាក់ និងមាននៅច្រើនប្រភេទទៀតឯណោះ។ មិនតែប៉ុណ្ណោះគឺពួកគាត់ផ្តល់នូវគំរូមួយសម្រាប់យុវជនឥឡូវឱ្យខិតខំសិក្សារៀនដើម្បីឱ្យខ្លួនឯងមាននូវចំណេះគ្រប់គ្រាន់សម្រាប់អភិវឌ្ឍន៍ជាតិទៀតផង។ ពេលណាដែលយើងចេះ ហើយពេលនោះយើងនឹងអាចប្រកបមុខរបរទំនិញធំៗបាន។ ការធ្វើកសិកម្មក៏ជាវិស័យមួយដែលខ្មែរយើងគ្រប់រូបកាលពីសម័យមុនមានការតស៊ូជម្នះគ្រប់ឧបសគ្គដែលអាចធ្វើឱ្យវិស័យមួយនេះដំណើរការទៅយ៉ាងរលូន មិនដែលលំបាកក្នុងការធ្វើវានោះទេ។ ការបង្កើតនូវម៉ាស៊ីនច្រូតស្រូវ ការបង្កើតនូវម៉ាស៊ីនកិនម្សៅ រោងចក្រអង្ករគឺខ្មែររបស់យើងនាសម័យនោះបង្កើតឡើងដោយខ្លួនឯងដើម្បីសម្របសម្រួលទៅដល់ការងារមួយភាគធំ។ បុព្វបុរសយើងគឺជាមនុស្សដែលជាមនុស្សមាននូវភាពឈ្លាសវៃគ្រប់កិច្ចការងារ ដែលអាចធ្វើឱ្យកូនខ្មែរជំនាន់ក្រោយមានការកោតសរសើរយ៉ាងក្រៃលែងដែលមិនសឹងតែមានអ្នកណាម្នាក់នឹងអាចធ្វើបានណាស់។ នេះជាកេរមរតកដ៏ថ្មីសន្លាងសម្រាប់យុវជនខ្មែរយើងយកគំរូទុកក្នុងដួងចិត្តរបស់យើង។ ជាពិសេសនោះទៅទៀតគឺបុព្វបុរសខ្មែរយើង បានបង្កើតនូវការថែរក្សាសត្វព្រៃ និងសម្បត្តិធម្មជាតិយ៉ាងល្អឯក។ ថែមទាំងអាចធ្វើឱ្យសត្វស្រុក ព្រៃ និងធម្មជាតិទាំងឡាយមានការបិតស្លេរជារៀងដរាបរៀងទៅ។ ម្យ៉ាងវិញទៀតការថែរក្សានេះ បានធ្វើឱ្យខ្សែភាពយន្តខ្មែរយើងកាន់តែល្បីរន្ទឺឡើងព្រោះបានថតរូបភាពជុំវិញកន្លែងដែលសម្បូរទៅដោយបក្សាបក្សី ម្រឹគីម្រឹគានិងធម្មជាតិដែលធ្វើឱ្យសិល្បៈខ្មែរយើង កាន់តែរីករាលដាលទៅផ្សព្វផ្សាយនៅប្រទេសក្រៅបាន។ ការធ្វើការថតខ្សែភាពយន្តនេះ ក៏បានធ្វើឱ្យជនជាតិបរទេសមួយចំនួនមានការកោតសរសើរ ដោយសារបុព្វបុរសខ្មែរយើងគាត់មានគំនិតលម្អចំពោះជាតិយើង។ សិល្បករ សិល្បការិនីទាំងឡាយក៏កាន់តែមានអារម្មណ៍កាន់តែខ្លាំងក្នុងការថតខ្សែភាពយន្តទៅមុខទៀត។ បើយើងនិយាយអំពីរបាំជាតិយើងវិញក៏វាមិនខុសអំពីសម្បត្តិដទៃទៀតដែរ។ បុព្វបុរសខ្មែរបានមានគំនិតឧត្តុង្គឧត្តម សម្រាប់បង្កើតនូវរបាំប្រពៃណីវប្បធម៌មុនគេបង្អស់នៃប្រទេសដទៃទៀត។ ប្រទេសកម្ពុជាមានក្បាច់របាំដ៏ល្អឥតខ្ចោះពិសេសរបាំត្រុដិ គោះត្រឡោកដែលរបាំនោះ មានកិត្តិនាមជាយូរណាស់មកហើយរហូតបានមកដល់បច្ចុប្បន្នសព្វថ្ងៃនេះ។ របាំគឺជាផ្នែកមួយនៃបេតិកភណ្ឌជាតិខ្មែរដូចនេះ បានជាគេបង្កើតវាឡើងនោះ។ បុព្វបុរសខ្មែរយើងពិតជាមានគំនិតល្អៗមែន។ ម្យ៉ាងវិញទៀតប្រសិនគ្មានប្រជាជនជំនាន់មុនៗ ថែរក្សាវប្បធម៌ប្រពៃណីនិងបង្កើតឡើងនោះទេប្រទេសយើងក៏មិនអាចមាននូវវប្បធម៌ អរិយធម៌បែបនេះ។ ជាស្នាដៃដ៏ឥតខ្ចោះរបស់បុព្វបុរសខ្មែរយើង។

បើយើងធ្វើការឆ្លុះបញ្ចាំងទៅក្នុងសង្គមជាក់ស្តែងវិញឃើញថា ប្រាសាទទាំងឡាយមានដូចជាប្រាសាទអង្គរវត្ត ប្រាសាទព្រះវិហារ បន្ទាយស្រី អង្គរធំ អង្គរតូចទាំងឡាយអាចកើតមានឡើងដោយសព្វថ្ងៃនេះបានគឺដោយសារតែពីសម័យមុន បុព្វបុរសយើងបានបង្កើតវាឡើងដោយមិនគិតពីកម្លាំងញើសឈាមរបស់គាត់ បុព្វបុរស បានកំពុងតែខំប្រឹងថែរក្សាទាំងសម្បត្តិវប្បធម៌ ទំនៀមទម្លាប់ប្រពៃណី ខិតខំបណ្តុះបណ្តាលជនជាតិខ្លួនឱ្យខិតខំកែប្រែវាឡើងវិញ ដោយមិនឱ្យធនធានទាំងនេះត្រូវបាត់បង់ឡើយ។ ធនធានខ្មែរមានច្រើនឥតគណនាតាំងពីតវេនគ្មានរហូតមកដល់សព្វថ្ងៃនេះ គឺគាត់បានបង្កើតឡើងនូវធនធានជាច្រើន ថែមទាំងគាត់បង្កើតនូវទឹកដីខ្មែរដ៏ធំល្វឹងល្វើយនេះទេ គឺថែមទាំងបង្កើតនូវធនធានរ៉ែ មាស រ៉ែត្បូង រ៉ែប្រេង ទាំងប្រេងកាតនិងប្រេងដទៃទៀត។ អ្វីដែលយើងគិតថាវាសំខាន់ជាងនោះ គឺគាត់ចេះឆ្លាក់ចម្លាក់រចនានូវអង្គរវត្តដែលធ្វើឱ្យកូនខ្មែរមានមោទនភាពធំបំផុត។

បើចោលភ្នែកក្រឡេកទៅមើលទំព័រប្រវត្តិសាស្ត្រវិញយើងឃើញថា នាសម័យអង្គរប្រជាជនខ្មែរយើងគ្រប់ៗគ្នាគឺតែងតែជួយគ្នាទៅវិញទៅមក ក្នុងការរៀបចំសណ្តាប់ធ្នាប់ ប្រទេសមិនឱ្យមានភាពរញ៉េរញ៉ៃនោះទេ។ ពួកគាត់ទាំងឡាយគឺបានសហការគ្នាយ៉ាងជិតស្និទ្ធបំផុត សម្រាប់បង្កើតនូវអ្វីដែលថ្មីៗដល់កូនខ្មែរយើងមើលថាតើនេះ ជារបស់អ្វីនោះជារបស់អ្វី។ ពួកគាត់ទាំងឡាយមានការគិតពិចារណាខ្ពស់ចំពោះជាតិខ្លួនទៅថ្ងៃអនាគត ដើម្បីឱ្យកូនខ្មែរជំនាន់ក្រោយរបស់យើងនោះមានការនឹកស្តាយស្រណោះដល់ពេលដែលបុព្វបុរសយើងនោះ លាចាកលោកអស់។ ពេលនោះហើយដែលពួកគាត់បង្កើតវាឡើង ដើម្បីជាតំណាងឱ្យពួកគាត់ទាំងឡាយនាសម័យមុននោះ។ នាសម័យកាលនោះ បុព្វបុរសខ្មែរយើងមានឧត្តមគតិខ្ពស់ ទើបបានជាធ្វើឱ្យជាតិរបស់យើងមានការរីកចម្រើន។ កត្តាដែលធ្វើឱ្យជាតិយើងនាសម័យនោះមានការអភិវឌ្ឍខ្ពស់ ព្រោះតែនាសម័យនោះ គឺមានប្រជាជន(បុព្វបុរស) យើងនោះមានការសាមគ្គីគ្នាជួយគ្នាកសាងនូវសម្បត្តិបេតិកភណ្ឌជាតិខ្មែរបានយ៉ាងច្រើន និងជាងនេះទៅទៀតគឺខិតខំកែច្នៃរបស់ប្រើប្រាស់ឱ្យកាន់តែចម្លែកភ្នែកទៅទៀត។ ប្រាង្គប្រាសាទជាច្រើន បានកសាងឡើងដោយសារតែស្នាដៃរបស់ពួកគាត់ទាំងឡាយមាននូវវិជ្ជាជីវៈត្រឹមត្រូវតាមស្តង់ដា។

សរុបមកបុព្វបុរសខ្មែរ បានបន្សល់ទុកនូវកេរមរតកជាច្រើនដល់កូនខ្មែរជំនាន់ក្រោយពិតមែន ពីព្រោះពួកគាត់បានកសាងនូវអ្វី ដែលខ្មែរយើងគ្រប់រូបមិនអាចនឹងធ្វើបាន។ ពួកគាត់បានបន្សល់ទុកនូវសម្បត្តិវប្បធម៌សម្បត្តិធម្មជាតិ ប្រាង្គប្រាសាទ សត្វបក្សា បក្សី និងជាពិសេសនោះគឺមានគំនិតឧត្តមគតិចំពោះជាតិខ្មែរ។ នេះជាស្នាដៃដ៏អស្ចារ្យរបស់បុព្វបុរសយើង ក្នុងការលើកតម្កើងជាតិ។

ឆ្លងតាមការបកស្រាយរៀបរាប់ភ្ជាប់សេចក្តីទាំងនៅក្នុងសង្គមជាក់ស្តែងក្តី ប្រវត្តិសាស្ត្រក្តីយើងអាចវាយតម្លៃប្រធានបានថា ពិតជាមានខ្លឹមសារល្អនិងប្រកបដោយអត្ថន័យយ៉ាងជ្រាលជ្រៅពិតមែនពីព្រោះថាបានបណ្តុះនូវស្មារតីកូនខ្មែរគ្រប់រូបឱ្យជួយថែរក្សាកេរដំណែលដែលបានបន្សល់ទុកឱ្យ មិនត្រូវភ្លើតភ្លើនភ្លេចជាតិរបស់ខ្លួន។ ពិសេសជាងនេះនោះ គឺត្រូវថែទាំសម្បត្តិទាំងឡាយដែលពួកជនបុព្វបុរសយើងបានបន្សល់ទុកឱ្យនិងបានបង្កើតឱ្យយើង។ ដូចនេះក្នុងនាមយើងជាកុលបុត្រកុលធីតាខ្មែរ ត្រូវតែខិតខំប្រឹងប្រែងរៀនសូត្រឱ្យមានចំណេះដឹងជ្រៅជ្រះ ជាពិសេសគឺចេះច្នៃប្រឌិតដូចបុព្វបុរសយើងធ្វើដូចគ្នាដែរ។ បើយើងធ្វើបានដូចនេះហើយនោះគ្រួសារយើង ប្រទេសនឹងមានការអភិវឌ្ឍរុងរឿងជាលំដាប់ជាក់ជាមិនខាននោះឡើយ។

**សិស្សទី២**

## សេចក្តីអធិប្បាយ

ខ្មែរជាជាតិសាសន៍មួយ ដ៏ចំណាស់ជាងគេនៅតំបន់អាស៊ីអាគ្នេយ៍ ដែលមានកេរមរតកសម្បត្តិវប្បធម៌ជាច្រើន ហើយបានបន្សល់ទុកដល់កូនចៅជំនាន់ក្រោយឱ្យបានដឹង បានយល់ និងស្គាល់។ អាស្រ័យហេតុហើយទើបមានពំនោលមួយពោលថា "បុព្វបុរសខ្មែរបានបន្សល់កេរមរតកជាច្រើនដល់កូនខ្មែរជំនាន់ក្រោយ"។

មុននឹងធ្វើការបកស្រាយនូវប្រធានខាងលើឱ្យក្បោះក្បាយនិងស៊ីជម្រៅថែមទៀតនោះជាដំបូង គប្បីស្វែងយល់នូវពាក្យ "បុព្វបុរសនិងកេរមរតក"ជាមុនសិន។ បុព្វបុរសមានន័យថា បុរសសម័យដើម បុរសសម័យដើមជាមនុស្សជំនាន់ដើម។ រីឯពាក្យកេរមរតកមានន័យថា ដំណែលជាសម្បត្តិដែលទុកដោយដូនតាឬមាតាបិតាសម័យដើម។ ន័យរបស់ប្រធានខាងលើនេះចង់និយាយថាខ្មែរជំនាន់ដើមបានទុកនូវកេរដំណែលច្រើនសម្រាប់កូនចៅជំនាន់ក្រោយបានដឹង បានយល់ និងបានស្គាល់ ពីកេរមរតកទាំងនោះ។

ជាការពិតណាស់យើងបានដឹងហើយថា ខ្មែរជាជាតិសាសន៍មួយដ៏ចំណាស់ជាងគេនៅតំបន់អាស៊ីអាគ្នេយ៍។ ខ្មែរជាជនជាតិមួយដែលមានបំណិនប្រសប់ខាងផ្នែកកសាង និងការច្នៃប្រឌិតរបស់របរផ្សេងៗ ដោយគ្មានការលួចចម្លងឬធ្វើតាមជាតិសាសន៍ដទៃ។ ហើយខ្មែរឬជាជនជាតិ ដែលមានគំនិតប្រាជ្ញាឈ្លាសវៃ ទាំងផ្នែកអក្សរសាស្ត្រ វិទ្យាសាស្ត្រ តក្កវិជ្ជា ហត្ថកម្ម សិល្បសាស្ត្រដែលធ្វើឱ្យប្រទេសខ្មែរមានការរុងរឿងដល់ចំណុចកំពូល (សម័យមហានគរ ឬយុគមាស) ធ្វើឱ្យខ្មែរមានភាពល្បីល្បាញរន្ទឺសុសសាយនៅលើសកលលោកទាំងផ្នែកស្ថាបត្យកម្ម ផ្នែកទំនៀមទម្លាប់ប្រពៃណី ជំនឿ សាសនា សិល្បៈ តូរ្យតន្ត្រី របាំ វិស័យកសិកម្ម សេដ្ឋកិច្ច វិស័យសុខាភិបាល វិស័យអប់រំ។ ផ្នែកស្ថាបត្យកម្មខ្មែរបុរាណបានកសាងនូវប្រាសាទច្រើនរាយពាសពេញផ្ទៃប្រទេសនិងមានក្បូរក្បាច់រចនាដ៏ល្អប្រណីតប្រហែលជាងមួយពាន់ប៉ែតសិបប្រាសាទ។ ប្រាសាទទាំងនោះរួមមានប្រាសាទអង្គរវត្ត ត្រូវបានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោកនិងត្រូវបានចាត់ទុកជានិមិត្តរូបនៃដួងព្រលឹងជាតិខ្មែរគ្រប់ជំនាន់ ហើយបានទាញយកផលប្រយោជន៍ជាច្រើនដូចជាទាក់ទាញបាននូវភ្ញៀវទេសចរជាតិ អន្តរជាតិចូលមកទស្សនាដោយនាំមកនូវថវិកាជាច្រើនសម្រាប់អភិវឌ្ឍប្រទេសជាតិ។ ក្រៅពីប្រាសាទអង្គរវត្តខ្មែរក៏បានបន្សល់នូវកេរមរតកជាច្រើនទៀតដូចជា ប្រាសាទព្រះវិហារ ត្រូវបានចាត់ទុកជាសម្បត្តិបេតិកភណ្ឌពិភពលោក ប្រាសាទបាយ័ន ប្រាសាទព្រះខ័ន ប្រាសាទតាព្រហ្ម ប្រាសាបន្ទាយស្រី ប្រាសាទបន្ទាយឆ្មារ ប្រាសាទកោះកេរ្តិ៍ ដែលសុទ្ធតែជាមរតកដ៏មានតម្លៃពុំអាចកាត់ថ្លៃបាន។ ផ្នែកទំនៀមទម្លាប់ប្រពៃណី ខ្មែរជាជាតិសាសន៍ដែលមានទំនៀមទម្លាប់ប្រពៃណីដ៏ល្អប្រពៃ មានល្អប្រសើរជាទីពេញចិត្តនិងជាទីចង់បានរបស់ជាតិសាសន៍ដទៃ ព្រោះទំនៀមទម្លាប់ប្រពៃណីខ្មែរជាវត្ថុដ៏មានតម្លៃ គ្មានពីរដែលបានឆ្លុះបញ្ចាំងពីទំនៀមទម្លាប់រស់នៅ ការស្លៀកពាក់ និងបានបង្ហាញពីវប្បធម៌អរិយធម៌ដ៏ឧត្តុង្គឧត្តមខ្ពស់របស់ខ្មែរ។ ផ្នែកជំនឿសាសនាព្រះពុទ្ធ និងសាសនាព្រាហ្មណ៍ ដែលមានកសាងបដិមាតំណាងព្រះជាច្រើន ព្រោះដើម្បីកុំឱ្យមានទំនាស់សាសនា ហើយសាសនាទាំងពីរក៏បានជួយកសាងសង្គមខ្មែរគ្មានលួច ឆក់ប្លន់ គ្មានការប្រព្រឹត្តអំពើបាបនានា ប្រទេសគ្មានភាពចលាចល ប្រជាជនរស់នៅដោយមានសន្តិភាពនិងមានការអភិវឌ្ឍ។ ផ្នែកតូរ្យតន្ត្រី ភ្លេង សិល្បៈ វិញមានច្រើនមុខច្រើនប្រភេទដូចជាជំ ដេញ ផ្លុំ កូតជាដើម ហើយភ្លេងទាំងនោះប្រើសម្រាប់ពិធីរៀបមង្គល ដែលញ៉ាំងឱ្យបរិយាកាសកាន់តែមានភាពអ៊ូអរ អ៊ឹកធឹក។ ផ្នែករបាំខ្មែរមានរបាំទន់ភ្លន់ដែលបង្ហាញពីទឹកចិត្តស្លូតបូតរបស់ខ្មែរគឺរបាំអប្សរា។ ក្រៅពីនេះក៏មានរបាំព្រះរាជទ្រព្យដែលត្រូវបានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោក និងល្ខោនស្រមោលស្បែកធំក៏ត្រូវបានចុះក្នុងបញ្ជីពិភពលោកដែរ។ ផ្នែកកសិកម្មខ្មែរមានកសាងប្រព័ន្ធធារាសាស្ត្រខ្ជាត់ខ្ជែង សម្រាប់បម្រើឱ្យវិស័យកសិកម្ម ហើយទទួលទិន្នផលខ្ពស់ជាទីគាប់ចិត្ត សម្រាប់ចិញ្ចឹមជីវិតរស់នៅប្រចាំថ្ងៃរបស់ប្រជាជនឱ្យបានគ្រប់គ្រាន់ និងជួយឱ្យប្រជាជនមានជីវភាពធូរធារចាកផុតពីភាពក្រីក្រឱ្យប្រទេសមានការអភិវឌ្ឍ។ ផ្នែកសេដ្ឋកិច្ចខ្មែរសម័យនោះមានភាពរុងរឿង ប្រជាជនគ្មានភាពក្រីក្រ សេដ្ឋកិច្ចរីកចម្រើន មានធ្វើពាណិជ្ជកម្មជាមួយប្រទេសជាសម្ព័ន្ធមិត្តចិនជាដើម។ ផ្នែកសុខាភិបាលព្រះរាជានាសម័យនោះ បានកសាងនូវមន្ទីរពេទ្យសម្រាប់ជួយសម្រួលដល់ការព្យាបាលសុខភាពប្រជារាស្ត្រមានគ្រូពេទ្យប្រកបដោយសីលធម៌ និងមានសមត្ថភាពខ្ពស់សម្រាប់ជួយព្យាបាលជំងឺប្រជាជន។ ផ្នែកវិស័យអប់រំ សម័យនោះសម្បូរទៅដោយ អ្នកប្រាជ្ញ បណ្ឌិត អ្នកខ្លះជារាជគ្រូខ្លះជាបុរោហិត ព្រមទាំងមានគម្ពីរក្បួនច្បាប់ជាច្រើនសម្រាប់សិក្សា ហើយព្រះរាជាក៏បានបង្កើតនូវសាលានិងសកលវិទ្យាល័យជាច្រើនទៀត សម្រាប់បម្រើដល់ការសិក្សានាសម័យនោះ។ នេះសរបញ្ជាក់ឱ្យឃើញថាខ្មែរបុរាណជាមនុស្សប៉ិនប្រសប់ក្នុងការអភិវឌ្ឍជាតិ និងបានបន្សល់ទុកនូវកេរមរតកជាច្រើនដល់កូនចៅជំនាន់ក្រោយ។

សរុបសេចក្តីមក បុព្វបុរសខ្មែរពិតជាមានស្នាដៃដ៏ធំធេង ក្នុងការកសាងប្រទេសឱ្យមានការរីកចម្រើន និងបានបន្សល់ទុកនូវកេរមរតកជាច្រើនដល់កូនចៅជំនាន់ក្រោយ។

ឆ្លងតាមការបកស្រាយខាងលើ យើងឃើញថាខ្មែរបុរាណពិតជាបានបន្សល់ទុកនូវកេរមរតកជាច្រើន សម្រាប់កូនខ្មែរគ្រប់រូប បានដឹង បានយល់ បានស្គាល់ពីតម្លៃរបស់វា។ ដូចនេះក្នុងនាមខ្ញុំជាកុលបុត្រ កុលធីតាខ្មែរជំនាន់ក្រោយត្រូវខិតខំរៀនសូត្រ និងយកចំណេះទាំងនោះទៅកសាងប្រទេសជាតិ ហើយបន្តវេនថែរក្សាកេរមរតកទាំងនោះមិនឱ្យបាត់បង់ឡើយ។

# ១៧- លំនាំបង្រៀនតែងសេចក្តី

## ១៧.១- លក្ខណៈទូទៅនៃលំនាំបង្រៀនតែងសេចក្តី

ការសិក្សាតែងសេចក្តី គឺជាផ្នែកមួយដ៏មានសារៈសំខាន់ក្នុងការរៀនភាសាខ្មែរ។ លំនាំបង្រៀនតែងសេចក្តី គឺជាល្បិចបង្រៀនដែលត្រូវរៀបចំឡើងសម្រាប់ឱ្យសិស្សធ្វើសកម្មភាពផ្សេងៗ ដើម្បីចាប់យកខ្លឹមសារមេរៀនបានល្អប្រសើរ ហើយធានាថាសិស្សនឹងចេះសរសេរតែងសេចក្តីបានល្អ។ លំនាំបង្រៀនតែងសេចក្តីខុសពីវិធីសាស្ត្រនៃការសរសេរតែងសេចក្តីត្រង់ថា លំនាំបង្រៀនគឺជាគរុកោសល្យជាវិធីឬល្បិចនៃការបង្រៀនតែងសេចក្តី រីឯវិធីសាស្ត្រសរសេរតែងសេចក្តីវិញ គឺជាក្បួនខ្នាតសម្រាប់យកមកអនុវត្តក្នុងការសរសេតែងសេចក្តី។ ចំណុចគន្លឹះក្នុងការសិក្សាតែងសេចក្តី គឺធ្វើយ៉ាងណាឱ្យសិស្សចេះរៀបរាប់ ពិពណ៌នា និងចេះពន្យល់ វែកញែក ស្រាយបំភ្លឺ បកស្រាយឱ្យបានយល់ច្បាស់។ ដូច្នេះ គ្រូបង្រៀន សាស្ត្រាចារ្យទាំងឡាយ គប្បីយកចិត្តទុកដាក់ក្នុងការបង្រៀនសិស្សយ៉ាងណាធានាឱ្យបានថា សិស្សចេះសរសេរតែងសេចក្តីបែបពិពណ៌នា ដោយចេះសរសេររៀបរាប់ ពិពណ៌នា ឱ្យបានក្បោះក្បាយច្បាស់លាស់ ដើម្បីឱ្យអ្នកអានហាក់ដូចជាមើលឃើញនឹងភ្នែកផ្ទាល់។ សិស្សចេះសរសេរតែងសេចក្តីបែបអត្ថាធិប្បាយ ដោយចេះសរសេរបកស្រាយ ស្រាយបំភ្លឺ ពន្យល់ វែកញែក ប្រកបដោយហេតុផល មានអំណះអំណាង និងចេះលើកជាឧទាហរណ៍មកបញ្ជាក់ឱ្យបានច្បាស់លាស់ ដើម្បីឱ្យអ្នកអានយល់ច្បាស់ និងមានភាពជឿជាក់លើការបកស្រាយ។

លំនាំបង្រៀនតែងសេចក្តី មានន័យទូលំលាយណាស់ ហើយវាពាក់ព័ន្ធខ្លាំងជាមួយនឹងដំណើរការរៀន និងបង្រៀន។ នៅក្នុងឯកសារនេះ យើងនឹងលើកយកលំនាំបង្រៀនទូទៅនៃការសរសេរតែងសេចក្តីមួយចំនួនមកបង្ហាញ គឺលំនាំបង្រៀនការអនុវត្តសរសេរតែងសេចក្តី។ អ្នកសិក្សាគប្បីដឹងថា លំនាំបង្រៀនមិនមែនមានតែមួយជាគំរូដែលល្អបណ្តាច់ជាងគេនោះទេ។ ប៉ុន្តែវាអាចមានលំនាំបង្រៀនល្អជាច្រើន សម្រាប់ជាជម្រើសក្នុងការរៀបចំការរៀននិងបង្រៀនឱ្យបានល្អ។ ក្នុងខ្លឹមសារមេរៀនតែមួយ គេអាចរៀបចំលំនាំបង្រៀនបានច្រើនបែបច្រើនយ៉ាងខុសៗគ្នា អាស្រ័យទៅតាមការច្នៃប្រឌិតរបស់អ្នកបង្រៀនម្នាក់ៗ។ ដូច្នេះក្នុងការរៀន និងបង្រៀនតែងសេចក្តី គ្រូបង្រៀន សាស្ត្រាចារ្យ គប្បីធ្វើយ៉ាងណាឱ្យសិស្សសម្រេចបាននូវវត្ថុបំណងគឺ វិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា។

## ១៧.២- លំនាំបង្រៀនការអនុវត្តសរសេរតែងសេចក្តី

ការរៀននិងបង្រៀនការអនុវត្តសរសេរតែងសេចក្តីនៅមធ្យមសិក្សាបឋមភូមិ ចែកចេញជាបីដំណាក់កាលគឺ៖

### ១៧.២.១- ការសិក្សាអត្ថបទតែងសេចក្តីគំរូ

## លំនាំបង្រៀនការសិក្សាអត្ថបទតែងសេចក្តីគំរូ

អត្ថបទតែងសេចក្តីគំរូនេះ មានច្រើនបែប ច្រើនយ៉ាង អាស្រ័យទៅតាមប្រភេទនៃប្រធានតែងសេចក្តីនីមួយៗ។ ការសិក្សាអត្ថបទតែងសេចក្តីគំរូ មានលំនាំបង្រៀនដូចខាងក្រោម៖

**ក- គោលបំណង**

អត្ថបទតែងសេចក្តីគំរូ គឺជាអត្ថបទដែលមាននៅក្នុងសៀវភៅសិក្សាគោល ឬបើពុំមាននៅក្នុងសៀវភៅសិក្សាគោលទេ គ្រូបង្រៀន សាស្ត្រាចារ្យ គប្បីតាក់តែងអត្ថបទនោះដោយខ្លួនឯងយកមកបង្រៀន។ មុនពេលឈានទៅដល់ដំណាក់កាលអនុវត្តសរសេរតែងសេចក្តី សិស្សត្រូវសិក្សាអត្ថបទតែងសេចក្តីគំរូជាមុនសិន។ ដូច្នេះដើម្បីឱ្យសិស្ស និស្សិតងាយចាប់បានខ្លឹមសារមេរៀន គ្រូបង្រៀន សាស្ត្រាចារ្យ គប្បីបង្ហាញគោលបំណងក្នុងការសិក្សាអត្ថបទតែងសេចក្តីគំរូនេះឱ្យគេបានដឹងជាមុនសិន។

***ឧទាហរណ៍:*** ការសិក្សាអត្ថបទគំរូនៃប្រធានបែបអត្ថាធិប្បាយពន្យល់ មានគោលបំណងឱ្យសិស្សបានយល់ដឹងពី៖

- ប្រភេទនៃប្រធានតែងសេចក្តី : ក្នុងប្រភេទនៃប្រធានតែងសេចក្តីមានចំណុចសំខាន់ៗគឺ លក្ខណៈសម្គាល់របស់ប្រភេទប្រធាន បម្រាប់ប្រធាន និងឃ្លាសំណួរ។
- ទម្រង់នៃប្រភេទតែងសេចក្តីនីមួយៗ ដែលក្នុងនោះមានផ្នែកសំខាន់ៗដូចជា៖
  - ✓ សេចក្តីផ្តើម: ក្នុងសេចក្តីផ្តើមមានចំណុចសំខាន់ៗគឺ លំនាំបញ្ហា ចំណូលបញ្ហា និងចំណោទបញ្ហា និងខ្លឹមសារដែលគេបានបរិយាយនៅតាមចំណុចទាំងនោះ។
  - ✓ តួសេចក្តី: ក្នុងតួសេចក្តីមានចំណុចសំខាន់គឺ ឃ្លាភ្ជាប់សេចក្តី ពន្យល់ពាក្យគន្លឹះ ពន្យល់ន័យប្រធាន បកស្រាយប្រធាន និងសរុបសេចក្តី និងខ្លឹមសារដែលគេបានបរិយាយនៅតាមចំណុចទាំងនោះ។
  - ✓ សេចក្តីបញ្ចប់: ក្នុងសេចក្តីបញ្ចប់មានចំណុចសំខាន់ៗគឺ វាយតម្លៃប្រធាន និងយោបល់ផ្ទាល់ខ្លួន និងខ្លឹមសារដែលគេបានបរិយាយនៅតាមចំណុចទាំងនោះ។

**ខ- ទំនាក់ទំនងមេរៀន**

▪ **ការសិក្សារូបភាព(បើសិនជាមាន)**

ការសិក្សារូបភាព មានគោលបំណងធំៗពីរ ទីមួយគឺបណ្តុះបំណិនសិស្សឱ្យចេះនិយាយរៀបរាប់ ឬពិពណ៌នា និងទីពីរគឺបណ្តុះបំណិនសិស្សឱ្យចេះនិយាយបកស្រាយ ពន្យល់អំពីអត្ថន័យនៃរូបភាពប្រកបដោយលក្ខណៈសមហេតុផល ឡូសិក មានអំណះអំណាង ភស្តុតាង និងមានសក្តិកម្ម។ ដូច្នេះគ្រូបង្រៀន សាស្ត្រាចារ្យ គប្បីប្រើវិធី ឬល្បិចបង្រៀនបែបណាដើម្បីឱ្យសិស្សគិត ត្រិះរិះ ពិចារណាបានស៊ីជម្រៅ។ សកម្មភាពរៀននិងបង្រៀនការសិក្សារូបភាពផ្តោតលើចំណុចសំខាន់ៗពីរគឺ៖

- គ្រូឱ្យសិស្សរៀបរាប់ ឬពិពណ៌នាអំពីរូបភាព៖
  - ✓ គោលបំណងនៃការឱ្យសិស្សរៀបរាប់ឮឬពិពណ៌នាអំពីរូបភាពនេះគឺ ចង់បណ្តុះសិស្សឱ្យមានបំណិនក្នុងការនិយាយរៀបរាប់ ឬការពិពណ៌នាពីរូបភាព តាមរយៈការសង្កេតឃើញដោយផ្ទាល់ភ្នែក មានន័យថាអ្វីដែលគេមើលឃើញនោះ គេអាចលើកមកនិយាយរៀបរាប់បានច្បាស់លាស់មានលក្ខណៈរស់រវើកដែរឬទេ។ ចំណុចនេះ អាចវាយតម្លៃសមត្ថភាពសិស្សបានតាមរយៈការឆ្លើយ

នឹងសំណួរថា តើការនិយាយរៀបរាប់ ឬការពិពណ៌នារបស់សិស្សអាចធ្វើឱ្យអ្នកស្តាប់ក្តាប់បាន ហើយមានអារម្មណ៍ថាហាក់បីដូចជាឃើញនឹងភ្នែកហើយឬនៅ?

- ✓ ដើម្បីសម្រេចគោលបំណងខាងលើ គ្រូបង្រៀន សាស្ត្រាចារ្យ គប្បីរៀបចំសកម្មភាព រៀននិងបង្រៀនយ៉ាងណា ឱ្យសិស្សរៀនសង្កេតផង ហើយអាចនិយាយរៀបរាប់ ឬការពិពណ៌នាពីអ្វីដែលមើលឃើញផង។ ការរៀបចំសកម្មភាពរៀននិងបង្រៀន គ្រូបង្រៀន សាស្ត្រាចារ្យអាចសួរសំណួរបំផុសឱ្យសិស្សឆ្លើយជារួម សិស្សអាចធ្វើសកម្មភាពជាបុគ្គល ដៃគូ ក្រុម ឬអាចរៀបចំជាសកម្មភាពផ្សេងៗទៀតសម្រាប់ដំណើរការរៀននិងបង្រៀន អាស្រ័យទៅតាមពេលវេលា និងស្ថានភាពជាក់ស្តែង។ សំណួរមួយចំនួនដែលគប្បីសួរសិស្សមានដូចជា តើអ្នកឃើញអ្វីខ្លះនៅក្នុងរូបភាពនេះ? ឬតើនៅក្នុងរូបភាពនេះ មានអ្វីខ្លី? ឬចូរអ្នករៀបរាប់ពីរូបភាពមានអ្វីខ្លះ?។ល។

- គ្រូឱ្យសិស្សបកស្រាយ ពន្យល់អំពីអត្ថន័យនៃរូបភាព៖
  - ✓ គោលបំណងនៃការឱ្យសិស្សបកស្រាយ ពន្យល់អំពីអត្ថន័យនៃរូបភាពនេះគឺ ចង់បណ្តុះសិស្សឱ្យមានបំណិនក្នុងការនិយាយបកស្រាយ ពន្យល់ពីអត្ថន័យនៃរូបភាព។ ចំណុចនេះ វាមានលក្ខណៈស៊ីជម្រៅជាងការរៀបរាប់ឬការពិពណ៌នា ព្រោះសិស្សមិនត្រឹមតែធ្វើការសង្កេតឱ្យឃើញផ្ទាល់ភ្នែក ហើយអាចបកស្រាយ ពន្យល់ វែកញែកបាននោះទេ។ ដើម្បីអាចបកស្រាយ ពន្យល់ពីអត្ថន័យនៃរូបភាពបានគឺសិស្សត្រូវសង្កេតឱ្យឃើញផ្ទាល់ភ្នែក គិត ត្រិះរិះ ពិចារណារកគំនិត យោបល់ឱ្យបានស៊ីជម្រៅដើម្បីធ្វើការបកស្រាយ និងត្រូវរកឧទាហរណ៍ អំណះអំណាង ភស្តុតាង និងសក្ខីកម្មឱ្យបានសមស្របយកមកបញ្ជាក់ ឬអះអាង ដើម្បីធ្វើឱ្យការបកស្រាយមានលក្ខណៈជាក់លាក់ ច្បាស់លាស់ សមហេតុផលឡូសិក។ ដូច្នេះមានន័យថាសិស្សត្រូវចេះនិយាយបកស្រាយផង និងចេះលើកឧទាហរណ៍ ឬអំណះអំណាងផង។ ចំណុចនេះ អាចវាយតម្លៃសមត្ថភាពសិស្សបានតាមរយៈការបកស្រាយ ពន្យល់ និងការលើកឧទាហរណ៍ឬការផ្តល់អំណះអំណាងទៅលើសេចក្តីបកស្រាយរបស់សិស្ស។
  - ✓ ដើម្បីសម្រេចគោលបំណងនេះបាន គ្រូបង្រៀន សាស្ត្រាចារ្យ គប្បីរៀបចំសកម្មភាពរៀននិងបង្រៀនយ៉ាងណា ឱ្យសិស្សបានសង្កេត គិត វិភាគ ត្រិះរិះ ពិចារណា ដើម្បីចេះបកស្រាយ និងចេះរកអំណះអំណាងមកបញ្ជាក់។ ការរៀបចំសកម្មភាពរៀននិងបង្រៀន គ្រូបង្រៀន សាស្ត្រាចារ្យអាចសួរសំណួរបំផុសឱ្យសិស្សឆ្លើយជារួម សិស្សអាចធ្វើសកម្មភាពជាបុគ្គល ដៃគូ ក្រុម ឬអាចរៀបចំជាសកម្មភាពផ្សេងៗទៀតសម្រាប់ដំណើរការរៀននិងបង្រៀន អាស្រ័យទៅតាមពេលវេលា និងស្ថានភាពជាក់ស្តែង។ សំណួរមួយចំនួនដែលគប្បីសួរសិស្សមានដូចជា តើរូបភាពនេះមានអត្ថន័យដូចម្តេច? ចូរផ្តល់អំណះអំណាង។ តើរូបភាពនេះចង់និយាយពីអ្វី? ចូរលើកឧទាហរណ៍។ ចូរអ្នកបកស្រាយពីអត្ថន័យនៃរូបភាពនេះ ដោយបញ្ជាក់ពីហេតុផល។ល។

▪ **ការសិក្សាចំណាងជើង**

- ការសិក្សាចំណាងជើង មានគោលបំណងសំខាន់ៗពីរគឺ បណ្តុះបំណិនសិស្សឱ្យចេះបកស្រាយអំពីអត្ថន័យនៃចំណងជើងនិងបណ្តុះបំណិនសិស្សឱ្យចេះការលើកឧទាហរណ៍ឬការផ្តល់អំណះអំណាងទៅលើការបកស្រាយ ដើម្បីឱ្យការបកស្រាយកបដោយភាពច្បាស់លាស់ មានលក្ខណៈសមហេតុផល ឡូសិក មានអំណះអំណាង ភស្តុតាង និងមានសក្ខីកម្ម។ ដូច្នេះមានន័យថាសិស្សត្រូវចេះបក

ស្រាយផង និងត្រូវចេះផ្តល់អំណះអំណាងផង។ គ្រូបង្រៀន សាស្ត្រាចារ្យ គប្បីប្រើវិធី ឬល្បិចបង្រៀនបែបណាដើម្បីឱ្យសិស្សគិត ត្រិះរិះ ពិចារណាបានស៊ីជម្រៅ។

- ដើម្បីសម្រេចគោលបំណងនេះបាន គ្រូបង្រៀន សាស្ត្រាចារ្យ គប្បីរៀបចំសកម្មភាពរៀននិងបង្រៀនយ៉ាងណា ឱ្យសិស្សបានសង្កេត គិត វិភាគ ត្រិះរិះ ពិចារណា ដើម្បីចេះបកស្រាយ និងចេះរកអំណះអំណាងមកបញ្ជាក់។ ការរៀបចំសកម្មភាពរៀននិងបង្រៀន គ្រូបង្រៀន សាស្ត្រាចារ្យអាចសួរសំណួរបំផុសឱ្យសិស្សឆ្លើយជារួម សិស្សអាចធ្វើសកម្មភាពជាបុគ្គល ដៃគូ ក្រុម ឬអាចរៀបចំជាសកម្មភាពផ្សេងៗទៀតសម្រាប់ដំណើរការរៀននិងបង្រៀន អាស្រ័យទៅតាមពេលវេលានិងស្ថានភាពជាក់ស្តែង។ សំណួរមួយចំនួនដែលគប្បីសួរសិស្សមានដូចជា តើចំណងជើងនេះមានអត្ថន័យដូចម្តេច? ហេតុអ្វីបានជាអ្នកហ៊ានបកស្រាយដូច្នោះ? តើចំណងជើងនេះចង់និយាយពីអ្វី? ចូរលើកឧទាហរណ៍។ ចូរអ្នកបកស្រាយពីអត្ថន័យនៃចំណងជើងនេះ ដោយបង្ហាញពីអំណះអំណាង។ល។

▪ **ការផ្សារភ្ជាប់សមត្ថភាពចាំបាច់ទៅនឹងខ្លឹមសារមេរៀនថ្មី**

- តើអ្វីទៅជាសមត្ថភាពចាំបាច់?

សមត្ថភាពចាំបាច់ គឺចំណេះដឹងនិងបំណិនមួយចំនួនដែលមាននៅក្នុងសមត្ថភាពស្រាប់។ សមត្ថភាពមានស្រាប់ គឺជាចំណេះដឹង បំណិន និងបទពិសោធ ដែលសិស្សទទួលបានពីជីវភាពរស់នៅប្រចាំថ្ងៃ គ្រួសារ សហគមន៍ សង្គម មេរៀនមុន និងពីថ្នាក់រៀនមុនជាដើម។ ចំណេះដឹងនេះ មានខ្លឹមសារជាប់ទាក់ទងជាមួយខ្លឹមសារមេរៀនថ្មីដែលយើងនឹងលើកយកមកបង្រៀន។ សមត្ថភាពនេះ គឺជាឈ្នាន់ដែលជាស្ពានឬជាមូលដ្ឋានគ្រឹះ សម្រាប់ទៅចាប់ខ្លឹមសារមេរៀនថ្មី។

- ដើម្បីបំផុសឱ្យបានសមត្ថភាពចាំបាច់នេះ គ្រូបង្រៀន សាស្ត្រាចារ្យ គប្បីរៀបចំសកម្មភាពរៀននិងបង្រៀនយ៉ាងណាឱ្យសិស្សបានសង្កេត ស្រាវជ្រាវ គិត វិភាគ ត្រិះរិះ ពិចារណា អនុវត្ត ដើម្បីបង្ហាញឡើងវិញនូវចំណេះដឹង បំណិនដែលគេមាន ហើយជាប់ទាក់ទៅនឹងខ្លឹមសារមេរៀនថ្មី។ ការរៀបចំសកម្មភាពរៀននិងបង្រៀន គ្រូបង្រៀន សាស្ត្រាចារ្យអាចសួរសំណួរបំផុសឱ្យសិស្សឆ្លើយជារួម សិស្សអាចធ្វើសកម្មភាពជាបុគ្គល ដៃគូ ក្រុម ឬអាចរៀបចំជាសកម្មភាពផ្សេងៗទៀតសម្រាប់ដំណើរការរៀននិងបង្រៀន អាស្រ័យទៅតាមពេលវេលា និងស្ថានភាពជាក់ស្តែង។ សំណួរមួយចំនួនដែលគប្បីសួរសិស្ស គឺសួរទៅលើខ្លឹមសារមេរៀនដែលសិស្សបានរៀនរួច ហើយជាប់ទាក់ទៅនឹងមេរៀនថ្មី។ ឧទារហាណ៍ថា បើមេរៀនតែងសេចក្តីថ្មីដែលនឹងត្រូវលើកយកមកសិក្សា គឺតែងសេចក្តីបែបអត្ថាធិប្បាយពន្យល់សុភាសិត នោះមានន័យថា សិស្សបានសិក្សារួចហើយអំពីតែងសេចក្តីបែបអត្ថាធិប្បាយពន្យល់ទស្សនៈ មតិ ឬពំនោល។ សមត្ថភាពចាំបាច់របស់សិស្ស សម្រាប់យកមកភ្ជាប់ជាមួយមេរៀនថ្មីគឺលក្ខណៈសម្គាល់ប្រធាន គម្រោងតែង ទម្រង់សេចក្តីផ្តើម តួសេចក្តី និងសេចក្តីបញ្ចប់ជាដើម។ ដូច្នេះគ្រូបង្រៀន សាស្ត្រាចារ្យ គប្បីសួរសំណួរផ្តោតលើចំណុចទាំងនេះ។

**គ- ការសិក្សាប្រធាន**

ប្រសិនបើមានប្រធានសរសេរនៅខាងលើអត្ថបទតែងសេចក្តីគំរូ យើងគប្បីដឹកនាំសិស្សសិក្សាប្រធានជាមុនសិន។ ការសិក្សាប្រធាន មានគោលបំណងឱ្យសិស្សកំណត់បានពីប្រភេទប្រធានតែងសេចក្តី។ ការរៀបចំសកម្មភាពរៀននិងបង្រៀន គ្រូបង្រៀន សាស្ត្រាចារ្យអាចសួរសំណួរបំផុសឱ្យសិស្សឆ្លើយជារួម សិស្សអាចធ្វើសកម្មភាពជាបុគ្គល ដៃគូ ក្រុម ឬអាចរៀបចំជាសកម្មភាពផ្សេងៗទៀតសម្រាប់ដំណើរការរៀន

និងបង្រៀន អាស្រ័យទៅតាមពេលវេលា និងស្ថានភាពជាក់ស្តែង។ សំណួរមួយចំនួនដែលគប្បីសួរឱ្យសិស្សឆ្លើយ គឺផ្តោតទៅលើចំណុចសំខាន់ៗដូចខាងក្រោម៖

- ប្រភេទប្រធានតែងសេចក្តី: តើប្រធាននេះជាប្រភេទប្រធានអ្វី?
- សិក្សាលក្ខណៈសម្គាល់របស់ប្រភេទប្រធាន: តើមានលក្ខណៈសម្គាល់ដូចម្តេចដែលអាចបញ្ជាក់ថាជាប្រភេទប្រធាននោះ?
- សិក្សាបម្រាប់ប្រធាន: តើប្រធានប្រភេទនោះមានបម្រាប់ប្រធានដូចម្តេចខ្លះ?
- សិក្សាឃ្លាសំណួរ: តើប្រធានប្រភេទនោះមានឃ្លាសំណួរដូចម្តេចខ្លះ?

### ឃ- ការសិក្សាពាក្យពិបាកក្នុងអត្ថបទ

ការសិក្សាពាក្យពិបាក មានគោលបំណងយល់ន័យពាក្យពិបាកដែលមាននៅក្នុងអត្ថបទ ព្រោះប្រសិនបើមានពាក្យពិបាកសិស្សមិនយល់ នោះមានន័យថាសិស្សក៏អាចនឹងមិនយល់អត្ថបទដែរ។ ពាក្យពិបាក គឺជាពាក្យដែលពិបាកអាន និងពិបាកយល់ន័យ។ ដូច្នេះគ្រូបង្រៀន សាស្ត្រាចារ្យអាចការរៀបចំដំណើរការរៀន និងបង្រៀន ដោយបំផុសសំណួរឱ្យសិស្សឆ្លើយជារួម សិស្សធ្វើសកម្មភាពជាបុគ្គល ដៃគូ ក្រុម ឬអាចរៀបចំជាសកម្មភាពផ្សេងៗទៀត អាស្រ័យទៅតាមពេលវេលានិងស្ថានភាពជាក់ស្តែង។ សកម្មភាពមួយចំនួនដែលគ្រូគប្បីអនុវត្តមានដូចខាងក្រោម៖

- គ្រូឱ្យសិស្សអានអត្ថបទដោយស្ងៀមស្ងាត់ និងរហ័សបំផុតឬអំណានត្រួសៗ ដើម្បីរកពាក្យពិបាកអាន និងពិបាកយល់ន័យ។
- គ្រូឱ្យសិស្សឡើងសរសេរពាក្យពិបាកនៅលើក្តារខៀន។
- គ្រូដឹកនាំសិស្សធ្វើការហ្វឹកហាត់អាន និងពន្យល់ន័យនៃពាក្យពិបាក។

*សម្គាល់:* ករណីក្នុងអត្ថបទមិនមានពាក្យពិបាក យើងមិនចាំបាច់អនុវត្តសកម្មភាពសិក្សាពាក្យពិបាកនេះឡើយ។

### ង- ការហ្វឹកហាត់អានឮ

ការហ្វឹកហាត់អានឮ មានគោលបំណងចង់ផ្ទៀងផ្ទាត់ការអានរបស់សិស្សថា តើពួកគេអានអត្ថបទបានត្រឹមត្រូវហើយ ឬនៅ? ការអានឮអត្ថបទបានត្រឹមផ្តោតលើចំណុចបីសំខាន់ៗគឺ ការអានអត្ថបទរួចមិនទើសទាក់និងការចេះលើកដាក់សំឡេង ការចេះគោរពសញ្ញាវណ្ណវាទ និងការធ្វើកាយវិការបានត្រឹមត្រូវ។ សកម្មភាពដែលគ្រូគប្បីអនុវត្តមានដូចជា៖

- គ្រូ ឬសិស្សអានឮអត្ថបទជាគំរូ។
- គ្រូឱ្យសិស្សហ្វឹកហាត់អានឮជារួម ជាបុគ្គល ជាដៃគូ ឬជាក្រុម ដោយផ្តោតលើបែបបទ ការចេះលើកដាក់សំឡេង ការគោរពសញ្ញាសម្ព័ន្ធ និងការធ្វើកាយវិការបានត្រឹមត្រូវ។

*សម្គាល់:* សម្រាប់សិស្សនៅមធ្យមសិក្សាទុតិយភូមិ បើសាស្ត្រាចារ្យយល់ថាសិស្សមិនមានការលំបាកលើការអាននោះទេ អាចមិនចាំបាច់អនុវត្តសកម្មភាពអានឮនេះក៏បាន។

### ច- ការសិក្សាសំណួរ

ការសិក្សាសំណួរ មានគោលបំណងចង់ឱ្យសិស្សស្វែងខ្លឹងសារសំណួរដែលនឹងត្រូវឆ្លើយ ក្រោយពេលអានអត្ថបទរួច និងចង់ឱ្យសិស្សចេះផ្តោតអារម្មណ៍ទៅខ្លឹមសារសំខាន់ៗនៅពេលអានអត្ថបទ។ ខ្លឹមសារសំណួរ អាចមាននៅខាងក្រោយអត្ថបទតែងសេចក្តីគំរូ តែងសេចក្តី ឬបើអត្ថបទគំរូនៅក្នុងសៀវភៅសិស្សពុំ

មានសំណួរ ឬក៏អត្ថបទគំរូតែងសេចក្តីនោះគ្រូតាក់តែងដោយខ្លួនឯង ក្នុងករណីនេះគ្រូត្រូវរៀបចំខ្លឹមសារសំណួរដោយផ្តោតទៅលើផ្នែកសំខាន់ៗគឺ ការសួរទៅលើខ្លឹសារទូទៅរបស់អត្ថបទ និងការសួរផ្តោតទៅលើទម្រង់តែងសេចក្តីរបស់អត្ថបទ។ គ្រូគប្បីរៀបចំសកម្មភាពរៀននិងបង្រៀនមួយចំនួននៅពេលអានសំណួរដូចខាងក្រោម៖

- គ្រូឱ្យសិស្សម្នាក់ឬក៏ពីរនាក់អានសំណួរ ចំណែកសិស្សដទៃទៀតគ្រូណែនាំឱ្យតាមដានស្តាប់ និងផ្ទៀងផ្ទាត់ ព្រមទាំងត្រិះរិះពិចារណាទៅលើខ្លឹមសារសំណួរ។
- គ្រូសួរសិស្សដើម្បីបញ្ជាក់ពីការយល់ដឹងរបស់សិស្សទៅលើខ្លឹមសារសំណួរ។ គ្រូអាចសួរសិស្សនៅពេលអានសំណួរចប់: តើសំណួរទី១ចង់និយាយពីអ្វី? តើសំណួរទី២ ទី៣ ទី៤...ចង់និយាយពីអ្វី? ក្នុងករណីបើមានសំណួរណាសិស្សមិនទាន់យល់ ឬយល់មិនទាន់ច្បាស់ គ្រូគួរពន្យល់បន្ថែម។

**ឆ- ការស្ទាត់ដើម្បីយល់ន័យ**

ការអានស្ទាត់ មានគោលបំណងឱ្យសិស្សយល់ន័យរបស់អត្ថបទ។ គ្រូគប្បីណែនាំសិស្សឱ្យអានដោយស្ងៀមស្ងាត់ អានដោយផ្តោតលើចំណុចសំខាន់ៗដែលត្រូវឆ្លើយនឹងសំណួរ និងគ្រូកំណត់ពេលវេលាឱ្យបានច្បាស់លាស់សិស្សអាន។ សកម្មភាពរៀននិងបង្រៀនការអានស្ទាត់នេះ ជាទូទៅធ្វើឡើងជាលក្ខណៈបុគ្គល។

**ជ- ការឆ្លើយសំណួរ**

ការឆ្លើយសំណួរមានគោលបំណងចង់វាស់ស្ទង់ការយល់ដឹងរបស់សិស្សទៅលើខ្លឹមសារអត្ថបទ។ សំណួរទាំងនោះ គឺជាសំណួរដែលសិស្សបានអានរួចមកហើយមុនពេលអានស្ទាត់។ នៅពេលឆ្លើយសំណួរ គ្រូគួរណែនាំសិស្សកុំឱ្យមើលអត្ថបទ ឬបិទសៀវភៅតែម្តង។ ក្នុងករណីមានសំណួរណាសិស្សឆ្លើយមិនបានត្រឹមត្រូវ គ្រូអាចអនុញ្ញាតឱ្យសិស្សអានអត្ថបទត្រង់ចំណុចនោះឡើងវិញ ដើម្បីធ្វើការផ្ទៀងផ្ទាត់ចម្លើយរបស់ខ្លួន។ គ្រូគប្បីរៀបចំសកម្មភាពរៀននិងបង្រៀនមួយចំនួននៅពេលឆ្លើយនឹងសំណួរមានដូចខាងក្រោម៖

- គ្រូសួរសំណួរទាក់ទងនឹងខ្លឹមសារទូទៅរបស់អត្ថបទឱ្យសិស្សឆ្លើយ ដើម្បីបញ្ជាក់ពីការយល់ដឹងរបស់សិស្សទៅលើខ្លឹមសារអត្ថបទ។
- គ្រូអាចសួរសំណួរមួយចំនួនដូចខាងក្រោម ដើម្បីទាញខ្លឹមសារអត្ថបទមកបញ្ចូលក្នុងគម្រោងតែងសេចក្តី៖
  - ✓ តើអត្ថបទនេះជាប្រភេទតែងសេចក្តីអ្វី? តើអ្នកមានអំណះអំណាងអ្វីខ្លះ បានជានិយាយថាវាជាប្រភេទតែងសេចក្តីនោះ?
  - ✓ តើអត្ថបទតែងសេចក្តីនេះ ចែកចេញជាប៉ុន្មានផ្នែក? ផ្នែកអ្វីខ្លះ? (ចែកចេញជាបីផ្នែកគឺ សេចក្តីផ្តើម តួសេចក្តី និងសេចក្តីបញ្ចប់)
  - ✓ តើសេចក្តីផ្តើមមានចំណុចសំខាន់ៗចំនួនប៉ុន្មាន? ចំណុចអ្វីខ្លះ? (មានចំណុចសំខាន់ចំនួនបីគឺ លំនាំបញ្ហា ចំណូលបញ្ហាឬបង្ហាញបញ្ហា និងចំណោទបញ្ហា)។
  - ✓ តើនៅក្នុងលំនាំបញ្ហាគេនិយាយដូចម្តេចខ្លះ?
  - ✓ តើនៅក្នុងចំណូលបញ្ហាគេនិយាយដូចម្តេចខ្លះ?
  - ✓ តើនៅក្នុងចំណោទបញ្ហាគេនិយាយដូចម្តេចខ្លះ?
  - ✓ តើតួសេចក្តីមានចំណុចសំខាន់ៗចំនួនប៉ុន្មាន? ចំណុចអ្វីខ្លះ? មានចំណុចសំខាន់ចំនួនប្រាំគឺ ឃ្លាភ្ជាប់សេចក្តី ពន្យល់ពាក្យគន្លឹះ ពន្យល់ន័យប្រធាន បកស្រាយប្រធាន និងសរុបសេចក្តី)។
  - ✓ តើនៅក្នុងឃ្លាភ្ជាប់សេចក្តីគេនិយាយដូចម្តេចខ្លះ?

- ✓ តើនៅក្នុងការពន្យល់ពាក្យគន្លឹះគេនិយាយដូចម្តេចខ្លះ?
- ✓ តើនៅក្នុងការពន្យល់ន័យប្រធានគេនិយាយដូចម្តេចខ្លះ?
- ✓ តើនៅក្នុងការបកស្រាយប្រធានគេនិយាយដូចម្តេចខ្លះ?
- ✓ តើនៅក្នុងសរុបសេចក្តីគេនិយាយដូចម្តេចខ្លះ?
- ✓ តើសេចក្តីបញ្ចប់មានចំណុចសំខាន់ៗចំនួនប៉ុន្មាន? ចំណុចអ្វីខ្លះ? (មានចំណុចសំខាន់ៗចំនួនពីរគឺ
- ✓ វាយតម្លៃប្រធាន និងយោបល់ផ្ទាល់ខ្លួន)។
- ✓ តើនៅក្នុងវាយតម្លៃប្រធានគេនិយាយដូចម្តេចខ្លះ?
- ✓ តើនៅក្នុងយោបល់ផ្ទាល់ខ្លួនគេនិយាយដូចម្តេចខ្លះ?

**ឈ- ការពង្រឹងចំណេះដឹង**

ការពង្រឹងចំណេះដឹង មានគោលបំណងចង់វាយតម្លៃការយល់ដឹងរបស់សិស្សទៅលើខ្លឹមសារមេរៀនដែលបានរៀនរួច។ ខ្លឹមសារសំណួរ គប្បីផ្តោតលើចំណុចសំខាន់ៗនៅក្នុងខ្លឹមសារមេរៀន។ ការវាយតម្លៃនេះគួរធ្វើជាលក្ខណៈបុគ្គលប្រសើជាងធ្វើជាក្រុម ឬធ្វើជារួមព្រោះការធ្វើជារួមឬជាក្រុម យើងពិបាកកំណត់ណាស់ថា តើសិស្សណាចេះ ឬសិស្សណាមិនចេះ។ ដូច្នេះក្នុងការសួរសិស្ស គប្បីផ្តោតលើសិស្សរៀនយឺត មានន័យថាបើសិស្សរៀនយឺតអាចឆ្លើយបានត្រឹមត្រូវ នោះមានន័យថាសិស្សដទៃទៀតក៏អាចយល់បានដែរ។ គ្រូគួរចៀសវាងសួរសំណួរវាយតម្លៃដូចជា តើអ្នកយល់ឬទេ? តើមែនឬទេ? ជាដើម ព្រោះសំណួរបែបនេះមិនអាចវាយតម្លៃការយល់ដឹងរបស់សិស្សបានច្បាស់លាស់ឡើយ។

**ញ- ការដាក់កិច្ចការស្រាវជ្រាវ**

ការដាក់កិច្ចការស្រាវជ្រាវមានគោលបំណងឱ្យសិស្សមានបំណិនក្នុងការសិក្សាស្រាវជ្រាវ។ ដូច្នេះចំណុចសំខាន់ដែលចង់ឱ្យសិស្សចេះនៅក្នុងចំណុចនេះគឺ សិស្សយល់ដឹងពីវិធីស្រាវជ្រាវ និងសិស្សចេះចងក្រងខ្លឹមសារនៃការសិក្សាស្រាវជ្រាវ។ គ្រូគប្បីដាក់ប្រធានបទ ឬសំណួរ ឬលំហាត់ឱ្យសិស្សសិក្សាស្រាវជ្រាវ។ ខ្លឹមសារសម្រាប់ការសិក្សាស្រាវជ្រាវ គឺទាក់ទៅនឹងខ្លឹមសារមេរៀនដែលបានរៀនរួចឬខ្លឹមសារមេរៀនខាងមុខដើម្បីឱ្យសិស្សមានចំណេះដឹងបន្ថែមកាន់តែទូលំទូលាយ។ ក្នុងសកម្មភាពសិក្សាស្រាវជ្រាវនេះ គប្បីរៀបចំសកម្មភាពមួយចំនួនដូចខាងក្រោម៖

- ការរៀបចំប្រធានបទ ឬសំណួរ ឬលំហាត់
- រូបភាពនៃការសិក្សាស្រាវជ្រាវ(ជាបុគ្គល ដៃគូ ក្រុម)
- ការរៀបចំដំណើរការសិក្សាស្រាវជ្រាវ(កំណត់សកម្មភាពសម្រាប់ដំណើរការសិក្សាស្រាវជ្រាវ តើត្រូវធ្វើសកម្មភាពអ្វីខ្លះ? តើសកម្មភាពណាធ្វើមុន សកម្មភាពណាធ្វើបន្ទាប់ សកម្មភាពណាធ្វើក្រោយ?
- ការកំណត់ទីកន្លែង
- ការកំណត់ពេលវេលា
- ការរៀបចំចងក្រងខ្លឹមសារនៃការសិក្សាស្រាវជ្រាវអំពីប្រធានបទ ឬសំណួរ ឬលំហាត់
- ការរៀបចំរបាយការណ៍
- ការបង្ហាញលទ្ធផលស្រាវជ្រាវ។

**ដ- ការសង្ខេបសកម្មភាពនិងខ្លឹមសារសំខាន់ៗ**

ការសង្ខេប មានគោលបំណងចង់ឱ្យសិស្ស ចេះនិយាយសង្ខេបឡើងវិញនូវសកម្មភាពរៀននិងបង្រៀនមេរៀននេះ និងចេះសង្ខេបខ្លឹមសារសំខាន់ៗដែលបានរៀននៅក្នុងមេរៀននេះ។ ដើម្បីអាចធ្វើសង្ខេបបានលុះ

ត្រាតែយកចិត្តទុកដាក់រៀនសូត្រ ចេះកត់ត្រាពីសកម្មភាព និងខ្លឹមសារសំខាន់ដែលបានរៀននិងបង្រៀន។ ដូច្នេះគ្រូគប្បីណែនាំសិស្សឱ្យកត់ត្រាពីសកម្មភាពរៀននិងបង្រៀននិងណែនាំសិស្សឱ្យយល់ដឹងពីវិធីកត់ត្រាផងដែរ។ ការសង្ខេបនេះ ច្រើនធ្វើជាលក្ខណៈបុគ្គលដោយមានការផ្លាស់ប្តូរវេនគ្នា ជាពិសេសត្រូវផ្តោតលើសិស្សរៀនយឺតឱ្យបានអនុវត្តច្រើនជាងគេ។

**ថ- ការបូកសរុប**

គ្រូធ្វើការបូកសរុបខ្លឹមសារសំខាន់ៗ ដែលតម្រូវឱ្យសិស្សយកចិត្តទុកដាក់ និងអាចណែនាំបន្ថែមឬពន្យល់បន្ថែម ទៅលើចំណុចមួយចំនួនដែលសិស្សខ្វះខាត ឬចំណុចសិស្សមិនទាន់យល់ច្បាស់។

**ឌ- ការកត់ត្រាមេរៀន**

សកម្មភាពកត់ត្រាមេរៀននេះ មានគោលបំណងឱ្យសិស្សចេះកត់នូវអ្វីដែលគេបានរៀន។ ការកត់ត្រាមិនមែនរង់ចាំដល់ចប់ទើបកត់នោះទេ ពោលគឺសិស្សត្រូវចេះកត់បណ្តើរៗនូវខ្លឹមសារផ្សេងៗតាមរយៈការស្តាប់ ការឆ្លើយសំណួរ ការធ្វើសកម្មភាព ការអាន និងការពន្យល់របស់គ្រូជាដើម។ គ្រូគប្បីណែនាំសិស្សឱ្យកត់ត្រា និងណែនាំសិស្សឱ្យយល់ដឹងពីវិធីកត់ត្រាផងដែរ។

### ១៧.២.២- ការសិក្សាគម្រោងតែងសេចក្តី

## លំនាំបង្រៀនការសិក្សាគម្រោងតែងសេចក្តី

ការសិក្សាគម្រោងតែងសេចក្តី គឺជាការចាំបាច់មួយដ៏មានសារៈសំខាន់ក្នុងដំណើររៀននិងបង្រៀនតែងសេចក្តី។ ដើម្បីសរសេរតែងសេចក្តីបានល្អ សិស្សត្រូវចេះធ្វើគម្រោងតែងជាមុនសិន។ ដើម្បីមានសមត្ថភាពអាចធ្វើគម្រោងតែងបាន គឺសិស្សត្រូវយល់ដឹងច្បាស់លាស់ពីវិធីធ្វើគម្រោង។ ដូច្នេះដើម្បីឱ្យយល់ដឹងពីវិធីគម្រោងតែងសេចក្តីគ្រូបង្រៀន សាស្ត្រាចារ្យ គប្បីរៀបចំសកម្មភាពរៀននិងបង្រៀនមួយចំនួនដូចខាងក្រោម៖

**ក- គោលបំណង**

ការសិក្សាគម្រោងតែងសេចក្តីគឺជាការចាំបាច់មួយដែលសិស្សត្រូវចេះ មុនពេលឈានទៅដល់ដំណាក់សរសេរតែងសេចក្តី។ ដូច្នេះដើម្បីឱ្យសិស្ស និស្សិតងាយចាប់បានខ្លឹមសារមេរៀន គ្រូបង្រៀន សាស្ត្រាចារ្យគប្បីបង្ហាញគោលបំណងនៃការសិក្សាគម្រោងតែងសេចក្តីនេះឱ្យគេបានដឹងជាមុនសិន។

***ឧទាហរណ៍:*** ការសិក្សាគម្រោងនៃប្រធានបែបអត្ថាធិប្បាយពន្យល់ មានគោលបំណងឱ្យសិស្សបានយល់ដឹងពី៖

- ប្រភេទនៃប្រធានតែងសេចក្តី: ក្នុងប្រភេទនៃប្រធានតែងសេចក្តីមានចំណុចសំខាន់ៗគឺ លក្ខណៈសម្គាល់របស់ប្រភេទប្រធាន បម្រាប់ប្រធាន និងឃ្លាសំណួរ។
- ទម្រង់នៃប្រភេទតែងសេចក្តីនីមួយៗ ដែលក្នុងនោះមានផ្នែកសំខាន់ៗដូចជា៖
  - ✓ សេចក្តីផ្តើម មានចំណុចសំខាន់ៗបីគឺ លំនាំបញ្ហា ចំណូលបញ្ហា និងចំណោទបញ្ហា
  - ✓ តួសេចក្តី មានចំណុចសំខាន់ៗប្រាំគឺ ឃ្លាភ្ជាប់សេចក្តី ពន្យល់ពាក្យគន្លឹះ ពន្យល់ន័យប្រធាន បកស្រាយប្រធាន និងសរុបសេចក្តី
  - ✓ សេចក្តីបញ្ចប់ មានចំណុចសំខាន់ៗពីរគឺ វាយតម្លៃប្រធាន និងយោបល់ផ្ទាល់ខ្លួន។

**ខ- ទំនាក់ទំនងមេរៀន**

គ្រូសួរសំណួរដើម្បីផ្សារភ្ជាប់សមត្ថភាពចាំបាច់ ឬបទពិសោធរបស់សិស្សទៅនឹងខ្លឹមសារមេរៀនថ្មី។

**គ- ការអានអត្ថបទ**

គ្រូឱ្យសិស្សហ្វឹកហាត់អានខ្លឹមសារគម្រោងទាំងមូល។

**ឃ- គ្រូដឹកនាំសិស្សការសិក្សាប្រធានះ**

ការរៀបចំសកម្មភាពរៀននិងបង្រៀនគប្បីផ្តោតលើចំណុចមួយចំនួនដូចខាងក្រោមះ

- ប្រភេទប្រធានតែងសេចក្តី: តើប្រធាននេះជាប្រភេទប្រធានអ្វី?
- សិក្សាលក្ខណៈសម្គាល់របស់ប្រភេទប្រធាន: តើមានលក្ខណៈសម្គាល់ដូចម្តេច ដែលអាចបញ្ជាក់ថាជាប្រភេទប្រធាននោះ?
- សិក្សាបម្រាប់ប្រធាន: តើប្រធានប្រភេទនោះមានបម្រាប់ប្រធានដូចម្តេចខ្លះ?
- សិក្សាឃ្លាសំណួរ: តើប្រធានប្រភេទនោះមានឃ្លាសំណួរដូចម្តេចខ្លះ?

**ង- ការសិក្សាទម្រង់នៃគម្រោងតែងសេចក្តី**

ការសិក្សាទម្រង់នៃគម្រោងតែងសេចក្តី មានគោលបំណងឱ្យសិស្សយល់ដឹងពីទម្រង់នៃគម្រោរបស់ប្រភេទតែងសេចក្តីនីមួយៗ។ ការសិក្សាទម្រង់នេះ គ្រូអាចរៀបចំសកម្មភាពរៀននិងបង្រៀននិងអាស្រ័យទៅតាមប្រភេទតែងសេចក្តីនីមួយៗដែលមានទម្រង់ខុសៗគ្នា។ ដូច្នេះគ្រូបង្រៀន សាស្ត្រាចារ្យអាចការរៀបចំដំណើរការរៀននិងបង្រៀន ដោយបំផុសសំណួរឱ្យសិស្សឆ្លើយជារួម សិស្សធ្វើសកម្មភាពជាបុគ្គល ដៃគូ ក្រុម ឬអាចរៀបចំជាសកម្មភាពផ្សេងៗទៀត អាស្រ័យទៅតាមពេលវេលា និងស្ថានភាពជាក់ស្តែង។ សកម្មភាពមួយចំនួនដែលគ្រូគប្បីអនុវត្តមានដូចខាងក្រោមះ

**ង.១- ទម្រង់នៃគម្រោងតែងសេចក្តីបែបពិពណ៌នាពីបាតុភូតធម្មជាតិ**

## តែងសេចក្តីបែបពិពណ៌នាពីបាតុភូតធម្មជាតិ

- តើគម្រោងតែងសេចក្តីនេះ ចែកចេញជាប៉ុន្មានផ្នែក? ផ្នែកអ្វីខ្លះ? (សេចក្តីផ្តើម តួសេចក្តីនិងសេចក្តីបញ្ចប់)។
- ការសិក្សាសេចក្តីផ្តើម: តើសេចក្តីផ្តើមនៃតែងសេចក្តីនេះមានចំណុចសំខាន់ៗអ្វីខ្លះ? (ពេលវេលា ទីកន្លែង ឈ្មោះ...)។
- ការសិក្សាតួសេចក្តី: តើតួសេចក្តីនៃតែងសេចក្តីនេះមានចំណុចសំខាន់ៗអ្វីខ្លះ? (មុនពេលកើតហេតុ ...ពេលកើតហេតុ...ក្រោយពេលកើតហេតុ... និងតើចំណុចនីមួយៗរៀបរាប់ផ្តោតលើអ្វីខ្លះ?...)
- ការសិក្សាសេចក្តីបញ្ចប់: តើសេចក្តីបញ្ចប់នៃតែងសេចក្តីនេះមានចំណុចសំខាន់ៗអ្វីខ្លះ? (វាយតម្លៃ ចំណាប់អារម្មណ៍...)
  - ✓ វាយតម្លៃ: តើចំណុចនេះត្រូវរៀបរាប់ផ្តោតលើអ្វីខ្លះ? (វាយតម្លៃផលប៉ះពាល់...)
  - ✓ ចំណាប់អារម្មណ៍: តើចំណុចនេះត្រូវរៀបរាប់ផ្តោតលើអ្វីខ្លះ? ( រៀបរាប់ពីអារម្មណ៍របស់អ្នកសរសេរ ឬអារម្មណ៍មនុស្សទូទៅចំពោះបាតុភូតនោះ...។

### ង.២- ទម្រង់នៃគម្រោងតែងសេចក្ដីបែបពិពណ៌នាពីការនិទានរឿង

## តែងសេចក្ដីបែបពិពណ៌នាពីការនិទានរឿង

- តើគម្រោងតែងសេចក្ដីនេះ ចែកចេញជាប៉ុន្មានផ្នែក? ផ្នែកអ្វីខ្លះ? (សេចក្ដីផ្ដើម តួសេចក្ដីនិងសេចក្ដីបញ្ចប់)។
- ការសិក្សាសេចក្ដីផ្ដើម: តើសេចក្ដីផ្ដើមនៃតែងសេចក្ដីនេះមានចំណុចសំខាន់ៗអ្វីខ្លះ? (ពេលវេលា ទីកន្លែង ឈ្មោះ... )។
- ការសិក្សាតួសេចក្ដី: តើតួសេចក្ដីនៃតែងសេចក្ដីនេះមានចំណុចសំខាន់ៗអ្វីខ្លះ? (ការនិទានដំណើររឿងទាំងមូល...ការបញ្ចប់រឿង...)
  - ✓ ការនិទានដំណើររឿងទាំងមូល: តើនៅក្នុងចំណុចនេះត្រូវពិពណ៌នាផ្ដោតទៅលើអ្វីខ្លះ? (តួអង្គ សកម្មភាព... ហើយនិទានតាមបែបបុរសទី៣...)
  - ✓ ការបញ្ចប់រឿង: តើនៅក្នុងចំណុចនេះត្រូវពិពណ៌នាផ្ដោតទៅលើអ្វីខ្លះ? (តើរឿងនោះបញ្ចប់ដោយរបៀបណា...)។
- ការសិក្សាសេចក្ដីបញ្ចប់: តើសេចក្ដីបញ្ចប់នៃតែងសេចក្ដីនេះមានចំណុចសំខាន់ៗអ្វីខ្លះ?(វាយតម្លៃ ចំណាប់អារម្មណ៍...)
  - ✓ វាយតម្លៃ: តើចំណុចនេះត្រូវរៀបរាប់ផ្ដោតលើអ្វីខ្លះ?(វាយតម្លៃថាល្អ...មានប្រយោជន៍...)
  - ✓ ចំណាប់អារម្មណ៍: តើចំណុចនេះត្រូវរៀបរាប់ផ្ដោតលើអ្វីខ្លះ?(រៀបរាប់ពីអារម្មណ៍របស់អ្នកសរសេរ ឬអារម្មណ៍មនុស្សទូទៅ សេចក្ដីរីករាយ មានអត្ថន័យល្អ...គួរយកគម្រាប់តាមតួអង្គណា មិនគួរយកតាមតួអង្គណា...)។

### ង.៣- ទម្រង់នៃគម្រោងតែងសេចក្ដីបែបពិពណ៌នាពីទេសភាពក្នុងរឿង

## តែងសេចក្ដីបែបពិពណ៌នាពីទេសភាពរឿង

- តើគម្រោងតែងសេចក្ដីនេះ ចែកចេញជាប៉ុន្មានផ្នែក? ផ្នែកអ្វីខ្លះ? (សេចក្ដីផ្ដើម តួសេចក្ដី និងសេចក្ដីបញ្ចប់)។
- ការសិក្សាសេចក្ដីផ្ដើម: តើសេចក្ដីផ្ដើមនៃតែងសេចក្ដីនេះមានចំណុចសំខាន់ៗអ្វីខ្លះ? (ចំណងជើងរឿង ឈ្មោះអ្នកនិពន្ធ កាលកំណត់តែង...)។
- ការសិក្សាតួសេចក្ដី: តើតួសេចក្ដីនៃតែងសេចក្ដីនេះមានចំណុចសំខាន់ៗអ្វីខ្លះ? (ឃ្លាភ្ជាប់សេចក្ដី... សេចក្ដីដកស្រង់ពីការពណ៌នាទេសភាពក្នុងរឿង...)
  - ✓ ឃ្លាភ្ជាប់សេចក្ដី: តើនៅក្នុងចំណុចនេះត្រូវពិពណ៌នាផ្ដោតទៅលើអ្វីខ្លះ?(ដើម្បីភ្ជាប់សេចក្ដីផ្ដើមទៅតួសេចក្ដី...)
  - ✓ សេចក្ដីដកស្រង់ពីការពណ៌នាទេសភាពក្នុងរឿង: តើនៅក្នុងចំណុចនេះត្រូវពិពណ៌នាផ្ដោតទៅលើអ្វីខ្លះ? (ដកស្រង់ខ្លឹមសាររឿង...)។
- ការសិក្សាសេចក្ដីបញ្ចប់: តើសេចក្ដីបញ្ចប់នៃតែងសេចក្ដីនេះមានចំណុចសំខាន់ៗអ្វីខ្លះ? (វាយតម្លៃ ចំណាប់អារម្មណ៍...)
  - ✓ វាយតម្លៃ: តើចំណុចនេះត្រូវរៀបរាប់ផ្ដោតលើអ្វីខ្លះ?(វាយតម្លៃលើស្នាដៃអ្នកនិពន្ធថាល្អ...មានសារៈសំខាន់...)

✓ ចំណាប់អារម្មណ៍: តើចំណុចនេះត្រូវរៀបរាប់ផ្តោតលើអ្វីខ្លះ?(រៀបរាប់ពីអារម្មណ៍របស់អ្នកសរសេរ ឬអារម្មណ៍មនុស្សទូទៅ...)។

### ង.៤- ទម្រង់នៃគម្រោងតែងសេចក្តីបែបសរសេរសំបុត្រ

## តែងសេចក្តីបែបសរសេរសំបុត្រ

- តើគម្រោងតែងសេចក្តីនេះ ចែកជាប៉ុន្មានផ្នែក? ផ្នែកអ្វីខ្លះ?(ផ្នែកខាងក្រៅ ផ្នែកខាងក្នុង)។
- ផ្នែកខាងក្រៅ: តើផ្នែកខាងក្រៅមានចំណុចសំខាន់ៗអ្វីខ្លះ? (កាខ្នងសំបុត្រ : ចេញពី...អាសយដ្ឋាន ...គោរពជូនឬជូនចំពោះ...អាសយដ្ឋាន និងតើចំណុចនីមួយៗរៀបរាប់ផ្តោតលើអ្វីខ្លះ?...)។
- ផ្នែកខាងក្នុង: តើផ្នែកខាងក្នុងមានចំណុចសំខាន់ៗអ្វីខ្លះ ?(ក្បាលសំបុត្រ តួសំបុត្រ ការបញ្ចប់សំបុត្រ)
  - ✓ ក្បាលសំបុត្រ: តើនៅក្នុងចំណុចនេះត្រូវពិពណ៌នាផ្តោតទៅលើអ្វីខ្លះ? (ចុះទីន្លែង...ចុះកាលបរិច្ឆេទ...ចំណងជើងសំបុត្រ...)
  - ✓ តួសំបុត្រ: តើនៅក្នុងចំណុចនេះត្រូវពិពណ៌នាផ្តោតទៅលើអ្វីខ្លះ? (រៀបរាប់ពីសុខទុក្ខអ្នកសរសេរ ...សួរសុខទុក្ខអ្នកដែលទទួលសំបុត្រ...សរសេររៀបរាប់រឿងរ៉ាវផ្សេងៗមានដូចជា ដំណឹង ការសប្បាយ ទុក្ខព្រួយ...)
  - ✓ ការបញ្ចប់សំបុត្រ: តើនៅក្នុងចំណុចនេះត្រូវពិពណ៌នាផ្តោតទៅលើអ្វីខ្លះ? (ជូនពរ...ភ្ជាប់ឃ្លាបញ្ចប់សំបុត្រ...ចុះហត្ថលេខា...ចុះឈ្មោះអ្នកសរសេរ...)។

### ង.៥- ទម្រង់នៃគម្រោងតែងសេចក្តីបែបអត្ថាធិប្បាយពន្យល់ទស្សនៈ មតិ ពំនោល

## តែងសេចក្តីបែបអត្ថាធិប្បាយពន្យល់ទស្សនៈ មតិ ពំនោល

- តើគម្រោងតែងសេចក្តីនេះ ចែកចេញជាប៉ុន្មានផ្នែក? ផ្នែកអ្វីខ្លះ? (ចែកចេញជាបីផ្នែកគឺ សេចក្តីផ្តើម តួសេចក្តី និងសេចក្តីបញ្ចប់)។
- ការសិក្សាសេចក្តីផ្តើម: តើសេចក្តីផ្តើមនៃតែងសេចក្តីនេះមានចំណុចសំខាន់ៗចំនួនប៉ុន្មាន? ចំណុចអ្វីខ្លះ? (មានចំណុចសំខាន់ៗចំនួនបីគឺ លំនាំបញ្ហា ចំណូលបញ្ហាឬបង្ហាញបញ្ហា និងចំណោទបញ្ហា)
  - ✓ លំនាំបញ្ហា: តើនៅក្នុងលំនាំបញ្ហាគេនិយាយផ្តោតទៅលើអ្វីខ្លះ? (គំនិតទូទៅ...យោបល់ដែលជាលំនាំដើម...)
  - ✓ ចំណូលបញ្ហាឬបង្ហាញបញ្ហា: តើនៅក្នុងចំណូលបញ្ហាឬបង្ហាញបញ្ហាគេនិយាយផ្តោតទៅលើអ្វីខ្លះ? (បញ្ចូលបញ្ហារបស់ប្រធាន...)
  - ✓ ចំណោទបញ្ហា: តើនៅក្នុងចំណោទបញ្ហាគេនិយាយផ្តោតទៅលើអ្វីខ្លះ? (ចោទសួរទៅលើប្រធាន...)។
- ការសិក្សាតួសេចក្តី: តើតួសេចក្តីនៃតែងសេចក្តីនេះមានចំណុចសំខាន់ៗចំនួនប៉ុន្មាន? ចំណុចអ្វីខ្លះ? (មានចំណុចសំខាន់ចំនួនប្រាំគឺ ឃ្លាភ្ជាប់សេចក្តី ពន្យល់ពាក្យគន្លឹះ ពន្យល់ន័យប្រធាន បកស្រាយប្រធាន និងសរុបសេចក្តី)
  - ✓ ឃ្លាភ្ជាប់សេចក្តី: តើនៅក្នុងឃ្លាភ្ជាប់សេចក្តីគេនិយាយផ្តោតទៅលើអ្វីខ្លះ? (ឃ្លាសម្រាប់ ជាកិច្ចចាប់ផ្តើម ដើម្បីភ្ជាប់ពីសេចក្តីផ្តើមទៅនឹងការពន្យល់ពាក្យគន្លឹះ...)
  - ✓ ពន្យល់ពាក្យគន្លឹះ: តើនៅក្នុងការពន្យល់ពាក្យគន្លឹះគេនិយាយផ្តោតទៅលើអ្វីខ្លះ? (ពន្យល់ន័យរបស់ពាក្យគន្លឹះនៃប្រធាន...)

- ✓ ពន្យល់ន័យប្រធាន: តើនៅក្នុងការពន្យល់ន័យប្រធានគេនិយាយផ្តោតទៅលើអ្វីខ្លះ? (ការបញ្ចូលគ្នាឡើងវិញនូវន័យរបស់ពាក្យគន្លឹះតាមន័យប្រធាន...)
- ✓ បកស្រាយប្រធាន: តើនៅក្នុងការបកស្រាយប្រធានគេនិយាយផ្តោតទៅលើអ្វីខ្លះ?(អាចបកស្រាយបានជាច្រើនគំនិត អាស្រ័យទៅតាមខ្លឹមសាររបស់ប្រធាន។ ក្នុងការបកស្រាយគំនិតនីមួយៗ អ្នកធ្វើតែងសេចក្តីគប្បីលើកមកភ្ជាប់ជានូវអំណះអំណាងឬឧទាហរណ៍ ដើម្បីបញ្ជាក់ទៅលើការបកស្រាយឱ្យកាន់តែច្បាស់លាស់...)
- ✓ សរុបសេចក្តី: តើនៅក្នុងសរុបសេចក្តីគេនិយាយផ្តោតទៅលើអ្វីខ្លះ? (ការប្រមូលបញ្ចូលគ្នានូវគំនិតដែលបានបកស្រាយបំភ្លឺរួចហើយដើម្បីគាំទ្រគំនិត ទស្សនៈរបស់ប្រធានឱ្យកាន់តែប្រាកដឡើង...)។

- ការសិក្សាសេចក្តីបញ្ចប់: តើសេចក្តីបញ្ចប់នៃតែងសេចក្តីនេះមានចំណុចសំខាន់ៗចំនួនប៉ុន្មាន? ចំណុចអ្វីខ្លះ? (មានចំណុចសំខាន់ចំនួនពីរគឺ វាយតម្លៃប្រធាន និងយោបល់ផ្ទាល់ខ្លួន)
  - ✓ វាយតម្លៃប្រធាន: តើនៅក្នុងវាយតម្លៃប្រធានគេនិយាយផ្តោតទៅលើអ្វីខ្លះ? (ការឱ្យតម្លៃប្រធានថាមានន័យ មានប្រយោជន៍ទៅតាមគោលបំណងរបស់ប្រធាន...)
  - ✓ យោបល់ផ្ទាល់ខ្លួន: តើនៅក្នុងយោបល់ផ្ទាល់ខ្លួនគេនិយាយផ្តោតទៅលើអ្វីខ្លះ? (ចំណាប់អារម្មណ៍ផ្ទាល់ខ្លួន របស់អ្នកសរសេរតែងសេចក្តី ចំពោះប្រធានដែលចោទឡើងខាងលើ និងយោបល់ផ្ទាល់ខ្លួនតាមរយៈបទពិសោធ ឬគោលគំនិតរបស់ប្រធាន...)។

### ង.៦- ទម្រង់នៃគម្រោងតែងសេចក្តីបែបអត្ថាធិប្បាយពន្យល់សុភាសិត

## តែងសេចក្តីបែបអត្ថាធិប្បាយពន្យល់សុភាសិត

- តើគម្រោងតែងសេចក្តីនេះ ចែកចេញជាប៉ុន្មានផ្នែក? ផ្នែកអ្វីខ្លះ? (ចែកចេញជាបីផ្នែកគឺ សេចក្តីផ្តើម តួសេចក្តី និងសេចក្តីបញ្ចប់)។
- ការសិក្សាសេចក្តីផ្តើម: តើសេចក្តីផ្តើមនៃតែងសេចក្តីនេះមានចំណុចសំខាន់ៗចំនួនប៉ុន្មាន? ចំណុចអ្វីខ្លះ? (មានចំណុចសំខាន់ៗចំនួនបីគឺ លំនាំបញ្ហា ចំណូលបញ្ហាឬបង្ហាញបញ្ហា និងចំណោទបញ្ហា)
- លំនាំបញ្ហា: តើនៅក្នុងលំនាំបញ្ហាគេនិយាយផ្តោតទៅលើអ្វីខ្លះ? (គំនិតទូទៅ...យោបល់ដែលជាលំនាំដើម...)
  - ✓ ចំណូលបញ្ហាឬបង្ហាញបញ្ហា: តើនៅក្នុងចំណូលបញ្ហាឬបង្ហាញបញ្ហាគេនិយាយផ្តោតទៅលើអ្វីខ្លះ? (បញ្ចូលបញ្ហារបស់ប្រធាន...)
  - ✓ ចំណោទបញ្ហា: តើនៅក្នុងចំណោទបញ្ហាគេនិយាយផ្តោតទៅលើអ្វីខ្លះ? (ចោទសួរទៅលើប្រធាន...)
- ការសិក្សាតួសេចក្តី: តើតួសេចក្តីនៃតែងសេចក្តីនេះមានចំណុចសំខាន់ៗចំនួនប៉ុន្មាន? ចំណុចអ្វីខ្លះ? (មានចំណុចសំខាន់ចំនួនប្រាំគឺ ឃ្លាភ្ជាប់សេចក្តី ពន្យល់ពាក្យគន្លឹះ ពន្យល់ន័យប្រធាន បកស្រាយប្រធាន និងសរុបសេចក្តី)
  - ✓ ឃ្លាភ្ជាប់សេចក្តី: តើនៅក្នុងឃ្លាភ្ជាប់សេចក្តីគេនិយាយផ្តោតទៅលើអ្វីខ្លះ? (ឃ្លាសម្រាប់ ជាកិច្ចចាប់ផ្តើម ដើម្បីភ្ជាប់ពីសេចក្តីផ្តើមទៅនឹងការពន្យល់ពាក្យគន្លឹះ...)
  - ✓ ពន្យល់ពាក្យគន្លឹះ: តើនៅក្នុងការពន្យល់ពាក្យគន្លឹះគេនិយាយផ្តោតទៅលើអ្វីខ្លះ? (ពន្យល់ន័យរបស់ពាក្យគន្លឹះនៃប្រធាន...)

✓ ពន្យល់ន័យប្រធាន: តើនៅក្នុងការពន្យល់ន័យប្រធានគេនិយាយផ្តោតទៅលើអ្វីខ្លះ? (ការបញ្ចូលគ្នាឡើងវិញនូវន័យរបស់ពាក្យគន្លឹះតាមន័យប្រធាន...)

✓ បកស្រាយប្រធាន: តើការបកស្រាយប្រធានមានចំណុចសំខាន់ៗចំនួនប៉ុន្មាន? ចំណុចអ្វីខ្លះ? (មានចំណុចសំខាន់ៗចំនួនពីគឺ ការបកស្រាយន័យអត្ថានុរូបឬន័យត្រង់ និងបកស្រាយអត្ថបដិរូបឬន័យធៀប)

- បកស្រាយន័យអត្ថានុរូបឬន័យត្រង់: តើនៅក្នុងការបកស្រាយន័យអត្ថានុរូបឬន័យត្រង់គេនិយាយផ្តោតទៅលើអ្វីខ្លះ? (បកស្រាយពីខ្លឹមសារត្រង់ៗរបស់ប្រធានដែលបានលើកមកនិយាយតែម្តង ដោយភ្ជាប់នឹងអំណះអំណាងឬឧទាហរណ៍បញ្ជាក់ច្បាស់លាស់...)

- បកស្រាយអត្ថបដិរូបឬន័យធៀប: តើនៅក្នុងការបកស្រាយអត្ថបដិរូបឬន័យធៀបគេនិយាយផ្តោតទៅលើអ្វីខ្លះ? (ស្រាយបំភ្លឺពីន័យបង្កប់ឬន័យប្រៀបប្រដូចរបស់ប្រធាន ដោយភ្ជាប់នឹងអំណះអំណាង ឬឧទាហរណ៍បញ្ជាក់ឱ្យបានច្បាស់លាស់...)

✓ សរុបសេចក្តី: តើនៅក្នុងសរុបសេចក្តីគេនិយាយផ្តោតទៅលើអ្វីខ្លះ?(ការប្រមូលបញ្ចូលគ្នានូវគំនិតដែលបានបកស្រាយបំភ្លឺរួចហើយ ដើម្បីគាំទ្រ គំនិត ទស្សនៈរបស់ប្រធានឱ្យកាន់តែប្រាកដឡើង...)។

- ការសិក្សាសេចក្តីបញ្ចប់: តើសេចក្តីបញ្ចប់នៃតែងសេចក្តីនេះមានចំណុចសំខាន់ៗចំនួនប៉ុន្មាន? ចំណុចអ្វីខ្លះ? (មានចំណុចសំខាន់ចំនួនពីរគឺ វាយតម្លៃប្រធាន និងយោបល់ផ្ទាល់ខ្លួន)

✓ វាយតម្លៃប្រធាន: តើនៅក្នុងវាយតម្លៃប្រធានគេនិយាយផ្តោតទៅលើអ្វីខ្លះ? (ការឱ្យតម្លៃប្រធានថាមានន័យ មានប្រយោជន៍ទៅតាមគោលបំណងរបស់ប្រធាន...)

✓ យោបល់ផ្ទាល់ខ្លួន: តើនៅក្នុងយោបល់ផ្ទាល់ខ្លួនគេនិយាយផ្តោតទៅលើអ្វីខ្លះ?(ចំណាប់អារម្មណ៍របស់អ្នកសរសេរតែងសេចក្តី ចំពោះប្រធានដែលចោទឡើងខាងលើ និងយោបល់ផ្ទាល់ខ្លួនតាមរយៈបទពិសោធ ឬគោលគំនិតរបស់ប្រធាន...)។

**ង.៧- ទម្រង់នៃគម្រោងតែងសេចក្តីបែបអត្ថាធិប្បាយពន្យល់អក្សរសិល្ប៍**

## តែងសេចក្តីបែបអត្ថាធិប្បាយពន្យល់អក្សរសិល្ប៍

- តើគម្រោងតែងសេចក្តីនេះ ចែកចេញជាប៉ុន្មានផ្នែក? ផ្នែកអ្វីខ្លះ? (ចែកចេញជាបីផ្នែកគឺ សេចក្តីផ្តើម តួសេចក្តី និងសេចក្តីបញ្ចប់)។

- ការសិក្សាសេចក្តីផ្តើម: តើសេចក្តីផ្តើមនៃតែងសេចក្តីនេះមានចំណុចសំខាន់ៗចំនួនប៉ុន្មាន? ចំណុចអ្វីខ្លះ? (មានចំណុចសំខាន់ៗចំនួនបីគឺ លំនាំបញ្ហា ចំណូលបញ្ហាឬបង្ហាញបញ្ហា និងចំណោទបញ្ហា)

✓ លំនាំបញ្ហា: តើនៅក្នុងលំនាំបញ្ហាគេនិយាយផ្តោតទៅលើអ្វីខ្លះ? (គំនិតទូទៅ ... យោបល់ដែលជាលំនាំដើម...)

✓ ចំណូលបញ្ហាឬបង្ហាញបញ្ហា: តើនៅក្នុងចំណូលបញ្ហាឬបង្ហាញបញ្ហាគេនិយាយផ្តោតទៅលើអ្វីខ្លះ? (បញ្ចូលបញ្ហារបស់ប្រធាន...)

✓ ចំណោទបញ្ហា: តើនៅក្នុងចំណោទបញ្ហាគេនិយាយផ្តោតទៅលើអ្វីខ្លះ?(ចោទសួរទៅលើប្រធាន...)។

- ការសិក្សាតួសេចក្ដី: តើតួសេចក្ដីនៃតែងសេចក្ដីនេះមានចំណុចសំខាន់ៗចំនួនប៉ុន្មាន? ចំណុចអ្វីខ្លះ? (មានចំណុចសំខាន់ចំនួនប្រាំគឺ ឃ្លាភ្ជាប់សេចក្ដី ពន្យល់ពាក្យគន្លឹះ ពន្យល់ន័យប្រធាន បកស្រាយប្រធាន និងសរុបសេចក្ដី)
  - ✓ ឃ្លាភ្ជាប់សេចក្ដី: តើនៅក្នុងឃ្លាភ្ជាប់សេចក្ដីគេនិយាយផ្ដោតទៅលើអ្វីខ្លះ? (ឃ្លាសម្រាប់ ជាកិច្ចចាប់ផ្ដើម ដើម្បីភ្ជាប់ពីសេចក្ដីផ្ដើមទៅនឹងការពន្យល់ពាក្យគន្លឹះ...)
  - ✓ ពន្យល់ពាក្យគន្លឹះ: តើនៅក្នុងការពន្យល់ពាក្យគន្លឹះគេនិយាយផ្ដោតទៅលើអ្វីខ្លះ? (ពន្យល់ន័យរបស់ពាក្យគន្លឹះនៃប្រធាន...)
  - ✓ ពន្យល់ន័យប្រធាន: តើនៅក្នុងការពន្យល់ន័យប្រធានគេនិយាយផ្ដោតទៅលើអ្វីខ្លះ? (ការបញ្ចូលគ្នាឡើងវិញនូវន័យរបស់ពាក្យគន្លឹះតាមន័យប្រធាន...)
  - ✓ បកស្រាយប្រធាន: តើនៅក្នុងការបកស្រាយប្រធានគេនិយាយផ្ដោតទៅលើអ្វីខ្លះ?(អាចបកស្រាយបានជាច្រើនគំនិត អាស្រ័យទៅតាមខ្លឹមសាររបស់ប្រធាន។ ក្នុងការបកស្រាយគំនិតនីមួយៗ អ្នកធ្វើតែងសេចក្ដីគប្បីលើកមកភ្ជាប់ជានូវអំណះអំណាងឬឧទាហរណ៍ ដើម្បីបញ្ជាក់ទៅលើការបកស្រាយឱ្យកាន់តែច្បាស់លាស់...)
  - ✓ សរុបសេចក្ដី: តើនៅក្នុងសរុបសេចក្ដីគេនិយាយផ្ដោតទៅលើអ្វីខ្លះ? (ការប្រមូលបញ្ចូលគ្នានូវគំនិតដែលបានបកស្រាយបំភ្លឺរួចហើយ ដើម្បីគាំទ្រ គំនិត ទស្សនៈរបស់ប្រធានឱ្យកាន់តែប្រាកដឡើង...)។
- ការសិក្សាសេចក្ដីបញ្ចប់: តើសេចក្ដីបញ្ចប់នៃតែងសេចក្ដីនេះមានចំណុចសំខាន់ៗចំនួនប៉ុន្មាន? ចំណុចអ្វីខ្លះ? (មានចំណុចសំខាន់ចំនួនពីរគឺ វាយតម្លៃប្រធាន និងយោបល់ផ្ទាល់ខ្លួន)
  - ✓ វាយតម្លៃប្រធាន: តើនៅក្នុងវាយតម្លៃប្រធានគេនិយាយផ្ដោតទៅលើអ្វីខ្លះ? (ការឱ្យតម្លៃប្រធានថាមានន័យ មានប្រយោជន៍ទៅតាមគោលបំណងរបស់ប្រធាន...)
  - ✓ យោបល់ផ្ទាល់ខ្លួន: តើនៅក្នុងយោបល់ផ្ទាល់ខ្លួនគេនិយាយផ្ដោតទៅលើអ្វីខ្លះ?(ចំណាប់អារម្មណ៍ផ្ទាល់ខ្លួន របស់អ្នកសរសេរតែងសេចក្ដី ចំពោះប្រធានដែលចោទឡើងខាងលើ និងយោបល់ផ្ទាល់ខ្លួនតាមរយៈបទពិសោធ ឬគោលគំនិតរបស់ប្រធាន...)។

**ង.៨- ទម្រង់នៃគម្រោងតែងសេចក្ដីបែបអត្ថាធិប្បាយប្រៀបធៀប**

## តែងសេចក្ដីបែបអត្ថាធិប្បាយប្រៀបធៀប

- តើគម្រោងតែងសេចក្ដីនេះ ចែកចេញជាប៉ុន្មានផ្នែក? ផ្នែកអ្វីខ្លះ?(ចែកចេញជាបីផ្នែកគឺ សេចក្ដីផ្ដើម តួសេចក្ដី និងសេចក្ដីបញ្ចប់)។
- ការសិក្សាសេចក្ដីផ្ដើម: តើសេចក្ដីផ្ដើមនៃតែងសេចក្ដីនេះមានចំណុចសំខាន់ៗចំនួនប៉ុន្មាន? ចំណុចអ្វីខ្លះ? (មានចំណុចសំខាន់ៗចំនួនបីគឺ លំនាំបញ្ហា ចំណូលបញ្ហាឬបង្ហាញបញ្ហា និងចំណោទបញ្ហា)
  - ✓ លំនាំបញ្ហា: តើនៅក្នុងលំនាំបញ្ហាគេនិយាយផ្ដោតទៅលើអ្វីខ្លះ? (គំនិតទូទៅ ... យោបល់ដែលជាលំនាំដើម...)
  - ✓ ចំណូលបញ្ហាឬបង្ហាញបញ្ហា: តើនៅក្នុងចំណូលបញ្ហាឬបង្ហាញបញ្ហាគេនិយាយផ្ដោតទៅលើអ្វីខ្លះ? (បញ្ចូលបញ្ហារបស់ប្រធាន...)
  - ✓ ចំណោទបញ្ហា: តើនៅក្នុងចំណោទបញ្ហាគេនិយាយផ្ដោតទៅលើអ្វីខ្លះ? (ចោទសួរទៅលើប្រធាន...)។

- ការសិក្សាតួសេចក្តី: តើតួសេចក្តីនៃតែងសេចក្តីនេះមានចំណុចសំខាន់ៗចំនួនប៉ុន្មាន? ចំណុចអ្វីខ្លះ? (មានចំណុចសំខាន់ចំនួនប្រាំគឺ ឃ្លាភ្ជាប់សេចក្តី ពន្យល់ពាក្យគន្លឹះ ពន្យល់ន័យប្រធាន បកស្រាយប្រធាន និងសរុបសេចក្តី)
  - ✓ ឃ្លាភ្ជាប់សេចក្តី: តើនៅក្នុងឃ្លាភ្ជាប់សេចក្តីគេនិយាយផ្តោតទៅលើអ្វីខ្លះ? (ឃ្លាសម្រាប់ជាកិច្ចចាប់ផ្តើម ដើម្បីភ្ជាប់ពីសេចក្តីផ្តើមទៅនឹងការពន្យល់ពាក្យគន្លឹះ...)
  - ✓ ពន្យល់ពាក្យគន្លឹះ: តើនៅក្នុងការពន្យល់ពាក្យគន្លឹះគេនិយាយផ្តោតទៅលើអ្វីខ្លះ? (ពន្យល់ន័យរបស់ពាក្យគន្លឹះនៃប្រធាន...)
  - ✓ ពន្យល់ន័យប្រធាន: តើនៅក្នុងការពន្យល់ន័យប្រធានគេនិយាយផ្តោតទៅលើអ្វីខ្លះ? (ការបញ្ចូលគ្នាឡើងវិញនូវន័យរបស់ពាក្យគន្លឹះតាមន័យប្រធាន...)
  - ✓ បកស្រាយប្រធាន: តើការបកស្រាយប្រធានមានចំណុចសំខាន់ៗចំនួនប៉ុន្មាន? ចំណុចអ្វីខ្លះ? (មានចំណុចសំខាន់ៗចំនួនពីរគឺ លក្ខណៈដូចគ្នា និងលក្ខណៈខុសគ្នា)
- លក្ខណៈដូចគ្នា: តើនៅក្នុងលក្ខណៈដូចគ្នាគេនិយាយផ្តោតទៅលើអ្វីខ្លះ? (បកស្រាយបង្ហាញលក្ខណៈដូចគ្នា ឬប្រហាក់ប្រហែលគ្នាត្រង់ចំណុចណាខ្លះទៅតាមចំណោទរបស់ប្រធាន ដោយភ្ជាប់នឹងអំណះអំណាងឬឧទាហរណ៍បញ្ជាក់ច្បាស់លាស់...)
- លក្ខណៈខុសគ្នា: តើនៅក្នុងលក្ខណៈខុសគ្នាគេនិយាយផ្តោតទៅលើអ្វីខ្លះ? (បកស្រាយបង្ហាញពីចំណុចខុសគ្នា ឬប្រឈមគ្នានៃចំណោទរបស់ប្រធានដែលបានចោទ ដោយភ្ជាប់នឹងអំណះ អំណាងឬឧទាហរណ៍បញ្ជាក់ឱ្យបានច្បាស់លាស់...)
  - ✓ សរុបសេចក្តី: តើនៅក្នុងសរុបសេចក្តីគេនិយាយផ្តោតទៅលើអ្វីខ្លះ? (សរុបឡើងវិញនូវលក្ខណៈដូចគ្នា និងខុសគ្នាពីក្នុងការបកស្រាយខាងលើ និងទាញរកចំណុចពិសេសដោយឡែក ឬទំហៀបផ្តាច់របស់ផ្នែកណាមួយ...)។
- ការសិក្សាសេចក្តីបញ្ចប់: តើសេចក្តីបញ្ចប់នៃតែងសេចក្តីនេះមានចំណុចសំខាន់ៗចំនួនប៉ុន្មាន? ចំណុចអ្វីខ្លះ?(មានចំណុចសំខាន់ចំនួនពីរគឺ វាយតម្លៃប្រធាន និងយោបល់ផ្ទាល់ខ្លួន)
  - ✓ វាយតម្លៃប្រធាន: តើនៅក្នុងវាយតម្លៃប្រធានគេនិយាយផ្តោតទៅលើអ្វីខ្លះ? (ការឱ្យតម្លៃប្រធានថាមានន័យ មានប្រយោជន៍ទៅតាមគោលបំណងរបស់ប្រធាន...)
  - ✓ យោបល់ផ្ទាល់ខ្លួន: តើនៅក្នុងយោបល់ផ្ទាល់ខ្លួនគេនិយាយផ្តោតទៅលើអ្វីខ្លះ? (ចំណាប់អារម្មណ៍របស់អ្នកសរសេរតែងសេចក្តី ចំពោះប្រធានដែលចោទឡើងខាងលើ និងយោបល់ផ្ទាល់ខ្លួនតាមរយៈបទពិសោធ ឬគោលគំនិតរបស់ប្រធាន...)។

### ច- ការពង្រឹងចំណេះដឹង

ការពង្រឹងចំណេះដឹងនេះក៏ដូចគ្នាទៅនឹងការពង្រឹងចំណេះដឹងមុនដែរ គឺមានគោលបំណងចង់វាយតម្លៃការយល់ដឹងរបស់សិស្ស។ ការវាយតម្លៃនេះគប្បីផ្តោតលើសិស្សរៀនយឺត មានន័យថាបើសិស្សរៀនយឺតអាចធ្វើបានត្រឹមត្រូវ នោះមានន័យថាសិស្សដទៃទៀតក៏អាចធ្វើបានដែរ។

### ឆ- ការដាក់កិច្ចការស្រាវជ្រាវ

ការកិច្ចការស្រាវជ្រាវនេះក៏ដូចគ្នាទៅនឹងការកិច្ចការស្រាវជ្រាវមុនដែរ គឺមានគោលបំណងឱ្យសិស្សយល់ដឹងពីវិធីស្រាវជ្រាវ និងសិស្សចេះចងក្រងខ្លឹមសារនៃការសិក្សាស្រាវជ្រាវ។ គ្រូគប្បីដាក់ប្រធានបទ ឬ

សំណួរ ឬលំហាត់ឱ្យសិស្សសិក្សាស្រាវ។ ក្នុងសកម្មភាពសិក្សាស្រាវជ្រាវនេះ គប្បីរៀបចំសកម្មភាពមួយចំនួនដូចខាងក្រោម៖

- ការរៀបចំប្រធានបទ ឬសំណួរ ឬលំហាត់
- រូបភាពនៃការសិក្សាស្រាវជ្រាវ(ជាបុគ្គល ដៃគូ ក្រុម)
- ការរៀបចំដំណើរការសិក្សាស្រាវជ្រាវ
- ការកំណត់ទីកន្លែង
- ការកំណត់ពេលវេលា
- ការរៀបចំចងក្រងខ្លឹមសារនៃការសិក្សាស្រាវជ្រាវអំពីប្រធានបទ ឬសំណួរ ឬលំហាត់
- ការរៀបចំរបាយការណ៍
- ការបង្ហាញលទ្ធផលស្រាវជ្រាវ។

**ជ- ការសង្ខេបសកម្មភាព និងខ្លឹមសារសំខាន់ៗ**

ចំណុចនេះក៏ដូចគ្នាទៅនឹងការសង្ខេបមុនដែរ គឺមានគោលបំណងឱ្យសិស្ស ចេះនិយាយសង្ខេបឡើងវិញនូវសកម្មភាពរៀននិងបង្រៀនមេរៀននេះ និងចេះសង្ខេបខ្លឹមសារសំខាន់ៗដែលបានរៀននៅក្នុងមេរៀននេះ។ ការសង្ខេបនេះ ច្រើនធ្វើជាលក្ខណៈបុគ្គលដោយមានការផ្លាស់ប្តូរវេនគ្នា ជាពិសេសត្រូវផ្តោតលើសិស្សរៀនយឺតឱ្យបានអនុវត្តច្រើនជាងគេ។

**ឈ- ការបូកសរុប**

គ្រូធ្វើការបូកសរុបខ្លឹមសារសំខាន់ៗ ដែលតម្រូវឱ្យសិស្សយកចិត្តទុកដាក់ និងអាចណែនាំបន្ថែម ឬពន្យល់បន្ថែម ទៅលើចំណុចមួយចំនួនដែលសិស្សខ្វះខាត ឬចំណុចសិស្សមិនទាន់យល់ច្បាស់។

**ញ- ការកត់ត្រាមេរៀន**

ការកត់ត្រាមេរៀននេះ មានគោលបំណងឱ្យសិស្សចេះកត់ត្រានូវអ្វីៗដែលគេកំពុងរៀន។ ការកត់ត្រានេះ មិនមែនរង់ចាំរហូតដល់ចប់ទើបកត់នោះទេ ពោលគឺសិស្សត្រូវចេះកត់បណ្តើរៗនូវខ្លឹមសារផ្សេងៗតាមរយៈការស្តាប់ ការឆ្លើយសំណួរ ការធ្វើសកម្មភាព ការអាន និងការពន្យល់របស់គ្រូជាដើម។ គ្រូគួរណែនាំសិស្សឱ្យកត់ត្រា និងយល់ដឹងពីវិធីកត់ត្រាផងដែរ។

### ១៧.២.៣- ការអនុវត្ត

## លំនាំបង្រៀនការអនុវត្តសរសេរតែងសេចក្តី

ការអនុវត្តសរសេរតែងសេចក្តី ក៏មិនខុសពីការអនុវត្តធ្វើកិច្ចការ ឬលំហាត់ដទៃទៀតដែរ។ សកម្មភាពអនុវត្តនេះ ពុំមែនមានន័យថាឱ្យសិស្សធ្វើកិច្ចការដោយខ្លួនឯងទាំងស្រុងគ្រប់ពេលវេលានោះទេ ពោលគឺសកម្មភាពអនុវត្តនេះគប្បីធ្វើឡើងក្រោមការដឹកនាំរបស់គ្រូ។ គ្រូបង្រៀនអាចរៀបចំសកម្មភាពរៀននិងបង្រៀនតាមលំនាំមួយចំនួនដូចខាងក្រោម៖

**ក- គោលបំណង**

ការអនុវត្តសរសេរតែងសេចក្តី គឺជាដំណាក់កាលមួយដែលសិស្សបានយល់ដឹងច្បាស់លាស់រួចហើយពីវិធីសរសេរតែងសេចក្តី។ ដូច្នេះដើម្បីឱ្យសិស្ស និស្សិតងាយចាប់បានខ្លឹមសារមេរៀន គ្រូបង្រៀន សាស្ត្រាចារ្យ គប្បីបង្ហាញគោលបំណងក្នុងការអនុវត្តសរសេរតែងសេចក្តីនេះឱ្យគេបានដឹងជាមុនសិន។

*ឧទាហរណ៍:* ការអនុវត្តសរសេរតែងសេចក្តីប្រធានបែបអត្ថាធិប្បាយពន្យល់ មានគោលបំណងឱ្យសិស្សចេះកំណត់ប្រភេទតែងសេចក្តី និងសរសេរតែងសេចក្តីបានត្រឹមត្រូវនូវ៖

- ប្រភេទនៃប្រធានតែងសេចក្តី: ក្នុងប្រភេទនៃប្រធានតែងសេចក្តីមានចំណុចសំខាន់ៗគឺ លក្ខណៈសម្គាល់របស់ប្រភេទប្រធាន បម្រាប់ប្រធាន និងឃ្លាសំណួរ
- ទម្រង់នៃប្រភេទតែងសេចក្តីនីមួយៗ ដែលក្នុងនោះមានផ្នែកសំខាន់ៗដូចជា៖
  - ✓ សេចក្តីផ្តើម: ក្នុងសេចក្តីផ្តើមមានចំណុចសំខាន់ៗគឺលំនាំបញ្ហា ចំណូលបញ្ហា និងចំណោទបញ្ហា
  - ✓ តួសេចក្តី: ក្នុងតួសេចក្តីមានចំណុចសំខាន់ៗគឺ ឃ្លាភ្ជាប់សេចក្តី ពន្យល់ពាក្យគន្លឹះ ពន្យល់ន័យប្រធាន បកស្រាយប្រធាន និងសរុបសេចក្តី
  - ✓ សេចក្តីបញ្ចប់: ក្នុងសេចក្តីបញ្ចប់មានចំណុចសំខាន់ៗគឺ វាយតម្លៃប្រធាន និងយោបល់ផ្ទាល់ខ្លួន។
- ការប្រមូលគំនិត សរសេរព្រាង កែលម្អ និងសរសេរសម្រេច។

**ខ- ទំនាក់ទំនងមេរៀន**

គ្រូសួរសំណួរដើម្បីផ្សារភ្ជាប់សមត្ថភាពចាំបាច់ ឬបទពិសោធរបស់សិស្សទៅនឹងខ្លឹមសារមេរៀនថ្មី។

**គ- គ្រូដឹកនាំសិស្សការសិក្សាប្រធាន**

ការរៀបចំសកម្មភាពរៀននិងបង្រៀនគប្បីផ្តោតលើចំណុចមួយចំនួនដូចខាងក្រោម៖

- ប្រភេទប្រធានតែងសេចក្តី: តើប្រធាននេះជាប្រភេទប្រធានអ្វី?
- សិក្សាលក្ខណៈសម្គាល់របស់ប្រភេទប្រធាន: តើមានលក្ខណៈសម្គាល់ដូចម្តេច ដែលអាចបញ្ជាក់ថាជាប្រភេទប្រធាននោះ?
- សិក្សាបម្រាប់ប្រធាន: តើប្រធានប្រភេទនោះមានបម្រាប់ប្រធានដូចម្តេចខ្លះ?
- សិក្សាឃ្លាសំណួរ: តើប្រធានប្រភេទនោះមានឃ្លាសំណួរដូចម្តេចខ្លះ?

**ឃ- ការប្រមូលគំនិត**

- ការប្រមូលគំនិត មានគោលបំណងឱ្យសិស្សរៀបចំឱ្យបានជាគម្រោងតែងសេចក្តីស្របតាមប្រភេទនៃប្រធានតែងសេចក្តីដែលបានដាក់ឱ្យ។ ក្នុងការប្រមូលគំនិតនេះ សិស្ស និស្សិតត្រូវបង្កើតឱ្យបានជាគម្រោងប្លង់តែង។ គម្រោងតែង ទាមទារឱ្យអ្នកសរសេររកគំនិតទាំងឡាយណាដែលទាក់ទងជាមួយអត្ថន័យរបស់ប្រធានមកសរសេរ ហើយការសរសេរនេះមិនទាមទារឱ្យសរសេរជាល្បះពេញលេញនោះទេ ពោលគឺសរសេរតែគោលគំនិតសំខាន់និងមានបញ្ជាក់ឧទាហរណ៍ ឬអំណះអំណាងជាគោលៗបានហើយ។
- ការរៀបចំសកម្មភាពរៀននិងបង្រៀន គ្រូបង្រៀន សាស្ត្រាចារ្យអាចសួរសំណួរបំផុសឱ្យសិស្សឆ្លើយជារួម សិស្សអាចធ្វើសកម្មភាពជាបុគ្គល ដៃគូ ក្រុម ឬអាចរៀបចំជាសកម្មភាពផ្សេងៗទៀតសម្រាប់ដំណើរការរៀននិងបង្រៀន អាស្រ័យទៅតាមពេលវេលា និងស្ថានភាពជាក់ស្តែង។
- **ឧទាហរណ៍មួយចំនួនដែលជាលទ្ធផលបានមកពីសកម្មភាពប្រមូលគំនិត**

**ឧទាហរណ៍ទី១ : តែងសេចក្តីបែបពិពណ៌នាពីបាតុភូតធម្មជាតិ**

ប្រធាន: រៀងរាល់ឆ្នាំក្នុងប្រទេសកម្ពុជាយើង តែងជួបប្រទះនូវគ្រោះធម្មជាតិខ្យល់កន្ត្រាក់។ ចូរប្អូនសរសេរតែងសេចក្តីពិពណ៌នាពីបាតុភូតនេះឱ្យបានក្បោះក្បាយ។

## គម្រោងតែង

- **សេចក្តីផ្តើម**

- ពេលវេលា និងទីកន្លែងកើតមានខ្យល់កន្ត្រាក់...
- ឈ្មោះខ្យល់កន្ត្រាក់...។

- **តួសេចក្តី**

- មុនពេលកើតមានខ្យល់កន្ត្រាក់៖
  - ✓ ទិដ្ឋភាពទូទៅនៃអាកាសធាតុ...
  - ✓ ទិដ្ឋភាពខ្យល់កន្ត្រាក់មុនពេលកើតឡើង...។
- ពេលកើតមានបាតុភូតធម្មជាតិ៖
  - ✓ ទិដ្ឋភាពពេលខ្យល់កន្ត្រាក់ចាប់ផ្តើមកើតឡើង...
  - ✓ ទិដ្ឋភាពពេលខ្យល់កន្ត្រាក់កំពុងកើតឡើង ...
  - ✓ ទិដ្ឋភាពចុងបញ្ចប់នៃការកើតមានខ្យល់កន្ត្រាក់ ...។
- ក្រោយពេលកើតមានខ្យល់កន្ត្រាក់៖
  - ✓ ទិដ្ឋភាពក្រោយពេលកើតមានខ្យល់កន្ត្រាក់ ...
  - ✓ សកម្មភាពអ្នកស្រុកក្រោយពេលកើតមានខ្យល់កន្ត្រាក់ ...
  - ✓ សកម្មភាពអាជ្ញាធរមូលដ្ឋាន ឬអង្គការមនុស្សធម៌ផ្សេងៗ...។

- **សេចក្តីបញ្ចប់**

- ការបូកសរុបនិងវាយតម្លៃលើការខូចខាត...
- ចំណាប់អារម្មណ៍ចំពោះខ្យល់កន្ត្រាក់នោះ...។

**ឧទាហរណ៍ទី២** : **តែងសេចក្តីបែបអត្ថាធិប្បាយពន្យល់ពាក្យស្លោក**

---

ប្រធាន: ពាក្យស្លោកមួយបានលើកឡើងថា៖ «សេចក្តីព្យាយាមគង់បានសម្រេច»។ ចូរប្អូនពន្យល់ពាក្យស្លោកនេះឱ្យបានក្បោះក្បាយ និងលើកឧទាហរណ៍មកបញ្ជាក់ផង។

---

## គម្រោងតែង

- **សេចក្តីផ្តើម**

- លំនាំបញ្ហា: បុព្វបុរសយើងតែងចង់ទូន្មានកូនចៅ.... រស់នៅបានសុខ...
- ចំណូលបញ្ហាឬបង្ហាញបញ្ហា: ...សេចក្តីព្យាយាមគង់បានសម្រេច...
- ចំណោទបញ្ហា: តើពាក្យស្លោកនេះ មានអត្ថន័យដូចម្តេច ...។

- **តួសេចក្តី**

- ឃ្លាភ្ជាប់សេចក្តី: ដើម្បីជាជំនួយ... គប្បីយល់នូវន័យ នៃពាក្យគន្លឹះរបស់ប្រធាន ...។
- ពន្យល់ពាក្យគន្លឹះ៖
  - ✓ ព្យាយាម : ...ព្យាយាម គឺខិតខំប្រឹងប្រែង សង្វាត...
  - ✓ សម្រេច : ... គឺធ្វើឱ្យរួចស្រេច ធ្វើឱ្យហើយស្រេច ធ្វើឱ្យបានដាច់ស្រេច...។

- ពន្យល់ន័យប្រធានៈប្រធានខាងលើមានន័យថា ការខិតខំប្រឹងប្រែងធ្វើកិច្ចការអ្វីមួយនឹងធ្វើឱ្យកិច្ចការនោះបានសម្រេច ...។
- បកស្រាយប្រធានៈ
  - ✓ ព្យាយាមដោយកម្លាំងកាយ ... គឺមានន័យថាការខិតខំប្រឹងប្រែងដោយប្រើប្រាស់កម្លាំងកាយក្នុងការធ្វើកិច្ចការផ្សេងៗឱ្យបានសម្រេច...
  - ✓ ឧទាហរណ៍...ដូចជាក្នុងរឿងចចកនិងកំពឹស នៅពេលក្រុមរបស់ចចក បាចទឹកជិតរីងត្រីក្រាញ់ខំននៀលទៅរកព្រះឥន្ទ្រជួយ ....
  - ✓ ព្យាយាមដោយកម្លាំងចិត្ត ... គឺមានន័យថាការមានទឹកចិត្តមោះមុត មានការប្តេជ្ញាចិត្តខ្ពស់ក្នុងការក្នុងការធ្វើកិច្ចការផ្សេងៗឱ្យបានសម្រេច ...
- ឧទាហរណ៍ ...ដូចជាក្នុងរឿងកុលាបប៉ៃលិន តួអង្គចៅចិត្រមានទឹកចិត្តក្លាហានប្រយុទ្ធតទល់នឹងចោរប្លន់ ....
- ព្យាយាមដោយកម្លាំងប្រាជ្ញា...គឺមានន័យថាការខិតខំត្រិះរិះ គិតពិចារណារិះរកវិធីផ្សេងៗក្នុងការធ្វើកិច្ចការផ្សេងៗឱ្យបានសម្រេចដោយបញ្ញា ...
- ឧទាហរណ៍ ... តួយ៉ាងដូចជាសិស្សានុសិស្សគ្រប់រូបត្រូវខិតខំព្យាយាមរៀនសូត្រតាំងពីតូចក្រូចឆ្មារហូតដល់ធំទើបទទួលបានចំណេះវិជ្ជា...។
- សរុបសេចក្តី: ការសិក្សារៀនសូត្រ ការធ្វើកិច្ចការអ្វីមួយ ការដោះស្រាយបញ្ហាគ្រប់បែបយ៉ាងទាំងអស់កាលណាយើងខិតខំប្រឹងប្រែងទាំងផ្លូវកាយ ទាំងផ្លូវចិត និងទាំងផ្លូវប្រាជ្ញា នោះទើបបានសម្រេច...។

▪ **សេចក្តីបញ្ចប់**

- វាយតម្លៃប្រធានៈ ....ពាក្យស្លោកដែលបានពោលខាងលើពិតជាមានអត្ថន័យអប់រំជ្រាលជ្រៅសម្រាប់អប់រំទូន្មានកូនចៅខ្មែរយើងគ្រប់រូប ...
- យោបល់ផ្ទាល់ខ្លួនៈ ...ក្នុងនាមជាសិស្ស ត្រូវខិតខំព្យាយាមរៀនសូត្រ ដើម្បីសម្រេចបានគោលដៅជីវិត...។

**ឧទាហរណ៍ទី៣ : តែងសេចក្តីបែបអត្ថាធិប្បាយពន្យល់សុភាសិត**

---

ប្រធានៈ សុភាសិតមួយចែងថា «ដើយស្កក ឱនដាក់គ្រាប់»។ ចូរពន្យល់សុភាសិតខាងលើឱ្យបានក្បោះក្បាយ ដោយលើកឧទាហរណ៍ជាក់ស្តែង និងក្នុងអក្សរសិល្ប៍មកបញ្ជាក់ផង។

---

## គម្រោងតែង

▪ **សេចក្តីផ្តើម**

- លំនាំបញ្ហាៈ ខ្មែរយើងបានបន្សល់ទុកនូវសុភាសិត ដើម្បីអប់រំកូនចៅ...
- ចំណូលបញ្ហាឬបង្ហាញបញ្ហាៈ ...ដើយស្កក ឱនដាក់គ្រាប់ ....
- ចំណោទបញ្ហាៈ តើសុភាសិតនេះមានអត្ថន័យដូចម្តេច ...។

▪ **តួសេចក្តី**

- ឃ្លាភ្ជាប់សេចក្តី : ...ដើម្បីជាជំនួយដល់ការបកស្រាយ... គប្បីយល់ន័យពាក្យគន្លឹះរបស់ប្រធានជាមុនសិន...។

- ពន្យល់ពាក្យគន្លឹះ៖
  - ✓ ងើយ : ឈរប្រាស់ឡើងទៅលើ ...
  - ✓ ស្កក : កួរស្រូវដែលមិនមានគ្រាប់ ...ឬសាច់អង្គរ ...
  - ✓ ឱន : ...ទន់ចុះក្រោម បន្ទន់ទៅមុខ សំយុងចុះ ....
  - ✓ ដាក់គ្រាប់ : ...ស្រូវមានគ្រាប់ពេញ ឬមានគ្រាប់អង្ករ....។
- ពន្យល់ន័យប្រធាន: ប្រធានមានន័យថា កួរស្រូវដែលឈរត្រង់ទៅលើ ... ប្រៀបដូចមនុស្សមានចរិតអួតក្អេងក្អាង... តែងមិនទទួលបាននូវផលល្អ ... ផ្ទុយទៅវិញកួរស្រូវដែលទន់ចុះ ... ប្រៀបដូចមនុស្សដែលចេះដាក់ខ្លួនឱ្យទាប... តែងទទួលបាននូវបានផលល្អ ...។
- បកស្រាយប្រធាន៖

  *បកស្រាយអត្ថន័យ "ងើយស្កក"៖*
  - ✓ អត្ថានុរូបឬន័យត្រង់: "ងើយស្កក" គឺសំដៅលើស្រូវដែលកួររបស់វាមានផ្លែតែគ្មានដាក់គ្រាប់ ...
  - ✓ អត្ថបដិរូបឬន័យធៀប: គេចង់ប្រៀបធៀបទៅនឹងមនុស្ស ដែលមានឥរិយាបថ ឆ្គាំឆ្គង ...
  - ✓ ឧទាហរណ៍ក្នុងសង្គមជាក់ស្តែង មនុស្សមានឫកពាក្អេងក្អាង ... មិនទទួលបានផលល្អ...
  - ✓ ឧទាហរណ៍ក្នុងអក្សរសិល្ប៍រឿងកុលាបប៉ៃលិន ...លោកបាឡាត់មានឫកពាក្អេងក្អាង ... ទទួលបរាជ័យ... ។

  *បកស្រាយអត្ថន័យ"ឱនដាក់គ្រាប់"៖*
  - ✓ អត្ថានុរូបឬន័យត្រង់: "ឱនដាក់គ្រាប់" គឺសំដៅទៅលើរុក្ខជាតិដែលមានទងកួរដាក់គ្រាប់ពេញធ្វើឱ្យកួរវាធ្ងន់ក៏ឱនចុះ...
  - ✓ ឧទាហរណ៍តួយ៉ាងដូចជាដំណាំស្រូវទុំដាក់គ្រាប់ពេញ ធ្វើឱ្យកួរវាធ្ងន់ក៏ឱនចុះ...
  - ✓ អត្ថបដិរូបឬន័យធៀប : លោកចង់ធ្វើការប្រៀបធៀបកួរស្រូវទៅនឹងការប្រព្រឹត្តរបស់មនុស្ស... ការរស់នៅ ការធ្វើការងារ ចេះដាក់ខ្លួនឱ្យទាប ទទួលបានជោគជ័យ...
  - ✓ ឧទាហរណ៍ក្នុងសង្គមជាក់ស្តែង មនុស្សចេះឱនលំទោន ... ទទួលបានផលល្អ...
  - ✓ ឧទាហរណ៍ក្នុងអក្សរសិល្ប៍រឿងកុលាបប៉ៃលិន ចៅចិត្រចេះឱនលំទោន...ទទួលបានជោគជ័យ... ។
- សរុប: កួរដែលងើយឈរត្រង់គឺជាកួរដែលស្កកមិនបានផល ប្រៀបដូចមនុស្សដែលមានចរិតក្អេងក្អាងតែងទទួលរងការរិះគន់... និងមិនទទួលបាននូវលទ្ធផលល្អ ...ផ្ទុយពីកួរទន់ចុះគឺ ...ដាក់គ្រាប់ទទួលបានផលល្អ ប្រៀបដូចមនុស្សដែលអាកប្បកិរិយាទន់ភ្លន់តែងទទួលបាននូវសេចក្តីថ្លៃថ្នូរ...។

▪ **សេចក្តីបញ្ចប់**

- វាយតម្លៃប្រធាន: សុភាសិតនេះពិតជាមានអត្ថន័យអប់រំយ៉ាងជ្រាលជ្រៅ សម្រាប់អប់រំកូនចៅ...
- យោបល់ផ្ទាល់ខ្លួន: ក្នុងនាមអ្នកសិក្សាត្រូវ... ខិតខំសិក្សាស្វែងយល់ ...។

**ង- ការសរសេរព្រាង**

- គ្រូដឹកនាំសិស្សធ្វើសំណេរព្រាងដោយ៖
  - ✓ សរសេរពង្រីកគំនិតនីមួយៗ ជាលក្ខណៈពង្រីកគំនិតដើម្បីផ្តល់សេចក្តីពន្យល់ជាលក្ខណៈបកស្រាយគំនិតឱ្យគេយល់ ជាលក្ខណៈបកស្រាយបញ្ហា ជាលក្ខណៈរៀបរាប់ពិពណ៌នា។ល។

✓ នៅក្នុងការបកស្រាយ ឬការពន្យល់ចំណុចនីមួយៗ ត្រូវលើកឧទាហរណ៍ ផ្តល់ភស្តុតាង និងផ្តល់អំណះអំណាងជាដើម ដែលទាញយកមកពីសង្គមជាក់ស្តែង និងក្នុងអក្សរសិល្ប៍ ដើម្បីឱ្យការបកស្រាយ ឬការពន្យល់ចំណុចនីមួយៗនោះ មានភាពច្បាស់លាស់ ឡូសីក មានហេតុផលត្រឹមត្រូវ។

- ការរៀបចំសកម្មភាពរៀននិងបង្រៀន គ្រូបង្រៀន សាស្ត្រាចារ្យអាចសួរសំណួរបំផុសឱ្យសិស្សឆ្លើយជារួម សិស្សអាចធ្វើសកម្មភាពជាបុគ្គល ដៃគូ ក្រុម ឬអាចរៀបចំជាសកម្មភាពផ្សេងៗទៀតសម្រាប់ដំណើរការរៀននិងបង្រៀន អាស្រ័យទៅតាមពេលវេលា និងស្ថានភាពជាក់ស្តែង។

**ច- ការកែលម្អ**

- គ្រូដឹកនាំសិស្សធ្វើការកែលម្អដោយ៖
  - ✓ ពិនិត្យកែលម្អលើទម្រង់តែងសេចក្តី មានគ្រប់ចំណុចនៃគម្រោងទៅតាមប្រភេទប្រធានហើយ ឬនៅ។
  - ✓ ពិនិត្យមើលគំនិតដែលបានលើកយកមកនោះគ្រប់គ្រាន់ អាចគាំទ្រដល់ការបកស្រាយបានហើយ ឬនៅ។
  - ✓ ពិនិត្យលើខ្លឹមសារនៃការបកស្រាយ ឬការពន្យល់បានត្រឹមត្រូវសមហេតុផលហើយ ឬនៅ។
  - ✓ ពិនិត្យលើការលើកឧទាហរណ៍ ការផ្តល់ភស្តុតាង និងការផ្តល់អំណះអំណាងត្រឹមត្រូវសមហេតុផលហើយ ឬនៅ។
  - ✓ ពិនិត្យកែលម្អលើទម្រង់ឃ្លា ល្បះ វេយ្យាករណ៍។
  - ✓ ពិនិត្យកែលម្អលើអក្ខរាវិរុទ្ធ។
- ការរៀបចំសកម្មភាពរៀននិងបង្រៀន គ្រូបង្រៀន សាស្ត្រាចារ្យអាចសួរសំណួរបំផុសឱ្យសិស្សឆ្លើយជារួម សិស្សអាចធ្វើសកម្មភាពជាបុគ្គល ដៃគូ ក្រុម ឬអាចរៀបចំជាសកម្មភាពផ្សេងៗទៀតសម្រាប់ដំណើរការរៀននិងបង្រៀន អាស្រ័យទៅតាមពេលវេលា និងស្ថានភាពជាក់ស្តែង។

**ឆ- ការសរសេរសម្រេច**

ការសរសេរសម្រេច គឺជាដំណាក់កាលចុងក្រោយនៃការសរសេរតែងសេចក្តី។ ដូច្នេះសិស្សសរសេរកិច្ចការរបស់ខ្លួនឡើងវិញឱ្យបានស្អាត បន្ទាប់ពីមានយោបល់កែលម្អ។

**ជ- ការពង្រឹងចំណេះដឹង**

ការពង្រឹងចំណេះដឹងនេះក៏ដូចគ្នាទៅនឹងការពង្រឹងចំណេះដឹងមុនដែរ គឺមានគោលបំណងចង់វាយតម្លៃការយល់ដឹងរបស់សិស្ស។ ការវាយតម្លៃនេះគប្បីផ្តោតលើសិស្សរៀនយឺត មានន័យថាបើសិស្សរៀនយឺតអាចធ្វើបានត្រឹមត្រូវ នោះមានន័យថាសិស្សដទៃទៀតក៏អាចធ្វើបានដែរ។

**ឈ- ការដាក់កិច្ចការស្រាវជ្រាវ**

ការកិច្ចការស្រាវជ្រាវនេះក៏ដូចគ្នាទៅនឹងការកិច្ចការស្រាវជ្រាវមុនដែរ គឺមានគោលបំណងឱ្យសិស្សយល់ដឹងពីវិធីស្រាវជ្រាវ និងសិស្សចេះចងក្រងខ្លឹមសារនៃការសិក្សាស្រាវជ្រាវ។ គ្រូគប្បីដាក់ប្រធានបទ ឬសំណួរ ឬលំហាត់ឱ្យសិស្សសិក្សាស្រាវ។ ក្នុងសកម្មភាពសិក្សាស្រាវជ្រាវនេះ គប្បីរៀបចំសកម្មភាពមួយចំនួនដូចមេរៀនមុនៗ។

**ញ- ការសង្ខេបសកម្មភាព និងខ្លឹមសារសំខាន់ៗ**

ចំណុចនេះក៏ដូចគ្នាទៅនឹងការសង្ខេបមុនដែរ គឺមានគោលបំណងឱ្យសិស្ស ចេះនិយាយសង្ខេបឡើងវិញនូវសកម្មភាពរៀននិងបង្រៀនមេរៀននេះ និងចេះសង្ខេបខ្លឹមសារសំខាន់ៗដែលបានរៀននៅក្នុងមេរៀននេះ។ ការសង្ខេបនេះ ច្រើនធ្វើជាលក្ខណៈបុគ្គលដោយមានការផ្លាស់ប្តូរវេនគ្នា ជាពិសេសត្រូវផ្តោតលើសិស្សរៀនយឺតឱ្យបានអនុវត្តច្រើនជាងគេ។

**ដ- ការប្រមូលសរុប**

គ្រូធ្វើការប្រមូលសរុបខ្លឹមសារសំខាន់ៗ ដែលតម្រូវឱ្យសិស្សយកចិត្តទុកដាក់ និងអាចណែនាំបន្ថែមឬពន្យល់បន្ថែម ទៅលើចំណុចមួយចំនួនដែលសិស្សខ្វះខាត ឬចំណុចសិស្សមិនទាន់យល់ច្បាស់។

# ឯកសារពិគ្រោះ


១- សៀវភៅភាសិត សុភាសិត អធិប្បាយ សម្រាយបំភ្លឺរបស់អ្នកនិពន្ធ សែម សូរ និងអ៊ិន សារុន បោះពុម្ព ឆ្នាំ១៩៧២។

២- សៀវភៅភាសាខ្មែរ ថ្នាក់ទី៧ ទី៨ និងទី៩ ក្រសួងអប់រំ យុវជន និងកីឡា។

៣- វិធីសាស្ត្រសម្រាប់ធ្វើតែងសេចក្តី របស់លោក លឹម សាខុន គ្រូបង្រៀននៅវិទ្យាល័យភ្នំធំ។

៤- សៀវភៅរឿង កុលាបប៉ៃលិន របស់អ្នកនិពន្ធ ញ៉ុក ថែម។

៥- សៀវភៅរឿង សុផាត របស់អ្នកនិពន្ធ រីម គីន។

៦- សៀវភៅរឿង មាលាដួងចិត្រ របស់អ្នកនិពន្ធ នូ ហាច។

៧- សៀវភៅរឿង ធនញ្ជ័យ។

៨- សៀវភៅរឿង ផ្កាស្រពោន របស់អ្នកនិពន្ធ នូ ហាច។

៩- សៀវភៅសរសេរតាមអាន និងតែងសេចក្តី អ្នកនិពន្ធ លោក យិន ធី បោះដោយគ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ ឆ្នាំ២០១៣។

១០- សៀវភៅសរសេរតាមអាន និងតែងសេចក្តី អ្នកនិពន្ធ លោក យ៉ង់ កំស៊ាន បោះដោយគ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ ឆ្នាំ២០១៣។

១១- សៀវភៅវិជ្ជានិពន្ធ របស់លោក អ៊ិត សុធា សាស្ត្រាចារ្យសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

១២- ឯកសារណែនាំការអភិវឌ្ឍគម្រូវិញ្ញាសាប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិរបស់ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០១៦។

១៣- បរមាធិប្បាយពិសេស សំរាប់សិក្សាអក្សរសាស្ត្រខ្មែរទូទៅ ដោយលោក«សែម សូរ» ព.ស ២៥១៣ គ.ស១៩៧០។

១៤- ឯកសារវិធីសាស្ត្រនៃការសរសេរតែងសេចក្តី របស់បណ្ឌិត ធ សោ

១៥- ឯកសារវិធីសាស្ត្រនៃការបង្រៀនតែងសេចក្តី របស់បណ្ឌិត ធ សោ